# ប្រវត្តិព្រះសហគមន៍

# នៅ

# ប្រទេសកម្ពុជា

រៀបរៀងដោយ

លោកបូជាចារ្យប៉ុងសូឌ៍

ឆ្នាំ ១៩៩២

# មាតិការឿង


អារម្ភកថា ដោយលោកអភិបាលព្រះសហគមន៍ អ៊ីវ រ៉ាមូស ..................ទំព័រ ៥
ជំពូកទី១ : ជាតិខេមរា..................................................................... ៧
ជំពូកទី ២ : ជនជាតិអឺរ៉ុប និងប្រជាជនកម្ពុជាចាប់ផ្តើមទាក់ទងគ្នា .................២៣
ជំពូកទី៣ : គ្រីស្តបរិស័ទ មកជ្រកកោននៅប្រទេសកម្ពុជា....................៤១
ជំពូកទី៤ : សម្តេចប៉ាបតែងតាំងអភិបាលព្រះសហគមន៍
សម្រាប់ណែនាំគ្រីស្តបរិស័ទ ទ្វីបអាស៊ី.............................. ៤៩
ជំពូកទី៥ : ការប្រកាសដំណឹងល្អដល់ជនជាតិខ្មែរ.......................... ៦៩
ជំពូកទី៦ : អភិបាលព្រះសហគមន៍ម្នាក់នៅរាជវាំងឧត្តុង្គ................ ៩៣
ជំពូកទី៧ : គ្រីស្តបរិស័ទវៀតណាមនៅប្រទេសកម្ពុជា................... ១១១
ជំពូកទី៨ : ព្រះសហគមន៍សម្រាប់ជនជាតិខ្មែរ.............................១២៥
ជំពូកទី៩ : ព្រះសហគមន៍ក្នុងសម័យអាណានិគម.........................១៤៥
ជំពូកទី១០ : ព្រះសហគមន៍ប្រទេសកម្ពុជាក្នុងសង្គ្រាមឥណ្ឌូចិន...........១៥៩
ជំពូកទី១១ : គ្រីស្តបរិស័ទខ្មែរណែនាំព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា...... ១៦៩
ជំពូកទី១២ : ព្រះសហគមន៍មានលក្ខណៈជាខ្មែរ........................ ១៨៣
ជំពូកទី១៣ : ភ្លើងសង្គ្រាមរាលរាលនៅប្រទេសកម្ពុជា................. ២០១
ជំពូកទី១៤ : គ្មានស្រឡាញ់ឯណាឲ្យខ្លាំងជាង.......................... ២១៣
ជំពូកទី១៥ : ព្រះសហគមន៍សាមគ្គីជាមួយអ្នកក្រខ្សត់ជាងគេ............. ២២៣
ជំពូកទី១៦ : ការព្រាត់ប្រាស................................................. ២៣៩
ជំពូកទី១៧ : គ្រីស្តបរិស័ទរួមស្លាប់ជាមួយព្រះយេស៊ូ.................... ២៥៧
ជំពូកទី១៨ : ជនរងគ្រោះដោយបដិវត្តន៍.................................. ២៧៧
ជំពូកទី១៩ : ព្រះសហគមន៍រស់ឡើងវិញ................................... ២៩៥
ជីវិតទៅអនាគត.................................................. ៣១១
ផែនទី ប្រទេសកម្ពុជា........................................................ ទំព័រ ៨
ផែនទី ទ្វីបអាស៊ីនៅសតវត្សទី ១៧ ............................................. ៣៩
ផែនទី សម័យលេបទឹកដី និងសម័យការពារទឹកដី........................ ៦៧
ផនែទី កំណើតពុ្រះសហគមន៍នៅបុ្រទសេកមុ្ពជា........................៧០
ផែនទី ព្រះសហគមន៍នៅប្រទេសកម្ពុជា................................. ២៥៦

*សូមឧទ្ទិសសៀវភៅនេះ ជូនចំពោះលោក **ឆ្មារ សាឡាស់** ជាអភិបាលព្រះសហគមន៍ខ្មែរដើមដំបូង ចំពោះអស់លោកបូជាចារ្យខ្មែរ គឺលោក **ទពេ អ៊ីម សុត្ថា** លោក **ឆ្មារ សាឡឹម** លោក **ឈឹម ជុនសរ** និងលោក **ឡឿន ចំរើន** ព្រមទាំងចំពោះជនជាតិខ្មែរទាំងប៉ុន្មានដែលបានរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ ។*

*«ពេលណាអ្នករាល់គ្នាចង់បំបាត់យើង*
*ពេលនោះយើងមានគ្នាកាន់តែច្រើនឡើង*
*គឺឈាមរបស់គ្រីស្តបរិស័ទ ជាពូជធារជីវិតប្រាកដ» ។*

*លោកទែរទុយលីយ៉ានុស* ( Tertulianus )

# អារម្ភកថា

*«ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាគ្រាប់ពូជដំឡូងមី ដែលបុរសម្នាក់យកទៅដាំក្នុងចម្ការរបស់ខ្លួន។ គ្រាប់ពូជនោះតូចជាងគ្រាប់ពូជទាំងអស់ ប៉ុន្តែពេលដុះឡើង វាធំជាងដំណាំឯទៀតៗ គឺទៅជាដើមឈើមួយយ៉ាងធំ ហើយបក្សាបក្សីមកធ្វើសំបុកអាស្រ័យនៅតាមមែករបស់វា»។ (ម៉ាថាយ ១៣,៣១-៣២)*

*ព្រះសហគមន៍ក្នុងប្រទេសកម្ពុជា ប្រៀបដូចជាគ្រាប់ពូជដំឡូងមីនោះដែរ។ ប៉ុន្តែទោះបី ព្រះសហគមន៍ បានចាក់ឫសក្នុងប្រទេសកម្ពុជាជាងបួនរយឆ្នាំក៏ដោយ ក៏ព្រះសហគមន៍មិនទាន់លូតលាស់ទៅជាដើមឈើធំនៅឡើយទេ!។ ប្រជាជនខ្មែរប្រៀបដូចជាដីដែលមានជីរជាតិល្អដែរ ព្រោះប្រជាជានខ្មែរមានអរិយធម៌ខ្ពង់ខ្ពស់តាំងពីយូរអង្វែងមកហើយ ព្រះពុទ្ធសាសនាបានអប់រំជនជាតិខ្មែរឲ្យមានចិត្តស្លូតបូត ចេះទទួលភ្ញៀវមិនឲ្យប្រកាន់អ្នកដទៃឬសាសនាដទៃទេ។ តែជាអកុសល ចាប់តាំងពីសម័យអង្គរមកប្រជាជនខ្មែរជួបប្រទះតែសង្គ្រាម និងការឈ្លានពានពីសត្រូវគ្រប់មជ្ឈដ្ឋាន បណ្ដាលឲ្យប្រជាជនខ្មែររងទុក្ខរងទុក្ខលំបាកវេទនាឥតឈប់ឈរឡើយ។*

*ដូច្នេះនៅប្រទេសកម្ពុជា ព្រះសហគមន៍ប្រៀបដូចជា កូនឈើដែលត្រូវខ្យល់ក្ដៅក្នុងរដូវប្រាំង។ អស់បីដងមកហើយ កូនឈើនេះក្រៀមស្វិតស្រពោន ហើយអ្នកផងទាំងពួងយល់ឃើញថាកូនឈើនេះ ងាប់បាត់ទៅហើយ!។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍បានរស់ឡើងវិញ ដូចផ្កានៅរដូវវស្សាដែរ ព្រោះមានគ្រីស្តបរិស័ទនៅតែកាន់ជំនឿរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ។*

*ជាពិសេស ក្នុងសម័យដ៏សែនវេទនានៃមហាវិនាសកម្ម ដែលទើបកន្លងផុតទៅមានគ្រីស្តបរិស័ទស៊ូទ្រាំ មិនព្រមលះបង់ជំនឿរបស់ខ្លួន គ្រីស្តបរិស័ទខ្លះទៀតសុខចិត្តស្លាប់ព្រោះតែជំនឿរបស់ខ្លួនផង។*

*បងប្អូនគ្រីស្តបរិស័ទខ្មែរ ត្រូវតែអានសៀវភៅនេះជាកំហិត ព្រោះសៀវភៅនេះមិនគ្រាន់តែរៀបរាប់ អំពីប្រវត្តិព្រះសហគមន៍ប៉ុណ្ណោះទេ គឺបង្ហាញអំពីព្រះជាម្ចាស់ដែលទ្រង់*

សព្វព្រះហឫទ័យណែនាំប្រជាជានខ្មែរ តាមធម៌មេត្តាករុណារបស់ព្រះអង្គ។ គ្មាននរណាអាចយល់អត្ថន័យអំពីទុក្ខលំបាករបស់ប្រជាជាខ្មែរទេ ព្រោះហួសពីការស្មានខ្លាំងពេក។ តែអ្នកដែលមានជំនឿអាចនឹកថា ប្រជាជនខ្មែមុខជាប្រជាជនជាទីស្រឡាញ់របស់ព្រះអង្គ ព្រោះទ្រង់បានប្រោសប្រទានឲ្យគេរងទុក្ខលំបាកដូចព្រះបុត្រាព្រះអង្គដែរ។

បងប្អូនជាគ្រីស្តបរិស័ទខ្មែរ បានទទួលជំនឿទុកជាកេរអាករមួយដ៏ប្រសើរតាំងពីដូនតាមក ត្រូវតែយកចិត្តទុកដាក់ប្រគល់កេរអាករនេះ ឲ្យកូនចៅតំណក្រោយៗតទៅទៀតផង ។

អុីវ រ៉ាមូស

អភិបាលព្រះសហគមន៍កាតូលិក

ប្រចាំប្រទេសកម្ពុជា

# ជំពូកទី១

# ជាតិខ្មែរ

### អារក្សអ្នកតាជាម្ចាស់ទឹកដី

ជនជាតិខ្មែរ តែងតែហៅមាតុភូមិរបស់ខ្លួនថា"ទឹកដី"។ តើទឹកដីមានព្រំដែនត្រឹមណា? ចុះដីគោកវិញ មានព្រំដែនត្រឹមណាដែរ? ។ នៅប្រទេសកម្ពុជាយើង ទឹកនិងដីលាយគ្នាស្ទើរតែគ្រប់ទីកន្លែង។

ជារៀងរាល់ឆ្នាំ ទឹកជំនន់ទន្លេមេគង្គ ដែលមានប្រភពចេញពីភ្នំទីបេ នាំដីល្បប់មកចាក់វាលទំនាបដ៏ធំធេង ដែលស្ថិតនៅចំកណ្ដាលឥណ្ឌូចិនភាគអាគ្នេយ៍។ នៅភាគខាងកើតនៃវាលទំនាបនេះមានកូនភ្នំទាបៗនៃជួរភ្នំអណ្ណាម ធ្វើឲ្យស្យល់ព្យុះបក់បោកមកលើប្រទេសខ្មែរក្នុងរដូវវស្សាបាន។ នៅភាគខាងលិចមានជួរភ្នំក្រវាញ ដែលជារនាំងមិនឲ្យមនុស្សឆ្លងចេញចូលទៅរកសមុទ្របានដោយងាយទេ ហើយនៅទិសខាងជើងមានជួរភ្នំដងរែកជាកំពែងខ្ពស់ ដើរឆ្លងកាត់ពុំបានឡើយ។ រីឯ ភាគខាងត្បូងវិញ ជាតំបន់មួយដែលបើកចំហទៅរកសមុទ្រ។ មានតែច្រកនៅចន្លោះជួរភ្នំក្រវាញ និងជួរភ្នំដងរែកខ្លះប៉ុណ្ណោះដែលអាចឲ្យគេធ្វើដំណើរទៅកាន់ទិសពាយ័ព្យបាន។ នៅចំកណ្ដាលស្រុកខ្មែរយើងមានបឹងទន្លេសាបដែលជាសំណល់ពីឈូងសមុទ្រកាលពីដើម។ បឹងទន្លេសាបមានត្រីច្រើនក្រៃលែង និងច្រើនប្រភេទទៀតផង។ ត្រីប្រភេទខ្លះបានបាត់បង់អស់រលីងពីតំបន់នានាក្នុងពិភពលោក គឺមាននៅសល់តែក្នុងប្រទេសខ្មែរយើងប៉ុណ្ណោះ។

ប្រហែលនៅឆ្នាំ ៣៥០០ មុនគ្រីស្តសករាជ មានមនុស្សរស់នៅភាគខាងត្បូងនៃជ្រោយឥណ្ឌូចិនរួចទៅហើយ អ្នកទាំងនោះមានសម្បុរខ្មៅស្រអែម មានជាប់ពូជអំបូរនឹងអ្នកស្រុកដើម ដែលរស់នៅលើកោះទាំងឡាយនៃសមុទ្រក្ដៅ ក្នុងប្រទេសឥណ្ឌូណេស៊ីនិងម៉ាឡេស៊ី។

# មានផែនទីប្រទេសកម្ពុជា

ជនទាំងនោះ ច្រើនតាំងទីលំនៅលើតំបន់ខ្ពស់ៗ ដែលស្ថិតនៅជុំវិញវាលទំនាបកណ្ដាល ដូចជា៖ នៅម្លូរព្រៃនៅមេមត់នៅជប់ចម្ការលើ ឬក៏នៅសំរោងសែនខាងត្បូងទន្លេសាប។ អ្នកខ្លះទៀត រស់នៅក្បែរកំពត និងនៅតាមឆ្នេរឈូងសមុទ្រសៀម។ អ្នកឯកទេសខាងស្រាវជ្រាវ បានរកឃើញសម្ភារៈប្រើប្រាស់ខ្លះៗ របស់ពួកអ្នកស្រុកដើមនៅកន្លែងទាំងនោះ។ អ្នកឯកទេសបានស្មានថា មានមនុស្សរស់នៅទីនោះ តាំងតែពីសម័យថ្មរំលីង គឺប្រហែល ៣៥០០ ឆ្នាំមុនគ្រីស្តសករាជមកម្ល៉េះ[១] ។

មនុស្សទាំងនោះរស់នៅក្នុងព្រៃ ហើយសង់ខ្ទមនៅលើដើមឈើ។ ទម្លាប់សង់ខ្ទមបែបនេះ បានឆ្លងរហូតមកទល់សព្វថ្ងៃ។ ដូច្នេះហើយទើបខ្មែរដែលជាកូនចៅបុព្វបុរសទាំងនោះ និយមសង់ផ្ទះនៅលើសសរខ្ពស់ពីដី។ អ្នកទាំងនោះតែងបេះបោចផ្លែឈើស្លឹកឈើ បរបាញ់សត្វ នេសាទត្រី និងដាំស្រូវសម្រាប់ជីវិត។ គេចិញ្ចឹមគោក្របី ដើម្បីភ្ជួរស្រែ។ ពួកគេអាចទ្រាំរស់នៅក្នុងព្រៃបានបង្គួរដែរ ព្រោះក្នុងឈាមរបស់គេមានគោលិកាឈាមក្រហមពិសេសម៉្យាងហៅថា"Hémoglobine E" ដែលការពារសរីរាង្គគេឲ្យឈ្នះជំងឺគ្រុនចាញ់បានមួយភាគធំ។

តាមអ្នកស្រាវជ្រាវបុព្វបុរសទាំងនោះ គោរពបូជាវិញ្ញាណក្ខន្ធអស់អ្នកដែលបានចែកស្ថានទៅហើយ។ ពួកគេថ្វាយសក្ការបូជាចំពោះទេវតារក្សាទឹកដីព្រៃភ្នំមាន"អ្នកតា" ជាដើម។ គេគោរពអារក្ស និងទេវតាទាំងនោះ ទុកជាអ្នកបង្កបង្កើតភូមិរបស់ពួកគេ ដូចជាម្ចាស់ស្រុកពិតៗ។ ពួកគេជឿថា អារក្សហ្នឹងហើយ ដែលតែងការពារភូមិ ផ្ដល់សុខភាពឲ្យមនុស្ស ធ្វើឲ្យមេឃបង្អុរភ្លៀងទៀងទាត់ល្អ ធ្វើឲ្យរដូវប្រែប្រួលធម្មតា និងធ្វើឲ្យភោគផលបានសម្បូរហូរហៀរ។ ដូច្នេះពួកគេតែងសែនផ្លែឈើនំចំណីស្រាជូនដល់ពួកអារក្សទាំងនោះ។ ប្រសិនបើគេបំភ្លេច ឬប្រមាថមើលងាយពួកអារក្សអ្នកតាទាំងនោះ ពួកគេតែងតែមានជំងឺ ហើយជួបគ្រោះថ្នាក់ដល់ជីវិតថែមទៀតផង។ ពស់នាគ[២] ក្បាលបី ឬក្បាលប្រាំពីរ ជានិមិត្តរូបតំណាង ឥទ្ធិពលរបស់ទេវតាទាំងអស់។ ទេវតាទាំងនេះ អាចផ្ដល់ផលប្រយោជន៍ដល់មនុស្ស និងធ្វើបាបមនុស្សដែរ។ ដូច្នេះគេត្រូវតែគោរពអារក្សអ្នកតាទាំងនោះជាចាំបាច់ ។

**ឥទ្ធិពលនៃខ្មែរទេសឥណ្ឌា**

តាំងពីយូរលង់ណាស់មកហើយ ពួកអ្នកសំពៅជាតិឥណ្ឌាតែងធ្វើជំនួញជាមួយអ្នកស្រុក

ដើមនៃជ្រោយឥណ្ឌូចិន។ នៅដើមគ្រិស្តសករាជ ប្រទេសឥណ្ឌាប៉ែកខាងជើងកើត ចលាចលវឹកវរដោយរឿងនយោបាយ។ ហេតុដូច្នេះហើយ បានជាមានជនជាតិឥណ្ឌា ទាំងក្រុមៗ ចាកចេញពីស្រុកកំណើតរបស់ខ្លួន ធ្វើដំណើរទៅរស់នៅភាគខាងត្បូងនៃ ឧបទ្វីបឥណ្ឌូចិន។ មានរឿងព្រេងចិនមួយនិទានដូចតទៅ៖

*«នៅដើមគ្រិស្តសករាជយើងនេះ ក្នុងរាត្រីមួយ ព្រាហ្មណ៍ម្នាក់ឈ្មោះកោណ្ឌញ្ញ ដែលជាប់ជាវណ្ណៈខ្ពស់មួយ ក្នុងចំណោមវណ្ណៈខ្ពស់ៗទាំងពីរនៃប្រទេសឥណ្ឌា យល់សុបិននិមិត្តរួចគាត់សម្រេចចិត្តថា ចេញដំណើរតាមសមុទ្រសំដៅទៅទិសខាងកើត។ ក្រោយពីបានធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃមក ព្រាហ្មណ៍នោះបានមកដល់ភូមិភាគសម្បូរសប្បាយមួយ នៅខាងត្បូងអាស៊ីភាគអាគ្នេយ៍។ ប៉ុន្តែ មិនទាន់ទាំងបានចុះពីសំពៅស្រួលបួលផង ព្រាហ្មណ៍នេះ ត្រូវពួកអ្នកស្រុកដែលស្ថិតនៅក្រោមការដឹកនាំរបស់ស្ដេចស្រីព្រះនាមលីវយី (តាមភាសាចិនឈ្មោះនេះមានន័យថា "ស្លឹកស្រស់" ចង់ប្លន់យកសំពៅរបស់គាត់។ ព្រាហ្មណ៍កោណ្ឌញ្ញបានបាញ់ព្រួញទិព្វ ទៅទម្លុះទូករបស់ព្រះនាង "ស្លឹកស្រស់" ធ្លាយពីម្ខាងទៅម្ខាង។ ដោយភ័យខ្លាចពេក ព្រះនាងក៏ចុះចូលនឹងលោក កោណ្ឌញ្ញនោះទៅ។ លោកកោណ្ឌញ្ញយកសំពត់ទៅបិទបាំងរាងកាយរបស់ព្រះនាង ហើយបានយកព្រះនាងធ្វើជាមហេសី»។*

មានរឿងព្រេងមួយទៀតជារឿងឥណ្ឌានិទានថា៖

*«ព្រាហ្មណ៍កោណ្ឌញ្ញធ្វើដំណើរតាមសមុទ្រ ចូលទៅឆ្នេរសមុទ្រខ្មែរ ហើយបានជួបនឹងព្រះនាងសោម៉ា (ឈ្មោះនេះមានន័យថា "បុត្រីព្រះច័ន្ទ") ដែលមកស្រង់ទឹក។ ព្រាហ្មណ៍នោះ ចាប់ចិត្តស្រឡាញ់ព្រះនាងយ៉ាងខ្លាំងជាទីបំផុត ហើយក៏សុំស្ដីដណ្ដឹងព្រះនាងធ្វើជាមហេសី។ ព្រះបិតារបស់ព្រះនាង ដែលជាស្ដេចនាគបានជួយបុត្រប្រសាររបស់ព្រះអង្គ ដោយបឺតស្រូបយកទឹកទាំងអស់នៅតំបន់នោះ ដើម្បីសង់ជារាជនីមួយ» ។*

អ្នកស្រុកពីដើមបានតាក់តែងរឿងព្រេងនេះឡើង ដើម្បីរ៉ាយរ៉ាប់អំពីជនជាតិឥណ្ឌាមកតាំងទីលំនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍។ ពួកអ្នកចំណូលថ្មីបានលើកទំនប់ ជីកប្រឡាយ ដើម្បីប្រែដីភក់ល្បាប់ឲ្យទៅជាដីសម្រាប់ភ្ជួររាស់ ដាំដំណាំបាន។ ជនជាតិឥណ្ឌាក៏នាំភាសា និងទំនៀមទម្លាប់របស់ខ្លួនចូលមកជាមួយដែរ។ ភាសានិងទំនៀម

ទម្លាប់ទាំងនេះបានឆ្លងទៅដល់អ្នកស្រុកដើមហើយអ្នកស្រុកបានកែប្រែទៅតាមចំណង់ចំណូលចិត្តនិងទៅតាមទំនៀមទម្លាប់របស់គេផ្ទាល់។ ភាសាសំស្ក្រឹតដែលជាភាសារបស់ពួកព្រាហ្មណ៍ក៏ត្រឡប់ទៅជាភាសាផ្លូវការសម្រាប់អ្នកកាន់អំណាចនិងអ្នករៀនអក្សរ។ ក្រោយមកជនជាតិខ្មែរ បានបង្កើតអក្សរម៉្យាង ដែលមានប្រភពចេញពីអក្សរសំស្ក្រឹត។

នៅពេលរាត្រី គេតែងនិទានរឿងរាមកេរ្តិ៍ ជារឿងឥណ្ឌាដ៏ល្បីល្បាញឲ្យអ្នកភូមិស្តាប់។ អ្នកភូមិរំជួលចិត្តអាណិតតួអង្គព្រះរាមដ៏ប្រិមប្រិយ ដែលដាច់សង្វែងស្វែងរកព្រះនាងសិតាដ៏សែនស្រស់ឆើតឆាយ ត្រូវក្រុងរាពណ៍ចាប់ពង្រត់យកទៅបាត់។ បន្ទាប់ពីព្រះរាមបានចងសម្ព័ន្ធមេត្រីជាមួយនឹងហនុមាន ជាស្តេចស្វាមានមហិទ្ធិតេជះបារមីដ៏ខ្លាំងក្លាអស្ចារ្យមក ព្រះអង្គផ្ចាញ់ក្រុងរាពណ៍ដ៏កាចសាហាវបាន[៣] ។

អ្នកស្រែចម្ការ ទឹមគោ ក្របី យកនង្គ័លឈើ និងរទេះគោដ៏ល្អប្រណិត តាមបែបឥណ្ឌាមកប្រើរហូត។ អ្នកស្រែដាំដើមត្នោត ធ្វើជាខណ្ឌសីមានៃដែនដីខ្មែរតាំងពីសម័យនោះមក។ ពួកអ្នកលេងខ្លួនសង្ហាស្លៀកសំពត់ចងក្បិនដូចពួកអ្នកមានបណ្ដាសក្តិឥណ្ឌាដែរ។ តាំងពីពេលនោះមកអ្នកស្រុកតែងលើកដៃសំពះគ្នាទៅវិញទៅមក តាមសុជីវធម៌បែបឥណ្ឌាដែរ។ ពេលមាតា បិតា ឬបង ប្អូន ទទួលមរណៈភាព សមាជិកគ្រួសារតែងកោរសក់ជាសញ្ញាសម្គាល់ការកាន់មរណៈទុក្ខ ហើយបូជាសពនោះផង។

ពួកព្រាហ្មណ៍ដែលមកតាំងទីលំនៅស្រុកនោះ បាននាំរបៀបចាត់ចែងសង្គមឲ្យមានវណ្ណៈឋានៈ ដូចនៅក្នុងស្រុកពួកគេដែរ[៤] ។

**ព្រហ្មញ្ញសាសនា**

ជនជាតិឥណ្ឌា ដែលចេញពីស្រុករបស់ខ្លួន មកតាំងទីលំនៅក្នុងស្រុកដទៃក៏នាំទាំងវប្បធម៌ ទាំងសាសនា របស់ពួកគេមកដែរ ពោលគឺព្រហ្មញ្ញសាសនា និងពុទ្ធសាសនា។ រីឯជនជាតិដើម ដែលជាម្ចាស់ស្រុកក៏ទទួលសាសនាទាំងនោះ ទាំងកែប្រែ និងលាយបញ្ចូលទំនៀមទម្លាប់គោរពអារក្ខអ្នកតារបស់គេ ។

ពួកព្រាហ្មណ៍តែងគោរពថ្វាយបង្គំព្រះបីអង្គដ៏ប្រសើរជាងគេបំផុតគឺ ព្រះព្រហ្មដែលមានព្រះភ័ក្ត្របួន ហើយដែលគេតែងគោរព ទុកជាព្រះដ៏មានតេជានុភាពសព្វប្រការ

ព្រះនរាយណ៍ដែលមានព្រះហស្តបួន ដែលពួកគេគោរព ទុកជាព្រះសង្គ្រោះរបស់ពិភពលោក ហើយព្រះឥសូរ ដែលបានបង្កើតពិភពលោក និងដែលអាចរំលាយពិភពលោកឲ្យសាបសូន្យផង។ ព្រះអង្គជាម្ចាស់ជីវិតប្រោសមនុស្សឲ្យមានជីវិត និងអាចដកជីវិតគេក៏បានដែរ។ តែជនជាតិខ្មែរនិយមគោរពថ្វាយបង្គំព្រះឥន្ទ ដែលទាក់ទងជាមួយមនុស្ស លោក ហើយមានទេវតាទេពអប្សរជាច្រើនអង្គ គោរពបម្រើព្រះអង្គ ព្រមទាំងមានទេវទូតដែលជាអ្នកនាំសាររបស់ព្រះអង្គដែរ។ ព្រះនិងទេវតាទាំងនេះ គង់នៅភ្នំព្រះសុមេរុ ដែលខ្មែរតែងហៅថា «ព្រះមេន» ស្ថិតនៅកណ្តាលពិភពលោក។ ពួកគេតែងជឿថា ព្រះទាំងនោះមានកិលេសតណ្ហាដូចមនុស្សយើងដែរ។

ពួកព្រាហ្មណ៍ស្គាល់របៀបគោរពទេវតា និងគោរពព្រះគ្រប់ព្រះអង្គ ស្របទៅតាមឋានន្តរសក្តិរបស់ព្រះទាំងនោះ។ ដូច្នេះហើយ បានជាពួកព្រាហ្មណ៍មានអំណាចទៅលើប្រជារាស្ត្រសាមញ្ញធម្មតា។

**ពុទ្ធសាសនា**

ព្រះសិទ្ធត្ថគោតម ចាប់បដិសន្ធិនៅសតវត្សទី ៦ មុនគ្រីស្តសករាជក្នុងភូមិភាគខាងជើងនៃប្រទេសឥណ្ឌា។ ពេលបានត្រាស់ជាព្រះពុទ្ធឬ "ព្រះសម្មាសម្ពុទ្ធ"ហើយ ទ្រង់បានទេសនាជំទាស់នឹងទ្រឹស្តីរបស់ពួកព្រាហ្មណ៍ ដែលពុំអាចជួយដោះស្រាយបញ្ហាជីវិតមនុស្សលោកបាន មានបញ្ហាទុក្ខនិងសេចក្តីស្លាប់ជាដើម។ ព្រះអង្គបានសម្តែងធម៌ទេសនាសម្រាប់ជួយរំដោះទុក្ខគឺ ត្រូវស្គាល់ឲ្យច្បាស់នូវអ្វីទៅដែលជាទុក្ខ រួចធ្វើសមាធិរម្ងាប់កាមកិលេសតណ្ហាដែលជាប្រភពដើមនៃទុក្ខ។ សាវ័កខ្លះពេញចិត្តគោរពបូជាព្រះពុទ្ធ ទុកជាព្រះបរមគ្រូ អ្នកទាំងនោះកាន់ព្រះពុទ្ធសាសនាតាមផ្នែក "ហីនយាន" (យានតូចសម្រាប់ទៅរកនិព្វាន)។ ផ្ទុយទៅវិញ សាវ័កខ្លះគោរពបូជាព្រះពុទ្ធ ទុកជាអាទិទេពមួយ ហើយនាំគ្នាថ្វាយខ្លួនចំពោះព្រះពោធិសត្វ ដែលពន្យារពេលចូលបរិនិព្វាន ដើម្បីជួយមនុស្សក្នុងលោកនេះ។ គេហៅថាផ្នែកនេះថា "មហាយាន" (យានធំសម្រាប់នាំចូលនិព្វាន)។

ពុទ្ធបរិស័ទបាននាំពុទ្ធសាសនាផ្នែកមហាយានចូលមកក្នុងប្រទេសកម្ពុជាប្រហែលជានៅដើមគ្រីស្តសករាជយើងនេះ។ ពួកឈ្មួញឥណ្ឌាខ្លះ បាននិមន្តព្រះសង្ឃមកតាមសំពៅរបស់ខ្លួន ឈ្មួញខ្លះទៀតដឹកនាំព្រះពុទ្ធរូប មានព្រះពោធិសត្វ "លោកេស្វរៈ" ជាដើម ដើម្បីឲ្យព្រះអង្គជួយការពារថែរក្សាពួកគេក្នុងពេលធ្វើដំណើរ។

**ពីនគរហ្វូណនមកនគរចេនឡា** *(សតវត្សទី ១ ដល់សតវត្សទី ៤)*

ព្រហ្មញ្ញសាសនាមានទ្រឹស្ដីម៉្យាង ចែងអំពីឋានៈរបស់ស្ដេចគឺ គេចាត់ទុកព្រះរាជាជាអ្នកដែលធ្វើឲ្យស្ថានកណ្ដាល (មនុស្សលោក) និងស្ថានលើ (ទេវលោក) មានទំនាក់ទំនងគ្នាដោយស្រួល។ ពួកគេយល់ថា ព្រះរាជវាំងប្រៀបបាននឹងភ្នំព្រះសុមេរុ ដែលជាលំនៅរបស់ពពួកទេវតា និងព្រះទាំងឡាយ។ ព្រះរាជាតែងសង់វាំងនៅលើភ្នំ ហើយតាំងរូបសំណាក «លិង្គព្រះឥសូរ» ក្នុងវាំងផង ព្រោះអស់លោកយល់ថា ក្នុងលិង្គនោះមានឫទ្ធិពលសម្រាប់គ្រប់គ្រងជីវិត។ វាំង និងវិហារជាកន្លែងសម្រាប់ឲ្យមនុស្សលោកអាចទាក់ទងជាមួយព្រះនិងទេវតាទាំងឡាយបាន។ ព្រះរាជាទ្រង់ទទួលមុខដំណែងពិសិដ្ឋមួយ គឺធ្វើឲ្យប្រទេសជាតិមានភោគទ្រព្យបរិបូរ និងមានភាពរុងរឿង។

ដោយទទួលមត៌កពីវប្បធម៌ឥណ្ឌាព្រាហ្មណ៍កោណ្ឌញ្ញ និងក្សត្រទាំងប៉ុន្មានដែលគ្រងរាជ្យបន្តមក ក៏ដាក់ព្រះនាមព្រះអង្គថា «ស្ដេចភ្នំ» គឺ "ហ្វូណន" តាមអក្សរសាស្ត្រចិន។

«ស្ដេចភ្នំ»ទាំងឡាយនៃនគរហ្វូណន បានគ្រងរាជ្យលើភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិនពីសតវត្សទី ១ ដល់សតវត្សទី ៧ នៃគ្រិស្ដសករាជ។ នៅក្នុងវាំង ស្ដេចនិងនាម៉ឺនទាំងពួងធ្លាប់កាន់ព្រហ្មញ្ញសាសនា ចំណែកប្រជាជនវិញ គេនាំគ្នាយកពុទ្ធសាសនាទៅអនុវត្តកាន់តែច្រើនឡើងៗជាលំដាប់ ។

ប្រជាជននគរភ្នំរកស៊ីធ្វើជំនួញ ច្រើនជាងប្រកបរបររកសិកម្ម។ ដូច្នេះ នគរភ្នំក៏បានទទួលឥទ្ធិពលយ៉ាងខ្លាំងពីប្រទេសក្រៅ[៥]។ ចាប់តាំងពីដើមគ្រិស្ដសករាជមកជនជាតិឡាតាំងនិងជនជាតិក្រិក ចាប់ផ្ដើមធ្វើជំនួញដូរជាមួយភូមិភាគនោះ តាមរយៈប្រទេសឥណ្ឌា។ ពួកអ្នកសំពៅឥណ្ឌាហៅដែនដីដែលលាតសន្ធឹងពីប្រទេសភូមាហូតដល់ប្រទេសឥណ្ឌូណេស៊ីថាជា "ជ្រោយមាស"។ ពួកគេស្មានថា ជួរភ្នំដែលគេមើលឃើញនាពេលព្រះអាទិត្យលិចនោះជា "ភ្នំមាស" ដែលជាព្រំដែននៃពិភពលោក។ ឈ្មោះជ្រោយមាសនេះ ក្លាយទៅជា "សុវណ្ណភូមិ" ដែលជាឈ្មោះប្រទេសកម្ពុជាក្នុងចម្រៀងខ្មែរបច្ចុប្បន្ន។

នយោបាយ និងវប្បធម៌របស់នគរភ្នំសម័យនោះ មានឥទ្ធិពលលើរដ្ឋចំណុះមួយចំនួន។ ក្នុងចំណោមរដ្ឋទាំងនោះ មាននគរចេនឡា ដែលស្ថិតនៅតាមដងទន្លេមេគង្គភាគកណ្តាល។ គ្រានោះរាជធានីនគរចេនឡាស្ថិតនៅត្រង់វត្តភូ (នៅភូមិភាគខាងត្បូងនៃប្រទេសលាវសព្វថ្ងៃ)។ ប្រជាជនដែលរស់នៅក្នុងនគរនោះ មានឈ្មោះថា៖ កម្ពុយ៉ា។ តាមសិលាចារឹកនៃសតវត្សទី១១ អ្នកស្រុកទាំងនោះស្មានថា ពួកគេមានដើមកំណើតពីព្រាហ្មណ៍ឥណ្ឌាម្នាក់ឈ្មោះព្រាហ្មណ៍ "កម្ពុ" ដែលបានមករស់នៅទីនោះ នាសតវត្សទី ៣ នៃគ្រិស្តសករាជ។ ព្រាហ្មណ៍នេះបានយកព្រះនាង "មេរ៉ា" ធ្វើជាភរិយា (តាមរឿងនិទានព្រះនាងមេរ៉ា មានកំណើតពីព្រះអាទិត្យ) ហើយបង្កបង្កើតបានជាប្រជាជនមួយដែលមានឈ្មោះថា "កម្ពុយា"។ ពាក្យ "កម្ពុជា" ប្រហែលជាកើតមកពីពាក្យ "កម្ពុយា" នេះឯង។

នៅចុងសតវត្សទី៦ នគរចេនឡាបានរំដោះខ្លួន រួចផុតពីអាណាព្យាបាលរបស់នគរភ្នំ។ មួយសតវត្សក្រោយមក ប្រទេសចេនឡាបានយកនគរភ្នំធ្វើជានគរចំណុះវិញ។ ក្រុងសម្បូរព្រៃគុកដែលស្ថិតនៅក្បែរកំពង់ធំសព្វថ្ងៃ ក៏ឡើងទៅរាជធានីនៃរាជាណាចក្រថ្មី។

> *«កាលពីដើម នគរភ្នំដែលស្ថិតនៅជាប់ឆ្នេរសមុទ្រ តែងតែទទួលឥទ្ធិពលពីប្រទេសខាងក្រៅ។ ប៉ុន្តែ ក្រោយពេលនគរនេះ បានធ្លាក់ទៅក្រោមការត្រួតត្រារបស់ប្រទេសចេនឡាមក អ្នកដឹកនាំមិនព្រមទទួលឥទ្ធិពលពីខាងក្រៅទាល់តែសោះ។ កាលពីដើមឡើយ នគរភ្នំមានសម្បត្តិធនធានស្តុកស្តម្ភ ដោយធ្វើជំនួញជួញដូរ។ ផ្ទុយទៅវិញ ប្រទេសចេនឡាក្រខ្សត់គ្មានទំនាក់ទំនងធ្វើជាមួយប្រទេសជិតខាង ក្រៅតែពីការធ្វើសឹកសង្គ្រាមលុកលុយ និងការប្លន់វាយដណ្តើមយកទ្រព្យសម្បត្តិគេតែប៉ុណ្ណោះ។ ប្រជាជននគរចេនឡា លែងជាពពួកឥណ្ឌូនេស៊ី ដែលជាអ្នកប្រកបតាមសមុទ្រនោះទៀតហើយ ពួកគេទៅជា "ខ្មែរ" គឺក្រុមមនុស្សដែលគ្មាននរណាបានដឹងឬសគល់ឲ្យប្រាកដច្បាស់លាស់ឡើយ។ ក្នុងប្រទេសចេនឡានេះ មានកើតចេញពីអរិយធម៌មួយដែលមានលក្ខណៈជាខ្មែរសុទ្ធសាធ»(៦)។*

នៅនគរចេនឡា សិលាចារឹកមានសរសេរជាភាសាសំស្ក្រឹត និងជាភាសាខ្មែរផង(៧)។ អ្នកស្រុកគោរពព្រះហរិហរៈ គឺព្រះមួយអង្គ ដែលភ្ជាប់ព្រះវិស្ណុ (ហរិ) ទៅនឹងព្រះឥសូរ (ហរៈ) នៅក្នុងរូបបដិមាតែមួយ។ ពេលនោះស្តេចធ្វើទុក្ខបុកម្នេញពុទ្ធបរិស័ទ។

ក្នុងចន្លោះឆ្នាំ ៧១០ ទៅ ៧១៥ នគរចេនឡាបែកចេញជាព្រះរាជាណាចក្រពីរគឺ "ចេនឡាដីគោក" និង "ចេនឡជើងទឹក"។ រាជាណាចក្រទាំងពីរនោះ ស្រដៀងនគរភ្នំ និងនគរចេនឡា។

**អង្គរតើបុរីដ៏ជាទីសក្ការបំផុតដែលមានពពួកទេវតាការពារថែរក្សា**

ប្រហែលក្នុងឆ្នាំ ៨០២ ព្រះបាទជ័យវរ្ម័នទី២ ជាក្សត្រនគរចេនឡាទ្រង់បានទទួលអភិសេកជា"ក្សត្រចក្រវាលទិន" គឺថាជា "ក្សត្រសកល" ដែលមានអំណាចពេញលក្ខណៈក្នុងព្រះរាជាណាចក្ររបស់ព្រះអង្គ។ ពិធីអភិសេកនេះ បានប្រារព្ធឡើងនៅឯភ្នំគូលេន ដែលជាភ្នំរបស់ព្រះឥសូរ។ ព្រះអង្គបានប្រគល់ឲ្យព្រាហ្មណ៍ម្នាក់ និងកូនចៅរបស់គាត់ធ្វើសក្ការៈថ្វាយព្រះឥសូរ ដែលជាស្ដេចនៃពួកទេវតា(៨)។ ពេលព្រះបាទជ័យវរ្ម័នទី ២ ចូលទិវង្គតទៅ អ្នកស្រុកគោរពព្រះអង្គដូចជារូបព្រះដែលព្រះអង្គធ្លាប់ស្រឡាញ់ កាលទ្រង់នៅមានព្រះជន្មនៅឡើយ។

ព្រះបាទជ័យវរ្ម័នទី២ និងក្សត្រទាំងឡាយដែលសោយរាជ្យបន្តពីព្រះអង្គ បានកសាងរាជធានីជាច្រើននៅក្នុងតំបន់អង្គរ។ ពាក្យ "អង្គរ" ក្លាយមកពីពាក្យ "នគរ" មានន័យថា "ក្រុង"។ ពេលមហាក្សត្រទាំងឡាយកសាងរាជធានី ទ្រង់តែងមានបំណងចង់បង្កើតទេវលោកនៅលើផែនដីយើងនេះ គឺនៅចំកណ្ដាលទីក្រុងនោះ មានភ្នំប្រសិទ្ធិ៍លេចអណ្ដែតឡើង ជានិមិត្តរូបភ្នំព្រះសុមេរុ ដែលជាលំនៅរបស់ទេវតាទាំងឡាយ។ កំពែងជុំវិញទីក្រុង ជាតំណាងជួរភ្នំចក្រវាឡ ដែលនៅជុំវិញពិភពលោក ស្នាមភ្លោះធំជានិមិត្តរូបមហាសមុទ្រ។ ដូច្នេះ ទីក្រុងអង្គរក៏ទៅជារាជធានីដ៏ឧត្តុងគឧត្តមមួយ ដែលផ្ដល់ឲ្យរាជាណាក្របានសម្បូរសប្បាយ និងគង់វង្សស្ថិតស្ថេរជានិច្ច(៩)។ ម្យ៉ាងទៀត ព្រះមហាក្សត្រទាំងនោះ ពុំយកអាវុធមកការពារទីក្រុងទេ គឺទ្រង់បែរជាយកជំនឿទៅលើទេវតាមកការពារក្រុងវិញ ហើយសូម្បីតែពេលទ្រង់ចេញទៅធ្វើសង្គ្រាម ក៏ទ្រង់ចាត់ទុកដូចជាកិច្ចការខាងសាសនាដែរ។

ទោះបី ប្រាសាទច្រើនក្នុងអង្គរបានឧទ្ទិសចំពោះព្រះឥសូរក្ដី ទោះបីស្ដេចព្រមទាំងមន្ត្រីរាជការទាំងអស់ កាន់ព្រហ្មញ្ញសាសនាក្ដី ក៏នៅតែមានគេគោរពប្រណិប័តន៍ព្រះពុទ្ធសាសនាដែរ។ ព្រះបាទជ័យវរ្ម័នទី៥ (៩៦៣-១០០១) ទ្រង់គោរពព្រះឥសូរ ក៏ប៉ុន្តែទ្រង់បានបញ្ជាឲ្យមន្ត្រីម្នាក់ដែលស្រឡាញ់ព្រះពុទ្ធសាសនាយ៉ាងខ្លាំង លើកពុទ្ធប្បដិមាចាស់ៗ ដែលពួកអ្នកប្រឆាំងពុទ្ធសាសនាបានវាយរំលំចោលនោះ មកតម្កល់ឡើងវិញ

ហើយទ្រង់បានបញ្ជាឲ្យគេសាងព្រះពុទ្ធប្បដិមាថ្មីៗខ្លះ ថែមទៀតផង។ ទ្រង់បញ្ជាឲ្យទិញក្បួនគម្ពីរ និងសៀវភៅអត្ថាធិប្បាយអំពីពុទ្ធសាសនាខាងមហាយានជាច្រើន។ នាសតវត្សទី១១ ជាងចម្លាក់បានឆ្លាក់រូបបដិមាព្រះពុទ្ធប្រក់នាគក្បាលប្រាំពីរ ជាលើកដំបូង។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គេក៏មិនបំបាត់ចោលព្រហ្មញ្ញសាសនាដែរ។ ព្រះបាទសុរិយាវរ្ម័នទី២ (១១១៣-១១៤៥) បានសាងប្រាសាទអង្គរវត្ត ឧទ្ទិសចំពោះព្រះវិស្ណុ គឺព្រះដែលទ្រង់ស្រឡាញ់ជាងគេ ។

ក្នុងឆ្នាំ ១១៧៧ ពួកចាមវាយយកក្រុងអង្គរបាន(១០)។ ពួកចាមបានប្លន់យករូបបដិមាដែលថែរក្សាការពាររាជាណាចក្រខ្មែរទៅជាមួយ និងវាយរូបបដិមាទាំងនោះ បាក់បែកខូចខាតខ្ទេចខ្ទី ដើម្បីឲ្យរូបបដិមាទាំងនោះបាត់បង់មហិទ្ធិឫទ្ធិពិសិដ្ឋ។

ដោយពួកចាមវាយយកក្រុងអង្គរបាន មានន័យថាឫទ្ធិបារមីរបស់ពពួកទេវតា គ្មានប្រសិទ្ធិភាពការពារក្រុងបានទេ។ ដូច្នេះ ព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨) ទ្រង់បានខិតខំរកមធ្យោបាយការពារក្រុងអង្គរ តាមបែបសាសនាមួយផ្សេងទៀត ដែលទ្រង់យល់ថាស័ក្តិសិទ្ធិជាងប្រព័ន្ធការពាររបស់ពួកក្សត្រសោយរាជ្យមុនៗព្រះអង្គ។ ទ្រង់ក៏ងាកទៅពឹងផ្អែកលើព្រះពោធិសត្វ"អវលោកេស្វរៈ" ដែលប្រមើលសុខទុក្ខរបស់សត្វលោក ហើយដែលពោរពេញដោយធម៌មេត្តាករុណា។ ទ្រង់បានខិតខំដាស់តឿនអ្នកស្រុកឲ្យធ្វើពិធីគោរពបូជាចំពោះព្រះទាំងប៉ុន្មាន ដែលពួកគេតែងគោរពតាំងពីរជំនាន់ដើមមកនោះ។ ទ្រង់ខិតខំប្រឹងប្រែងប្រមូលផ្តុំព្រះទាំងនោះ ឲ្យចូលរួបរួមជាមួយព្រះពោធិសត្វអវលោកេស្វរៈ ដើម្បីការពារក្រុង។ ដូច្នេះ ព្រះអង្គបានធ្វើឲ្យរាជធានីអង្គរមានទម្រង់ថ្មីទាំងស្រុង គឺនៅចំកណ្តាលទីក្រុងទ្រង់បានសាងប្រាសាទបាយ័ន ដែលជាប្រាសាទភ្នំ និងជាព្រះដំណាក់របស់ពពួកទេវតាស្របទៅតាមព្រហ្មញ្ញសាសនា។ ទ្រង់បានឧទ្ទិសវិហារដែលនៅកណ្តាលប្រាសាទបាយ័ននេះ ថ្វាយចំពោះព្រះពុទ្ធ។ កំពូលប្រាសាទនេះ មានប្រាង្គមុខបួនជាច្រើន។ ប្រាង្គទាំងនេះតំណាងនូវទេវតាជាអ្នកចម្បាំង និងជាអ្នកថែរក្សាការពារព្រះរាជាណាចក្រ។ ជុំវិញទីក្រុងអង្គរ ទ្រង់បានឲ្យប្រជាជនសង់កំពែងដែលមានប្រវែងមួយជ្រុងៗ ៤ គ.ម និងមានស្នាមភ្លោះទទឹងប្រវែង ១០០ ម៉ែត្រ ព័ទ្ធពីក្រៅកំពែងទាំងនោះថែមទៀតផង។ ដូចពីសម័យដើម កំពែងទាំងនោះជានិមិត្តរូបនៃជួរភ្នំដែលនៅជុំវិញចក្រវាឡ ហើយស្នាមភ្លោះ ជានិមិត្តរូបមហាសមុទ្រ។ នៅក្លោងទ្វារទាំងប្រាំនៃក្រុងអង្គរមានរូបបដិមាមុខបួនជាតំណាងអាទិទេពការពារគ្រប់ទិស។ អាទិទេព

មានពីរបែប គឺទេវតានិងអសុរៈ កាន់នាគរាជចាំយាមការពារស្ពាន ដែលឆ្លងកាត់ប្រឡាយនៅមុខកំពែង។ នៅជិតអង្គរទ្រង់ឲ្យជីកស្រះនាគព័ន្ធ ដែលនឹងត្រូវរីងស្ងួតក្រោយគេនាពេលចុងបំផុងនៃកាលវេលា។ តាមជំនឿ ក្នុងព្រះពុទ្ធសាសនា រាជាណាចក្រណាដែលកាន់កាប់ស្រះនាគព័ន្ធនេះ នឹងស្ថិតស្ថេរគង់វង់យូរអង្វែងតរៀងទៅ។ ដោយព្រះអង្គមានព្រះហឫទ័យជឿយ៉ាងខ្លាំងទៅលើ ការជួយជ្រោមជ្រែងរបស់ពពួកទេវតា ទ្រង់ឈ្វេងយល់ថា ទីក្រុងអង្គរត្រូវតែបានសេចក្តីសុខគ្មានអ្វីអាចយាយីបានឡើយ។

សិលាចារឹកនាម័យនោះបញ្ជាក់ថា យោធាមិនសំខាន់ដូចបុណ្យកុសលទេ។ ដូច្នេះហើយបានជាព្រះបាទជ័យវរ្ម័នទី៧ បញ្ជាឲ្យសាងប្រាសាទ និងវត្តអារាមជាច្រើនពេញទូទាំងប្រទេសជាពិសេសនៅភូមិភាគអង្គរ។ ដោយព្រះអង្គមានព្រះទ័យពោរពេញដោយធម៌មេត្តាករុណា ចំពោះសត្វលោកដែលកើតទុក្ខ ទ្រង់បានបញ្ជាឲ្យសាងមន្ទីរពេទ្យចំនួន ១០២ ដែលស្ថិតនៅក្រោមម្លប់ដ៏ត្រជាក់ របស់ព្រះពោធិសត្វអវលោកេស្វរៈដែលព្យាបាលជំងឺទាំងអស់។ ព្រះមហាក្សត្រប្រហែលជាកើតឃ្លង់ផង។

> *«ព្រះអង្គឈឺចាប់ខ្លោចផ្សារ នឹងជំងឺឈឺថ្កាត់របស់ប្រជារាស្ត្រព្រះអង្គ ជាងរោគាព្យាធិរបស់ព្រះអង្គផ្ទាល់ ព្រោះទុក្ខវេទនានិងការឈឺចាប់របស់ប្រជារាស្ត្រ គឺជាទុក្ខវេទនា និងការឈឺចាប់របស់ព្រះមហាក្សត្រ មិនមែនការឈឺចាប់របស់ព្រះអង្គផ្ទាល់ឡើយ ដែលធ្វើឲ្យព្រះអង្គខ្លោចផ្សារនោះ»។ រាជបញ្ញត្តិរបស់ព្រះបាទវរ្ម័នទី៧ ស្តីពីមន្ទីពេទ្យ ចារឹកទុកនៅលើសិលាស្តម្ភសាយហ្វុង* (១១)។

ព្រះរាជបុត្ររបស់ព្រះបាទជ័យវរ្ម័នទី៧ មួយអង្គ ព្រះនាមតមៈលិន្ទ បានទៅរស់នៅឯប្រទេសសេរីលង្កា។ នៅសម័យនោះ ប្រទេសសេរីលង្កាជាមណ្ឌលកែទម្រង់ពុទ្ធសាសនាយ៉ាងសំខាន់។ ប្រជាជនសេរីលង្កាមានបំណងធ្វើឲ្យព្រះពុទ្ធសាសនា មានភាពបរិសុទ្ធឥតខ្ចោះ ដូចពីដើម។ ព្រះអង្គម្ចាស់តមៈលិន្ទ នាំយកពុទ្ធសាសនា ដែលទ្រង់ចូលចិត្តគឺ"ពុទ្ធសាសនាទម្រង់ថេរវាទ" (ហីនហាន) ចូលមកក្នុងប្រទេសកម្ពុជា។

ថែមពីលើសំណង់សម្រាប់ការពារក្រុងអង្គរតាមជមនឿសាសនា ព្រះមហាក្សត្របានបញ្ជាឲ្យប្រជាជនកសាងប្រព័ន្ធទឹកយ៉ាងវិសេសវិសាលក្រៃលែង ក្នុងតំបន់អង្គរនេះ ដោយមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពស្រែចម្ការ អ្នកស្រែអាចធ្វើស្រូវបានបី ឬបួនដងបណ្តាក់តៗគ្នាពេញមួយឆ្នាំ នៅលើទីដីជិតៗគ្នានៃស្រុកភូមិតែមួយ ដូច្នេះគេអាចប្រមូល

ផលបានយ៉ាងបរិបូរ។ ដោយព្រះមហាក្សត្រជាម្ចាស់ទឹកដី ម្ចាស់ដី ព្រះអង្គចាត់ចែង និងត្រួតលើប្រព័ន្ធបញ្ចេញទឹកយ៉ាងសកម្មបំផុត នាំឲ្យសេដ្ឋកិច្ចមានដំណើរការបានល្អ។ ព្រះអង្គធ្វើឲ្យស្រូវបានផលបរិបូរ និងធ្វើឲ្យចំណានួនប្រជារាស្ត្រកើនច្រើនឡើងៗជាលំដាប់។ នៅសម័យនោះ ព្រំប្រទល់នៃព្រះរាជាណាចក្រខ្មែរលាតសន្ធឹងចាប់ពីសមុទ្រចិន (ខាងកើត) រហូតដល់វាលទំនាបនៃទន្លេមេណាម (កណ្ដាលប្រទេសថៃសព្វថ្ងៃ) និងទៅដល់ប្រទេសម៉ាឡេស៊ី (ខាងលិច)។ នៅខាងត្បូងលាតសន្ធឹងពីជ្រោយទឹកខ្មៅ (ភាគខាងត្បូងបំផុតនៃជ្រោយឥណ្ឌូចិន) និងនៅខាងជើងរហូតទៅដល់វៀងច័ន្ទ (កណ្ដាលប្រទេសលាវសព្វថ្ងៃ)។

**ព្រះបាទជ័យវរ្ម័នទី៧** *(សតវត្សទី ១៤ និងទី ១៥)*

ក្រោយពីសម័យដ៏រុងរឿងនោះមក ប្រទេសកម្ពុជាស្គាល់តែអសន្តិសុខ និងការរំជើបរំជួល ទាំងខាងនយោបាយ ទាំងខាងសាសនា។ ពួកអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ ពុំបានដឹងអ្វីឲ្យច្បាស់អំពីហេតុការណ៍ទាំងឡាយ ដែលបានកើតឡើងក្នុងសតវត្សទាំងនោះឡើយ។

ក្នុងចំណោមក្សត្រទាំងឡាយ ដែលសោយរាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី ៧ មានក្សត្រមួយអង្គ បានបញ្ជាឲ្យអ្នកស្រុកគោរពព្រះឥសូរឡើងវិញ។ ក្នុងរជ្ជកាលស្ដេចអង្គនោះ ពួកអ្នកប្រឆាំងនឹងព្រះពុទ្ធសាសនាខ្លះ បានវាយកម្ទេចបំផ្លាញរូបបដិមាព្រះពុទ្ធ នៅប្រសាទអង្គរ។ ប៉ុន្តែ ប្រជារាស្ត្រនិងមន្ត្រីជាច្រើន ស្រឡាញ់ចូលចិត្តធម៌មេត្តាករុណារបស់ព្រះពុទ្ធជាជាងទ្រឹស្ដីដ៏សាំញ៉ាំនៃព្រាហ្មណ្ណសាសនាទៅវិញ។

នៅសម័យនោះមានវិបត្តិនយោបាយ និងវិបត្តិសង្គមថែមទៀត។ ក្នុងសម័យអង្គរ អ្នកក្រុងដែលរកស៊ីធ្វើជំនួញ មានធនធានកាន់តែច្រើនឡើងៗ។ ពួកអ្នកមានស្តុកស្តម្ភទាំងនោះ មិនសូវពេញចិត្តនឹងរបៀបស្ដេចដឹកនាំសេដ្ឋកិច្ចទេ។ រីឯពួកព្រាហ្មណ៍និងមេទាហានចម្បាំងរកធនធានច្រើន ដោយចាប់អ្នកស្រុកធ្វើជាទាសករ ចាប់កសិករឲ្យសង់ឬថែរក្សាប្រព័ន្ធបញ្ជូលទឹក និងថែរក្សាប្រាសាទខាងព្រហ្មញ្ញសាសនាផងដែរ។

ប្រជាជនកសិករបានបះបរឡើងប្រឆាំងពួកព្រាហ្មណ៍ទាំងនោះ និងស្ដេចគ្រងរាជ្យ។ មានមន្ត្រីម្នាក់បះបោរដណ្ដើមយកអំណាចបាន ហើយអនុញ្ញាតអ្នកស្រុកឲ្យកាន់ព្រះពុទ្ធ

សាសនាឡើងវិញ ។ មន្ត្រីនោះ បានឡើងសោយរាជ្យ ដោយសារព្រះនាមថា ព្រះបាទឥន្ទ្រវរ្ម័ន (១២៩៥-១៣០៥)។ នៅលើសិលាចារឹកជាផ្លូវការទ្រង់យកភាសាបាលី ដែលជាភាសារបស់ពុទ្ធសាសនា មកប្រើជំនួសភាសាសំស្ក្រឹតដែលជាភាសារបស់ពួកព្រាហ្មណ៍។

មានរឿងព្រេងមួយ បានបរិយាយអំពីការរីករវរនៅក្នុងសង្គម ដែលបណ្តាលឲ្យរលំរាជវង្សនុវង្ស ដូចតទៅ៖

*«មានព្រះមហាក្សត្រមួយអង្គ បានបញ្ជាឲ្យអ្នកថែសួនម្នាក់ យាមចម្ការត្រសក់ផ្អែមរបស់ព្រះអង្គ។ ទ្រង់បានប្រគល់លំពែងមួយដល់អ្នកយាមនោះ និងបញ្ជាឲ្យសម្លាប់ចោរណា ដែលប៉ុនប៉ងលួចត្រសក់ដ៏មានឱជារស់ឆ្ងាញ់ទាំងនោះ។ រាត្រីមួយដោយឃ្លានត្រសក់ខ្លាំងពេក ស្តេចក៏យាងចុះទៅបេះត្រសក់ពុំបានប្រាប់អ្នកយាមឲ្យដឹងជាមុន។ អ្នកយាមនោះច្រឡំស្មានថា ជាចោរចូលមកលួចបេះត្រសក់ក៏យកលំពែងចាក់ព្រះអង្គស្លាប់ទៅ។ ពេលនោះ បញ្ហាបន្តរាជ្យសម្បត្តិបានចោទឡើង។ នាម៉ឺនសព្វមុខមន្ត្រីឲ្យដំរីរាជ្យផ្សង ជ្រើសរើសរកព្រះមហាក្សត្រថ្មី។ ដំរីរាជ្យមកឈប់នៅពីមុខអ្នកយាម ដែលធ្វើគុតស្តេច ហើយឃោលប្រម៉ោយ។ អ្នកយាមចម្ការនោះក៏ឡើងសោយរាជ្យ ហើយយកបុត្រីតែមួយរបស់ស្តេច មកធ្វើជាភរិយាថែមទៀតផង។ គេថ្វាយនាមថា ព្រះបាទត្រសក់ផ្អែម។ ក្រោយពេលអភិសេកហើយ ទ្រង់មានព្រះរាជនាមថា "ព្រះបាទនិព្វានបទ"»។*

តាំងពីពេលនោះមកអ្នកស្រុកបានគោរពពុទ្ធសាសនាហីនយាន ទុកជាសាសនារបស់រដ្ឋរហូតតរៀងមក។ នៅលើសិលាចារឹកក៏ដូចជានៅក្នុងពិធីបុណ្យផ្សេងៗដែរ អ្នកប្រាជ្ញាឈប់យកភាសាសំស្ក្រឹតមកប្រើ គឺយកភាសាបាលីមកប្រើជំនួសវិញ។

**«ត្រូវបានបំផ្លាញក្រុងអង្គរចោល »**

ពេលប្រទេសកម្ពុជាកំពុងជួបប្រទះវិបត្តិផ្ទៃក្នុងនោះ ពួកសៀមចាប់ផ្តើមចូលលុកលុយប្រទេសកម្ពុជា។

ព្រះចៅអធិរាជយូប៊ីឡៃ ដែលជាចៅរបស់ឈីងជីខាន ទើបតែដណ្តើមបានជ័យជំនះលើប្រទេសចិន។ នៅឆ្នាំ ១២៨២ ព្រះចៅអធិរាជយូប៊ីឡៃនេះ បានវាយឈ្នះប្រទេសភូមានិងចង់កាន់កាប់នគរកម្ពុជាដែរ តែត្រូវបរាជ័យ។ ពួកទាហានម៉ុងហ្គោលីរបស់ព្រះចៅយូប៊ីឡៃ បានរុញច្រានកុលសម្ព័ន្ធថៃ ដែលរស់នៅភាគខាងត្បូងនៃប្រទេស

ចិន។ ជនជាតិថៃទាំងនោះ បានរំកិលចូលបន្តិចម្តងៗ តាមជ្រលងភ្នំទាំងប៉ុន្មាន នៃឥណ្ឌូចិនភាគកណ្តាល និងប្រទេសភូមា។ កុលសម្ព័ន្ធថៃទាំងនោះ បានយកអក្សរខ្មែរមកប្រើ ហើយរៀបចំកងទ័ពតាមរបៀបពួកម៉ុងហ្គោល។ ពួកគេខិតខំប្រឹងប្រែងដណ្តើមយកតំបន់ដែលស្ថិតនៅតាមវាលទំនាបនៃទន្លេមេណាម និងនៅប្រទេសលាវពីព្រះរាជាណាចក្រខ្មែរ។ ស្តេចខ្មែរបានកែនប្រជារាស្ត្រឲ្យទៅវាយដេញពួកថៃ តែកងទ័ពខ្មែរត្រូវទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ។ ពួកកុលសម្ព័ន្ធថៃបានបង្កើតរាជាណាចក្រមួយគឺ "ប្រទេសសៀម" ដែលមានក្រុងសុខោទ័យ (ក្រុងខ្មែរពីមុន) ជារាជធានី។ នៅឆ្នាំ ១៣៥០ ស្តេចសៀមថ្មីបានផ្ទេររាជធានីមកនៅអយុធ្យា ដែលស្ថិតនៅលើកោះមួយ នៃទន្លេមេណាមវិញ [១២]។

ពួកសៀមមានបំណងវាយយករាជាណាចក្រខ្មែរទាំងមូល។ នៅឆ្នាំ ១៣៥២ កងទ័ពសៀមបានឡោមព័ទ្ធក្រុងអង្គរអស់រយៈពេលមួយឆ្នាំ រួចពួកគេក៏វាយយកក្រុងនេះបាន។ ប្រជារាស្ត្រភាគច្រើនត្រូវគេជម្លៀស ហើយអាណាខេត្តខ្មែរទាំងឡាយបានធ្លាក់នៅក្រោមអំណាចរបស់ស្តេចសៀម។ ក្រោយមក ប្រជារាស្ត្រខ្មែរបានរំដោះប្រទេស រួចផុតពីការកាន់កាប់របស់សៀម ហើយស្គាល់សន្តិភាពបានបី បួនឆ្នាំប៉ុណ្ណោះ រួចសង្គ្រាមក៏ផ្ទុះឡើងសាជាថ្មីទៀត។ នៅឆ្នាំ ១៣៩៤ ពួកសៀមបានឡោមព័ទ្ធក្រុងអង្គរម្តងទៀត ហើយបានជម្លៀសប្រជាជនខ្មែរចំនួន ៧ ម៉ឺននាក់ទៅប្រទេសសៀម។ ពួកសៀមវាយកម្ទេចក្រុងអង្គរជាថ្មីម្តងទៀង នៅឆ្នាំ ១៤២០។ ព្រះបាទពញាយ៉ាត ជាព្រះមហាក្សត្រខ្មែរ បានរំដោះយកក្រុងអង្គរមកវិញនៅ ឆ្នាំ១៤៣១។ នៅឆ្នាំ ១៤៣២ ព្រះអង្គបានសម្រេចព្រះទ័យបោះបង់ចោលរាជធានីអង្គរ ដែលស្ថិតនៅជិតប្រទេសសៀមពេកនោះ ទៅគង់នៅឯស្រីសន្ធរវិញ។

សង្គ្រាមដែលមានឥតឈប់ឈរ បានធ្វើឲ្យប្រជារាស្ត្រនៅតំបន់អង្គរ មិនអាចថែរក្សាប្រព័ន្ធភ្លឺស្រែ និងប្រឡាយទាំងនោះបានឡើយ។ ម៉្យាងទៀត សង្គ្រាមធ្វើឲ្យប្រជារាស្ត្រដែលរស់នៅក្នុងតំបន់អង្គរនេះ រងគ្រោះនិងស្លាប់អស់ជាច្រើន ហើយប្រជារាស្ត្រមួយចំនួនទៀត បានរត់ភៀសខ្លួនចេញពីទីនោះ ទៅរស់នៅកន្លែងដទៃ។

ក្នុងឆ្នាំ ១៤៣៤ ព្រះបាទពញាយ៉ាតដែលគង់នៅឯស្រីសន្ធរ បានលើកព្រះរាជធានីទៅតាំងនៅឯចតុមុខ (ភ្នំពេញសព្វថ្ងៃនេះ) វិញ។ ព្រះរាជធានីថ្មីអនុគ្រោះដល់ការទាក់ទង និងការធ្វើដំណើរទៅមក ជាពិសេសតាមផ្លូវទឹក ព្រោះក្រុងថ្មីនេះ ស្ថិតនៅត្រង់ទីប្រសព្វ

នៃទន្លេមេគង្គ និងទនន្លេសាប។ ម៉្យាងទៀត វាលទំនាប និងវាលភក់នៅជុំវិញទន្លេទាំងពីរនេះ អនុគ្រោះដល់ដំណាំដាំដុះបានគួរសមដែរ។

រាជាណាចក្រកម្ពុជា ស្គាល់សន្តិភាពបានដប់-ម្ភៃឆ្នាំ គឺនៅក្នុងរាជ្យរបស់ព្រះបាទពញាយ៉ាត និងក្នុងរាជ្យរបស់ព្រះបាទនរាយណ៍ (១៤៦៣-១៤៦៨)។ ប៉ុន្តែ តាំងពីក្សត្រអង្គនេះចូលទិវង្គតទៅ វិបត្តិក្នុងរាជវង្សនុវង្ស ចេះតែកើតមានឡើងឥតឈប់ឈរបណ្តាលឲ្យប្រទេសជាតិធ្លាក់ចុះទន់ខ្សោយ ហើយត្រូវធ្លាក់ក្នុង កណ្តាប់ដៃរបស់សៀម។ នៅចុងសតវត្សទី ១៥ ប្រទេសសៀមបានយកតំបន់នៅខាងជើងជួរភ្នំដងរែកដាក់បញ្ចូលទៅក្នុងរាជាណាចក្ររបស់ពួកគេ។

---

(១) បើចង់ដឹងអំពីសម័យបុរេប្រវត្តិ សូមអាន "Préhistoire du Cambodge" របស់ Roland Moure, Archeogia លេខ ២៣៣ ខែមីនា ១៩៨៨ ទំព័រ ៤០-៥២។ ចំពោះភូមិវិទ្យាវិញ សូមអានសៀវភៅរបស់លោក Jean Delvert, Le Paysan cambodgien, ប៉ារីស ឆ្នាំ ១៩៦១ ឬ Que sais-je ប៉ារីស ឆ្នាំ ១៩៨៣។

(២) នៅប្រទេសកម្ពុជាបច្ចុប្បន្ន នាគនៅតែវត្ថុសម្រាប់លម្អ ដែលគេនិយមប្រើច្រើន គឺជាទេព្រក្សទំនុកបម្រុងប្រទេស។ មានរបាំខ្លះដែលគេយកមករាំសព្វថ្ងៃ ដូចជារបាំ "ត្រុត" បង្ហាញអំពីពិធីបរបាញ់ និងនេសាទជំនាន់ដើម។ សូមអានសៀវភៅ Les Khmers របស់អ្នកស្រី Solange Thierry ប៉ារីស ១៩៦៤ ទំព័រទី ១០ ។

(៣) រឿង "រាមាយណៈ" ឥណ្ឌាក្លាយទៅជារឿង "រាមកេរ្តិ៍" ខ្មែរ។

(៤) ក្នុងសង្គមខ្មែរ គេអាចសង្កេតឃើញ នៅតែមានសល់វណ្ណៈដូចនៅប្រទេសឥណ្ឌាដែរ។ សង្គមមានវណ្ណៈបីគឺ៖ ស្តេច-វាំង-រដ្ឋាបាល អ្នកស្រែចម្ការ អ្នកជំនួញ។ មន្ត្រីសំខាន់នីមួយៗ មានចោមរោមទៅដោយភ្ញៀវពន្លឺរបស់គេ។

(៥) តាមលោកសាស្ត្រាចារ្យ Delvert បាននិយាយថា៖ មានសំពៅ "កូឡង់ឌីយ៉ា" គឺសំពៅធំៗ សម្រាប់ដឹកទំនិញពីចក្រភពរ៉ូម៉ាំង តែងចូលចតនៅអូកែវ ដែលជាកំពង់ផែមួយស្ថិតនៅក្នុងតំបន់រ៉ាចយ៉ា (Rach Già) នៅភាគនិរតីនៃប្រទេសវៀតណាមសព្វថ្ងៃនេះ។ នៅក្រុងរ៉ាចយ៉ា ក្រុមអ្នកឯកទេសស្រាវជ្រាវវត្ថុបុរាណ បានរកឃើញប្រាក់ដែលមានរូបឆាយាលកណ្ឋ៍របស់ព្រះចៅអធិរាជរ៉ូម៉ាំង ព្រះនាម អង់តូណាំង ឡឺពីយើ (Antonin le Pieux 136-161)។ សូមអានសៀវភៅ Quesais-je? ទំព័រទី ៦។

(៦) Solange Thierry, op. Cit., ទំព័រ ៥៦។

(៧) អត្ថបទទាំងឡាយ ដែលនិយាយអំពីរឿងសក្ការបូជា និងអំពីច្បាប់ទម្លាប់នៃរាជវង្សានុវង្ស គេសរសេរជាភាសាសំស្ក្រឹត។ ចំណែកឯអត្ថបទដែលទាក់ទងនឹងកិច្ចការរបស់ជនសាមញ្ញវិញ ដូចជាបញ្ហាចែកដីធ្លីការលក់ពួកខ្ញុំបម្រើ... គេសរសេរជាភាសាខ្មែរ។

(៨) ក្នុងឆ្នាំ ១៩៧០ ក្រុម"បាគូ" តែងតែធ្វើពិធីផ្សេងៗនៅឯរាជវាំងភ្នំពេញនៅឡើយ។ អស់លោកទាំងនោះតែងតែនិយាយថា ពួកគេជាកូនចៅរបស់ព្រាហ្មណ៍នោះ។

(៩) អំពីរឿងទាំងនេះ យើងសរសេរតាមអ្នកស្រី ម៉ាដឺឡែនហ្សីតូ (Madeleine Giteau), op. Cit. ជាពិសេសក្នុងទំព័រលេខ ១១, ២០, ៧៣ និង ៨៤។ សៀវភៅនេះ មានសារសំខាន់ជាទីបំផុត ដើម្បីឲ្យបានយល់នូវនិមិត្តរូបខាងសាសនា នៅក្នុងសម័យអង្គរ។

(១០) ពួកចាមជាប្រជាជននៃនគរចម្ប៉ា។ ឥណ្ឌូណេស៊ីបានបង្កើតរាជាណាចក្រចម្ប៉ា ក្នុងសតវត្សទី២ នៃគ្រិស្តសករាជ។ នគរចម្ប៉ា ស្ថិតនៅខាងកើតប្រទេសកម្ពុជា គឺនៅចំកណ្តាលប្រទេសវៀតណាមសព្វថ្ងៃ។ ពួកចាមបានច្បាំងនឹងចិន ហើយនិងវៀតណាមក្នុងអំឡុងជាច្រើនសតវត្ស ដើម្បីរកទឹកដីទូលំទូលាយស្រួលរស់នៅ សម្រាប់ប្រជាជនគេ ដែលគេចេះតែកើនច្រើនឡើងៗជាលំដាប់។ ក្រោយមក ពួកគេបានច្បាំងនឹងប្រទេសកម្ពុជា ហើយកាន់កាប់ក្រុង អង្គរអស់រយៈពេល ៥ ឆ្នាំ។ បន្ទាប់មកព្រះបាទជ័យវរ្ម័នទី៧ បានវាយយកនគរចម្ប៉ាធ្វើជាអាណាខេត្តខ្មែរ ក្នុងអំឡុងពេល ៣០ ឆ្នាំ។ ចាប់ពីពាក់កណ្តាលសតវត្សទី ១៣ មក ពួកចាមត្រូវប្រឈមមុខតទល់នឹងពួកវៀតណាម ដែលលុកលុយយកប្រទេសគេធ្វើជាអាណាខេត្តរបស់ខ្លួន។ ពួកវៀតណាមបានឲ្យទាហានចូលទៅកាន់កាប់និងតាំងទីលំនៅលើទឹកដីទាំងនោះ។ ក្នុងឆ្នាំ ១៦៦០ ពួកជនភៀសខ្លួនចាមនៅក្នុងប្រទេសកម្ពុជា បានបះបោរប្រឆាំងនឹងព្រះបាទបរមរាជា ដែលបានដកយកឯកសិទ្ធិផ្សេងៗរបស់ពួកគេ។ នៅឆ្នាំ ១៦៩២ គឺនៅក្នុងរាជ្យរបស់ព្រះបាទជ័យជេដ្ឋាទី៤ ចាម ៥០០០នាក់ ដែលពួកវៀតណាមបណ្តេញចេញពីមាតុភូមិរបស់ខ្លួន មកសុំសិទ្ធិជ្រកកោននៅប្រទេសកម្ពុជា។ ក្សត្រអង្គនេះ យល់ព្រមហើយបានប្រគល់ដីនៅជិតរាជធានីលង្វែក ឲ្យពួកចាមទាំងនោះតាំងទីលំនៅ។ នៅឆ្នាំ ១៧៩២ វៀតណាមបានលេបរាជាណាចក្រចាម បញ្ចូលក្នុងរដ្ឋរបស់ខ្លួនរហូតតទៅ។

(១១) នៅជិតក្រុងវៀងច័ន្ទ ក្នុងប្រទេសលាវសព្វថ្ងៃ ។

(១២) ពីឆ្នាំ ១៩៣៩ ដល់ ១៩៤៥ រួចពី ១៩៤៨ រហូតដល់សព្វថ្ងៃនេះ ប្រទេសសៀមប្រែឈ្មោះថា ប្រទេសថៃវិញ។ អយុធ្យាជារាជធានីរបស់សៀមរហូតដល់ឆ្នាំ ១៧៦៨។

### ជំពូកទី២

## ជនជាតិអឺរ៉ុបនិងប្រជាជនកម្ពុជាចាប់ផ្ដើមទាក់ទងគ្នា

កាលពីជំនាន់ដើម មនុស្សទាំងអស់ក្នុងពិភពលោកយើងនេះ អាចទាក់ទងគ្នាទៅវិញទៅមកបានតែតាមរយៈផ្លូវគោកប៉ុណ្ណោះ។ តាំងពីមុនគ្រីស្តសករាជមកម្ល៉េះ ជនជាតិដែលនៅទ្វីបអឺរ៉ុបបានទាក់ទងជាមួយជនជាតិឥណ្ឌា និងជនជាតិចិនតាមផ្លូវគោកនេះ។ នៅឆ្នាំ ៣២៧ មុនគ្រីស្តសករាជ ព្រះចៅអធិរាជអាឡិចសង់ ( Alexandre le Grand ) បានឆ្លងទន្លេសិន្ធូនៃប្រទេសឥណ្ឌា។ បន្ទាប់មក ពួកសិល្បករក្រិកក៏ បានធ្វើដំណើរតាមផ្លូវគោកនេះដែរ ហើយបានផ្សព្វផ្សាយឥទ្ធិពលសិល្បៈរបស់គេ ជាពិសេសរបៀបសូនរូបរហូតដល់បង្ហាត់ជនជាតិអាស៊ីឲ្យចេះសូនធ្វើព្រះពុទ្ធរូបផង។

គ្រីស្តបរិស័ទឥណ្ឌាតែងនិយាយថា គ្រីស្តទូតថូម៉ាស បានមកដល់ប្រទេសគេ តាំងពីសតវត្សទី១ នៃគ្រីស្តសករាជមកម្ល៉េះ ហើយបានកសាងព្រះសហគមន៍នៅប្រទេសនោះ។ ក្រោយមក គឺនៅសតវត្សទី៧ ព្រះសហគមន៍បានកើតមានឡើងនៅប្រទេសចិន តែព្រះសហគមន៍ទាំងនោះ កាន់ជំនឿតាមលោក ណេស្តូរីយ៉ូស[១]។ នៅឆ្នាំ ១២៦៤ អ្នកដំណើរជាតិអ៊ីតាលីម្នាក់ឈ្មោះម៉ាកូប៉ូឡូ ធ្វើដំណើរកាត់ប្រទេសអាកមេនី ប្រទេសពែរស៊ីរហូតទៅដល់ប្រទេសចិន។ លោកចូលទៅក្នុងព្រះរាជវាំង ថ្វាយបង្គំព្រះចៅអធិរាជយូប៊ីឡៃនារាជធានីកំបាលុក (គឺក្រុងប៉េកាំងសព្វថ្ងៃនេះ)។ ព្រះចៅអធិរាជយូប៊ីឡៃ សុំឲ្យលោកម៉ាកូប៉ូឡូជួយធ្វើអន្តរាគមន៍សុំសម្តេចប៉ាបចាត់សាសនាទូតខ្លះៗ ឲ្យមកផ្សព្វផ្សាយគ្រីស្តសាសនានៅប្រទេសចិន។ នៅសតវត្សទី១៤ សម្តេចប៉ាប បានចាត់បព្វជិតខាងក្រុមគ្រួសារហ្វ្រង់ស៊ីស្កាំង ចំនួនដប់នាក់ឲ្យទៅប្រទេសចិនបានពីរលើក ប៉ុន្តែធម្មទេសនារបស់ពួកបព្វជជិតទាំងនោះមិនបានលទ្ធផលសោះ ។

រីឯអ្នកជំនួញសូត្រ ដែលតែងធ្វើដំណើរឆ្លងពីទ្វីបអាស៊ីទៅទ្វីអឺរ៉ុប ពួកគេបានយក

ផលិតផលរបស់ប្រទេសចិនដ៏ឆ្ងាយដាច់សង្វែង ទៅលក់ឲ្យពួកបស្ចិមប្រទេស។ តាមផ្លូវគោកដដែលនេះ មានលេចឮល្បីឈ្មោះបណ្ឌិតខាងបូព៌ាប្រទេសម្នាក់ជាអរហន្ត ដែលមានគុណសម្បត្តិប្រសើរខ្ពស់បំផុត។ ព្រះសហគមន៍កាតូលិកបានលើកតម្កើងបណ្ឌិតនោះដែលមានន័យថា «អរហន្តយូសាផ្វាត» ដែលពុំមែនជាអ្នកណាផ្សេងក្រៅពីព្រះពុទ្ធឡើយ។ រីឯបច្ចេកទេសខាងនាវា ចេះតែរីកចម្រើនឡើងឥតឈប់ឈរ ជាពិសេសអ្នកបច្ចេកទេសបានបង្កើតត្រីវិស័យនិងចង្កូត។ ដូច្នេះ ពួកអ្នកបើកនាវា អាចបញ្ជានាវាឆ្លងកាត់សមុទ្រតូចធំបានដោយស្រួល ហើយអ្នកជំនួញបស្ចិមប្រទេសបានចាប់ផ្តើមលក់ដូរនៅក្នុងភូមិភាគខាងត្បូងនៃទ្វីបអាស៊ី យើងដែលជាភូមិភាគមួយឆ្ងាយដាច់ស្រយ៉ាលពីផ្លូវគោធំៗ។

**ទ្វីបអឺរ៉ុបទាក់ទងនឹងទ្វីបអាស៊ី**

ក្នុងឆ្នាំ ១៤៨៧ ជនជាតិព័រទុយហ្គាល់ ( Portugal ) ម្នាក់ឈ្មោះ បារតូឡូមេអូឌីយ៉ាស ( Bartolomeo Diaz ) បើកសំពៅចេញពីប្រទេសព័រទុយហ្គាល់ សសៀរៗតាមឆ្នេរសមុទ្រខាងលិចនៃទ្វីបអាហ្វ្រិក។ ក្នុងឆ្នាំ ១៤៩២ ជនជាតិអ៊ីតាលីម្នាក់ មានដើមកំណើតនៅទីក្រុងហ្សែន ( Gênes ) ឈ្មោះគ្រីស្តូហ្វកូឡុំ ( Christophe Colomb ) ដែលបម្រើស្តេចប្រទេសអេស្ប៉ាញ ( Espagne ) បានរកឃើញទ្វីបអាមេរិក ( Amérigur )។ គាត់ច្រឡំទ្វីបអាមេរិកដែលលោកទើបទៅដល់នោះថាជាប្រទេសឥណ្ឌា គាត់ក៏ហៅអ្នកស្រុកដែលគាត់បានជួបថា "*ពួកឥណ្ឌា*"។ ក្នុងឆ្នាំ ១៤៩៧-១៤៩៩ លោកវ៉ាសកូដឺហ្គាម៉ា ( vasco de Gama ) បានធ្វើដំណើរតាមសំពៅ ចេញពីប្រទេសព័រទុយហ្គាល់ បើកសំពៅសសៀរតាមចុងទ្វីបអាហ្វ្រិក ហើយបានទៅ ដល់ប្រទេសឥណ្ឌា។ ក្នុងឆ្នាំ ១៥១០ ជនជាតិព័រទុយហ្គាល់ម្នាក់ទៀត ឈ្មោះអាល់ប៊ូគែក ( Albuguergue ) វាយយកក្រុងហ្គោអា ( Goa ) ដែលស្ថិតនៅលើឆ្នេរសមុទ្រខាងលិចនៃប្រទេសឥណ្ឌាបាន រួចវាយយកម៉ាឡាកា ( Malacca ) នៅលើឆ្នេរសមុទ្រខាងលិចនៃប្រទេសម៉ាឡេស៊ី ( Malaisie ) សព្វថ្ងៃ។ នៅចន្លោះឆ្នាំ ១៥១៩-១៥២២ លោកម៉ាសែឡង់ ( Magellan ) ជាជនជាតិព័រទុយហ្គាល់ដែលនៅបម្រើព្រះចៅស្រុកអេស្ប៉ាញ បានធ្វើដំណើរជុំវិញពិភពលោកជាលើកទីមួយ។ លោកបើកសំពៅតម្រង់ទិសខាងលិចជានិច្ច វាងទ្វីបអាមេរិកខាងត្បូង ហើយចូលមកប្រទេសរបស់លោកវិញ ដោយកាត់តាមប្រទេសហ្វីលីពីន ( Philippines ) និងប្រទេសឥណ្ឌា ( Inde )។ ក្នុងឆ្នាំ ១៥៦៥ ប្រទេសអេស្ប៉ាញវាយយកប្រទេសហ្វីលីពីនបាន។

ប្រទេសអេស្ប៉ាញ និងប្រទេសព័រទុយហ្គាល់ ដែលជាមហាអំណាចខាងសមុទ្រនាសម័យនោះចេះតែច្បាំងគ្នា។ ដូច្នេះ នៅឆ្នាំ ១៤៩៤ សម្តេចប៉ាបអាឡិសង់ទី៦ បានចែកពិភពលោកជាពីរផ្នែកប្រគល់ឲ្យមហាអំណាចទាំងពីរ គឺស្រុកទាំងប៉ុន្មានដែលស្ថិតនៅខាងលិចខ្សែបន្ទាត់ ចម្ងាយ ៣២០ គ.ម ខាងលិចទ្វីបអាហ្វ្រិក ពោលគឺខ្សែបន្ទាត់នៅចំកណ្តាលមហាសមុទ្រអាត្លង់ទិក(Atlantigue) ត្រូវធ្លាក់នៅក្រោមការត្រួតត្រារបស់ប្រទេសអេស្ប៉ាញ។ រីឯស្រុកទាំងប៉ុន្មានដែលនៅខាងកើតខ្សែបន្ទាត់ដដែលនោះ ត្រូវនៅក្រោមការត្រួតត្រារបស់ប្រទេស់ព័រទុយហ្គាល់វិញ។ សម្តេចប៉ាបបានសម្រេចដូច្នេះ ដោយមានបំណងចង់ឲ្យប្រទេសទាំងពីរ ដែលកាន់សាសនាកាតូលិកដូចគ្នា បានប្រកបដោយសុខសន្តិភាពវិ។ លោកក៏ប្រគល់ឲ្យមហាអំណាចទាំងពីរ ទទួលបន្ទុកផ្សព្វផ្សាយគ្រីស្តសាសនា ក្នុងផែនដីថ្មីនោះថែមទៀតផង។ មហាអំណាចទាំងពីរ បានចុះហត្ថលេខាយល់ព្រមតាមសេចក្តីសម្រេចនេះ  នៅក្រោមសន្ធិសញ្ញាក្រុងទ័កដេស៊ីឡាស (Tordésillas) នាឆ្នាំ ១៤៩៤។

អាស្រ័យហេតុនេះ ទ្វីបអាមេរិកដែលហៅថា "ប្រទេសឥណ្ឌាប៉ែកខាងលិច" ត្រូវធ្លាក់នៅក្រោមការត្រួតត្រារបស់ប្រទេសអេស្ប៉ាញ។ ដោយពួកអ្នកផ្សងព្រេងជាតិអេស្ប៉ាញបានរកឃើញប្រទេសហ្វីលីពីនមុនគេ សម្តេចប៉ាបក៏ប្រគល់ប្រទេសហ្វីលីពីននោះ ឲ្យពួកអេស្ប៉ាញត្រួតត្រាដែរ។ ចំណែកឯ "ប្រទេសឥណ្ឌាប៉ែកខាងកើត" ពោលគឺចុងបូព៌ាប្រទេស ត្រូវធ្លាក់នៅក្រោមការត្រួតត្រារបស់ប្រទេសព័រទុយហ្គាល់។ មហាអំណាចទាំងពីរ ទទួលបន្ទុកទាំងការគ្រប់គ្រង ទាំងការតែងតាំងសាសនា ក្នុងដែនដីថ្មីទាំងនោះ។

គ្រានោះ ប្រទេសព័រទុយហ្គាល់មានប្រជាជនមិនលើសពីមួយលានកន្លះផង។ ទោះបីជាប្រជាជនព័រទុយហ្គាល់មានជំនឿខាងគ្រីស្តសាសនាមាំមួនក៏ដោយ ក៏ប្រជាជនប្រទេសនេះពុំអាចនឹងរកបូជាចារ្យឲ្យបានគ្រប់ចំនួន ដើម្បីតែងតាំងគ្រីស្តសាសនា ក្នុងដែនដីដែលពួកគេវាយយកបាននោះឡើយ។ ព្រះមហាក្សត្រត្រូវតែអំពាវនាវ សុំឲ្យក្រុមគ្រួសារបព្វជិត ស្ម័គ្រចិត្តទៅប្រកាសដំណឹងល្អនៅលើទឹកដីទាំងនោះ។ អ្នកបួសទាំងអស់នោះពុំនៅក្រោមការចាត់ចែងរបស់អភិបាលព្រះសហគមន៍ទេ គឺពួកគេនៅក្រោមអំណាចនាយករបស់ក្រុមគ្រួសារគេតែមួយគត់។ លក្ខន្តិកៈនេះ ធ្វើឲ្យអ្នកបួសទាំងនោះ

មានសេរីភាពពេញលេញ មិនបាច់គោរពបញ្ជាអភិបាលព្រះសហគមន៍ ដែលពុំមែនជាជនជាតិព័រទុយហ្គាល់ឡើយ។

ដោយព្រះចៅប្រទេសព័រទុយហ្គាល់ អំពាវនាវរកអ្នកបួសដូច្នេះ ទ្រង់ត្រួតត្រាលើបុគ្គលិកទាំងប៉ុន្មានដែលបានបញ្ជូនទោងដែនដីអាណានិគម។ អ្នកបួសទាំងអស់ដែលចេញទៅទ្វីបអាស៊ី ទោះជាមានសញ្ជាតិណាក៏ដោយ ក៏ត្រូវតែកាត់ទីក្រុងលីសបោន (Lisbonne) ជាដាច់ខាត ដើម្បីឲ្យរាជការប្រទេសព័រទុយហ្គាល់ត្រួតពិនិត្យមើលយ៉ាងតឹងរឹងជាទីបំផុត។ បព្វជិតទាំងនោះ ដូចជាទទួលសញ្ជាតិព័រទុយហ្គាល់នៅក្រុងលីសបោននោះដែរ។ ព្រះមហាក្សត្ររ៉ាប់រងឲ្យបព្វជិតទាំងនោះ ធ្វើដំណើរតាមកប៉ាល់របស់ព្រះអង្គ ហើយទ្រង់ធានាផ្គត់ផ្គង់សោហ៊ុយ ដល់បព្វជិតទាំងអស់នោះថែមទៀតផ្សេងៗផង។ ម្យ៉ាងទៀតព្រះមហាក្សត្រសន្យាថា នឹងចេញប្រាក់សាងវិហារ និងគ្រឹះស្ថានផ្សេងៗសម្រាប់គ្រីស្តសាសនា។ ពេលបព្វជិតទៅដល់ទីក្រុងហ្គោអា (Goa) អស់លោកត្រូវព្រះឧបរាជនៃប្រទេសព័រទុយហ្គាល់ត្រួតពិនិត្យម្តងទៀត មុននឹងបន្តដំណើរទៅកាន់ប្រទេសជប៉ុន ឬប្រទេសចិន។

**ទំនាស់ផ្ទៃក្នុងនៃព្រះសហគមន៍**

ក្នុងសតវត្សទី១៦ ទ្វីបអឺរ៉ុបមានការរីកចម្រើនយ៉ាងខ្លាំង ហើយបានឈ្លានពានលើប្រទេសផ្សេងៗជាច្រើនទៀតផង។ ក្នុងសតវត្សនោះ ទំនាស់ផ្ទៃក្នុងនៃព្រះសហគមន៍បានកើតមានឡើង ហើយគ្រីស្តបរិស័ទបានបែកចេញទៅជាកាតូលិកនិងប្រូតេស្តង់។ គណៈគ្រីស្តសាសនាទាំងពីរនេះ បានប៉ះទង្គិចគ្នា រហូតដល់ទៅច្បាំងគ្នា និងបណ្តាលឲ្យមានគំនុំចងពៀរនឹងគ្នាយ៉ាងស្វិតស្វាញ។ ជាពិសេស ពេលពួកកាតូលិកជាតិអេស្ប៉ាញវាយយកប្រទេសហូឡង់ (Holland) បាន ពួកគេបានធ្វើទុក្ខបុកម្នេញពួកប្រូតេស្តង់ហ៊ុយហ្គឺណូ (Huguenots) ហួសពីការស្មាន។

ពេលនោះ ព្រះសហគមន៍កាតូលិកក៏ភ្ញាក់ស្មារតីដែរ ហើយយកចិត្តទុកដាក់បំបាត់បុព្វហេតុទាំងឡាយ ដែលនាំឲ្យមានចលនាប្រែទម្រង់កើតឡើង និងបណ្តាលឲ្យបែកសាមគ្គីគ្នា។ នៅផ្ទៃក្នុងព្រះសហគមន៍កាតូលិក មានបព្វជិតជាច្រើនខិតខំធ្វើឲ្យសាសនាមានទម្រង់ថ្មី គឺលោកអ៊ីញ៉ាសនៅ ឡូយ៉ូឡា (Ignace de Loyola ១៤៩១-១៥៥៦) បានបង្កើតក្រុមគ្រួសារបព្វជិត "មិត្តសម្លាញ់របស់ព្រះយេស៊ូ" (Jésuites)។ នាងថេរ៉េសា

នៅក្រុងអាវីឡា( Thérèse d'Avila ១៥១៥-១៥៨២ ) និងលោកយ៉ូហានជាអ្នកគោរពព្រះឈើឆ្កាង ( Jean de la Croix ១៥៤២-១៥៩១ ) បានបង្កើតវត្តអារាមជាច្រើន ដែលមានឥទ្ធិពលសាយភាយហួសពីព្រំដែននៃប្រទេសអេស្ប៉ាញទៅទៀត។ អភិបាលព្រះសហគមន៍កាតូលិកទាំងប៉ុន្មាន បានជួបជុំគ្នាជាមហាសន្និបាតសកលនៅក្រុងត្រេនតូ ( Trento ) ប្រទេសអ៊ីតាលី ចាប់ពីឆ្នាំ ១៥៤៥ ដល់ឆ្នាំ ១៥៦៣។ អស់លោកបានបញ្ជាក់ពីគោលសំខាន់ៗនៃគ្រីស្តសាសនា និងចាត់ចែងឲ្យមានវិន័យថ្មី។ អស់លោកបានសម្រេចថា នឹងសរសេរសៀវភៅប្រៀនប្រដៅស្តីអំពីគោលសំខាន់ៗនៃគ្រីស្តសាសនា ព្រមទាំងបង្កើតទេវវិទ្យាល័យ គឺសាលាសម្រាប់អប់រំបូជាចារ្យផង។

ក្នុងសម័យនោះ ពួកបស្ចឹមប្រទេសបានចាប់ផ្តើមទាក់ទងជាមួយប្រទេសកម្ពុជា ជាលើកដំបូងបង្អស់។ ប្រទេសកម្ពុជាស្ថិតនៅឆ្ងាយដាច់ស្រយាលពីផ្លូវគោក ហើយក៏នៅឆ្ងាយដាច់ស្រយាលពីផ្លូវសមុទ្រផងដែរ។ ម្យ៉ាងទៀតក្នុងប្រទេសកម្ពុជាពុំមានគ្រឿងទេសទេ ហើយទំនិញល្អៗដែលមានតម្លៃខ្ពស់ក៏ពុំមានដែរ។ ទោះជាយ៉ាងណាក៏ដោយ ពួកអ្នកដើរសំពៅបានកត់ឈ្មោះប្រទេសកម្ពុជាចូលក្នុងសៀវភៅអឺរ៉ុបតាំងពីឆ្នាំ ១៥១១ ហើយមានកត់នៅក្នុងផែនទីសមុទ្រ និងកំពង់ផែតាំងពីឆ្នាំ ១៥២៧ មកម្ល៉េះ។ គេសរសេរឈ្មោះ ប្រទេសកម្ពុជាថា៖ កាំប៊ូសា។

នៅសម័យនោះ ប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀម ហើយនៅតែមានសង្គ្រាមក្នុងស្រុកឥតឈប់ឈរ។ ក្នុងឆ្នាំ ១៥១៥ ស្តេចខ្មែរព្រះនាមព្រះបាទអង្គច័ន្ទទី១ (១៥១៥-១៥៦៦) បានទាក់ទងជាមួយពួកព័រទុយហ្គាល់ ដែលទើបមកដល់កោះជ្វាថ្មីៗ ដើម្បីទិញកាំភ្លើងធំ ១៥០គ្រឿង និងកាំភ្លើងអាកឺប៊ុយ ២០០០ ដើម។ ដោយមានគ្រឿងសស្ត្រាវុធទាន់សម័យដូច្នេះ ទ្រង់បានវាយឈ្នះស្តេចកន ដែលធ្វើគុតនិងដណ្តើមយករាជ្យបល្ល័ង្គពីព្រះរៀម ព្រះអង្គព្រះនាមព្រះបាទ ស្រីសុគន្ធបទ។ ក្នុងឆ្នាំ ១៥២៥ ទ្រង់បានវាយបង្ក្រាបកងទ័ពសៀមឲ្យបរាជ័យនៅក្នុងតំបន់អង្គរ។ ហេតុដូច្នេះហើយ បានជាទ្រង់ដាក់ឈ្មោះទីនោះថា "*សៀមរាប* " គឺសៀមចាញ់រាបដូចកន្ទេលហ្នឹងឯង។ ព្រះអង្គបានតាំង រាជធានីនៅលង្វែកវិញ ដើម្បីឲ្យបានសន្តិសុខរឹងមាំល្អ។ ក្រុងលង្វែកនេះ ស្ថិតនៅចម្ងាយ ៤០ គ.ម ខាងជើងរដ្ឋធានីភ្នំពេញសព្វថ្ងៃ ។ ព្រះអង្គគោរពព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ហើយទ្រង់បញ្ជាឲ្យសង់វត្តជាច្រើនក្នុងព្រះរាជធានីនោះ។

**លោកកាស្ប៉ាដាគ្រុស** ( Gaspa da Crus )

ក្នុងឆ្នាំ ១៥៥៥ ព្រះបាទអង្គច័ន្ទ ទតឃើញជនបរទេសម្នាក់មកដល់រាជធានីលង្វែក។ ជននោះ មានសម្លៀកបំពាក់ប្រហែលនឹងស្បង់ចីពររបស់ព្រះសង្ឃនៃព្រះពុទ្ធសាសនាដែរ តែប្លែកត្រង់មានពណ៌សប៉ុណ្ណោះ។ ជនជាតិព័រទុយហ្គាល់នោះ ឈ្មោះហ្គាស្ប៉ាដាគ្រុស ( Gaspar da Crus ) ជាបព្វជិតក្រុមគ្រួសារ ដូមីនីកាំង មកពីក្រុងម៉ាឡាកា ហើយបានចុះចតនៅឯផែពាម ( ខេត្តហាទៀងសព្វថ្ងៃ )។ លោកបាន ទទួលការអប់រំពីលោកដូមីនីកដាស៊ូសា( Dominigue Da Souza ) ដែលជាអ្នកជំនិតរបស់លោក អាល់ប៊ូគែក ( Albuguergue ) ជាឧបរាជនៃ "ប្រទេសឥណ្ឌារបស់ព័រទុយហ្គាល់"។ លោកប្រាកដជាបានស្គាល់លោកហ្វ្រង់ស្វ័រសាវីយេ( François Xavier ) ដែលបានចេញពីក្រុងម៉ាឡាកាទៅកាន់ប្រទេសជប៉ុន ក្នុងឆ្នាំ ១៥៤៨។ ប្រហែលព្រះមហាក្សត្រផ្ទាល់ បានអញ្ជើញលោកហ្គាស្ប៉ាដាគ្រុសនេះឲ្យមកប្រទេសកម្ពុជា។ ប្រហែលមានពួកឈ្មួញជាតិព័រទុយហ្គាល់ដែលរស់នៅព្រះរាជធានីលង្វែក បានទូលស្ដេច ឲ្យសុំជំនួយពីប្រទេសព័រទុយហ្គាល់នោះ។ ពួកឈ្មួញទាំងនោះ បានជូនដំណឹងទៅនាយក នៅក្រុងម៉ាឡាកាថា ជនជាតិកម្ពុជាប៉ងប្រាថ្នាចង់ចូលគ្រីស្តសាសនាជាខ្លាំង។ មកដល់មិនទាន់បាន ស្រួលបួលផង លោកហ្គាស្ប៉ាដាគ្រុស ចាប់ផ្ដើមរៀនភាសាខ្មែរ។ តែមិនយូរប៉ុន្មានលោកក៏យល់ថា ជនជាតិខ្មែរពុំមានបំណងចង់ចូលគ្រីស្តសាសនាសោះឡើយ។ លោកនៅក្នុងវាំងលង្វែកបានមួយឆ្នាំ រួចចេញដំណើរទៅប្រទេសចិន។ បន្ទាប់មក លោកត្រឡប់ទៅស្រុកកំណើតរបស់លោកវិញ។

នៅឆ្នាំ ១៥៦៨ ព្រះបាទបរមរាជទី៤ ( ១៥៦៦-១៥៧៦ ) បានបញ្ជូនរាជទូតម្នាក់ទៅក្រុងម៉ាឡាកា ដើម្បីសុំបព្វជិតគ្រីស្តសាសនាម្ដងទៀត។ ការនេះ ជាមធ្យោបាយទាក់ទង ដើម្បីសុំជំនួយយោធាសម្រាប់តទល់នឹងពួកសៀម។ សេចក្ដីសុំនេះ ជាមធ្យោបាយម្យ៉ាងទៀត សម្រាប់ទទួលការអនុគ្រោះ ពីប្រទេសព័រទុយហ្គាល់ ដែលបានចាត់បព្វជិតទៅប្រទេសសៀមក្នុងឆ្នាំ ១៥៦៦។ ដូច្នេះហើយបានជា លោកឡូប៉ូការដូសូ ( Lopo Cardoso ) និងលោកយ៉ូហានម៉ាដឺរ៉ា( Joâo Madeira ) ដែលជាបព្វជិតដូមីនីកាំងព័រទុយហ្គាល់ទាំងពីរនាក់ បានមករស់នៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៥៧៧។ លោកទាំងពីរនេះ បានប្រកាសជំនឿនៃគ្រីស្តសាសនា ចំពោះតែពួកឈ្មួញ និងអ្នកផ្សងព្រេងជាតិ

ព័រទុយហ្គាល់ ដែលស្នាក់អាស្រ័យនៅក្នុងស្រុក ជាពិសេសនៅជិតៗព្រះរាជធានីលង្វែក ប៉ុណ្ណោះ។ ពួកព្រាហ្មណ៍ និងព្រះសង្ឃពុទ្ធសាសនាមិនសូវពេញចិត្ត ចំពោះវត្តមានរបស់បព្វជិតខាងគ្រីស្តសាសនាទាំងនោះទេ ហើយតែងតែប៉ុនប៉ង ហាមឃាត់មិនឲ្យផ្សាយធម៌ និងទេសនាចំពោះជនជាតិខ្មែរផង។

**លោកសីលវ៉េសដាស៊េវ៉េដូ** (Sylvester d'Azevedo)

ក្នុងឆ្នាំ ១៥៧៤ បព្វជិតដូមីនីកាំងសញ្ជាតិព័រទុយហ្គាល់ម្នាក់ឈ្មោះ ស៊ីលវ៉េសដាស៊េវ៉េដូ បានមកដល់ប្រទេសកម្ពុជា។ លោកបានរស់នៅក្នុងប្រទេសខ្មែរអស់រយៈពេល ១៥ ឆ្នាំ។ មកដល់កម្ពុជាមិនបានប៉ុន្មានថ្ងៃផង បព្វជិតនេះក៏កើតរឿង ព្រោះទាសាពីរនាក់ ដែលព្រះមហាក្សត្រខ្មែរប្រគល់ឲ្យលោក នាំទៅជូនលោកនាយកក្រុមបព្វជិត នៅក្រុងម៉ាឡាកា បានរត់រួចបាត់ទៅ។ ព្រះរាជាទ្រង់ព្រះពិរោធ ហើយបញ្ជាឲ្យ ចាប់លោកឃុំឃាំង។ នៅក្នុងគុក លោកយកតម្រាប់តាមគ្រីស្តទូតប៉ូល ហើយបញ្ជាប្រៀនប្រដៅអ្នកទោសបរទេសប្រាំរយនាក់ នាំចូលក្នុងគ្រីស្តសាសនា គឺមានទាំងជនជាតិជប៉ុន ជ្វា និងចិន(២) ។

ក្នុងឆ្នាំ ១៥៧៨ ព្រះបាទសត្ថាគ្រង់រាជ្យបន្តមកទៀត ព្រោះព្រះរាជបុត្រព្រះអង្គនៅមានវ័យក្មេងនៅឡើយ។ ទ្រង់បានដោះលែងបព្វជិតនោះចេញពីគុក ដោយទ្រង់ខ្លាចពួកព័រទុយហ្គាល់នៅក្រុងម៉ាឡាកាសងសឹក។ ព្រះរាជាទ្រង់ឈ្វេងយល់ទៀតថា ទ្រង់មុខជានឹងបានជំនួយយោធាដែលទ្រង់ត្រូវការជាចាំបាច់ ដើម្បីតទល់នឹងប្រទេសសៀម។ កាលរួចខ្លួនពីគុកមក លោកដាសេវ៉េដូ ត្រូវព្រះមហាក្សត្រគោរពយ៉ាងខ្លាំង ព្រះរាជាហៅលោកថា "ប៉ៃ" (៣)។ លោកមានសិទ្ធិអង្គុយនៅចំពោះមុខព្រះរាជា ហើយមានសិទ្ធិពាក់មួកធំ ជាសញ្ញាបង្ហាញឋានន្តរសក្តិខ្ពង់ខ្ពស់ថែមទៀតផង។ លោកឆ្លៀតឱកាសនោះសុំអនុញ្ញាតពីព្រះរាជា ដើម្បីសង់ព្រះវិហារមួយ។ ព្រះមហាក្សត្រអនុញ្ញាតឲ្យ តែទ្រង់មិនព្រមឲ្យលោកធ្វើបុណ្យជ្រមុជទឹកជូនជនជាតិខ្មែរ ដែលចង់ចូលគ្រីស្តសាសនាជាដាច់ខាត។ ពេលនោះ អ្នកដឹកនាំក្រុមគ្រួសារបព្វជិតដូមីនីកាំង នៅក្រុងម៉ាឡាកាស្មានថា លោកបានបោះបង់ចោលមុខងារជាបូជាចារ្យហើយ ត្រឡប់ទៅធ្វើជានាម៉ឺនខ្មែរមួយរូបវិញ។ អ្នកដឹកនាំក្រុមគ្រួសារបព្វជិត បានគំរាមដេញលោកចេញពីគ្រីស្តសាសនាថែមទៀតផង។

តែក្នុងឆ្នាំ ១៥៨៥ លោកអភិបាលព្រះសហគមន៍ក្រុងម៉ាឡាកា បានចាត់បព្វជិតមួយចំនួនទៀត ឲ្យមកជួយលោកដាសេរ៉េដូ។ ក្នុងចំណោមបព្វជិតទាំងនោះ មានបព្វជិតដូមីនីកាំងពីរនាក់គឺលោកដ័រតា(Dorta) និងលោកកាលដឺរ៉ា(Caldeira) ព្រមទាំងបព្វជិតហ្វ្រង់ស៊ីស្កាំងបួន ឬប្រាំនាក់ទៀត ដែលយើងពុំស្គាល់ឈ្មោះ។ ព្រះរាជាបានទទួលលោកទាំងនោះយ៉ាងរាក់ទាក់ ហើយអនុញ្ញាតឲ្យផ្សាយគ្រីស្តសាសនាដោយសេរី។ ព្រះអង្គក៏អនុញ្ញាតឲ្យអស់លោកមានសិទ្ធិជជែកជាមួយព្រះសង្ឃ ពីបញ្ហាសាសនាជាសាធារណៈផងដែរ។ ប៉ុន្តែ ព្រះមហាក្សត្របានទូន្មានលោកទាំងនោះ ឲ្យផ្សាយសាសនារបស់អស់លោកដោយស្ងាត់ៗ ខ្លាចក្រែងប្រជាជនបះបោរប្រឆាំងនឹងសាសនាថ្មី។ នៅពេលនោះ ក្សត្រដែនយ៉ូហ៊រ(Juhore)[៤] ដែលកំពុងច្បាំងនឹងពួកព័រទុយហ្គាល់ បានចាត់ទូតមកគាល់ព្រះមហាក្សត្រខ្មែរ សូមឲ្យព្រះអង្គប្រុងប្រយ័ត្ន ចំពោះក្រុមបព្វជិតទាំងនោះដោយចោទថា អស់លោកប៉ុនប៉ងវាតទីលើព្រះរាជាណាចក្រ ដើម្បីជាប្រយោជន៍ដល់ប្រទេសព័រទុយហ្គាល់។ ដោយព្រះរាជាជឿតាមពាក្យទូតនោះ ទ្រង់ខ្វាល់ និងបានចេញរាជបញ្ជាឲ្យចាប់បព្វជិតទាំងអស់ឃុំឃាំង។ ក្រោយមក ព្រះអង្គបានដេញបព្វជិតទាំងនោះចេញពីប្រទេស លើកលែងតែលោកដាស៊េរ៉េដូ ដែលជាមិត្តរបស់ព្រះអង្គចេញ។ តែនៅឆ្នាំ ១៥៩០ ព្រះបាទសត្ថាបានទទួលស្គាល់ថា ទូតបានចោទអ្នកបួសទាំងនោះដោយផ្តេសផ្តាស ហើយទ្រង់បានចេញប្រកាសឲ្យប្រជាពលរដ្ឋគ្រប់រូប ទោះបីមានវណ្ណៈឬឋានៈយ៉ាងណាក៏ដោយ ក៏មានសិទ្ធសេរីភាពអាចកាន់សាសនាណាក៏បាន ហើយជនជាតិខ្មែរក៏មានសិទ្ធិទទួលបុណ្យជ្រមុជទឹកដែរ។

លោកដាសេរ៉េដូ សំអាងទៅលើសេរីភាពថ្មីនេះ បានសុំលោកអភិបាលព្រះសហគមន៍នៅក្រុងម៉ាឡាកា ឲ្យចាត់បព្វជិតឯទៀតៗមក។ លោកអភិបាលក៏បានចាត់បព្វជិតគណៈដូមីនីកាំងពីររូបមក គឺលោកលុយដាហ្វុងសេកា(Luis da Fonseca) និងលោកយ៉រកូដាមូតា(Jorgo da Mota)។ លោកទាំងពីរបានមកដល់ប្រទេសកម្ពុជា នៅឆ្នាំ ១៥៩១ រួមជាមួយនឹងសហការីទាំងពីរនោះ លោកដាស៊េរ៉េដូ បានតែងសៀវភៅតូចមួយគឺជាសៀវភៅទីមួយ ដែលពន្យល់អំពីគ្រីស្តសាសនាឲ្យប្រជារាស្ត្រខ្មែរស្គាល់។

**ព្រះសហគមន៍នៅសម័យប្រទេសអេស្ប៉ាញនិងប្រទេសព័រទុយហ្គាល់គ្រប់គ្រង**

នៅឆ្នាំ ១៥៨០ ប្រទេសព័រទុយហ្គាល់បានរួមចូលជាមួយប្រទេសអេស្ប៉ាញ ធ្វើជារាជា

ណាចក្រតែមួយ។ តាំងពីពេលនោះមក ព្រះមហាក្សត្រទាំងឡាយនៅទ្វីបអាស៊ីក៏ទាក់ទង ជាមួយព្រះរាជប្រតិភូអេស្ប៉ាញ ដែលនៅក្រុងម៉ានីល(Manille) នាប្រទេសហ្វីលីពីន។ គ្រានោះ កងទ័ពដែលចេញទៅច្បាំង ព្រមទាំងពួកបព្វជិតក៏ចេញពីក្រុងនេះដែរ(៥) ។ ក្នុងអំឡុងឆ្នាំ ១៥៨០-១៥៨១ អ្នកផ្សងព្រេងជាតិព័រទុយហ្កាល់ម្នាក់ ឈ្មោះឌីយេកូវេឡូសូ (Diégo Veloso) អាយុ ២០ឆ្នាំ បានមកដល់ប្រទេសកម្ពុជា ដោយមានទាហានមួយចំនួន តូចអមដំណើរផង។ គាត់រៀនភាសាខ្មែរ ហើយព្រះរាជាទុកចិត្ត និតស្រឡាញ់គាត់ រហូត ដល់លើកប្អូនស្រីជីដូនមួយឲ្យធ្វើជាភរិយា។ ឆ្នាំ ១៥៩៣ អ្នកផ្សងព្រេងម្នាក់ទៀត ជាតិ អេស្ប៉ាញមាននាមថាប្លាសរីសដឺហ៊ែរណាន់ហ្គុងសាលេស(Blas Ruiz de Hernan Gonzales) បានមករស់នៅក្នុងប្រទេសកម្ពុជាដែរ។ ព្រះរាជាក៏បានយកគាត់ធ្វើជាអង្គរក្ស។

ថ្ងៃទី ២០ កក្កដា ១៥៩៣ ព្រះបាទសត្ថាបានចាត់លោកវេឡូសូទៅក្រុងម៉ានីល សុំ ឲ្យមានបព្វជិតកាតូលិកខ្លះ មកផ្សព្វផ្សាយគ្រីស្តសាសនា នៅក្នុងព្រះរាជាណាចក្រ របស់ព្រះអង្គ ព្រមទាំងសុំទាហានជាច្រើនឲ្យមកការពារលោកទាំងនោះផង។ ទ្រង់ក៏ បានសុំឲ្យប្រទេសអេស្ប៉ាញចេញទៅច្បាំង វាយយកនគរចម្ប៉ាផងដែរ ព្រោះប្រទេស នេះចេះតែវាយលុកលុយប្រទេសខ្មែរ។ ទ្រង់សុំឲ្យកងទ័ពអេស្ប៉ាញមកជួយព្រះអង្គ ដែលកំពុងច្បាំងនឹងកងទ័ពសៀមថែមទៀតផង។ ប្រសិនបើប្រទេសអេស្ប៉ាញមកជួយព្រះ អង្គមែន ព្រះរាជានឹងអនុគ្រោះចំពោះគ្រីស្តបរិស័ទ ហើយប្រហែលជាទ្រង់សព្វព្រះហឫទ័យ ចូលគ្រីស្តសាសនាផងដែរ។ តាមពិតព្រះរាជាមានព្រះទ័យព្រួយបារម្ភជាខ្លាំង ចំពោះ ជោគវាសនានៃរាជាណាចក្រខ្មែរ។ ក្នុងសម័យនោះ ជំងឺអាសន្នរោគរាតត្បាតពាសពេញ ប្រទេសកម្ពុជា ហើយមានទុរ្ភិក្សថែមទៀតផង។ ព្រះចៅប្រទេសសៀម ព្រះនាម ព្រះបាទណារ៉េត បានឆ្លៀតឱកាសនោះកេនទាហានចំនួនមួយសែននាក់ ដំរីប្រាំបីរយក្បាល សេះមួយពាន់ប្រាំរយក្បាល ចូលលុកលុយប្រទេសកម្ពុជា។ ព្រះបាទសត្ថាបានកេនប្រមូល កងទ័ពខ្មែរជាបន្ទាន់ ហើយច្បាំងទប់ទល់នឹងកងទ័ពសៀមវិញ តែទ្រង់ទទួលបរាជ័យ នៅគ្រប់សមរភូមិទាំងអស់។ ក្នុងខែមករាឆ្នាំ ១៥៩៤ កងទ័ពសៀមវាយយកបន្ទាយ លង្វែកបាន។ ពួកសៀមបានដុតបំផ្លាញឯកសារខ្មែរចោល គឺដុតបំផ្លាញ ក្បួនគម្ពីរ ពុទ្ធសាសនានិងក្រមច្បាប់ផ្សេងៗ។ គេកម្ទេចព្រះរាជវាំង និងវត្តអារាមចោល ប្លន់យក ព្រះពុទ្ធប្បដិមាធ្វើអំពីកែវមរកត និងរូបព្រះគោ ដែលជាវត្ថុស័ក្តិសិទ្ធិ ការពារព្រះរាជា ណាចក្រខ្មែរ យកទៅក្រុងអយុធ្យាទាំងអស់។ ពួកសៀមធ្វើដូចនេះ ដោយមានបំណង

បំបាត់ចោលកិត្តិនាមដ៏រុងរឿងរបស់ខ្មែរ ដែលមានតាំងពីបុរាណកាលមកនោះ(៦) ។

ព្រះបាទសត្ថា ព្រមទាំងព្រះរាជបុត្រ បានរត់ភៀសព្រះអង្គទៅគង់នៅស្រុកស្រីសន្ធរ តាំងពី មុនកងទ័ពសៀមឡោមព័ទ្ធព្រះរាជធានី។ នៅពេលវាយកម្ទេចបន្ទាយលង្វែក ពួកសៀមបានចាប់អ្នកដែលសល់រួចពីស្លាប់ ធ្វើជាឈ្លើយសង្គ្រាម នាំយកទៅក្រុងអយុធ្យា ជារាជធានីរបស់ពួកគេ។ នៅក្នុងចំណោមពួកឈ្លើយសង្គ្រាមទាំងនោះ មានលោកប្លាសរីស មានគ្រីស្តបរិស័ទមួយចំនួនធំ ព្រមទាំងមានលោកដាស៊េវេដូ លោក ដាហ្វុងសេកា និងលោកដាម៉ូតាផង(៧) ។

លោកវេឡូសូ ត្រឡប់មកពីទីក្រុងម៉ានីលវិញ ទាំងនាំចម្លើយរបស់ព្រះរាជប្រតិភូអេស្ប៉ាញថា សូមឲ្យព្រះបាទសត្ថារង់ចាំសិន។ ពួកសៀមក៏ចាប់គាត់ធ្វើជាឈ្លើយដែរ ប៉ុន្តែគាត់បែរទៅបម្រើព្រះចៅសៀមវិញ។ ព្រះចៅសៀមក៏បានចាត់គាត់ឲ្យនាំព្រះរាជសាររបស់ព្រះអង្គ ទៅជូនអាជ្ញាធរអេស្ប៉ាញនៅប្រទេសហ្វីលីពីន។ ចំណែកឯលោកប្លាសរីសវិញ គាត់បានរត់រួចក្នុងពេលធ្វើដំណើរទៅកាន់ក្រុងអយុធ្យា ហើយត្រឡប់ទៅក្រុងម៉ានីលវិញ។ នៅទីនោះ គាត់បានជួបនឹងលោកវេឡូសូ។ លោកទាំងពីរនាក់ បានអង្វរព្រះរាជប្រតិភូអេស្ប៉ាញ នៅប្រទេសហ្វីលីពីន ឲ្យមកជួយប្រទេសកម្ពុជាវិញ។ ពួកអេស្ប៉ាញបានលើកទ័ពមកជួយ តាមពាក្យអង្វររបស់លោកទាំងពីរ គឺមានកប៉ាល់បី និងទាហានជាងមួយរយនាក់ ព្រមទាំងមានបព្វជិតដូមីនីកាំងពីរនាក់ គឺលោកអាឡុងសូជីមេណេស(Alonso Jimenez) និងលោក ឌីយេកូអាឌូអាតេ(Diego Aduarte)។ តែខ្យល់ព្យុះធ្វើឲ្យនាវាទាំងនោះបែកគ្នា។ ទោះជាយ៉ាងណាក៏ដោយ ក៏លោកវេឡូសូ លោកប្លាសរីសនិងបព្វជិតដូមីនីកាំងទាំងពីរនាក់ បានមកដល់ប្រទេសកម្ពុជាដែរ។ ពេលនោះ លោកទាំងនោះទទួលដំណឹងថា ព្រះបាទសត្ថាសោយទិវង្គតទៅហើយ ហើយមានឈ្មោះជើងព្រៃកំពុងតែដណ្តើមរាជ្យ។ អស់លោកបានវាយលុកចូលរាជវាំងស្រីសន្ធរ។ លោកយ៉ឹមមេណេបន់ស្រន់ ឯលោកអាឌូអាតេបាន ចូលប្រឡូកក្នុងចម្បាំងយ៉ាងសកម្ម។ ឈ្មោះជើងព្រៃក៏ត្រូវគេសម្លាប់។ ពេលនោះ មេទ័ពអេស្ប៉ាញខឹងយ៉ាងខ្លាំង ហើយនាំទាំងទាហាន ទាំងបព្វជិតត្រឡប់ទៅក្រុងម៉ានីលវិញ។

ព្រះបាទបរមរាជទី៦ (១៥៨៦-១៥៩៩) បានឡើងសោយរាជ្យនៅប្រទេសកម្ពុជា។ ទ្រង់ជាព្រះរាជបុត្រមួយអង្គ ក្នុងចំណោមព្រះរាជបុត្រទាំងបួនរបស់ព្រះបាទសត្ថា។ ទ្រង់

បានអំពាវនាវ ចំពោះក្រុមគ្រួសារបព្វជិតទាំងឡាយ នៅឯក្រុងម៉ាឡាកា និងក្រុងហ្គោអា ឲ្យមកនៅប្រទេសកម្ពុជា។ តាមពិត ព្រះអង្គសុំឲ្យបព្វជិតកាតូលិកមករស់នៅក្នុងព្រះរាជាណាចក្រ ដើម្បីឲ្យបានជំនួយយោធាជាថ្មីម្តងទៀត។ ទ្រង់មានបន្ទូលសន្យាថា នឹងប្រោសប្រទានសេរីភាពពេញលេញឲ្យគ្រីស្តបរិស័ទ៖

*«ព្រះបាទបរមរាជា ជាក្សត្រធិបតីនៃនគរកម្ពុជា សូមជម្រាបមកក្រុមគ្រួសារបព្វជិតហ្វ្រង់ស៊ីស្កាំងនៅក្រុងម៉ាឡាកា សូមជ្រាប!*

*ឥឡូវនេះ យើងសុំឲ្យក្រុមបព្វជិតមកទាក់ទងនឹងយើង។ សូមបព្វជិតទាំងនោះអង្វរព្រះជាម្ចាស់ឲ្យជួយថែរក្សារាជាណាចក្រនេះ ដូចអស់លោកធ្លាប់បានធ្វើកាលពីមុន គឺកាលព្រះមហាក្សត្រ ដែលជាបិតារបស់យើង និងជាម្ចាស់ជីវិតលើត្បូងនៅគ្រងរាជ្យនៅឡើយនោះ។ សូមអស់លោក ចាត់បព្វជិតមកឲ្យយើង ព្រោះថា បព្វជិតនៃក្រុមគ្រួសារនេះហើយ ដែលបានមកប្រៀនប្រដៅសាសនានេះក្នុងរាជាណាចក្ររបស់យើង មុនគេបង្អស់។ កាលយើងនៅជារាជកុមារនៅឡើយ យើងបានទាក់ទងជាមួយបព្វជិតទាំងនោះ ហើយយើងស្រឡាញ់អស់លោកជាខ្លាំង។ ដូច្នេះ គ្រីស្តសាសនា មានសិទ្ធិពេញលេញនៅក្នុងរាជាណាចក្រយើងនេះ។ យើងបានចេះដឹង ដោយយើងបានទទួលការអប់រំ ប្រៀនប្រដៅពីសំណាក់បព្វជិតទាំងនោះ។ យើងទទូចអំពាវនាវ សុំឲ្យអស់លោកទាំងនោះមកក៏ដូចអស់លោក មានកាតព្វកិច្ចនឹងមកមើលកិច្ចការរបស់អស់លោក នៅក្នុងនគរនេះដែរ។ យើងសន្យាថា នឹងសង់វិហារដ៏ល្អឆ្អិនឆ្អៅជូន ហើយនឹងផ្តល់ជូនដល់អស់លោកនូវអ្វីៗទាំងអស់ ដែលអស់លោកចង់បាន។ យើងសុំឲ្យអស់លោកអញ្ជើញមកកុំខាន ដើម្បីលើកទឹកចិត្តគ្រីស្តបរិស័ទនៅទីនេះ ហើយដែលបានទទូចសុំយើង ឲ្យហៅលោកទាំងនោះមក[៨] ។*

លោកអភិបាលព្រះសហគមន៍ក្រុងម៉ាឡាកាឆ្លើយតបវិញ ដោយចាត់បព្វជិត ហ្វ្រង់ស៊ីស្កាំងម្នាក់មក គឺលោកសិលាគុស្តូឌីយ៉ូ(Pedro Custodio)។ តែលោកត្រូវចោរសម្លាប់ក្រោយពេលមកដល់ប្រទេសកម្ពុជាបី បួនខែប៉ុណ្ណោះ។ ឆ្នាំ១៥៩៧ ឬ ១៥៩៨ បព្វជិតហ្វ្រង់ស៊ីស្កាំងពីរនាក់ទៀត គឺលោកសិលា អ័រទីសកាបីសាស(Pedro Ortiz Cabezas) និងលោកសិលាឌឺឡូសសង់តូស(Pedro de Los Santos) បានតាំងទីលំនៅនៅស្រីសន្ធរជិតព្រះរាជវាំង។

ឆ្នាំ ១៥៩៨ ដដែលនេះ ព្រះរាជប្រតិភូអេស្ប៉ាញ នៅក្រុងម៉ានីលបានរៀបចំកប៉ាល់ចម្បាំងបីគ្រឿង ដោយមានទាហានអេស្ប៉ាញចំនួន ២០០នាក់ និងមានបព្វជិតដូមីនីកាំងពីរនាក់ គឺលោកយ៉ីមមេណេស និងលោកអាឌូអាតេ ព្រមទាំងបព្វជិត ហ្វ្រង់ស៊ីស្កាំង គឺលោកយូហានបូទីស្តា(Juan Bautista) និងលោកឌីយេហ្គោ ដេសន្តតាម៉ារីយ៉ា(Diego de Santa Maria) ធ្វើដំណើរមកជាមួយផង។ ជាថ្មីម្តងទៀត ព្យុះសង្ឃរាបានធ្វើឲ្យកប៉ាល់ពីរគ្រឿងលិច។ មានតែកប៉ាល់ដែលបព្វជិត ហ្វ្រង់ស៊ីស្កាំងជិះប៉ុណ្ណោះទេ ដែលបានមកដល់ប្រទេសខ្មែរ។ ក្រោយនោះបន្តិច កប៉ាល់អេស្ប៉ាញមួយគ្រឿងដែលបើកទៅប្រទេសសៀម បានដាក់បព្វជិត ដូមីនីកាំងពីររូប គឺលោកយ៉ូហានម៉ាល់ដូណាដូ(Juan Maldondo) និងលោក សិលាឡាបាស្ទីដា(Pedro Labastida) ចុះនៅប្រទេសកម្ពុជា។

ពួកអេស្ប៉ាញ ចាត់លោកវេឡូសូ លោកប្លាសរឺស និងលោកម៉ាល់ដូណាដូជាតំណាង និងជាទូតរបស់ពួកគេប្រចាំប្រទេសខ្មែរ។ ឆ្នាំ ១៥៩៩ ពេលលោកទាំងនោះកំពុងចរចាជាមួយព្រះបាទបរមរាជា ដើម្បីដាក់ប្រទេសកម្ពុជា នៅក្រោមអាណាព្យាបាលនៃប្រទេសអេស្ប៉ាញ ពួកចិន ពួកអេស្ប៉ាញ ពួកជប៉ុន និងពួកម៉ាឡាយូ ដែលរស់នៅក្រុងភ្នំពេញបានឈ្លោះទាស់ទែងគ្នាយ៉ាងខ្លាំង។ ជម្លោះនេះ បានទៅជាចម្បាំងប្រឈមមុខ។ លោកវេឡូសូ លោកប្លាសរឺស លោកឡាបាស្ទីដា និងលោកអ័រទីស ត្រូវគេសម្លាប់ចោល ហើយពួកអេស្ប៉ាញ និងពួកព័រទុយហ្កាល់មួយភាគធំក៏ត្រូវគេសម្លាប់រង្គាលដែរ។ លោកម៉ាល់ដូណាដូ បានរួចផុតពីក្តីមរណៈ ដោយហែលទឹកទៅនាវាអេស្ប៉ាញមួយគ្រឿងដែលចតកណ្តាលទន្លេ។

នៅឆ្នាំ ១៦០២ ព្រះអង្គម្ចាស់ញ៉ុម ជាព្រះរាជបុត្រទី៣ របស់ព្រះបាទសត្ថា ឡើងគ្រប់គ្រងប្រទេសកម្ពុជា។ ព្រះអង្គបានផ្ញើព្រះរាជាសារមួយ ទៅលោកនាយកក្រុមគ្រួសារបព្វជិតហ្វ្រង់ស៊ីស្កាំង តាមរយៈលោកយ៉ាកូមដាកុងសេសាវ(Jacome da Conceiçao) ដែលទើបមកដល់ប្រទេសកម្ពុជា។ ក្នុងព្រះរាជសារនេះ ព្រះរាជាសន្យាថា នឹងផ្តល់សេរីភាពពេញលេញឲ្យផ្សាយគ្រីស្តសាសនា ដូចដែលព្រះបិតាទ្រង់បានសន្យាមកហើយដែរនោះ(៩)។ នៅឆ្នាំ ១៦០៣ លោកអភិបាលព្រះសហគមន៍ប្រចាំក្រុងម៉ានីល បានចាត់បព្វជិតដូមីនីកាំងអេស្ប៉ាញបីនាក់មក គឺលោក អ៊ីនីហ្គោដឺសន្ត ម៉ារីយ៉ា(Inigo de Santa Maria) លោកយេរ៉ូមដេបេឡឹម(Jérôme de Belem) និងលោកអាឡុងសូកុលឡារ

(Alonso Collar)។ ព្រះរាជាទទួលបព្វជិតទាំងនោះយ៉ាងរាក់ទាក់ ហើយអស់លោកមានសេរីភាពពេញលេញ ក្នុងការផ្សាយគ្រីស្តសាសនា និងសាងវិហារបាន។ លោកដេសន្តម៉ារីយ៉ាសុខចិត្តនាំយកព្រះរាជសារមួយទៀត ស្នើសុំឲ្យចាត់សាសទូត និងទាហានមកថែមទៀត។ ក៏ប៉ុន្តែ លោកទទួលមរណភាពក្នុងពេលធ្វើដំណើរទៅក្រុងម៉ានីលនោះទៅ។ ចំណែកឯលោកអាឡុងសូកុលឡារ បន្ទាប់ពីបានប្រយុទ្ធតទល់ជាមួយក្រុមចោរប្លន់ជាតិចិនមក លោកហត់អស់កម្លាំងខ្លាំងពេក ក៏ទទួលមរណភាពកាលដែរ។ លោកដេបេឡឹមនៅម្នាក់ឯង និងអស់សង្ឃឹម ចំពោះអាកប្បកិរិយារបស់ព្រះបាទសុរិយោពណ៌ ជាព្រះមហាក្សត្រថ្មី (១៦០៣-១៦១៨) លោកក៏ធ្វើដំណើរត្រឡប់ទៅកាន់ក្រុងម៉ានីលវិញទៅ។

នាដើមសតវត្សទី១៧ ទោះបី បព្វជិតបានខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏នៅប្រទេសកម្ពុជា មានតែព្រះសហគមន៍ដ៏តូចមួយប៉ុណ្ណោះ។ នៅក្នុងព្រះសហគមន៍នោះគ្រីស្តបរិស័ទភាគច្រើនមានសញ្ជាតិជាព័រទុយហ្គាល់ ហើយគេច្រើនរស់នៅជិតរាជធានីលង្វែក។

(១).លោកណេស្តូរីយុស ជាអភិបាលព្រះសហគមន៍ក្រុងកុងស្តង់ទីណូប (Constantinople) ក្នុងឆ្នាំ ៤២៨។ លោកណេស្តូរីយុស តែងប្រៀនប្រដៅថា ព្រះយេស៊ូជាមនុស្សអស្ចារ្យមួយរូប តែពុំមែនជាព្រះបុត្រារបស់ព្រះជាម្ចាស់ទេ។ នៅឆ្នាំ ៤៣១ មហាសន្និបាតសកល នៅក្រុងអេភេសូ (Ephèse) បានហាមផ្តាច់មិនឲ្យគ្រីស្តបរិស័ទជឿតាមទ្រឹស្តីនេះទេ។

(២).ពេលលោកជាសេរ៉េដូជាប់ក្នុងទីឃុំឃាំង ចោរបានលួចប្លន់គ្រឿងសម្រាប់ថ្វាយអភិបូជាអស់។ កាលចេញពីគុក លោកបានទៅរស់នៅក្នុងផ្ទះមួយនៅក្នុងទីក្រុង ហើយលោករស់នៅដូចជាលោកសង្ឃខាងពុទ្ធសាសនា។ ភិក្ខុសង្ឃទាំងពួងចាប់អារម្មណ៍នឹងរបៀបលោករស់នៅ ហើយក៏តែងតែមកជួបលោក។ ក្នុងចំណោមព្រះសង្ឃទាំងនោះ មានព្រះសង្ឃមួយអង្គ បានសុំលោកទទួលបុណ្យជ្រមុជទឹក។ តែរឿងនេះបានលេចឡើងរន្ទឺឡើង ហើយព្រះភិក្ខុដែលបានចូលគ្រីស្តសាសនានោះ ត្រូវគេយកទៅប្រហារជីវិត។

បើរឿងនេះជារឿងពិត លោកសង្ឃនោះ នឹងមានឈ្មោះថា "មរណសាក្សី" ខ្មែរទី១។

(៣) ក្នុងភាសាព័រទុយហ្គាល់ "ប៉ៃ" គឺឪពុក។

(៤) គឺព្រះរាជាណាចក្រដ៏តូចមួយស្ថិតនៅខាងត្បូងជ្រោយម៉ាឡាយូជិតក្រុងម៉ាឡាកា។

(៥) មិនសូវមានឯកសារស្តីអំពីប្រវត្តិសាសនាកាតូលិក ក្នុងសម័យនេះទេ។ ឯកសារទាំងនោះច្រើនតែជាសំបុត្រ ដែលបព្វជិតព័រទុយហ្គាល់ឬអេស្ប៉ាញ បានសរសេរទៅស្រុកកំណើត។

ម្យ៉ាងទៀត អ្នកស្រាវជ្រាវមិនសូវទុកចិត្តលើឯកសារទាំងនោះឡើយ ព្រោះសំបុត្រទាំងនោះច្រើនតែខំលើកតម្កើងគ្រីស្តសាសនា និងបព្វជិតជាងនិយាយរៀបរាប់ពីព្រឹត្តិការណ៍ ដែលកើតមានឡើងក្នុងសម័យនោះ។ ដោយពិនិត្យមើលឯកសារទាំងនោះ យ៉ាងហោចណាស់ក៏យើងរកភស្តុតាងថា មានបព្វជិតមួយចំនួនបានស្នាក់អាស្រ័យនៅក្នុងប្រទេសកម្ពុជាពិតមែន តែយើងមិនបានដឹងច្បាស់អំពីកិច្ចការដែលអស់លោកបានប្រព្រឹត្តិទេ។ យើងក៏មិនសូវស្គាល់ពីជីវភាពរបស់ព្រះសហគមន៍ដែរ។

(៦) តាមការចងចាំរបស់ខ្មែរ ក្រុងលង្វែកមានដាំឫស្សីបន្លាដ៏ក្រាស់ព័ទ្ធជុំវិញ ចូលពុំចុះទេ។ ពួកសៀមបានឡោមព័ទ្ធក្រុងនោះ អស់រយៈពេលដ៏យូរ តែពុំអាចយកជ័យជំនះបាន។ ពួកសៀមបានប្រើឧបាយកលមួយ គឺបានបាញ់ប្រាក់ខ្លួងចូលទៅក្នុងរបងឫស្សីនោះ។ ទាហានខ្មែរបានកាប់ឆ្ការរបងឫស្សី ដើម្បីរើសយកប្រាក់នោះជាហេតុបណ្តាលឲ្យពួកសៀមអាចវាយចូលបាន។

(៧) ឆ្នាំ ១៥៩៦ បព្វជិតទាំងបីនាក់រួចខ្លួនពីទីឃុំឃាំង។ បន្ទាប់មកលោកដាហ្មុងសេកា និងលោកដាម៉ូតាបានទៅរស់នៅអយុធ្យាជារាជធានីនៃប្រទេសសៀម។ ចំណែកលោកដាស៊េរ៉េដូវិញ លោកបានត្រឡប់មកកម្ពុជាតែម្នាក់ឯង ហើយក្នុងពេលបន្តិចក្រោយមក លោកក៏ទទួលមរណភាពនៅទីនោះទៅ។

(៨) ដកស្រង់ពីរាជសារទី១។ មានតែសំបុត្រផ្ញើទៅបព្វជិត ហ្វ្រង់ស៊ីស្កាំងប៉ុណ្ណោះ ដែលគេរក្សាទុក។ សារទី២ មានលក្ខណៈដូចជាសន្ធិសញ្ញាដ៏តូចមួយ មានសេចក្តីជាអាទិ៍ដូចតទៅៈ

*«មាត្រាទី១: យើងយល់ព្រមប្រគល់សិទ្ធិពេញលេញ ជូនចំពោះបព្វជិតហ្វ្រង់ស៊ីស្កាំង ឲ្យលោកទាំងនោះ អាចធ្វើបុណ្យជ្រមុជទឹក ជូនប្រជារាស្ត្រនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីថ្ងៃនេះតទៅ(...) ទោះបីជាអ្នកនោះមានសញ្ជាតិ មានលក្ខខណៈ ឬមានឋានៈយ៉ាងណាក៏ដោយ។ ពេលចូលគ្រីស្តសាសនា អ្នកទាំងអស់នោះគ្មានបាត់បង់សិទ្ធិសេរីភាព ឬក៏បាត់បង់នូវមុខតំណែង ដែលគេបានកាន់កាប់ពីមុនៗឡើយ។*

*មាត្រាទី២: យើងយល់ព្រមជូនអស់លោកបព្វជិតទាំងនោះ នូវអំណាចពេញលេញទៅលើគ្រីស្តបរិស័ទទាំងឡាយ គឺទៅលើគ្រីស្តបរិស័ទរួចមកហើយ ក៏ដូចទៅលើអ្នកដែលនឹងទៅជាគ្រីស្តបរិស័ទនៅពេលក្រោយ ទោះបី អ្នកទាំងនោះជាបរិសាររបស់យើងក្តី ឬក៏ជារាជវាំងក្តី។*

*មាត្រាទី៣: ចំពោះគ្រប់ទាសាទាសីដែលចង់ចូលគ្រីស្តសាសនា យើងចេញបញ្ជាឲ្យម្ចាស់ទាសាទាសីនោះថាៈ គេគ្មានសិទ្ធិឃាត់ឃាំង មិនឲ្យទាសាទាសីចូលគ្រីស្តសាសនានេះបានឡើយ។ ប្រសិនបើម្ចាស់នោះឃាត់ឃាំងទាសាទាសីមិនឲ្យចូល យើងត្រូវតែយកទាសាទាសីនោះ ដោយចេញថ្លៃលោះឲ្យគាត់តាមដែលលោកបូជាចារ្យ ឬមន្ត្រីម្នាក់កម្រិតឲ្យ។ បើប្រសិនជាម្ចាស់អនុញ្ញាតឲ្យទាសាទាសី ដែលចូលគ្រីស្តសាសនាហើយ នៅបម្រើខ្លួនតទៅទៀតនោះ ម្ចាស់ត្រូវ*

តែផ្តល់សេរីភាពពេញលេញឲ្យទាសាទាសីនោះ អាចបំពេញកាតកិច្ចរបស់ខ្លួនជាគ្រីស្ត
បរិស័ទ ហើយនិងឲ្យទៅវិហារក្នុងថ្ងៃបុណ្យទាំងឡាយ។
មាត្រាទី៤: យើងបញ្ជាព្រះរាជវង្សានុវង្សទាំងអស់ និងនាម៉ឺនសព្វមុខមន្ត្រីនៃព្រះរាជាណាចក្ររបស់
យើង ព្រមទាំងក្រុមប្រឹក្សារបស់យើង ឲ្យគោរពអស់លោកបព្វជិតហ្វ្រង់ស៊ីស្កាំងទាំងនោះ
ដូចអស់លោកតែងគោរពសង្ឃរាជរបស់យើងនោះដែរ។
មាត្រាទី៥: យើងសន្យាថា ពេលចប់សង្គ្រាម យើងនឹងសាងព្រះវិហារដ៏ល្អប្រណិត ជូនលោក
បព្វជិតទាំងអស់។
មាត្រាទី៦: យើងសន្យាថែមទៀតថា នឹងផ្តល់ជូនលោកបព្វជិតទាំងនោះ នូវអង្ករ អំបិល ទៀន
និងអ្នកបម្រើ ។
មាត្រាទី៧: យើងធានាចំពោះអស់លោកបព្វជិតទាំងអស់ថា អាជ្ញាធរមានសមត្ថកិច្ចគ្មានសិទ្ធិ
នឹងចាប់ជនពាលទាំងឡាយ ទោះបីជាមានទោសល្មើសបែបណាក៏ដោយ ដែលបានចូល
ជ្រកកោណនៅក្នុងព្រះវិហារទាំងឡាយរបស់អស់លោកទេ។
អ្វីៗទាំងអស់ដែលបានព្រមព្រៀងហើយខាងលើនេះ យើងប្រគល់ជូនអស់លោកបព្វជិត
ហ្វ្រង់ស៊ីស្កាំងទាំងអស់នៃក្រុមម៉ាឡាកា សម្រាប់អនុវត្តជាដរាបរៀងទៅ។ អាស្រ័យ
ដោយហេតុនេះ យើងបានបញ្ជាឲ្យបោះត្រារបស់យើង។

ធ្វើនៅស្រីសន្ធរ»។

(៩) «ព្រះបរមរាជា ព្រះចៅនគរកម្ពុជា សូមធ្វើសេចក្តីនឹករលឹកដ៏ជ្រាលជ្រៅមកលោកនាយ
ក្រុមគ្រួសារបព្វជិត ហ្វ្រង់ស៊ីស្កាំងនៅក្រុងម៉ាឡាកា។

លោកនាយកនៅក្រុងម៉ាឡាកាបានផ្ញើលិខិតមួយមកយើង តាមរយៈលោកយ៉ាកូមេដាកុងសីសារ។ នៅក្នុងលិខិតនោះ លោកបានសរសេរថា លោកដាកុងសិសារនេះនឹងរស់នៅក្នុងព្រះរាជាណាចក្ររបស់យើង ហើយសូមឲ្យយើងទទួលលោក ដូចដែលព្រះរៀមរបស់យើង បានទទួលបព្វជិតទាំងអស់ដែលនៅអមព្រះអង្គដែរ។ សេចក្តីនេះ បានធ្វើឲ្យយើងមានហឫទ័យរីករាយជាខ្លាំង។ យើងតែងតែស្រឡាញ់ និងរាប់អានបព្វជិតទាំងអស់ ខាងក្រុមគ្រួសារ ហ្វ្រង់ស៊ីស្កាំង ដូចជាព្រះរាមរបស់យើង បានស្រឡាញ់លោកទាំងនោះដែរ។ ឥឡូវនេះ យើងសូមអរគុណចំពោះព្រះតេជគុណដែលបានចាត់លោក យ៉ាកូមេដាកុងសីសារ មកនគររបស់យើង។ លោកនេះ នឹងធឹង ហើយស្រឡាញ់សន្តិភាពណាស់ លោកបានរំលត់ជម្លោះរវាងពួកព័រទុយហ្គាល់ និងពួក ជប៉ុន ហើយបានធ្វើឲ្យពួកទាំងពីរក្រុមនេះ ជានានឹងគ្នាឡើងវិញ។ តាំងពីលោកមកដល់ លោកបានធ្វើបុណ្យជ្រមុជទឹកជូនមនុស្សសែសិបនាក់។ យើងរីករាយណាស់ ហើយយើងអនុញ្ញាតឲ្យលោកធ្វើបុណ្យ

*ជ្រមុជទឹក ជូនដល់ប្រជារាស្ត្រ ដែលរស់នៅក្នុងព្រះរាជាណាចក្ររបស់យើងតទៅទៀត ទៅតាមលទ្ធភាពអស់លោកដែលអាចធ្វើបាន។*

*ធ្វើនៅរាជវាំងរបស់យើង ថ្ងៃទី ២០ ខែតុលា ឆ្នាំ ១៦២០»។*

# រូបផនៃធី

# ជំពូកទី ៣

# គ្រីស្តសាសនាមកដល់កាន់នៅប្រទេសកម្ពុជា

នៅឆ្នាំ ១៥៩៤ កងទ័ពសៀមវាយបែកបន្ទាយលង្វែក ហើយកម្ទេចបន្ទាយនោះឲ្យខ្ទេចខ្ទីអស់។ បន្ទាប់មក ប្រទេសសៀមត្រួតត្រាលើប្រទេសកម្ពុជាទាំងមូល។ ព្រះបាទជ័យជេដ្ឋាទី ២ (១៦១៨-១៦២៨) បានខំប្រឹងជៀសពីការកៀបសង្កត់របស់សៀមនេះ ដោយទ្រង់តាំងព្រះរាជធានីនៅឧត្តុង្គ។ នៅក្រុងឧដុង្គនេះ ទ្រង់បានបញ្ជាឲ្យនាម៉ឺនសព្វមុខមន្ត្រីកាន់សុជីវធម៌តាមរបៀបខ្មែរឡើងវិញ។

ព្រះបាទជ័យជេដ្ឋាទី ២ មានបំណងពឹងលើវៀតណាម ដើម្បីរំដោះប្រទេសកម្ពុជាឲ្យរួចពីការគ្រប់គ្រងរបស់សៀម។ ព្រះអង្គបានយកម្ចាស់ក្សត្រីវៀតណាម ខ្សែង្វៀង (Nguyen) ម្នាក់មកធ្វើជាមហេសី។ ព្រះរាជវង្សវៀតណាមខ្សែ ង្វៀង ដែលសោយរាជ្យនៅក្រុងហ្វេ (Hué) ទើបតែរំដោះខ្លួនផុតពីការត្រួតត្រា របស់ព្រះចៅអធិរាជឡេ (Lê) ដែលសោយរាជ្យនៅក្រុងហាណូយ។ នៅឆ្នាំ ១៦២៣ ក្សត្រង្វៀងបានចាត់អង្គទូតម្នាក់មកគាល់ស្តេចខ្មែរនៅក្រុងឧដុង្គ សុំអនុញ្ញាតតែងតាំង គ្រឹះស្ថានជំនួញនៅក្នុងខេត្តព្រៃនគរ។ ព្រះបាទជ័យជេដ្ឋាទី ២ យល់ព្រមតាមសេចក្តីស្នើសុំនេះ និងបានអនុញ្ញាតឲ្យរដ្ឋអំណាចវៀតណាម មានសិទ្ធិទារពន្ធអាករពីអ្នកធ្វើជំនួញក្នុងក្រុងព្រៃនគរទៀតផង។ តាំងពីពេលនោះមក ព្រះចៅវៀតណាមដែល សោយរាជ្យនៅក្រុងហ្វេ បានបញ្ជូនប្រជារាស្ត្រវៀតណាម ឲ្យចូលមកតាំងទីលំនៅក្នុងខេត្តខ្មែរនានា ក្នុងដែនដីកូសាំងស៊ីន។ ជនជាតិវៀតណាមចាប់ផ្តើមចូលមករស់នៅដោយស្ងាត់ៗលើទឹកដីខ្មែរ អស់អំឡុងរាប់ឆ្នាំមកហើយ។ ព្រះចៅវៀតណាមចាប់ផ្តើមយកលេសថា ជួយថៅហ្វាយខេត្តខ្មែរ ឲ្យថែរក្សារបៀបរៀបរយ នៅដែនដីកូសាំងស៊ីន ហើយបានចាត់ឧត្តមសេនីយវៀតណាម

ម្នាក់ ឲ្យមកធ្វើជាមេបញ្ជាការនៅក្នុងក្រុងព្រៃនគរ។ តាំងពីពេលនោះមក ជនជាតិវៀតណាមវាតទីលេបទឹកដីខ្មែរ ដោយបញ្ជូនកសិករដែលជាទាហានប្រដាប់អាវុធ ឲ្យមករស់នៅលើទឹកដីខ្មែរ។ ទាហាន កសិករទាំងនេះ អាចការពារទឹកដីដែលខ្លួនកាន់កាប់បានដោយងាយ។ ព្រះបាទជ័យជេដ្ឋាទី ២ ចូលទិវង្គតនៅឆ្នាំ ១៦២៨ ។ ពេលនោះ ខេត្តព្រៃនគរ (Saigon) និងខេត្តកំពប់ស្រកាត្រី (Bien Hoà) ធ្លាក់នៅក្រោមអាណាព្យាបាលវៀតណាម ទាំងស្រុងតែម្តង។ ព្រះមហាក្សត្រខ្មែរទទួលស្គាល់ស្ថានភាពនេះជាផ្លូវការនៅឆ្នាំ ១៦៩៩ ។

ពេលនោះ វាសនានៃប្រទេសកម្ពុជាធ្លាក់នៅក្រោមកណ្តាប់ដៃប្រទេសជិតខាងទាំងពីរ គឺប្រទេសវៀតណាម និងប្រទេសសៀម ដែលត្រូវការដីឲ្យប្រជាជនគេរស់នៅ។ ម្យ៉ាងទៀត អ្នកដឹកនាំខ្មែររវល់តែបែកបាក់គ្នា ព្រោះវក់នឹងអំណាច។ កាលក្សត្រខ្មែរអង្គណាមួយចូលទិវង្គត បុត្រទាំងប៉ុន្មានរបស់ស្តេចអង្គនោះវាយគ្នាដណ្តើមយករាជ្យសម្បត្តិ គឺបុត្រម្នាក់ទៅពឹងទ័ពសៀម បុត្រម្នាក់ទៀតទៅពឹងទ័ពអណ្ណាម (ឬវៀតណាម)[១] ។ ព្រះរាជវង្សានុវង្ស ចេះតែឈ្លោះទាស់ទែងគ្នាជាបន្តបន្ទាប់ និងយ៉ាងសាហាវជាទីបំផុត។ រាជាណាចក្រកម្ពុជាលិចស្រឹមក្នុងអនាធិបតេយ្យ ហើយក៏បាត់បង់អាណាខេត្តបន្តិចម្តងៗ។

**មុននេះសោហុលឡង់** : *មហាអំណាចថ្មី*

ក្នុងឆ្នាំ ដែលទ័ពវៀតណាមមកតាំងទីលំនៅក្នុងព្រៃនគរនោះប្រទេសហុលឡង់មានការរីកចម្រើនជាខ្លាំង ហើយបានចងចំណងពាណិជ្ជកម្មជាមួយប្រទេសកម្ពុជាដែរ។

នៅឆ្នាំ ១៥៧៩ ប្រជាជននៅភាគខាងជើងនៃទ្វីបអឺរ៉ុប បានរំដោះខ្លួនចេញផុតពីអាណាព្យាបាលនៃប្រទេសអេស្ប៉ាញ ហើយអាណាខេត្តទាំងឡាយដែលមានគ្រីស្តបរិស័ទប្រូតេស្តង់រស់នៅច្រើនជាងគេ ទាមទារឯករាជ្យបាន និងដាក់ឈ្មោះស្រុកថា "អាណាខេត្តរួម"។ ក្រោយមក ខេត្តទាំងនោះបានប្រែឈ្មោះទៅជា "ហុលឡង់" (Holland) ។ រីឯ អាណាខេត្តដែលមានគ្រីស្តកាតូលិករស់នៅជាច្រើន ក៏បានបង្កើតប្រទេស "បែលស៊ីក" (Belgigue)។ កាលពីដើមពួកហុលឡង់ជាប្រជាពលរដ្ឋអេស្ប៉ាញ ដូច្នេះ

ក្រោយពីពួកគេបានឯករាជ្យមក គេអាចចូលទៅកាន់ដែនដីដែលប្រទេសអេស្ប៉ាញ និង ប្រទេសព័រទុយហ្គាល់ កាន់កាប់នៅទ្វីបអាស៊ីបានដោយងាយ។ ពួកគេបានតាំងគ្រឹះស្ថាន ពាណិជ្ជកម្ម នៅលើដែនដីទាំងនោះ។ ដោយពួកអេស្ប៉ាញដែលជាគ្រីស្តបរិស័ទកាតូលិក បានធ្វើទុក្ខបុកម្នេញពួកប្រូតេស្តង់កាលពីសម័យមុនៗ ពួកហុលឡង់ចង់សងសឹកនឹងពួក កាតូលិក នៅលើដែនដីដែលទើបតែធ្លាក់មកនៅក្រោមការត្រួតត្រារបស់ពួកគេដែរ។

នៅឆ្នាំ ១៥៩៦ ពួកហុលឡង់វាយដណ្តើមយកបានប្រជុំកោះម៉ូលុក(២)។ បន្ទាប់មក ពួកគេដណ្តើមយកប្រទេសឥណ្ឌូណេស៊ីទៀត។ នៅឆ្នាំ ១៦០២ ប្រទេសហុលឡង់ បានបង្កើត "*សមាគមនៃប្រទេសឥណ្ឌាប៉ែកខាងបូព៌ា* ( Compagie générale des Indes Orientales )" ដែលកាន់កាប់ជំនួញតាមផ្លូវ សមុទ្រជាមួយទ្វីបអាស៊ី។ ក្នុងអំឡុង ប៉ុន្មានឆ្នាំបន្តបន្ទាប់មកទៀត សមាគមនេះបង្កើតបានទីតាំងពាណិជ្ជកម្មជាច្រើន ដែលមានក្រុងបាតាវីយ៉ា( Batavia គឺក្រុងជ្យាការតាសព្វថ្ងៃ ) ជាមណ្ឌលសំខាន់ជាងគេ។ ពួកអ្នកសំពៅហុលឡង់ស្វែងរកទិញទំនិញថ្មីៗ ក៏ទាក់ចិត្តនឹងប្រទេសកម្ពុជា។ ពួកគេ បើកសំពៅតាមដងទន្លេមេគង្គ នៅឆ្នាំ ១៦២៣ ពួកគេបានតាំងហាងជំនួញមួយ នៅកំពង់ហ្លួង ជាកំពង់ផែតូចមួយ នៅជិតក្រុងឧដុង្គរាជធានីខ្មែរ។

ពេលមកដល់ប្រទេសកម្ពុជា ពួកហុលឡង់បានបង្អាប់បង្អោនកិត្តិយសពួកព័រទុយហ្គាល់ ជាគ្រីស្តបរិស័ទកាតូលិក។ ប៉ុន្តែ ដោយទាហានហុលឡង់ប្លន់អ្នកស្រុក ព្រះមហាក្សត្រខ្មែរ ទ្រង់ខ្វាល់នឹងជនជាតិហុលឡង់ទាំងនោះ។ ម្យ៉ាងទៀត ពួកចាម និងជ្វាដែលរស់នៅ ប្រទេសខ្មែរ ច្រើនតែរកស៊ីធ្វើជំនួញ។ ដោយពួកគេភ័យខ្លាចហុលឡង់មកធ្វើជំនួញ ដែរនោះ គេបបួលព្រះមហាក្សត្រខ្មែរ ឲ្យចងសម្ព័ន្ធមេត្រីជាមួយពួកព័រទុយហ្គាល់វិញ។ ព្រះបាទអង្គច័ន្ទ មានមហេសីជាតិជ្វា និងចូលសាសនាអ៊ីស្លាមថែមទៀតផងដើម្បីសងគុណ ចំពោះពួកចាមនិងជ្វា ដែលបានជួយព្រះអង្គឲ្យបានឡើងសោយរាជ្យនោះ។ ទ្រង់ យល់ព្រមតាមបំណងរបស់ពួកចាមនិងជ្វានោះ។ នៅឆ្នាំ ១៦៤៣ ទ្រង់បណ្តោយឲ្យ ចោរមួយក្រុមសម្លាប់រង្គាលពួកឈ្មួញហុលឡង់ នៅភ្នំពេញ។ ឆ្នាំ ១៦៤៤ ទ្រង់បញ្ជាឲ្យ ឆែកឆេរកប៉ាល់ហុលឡង់ពីរគ្រឿង ដែលចតនៅកំពង់ផែកំពង់ហ្លួង។ ការឆែកឆេរនេះ បណ្តាលឲ្យខ្មែរ និងហុលឡង់វាយកាប់សម្លាប់គ្នា តែពួកហុលឡង់ចាញ់ខ្មែរ។ ក្នុងឆ្នាំ ១៦៦៧ គ្រឹះស្ថានពាណិជ្ជកម្មនៅកំពង់ហ្លួង ត្រូវចោរប្លន់យកឥវ៉ាន់អស់។ រួចនៅ

ឆ្នាំ ១៦៨២ ពួកហុលឡង់បិទគ្រឹះស្ថានទាំងនោះរហូត។

ក្នុងសភាពការណ៍នយោបាយជាតិ និងអន្តរជាតិបែបនេះ មានក្រុមគ្រីស្តបរិស័ទខ្លះ បានភៀសខ្លួនមក សុំជ្រកកោនលើទឹកដីខ្មែរ។

**ពួកជប៉ុន**

មានគ្រីស្តបរិស័ទជប៉ុនមួយក្រុម ភៀសខ្លួនមករស់នៅក្នុងប្រទេសកម្ពុជាមុនគេបង្អស់។ លោកហ្វ្រង់ស្វ័រសាវីយេ (Saint François Xavier) បានទៅដល់ប្រទេសជប៉ុន នៅឆ្នាំ ១៥៤៩។ លោកបានណែនាំជនជាតិជប៉ុនជាច្រើនពាន់នាក់ ឲ្យចូលគ្រីស្តសាសនា។ ប្រភពខ្លះបាននិយាយថា នៅឆ្នាំ ១៥៨០ មានគ្រីស្តបរិស័ទជាតិជប៉ុនជិតពីរសែននាក់។ អ្នកកាន់អំណាចជប៉ុនខ្លាចសាសនាថ្មីនេះ នាំឲ្យរលំអំណាចរបស់គេ និងនាំឲ្យកើតចលាចលក្នុងសង្គមជាតិរបស់គេទៀតផង។ ដូច្នេះហើយ បានជាក្នុងឆ្នាំ ១៥៩៧ រដ្ឋអំណាចនៅក្រុងណាហ្គាសាគី (Nagasaki) ចាប់គ្រីស្តបរិស័ទ ២៦ នាក់ ឆ្កាងសម្លាប់ចោល។ អំណាចជប៉ុន បានធ្វើទុក្ខបុកម្នេញលើគ្រីស្តបរិស័ទទាំងឡាយទៀត។ ក្នុងចន្លោះឆ្នាំ ១៦១៤ និងឆ្នាំ ១៦៣៨ ពួកគេសម្លាប់រង្គាលគ្រីស្តបរិស័ទជប៉ុនរាប់ម៉ឺននាក់ ហើយអស់លោកដែលមកផ្សាយគ្រីស្តសាសនា ក៏ត្រូវរដ្ឋអំណាចបណ្តេញចេញពីប្រទេសទៅទៀត។ គ្រីស្តបរិស័ទជប៉ុនមួយចំនួនក៏បានចាកចេញពីស្រុករបស់ខ្លួន មកកាន់ក្រុងហ្វៃហ្វូ (Faïfo) ជិតក្រុងទូរ៉ាន (ដាណាង)[៣] គ្រីស្តបរិស័ទខ្លះទៅកាន់ក្រុងអយុធ្យាក្នុងប្រទេសសៀម ហើយមួយក្រុមទៀតចូលមកជ្រកកោននៅប្រទេសកម្ពុជា។ ពួកគេបានតាំងទីលំនៅ នៅតាមដងទន្លេសាបប្រហែលជាមួយគីឡូម៉ែត្រខាងត្បូងពញាឮ[៤] ជាភូមិដែលមានពួកកូនកាត់ព័រទុយហ្គាល់ និងអេស្ប៉ាញរស់នៅ។

**គ្រីស្តបរិស័ទព័រទុយហ្គាល់**

ក្នុងឆ្នាំ ១៦៦០ មានគ្រីស្តបរិស័ទមួយចំនួនទៀត បានមកដល់រាជវាំងឧដុង្គ គឺពួកព័រទុយហ្គាល់ និងកូនកាត់ព័រទុយហ្គាល់។ ក្រុមនេះមកពីក្រុងម៉ាកាសសា (Macassar) នៃកោះសេឡេប(Célébes)[៥]។ មុនពេលលោក ហ្វ្រង់ស្វ័រសាវីយេ អញ្ជើញទៅប្រទេសជប៉ុន លោកបានទៅប្រកាសដំណឹងល្អអំពីព្រះគ្រីស្ត នៅលើកោះនោះ។ មានមនុស្សប្រមាណជាង ២៥.០០០ នាក់ បានចូលគ្រីស្តសាសនា ហើយក្នុងចំណោមនោះ មានទាំង

ព្រះមហាក្សត្រផងដែរ។ ប៉ុន្តែ ក្រោយមក គឺនៅឆ្នាំ ១៦៥០ ពួកប្រូតេស្តង់ជាតិហុលឡង់ បានដេញពួកព័រទុយហ្គាល់និងគ្រីស្តបរិស័ទកាតូលិក ឲ្យចេញពីកោះនោះអស់។ ដូច្នេះ ពួកគេមួយចំនួន បានភៀសខ្លួនមកនៅប្រទេសកម្ពុជា។ ក្នុងចំណោមអ្នកទាំងនោះ មាន ៤០០នាក់ បានចូលទៅនៅកក្នុងជំរំទ័ពព័រទុយហ្គាល់នៅឯភ្នំពេញ ដោយមាន លោកបូជាចារ្យដាកូស្តា (da Costa) ជាអ្នកណែនាំ ហើយមានមួយក្រុមទៀតបាន មកតាំងទីនៅភូមិពញាឮ ដោយមានលោករ៉ូស្សា (Rocah) ជាអ្នកណែនាំ។ ក្នុង ចំណោមគ្រីស្តបរិស័ទទាំងនោះ មានបុរសម្នាក់ឈ្មោះ អង់ទន់ដឺម៉ុងតេរ៉ូ (Antoine de Monteiro) បានយករូបបដិមាព្រះមាតាមកជាមួយផង។

ជនជាតិខ្មែរតែងដំណាលរឿងអ្នកទាំងនោះដូចតទៅ៖

> *«ពួកអ្នកមកដល់ថ្មី បានទៅបង្ហាញខ្លួនចំពោះព្រះមហាក្សត្រ ទាំងកាន់ស្បែកក្របីមួយ និងប្រាក់មួយហាប(៦)។ ពួកគែបានក្រាបថ្វាយបង្គំតាមទម្លាប់ខ្មែរ រួចពួកគេសុំព្រះរាជា ព្រះរាជាទានដីមួយកន្លែង ជិតព្រះរាជវាំងទំហំប៉ុនស្បែកក្របីនោះ។ ពួកគេសុខចិត្តថ្វាយប្រាក់មួយហាបនេះ សម្រាប់ទិញដីនោះ។ ព្រះរាជាចាត់ពួកជនបរទេសទាំងនោះទុកជាមនុស្សឆោត ហើយមិនទាំងយកព្រះទ័យទុកដាក់ ចំពោះពាក្យស្នើរបស់ពួកគេនោះផង។ ដោយពួកគេចេះតែទទូចសុំ ព្រះរាជាក៏យល់ព្រមប្រោសប្រទានដី តាមពាក្យសុំរបស់ពួកបរទេសនោះ។ ដល់ត្រឡប់ទៅផ្ទះគេវិញ ពួកកូនកាត់ព័ទុយហ្គាល់ទាំងនោះ តាំងខំផ្ចិតផ្ចង់កាត់ស្បែកក្របី ជាព្រ័តចម្រៀកតូចៗឆ្មារៗក្រៃលែង មិនទាំងធំជាងខ្សែឆ្មារផង។ ពួកគេយកព្រ័តឆ្មារតជាប់គ្នានោះ មកវាស់យកទំហំដីតាមបណ្តោយមាត់ទន្លេ ដែលចេញពីពញាឮ ហើយដែលផុតចប់នៅជិតព្រះរាជដំណាក់។ ជនជាតិខ្មែរទាំងអស់ដែលនៅលើដីវាស់ហើយនេះ ត្រូវចាកចេញពីទីកន្លែងតាមបញ្ជាព្រះរាជា។ ព្រះរាជាទ្រង់ឈ្វេងយល់ថា ត្រូវទទួលជនបរទេសទាំងនោះ មកធ្វើជាអ្នករាជការព្រះអង្គ ព្រោះពួកជនឆ្លាតៗបែបនេះ អាចគាំទ្រព្រះរាជបល្ល័ង្កយ៉ាងសកម្មបាន។*

គឺគ្រីស្តបរិស័ទមកពីកោះសេឡែបទាំងនោះឯង ដែលជាដើមកំណើតព្រះសហគមន៍កាតូលិកកម្ពុជា។ ក្នុងព្រះសហគមន៍កាតូលិកមានគ្រីស្តបរិស័ទ ឈ្មោះ ដឺម៉ុងតេរ៉ូ (de Monteiro) ដឺឌីយ៉ាស (de Diaz) ដាប្រេអូ (d'Adréo) ដឺឡាគ្រុស (de la Cruz) មានរហូតទល់សព្វថ្ងៃនេះ(៧)។

**គ្រីស្តបរិស័ទវៀតណាម**

នៅឆ្នាំ ១៦៦៥ មានគ្រីស្តបរិស័ទវៀតណាមមួយក្រុម រស់នៅលើច្រាំងខាងកើតទន្លេមេគង្គទល់មុខភ្នំពេញ។

សាសនទូត ចាប់ផ្តើមផ្សាយគ្រីស្តសាសនា នៅប្រទេសវៀតណាម ៤០ ឆ្នាំ ក្រោយប្រទេសកម្ពុជា គឺចាប់ពីឆ្នាំ ១៦១៤ មក។ ដោយរដ្ឋអំណាចជប៉ុន ដេញអ្នកផ្សាយគ្រីស្តសាសនាចេញពីប្រទេសរបស់គេ សាសនទូតក៏បានមកផ្សាយគ្រីស្តសាសនានៅប្រទេសអណ្ណាម។ លោកអាឡិចសង់ដឺរ៉ូដ៍ ( Alexandre de Rhodes ) ជាបព្វជិតខាងសមាគមព្រះយេស៊ូ ( Jésuite ) បានរស់នៅក្រុងហ្វេ ក្នុងឆ្នាំ ១៦២៦។ តាំងពីរឆ្នាំ ១៦៤៤ មក អ្នកកាន់អំណាចវៀតណាមចាប់ផ្តើមធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ដោយខ្លាចថាគ្រីស្តបរិស័ទទាំងនោះ នឹងបំផ្លាញរបៀបរៀបរយក្នុងសង្គមរបស់អស់លោក។ ដូច្នេះគ្រីស្តបរិស័ទវៀតណាមមួយចំនួនតូច បានភៀសខ្លួនមកជ្រកកោននៅក្នុងប្រទេសកម្ពុជា ជាប្រទេសជិតខាង។ ក្នុងចំណោមគ្រីស្តបរិស័ទទាំងនោះ មានអ្នកខ្លះបានមកស្នាក់នៅជិតភ្នំពេញ។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា ព្រះសហគមន៍ប្រទេសកម្ពុជា មានដើមកំណើតពីក្រុមគ្រីស្តបរិស័ទជាតិអាស៊ីផងដែរ គឺជិត ២០០ ឆ្នាំ មុនជនជាតិបារាំងចូលមកតែងតាំងអាណានិគម។

---

( ១ ) នៅសម័យនោះ គេហៅប្រទេសវៀតណាមថា "ដាយវៀត" មានភូមិភាគពីរ ដែលវាយច្បាំងគ្នាជាញឹកញយគឺដែនដីតុងកឹង ( Tonkin ) នៅភាគខាងជើង ស្ថិតនៅក្រោមអំណាចរាជវង្សឡេ ( Lé ) ហើយនឹងដែនដីអណ្ណាម ( Annam ) នៅខាងត្បូង ស្ថិតនៅក្រោមអំណាចរាជវង្សង្វៀង ( Nguyen ) ដែលមានក្រុងហ្វេ ( Hué ) ជារាជធានី។ ឯដែនកូសាំងស៊ីនជាដីខ្មែរ។ កាលនោះ គេពុំបាននិយាយ ថា "វៀត ណាម" ដូចសព្វថ្ងៃនេះឡើយ។ ជនជាតិខ្មែរសម័យនោះ ច្រើនតែមានការទាក់ទងជាមួយនឹងព្រះចៅហ្វេ ដែលជារាជធានីប្រទេសអណ្ណាម។ ដូច្នេះ គេប្រើពាក្យ "អណ្ណាម" ជាពាក្យសម្រាប់ហៅពួក វៀតណាមរហូតដល់ឯករាជ្យវៀតណាម ( ១៩៥៤ )។ ក្នុងសៀវភៅនេះ ដោយចង់ឲ្យងាយយល់ យើងប្រើតែពាក្យៈ ជនជាតិវៀតណាមប៉ុណ្ណោះ។

(២) ប្រជុំកោះប្រទេសឥណ្ឌូនេស៊ី ស្ថិតនៅចន្លោះកោះស៊ូឡាវេស៊ី និងប្រទេសនូវែលហ្គីណេ (អ៊ីរីយ៉ង) ខាងលិច។

(៣) នៅចំកណ្ដាល់ប្រទេសវៀតណាមសព្វថ្ងៃ។

(៤) ឈ្មោះភូមិ "ពញាព្ទ" ប្រហែលក្លាយមកពីពាក្យ "ប៉ូញារីស" ដែលក្នុងសម័យដើមស្តេចខ្មែរបានប្រោសប្រទានឋានន្តរសក្តិជា "ប៉ុញា" ឲ្យអ្នកជ្យងព្រេងអេស្ប៉ាញម្នាក់ ឈ្មោះ ប្លាសរីសដឺហ៊ែរណាន់ ហ្គុងសាឡេស ជាមិត្តរបស់លោក វេឡូសូ ដ៏ល្បីល្បាញ។

(៥) សព្វថ្ងៃនេះគឺកោះស៊ូឡាវេស៊ី នាប្រទេសឥណ្ឌូនេស៊ី។

(៦) ៦០ គីឡូក្រាម។

(៧) មកទល់នឹងឆ្នាំ ១៩៧៥ គ្រីស្តបរិស័ទទាំងនោះ ហៅខ្លួនផ្ទាល់ថា "ហ្វំឡង់" គឺកូនចៅរបស់ពួកហុលឡង់។ តាមពិតពួកគេជាកូនចៅរបស់ពួកកូនកាត់ព័រទុយហ្គាល់ ដែលបានរងទុក្ខទោសពីសំណាក់ពួកហុលឡង់នោះ។ គ្រីស្តបរិស័ទទាំងនោះ រស់នៅប្រទេសកម្ពុជាដោយយកចិត្តទុកដាក់ថែរក្សាប្រពៃណីរបស់គេឲ្យបានគង់វង់។ គ្រីស្តបរិស័ទទាំងនោះ តែងស្លៀកពាក់តាមរបៀបខ្មែរ លើកលែងតែប្រុសៗ នៅថ្ងៃរៀបមង្គលការរបស់ខ្លួន។ នៅថ្ងៃនោះ ពួកគេស្លៀកពាក់ឯកសណ្ឋានចាស់ៗ របស់មេទាហានព័រទុយហ្គាល់ រហូតមកដល់សម័យថ្មីនេះ។ ពួកនោះ តែងប្រើភាសាព័រទុយហ្គាល់ ក្នុងកំឡុងជិតពីរសតវត្ស។ នៅសតវត្សទី ២០ គេប្រើពាក្យដែលក្លាយមកពីភាសាព័រទុយហ្គាល់ខ្លះៗសម្រាប់ហៅគ្នា ដូចជាពាក្យ "ទាវ" សម្រាប់ហៅឪពុកមា "ទា" សម្រាប់ហៅម្តាយមីង "ញ៉ាំង" សម្រាប់ហៅបងស្រី "ញ៉ូង" សម្រាប់ហៅបងប្រុស។ ក្នុងអំឡុងច្រើនសតវត្សមកព្រះមហាក្សត្រទុកព្រះទ័យលើគ្រីស្តបរិស័ទទាំងនោះ ព្រោះពួកគេមានចិត្តស្មោះត្រង់ឥតប្រែប្រួលចំពោះព្រះអង្គ។ សមាជិកជាច្រើននៃក្រុមព្រះសហគមន៍នេះ បានកាន់កាប់ដំណែងជារដ្ឋមន្ត្រីផង។

## ជំពូកទី ៤

# សម្តេចប៉ាបតែងតាំងអភិបាលព្រះសហគមន៍សម្រាប់គ្រីស្តបរិស័ទទ្វីបអាស៊ី

អស់លោកអភិបាលព្រះសហគមន៍កាតូលិក ដែលបានរួមប្រជុំក្នុងមហាសន្និបាតសកល នៅក្រុងត្រេនតូ (Trento)[១] មានបំណងរកមធ្យោបាយឲ្យព្រះសហគមន៍ អាចបំពេញភារកិច្ចយ៉ាងសកម្ម ទៅតាមសភាពការថ្មីផង។ អស់លោកបានបញ្ជាក់នូវគោលសំខាន់ៗនៃគ្រីស្តសាសនា ដើម្បីប្រឆាំងនឹងក្រុមប្រូតេស្តង់ ដែលបានប្រែទម្រង់គ្រីស្តសាសនា ហើយដែលមិនព្រមទទួលស្គាល់អំណាចរបស់ព្រះសហគមន៍។ មហាសន្និបាតបានចាត់ចែងឲ្យអស់លោកសាសនទូតដែលផ្សាយគ្រីស្តសាសនា បំពេញភារកិច្ចរបស់ខ្លួនរួមជាមួយអភិបាលព្រះសហគមន៍តាមភូមិភាគនីមួយៗ។ តាមសេចក្តីសម្រេចនៃមហាសន្និបាត នៅឆ្នាំ ១៥៦៨ សម្តេចប៉ាបពីយ៉ូទី ៥ (Saint Pie V) បានបង្កើត "គណៈកម្មាធិការសម្រាប់ទាក់ទងជាមួយអ្នកពុំមានជំនឿ"។ ក្នុងគណៈកម្មាធិការនេះ មានលោកទីប្រឹក្សារបស់សម្តេចប៉ាប (កាឌីណាល់ Cadinal) បួនរូបចូលរួម។ គណៈកម្មាធិការនេះ មានមុខងារចាត់ចែង និងដោះស្រាយគ្រប់កិច្ចការ ដែលទាក់ទងទៅនឹងអ្នកកាន់សាសនាដទៃ ហើយដែលចង់ចូលគ្រីស្តសាសនា[២]។ នាឆ្នាំ ១៦២២ សម្តេចប៉ាប គ្រេក័រទី ១៥ (Grégoire XV) បានប្រែគណៈកម្មាធិការនេះ ឲ្យទៅជា "*ក្រសួងទទួលភារកិច្ចផ្សព្វផ្សាយជំនឿ*" (Propaganda fide) ដើម្បីចាត់ចែងសកម្មភាពរបស់អ្នកផ្សាយសាសនាដោយផ្ទាល់លោក។

នៅចន្លោះឆ្នាំ ១៦២៥ និង ១៦៤៤ ក្រសួងនេះបានតែងសេចក្តីរាយការណ៍បីច្បាប់ស្តី អំពីសភាពការរបស់អ្នកផ្សាយគ្រីស្តសាសនា។ ក្នុងសេចក្តីរាយការណ៍ទាំងនោះ អ្នកតែងបានរិះគន់សកម្មភាពសាសនាទូត ដោយសរសេរថា៖

*«បព្វជិតដែលមកពីប្រទេសផ្សេងៗ មិនចុះសម្រុងនឹងគ្នា ខ្វែងយោបល់គ្នាពេលជ្រើសរើស និងអប់រំអ្នកផ្សាយសាសនា អស់លោកទ្វេសប្រហែស និងធូរពេក*

*អស់លោកមិនចេះភាសាអ្នកស្រុក អស់លោកជ្រៀតជ្រែកចូលរឿងនយោបាយ ហើយលើសពីនេះទៅទៀត អាជ្ញាធរស៊ីវិលចូលជ្រៀតជ្រែកក្នុងកិច្ចការគ្រីស្ត សាសនាផង។ ក្រសួងបារម្ភអំពីសាសនទូតមានចំនួនតិចពេក អ្នកទាំងនោះខ្វះខាតគ្មានសម្ភារៈគ្រប់គ្រាន់ គេពុំមានសេរីភាពប្រកាសផ្សាយសេចក្តីដែលសម្តេចប៉ាបបានសម្រេច ដោយគ្មានការអនុញ្ញាតពីព្រះមហាក្សត្រអេស្ប៉ាញ ឬព័រទុយហ្គាល់ទេ»* ។

អ្នកកាន់អំណាចនៅប្រទេសជប៉ុន នៅតុងកឹង និងនៅដែលនកូសាំងស៊ីន បានធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ជាហេតុបណ្តាលឲ្យផ្សាយគ្រីស្តសាសនាជាតិបរទេស ពុំអាចរស់នៅក្នុងតំបន់ទាំងនោះបាន។ គេដេញលោកអាឡិចសង់ដឺរ៉ូដ៍ (Alexandre de Rhodes) ជាសាសនទូតប្រចាំដែនដីកូសាំងស៊ីនតាំងពីឆ្នាំ ១៦២៥ ឲ្យចេញពីតំបន់នោះដល់ទៅ ៥ ដង។ ដូច្នេះគ្រីស្តបរិស័ទថ្មីៗក្នុងស្រុកនោះ គ្មានអ្នកណាជួយណែនាំទេ។ តាំងពីគ្រានោះមក នៅទីក្រុងប៉ារីស និងនៅទីក្រុងរ៉ូម លោកអាឡិចសង់ដឺរ៉ូដ៍ ទទូចទាមទារឲ្យតែងតាំងបូជាចារ្យជាតិវៀតណាម នៅដែនដីកូសាំងស៊ីន និងនៅឯតុងកឹង។ លោកយល់ថា ប្រសិនបើគ្មានបូជាចារ្យជាតិវៀតណាមនៅស្រុកទាំងពីរនោះទេ ការផ្សាយគ្រីស្តសាសនាមិនអាចនៅស្ថិតស្ថេរគង់វង្សយូរអង្វែងបានឡើយ។ មានតែបូជាចារ្យជាអ្នកស្រុកដើមសុទ្ធសាធ ដែលនឹងអាចអប់រំជំនឿជនរួមជាតិរបស់ខ្លួន ព្រមទាំងអគ្គសញ្ញាជូនអ្នកទាំងនោះបាន ដោយរបៀបអូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក។

ដូច្នេះ ត្រូវតែចាត់អភិបាលព្រះសហគមន៍ខ្លះៗ ដើម្បីនឹងតែងតាំងអ្នកស្រុកដើមធ្វើជាបូជាចារ្យ។ អភិបាលព្រះសហគមន៍ទាំងនោះ នឹងស្ថិតនៅក្រោមអំណាចរបស់សម្តេចប៉ាបផ្ទាល់តែម្តង។ គេនឹងហៅអភិបាលព្រះសហគមន៍ទាំងនោះថា៖ អភិបាលព្រះសហគមន៍ទទួលបន្ទុកភូមិភាគក្នុងនាមសម្តេចប៉ាប (Vicaire Apostoligue)។ សម្តេចប៉ាបធ្វើដូច្នេះ ដោយមានបំណងឲ្យព្រះសហគមន៍ ជៀសផុតពីការត្រួតត្រារបស់មហាក្សត្រប្រទេសអេស្ប៉ាញ និងប្រទេសព័រទុយហ្គាល់ ដែលធ្លាប់តែងតាំងអភិបាលព្រះសហគមន៍នៅក្នុងដែនដីនៅក្រោមអំណាចរបស់ព្រះអង្គ។ ម្យ៉ាងទៀត ដោយប្រទេសអេស្ប៉ាញ និងប្រទេសព័រទុយហ្គាល់ប្រកួតប្រជែងគ្នាផ្នែកនយោបាយ ព្រះមហាក្សត្រនៃប្រទេសអេស្ប៉ាញមិនព្រមតែងតាំងអភិបាលព្រះសហគមន៍ នៅកន្លែងជាច្រើន។ នៅឆ្នាំ ១៥៨០ ជនជាតិអេស្ប៉ាញយកប្រទេសព័រទុយហ្គាល់ដាក់បញ្ចូលទៅក្រោមការត្រួតត្រារបស់

ប្រទេសរបស់ខ្លួន។ ៦០ ឆ្នាំក្រោមមកនោះ ប្រទេសព័រទុយហ្គាល់ដណ្ដើមឯករាជ្យរបស់ខ្លួនវិញបាន ក៏ប៉ុន្តែ ស្តេចអេស្ប៉ាញមិនព្រមទទួលស្គាល់ឯករាជ្យនោះទេ ហើយក៏មិនព្រមតែងតាំងអភិបាលព្រះសហគមន៍នៅក្នុងដែនដីទាំងឡាយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសព័រទុយហ្គាល់ឡើយ ជាពិសេសនៅក្រុងម៉ាឡាកា និងនៅក្រុងម៉ាកាវ។

ក្នុងអំឡុងរាប់ឆ្នាំ សម្តេចប៉ាបបានខិតខំរកមធ្យោបាយដើម្បីផ្គត់ផ្គង់អស់លោកអភិបាលព្រះសហគមន៍ ដែលសម្តេចមានបំណងចាត់ឲ្យទៅបំពេញភារកិច្ចនៅប្រទេសទាំងឡាយនៅក្រោមការគ្រប់គ្រងរបស់ប្រទេសព័រទុយហ្គាល់ និងប្រទេសអេស្ប៉ាញ៉ុលនោះ។ ប្រសិនបើអស់លោកមានប្រាក់គ្រប់គ្រាន់ អស់លោកអាចគេចផុតពីអាណាព្យាបាលរបស់មហាអំណាចធំៗទាំងពីរនេះបាន។ នៅថ្ងៃទី ២៩ ខែកក្កដា ១៦៥៨ ដោយរកថវិការបានគ្រប់គ្រាន់ហើយ សម្តេចប៉ាបអាឡិចសង់ ទី ៧ (Alexandre VII) តែងតាំងអភិបាលព្រះសហគមន៍ទទួលបន្ទុកភូមិភាគក្នុងនាមសម្តេចប៉ាប បីរូប។ លោកទាំងបីរូបនោះ មានសញ្ជាតិជាបារាំង ហើយទទួលបន្ទុកផ្សព្វផ្សាយគ្រីស្តសាសនានៅទ្វីបអាស៊ី ជាពិសេសនៅប្រទេសចិន។ អភិបាលព្រះសហគមន៍ម្នាក់ មានឈ្មោះ សិលាឡាំប៉ែរដឺឡាម៉ុត (Pierre Lambert de la Motte) ជាអភិបាលព្រះសហគមន៍នៅបេរីត (Béryte)(៣) ទទួលបន្ទុកលើដែនដីកូសាំងស៊ីនគរចម្ប៉ា ព្រមទាំងអាណាខេត្តឆេឆាង (Che Chang) ភ្វេនស៊ី (Fouensis) កងទុង (Quantung) ស៊ីយ៉ាមស៊ី (Chiamsy) កោះហៃណាម និងកោះឯទៀតៗ។ អភិបាលព្រះសហគមន៍ម្នាក់ទៀតឈ្មោះហ្វ្រង់ស្វ័រប៉ាលុយ (FranÇois Pallu) ជាអភិបាលព្រះសហគមន៍នៅអេលីយ៉ូប៉ូលី (Héliopolis)(៤) ទទួលបន្ទុកផ្សាយគ្រីស្តសាសនា នៅតុងកឹង នៅប្រទេសលាវ និងនៅភាគខាងលិចនៃប្រទេសចិន។ បីបួនខែក្រោយមក សម្តេចប៉ាប បានតែងតាំងលោកបូជាចារ្យ អ៊ីញ៉ាសកូតូលេនឌី (Ignace Cotolendi) ជាអភិបាលព្រះហគមន៍នៃក្រុងមេតែឡូប៉ូលីស (Métellopolis) ឲ្យទទួលភារកិច្ចក្នុងប្រទេសសៀមខេត្តណង់គីន (Nankin) ប៉េកាំង ដែសមុទ្រតារតារី (Tartarie) ប្រទេសកូរ៉េ ហើយនិងដែនដីឯទៀតៗ ថែមទៀតផង។

## លិខិតបង្រៀនបុរេដាវឆ្នាំ ១៦៥៩

ថ្ងៃទី ១០ វិច្ឆិកា ១៦៥៩ ក្រសួងទទួលភារកិច្ចផ្សាយជំនឿ បានប្រកាសលិខិតមួយ

បញ្ជាក់នូវគោលសំខាន់ៗ សម្រាប់អភិបាលព្រះសហគមន៍ទាំងបីនាក់នោះ។ អ្នកនិពន្ធលិខិតនេះបានរិះគិតអស់ពេលមួយឆ្នាំ ហើយគេចាត់ទុកលិខិតនេះ ជាគោលនៃការផ្សាយគ្រីស្តសាសនារបស់ព្រះសហគមន៍ នៅសម័យនោះ។ កាលពីសម័យមុនៗ សាសនទូតតែងយល់ថាមុខនាទីរបស់ពួកគេ គឺប្រកាសដំណឹងល្អ ដល់ជនទាំងឡាយ ណាដែលមិនទាន់ស្គាល់ព្រះគ្រីស្តនៅឡើយ។ ក្នុងលិខិតនោះ អស់លោកនិពន្ធបញ្ជាក់ថា សាសនទូតមានមុខនាទីមិនត្រឹមតែ «*ប្រកាសដំណឹងល្អ*» ប៉ុណ្ណោះទេ តែត្រូវ «*ចាក់គ្រឹះរបស់ព្រះសហគមន៍*» ក្នុងស្រុកណាមួយ រួមជាមួយលោកអភិបាលព្រះសហគមន៍ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសម្តេចប៉ាបថែមទៀតផង។

លិខិតនោះចែកជាបីជំពូក គឺពាក្យប្រៀនប្រដៅមុនចេញដំណើរ ក្នុងពេលធ្វើដំណើរ ពេលប្រកាសផ្សាយសាសនា។ ចំណុចសំខាន់ៗបួន មានសេចក្តីសង្ខេបដូចតទៅ៖

**១-តែងតាំងអ្នកស្រុកធ្វើជាបូជាចារ្យ**

*«ក្រសួងមានបន្ទុកផ្សាយជំនឿ តែងតាំងលោកអភិបាលព្រះសហគមន៍នៅតំបន់ទាំងនោះ ជាពិសេសដើម្បីឲ្យលោកខិតខំរកគ្រប់មធ្យោបាយ បង្ហាត់បង្រៀនយុវជនក្នុងស្រុកនោះ ឲ្យមានសមត្ថភាពគ្រប់គ្រាន់ នឹងអាចទទួលមុខងារជាបូជាចារ្យបាន។ រួចចាត់បូជាចារ្យថ្មីៗទាំងនោះឲ្យបម្រើគ្រីស្តសាសនា ដោយចិត្តស្ម័គ្រ ក្រោមការដឹកនាំរបស់អស់លោក»។*

*«ក្នុងចំណោមអ្នកទាំងប៉ុន្មាន ដែលលោកបានតែងតាំងជាបូជាចារ្យហើយនោះ ប្រសិនបើ មានអ្នកខ្លះ សមគួរនឹងទទួលមុខងារជាអភិបាលព្រះសហគមន៍បាន សូមលោកកុំប្រគល់មុខដំណែងខ្ពស់នេះឲ្យគេឡើយ។ យើងហាមជាដាច់ខាត។ សូមលោកសរសេរសំបុត្រទៅជម្រាប ក្រសួងទទួលបន្ទុកផ្សាយជំនឿ ជាមុនសិនពីឈ្មោះ អាយុ គុណសម្បត្តិរបស់គេ ហើយនិងពីអ្វីៗ ដែលគួរឲ្យក្រសួងនេះដឹង ដូចជា លោកនឹងធ្វើពិធីតែងតាំងនោះ នៅត្រង់កន្លែងណា លោកនឹងតែងតាំងអ្នកទាំងពីរឲ្យដឹកនាំភូមិភាគណា។ល។»។*

ក្នុងលិខិតមានសេចក្តីទូន្មាន ចំពោះអស់លោកអភិបាលឲ្យ «*បើកសាលារៀនគ្រប់ទីកន្លែងដោយ យកចិត្តទុកដាក់ជាទីបំផុត ហើយកុំឲ្យឃើតឃូរឲ្យសោះ*»។

### ២-ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសម្តេចប៉ាប

*«ព្រះសហគមន៍កាតូលិកទាំងមូល មានឯកភាពមាំមួន និងមានសហភាពរវាងគ្រីស្តបរិស័ទទាំងឡាយ លុះត្រាតែស្តាប់បញ្ជារបស់សម្តេចប៉ាប។ ប្រសិនបើអស់លោកស្តាប់បញ្ជារបស់សម្តេចប៉ាបនោះ គ្មានការឃ្លាតចាកពីសេចក្តីពិត ហើយគ្មានការបែកបាក់ក្នុងព្រះសហគមន៍ឡើយ(...)។ ដូច្នេះ អស់លោកត្រូវតែបង្ហាញឲ្យឃើញច្បាស់ថា អស់លោកសុខចិត្តធ្វើតាមឱវាទ របស់សម្តេចប៉ាប ក្រុងរ៉ូម គ្រប់ប្រការទាំងអស់ ដោយចិត្តស្រឡាញ់(...) ។*

*សូមកុំដោះស្រាយបញ្ហាសំខាន់ណាមួយ ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកផ្សាយជំនឿឲ្យសោះ។ សូមធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍ជាអក្សរជូនក្រសួងនោះ អំពីអ្វីៗដែលលោកបានធ្វើនៅក្នុងកិច្ចការ របស់លោក ទៅតាមកាលៈទេសៈដែលលោកជួបប្រទះ» ។*

មានពាក្យទូន្មានជាក់លាក់ ឲ្យបញ្ជូនដំណឹងទៅសម្តេចប៉ាបថែមទៀតផង។

### ៣-ត្រូវចៀសវាងកុំជ្រៀតជ្រែកចូលក្នុងរឿងនយោបាយ

*«ប្រសិនជាមានក្សត្រអង្គណាមួយឬ ឬមន្ត្រីណាមួយ ដែលបានស្តាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ ហើយដែលមានព្រះទ័យអនុគ្រោះចំពោះអស់លោក និងចំពោះគ្រីស្តបសាសនា សូមអស់លោកថ្លែងអំណរព្រះគុណ។ ក៏ប៉ុន្តែក្រែងលោមានអ្នកដ៏ទៃច្រណែន សូមអស់លោកកុំទាមទារឯកសិទ្ធអ្វីឲ្យសោះ កុំសុំឲ្យគ្រីស្តបរិស័ទរួចខ្លួនពីពន្ធដារ កុំឲ្យមានតុលាការពិសេស សម្រាប់វិនិច្ឆ័យគ្រីស្តបរិស័ទឡើយ។ សូមអស់លោក ជៀសវាងកុំធ្វើឲ្យព្រះមហាក្សត្របារម្ភថា នឹងបាត់អំណាច ឬបាត់សិទ្ធរបស់ព្រះអង្គ(...)។*

*សូមអស់លោកកុំលូកដៃចូលក្នុងរឿងនយោបាយ ឬកិច្ចការរដ្ឋអំណាចជាដាច់ខាត។ សូមកុំទទួលមុខតំណែងរដ្ឋការណាមួយសោះឡើយ ទោះបីគេសុំអស់លោកជាផ្លូវការឲ្យកាន់កាន់មុខតំណែងនោះក្តី ទោះបីគេរំខាននិងទទូចអង្វរករអស់លោកក្តី ក៏កុំទទួលជាដាច់ខាត(...)។ ទោះបីជាអស់លោមើលឃើញថា ការកាន់កាប់មុខដំណែងនោះ ធ្វើឲ្យមានក្តីសង្ឃឹមថា គ្រីស្តសាសនានឹងរីកចម្រើនឡើងក៏ដោយ ក៏អស់លោកត្រូវយល់ថា ការកាន់កាប់មុខតំណែងបែបនេះនឹង បណ្តាលឲ្យខូចប្រយោជន៍គ្រីស្តសាសនា និងបង្វែរបូជាចារ្យងាកចេញពី*

ភារកិច្ចរបស់ខ្លួនផ្ទាល់តែប៉ុណ្ណោះ។

សូមធ្វើឲ្យប្រជាជនទូទៅដឹងច្បាស់ថា អស់លោកប្រាថ្នាចង់បានតែប្រយោជន៍ខាងសាសនា និងចង់សង្គ្រោះមនុស្សប៉ុណ្ណោះ។ ត្រូវធ្វើឲ្យមនុស្សផងទាំងពួងដឹងថា អស់លោកគិតតែពីរកធម៌អាថ៌ ក្នុងគ្រប់កិច្ចការទាំងអស់ ដែលលោកប្រព្រឹត្ត និងឥតមានគិតគូររកអ្វីផ្សេងទៀតឡើយ(...)។

ក៏ប៉ុន្តែប្រសិនបើមានស្ដេចអង្គណាមួយ ត្រូវការសុំយោបល់ពីអស់លោក ពេលនោះ សូមអស់លោកបញ្ចេញយោបល់ត្រឹមត្រូវ ដែលមានខ្លឹមសារតាមធម៌អាថ៌ ថ្វាយស្ដេចអង្គនោះ ដោយស្មោះត្រង់ទៅ(...) លុះត្រាតែស្ដេចនោះអង្វរជាច្រើនជាដង។ ម្យ៉ាងទៀត អស់លោកត្រូវយកពាក្យហាមប្រាមរបស់យើងនេះ ថ្វាយស្ដេចនោះផង។

សូមអស់លោក ទូន្មានប្រជាជនទាំងពួង ឲ្យចេះស្ដាប់បង្គាប់ព្រះមហាក្សត្ររបស់គេ ទោះបី ស្ដេចនោះតឹងរឹងក៏ដោយ។ ទាំងនៅផ្ទះក្ដី ទាំងនៅទីសាធារណៈក្ដី សូមអស់លោកអង្វរព្រះជាម្ចាស់ ដោយស្មោះអស់ពីចិត្ត សូមទ្រង់ប្រទានពរស្ដេចទាំងនោះ ឲ្យបានសម្បូរសប្បាយ រុងរឿង និងទទួលការសង្គ្រោះពីព្រះអង្គផង។ សូមអស់លោកកុំរិះគន់កិច្ចការដែលស្ដេចទាំងនោះប្រព្រឹត្តឲ្យសោះ ទោះបីស្ដេចទាំងនោះ បានធ្វើទុក្ខបុកម្នេញអស់លោកក៏ដោយ។ សូមអស់លោកកុំត្អូញត្អែរដៀល ចំពោះកិរិយាមារយាទ សូមអស់លោកមានចិត្តអត់ធន់ខន្តី ហើយនៅស្ងៀមស្ងាត់ទៅ រង់ចាំពេលព្រះជាម្ចាស់យាងមកសម្រាលទុក្ខអស់លោក»។

### ៤- សូមជួយអស់លោក សម្របទៅតាមទំនៀមទម្លាប់ប្រពៃណីរបស់ប្រទេសនីមួយៗ

សូមកុំខ្នះខ្នែង កុំជំរុញជំរែកដេញដោលអ្នកប្រាជ្ញ បញ្ចុះបញ្ចូលប្រជាជនទាំងឡាយ ឲ្យដូរពិធី ដូរទំនៀមទម្លាប់ ឬប្រពៃណីរបស់ពួកគេសោះឡើយ លើកលែងតែទំនៀមទម្លាប់ណា ឬប្រពៃណីណាដែលមានលក្ខណៈផ្ទុយនឹងសាសនា ឬផ្ទុយនឹងសីលធម៌យ៉ាងច្បាស់។ យកប្រពៃណី និងទំនៀមទម្លាប់របស់ប្រទេសបារាំង ប្រទេសអេស្ប៉ាញ ប្រទេសអ៊ីតាលី ឬរបស់ប្រជាជាតិដទៃទៀតនៃទ្វីបអឺរ៉ុប មកបង្ខំឲ្យពួកចិនគោរពតាម គឺពិតជាអំពើមួយឆ្កួតលេលាមែន។ សូមកុំនាំប្រពៃណីរបស់យើង ទៅបញ្ចូលក្នុងស្រុកទាំងនោះឡើយ សូមនាំជំនឿលើព្រះជាម្ចាស់វិញ។

*ជំនឿនេះមិនប្រកាន់ ឬច្រានចោលពិធី និងទំនៀមទម្លាប់របស់ប្រជាជនទាំងនោះឡើយ ឲ្យតែទំនៀមទម្លាប់ទាំងនោះ មិនមានលក្ខណៈគួរឲ្យស្អប់ខ្ពើមទេ។ ជំនឿនេះ រឹតតែនាំឲ្យពួកគេខំថែរក្សាការពារពិធីនិងប្រពៃណីទាំងអស់នោះ។ មនុស្សទាំងអស់តែងតែស្រឡាញ់ តែងតែគោរពប្រពៃណីទាំងប៉ុន្មានរបស់ប្រទេសខ្លួន និងលើកតម្កើងប្រទេសរបស់ខ្លួនលើសអ្វីៗទាំងអស់ក្នុងលោកនេះ។ ដូច្នេះ គ្មានហេតុណាបណ្ដាលឲ្យមនុស្សឃ្លាតឆ្ងាយពីជំនឿ ឬឲ្យគេស្អប់ខ្ពើមគ្រីស្តសាសនាខ្លាំងជាងការផ្លាស់ប្ដូរទំនៀមទម្លាប់ផ្ទាល់របស់ប្រជាជនណាមួយឡើយ ជាពិសេសការផ្លាស់ប្ដូរប្រពៃណីដែលពួកគេធ្លាប់គោរពតាំពីបុព្វបុរសមកនោះ។ ប្រសិនបើអស់លោក បំបាត់ទំនៀមទម្លាប់ និងប្រពៃណីរបស់ប្រទេសណាមួយ ហើយនាំយកប្រពៃណីរបស់ស្រុកអស់លោក ទៅដាក់ជំនួសឲ្យគេកាន់ តើអរិយធម៌របស់ស្រុកនោះ នឹងទៅជាយ៉ាងណា? ដូច្នេះ សូមអស់លោកកុំយកទំនៀមទម្លាប់ និងប្រពៃណីរបស់ប្រជាជនទាំងនោះ មកប្រៀបធៀបនឹងទំនៀមទម្លាប់ប្រពៃណីអឺរ៉ុបឲ្យសោះ ផ្ទុយទៅវិញ សូមអស់លោកយកចិត្តទុកដាក់សម្របខ្លួនទៅតាមទម្លាប់អ្នកស្រុកនោះ។ សូមស្ញើចសរសើរ ចំពោះប្រពៃណីណា ដែលគួរស្ញើចសរសើរ។ ប្រពៃណីណាដែលមិនគួរសរសើរអស់លោក មិនត្រូវសរសើរទេ។ កុំប្រព្រឹត្តដូចពួកអ្នកបញ្ចោរអែបអប តែអស់លោកត្រូវប្រយ័ត្ន កុំចោទប្រកាន់ កុំដាក់ទោសដោយងាយ ឬដោយជ្រុលហួសឲ្យសោះ។ ចំណែកឯទំនៀមទម្លាប់ទាំងពួងដែលពិតជាអាក្រក់មែនវិញ គប្បីជំទាស់នឹងទម្លាប់ទាំងអស់នោះ ដោយគ្រាន់តែគ្រវីក្បាល ឬដោយនៅស្ងៀម ប្រសើរជាងដោយប្រើពាក្យសម្ដី។ ប៉ុន្តែបើមានអ្នកស្ម័គ្រចិត្តទទួលសេចក្ដីពិត ត្រូវឆ្លៀតឱកាសផ្សេងៗ ដើម្បីណែនាំពួកគេលះបង់ចោលទម្លាប់អាក្រក់នេះបន្តិចម្ដងៗ»។*

បណ្ដាំចុងក្រោយនេះ ខុសប្លែកពីរបៀបប្រតិបត្តិរបស់សាសនទូត ដែលផ្សាយគ្រីស្តសាសនានៅសម័យនោះ។ តែពាក្យបញ្ជារបស់សម្ដេចប៉ាប ក្នុងគ្រប់កិច្ចការទាំងនោះ មិនបណ្ដោយឲ្យអស់លោកអភិបាលអនុវត្តតាមបំណងរបស់អស់លោកបានទេ។ ឧទាហរណ៍ មុនលោកអភិបាលទាំងបីរូបចេញដំណើរទៅទ្វីបអាស៊ី អស់លោកសុំអនុញ្ញាតឲ្យប្រើភាសាចិនក្នុងពិធីបុណ្យនានា តែសម្ដេចប៉ាបបដិសេធ ហើយបង្ខំឲ្យយកភាសាឡាតាំងទៅប្រើវិញ ព្រោះសម្ដេចប៉ាបខ្លាចថា ការធ្វើពិធីបុណ្យតាមអរិយធម៌ជាតិនីមួយៗ បណ្ដាលឲ្យព្រះសហគមន៍បាក់បែក។ ក្រោយមកទៀតលោកឡាណូ (Laneau) ដែល

ទទួលមុខតំណែងជាអភិបាលព្រះសហគមន៍បន្តពីលោកឡាំប៊ែរដឺឡាម៉ុត សុំអនុញ្ញាតឲ្យអស់លោកបូជាចារ្យគ្រងស្បង់ចីពរ របស់ព្រះសង្ឃខាងពុទ្ធសាសនា។ សម្ដេចប៉ាបឆ្លើយថា៖«*ទេមិនព្រមជាដាច់ខាត សូម្បីតែពណ៌ក៏មិនបានដែរ* »។

## លោកអភិបាលប្រចាំក្រុងអយុធ្យា

លោក សិលាឡាំប៊ែរ ដឺឡាម៉ុត (Pierre Lambert de la Motte) ចេញដំណើរពីក្រុងប៉ារីសនៅថ្ងៃ ១៨ មិថុនា ឆ្នាំ ១៦៦០ ជាមួយលោកដឺប៊ួរ៍ស (de Bourges) និងលោកដឺឌីយេ (Deydier)[៥]។ លោកទាំងបីនាក់ចាកចេញពីក្រុងម៉ាកសី (Marseille) ឆ្លងឆ្ពោះទៅកាន់កោះម៉ាល់ត៍ (Malte) កោះស៊ីប្រ៊ីស (Chypre) និងកំពង់ផែអាឡិចសង់ដ្រេត (Alexandrette) រួចដើរកាត់ប្រទេសស៊ីរី (Syrie) ប្រទេសអ៊ីរ៉ាក់ (Irak) ប្រទេសពែរស៍ (Perse) ជាមួយអ្នកធ្វើជំនួញ។ លោកទាំងបីនាក់នោះជិះសំពៅចេញពីផែអ័កមុស (Ormuz) ឆ្ពោះទៅកាន់ប្រទេសឥណ្ឌា។ លោកដើរតាមផ្លូវគោកកាត់ប្រទេសឥណ្ឌា រួចចុះដើរតាមនាវាវិញ រហូតដល់ក្រុងតេណាសេរីម (Ténassérim) ជាកំពង់ផែសៀមដ៏សំខាន់ក្នុងសម័យនោះ រួចក៏បន្តដំណើរតាមផ្លូវគោករហូតដល់ក្រុងអយុធ្យា (Ayuthya)។ លោកមកដល់ក្រុងនេះ នៅថ្ងៃ ២២ សីហា ១៦៦២។ លោកទាំងបីនាក់ធ្វើដំណើរដូច្នេះស្របទៅតាមពាក្យផ្ដែផ្ដាំរបស់ក្រសួងទទួលបន្ទុកផ្សាយជំនឿ ដើម្បីជៀសវាងមិនឲ្យជួបពួកព័រទុយហ្គាល់ដែលត្រួតត្រាលើសមុទ្រ និងកំពង់ផែទាំងឡាយនាសម័យនោះ។

រីឯលោកអភិបាលអ៊ីញ៉ាស កូតូឡិនឌី (Ignace Cotolendi) វិញ លោកបានចេញដំណើរក្នុងឆ្នាំ ១៦៦១ តាមផ្លូវដដែល ជាមួយបូជាចារ្យបួននាក់ទៀត។ ក្នុងចំណោមបូជាចារ្យទាំងបួននាក់នោះមានលោក លុយសឺវ៉េរ៉ុល (Louis Cheverul) ដែលមានដើមកំណើតនៅខេត្តរ៉ែន (Rennes) ប្រទេសបារាំង។ ប៉ុន្ដែ លោកអភិបាលបានទទួលមរណភាពនៅប្រទេសឥណ្ឌា ក្នុងជន្មាយុសាមសិបពីរឆ្នាំ។ មានបូជាចារ្យពីរនាក់ទទួលមរណភាពក្នុងពេលធ្វើដំណើរនោះដែរ។

ចំណែកឯលោកហ្វ្រង់ស្វ័រប៉ាល់លុយ (FranÇois Pallu) វិញ លោកចេញដំណើរពីក្រុងប៉ារីសនៅឆ្នាំ ១៦៦១ ជាមួយនឹងសាសនទូតប្រាំបួននាក់ទៀត។ ក្នុងចំណោមអ្នកទាំងនោះមានលោកលុយឡាណូ (Louis Laneau) ដែរ។ ក្រោយពីបានធ្វើដំណើរយ៉ាងសែនលំបាកអស់រយៈពេលពីឆ្នាំ បីអាទិត្យមក អស់លោកបានមកដល់ក្រុងអយុធ្យា ជារាជធានីនៃ

ប្រទេសសៀម នាថ្ងៃទី ២៤ មករា ឆ្នាំ ១៦៦៤។ តែក្នុងចំណោមអ្នកធ្វើដំណើរទាំងអស់នោះ មានគ្នាតែបីនាក់គត់ដែលសល់ពីស្លាប់។

ទោះបីសម្តេចប៉ាបបានចាត់លោកអភិបាលទាំងពីររូប ទៅណែនាំគ្រីស្តបរិស័ទនៅប្រទេសចិន នៅដែនកូសាំងស៊ីន និងដែនដីតុងកឹងក៏ដោយ ក៏លោកអភិបាលទាំងពីរបានតាំងទីលំនៅក្នុងក្រុងអយុធ្យា ជារាជធានីប្រទេសសៀមវិញ។ នាសម័យនោះ ក្នុងទ្វីបអាស៊ីទាំងមូល មានតែប្រទេសសៀមទេ ដែលមិនធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ។ ម្យ៉ាងទៀត នៅប្រទេសសៀម លោកអភិបាលពុំខ្លាចពួកព័រទុយហ្គាល់ ឬពួកហុលឡង់ឡើយ ព្រោះនៅស្រុកនោះ ពួកនេះមិនសូវមានគ្នាទេ។

ក្នុងឆ្នាំ ១៦៦៥ លោកទាំងពីររូប បានទទួលករណីកិច្ចណែនាំគ្រីស្តបរិស័ទនៅស្រុកសៀមដែរ។ សម្តេចប៉ាបបានប្រគល់ករណីកិច្ចនេះ មកលោកអ៊ីញ៉ាសកូតូឡិនឌី កាលពីមុន។ នៅពេលនោះ គ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ប្រទេសចម្ប៉ា ដែនកូសាំងស៊ីន និងប្រទេសសៀម ស្ថិតនៅក្រោមការណែនាំរបស់អភិបាលព្រះសហគមន៍តែម្នាក់។ ស្ថានភាពនេះ មានរហូតដល់ឆ្នាំ ១៦៧៩ គឺរហូតដល់ពេល មានអភិបាលម្នាក់ទទួលបន្ទុកតែលើប្រទេសសៀមប៉ុណ្ណោះ។

លោក ឡាំប៉ែរដឺឡាម៉ុត តែងរស់នៅក្រុងអយុធ្យា។ នៅទីនោះ លោកចាត់ចែងការផ្សាយគ្រីស្តសាសនា នៅលើដែនដីទាំងអស់ដែលស្ថិតនៅក្នុងបន្ទុករបស់លោក។ រីឯលោកប៉ាល់លុយវិញ លោកបានចំណាយពេលជាច្រើន ក្នុងការធ្វើដំណើរ។ លោកមានភារកិច្ចទៅក្រុងរ៉ូមជាញឹកញយ ដើម្បីជម្រាបសម្តេចប៉ាប អំពីឧបសគ្គទាំងប៉ុន្មានដែលសាសនទូតជាអ្នកគ្រីស្តសាសនា តែងជួបប្រទះនៅក្នុងភារកិច្ចរបស់ខ្លួន។ លោកក៏ធ្វើដំណើរ ដើម្បីជូនដំណឹងដល់សប្បុរសជនជាអ្នកធ្វើអំណោយ ហើយជាពិសេស លោកទៅដាស់តឿនគ្រីស្តបរិស័ទ ឲ្យមានយុវជនស្ម័គ្រចិត្តធ្វើជាបូជាចារ្យ និងសាសនទូតផង។ ជួនកាល លោកត្រូវពួកភ្នាក់ងារអេស្ប៉ាញ៉ុល ដែលធ្វើការឲ្យ "សមាគមសហជីវិនព្រះយេស៊ូ" (Jésuites) ប្រចាំក្រុងម៉ានីលចាប់លោកចងដាក់ក្នុងសំពៅ រួចបញ្ជូនទៅក្រុងម៉ាឌ្រីតប្រទេសអេស្ប៉ាញ (Madrid) ដោយឆ្លងកាត់មហាសមុទ្រប៉ាស៊ីហ្វិក (Pacifigue) ប្រទេសម៉ិកស៊ីក (Mexigue) និងមហាសមុទ្រអាត្លង់ទិក (Atlantigue) ។

លោកអភិបាលព្រះសហគមន៍ បានជួបប្រទះនឹងឧបសគ្គផ្សេងៗដែលមានជាធម្មតាក្នុងការផ្សាយសាសនា។ លើសពីនេះទៀត លោកក៏ជួបប្រទះនឹងឧបសគ្គដែលបណ្ដាលមកពីស្ថានការណ៍នយោបាយដ៏ស្មុគស្មាញ ក្នុងសម័យនោះ ជាពិសេស លោកអភិបាលត្រូវក្រុមគ្រួសារបព្វជិតផ្សេងៗជំទាស់មិនព្រមទទួលស្គាល់មុខងាររបស់លោក។ អភិបាលព្រះសហគន៍ទាំងនោះ ជាតំណាងរបស់សម្ដេចប៉ាប ហើយបានទទួលភារកិច្ចតែងតាំងព្រះសហគមន៍កាតូលិកនៅទ្វីបអាស៊ី។ លោកគ្មានបំណងបម្រើរដ្ឋាភិបាលរបស់ប្រទេសលោកផ្ទាល់សោះឡើយ។ រីឯក្រុមគ្រួសារបព្វជិតព័រទុយហ្គាល់វិញ គេមានបំណងផ្សាយឥទ្ធិពលប្រទេសរបស់គេ។ ក្នុងចំណោមក្រុមគ្រួសារបព្វជិតទាំងនោះ សមាគមនសហជីវិនព្រះយេស៊ូ (Jésuites) មានចំនួនច្រើនជាងគេ និងស្វាហាប់ជាងគេផង។ ម្យ៉ាងទៀតបព្វជិតទាំងនោះ មានបំណងនាំឲ្យមនុស្សម្នាក់ៗ ជាពិសេស នាំអ្នកកាន់អំណាចធំៗប្រែចិត្តគំនិតចូលគ្រីស្តសាសនា។ ផ្ទុយទៅវិញ អភិបាលព្រះសហគមន៍ បានទទួលភារកិច្ចបង្កើត និងចាត់ចែងព្រះសហគមន៍ឲ្យបានស្ថិតស្ថេរ និងប្រកបដោយរបៀបរៀបរយត្រឹមត្រូវក្នុងស្រុកនីមួយៗ។ លោកឡាំប៊ែរដឺឡាម៉ុត តែងបន្ទោសបព្វជិតព័រទុយហ្គាល់ទាំងនោះថា អស់លោកប្រើមធ្យោមិនសមរម្យ ដើម្បីបញ្ចុះបញ្ចូលអ្នកស្រុក ឲ្យចូលគ្រីស្តសាសនា ដូចជា អស់លោករស់នៅជិតវាំងស្ដេច ឬចូលចិត្តទាក់ទងជាមួយពួកបញ្ញវន្តជាដើម។ ចំណែកលោកដឺឡាម៉ុតវិញ លោកទូន្មានឲ្យអស់លោកប្រើតែមធ្យោបាយខាងសាសនា ដូចជា អង្វរព្រះជាម្ចាស់ ពន្យល់ព្រះបន្ទូលរបស់ព្រះអង្គ និងតមអាហារតែប៉ុណ្ណោះ។

សម្ដេចប៉ាប បានប្រៀនប្រដៅលោកអភិបាលថា ត្រូវហាមបព្វជិតមិនឲ្យរកស៊ីធ្វើជំនួញ។ បើតាមយោបល់របស់សហជីវិនព្រះយេស៊ូវិញ អ្នកប្រកាសដំណឹងល្អ ត្រូវតែធ្វើជំនួញជួញដូរ ដើម្បីទ្រទ្រង់ជីវភាព ព្រោះសម្ដេចប៉ាបបានចាត់អស់លោកមកតែមិនផ្គត់ផ្គង់ជីវភាពរស់នៅរបស់អស់លោកទេ។

ការខ្វែងគំនិតគ្នារបៀបនេះ បានរារាំងការផ្សាយគ្រីស្តសាសនានៅទ្វីបអាសីក្នុងអំឡុងជិតពីរសតវត្ស។ ក៏ប៉ុន្តែ ទោះបីព្រះសហគមន៍បែកបាក់យ៉ាងនេះក៏ដោយ ក៏មានបូជាចារ្យជាច្រើនរូបបានបំពេញមុខងារដ៏លំបាករបស់ខ្លួនយ៉ាងល្អប្រសើរ រហូតដល់ចប់ចុងចប់ដើមដែរ។

**លោកលុយសីវ៉្រឺល** ( Louis Chevreul )

នៅឆ្នាំ ១៦៦៤ លោកឡាំប៊ែរដឺឡាម៉ុត ចាត់លោកលុយសីវ្រើលទៅក្រុងហ្វៃហ្វើ (FaifÖ) នៅដែនដីកូសាំងស៊ីន ដើម្បីសួរសុខទុក្ខគ្រីស្តបរិស័ទកាតូលិកជប៉ុនចំនួនបីរយនាក់ ដែលបានភៀសខ្លួនមកជ្រកកោននៅក្រុងនោះ និងដើម្បីប្រកាសដំណឹងល្អដល់អ្នកស្រុកកូសាំងស៊ីនផង។ តែអ្នកកាន់អំណាចដែនដីកូសាំងស៊ីននេះ កំពង់ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ។ លោកត្រូវភៀសខ្លួនចេញពីក្រុងហ្វៃហ្វើត្រឡប់ទៅក្រុងអយុធ្យាវិញ។ ឆ្នាំបន្ទាប់មក លោកចេញទៅក្រុងហ្វៃហ្វើម្តងទៀត។ ក្នុងពេលធ្វើដំណើរ លោកធ្លាក់ខ្លួនឈឺជាទម្ងន់។ អ្នកធ្វើដំណើរជាមួយ ឲ្យលោកចុះនៅកំពង់ផែខ្មែរឈ្មោះបារៀ(៦) ផ្ញើគ្រួសារគ្រីស្តបរិស័ទវៀតណាមមួយ ទទួលយកឲ្យស្នាក់អាស្រ័យនៅជាមួយ និងថែទាំលោករហូតដល់បានជាសះស្បើយ។ បន្ទាប់មក គេនាំលោកមកក្រុងភ្នំពេញវិញ។ នៅទីនោះ លោកបានជួបនឹងជនជាតិព័រទុយហ្គាល់ ៤00 នាក់ ដែលត្រូវពួកហុលឡង់ដេញចេញពីក្រុងម៉ាកាសាមក ហើយដែលបានតាំងទីលំនៅជុំវិញព្រះវិហារមួយដ៏ធំ ក្រោមដូចជាទេវទូតមួយរូប ព្រោះគាត់ចាស់ជរាណាស់ទៅហើយ (លោកមានជន្មាយុ៦៤ឆ្នាំ!) ហើយមានជម្ងឺផងនោះ។ លោកក៏សុំឲ្យលោកសីវ្រើល ទទួលតំណែងរបស់គាត់។ ដូច្នេះ គាត់មានលទ្ធភាពអាចវិលត្រឡប់ទៅកាន់ទីក្រុងហ្គោអា (Goa) វិញ។

បីខែក្រោយមក ពួកចិនមួយក្រុមបានឈ្លោះប្រកែកជាមួយពួកកូសាំងស៊ីន ដែលរស់នៅជ្រោយចង្វារ។ នៅក្នុងចំណោមពួកកូសាំងស៊ីនទាំងនោះ មានគ្រីស្តបរិស័ទចំនួនហាសិបនាក់ផង។ យប់មួយ ពួកចោរប្លន់ចិនបានវាយលុកចូលភូមិវៀតណាម សម្លាប់ប្រជាជនរង្គាល ហើយក្នុងចំណោមគ្រីស្តបរិស័ទទាំងនោះ មានតែបួននាក់ប៉ុណ្ណោះដែលបានរួចជីវិត។ ពួកកូសាំងស៊ីន បានចោទលោកសីវ្រើលថា៖ មកពីលោកទើបបងប្អូនគេត្រូវចោរសម្លាប់ចោលដូច្នេះ ពួកគេហាមផ្តាច់មិនឲ្យលោកចូលដែនដីកូសាំងស៊ីនជាដាច់ខាត។ ដូច្នេះ តាំងពីពេលនោះមក លោកបានបម្រើប្រជាជនកម្ពុជាអស់ពីសមត្ថភាព។

លោក សីវ្រើលចេញទៅភូមិពញាឮ ដើម្បីជួបនឹងលោក រ៉ូសា (Rocha) ។ លោករ៉ូសានេះជាសមាជិកសមាគមសហជីវិនព្រះយេស៊ូ មានដើមកំណើតនៅស្រុកសាវ៉ៃ (Savoie)។ លោករស់នៅជាមួយនឹងពួកព័រទុយហ្គាល់មួយក្រុម ដែលភៀសខ្លួនមកពីក្រុងម៉ាកាសា

នោះ។ លោកបូជាចារ្យទាំងពីរនាក់ត្រូវរ៉ូវគ្នាណាស់ ហើយគោរពគ្នាទៅវិញទៅមក។ ពេលនោះ លោកលុយសឺវ្រើលចាប់ផ្ដើម ប្រកាសដំណឹងល្អដល់ជនជាតិខ្មែរ ប៉ុន្តែ លោកគ្អញគ្អែរ ព្រោះ "*រកអ្នកបកប្រែភាសា ដែលចេះពាក្យពេចន៍ក្នុងគ្រីស្តសាសនា ឲ្យបានល្អមគួរសមពុំបាន*"។

លោកស្ញើចសរសើរចំពោះជនជាតិខ្មែរជាខ្លាំង ៖

*«ជនទាំងអស់ដែលខ្ញុំបានជួបនោះ សុទ្ធតែមានចរិតស្លូតនិងចេះគួរសម។ អ្នកទាំងនេះ សុភាពរាបសារណាស់។ យើងគួរចាត់ចរិតលក្ខណៈទាំងនោះទុកជាព្រះអំណោយទានដ៏ថ្លៃថ្លាពីព្រះជាម្ចាស់ ដើម្បីឲ្យយើងតែងតាំងគ្រីស្តសាសនាបាន។ អ្នកទាំងនេះចេះទទួលភ្ញៀវយ៉ាងរាក់ទាក់ជាទីបំផុត។ ទោះបីនៅភូមិណាក៏ដោយឬនៅក្នុងព្រៃស្បាតក៏ដោយ អ្នកទាំងនេះធ្លាប់ទទួលអ្នកធ្វើដំណើរទាំងអស់ ដោយចិត្តស្មោះ។ គេអង្វរអ្នកដំណើរឲ្យស្នាក់អាស្រ័យនៅផ្ទះរបស់ខ្លួន និងប្រគល់អ្វីៗទាំងអស់ដែលអ្នកដំណើរត្រូវការ ដោយឥតគិតថ្លៃ»*។

លោកសឺវ្រើល ក៏ចាប់អារម្មណ៍ខ្លាំង ចំពោះរបៀបរស់នៅរបស់លោកសង្ឃនៃពុទ្ធសាសនាដែរ។ របៀបរស់នៅរបស់លោកសង្ឃ សមស្របទៅនឹងចិត្តគំនិតរបស់បព្វជិតអឺរ៉ុប នាសម័យនោះ៖

*«របៀបរស់នៅរបស់លោកសង្ឃ មានលក្ខណៈក្រខ្សត់និងតឹងរឹងក្រៃលែង។ បើគិតតែពីខាងក្រៅ លោកសង្ឃទាំងនោះមិនចាញ់បព្វជិតទាំងឡាយនៃព្រះសហគមន៍កាទូលិកយើង ដែលបានកែទម្រង់វិន័យយ៉ាងតឹងរឹងខ្លាំងឡើយ។ លោកសង្ឃតែងបិណ្ឌបាត ដើម្បីបានចង្ហាន់ឆាន់ គ្មានអ្វីជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ ហើយពុំមានសិទ្ធិជំនួញឡើយ។ លោកសង្ឃពុំបានឆាន់សោះ ពេលល្ងាច លោកមិនឆាន់អ្វីជារបស់ឆ្អិនទេ គឺឆាន់តែផ្លែឈើស្រស់បន្តិចបន្តួចប៉ុណ្ណោះ។ យើងអាចនិយាយថា លោកសង្ឃទាំងនោះ តមអាហារជានិច្ចនិរន្តរ៍ និងដោយទៀតទាត់...»*។

*«គួរគប្បីតែសាសនទូត ដែលមានបំណងចង់ឲ្យជនជាតិខ្មែរស្គាល់គ្រីស្តសាសនា យកចិត្តទុកដាក់រស់នៅយ៉ាងតឹងរឹងដូចលោកសង្ឃទាំងនោះ»*[៧]។

លោកសឺវ្រើលមិនគ្រាន់តែស្ញើចសរសើរព្រះសង្ឃប៉ុណ្ណោះទេ គឺលោកយកគម្រាប់និងធ្វើតាមទៀតដូច លោករ៉ូសា បានសង្កេតឃើញ៖

*«លោកសឺវ្រើលប្រកាសដំណឹងល្អគ្មានឈប់គ្មានឈរទេ។ លោកក៏តមអាហាររាល់ថ្ងៃដែរ។ លោកពុំមានទទួលអ្វីអំពីគ្រីស្តបរិស័ទសោះឡើយ(...)។ លោកធ្វើជាគំរូល្អ គួរឲ្យប្រតិបត្តិតាម។*

លោកលុយសឺវ្រើលបានឮគេនិយាយពី "*អង្គរ*" តាំងពីយូរឆ្នាំមកហើយ មុនពួកអ្នកស្រាវស្រាវវត្ថុបូរាណ នាសតវត្សទី ១៩ ម្ល៉េះ៖

*«មានប្រាសាទចាស់បូរាណដ៏ល្បីល្បាញពីពញាឮ បើធ្វើដំណើរដោយថ្មើរជើង គឺប្រាំបីថ្ងៃទើបដល់។ ខ្ញុំសង្ឃឹមថា នឹងបានធ្វើដំណើរទៅទីនោះដែរ។ ប្រាសាទនោះ មានឈ្មោះល្បីរន្ទឺលើសប្រាសាទដ៏ល្បីល្បាញទាំងឡាយ ដែលមានក្នុងប្រាំ ឬប្រាំមួយរាជាណាចក្រធំៗ គឺមានឈ្មោះល្បីដូចព្រះវិហារនៅក្រុងរ៉ូមក្នុងចំណោមគ្រីស្តបរិស័ទទាំងឡាយយ៉ាងនោះដែរ។ នៅទីនោះ មានបណ្ឌិតខាងធម្មវិន័យ។ អ្នកស្រុកតែងតែទទួលយកទំនាយពីបណ្ឌិតទាំងនោះ ហើយនិងសេចក្តីសម្រេចខាងសាសនា ដូចយើងជាគ្រីស្តបរិស័ទទទួលអំពី សម្តេចប៉ាបដែរ។ ប្រាសាទនោះ មានឈ្មោះថា "អង្គរ"...»។*

ដោយលោកសឺវ្រើលពុំចេះនិយាយភាសាខ្មែរ លោកក៏ងាកប្រកាសដំណឹងល្អដល់ពួកកូសាំងស៊ីនវិញ ជាហេតុធ្វើឲ្យលោកអង់ទាន់ដឺម៉ូរ៉េ (Antoine de Morais) មានសេចក្តីច្រណែនឈ្នានីស។

លោកម៉ូរ៉េនេះ ជាសមាជិកសមាគមសហជីវិនព្រះយេស៊ូ ជាតិព័រទុយហ្គាល់ម្នាក់ រស់នៅឯរាជវាំងលង្វែក។ នៅឆ្នាំ ១៦៧០ លោកចាត់គ្នាគាត់មួយក្រុមចាប់លោកសឺវ្រើល បញ្ជូនទៅដាក់គុកនៅឯម៉ាកាវ (Macao) រួចក្រោយមក បញ្ជូនទៅតុលាការសាសនានៅក្រុងហ្គោអា (Goa)។ គេចោទលោកថា លោកបានមកប្រកាសដំណឹងល្អតាមបញ្ជារបស់សម្តេចប៉ាប ដោយគ្មានច្បាប់អនុញ្ញាតពីព្រះករុណា ព្រះចៅរាជាណាចក្រព័រទុយហ្គាល់។ ពេលកាត់ក្តី តុលាការលែងឲ្យលោកសឺវ្រើលឲ្យរួចខ្លួន។ លោកវិលត្រឡប់មកកាន់ប្រទេសសៀមវិញក្នុងឆ្នាំ ១៦៧២។ ពេលនោះ លោកកើតទុក្ខព្រួយ ថយកម្លាំង ហើយបានចំណាយពេលវេលា អធិដ្ឋាន និងសូមអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់ព្រះសហគមន៍ក្នុងស្រុកទាំងឡាយ និងប្រទានពរដល់អ្នកបង្កើតព្រះសហគមន៍ទាំងនោះផង។ កាល់លោកប៉ាលុយឃើញមិត្តរបស់លោកឈឺ ព្រោះតែគេធ្វើបាននោះ លោកក៏

ប្រញាប់ចាត់ទូតម្នាក់ដំឆើតទៅក្រុងរ៉ូម ដើម្បីឲ្យក្រុមបព្វជិត ឈប់ធ្វើនូវអំពើទុច្ចរិតដូច្នេះ តែគ្មានបានទទួលលទ្ធផលអ្វីឡើយ។ លោកលុយសីវ្រើលទទួលមរណភាពក្នុងឆ្នាំ ១៦៨៣។

### គ្រីស្តបរិស័ទរស់ទនៃគ្រូនា

លោកលុយឡាណូ (Louis Laneau) ដែលបានរួមដំណើរជាមួយលោកហ្វ្រង់ស្វ័រប៉ាល់លុយ (François Pallu) បានទទួលដំណែងជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសសៀមបន្តពីលោកឡាំប៊ែរដឺឡាម៉ុត។ លោកក៏គ្រប់គ្រងព្រះសហគមន៍នៅដែនកូសាំងស៊ីន និងនៅកម្ពុជាផងដែរ។ នៅចុងឆ្នាំ ១៦៨០ លោកចាត់លោក ឡឺន័រ (Lenoir) ទៅប្រទេសកម្ពុជា។ លោកឡឺន័រត្រូវបានព័រទុយហ្គាល់ធ្វើបាប ព្រោះលោកបានស្តីបន្ទោសពួកគេថាជាមនុស្សខិលខូច។ លោកបានបញ្ឈឺចិត្តគ្រីស្តបរិស័ទព័រទុយហ្គាល់ ដោយទៅរស់នៅក្នុងភូមិមួយ ដែលមានតែពួកកូសាំងស៊ីន ដូច្នេះលោកត្រូវវិលត្រឡប់មកកាន់ក្រុងបាងកកវិញ។

ក្នុងឆ្នាំ ១៦៨២ លោកឡាណូចាត់បូជាចារ្យពីរនាក់ទៀតទៅប្រទេសកម្ពុជា គឺលោកយ៉ូហានស៊ើនូ (Jean Genoud) អាយុ ៣១ ឆ្នាំ ជាបូជាចារ្យជាតិស្វ៊ីស និងជាសមាជិកក្រុមសមាគមសាសនទូតក្រៅប្រទេស (Missions Etrangères de Paris) និងលោកលុយដឺឡាម៉ែរដឺឌីយើ (Louis de la Mère de Dieu) ជាបូជាចារ្យ ហ្វ្រង់ស៊ីស្កាំងជាតិព័រទុយហ្គាល់ អាយុ ៦០ ឆ្នាំ ដែលបានរៀនវិជ្ជាពេទ្យ និងវិជ្ជាវះកាត់ នៅក្រុងលីសបោ៉ន (Lisbonne)។ នៅស្រុកខ្មែរ លោកទាំងពីរបានជួបលោក អ៊ីញ៉ាសសង់ហ្គា (Ignace Sanga) ជាសមាជិកសមាគមសហជីវិនព្រះយេស៊ូ ជាតិជប៉ុន ដែលរស់នៅក្នុងប្រទេសកម្ពុជាបីឆ្នាំមកហើយ។ លោកសង់ហ្គានេះ ចេះនិយាយភាសាខ្មែរផង។ ព្រះមហាក្សត្រទទួលលោកទាំងពីរយ៉ាងរាក់ទាក់។ បន្ទាប់មក លោកទាំងពីរក៏ទៅរស់នៅក្នុងជំរុំព័រទុយហ្គាល់ឯពញាឮ។ នៅទីនោះ លោកទាំងពីរបានសង់ព្រះវិហារមួយ និងមន្ទីរពេទ្យមួយ។ លោកយ៉ូហានស៊ើនូរៀនភាសា និងអក្សរខ្មែរ។ ដោយលោកមានសញ្ជាតិជាស្វ៊ីស គ្មាននរណារករឿងលោកទេ។ ចំណែក លោកលុដឺឡាម៉ែរដឺឌីយើវិញ លោកយកចិត្តទុកដាក់ណែនាំជនរួមជាតិរបស់លោក ឲ្យត្រឡប់មកក្នុងគន្លងធម៌វិញ ហើយនិងព្យាបាលអ្នកជម្ងឺផង។

ជនជាតិខ្មែរជាច្រើន ទទួលការព្យាបាលពីលោកដោយឥតគិតថ្លៃ ហើយបានជាសះស្បើយថែមទៀត។ មានជនជាតិខ្លះ សុំរៀនធម៌ និងសូមទទួលពិធីជ្រមុជទឹកដែរ។ ចំនួនអ្នកទទួលការអប់រំចូលគ្រីស្តសាសនានោះ ចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ក៏ប៉ុន្តែ ពួកចោរប្លន់តែងចូលវាយលុកភូមិ និងព្រះវិហារជាញឹកញយ។ កងទ័ពវៀតណាមបានចូលវាយក្រុងឧដុង្គ ប្លន់ជំរំពួកព័រទុយហ្គាល់ ដុតទាំងផ្ទះអ្នកស្រុក ដុតទាំងព្រះវិហារ សម្លាប់រង្គាលមនុស្សមួយចំនួន ហើយបានបកសម្លៀកបំពាក់របស់លោកបូជាចារ្យទាំងពីរនោះចោល ដោយស្មានថា លោកទាំងពីរបានទទួលមរណកាលទៅហើយ។ មេដឹកនាំនាវាជាតិហុលឡង់ម្នាក់មានចិត្តមេត្តា បញ្ជាឲ្យគេសែងបូជាចារ្យទាំងពីរមកលើនាវារបស់គាត់ ដើម្បីព្យាបាល និងនាំលោកទាំងពីរ ទៅប្រទេសសៀមវិញ។ លោកលុយមិនបានជាសះស្បើយល្អទេ។ ចំណែកលោកយ៉ូហានស៊ើន្សវិញ លោកបានជាស្រួលបួលដូចដើម រួចត្រូវលោកអភិបាលព្រះសហគន៍ទាំងនោះចាត់ឲ្យទៅក្រុងប៉េគូ (Pègu) នាប្រទេសភូមា។ រីឯលោកអ៊ីញ៉ាសសង់ហ្គាវិញ ប្រហែលជាលាក់ខ្លួននៅក្នុងប្រទេសកម្ពុជារហូត។

ក្នុងសម័យនោះ ប្រទេសខ្មែរមានអសន្តិសុខជាប់ជានិច្ច ដោយមានកងទ័ពសៀម និងកងទ័ពវៀតណាមវាយលុក និងវាយឆ្មក់រួមគ្នា។ នៅក្នុងវង្វង់ព្រះសហគមន៍កាតូលិកក៏មានការប្រកួតប្រជែងគ្នាដែរ។

នៅដើមសតវត្សទី ១៨ គ្រីស្តបរិស័ទកាតូលិកព័រទុយហ្គាល់ បែកចេញជាពីរបក្ស គឺមានបក្សខាងសូអារេស (Soarez) ដែលជាអ្នកបោះប្រាក់កាសរបស់ព្រះរាជា និងជាអ្នកកាន់ជើងស្តេចព័រទុយហ្គាល់ និងបក្សមួយទៀតខាងឌីយ៉ាស (Diaz) ដែលជាអតីតបាលក្រុងសំបុក និងដែលសុខចិត្តទទួលស្គាល់ អំណាចរបស់អភិបាលព្រះសហគន៍។ ក្នុងឆ្នាំ ១៧១៣ លោកមីសែលដូណូ (Michel Dono) ជាបូជាចារ្យជាតិជប៉ុន (ឪពុកគាត់ជាគ្រីស្តបរិស័ទជាតិជប៉ុន ដែលចូលមករស់នៅក្នុងប្រទេសសៀមនោះ) មករស់នៅក្នុងភូមិពញាឮ។ មុនដំបូង លោកកាន់ជើងបក្សខាងសូអារេស តែក្រោយមក ដោយបានជ្រាបអំពីអំណាចរបស់លោកអភិបាលព្រះសហគមន៍ លោកក៏សុខចិត្តស្តាប់ លោកអភិបាលនោះ ជាហេតុបណ្តាលឲ្យពួកសូអារេសក្រោធខឹងខ្លាំង។ នារាត្រីខែភ្លឺមួយ ក្នុងខែមករា ឆ្នាំ ១៧១៧ លោកត្រូវគេលួចធ្វើឃាត ដោយកាប់ដាច់កំបុតជើងម្ខាង។ បីបួនម៉ោង

ក្រោយមក ក៏ទទួលមរណភាពទៅ។ គេសង្ស័យលើបុរសក្មេងម្នាក់ ឈ្មោះអាឡិច ស៊ីសហ្វេរ៉ៃរ៉ា (Alexis Fereira) ថាជាអ្នកប្រព្រឹត្តអំពើមនុស្សឃាតនេះ ដើម្បីជាប្រយោជន៍ដល់ក្រុមគ្រួសារសូអារេស។ គ្រីស្តបរិស័ទជាតិជប៉ុន ដែលរស់នៅក្បែរពញាឮ ក្តៅក្រហាយចំពោះរឿងមនុស្សឃាតនេះ ក៏បោះបង់ចោលព្រះសហគមន៍រហូត។ បក្សពួកឌីយ៉ាស និងគ្រីស្តបរិស័ទព័រទុយហ្គាល់ចំនួន មួយភាគបី ក៏បានចាកចេញពីពញាឮ ទៅតាំងទីលំនៅឯផ្អោល ចម្ងាយមួយគ.ម. កន្លះ ទៅខាងជើងទៀត។

ក្នុងឆ្នាំបន្ទាប់មក សមាជិកសមាគមនសហជីវិនព្រះយេស៊ូជាតិព័រទុយហ្គាល់ម្នាក់ឈ្មោះ អ៊ីញ៉ាសហ្វ្រង់កូ (Igace Franco) មកដល់ប្រទេសកម្ពុជា។ លោកកាន់ជើងគ្រីស្តបរិស័ទនៅផ្អោល។ លោកសុំពួកព័រទុយហ្គាល់នៅពញាឮ ឲ្យចុះចូលនឹងអភិបាលព្រះសហគមន៍។ តែពួកគេប្រកែកមិនព្រមធ្វើតាមលោកទេ។ ដូច្នេះ លោកបញ្ជាឲ្យពួកឌីយ៉ាស រឹបអូសយកគ្រឿងសម្រាប់ធ្វើពិធីបុណ្យចេញពីព្រះវិហារពញាឮ។ ពួកព្រះមាតា ដែលរស់នៅអន់ទន់ដឹម៉ុងតេរ៉ូយកពីក្រុមម៉ាកាសាមក កាលពីឆ្នាំ ១៦៦០ នោះ។ គ្រីស្តបរិស័ទភូមិទាំងពីរវាយគ្នាជាញឹកញយ រហូតដល់អ្នកថែរក្សាព្រះវិហារម្នាក់ត្រូវគេសម្លាប់។ ព្រះរាជាចាត់ភ្នាក់ងារនគរបាលមក មកធ្វើឲ្យមានសភាពការស្ងាត់ស្ងៀមឡើងវិញ។ បន្ទាប់ពីលោកអ៊ីញ៉ាសហ្វ្រង់កូ ទទួលមរណភាពទៅ ប្រទេសកម្ពុជាពុំបានបូជាចារ្យនៅអស់រយៈពេលប្រាំមួយឆ្នាំ។

នៅឆ្នាំ ១៧២៤ មានបូជាចារ្យហ្វ្រង់ស៊ីស្កាំងពីរនាក់ ដើមកំណើតនៅស្រុកបាវីយែរនៃប្រទេសអាឡឺម៉ាញ (Bavière) បានមកដល់ប្រទេសកម្ពុជា គឺលោកវ៉ាលែរីស្ត (Valère Rist) និងលោកសេរ៉ាហ្វាំង (Sèrap hin)។ លោករៀនភាសាខ្មែរទាំងពីរនាក់។ លោកសេរ៉ាហ្វាំងនៅប្រទេសកម្ពុជាអស់រយៈពេលដប់ឆ្នាំ ហើយលោកវ៉ាលែរីស្តដប់បីឆ្នាំ។ គ្មាននរណាដឹងច្បាស់អំពីកិច្ចការដែលលោកទាំងពីរបានធ្វើឡើយ គ្រាន់តែដឹងថា លោកទាំងពីរបានធ្វើឲ្យគ្រីស្តបរិស័ទនៅផ្អោល និងនៅពញាឮបានជានានឹងគ្នាឡើងវិញ។

នៅឆ្នាំ ១៧៣៣ លោកអភិបាលព្រះសហគមន៍ក្រុងម៉ាឡាកាក្រោធខឹង ដោយដឹងថាគ្រីស្តបរិស័ទខ្មែរ គេចផុតពីការគ្រប់គ្រង់របស់ព័រទុយហ្គាល់។ លោកក៏ចាត់បព្វជិតគណៈថេអាតាំង (Thèatins) ពីរនាក់មកប្រទេសកម្ពុជា គឺលោកអង់ដ្រេហ្វីណាល់ (Andrè Final) និងលោក សឺហ្គារីហ្គា (Segariga)។ លោកបូជាចារ្យទាំងពីរនាក់នេះ កាន់ជើង

គ្រីស្តបរិស័ទនៅពញាឮ។ ពេលនោះ គ្រីស្តបរិស័ទពញាឮទាំងនោះ ក៏ចាកចោលភូមិរបស់ខ្លួន ដើម្បីទៅនៅឯលង្វែក ជិតព្រះរាជវាំង។ បីឆ្នាំក្រោយមក ពួកគេទៅនៅភូមិប្រាំបីឆោម ចម្ងាយប្រាំបីគីឡូម៉ែត្រ ខាងត្បូងរាជធានីលង្វែក។ សង្គ្រាមសាសនាដ៏តូចនេះបានស្ងប់ស្រាកស្រាន្ត នៅចុងសតវត្សទី ១៨ ។

ក្នុងឆ្នាំ ១៧៣៦ ព្រះបាទសត្ថាទី ២ ប្រហែលបានសុំឲ្យលោករីស្ត ធ្វើពិធីបុណ្យជ្រមុជទឹកថ្វាយ ប៉ុន្តែ ទ្រង់បានសុំធ្វើតែក្នុងពេលដែលទ្រង់អាពាធខ្លាំង ជុំជាប់លើព្រះទែនចាំតែចូលទិវង្គត។ ទ្រង់បាតម្តថា បើទ្រង់ចូលគ្រីស្តសាសនានោះ នឹងអាចបណ្តាលឲ្យកើតវិបត្តិវឹកវរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លោកវ៉ាលែរីស្តទទួលមរណភាពនៅឆ្នាំ ១៧៣៧ គឺក្នុងឆ្នាំដែលលោកបានទទួលបន្ទុកជាអភិបាលឧបការីព្រះសហគមន៍។

នៅសម័យប្រហែលគ្នានោះ សមាជិកហ្វ្រង់ស៊ីស្កាំងម្នាក់ មានដើមកំណើតនៅក្រុងមីឡង់ ប្រទេសអ៊ីតាលី (Milan) គឺលោកសាំព្លីស៊ីយាងដឺឡាកុងសិបស្យុង (Simplicien de la Conception) មកប្រកាសដំណឹងល្អដល់ជនជាតិខ្មែរ ហើយមានជនជាតិខ្មែរជាច្រើនដែលជាទាសារបស់ពួកគ្រីស្តបរិស័ទទុយហ្គាល់ បានទទួលពិធីជ្រមុជទឹកពីលោក។

នៅពាក់កណ្តាលសតវត្សទី ១៨ ព្រះសហគមន៍នៃប្រទេសកម្ពុជា មានសភាពប្រហាក់ប្រហែលនឹង សភាពប្រទេសដែលបាក់បែកប្រេះឆា ដោយសារជម្លោះផ្ទៃក្នុង។ ទោះបីសម្តេចប៉ាបបានតតែងតាំង អភិបាលព្រះសហគមន៍ក្នុងនាមលោកក៏ដោយ ក៏ព្រះសហគមន៍ពុំអាចគេចចេញផុតពីអំណាចរបស់ស្តេច ប្រទេសអេស្ប៉ាញ និងប្រទេសព័រទុយហ្គាល់បានឡើយ។ ទោះបីមានបូជាចារ្យជាច្រើន បានប្រកាសដំណឹងល្អទៅជនជាតិខ្មែរក៏ដោយ ក៏គ្រីស្តបរិស័ទស្ទើរតែទាំងអស់ជាជនជាតិបរទេស គឺពួកព័រទុយហ្គាល់និងពួកកូសាំងស៊ីន។

---

(១) សម័យប្រជុំផ្សេងៗនៃមហាសន្និបាតសកលរបស់អស់លោកអភិបាលព្រះសហគមន៍ កើតមានឡើងជាបន្តបន្ទាប់តាំងពីឆ្នាំ ១៥៥៤ រហូតដល់ឆ្នាំ ១៥៦៣។

(២) ពួកអ្នកមិនមែនជាគ្រីស្តបរិស័ទ មានឈ្មោះថា "*អ្នកមិនជឿ* " (Infidèles) គឺថាពួកអ្នកដែលពុំមានជំនឿទៅលើព្រះជាម្ចាស់។

(៣) លោកឡាំប៉ែរដឺឡាម៉ុត បានទទួលបន្ទុកជាអភិបាលព្រះសហគមន៍ បេរីត (Bèryte) ជាអតីតទីស្នាក់ការរបស់អភិបាលព្រះសហគមន៍នៅប្រទេស ហ្វេនីស៊ី (Phènicie) ជាប់សមុទ្រមេឌីទេរ៉ាណេ (Mèditerranèe) ជិតក្រុងបីរូត (Beyrouth)។

(៤) ជាទីក្រុងមួយនៅប្រទេសអេស៊ីប (Egypte) ឬនៅប្រទេសលីបង់ (Liban) នាក្រុងបាល់បេក (Balbek) ។

(៥) មុននឹងចេញដំណើរ លោកអភិបាលទាំងបីរូប បានប្រគល់សិទ្ធិចាត់ចែងគ្រប់កិច្ចការសព្វសារពើក្នុងនាមរបស់លោក ឲ្យបូជាចារ្យជាមិត្តរបស់លោក គឺសូមអប់រំបូជាចារ្យនៃភូមិភាគ ក្នុងប្រទេសបារាំង ដែលប្រាថ្នាចង់ចេញទៅកាន់ទ្វីបអាស៊ីក្នុងឆ្នាំ ១៦៦៣។ អ្នកទទួលសិទ្ធិទាំងនោះបានបង្កើត "*ទេវវិទ្យាល័យសាសនទូតក្រៅប្រទេសនាក្រុងប៉ារី* " ដែលអប់រំសាសនទូតមួយចំនួនធំ គួរឲ្យចាប់អារម្មណ៍រហូតមកដល់សព្វថ្ងៃនេះ ។

៦) នៅជិតក្រុងវុងតាវ (Vung-Tau) សព្វថ្ងៃ។ គេស្គាល់ក្រុងនោះ តាមឈ្មោះថា ជ្រោយសាំងហ្សាក់ (Cap Saint Jancques) នាភាគនិរតីទីក្រុងហូជីមិញ។

(៧) លោក ឡាំប៉ែរដឺឡាម៉ុត បានទូន្មានដល់បូជាចារ្យទាំងឡាយ ឲ្យប្រកាន់ខ្ជាប់នូវរបៀបរស់នៅយ៉ាងតឹងរឹងដូច្នេះ ទុកជាមធ្យោបាយសម្រាប់បំពេញភារកិច្ចរបស់អស់លោក។

# រូបភាពផែនទី

## ជំពូកទី៥

# ការប្រកាសជំនឿលុះអដល់ជនជាតិខ្មែរ

នៅចន្លោះឆ្នាំ ១៧៥០-១៨៥០ ប្រទេសសៀមនិងប្រទេសវៀតណាមបានពង្រីកឥទ្ធិពលរបស់ខ្លួន និងបានវាតទីលេបយកទឹកដីប្រទេសកម្ពុជាមួយភាគធំ។ ជ្រោយឥណ្ឌូចិនកើតមានសង្គ្រាមឥតស្រាកស្រាន្ត។ ក្នុងសម័យដ៏សែនវេទនានោះ ព្រះសហគមន៍បានចាក់ឫសនៅក្នុងប្រទេសកម្ពុជាទោះបីមានឧបសគ្គច្រើនយ៉ាងណាក៏ដោយ។

**ពួក "អ្នកលេបទឹកដី" និង "ពួកអ្នកអាណាព្យាបាល"**

នាដើមសតវត្សទី ១៨ ប្រទេសវៀតណាម បានលេបប្រទេសចម្ប៉ា[១] រួចទៅហើយ។ បន្ទាប់ពីទ័ពវៀតណាមបានចូលមកតាំងទីលំ នៅក្នុងក្រុងព្រៃនគរ (Saigon) នោះ ពួកអាណិកជនវៀតណាមចូលមករស់នៅក្នុងដែនដីកូសាំងស៊ីនជាបន្តបន្ទាប់ឥតឈប់ឈរ គឺចូលមកនៅលើទឹកដីកំណើតរបស់ប្រជាជនខ្មែរតែម្តង។ ពេលពួកវៀតណាមកំពុងវាតទីលេបទឹកដីខ្មែរនោះ ប្រទេសសៀមក៏ពុំនៅស្ងៀមដែរ គឺពួកគេលើកទ័ពមកវាយប្រទេសកម្ពុជាជាច្រើនលើកជាច្រើនសា ដើម្បីបញ្ជាក់ថា ពួកគេក៏មានសិទ្ធិត្រួតត្រានគរខ្មែរដែរ។ ប៉ុន្តែ សកម្មភាពរបស់កងទ័ពសៀម ពុំបានធ្វើឲ្យឥទ្ធិពលវៀតណាមចុះអន់ថយ ទន់ខ្សោយឡើយ ផ្ទុយទៅវិញ វាកាន់តែរឹងមាំខ្លាំងឡើងថែមទៀត។ ឆ្លៀតពេលសៀមលុកលុយចូលស្រុកខ្មែរ កងទ័ពវៀតណាមបានលើកទ័ពចូលមកស្រុកខ្មែរដែរ ដោយយកលេសថាមក "*ជួយខ្មែរ* " ទប់ទល់ប្រឆាំងនឹងកងទ័ពសៀមឈ្លានពាន។ វៀតណាមក៏កាត់យកដីមួយភាគទុកជាកម្រៃក្នុងការមកជួយនោះ[២] ។

ដូច្នេះ នៅឆ្នាំ ១៧១៥ ប្រទេសវៀតណាម បានកាត់យកខេត្តពាម (ហាទៀង) ក្រុងរ៉ាចស្យា និងកោះត្រល់ (Phu Quoc) ទុកជាសគុណដែលបានជួយមហាក្សត្រខ្មែរ។

# រូបផែនទី

នៅឆ្នាំ ១៧៣១ ប្រទេសវៀតណាម បានរឹបយកខេត្តមេសរ (Mytho) និងខេត្តវិញឡុង (Vinh Long) រួចនៅឆ្នាំ ១៧៥៧ យកខេត្តផ្សារដែក (Sadec) និងខេត្តមាត់ជ្រូក (Chau Doc) ទៀត។ ក្នុងឆ្នាំបន្ទាប់មក ព្រះមហាក្សត្រខ្មែរ ព្រះបាទឧទ័យទី ២ បានប្រគល់ខេត្តព្រះត្រពាំង (Traving) ឲ្យវៀតណាមជាសគុណ ដោយគេមកជួយឲ្យទ្រង់ឡើងសោយរាជ្យ។

គ្រានោះ ប្រទេសសៀមជាប់ធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសភូមាដែលជាសត្រូវស្ទួរពូជរបស់ពួកគេ។ ក្នុងឆ្នាំ ១៧៦៧ ទ័ពភូមាបានវាយលុក និងដុតអយុធ្យារាជធានីសៀមនោះចោល ហើយបានធ្វើគុតព្រះមហាក្សត្រសៀមទៀតផង។ ឧត្តមសេនីយតាក់ស៊ីនដែលបានគេចខ្លួនផុតពីការកាប់សម្លាប់របស់រង្គាលនោះ បានឡើងសោយរាជ្យ ហើយត្រូវធ្វើសង្គ្រាមពេញមួយរជ្ជកាលរបស់ព្រះអង្គ (១៧៦៧-១៧៨២) ដើម្បីបង្រួបបង្រួមរាជាណាចក្រដែលបាក់បែក និងដើម្បីការពារព្រំដែនផង។ ក្នុងឆ្នាំ ១៧៦៩ ទ្រង់បានលើកក្សត្រមួយអង្គដែលទ្រង់ទំនុកបម្រុងឲ្យគ្រងរាជ្យលើប្រទេសកម្ពុជា ក៏ប៉ុន្តែស្ដេចនោះ ពុំបានសោយរាជ្យជាប់ឡើយ។ ក្នុងឆ្នាំបន្ទាប់មក កងទ័ពរបស់សៀមបានចូលលុកលុយប្រទេសកម្ពុជា តែត្រូវទទួលបរាជ័យជាថ្មីម្ដងទៀត។

ការវាយឆ្មក់ទាំងនោះ បណ្ដាលឲ្យជនជាតិខ្មែរ គ្រប់ទីកន្លែងទូទាំងប្រទេសរឹកររនិងច្របូលច្របល់យ៉ាងខ្លាំង។ ប្រជាជនរងទុក្ខវេទនា និងស្លាប់អស់ជាច្រើន។ កសិករត្រូវបង្ខំចិត្តបោះបង់ចោលស្រែចម្ការ ហើយនាំគ្នារត់លាក់ខ្លួននៅក្នុងព្រៃ ដើម្បីគេចពីកំណៃន។ តាមភូមិទាំងឡាយនៅខេត្តបាត់ដំបង និងខេត្តពោធិសាត់ នៅសល់តែក្មេងៗ និងមនុស្សចាស់ជរាទេ ព្រោះពេលកងទ័ពសៀមដកថយទៅវិញ គេបានចាប់បុរស និងស្ត្រីដែលមានកម្លាំងមាំមួន ធ្វើជាឈ្លើយសង្គ្រាមកៀរយកទៅ។ មិនតែប៉ុណ្ណោះ ប្រទេសកម្ពុជាត្រូវជំងឺអាសន្នរោគ និងជំងឺអុតធំរាតត្បាតគ្រប់ទីកន្លែង។

គ្រានោះ ប្រទេសកម្ពុជាបានរួចផុតពីអំណាចវៀតណាម ហើយធ្លាក់ចូលទៅក្រោមការត្រួតត្រារបស់សៀមវិញ។ ក្នុងអំឡុងពេល ១៥ ឆ្នាំ គឺចាប់ពីឆ្នាំ ១៧៧៥ ស្ដេចវៀតណាមត្រូវប្រឈមមុខ ទប់ទល់នឹងជនបះបោរមួយក្រុម ដឹកនាំដោយបងប្អូនបីនាក់ដែលមានដើមកំណើតនៅភូមិតៃសុន (Tay Son) ខាងត្បូងប្រវៀតណាម។ ពួកបះបោរដណ្ដើមយកបានក្រុងព្រៃនគរ ក្រុងហ្វេ និងស្រុកតុកកឹងទៀតផង។ ក្នុងពេល

ប្រទេសវៀតណាមកំពុងចុះទន់ខ្សោយនោះ ស្តេចខ្មែរមិនបានឆ្លៀតឱកាសដ៏ល្អនេះ ដណ្តើមឯករាជ្យមកវិញទេ តែបែរជាខំហែកហួរគ្នាឯងទៅវិញ។ ពេលនោះ ប្រទេសសៀមបានគាំទ្រព្រះអង្គម្ចាស់មួយអង្គ រួចបានកាត់យកខេត្តបាត់ដំបង ខេត្តអង្គរ ខេត្តមង្គលបូរី និងខេត្តស៊ីសុផុនទុកជាសគុណ។ ក្នុងឆ្នាំ ១៧៩២ ប្រទេសសៀមបានលើកឧកញ៉ា បែន ឲ្យគ្រួតត្រាប្រទេសកម្ពុជា។ លោកឧកញ៉ា បែន នេះ បានកៀរខ្មែរមួយម៉ឺន នាក់ឲ្យជីកព្រែកនៅបាងកក។ បីបួនឆ្នាំក្រោយមក នាហ្មឺនខ្មែរម្នាក់ទៀតឈ្មោះឧកញ៉ា ប៉ុក បញ្ជូនទាហានខ្មែរមួយចំនួនធំទៅជួយកងទ័ពសៀម ដែលកំពុងច្បាំងតទល់នឹងពួកភូមា។ លោកបានបញ្ជូនទាហានមួយចំនួនទៀត ទៅជួយព្រះចៅអធិរាជវៀតណាម ឈ្មោះយ៉ាឡុង ដើម្បីផ្ចាញ់ពួកតៃសុន។ លោកឧកញ៉ាប៉ុក បញ្ជូនទ័ពដូច្នេះគឺធ្វើតាមបញ្ជារបស់សៀម។ ទាហានខ្មែរដែលប្រកែកមិនព្រមចេញទៅច្បាំង ដើម្បីជាប្រយោជន៍ដល់ប្រទេសវៀតណាមតាមបញ្ជារបស់ឧកញ៉ាប៉ុកនោះត្រូវគេ សម្លាប់ចោលទាំងអស់(៣)។

ពួកសៀម និងពួកវៀតណាមមានបំណងតែមួយ គឺគ្រួតត្រាប្រទេសកម្ពុជាដូចគ្នាហើយចេះតែលុកលុយប្រទេសខ្មែរជាញឹកញាប់។ នៅឆ្នាំ ១៨១៣ ប្រទេសសៀមបានយកខេត្តម្លូព្រៃ ខេត្តទន្លេពៅ និងខេត្តស្ទឹងត្រែងធ្វើជាអាណាចក្ររបស់គេ។ អ្នកកាន់អំណាចវៀតណាមក្តៅក្រហាយជាខ្លាំង ចំពោះការលេបយកទឹកដីខ្មែរនេះ ហើយក៏បានលើកទ័ពចូលមកវាយលុកប្រទេសកម្ពុជា។ នៅឆ្នាំ ១៨១៣ ដដែលនេះ ព្រះចៅអធិរាជវៀតណាមបានបញ្ជាឲ្យអភិបាលក្រុងព្រៃនគរ ទៅគ្រួតត្រាលើប្រទេសខ្មែរទាំងមូលតែម្តង។ ទ្រង់បង្ខំឲ្យលោកឲ្យកែនជនជាតិខ្មែរជាច្រើនពាន់នាក់ ដើម្បីជីកព្រែកមួយប្រវែង ៥៣ គ.ម. គឺចាប់ពីទន្លេបាសាក់ក្រៅ រហូតដល់ឈូងសមុទ្រសៀម។ ព្រែកនោះ មានឈ្មោះថា "*ព្រែកជីកហាទៀង*" ហើយគេត្រូវជីកអស់រយៈ ពេល ៥ ឆ្នាំ ទើបហើយ។ ការជីកព្រែកនេះ បណ្តាលឲ្យស្លាប់មនុស្សអស់ច្រើនណាស់ ហើយរហូតមកទល់សព្វថ្ងៃកាលណាជនជាតិខ្មែរនឹងដល់ព្រែកជីកនេះ គេក្តុកក្តួលក្នុងចិត្តឥតឧបមា។ ក្នុងឆ្នាំ ១៨១៨ និងឆ្នាំ ១៨៣១ មានឧត្តមសេនីយវៀតណាមខ្លះ ចូលមកក្នុងប្រទេសកម្ពុជាដើម្បី «រៀបចំឲ្យមានរបៀបរៀបរយ»។ ពួកនេះ បានបង្ក្រាបប្រជាជនយ៉ាងម៉ឺងម៉ាត់និងតឹងរ៉ឹងជាទីបំផុត ។

ក្នុងសម័យព្រះមហាក្សត្រក្រុងហ្វេ កាន់កាប់ប្រទេសកម្ពុជានោះ ពួកឧត្តមសេនីយ វៀតណាម បានហូតពន្ធអាករពីប្រជាជនខ្មែរ ផ្លាស់ប្តូរអភិបាលខេត្ត និងបញ្ជាឲ្យ ព្រះរាជាខ្មែរអនុវត្តតាមក្បួនច្បាប់ របស់ព្រះចៅក្រុងហ្វេប្រការទាំងអស់។ ស្តេច និងមន្ត្រីខ្មែរត្រូវពាក់អាវផាយ និងត្រូវបួងសក់ជាផ្នួងតាមបែបវៀតណាមដែរ។ មន្ត្រី វៀតណាមម្នាក់នៅប្រចាំការក្នុងព្រះរាជវាំងខ្មែរជាអចិន្ត្រៃយ៍។ ព្រះមហាក្សត្រកម្ពុជា ត្រូវប្រគល់លិខិតចុតហ្មាយទាំងអស់ ឲ្យមន្ត្រីវៀតណាមនោះត្រួតពិនិត្យមើលជាមុន សិន ទើបចេញប្រើការជាផ្លូវការបាន។

នៅក្នុងរជ្ជកាលព្រះចៅអធិរាជវៀតណាម មិញ ម៉ាង (Minh Mang 1820-1841) ការ ត្រួតត្រារបស់វៀតណាមមានភាពកាចសាហាវ និងឃោរឃៅជាទីបំផុត។ ចាប់ពីសម័យ នោះមក ជនជាតិខ្មែរ តែងតែនិយាយរំឭករឿង "*កំពប់តែអុង*" ជាប់ជាប្រចាំរហូតមក ដល់សព្វថ្ងៃ ដែលមានដូចតទៅ៖

> *នៅសម័យនោះ ពួកទាហានព្រះចៅអធិរាជ្យវៀតណាមបានកប់ខ្មែរ ដែល ប្រឆាំងនឹងវៀតណាមទាំងរស់ដោយទុកតែក្បាលឲ្យផុតពីដី ធ្វើជាជុំជើង ក្រានដាំតែ។ អ្នកជាប់ទោសនោះ ឈឺក្តៅផ្សាជាខ្លាំង ដោយដុតគ្នាទាំងរស់ដូច្នេះ គេខំរើ ហើយពួកវៀតណាមតែងស្រែកគំរាមថា "ប្រយ័ត្នកំពប់តែអញ!"*

ពួកវៀតណាមបានបន្ថយចំនួនខេត្តខ្មែរពី ៥៦ មក ៣៣ ហើយព្រះចៅមិញម៉ាងបាន បញ្ជាឲ្យដូរឈ្មោះ ខេត្តខ្មែរទាំងឡាយ ដាក់ជាឈ្មោះវៀតណាមវិញ។ ជនជាតិ វៀតណាមម្នាក់ នៅត្រួតមើលលើអភិបាលខេត្តខ្មែរនីមួយៗ។ ប្រទេសវៀតណាមបាន បង្ខំឲ្យរដ្ឋបាលខ្មែរ យកភាសាវៀតណាមមកប្រើ។ ពួកឧត្តមសេនីយវៀតណាម ធ្វើទុក្ខបុកម្នេញដល់ព្រះសង្ឃខ្មែរ ព្រោះពួកគេសង្ស័យថា ព្រះសង្ឃខ្មែរនោះមានគំនិត អ្នកជាតិនិយម។ ពួកវៀតណាមបានវាយបំផ្លាញព្រះពុទ្ធប្បដិមា និងចេតិយ ទាំងឡាយចោល[៤]។

នៅឆ្នាំ ១៨៤០ ប្រទេសវៀតណាមកាន់កាប់ភូមិភាគស្រុកទ្រាំង (Soc Trang)។ ពីឆ្នាំ ១៨៤១ ដល់ឆ្នាំ ១៨៤៥ វៀតណាមយកប្រទេសកម្ពុជាទាំងមូល ធ្វើជាអាណាខេត្តមួយ របស់ខ្លួនតែម្តង។ គ្រានោះ ឧត្តមសេនីយវៀតណាមឈ្មោះទ្រឿងមិញយ៉ាង (Truong Minh Giang) ដឹកនាំ និងត្រួតត្រាលើប្រទេសកម្ពុជា[៥]។

**លទ្ធផលនៃការធ្វើទុក្ខបុកម្នេញ**

ពេលកងទ័ពភូមាចូលលុកលុយប្រទេសសៀម សាសនទូត និងគ្រីស្តបរិស័ទជាច្រើន បានភៀសខ្លួនចេញពីស្រុកសៀមនោះ។ នៅប្រទេសវៀតណាម អ្នកកាន់អំណាចក៏ធ្វើទុក្ខបុកម្នេញសាសនទូត និងគ្រីស្តបរិស័ទដែរ។ ទាំងរដ្ឋអំណាចសៀម និងរដ្ឋអំណាចវៀតណាម មានការសង្ស័យទៅលើគ្រីស្តបរិស័ទ និងសាសនទូតទាំងនោះ ដោយចាត់ទុកថា ជាអ្នកជួយខ្មាំង ឬជួយផ្សាយឥទ្ធពលនៃប្រទេសរបស់អស់លោក។ ដូច្នេះហើយ បានជារដ្ឋអំណាចនៃប្រទេសទាំងពីរ បានជម្លៀសអស់លោកជាបន្តបន្ទាប់។ សាសនទូតនិងគ្រីស្តបរិស័ទទាំងឡាយ បានចូលរួមយ៉ាងជិតស្និទ្ធបំផុតជាមួយប្រជាជនខ្មែរ ដែលកំពុងរងទុក្ខវេទនានោះ។

នៅខែកក្កដា ១៧៥០ បព្វជិតទាំងឡាយដែនដីកូសាំងស៊ីន ត្រូវរដ្ឋអំណាចធ្វើទុក្ខបុកម្នេញ ដេញចេញទាំងអស់(៦)។ បព្វជិតទាំងនោះមានគ្នា ២៥ នាក់ ក្នុងចំណោមបព្វជិតទាំងនោះ មានសមាជិកសមាគមនសហជីវិនព្រះយេស៊ូ ៩ នាក់ បព្វជិតហ្វ្រង់ស៊ីស្កាំង ៩ នាក់ បព្វជិតនៃក្រសួងផ្សាយជំនឿ ២ នាក់ ហើយនិងបព្វជិតទាំងខាងទេវវិទ្យាល័យសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស ៥ នាក់។ ក្នុងចំណោមបព្វជិតទាំងនោះ មានបូជាចារ្យពីរនាក់បានចូលមកនៅប្រទេសកម្ពុជា គឺលោក ប៉ែរត្រង់ដាស៊ើម៉ា (Bertrand d'Azema) និងលោកឡឺហ្វែរ (Lefebvre) ដែលជាអភិបាលព្រះសហគមន៍។ លោកនីកូឡាលីឌួរ (Nicolas Lidur) ដែលជាបូជាចារ្យ កើតនៅក្រុងប៉ុងឌីស៊េរី (Pondicheri) នាប្រទេសឥណ្ឌា ក៏ត្រូវគេបណ្តេញចេញពីដែនដីកូសាំងស៊ីននោះដែរ។ នៅឆ្នាំ ១៧៥២ លោកបានលួចចូលមករស់នៅក្នុងប្រទេសកម្ពុជា ហើយលោករស់នៅរហូតដល់ពេលលោកទទួលមរណភាព នាឆ្នាំ ១៧៦៣។ មកទល់នឹងពេលនោះលោកអភិបាលព្រះសហគមន៍ទទួលបន្ទុកប្រចាំប្រទេសកម្ពុជា បានតាំងទីស្នាក់ការរបស់លោកនៅក្រុងអយុធ្យា ឬនៅដែនកូសាំស៊ីន។ ដោយរដ្ឋអំណាចវៀតណាមធ្វើទុក្ខបុកម្នេញដូច្នេះ លោកក៏ចូលមកតាំងទីចាត់ការរបស់ខ្លួនក្នុងប្រទេសកម្ពុជាវិញ គឺមុនដំបូងនៅភូមិប្រាំបីឆោម ក្រោយមកនៅភូមិធ្មោល។ លោកអភិបាលព្រះសហគមន៍ ឡឺហ្វែរ បានទៅនៅភូមិធ្មោលនេះមុនគេ។

លោកប៉ែរត្រង់ដាស៊ើម៉ា មកដល់ប្រទេសកម្ពុជាមិនទាន់ទាំងបានស្រួលបួលផង ត្រូវរត់ចេញសាជាថ្មីទៀត ព្រោះវៀតណាមនិងខ្មែរច្បាំងគ្នាពេញទំហឹង។ មានសមាជិក

សមាគមនជីវិនព្រះយេស៊ូ ជាតិព័រទុយហ្គាល់ម្នាក់ បានរត់ជាមួយលោកដែរ។ ពួកវៀតណាមបានកាត់កលោកបូជាចារ្យជាតិព័រទុយហ្គាល់នោះ នៅលើកប៉ាល់ដែលនាំលោកទាំងពីរចេញពីស្រុកខ្មែរ។ ពេលលោក ដាសេម៉ា ឃើញមិត្តសម្លាញ់ដេកស្លាប់ក្នុងថ្លុកឈាមដូច្នេះ លោកក៏ផ្តេកខ្លួននៅលើក្តារ រង់ចាំស្លាប់ ព្រោះលោកយល់ថា លោកពុំអាចជៀសផុតពីសេចក្តីស្លាប់បានឡើយ។ ក៏ប៉ុន្តែ នាយទាហានវៀតណាមរំជើបរំជួលចិត្តកើតចិត្តមេត្តា ហើយក៏បញ្ជាទាហានមិនឲ្យបាបលោកជាដាច់ខាត។

ពេលលោកដាសេម៉ា ត្រឡប់មកកម្ពុជាវិញ លោកក៏រៀនភាសាខ្មែរ ហើយបានសាងព្រះវិហារមួយនៅផ្ទោល។ ក្រោយមក គឺក្នុងឆ្នាំ ១៧៥៩ លោកពើបប្រទះនឹងសង្គ្រាមសាជាថ្មីទៀត។ ពួកទាហានវៀតណាម ឈ្លានពានបានដុតព្រះវិហារនោះ ព្រមទាំងផ្ទះសំបែងរបស់គ្រីស្តបរិស័ទទាំងប៉ុន្មាន។ គេចោទគ្រីស្តបរិស័ទថា ជាអ្នកគាំទ្រព្រះមហាក្សត្រខ្មែរ។ លោកដាសេម៉ាទទួលមរណៈភាពនៅចាក់អង្រែ ជិតក្រុងភ្នំពេញក្នុងឆ្នាំ ១៧៥៩ ដដែលនេះ។

នៅឆ្នាំ ១៧៥១ បូជាចារ្យបារាំងម្នាក់ គឺលោកពីហ្គែល (Piguel) មកដល់ប្រទេសកម្ពុជា។ លោកបានទៅជួបលោកដាសេម៉ា នៅឯភូមិផ្ទោល។ លោកប្រើចិត្តអំណត់អត់ធ្មត់ជាខ្លាំង ហើយបានណែនាំគ្រីស្តបរិស័ទភូមិប្រាំបីឆោម ឲ្យចុះចូលនឹងអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា។ លោកបានធ្វើឲ្យក្រុមគ្រីស្តបរិស័ទទាំងពីរដែលប្រជែងគ្នា បានស្រុះស្រួលជានានឹងគ្នាឡើងវិញ។ ក្នុងឆ្នាំ ១៧៦១ លោកពីហ្គែលទទួលមុខដំណែងជាអភិបាលព្រះសហគមន៍ បន្តពីលោកឡឺហ្វែរ។ លោកមកតាំងទីស្នាក់ការនៅភូមិប្រាំបីឆោម គឺនៅក្នុង «វាំង» មួយដ៏ល្អត្រចះត្រចង់ ដែលធ្វើឲ្យសហការីរបស់លោកម្នាក់ សរសេរដោយស្ងើចសរសើរជាខ្លាំងថា៖

> *«លំនៅស្ថានទាំងមូលសង់ឡើងនៅលើសសរខ្ពស់ត្រដែតផុតពីដី ព្រោះមានទឹកជំនន់ស្ទើរតែរាល់ឆ្នាំ។ ផ្ទះលោកមានជញ្ជាំង មានរនាបឬស្សី និងដំបូលប្រក់ស្បូវ។ បន្ទប់របស់លោកខណ្ឌដោយជញ្ជាំងស្លឹកត្បាញខ្វាត់ខ្វែងគ្នា។ ពីលើរនាបផ្ទះមានក្រាលកន្ទេល។ ទ្វារនិងបង្អួចទាំងឡាយ សឹងធ្វើពីស្លឹកដូងទាំងអស់។ ទោះបីខ្ញុំនៅក្នុងបន្ទប់របស់លោកអភិបាលព្រះសហគមន៍ក៏ដោយ ក៏ខ្ញុំមិនត្រូវការបើកទ្វារបង្អួច ដើម្បីឲ្យខ្យល់ចេញចូលឡើយ ព្រោះបន្ទប់នោះមានខ្យល់អាកាសគ្រប់គ្រាន់។ ពេលភ្លៀង ខ្ញុំឃើញគ្រែរបស់លោក បើនិយាយឲ្យចំគឺ "រនាបក្រាល" ទទឹកជោក(...)[៧]។*

ទោះបីជាលោកពីហ្គែលចាស់ជរាហើយក្តី ក៏លោកតែងតែធ្វើទស្សនកិច្ចនៅដែនដីកូសាំងស៊ីនអស់រយៈពេលប្រហែល ៦ខែ ដើម្បីណែនាំគ្រីស្តបរិស័ទ ពេលនោះ ចំលើពេលអាជ្ញាធរកំពុងធ្វើទុក្ខបុកម្នេញ គ្រីស្តបរិស័ទថែមទៀតផង។

លោកពីហ្គែលខ្វល់ខ្វាយជាខ្លាំងចំពោះសង្គ្រាមឥតឈប់ឈរ ដែលរារាំងការប្រកាសដំណឹងល្អនិងបណ្តាលឲ្យប្រជាជនខ្មែររងទុក្ខវេទនានោះ។ លោកបានផ្តល់ យោបល់ដល់អស់លោកនាយក ទេវវិទ្យាល័យក្រុងប៉ារីសថា គួរស្នើទៅក្រុមហ៊ុនបារាំងនាដែនដីឥណ្ឌា (Compagnie des Indes) ឲ្យបើកគ្រឹះស្ថានជំនួញមួយនៅប្រទេសកម្ពុជា។ ក្រុមហ៊ុននោះកើតឡើងតាំងពីឆ្នាំ ១៦៦២ មកម្ល៉េះ។ នៅឆ្នាំ ១៧៦៧ លោក បានសរសេរថា៖

> *«ព្រះមហាក្សត្រប្រទេសកម្ពុជា សុំឲ្យយើងជួយការពារព្រះអង្គ ព្រោះពួកដែនកូសាំងស៊ីនចេះតែ ចូលលុកលុយ (...) ទាហាន ២០០ នាក់ ប្រហែលជាគ្រប់គ្រាន់នឹងការពារបាន។»*

លោកបញ្ជាក់ថែមទៀតថា៖

> *«ខ្ញុំស្នើឲ្យប្រទេសបារាំងយើងមកជួយការពារដូច្នេះ ដើម្បីជាប្រយោជន៍ដល់គ្រីស្តបរិស័ទតែប៉ុណ្ណោះ»*[៨]។

លិខិតនេះ ពុំបានទទួលលទ្ធផលអ្វីឡើយ។ ប៉ុន្តែ ជាលិខិតមួយបង្ហាញច្បាស់អំពីបំណងរបស់លោកអភិបាល គឺលោករកតែប្រយោជន៍សម្រាប់ដែនដី ដែលលោកស្នាក់នៅនោះ។ លោកមិនរកប្រយោជន៍សម្រាប់មាតុភូមិរបស់លោកផ្ទាល់ឡើយ។

លោក ពីហ្គែល បានប្រកាសឲ្យដឹងថា លោកបានធ្វើពិធីជ្រមុជទឹកឲ្យជនជាតិខ្មែរ បានបួន ដប់នាក់ប៉ុណ្ណោះ។ អ្នកទាំងនោះ ជាអ្នកភ្នំ ដែលត្រូវគេចាប់ធ្វើជាឈ្លើយ និងដែលរស់នៅក្រោមការគ្រប់គ្រងរបស់គ្រីស្តបរិស័ទទៀតផង[៩]។ តែទោះជាយ៉ាងនេះក៏ដោយ ក៏លោកបានខិតខំជំរុញការប្រកាសដំណឹងល្អដល់ប្រជាជនខ្មែរ និងដល់ប្រជាជនដែលរស់នៅតាមជួរភ្នំអណ្ណាមដែរ។

**លោកស៊ែរវេសឡឺវ៉ាវ៉ាស័រ: "សាសនទូតរបស់ប្រជាជនខ្មែរ"**

លោក ស៊ែរវេសឡឺវ៉ាវ៉ាស័រ (Gervais Levavasseur) ជាបូជាចារ្យ មានដើមកំណើតនៅក្រុងសេ (Sées) នាប្រទេសបារាំង។ លោកបានចេញដំណើរពីប្រទេសបារាំង នៅថ្ងៃ

ទី ២៦ មករា ១៧៦៦ ហើយលោកមកដល់ភូមិផ្ទោល នៅថ្ងៃទី ១៥ ឧសភា ១៧៦៨។ លោកបានរង់ចាំអស់ពេលជាយូរនៅក្រុង ប៉ុងឌីស៊េរី (ប្រទេសឥណ្ឌា) និងនៅក្រុងម៉ាការ ទម្រាំមកដល់ប្រទេសកម្ពុជា ជាប្រទេសដែលលោកនាយកទេវវិទ្យានាក្រុងប៉ារីស បាន ចាត់លោកឲ្យមកបំពេញភារកិច្ចនោះ។ ដោយលោកបានធ្វើកំណត់ ហេតុការណ៍ប្រចាំ ថ្ងៃ យើងបានដឹងច្បាស់ពីរកិច្ចការផ្សេងៗ ដែលលោកបានធ្វើក្នុងពេលលោកមកបំពេញ ភារកិច្ចនៅក្នុងប្រទេសកម្ពុជា[១០]។

នៅសម័យនោះ អាជ្ញាធរវៀតណាមធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទដែនដីកូសាំងស៊ីន។ ដូច្នេះហើយ បានជានៅថ្ងៃទី ២២ ឧសភា គឺនៅពេលបុណ្យថ្ងៃទីហាសិប (Pente cÔte) លោកពីហ្គែល បានប្រគល់ឲ្យលោក ឡឺវ៉ាវ៉ាស័រ នូវភារកិច្ចប្រកាសដំណឹងល្អ ចំពោះ ប្រជាជនខ្មែរតែប៉ុណ្ណោះ។ ថ្ងៃទី ៨ សីហា លោកបូជាចារ្យនេះ ស្នាក់នៅក្នុងភូមិតូចមួយ ឈ្មោះភូមិគុកងួន (Kuc Nguon) ក្នុងខេត្តកំពង់ស្វាយ[១១]។ លោកសំណាក់នៅផ្ទះគាត់ ជាគ្រីស្តបរិស័ទម្នាក់ដែលជាប់ពូជពង្សព័រទុយហ្គាល់ ហើយដែលមានបងប្អូននៅកំពង់ធំ។ លោកខំរៀនភាសាខ្មែរ ដោយយកចិត្តទុកដាក់ជាទីបំផុត *«ដោយមានព្រះសង្ឃពុទ្ធសាសនា ក្នុងវត្តជួយផង»*។ ថ្ងៃទី ១៤ ឧសភា ឆ្នាំ ១៧៦៩ ត្រូវនឹងថ្ងៃបុណ្យ ថ្ងៃទីហាសិប លោកទេសនាជាភាសាខ្មែរជាលើកដំបូង។ លោកតែងជជែកពិភាក្សាជាមួយ ព្រះសង្ឃនិងអ្នកផងទាំងពួងជាច្រើន។ មានអ្នកខ្លះ និយាយសំអុយបង្ខូចឈ្មោះលោក ថា៖ លោកនឹងធ្វើឲ្យកើតមានទុរ្ភិក្ស លោកជាមេចោរមកបង្កើលមនុស្ស មកសម្លាប់ មនុស្សយកប្រម៉ាត់ និងហុតឈាមមនុស្ស លោកជាយក្ស ដែលនឹងមកស៊ីសាច់អ្នក ស្រុក។ល។ ប៉ុន្តែ លោកអភិបាលខេត្តការពារលោកដោយប្រាប់ប្រជាជនថា គាត់ ស្គាល់បូជាចារ្យជាតិអឺរ៉ុបទាំងឡាយ គឺលោកទាំងនោះសុទ្ធតែជាមនុស្សស្មោះត្រង់ ហើយ គាត់មានអំណរសប្បាយនិងពេញចិត្តណាស់ ដោយមានបូជាចារ្យជាតិអឺរ៉ុបម្នាក់ មកនៅ ស្រុកគាត់។ គាត់ពោលទៀតថា អ្នកដែលរអ៊ូរទាំនឹងពិធីបុណ្យគ្រីស្តសាសនា ប្រហែល ជាមិនដែលបានទៅព្រះរាជវាំងទេ។ នៅទៅនោះ មានព្រះវិហារកាតូលិកពីរ មួយនៅ ផ្ទោល និងមួយទៀតនៅប្រាំបីឆោម។ លោកអភិបាលខេត្ត បានស្នើជូនដីមួយកន្លែង ដល់លោកឡឺវ៉ាវ៉ាស័រ ដើម្បីសង់ព្រះវិហារផង។

លោកស៊េរវេសឡឺវ៉ាវ៉ាស័ររស់នៅភូមិគុកងួន បានពីរឆ្នាំ។ ក្នុងរយៈពេលនោះ លោក

បកប្រែធម៌សំខាន់ៗនៃគ្រីស្តសាសនាជាភាសាខ្មែរ ហើយបង្រៀនធម៌នោះឲ្យគ្រីស្ត
បរិស័ទចេះសូត្រទៀត។ លោកក៏ប្រែសៀវភៅអប់រំគោលសំខាន់ៗនៃជំនឿគ្រីស្តសាសនា
ផងដែរ។ លោកបង្រៀនអ្នកចូលគ្រីស្តសាសនា ហើយធ្វើពិធីបុណ្យជ្រមុជទឹកឲ្យ
ក្មេងៗដែលហៀបនឹងស្លាប់[១២]។ ក្នុងឆ្នាំ ១៧៧០ លោកធ្វើពិធិបុណ្យជ្រមុជទឹកជូន
មនុស្សពេញវ័យ ១០ នាក់។ អ្នកទាំងនោះសុទ្ធតែបានរៀនធម៌ជាភាសាខ្មែរ។

លោកឡឺវ៉ាស័រ មិនគ្រាន់តែអប់រំគោលសំខាន់ៗនៃគ្រីស្តសាសនា និងធ្វើពិធីបុណ្យ
ជ្រមុជទឹកប៉ុណ្ណោះទេ គឺលោកបានរួមចិត្តគំនិតជាមួយលោកអភិបាលព្រះសហគមន៍
ដើម្បី តែងតាំងរចនាសម្ព័ន្ធនៃព្រះសហគមន៍នៃព្រះសហគមន៍ថែមទៀតផង។

## វិទ្យាល័យ

លោកអភិបាលព្រះសហគមន៍ បានទទួលភារកិច្ចមួយដ៏សំខាន់ពីសម្តេចប៉ាប គឺអប់រំ
អ្នកនៅក្នុងស្រុក ឲ្យបំពេញមុខងារជាបូជាចារ្យ នៅក្នុងព្រះសហគមន៍រៀងៗខ្លួន។
ដូច្នេះហើយ ទើបនៅសតវត្សមុន លោកឡាំប៊ែដឺឡាម៉ុត បានបង្កើត «វិទ្យាល័យ» មួយ
នៅក្រុងអយុធ្យា ដើម្បីអប់រំយុវជនដែលស្ម័គ្រចិត្តធ្វើជាបូជាចារ្យ[១៣]។ ក៏ប៉ុន្តែ ដោយ
កងទ័ពភូមា និងសៀមច្បាំងគ្នាពុំរ៉េ តាំងពីឆ្នាំ ១៧៥៨ មក វិទ្យាល័យនេះពុំ មានសន្តិសុខ
ឡើយ។ ក្នុងឆ្នាំ ១៧៦៥ អស់លោកនាយកនិងសិស្សទាំង ៣០ នាក់ បាននាំគ្នារត់ទៅនៅ
ខេត្តចន្ទតាប៊ុន ដែលស្ថិតនៅចម្ងាយប្រមាណ ២០០ គ.ម. ខាងត្បូងក្រុងបាងកក។ ជា
សំណាងដ៏ល្អមែន ព្រោះកងទ័ពភូមាបានវាយបែកក្រុងអយុធ្យាក្នុងឆ្នាំ ១៧៦៩ ។ ប៉ុន្តែ
ដោយកងទ័ពភូមានៅតែវាយលុកប្រទេសសៀមតទៅទៀត វិទ្យាល័យនេះបានផ្លាស់កន្លែង
ទៅតាំងនៅឯហុងដាត (Hondat) ជិតពាម (Hatien) វិញ។ ចិនម្នាក់ឈ្មោះ ម៉ាក់ធៀនទុយ
(Mac Thien Tu)[១៤] គ្រប់គ្រងក្រុងហុងដាតនេះ។ លោកពីហ្គែលពុំមានសាសនទូត
ច្រើននាក់ជាសហការីទេ តែទោះជាយ៉ាងណាក៏ដោយ លោកបានចាត់បូជាចារ្យពីរនាក់
គឺលោកពីញ៉ូដឺបេអែន (Pigneau de Béhaine) និងលោកម័រវ៉ង់ (Morvan) ឲ្យធ្វើជា
នាយកវិទ្យាល័យដែរ។ ការនេះបង្ហាញឲ្យឃើញថា លោកអភិបាលយកចិត្តទុកដាក់
យ៉ាងខ្លាំង ចំពោះការអប់រំអ្នកស្រុកឲ្យទៅជាបូជាចារ្យនោះ។ ប៉ុន្តែ ដោយមានកើត
ឧបទ្ទវហេតុជាបន្តបន្ទាប់ វិទ្យាល័យនេះត្រូវបានបិទទ្វារជាថ្មីម្តងទៀត។ ក្នុងឆ្នាំ ១៧៦៩
កូនសិស្សនិងនាយកមួយចំនួនភៀសខ្លួនទៅក្រុងម៉ាឡាកា រួចទៅក្រុងប៉ុងឌីសេរី[១៥]។

ដោយសារព្រឹត្តិការណ៍ទាំងនេះហើយ ទើបនៅឆ្នាំ ១៧៦៩ លោកអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា ប្រគល់ឲ្យលោកឡឺវ៉ាវ៉ាស័រ ដែលស្នាក់នៅភូមិគុកង្គួន បង្រៀនភាសាឡាតាំង ឲ្យយុវជនសៀមប្រាំនាក់ ដែលជាអតីតសិស្សវិទ្យាល័យពាម។ ឆ្នាំបន្ទាប់មក លោកពីហ្គែលបាន ប្រគល់ភារកិច្ចឲ្យលោកឡឺវ៉ា វ៉ាស័ររៀបចំសង់ និងណែនាំ "វិទ្យាល័យតូចមួយ" សម្រាប់កូនសិស្សមកពីផែនដី កូសាំងស៊ី និងកូនសិស្សខ្មែរដែរ។ "វិទ្យាល័យតូច" នេះ ចាប់ដំណើរការនៅភូមិគុកង្គួន ដោយមានយុវជនសៀម ៥ នាក់ជួយបង្រៀនផង។ នៅឆ្នាំ ១៧៧១ គេលើកវិទ្យាល័យនេះ ទៅនៅភូមប្រាំបីឆោមវិញ ព្រោះលោកឡឺវ៉ាវ៉ាស័រទទួលបន្ទុកណែនាំគ្រីស្តបរិស័ទនៅភូមិនោះ។ គ្រីស្តបរិស័ទជាកូនកាត់ព័រទុយហ្គាល់ ដែលបានរត់ចេញពីក្រុងអយុធ្យា ពេលកងទ័ពភូមាចូលវាយកម្ទេចកាលពីពីរឆ្នាំមុននោះ ក៏បានមកចូលរួមក្នុងព្រះសហគមន៍ប្រាំបីឆោមនេះដែរ។

**ក្រុមគ្រួសារ "នាងបូរផ្កាច់នឹងឈើឆ្កាងព្រះយេស៊ូ "**

នៅឆ្នាំ ១៦៦៥ លោកឡាំប៊ែរដឺឡាម៉ុត បានបង្កើតក្រុមគ្រួសាររបស់ "*នាងបូរផ្កាច់នឹងឈើឆ្កាងព្រះយេស៊ូ* " នៅប្រទេសសៀម។ នៅភូមិប្រាំបីឆោមក្នុងចន្លោះពីឆ្នាំ ១៧៧២ និងឆ្នាំ ១៧៧៤ លោក ឡឺវ៉ាវ៉ាស័រ បានបង្កើតសាខាមួយរបស់ក្រុមគ្រួសារបព្វជិតនោះ ដែលមានយុវនារីកូនកាត់ខ្មែរ-ព័រទុយហ្គាល់ចូលរួមផង។ ក្រុមគ្រួសារនេះ មាន "*នាងសាទួកនីកា* (Saturnica) ជានាយិកា នាងហ្វីលី ពីណាដេអ័រតា (Philipina de Orta) *ជានាយិការង នាងហ្វូស្ទីណារ៉ាយេស* (Faustina Rayel) *ជាគិលានុដ្ឋាយិកា នាងណារស៊ីហ្សាដេអ័រតា* (Narciza de Orta) *ជាហិរញ្ញឹក និងនាងអាប៉ូលិនីញ៉ា* (Apollinia) *ជាអ្នកគ្រួអប់រំនាងចូលថ្មីៗ* " ។ លោកឡឺវ៉ាវ៉ាស័រក៏បានបង្កើតសមាគមស្ត្រី ដែលទទួលបន្ទុកសង្គ្រោះអ្នកក្រីក្រនិងដើរព្យាបាលអ្នកជំងឺ ដែលគ្មានទីពឹង។

**ដំណើរឆ្ពោះទៅកាន់ពួកស្រៀង**

ម៉្យាងទៀត លោកពីហ្គែលខ្វល់ខ្វាយក្នុងការប្រកាសដំណឹងល្អ ចំពោះប្រជាជនដើមនៃដែនកូសាំងស៊ីនផងដែរ គឺចំពោះពួកជនដែលរស់នៅតាមជួរភ្នំអណ្ណាម ក្នុងចន្លោះប្រទេសកម្ពុជា និងប្រទេសអណ្ណាម។ នៅឆ្នាំ ១៧៦៥ លោកបានសរសេរលិខិតទៅជម្រាបអស់លោកនាយកទេវវិទ្យាល័យនាក្រុងប៉ារីស សុំឲ្យបញ្ជូនសាសនទូតមួនចំនួនមក។

ក្នុងលិខិតនោះ លោកសរសេរថា៖

*«លោកទាំងនោះមានឈ្មោះថា ស្មៀង ព្រៅ យ៉ារ៉ៃ ព្នង។ មនុស្សទាំងអស់នោះហាក់ដូចជាគ្រីស្តបរិស័ទ តាំងពីកំណើតមក។ ពួកគេមានគុណធម៌ខ្ពស់ និងមានគុណវិបត្តិតែបន្តិចបន្តួចទេ។ ពួកគេគ្មានវត្ត គ្មានព្រះសង្ឃទេ ហើយខ្ញុំសង្ឃឹមថា នឹងចូលគ្រីស្តសាសនាប្រសិនបើមានសាសនទូតប្រាំពីរ ឬប្រាំនាក់មកដល់មានមនុស្សជាច្រើននៅក្នុងចំណោមអ្នកទាំងនោះ។ ខ្ញុំគ្មានបញ្ហាទើសទាល់អ្វីជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងករណីនេះសោះឡើយ (...) ។ ព្រះមហាក្សត្រខ្មែរមានព្រះទ័យសប្បុរសចំពោះខ្ញុំគ្រប់បែបយ៉ាង។ ម្យ៉ាងទៀត ខ្ញុំមិនទើសទាល់អ្វីទេ ឲ្យសាសនទូតទាំងនោះ មានការធ្វើទាំងអស់គ្នា"*(១៦)។

ក្នុងឆ្នាំ ១៧៧៥ លោក ពីញ៉ូដឺបេអែន ដែលទទួលតំណែងអភិបាលព្រះសហគមន៍បន្តពីលោកពីហ្គែល បានចាត់លោកឡឺវ៉ាវ៉ាស័រ និងសាសនទូតពីរនាក់ទៀត ទៅប្រកាសដំណឹងល្អ ដល់ពួកជនភាគតិចនៅប៉ែកខាងលើទន្លេមេគង្គ។ សាសនទូតទាំងពីរនោះឈ្មោះលោកយូលីយាំងហ្វូលែ (Julien Faulet) និង លោកទីត ឡឺគ្លែរ (Tite Leclerc)។ លោកទាំងបីបានជិះសំពៅតាមដងទន្លេរហូតដល់ឆ្លូង។ លោកហ្វូលែបានស្នាក់នៅឆ្លូងសិន មុននឹងចេញដំណើរទៅកាន់ស្មៀងទៀត។ កាលពីបីឆ្នាំមុននេះ មានបូជាចារ្យម្នាក់ឈ្មោះសិលាយូហ្គេ (Pierre Juguet) ពីសាំងម៉ាឡូ (Saint Malo) នាប្រទេសបារាំង មកដល់ភូមិភាគនេះ ជាលើកដំបូងដែរ តែលោកត្រូវទទួលមរណភាពដោយជំងឺគ្រុនចាញ់ក្នុងជន្មាយុ ៣០ ឆ្នាំ។

ចំណែកឯលោក ឡឺវ៉ាវ៉ាស័រ និងលោកឡឺគ្លែរវិញ លោកទាំងពីរធ្វើដំណើរតាមទន្លេមេគង្គរហូតទៅដល់ស្រុកសំបូរ ចម្ងាយ ៣០ គ.ម. នៅខាងលើក្រុងក្រចេះ។ លោកទាំងពីររកកន្លែងសមគួរ ដើម្បីនឹងសង់ "វិទ្យាល័យ" ឲ្យឆ្ងាយផុតពីសង្គ្រាម។ ក៏ប៉ុន្តែលោកហ្វូលែធ្លាក់ខ្លួនឈឺជាទម្ងន់ ជាហេតុបណ្តាលឲ្យលោកបូជាចារ្យទាំងបីត្រឡប់មកភូមិប្រាំបីឆោមវិញជាប្រញាប់។ ក្រោយពីបានជាសះស្បើយ ហើយលោកហ្វូលែចេញដំណើរទៅឆ្លូងជាថ្មីម្តងទៀត ជាមួយនឹងលោក ឡឺគ្លែរ បន្ទាប់មក លោកហ្វូលែទៅនៅស្រុកស្មៀងតែម្នាក់ឯង។ ដោយលោកត្រូវអ្នកនាំផ្លូវប្លន់យករបស់របរ និងប្រាក់អស់រលីង លោកត្រូវពិសាចំណីអាហារ តាមរបៀបអ្នកស្រុកនោះ៖ "*អស់រយៈជាច្រើនខែ លោកពិសាបាយ និងស្លឹកឈើ ព្រមទាំងអំបិលបន្តិចបន្តួចប៉ុណ្ណោះ។ យូរៗម្តង លោកបានល្ពៅពិសា*"។

ដោយឈឺផង និងដោយនៅតែម្នាក់ឯងផង លោកក៏ឈប់នៅទីនោះ ហើយធ្វើដំណើរត្រឡប់ទៅប្រទេសបារាំងវិញ។ លោកបានទទួលមរណភាព ក្នុងពេលធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតវិញ(១៧)។

នៅឆ្នាំ ១៧៧៧ លោកឡឺវ៉ាវ៉ាស័រ ដែលមានជន្មាយុ ៤០ ឆ្នាំ បានទៅជួបលោកពីញ៉ូដឺបេអែន នៅដែនដីកូសាំងស៊ីន ដើម្បីសួរយោបល់អំពីបញ្ហាណែនាំគ្រីស្តសាសនា។ លោកក៏ទទួលមរណភាពនៅទីនោះដោយរោគរាកមួល។

**លោកឡឺវ៉ាវ៉ាស័រចាក់គ្រឹះសម្រាប់កសាងព្រះសហគមន៍**

ក្នុងអំឡុងជិតដប់ឆ្នាំ ដែលលោកឡឺវ៉ាវ៉ាស័របានប្រកាសដំណឹងល្អនៅប្រទេសកម្ពុជា គឺឆ្នាំ ១៧៦៨ រហូតដល់ឆ្នាំ ១៧៧៧ លោកផ្ដួងផ្ដើមចាក់គ្រឹះសម្រាប់កសាងព្រះសហគមន៍ក្នុងចំណោមប្រជាជនខ្មែរ។ ទោះបីមានចម្បាំងឥតឈប់ឈរ និងលំបាកវេទនាយ៉ាងណាក្ដី ក៏លោកបានតែងសៀវភៅជាភាសាខ្មែរ ជាច្រើនច្បាប់គួរឲ្យចាប់អារម្មណ៍ គឺសៀវភៅអប់រំគោលសំខាន់ៗនៃគ្រីស្តសាសនាមួយ សៀវភៅធម៌សម្រាប់សូត្រជារៀងរាល់ថ្ងៃមួយ ក្បួនតម្រាប្រឆាំងនឹងជំនឿអកុសលមួយ វចនានុក្រមខ្មែរ-ឡាតាំងមួយ(១៨)។

ដូចលោកសឺវ្រើល នាសតវត្សមុន លោកឡឺវ៉ាវ៉ាស័រ មានចិត្តស្រឡាញ់ជនជាតិខ្មែរយ៉ាងខ្លាំង។ លោកបានសរសេរថា៖ «*សូមឲ្យគេឈប់និយាយថា ជនជាតិខ្មែរមិនអាចចូលគ្រីស្តសាសនាយើងបានទៀតទៅ*»។ វិធីប្រកាសដំណឹងល្អរបស់លោក សឹងតែធ្វើតាមគោលធំៗ ដែលមហាសន្និបាតក្រុងត្រែនតូបានចាត់ចែងមក និងរបៀបសហគមន៍កាតូលិកនៅប្រទេសបារាំងក្នុងសម័យនោះ គឺលោករូវ "*បង្រៀនធម៌*" និង "*សេចក្តីពិតសំខាន់ៗនៃគ្រីស្តសាសនា*"។ លោកក៏ត្រូវប្រឆាំងនឹង "*ជំនឿអកុសល*" ផងដែរ។ ម្យ៉ាងទៀត លោកមិនសូវដឹង មិនសូវយល់អំពីព្រះពុទ្ធសាសនាទេ គឺលោកនិងសាសនទូតឯទៀតៗ នៅក្នុងសម័យនោះ ស្មានថាព្រះពុទ្ធជា "*ព្រះក្លែងក្លាយ*" ឬជា "*អាទិទេពមួយអង្គ*" ដែលប្រជាជនខ្មែរហាក់ដូចជាមិនសូវជឿទុកចិត្តទេ លោកចាត់ទុកព្រះពុទ្ធនេះដូចពពួកទេវតាឯទៀតៗ ដូចជា "*ព្រះអាទិត្យ ព្រះចន្ទ និងនាងគង្ហីងព្រះធរណី*" ។ លោកចាត់ទុកព្រះសង្ឃ ថាជា "*បូជាចារ្យរបស់ព្រះក្លែងក្លាយ*"។ លោកបានជួបប្រទះនឹងឧបសគ្គដែលរារាំងពុទ្ធបរិស័ទមិនឲ្យយល់អំពីគ្រីស្តសាសនាបាន គឺលោកសរសេរដូចតទៅ៖

*«អ្នកទាំងនោះស្តាប់ហើយទទួលស្គាល់ថា សាសនាយើងល្អដែរ (...)។ ខ្ញុំពិបាកនឹងធ្វើឲ្យពួកគេចូលចិត្ត។ ប្រជាជនភាគច្រើនស៊ើចសរសើរសាសនាយើង លើកលែងតែរឿងសម្លាប់សត្វចេញ ព្រោះពួកគេជឿខ្លាំងណាស់ចំពោះ កម្មពៀរដែលអន្ទោលតាម និងដំណើរវិលកើតស្លាប់ក្នុងវាលវដ្តសង្សារដ៏ធំធេង»។ អ្នកខ្លះដែលមានការចេះដឹងច្រើនជាងគេ និយាយថា៖ «យើងខុសប្លែកពីអស់លោកត្រង់ជំនឿ។ យើងក៏ពុំដឹងជាឆ្លើយយ៉ាងដូចម្ដេចចំពោះលោក ក៏ប៉ុន្តែ យើងរង់ចាំពេលលោកបកប្រែសាសនា របស់លោកឲ្យបានច្បាស់លាស់ជាភាសារបស់យើង និងសរសេរក្បួនធម៌សាសនានោះ ជាអក្សររបស់យើងសិន ទើបយើងហ៊ានឆ្លើយជូនលោក។ ចំណែកឯទំនៀមទម្លាប់ បញ្ញត្តិវិន័យវិញ មានដូចគ្នា ខុសប្លែកពីគ្នានៅត្រង់លោកធ្វើតាមបញ្ញត្តិនោះ រីឯលោកសង្ឃយើងពុំធ្វើតាមបញ្ញត្តិនោះទេ»*[១៩]។

លោកឡឺវ៉ាវ៉ាស័រខិតខំសិក្សាឲ្យបានយល់ច្បាស់ដូចលោកសរសេរថា ៖

*«យើងបានបកប្រែធម៌ និងចំណុចសំខាន់ៗនៃគ្រីស្តសាសនាជាភាសាខ្មែររួចហើយ។ ខ្ញុំខិតខំរៀន ឲ្យបានយល់ច្បាស់ពីសាសនារបស់ប្រទេសនេះ។ ខ្ញុំត្រូវអានគម្ពីរខាងពុទ្ធសាសនា និងសន្ទនាជាមួយព្រះសង្ឃផង ដើម្បីឲ្យដឹងថា តើខ្ញុំត្រូវនិយាយយ៉ាងដូចម្ដេចនៅក្នុងការជជែកពិភាក្សាគ្នា»*[២០]។

ត្រូវចាំរហូតដល់ពាក់កណ្ដាលសតវត្សទី ២០ ទៅ ទើបមានបន្តការសិក្សាឲ្យបានជ្រៅជ្រះអំពីព្រះពុទ្ធនោះ។

### ព្រះសហគមន៍នៅក្នុងគ្រាលំបាក

នៅឆ្នាំ ១៧៧៦ គឺមួយឆ្នាំមុនលោកឡឺវ៉ាវ៉ាស័រទទួលមរណភាព លោកពីញ៉ូដឺបេអែនតែងតាំងសិស្សបីនាក់នៃវិទ្យាល័យប្រាំបីឆោម ធ្វើជាបូជាចារ្យ។ លោកម្នាក់ឈ្មោះសិលាឡង់ស៊ើន័រ (Pierre Langenois) ដែលមានកំណើតពីកោះដឺហ្វ្រង់ (Ile de France) គឺកោះម៉ូរីស (Maurice) សព្វថ្ងៃ។ លោកមានឈ្មោះល្បីថា "*ចេះនិយាយភាសខ្មែរបានល្អណាស់*"។ លោកបន្តកិច្ចការរបស់លោកឡឺវ៉ាវ៉ាស័រ តទៅមុខទៀត ទោះបីមានសង្គ្រាម និងមានការជម្លៀសប្រជាជនជាច្រើនលើកច្រើនសារក៏ដោយ។ លោកឡង់ស៊ើន័រ ទទួលបន្ទុកណែនាំព្រះសហគមន៍នៅផ្ទោល និងនៅប្រាំបីឆោម។ ក្នុងខែមីនា ១៧៨២ លោកត្រូវរត់គេចពីកងទ័ពសៀម ដែលបានចូលមកប្លន់ និងបំផ្លាញប្រជាជនភូមិទាំងពីរនោះ។

លោកឡង់សេុីន័រ លោកពីញ៉ូ ដឹបេអែន និងបូជាចារ្យបីនាក់ទៀត ព្រមទាំងគ្រីស្តបរិស័ទជាច្រើន ត្រូវសម្ងំពួនលាក់ខ្លួនក្នុងសំពៅ នៅតាមតំបន់ព្រៃលិចទឹកក្បែរៗក្រុងភ្នំពេញអស់រយៈពេលប្រាំមួយអាទិត្យ រង់ចាំឲ្យកងទ័ពសៀមដកថយចេញពី ភូមិភាគនេះទៅវិញ។ បន្ទាប់មកទៀត អស់លោកត្រូវធ្វើដំណើរទៅរាប់ខែ តាមដងទន្លេសាប និងតាមស្ទឹងសែន ដើម្បីរត់គេចពីពួកតៃសុនដែលចូលលុកលុយប្រទេសកម្ពុជា។ នៅខែតុលា ១៧៨២ មានតែលោកបូជាឡង់សេុីន័រម្នាក់គត់ ដែលរស់នៅក្នុងប្រទេសកម្ពុជា។ នៅចុងឆ្នាំ ១៧៨៣ មានបូជាចារ្យហ្វ្រង់ស៊ីស្កាំងជាតិអេស្ប៉ាញពីរនាក់បានរត់គេចពីពួកតៃសុន ដែលកំពុងបំផ្លាញដែនកូសាំងស៊ីននោះ បានមករស់នៅប្រទេសកម្ពុជា ជាមួយលោកឡង់សេុីន័រដែរ។

ខែមករា ១៧៨៤ ពួកតៃសុនវាយឆ្មក់ស្រុកខ្មែរជាថ្មីទៀត។ ពួកគេមកដល់បន្ទាយលង្វែក ប្លន់ក្រុងនោះ ហើយកៀរបូជាចារ្យទាំងបីនាក់ ព្រមទាំងគ្រីស្តបរិស័ទជាតិព័រទុយហ្គាល់ ធ្វើជាឈ្លើយសង្គ្រាមយកទៅខេត្តផ្សារដែក ដែនកូសាំងស៊ីន។ ឆ្នាំបន្ទាប់មកទៀត ទាហានសៀមបានចូលលុកលុយ ប្លន់យកទ្រព្យសម្បត្តិនៅដែនដីកូសាំងស៊ីន និងបានជម្លៀសលោកឡង់សេុីន័រ ព្រមទាំងគ្រីស្តបរិស័ទ ៩០០ នាក់ ដែល ជាប់ឃុំឃាំងនៅផ្សារដែកនោះ ទៅក្រុងបាងកក រាជធានីថ្មីរបស់ប្រទេសសៀមវិញ។ គ្រីស្តបរិស័ទម្នាក់ បានយករូបបដិមារបស់ព្រះមាតា ដែលដូនតាបានយកមកពីម៉ាកាសា (Macassar) កាលគ្រាមុននោះទៅជាមួយផង។ គ្រីស្តបរិស័ទទាំងនោះ ផ្តុំគ្នាបង្កើតបានជាភូមិគ្រីស្តបរិស័ទនៅសង្កាត់សំសេន គឺនៅជុំវិញវិហារ "នាងម៉ារីគ្មានជំពាក់បាបកម្ម" នាក្រុងបាងកកសព្វថ្ងៃ។ ប្រទេសវៀតណាមបានលេបទឹកដីកូសាំងស៊ីនបន្តិចម្តងៗ ជាហេតុបណ្តាលឲ្យគ្រីស្តបរិស័ទខ្មែរ ៤៥០ នាក់ ដែលរស់នៅទីនោះ ជួបការលំបាកកាន់តែខ្លាំងឡើងៗជាលំដាប់។

លោកលីយ៉ូ (Liot) ដែលជាមិត្តដ៏ជិតស្និទ្ធ និងជាទីប្រឹក្សារបស់លោកអភិបាលព្រះសហគមន៍ បានសរសេរលិខិតទៅលោកនាយកវិទ្យាល័យនាក្រុងប៉ារីស ស្នើសុំដល់គ្រីស្តបរិស័ទព័រទុយហ្គាល់ ដែលជាម្ចាស់ទាសាទាសី ឲ្យដោះលែងទាសាទាសីរបស់ខ្លួន ដើម្បីប្រមូលអ្នកទាំងនោះនៅភូមិតែមួយក្នុងប្រទេសកម្ពុជា៖

*«ប្រហែលមានមធ្យោបាយមួយ សម្រាប់តែងតាំងគ្រីស្តសាសនានៃប្រទេសកម្ពុជា។ រហូតមកដល់ឥឡូវនេះ ជនជាតិខ្មែរបានឃើញតែគ្រីស្តបរិស័ទជាតិ*

*ព័រទុយហ្គាល់ប៉ុណ្ណោះ។ ចំណែកគ្រីស្តបរិស័ទខ្មែរវិញ មានតែបួនដប់នាក់ដែល ជាទាសាទាសី ឬកូនបំណុលរបស់ពួកព័រទុយហ្គាល់ទាំងនោះថែមទៀត។ ប្រសិន បើជនជាតិខ្មែរឃើញថាក្រុមគ្រីស្តបរិស័ទសឹងតែជាជនរួមជាតិខ្លួននោះ មុខជា ពួកគេនឹងមើលសេចក្តីពិតឃើញ ព្រោះហេតុថា ពួកគេមិនចង់ទៅនៅជាមួយ ពួកព័រទុយហ្គាល់ទាំងបង្ខំចិត្តឡើយ»*(២១)។

លោកឡឺឡាប៊ូស (Le Labousse) ជាសាសនទូតប្រចាំដែនដីកូសាំងស៊ីន។ ក្នុងលិខិតមួយចុះថ្ងៃទី ១៣ ធ្នូ ឆ្នាំ ១៧៩០ លោកបានរាយការណ៍អំពីក្មេងស្រីម្នាក់ ដែលបានរងទុក្ខជាខ្លាំង ព្រោះតែជំនឿរបស់ខ្លួន៖

*«មានក្មេងស្រីម្នាក់ អាយុប្រហែល ១៨ឆ្នាំ ជាទាសីរបស់គ្រីស្តបរិស័ទម្នាក់។ ម្ចាស់នាងបានធ្វើបុណ្យជ្រមុជទឹកឲ្យនាងទៅជាគ្រីស្តបរិស័ទ។ តែក្រោយពេល ម្ចាស់នោះស្លាប់ទៅ នាងក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកទទួលមត៌ក ដែលមានចិត្ត អាក្រក់កាចសាហាវ។ បុរសនោះយកនាងទៅឲ្យអ្នកឥតសាសនា ទោះបី ជានាងខំអង្វរសុំឲ្យលក់នាងទៅគ្រីស្តបរិស័ទយ៉ាងណាក្តី ក៏បុរសនោះពុំព្រមដែរ។ ម្ចាស់ថ្មីឥតសាសនានោះ បានបង្ខំនាងឲ្យប្រព្រឹត្តតាមជំនឿអកុសលរបស់គាត់ ប៉ុន្តែ នាងប្រកែកជានិច្ច មិនព្រមធ្វើតាមទេ ទោះបីជននោះ បានធ្វើទុក្ខបុកម្នេញ គ្រប់បែបយ៉ាង ដើម្បីបង្ខំនាងឲ្យធ្វើតាម ក៏ពុំបានសម្រេចដូចបំណងឡើយ។ ដោយឈឺចិត្ត ព្រោះពុំអាចឈ្នះទាសីរបស់ខ្លួនបាន បុរសនោះក៏ប្រគល់នាងឲ្យទៅ មិត្តគាត់ម្នាក់ ដែលជាមនុស្សមានចិត្តឃោរឃៅដូចគ្នា។ បុរសក្រោយនេះក្រេវ ក្រោធយ៉ាងខ្លាំង វាយដំច្រំធាក់នាងជាទម្ងន់បណ្តាលឲ្យនាងស្លាប់ គឺនាងស៊ូស្លាប់ ព្រោះតែជំនឿលើព្រះជាម្ចាស់។ ដោយឃើញទឹកចិត្តឥតប្រែប្រួលរបស់នាងទាសី ចំពោះព្រះយេស៊ូគ្រីស្តដូច្នេះ គ្រីស្តបរិស័ទក៏បានយកសពនាងមកគោរពទាំង ធ្វើបុណ្យបញ្ចុះសពនោះយ៉ាងអធិអធម ទៅតាមលទ្ធភាពដែលពួកគេមាន»*(២២)។

ក្រៅពីរឿងដែលបណ្តាលមកពីបុគ្គលដូចខាងលើនេះ អ្នកកាន់អំណាចវៀតណាមនៅ ដែនដីកូសាំងស៊ីន បានធ្វើបាបគ្រីស្តបរិស័ទជាតិព័រទុយហ្គាល់ ជាតិអេស្ប៉ាញ ឬជាតិចិន ដោយខិតខំធ្វើឲ្យអ្នកទាំងនោះវិនាសផុតពូជ។ អ្នកកាន់អំណាចវៀតណាមតែងគិត និងយល់ថា គ្រីស្តបរិស័ទទាំងនោះ រួមចិត្តគំនិតជាមួយខ្មែរដែលកាន់ព្រះពុទ្ធសាសនា ព្រោះគ្រីស្តបរិស័ទនិយាយភាសាខ្មែរនិងរស់នៅតាមរបៀបខ្មែរ ដូចជនជាតិខ្មែរដែរ(២៣)។

## គ្រីស្តបរិស័ទនៅបាត់ដំបង

គ្រីស្តបរិស័ទខ្មែរប្រហែល ៣០០ នាក់ ដែលបានរត់រួចផុតពីភូមិប្រាំបីឆោម និងសមាជិក ៦ នាក់ នៃក្រុមគ្រួសារ នាងប្លូផ្តាច់នឹងឈើឆ្កាងព្រះយេស៊ូ ដែលជាកូនកាត់ខ្មែរ-ព័រទុយហ្គាល់ បានគ្រាច់ចរទៅនៅខេត្តពោធិសាត់ និងខេត្តកំពង់ស្វាយ រហូតដល់ពេលលោកយ៉ូហាន ដាយេស៊ូ (Jean da Jesus) បានប្រមូលគ្រីស្តបរិស័ទទាំងនោះនាំទៅតាំងទីលំនៅឯបាត់ដំបង នាថ្ងៃទី ៥ មករា ឆ្នាំ ១៧៩០។ ខេត្តបាត់ដំបងនេះ ត្រូវសៀមកាន់កាប់តាំងពីឆ្នាំ ១៧៨២ មកម្ល៉េះ។ លោកយ៉ូហាន ដាយេស៊ូ ជាបូជាចារ្យប្រាំងស៊ីស្កាំង ដែលបានជាប់ជាឈ្លើយ ជាមួយលោកឡង់សឺន័រនៅផ្សារដែកកាលពីមុន។ លោកបានរស់នៅជាមួយក្រុមគ្រីស្ត បរិស័ទនៅបាត់ដំបងបានតែពីរបីខែប៉ុណ្ណោះ រួចក៏ចេញដំណើរទៅក្រុងម៉ាការ។

នៅពេលនោះ រដ្ឋអំណាចក្រុងបាងកកបានដោះលែងលោកឡង់ស៊ើន័រ ឲ្យមាន សេរីភាពវិញ។ លោកឈប់ឈប់ណែនាំគ្រីស្តបរិស័ទកូនកាត់ខ្មែរ-ព័រទុយហ្គាល់ដែល ភៀសខ្លួនទៅនៅបាងកក ហើយអញ្ជើញមកខេត្តបាតដំបងជួបគ្រីស្តបរិស័ទខ្មែរវិញ។ លោករស់នៅទីនេះ រហូតដល់ពេលលោកទទួលមរណភាព នាឆ្នាំ ១៧៩៥ ។ នៅបាត់ដំបង លោកបានបកប្រែសៀវភៅស្តីអំពីគោលសំខាន់ៗនៃគ្រីស្តសាសនា របស់លោកអាឡិច សង់ដឺរ៉ូដ៍ (Alexandre de Rhodes) ជាភាសាខ្មែរ។ ក្នុងសតវត្សក្រោយមក អ្នកអាន សៀវភៅនេះ នាំគ្នាស្ញើចសរសើររបៀបសរសេរដ៏ល្អបំផុត និងដ៏ត្រឹមត្រូវតាម អក្សរសាស្ត្រខ្មែរសុទ្ធសាធ។

ពីរឆ្នាំក្រោយលោក ឡង់ស៊ើន័រ ទទួលមរណភាព លោកលីយ៉ូ (Liot) មកសួរសុខទុក្ខ គ្រីស្តបរិស័ទនៅបាត់ដំបង។ លោកស្គាល់ពួកគេច្បាស់ ព្រោះពេលលោកមកដល់ប្រទេស កម្ពុជា ឆ្នាំ ១៧៧៨ លោកបានរៀនភាសាខ្មែរពីគ្រីស្តបរិសទទាំងនោះ កាលពួកគេ នៅភូមប្រាំបីឆោមនៅឡើយ។ បន្ទាប់មក លោកស្នាក់នៅដែនដីកូសាំងស៊ីន រួចត្រឡប់ មករស់នៅភូមិប្រាំបីឆោមពីរឆ្នាំ គឺនៅ ១៧៨១ និង១៧៨២ មុននឹងរត់គេចពីពីពួក តៃសុនជាមួយលោកឡង់ស៊ើន័រ។ នៅឆ្នាំ ១៧៩៧ លោកលីយ៉ូមានតំណែងជានាយក "វិទ្យាល័យ" ដែលស្ថិតនៅជាបណ្តោះអាសន្នក្នុងខេត្តចន្ទតាប៊ុន។ ដោយហេតុតែ ខេត្ត បាត់ដំបងនៅជិតខេត្តចន្ទតាប៊ុន ទើបលោកអាចឆ្លៀតឱកាសមកជួប និងសួរសុខ ទុក្ខគ្រីស្តបរិស័ទនៅបាត់ដំបងអស់រយៈពេលពីរបីខែ។

ចាប់តាំងពីឆ្នាំ ១៧៩៧ មក គ្មានបូជាចារ្យណាបានណែនាំគ្រីស្តបរិស័ទនៅបាត់ដំបងទេ ព្រោះនៅប្រទេសបារាំងមានកើតបដិវត្តន៍ ជាហេតុបណ្តាលឲ្យសាសនទូតមានចំនួនកាន់តែតិចទៅៗ។ ម្យ៉ាងទៀត អស់លោកបូជាចារ្យក្នុងភូមិភាគអាស៊ីភាគអាគ្នេយ៍ត្រូវនៅណែនាំថែរក្សាគ្រីស្តបរិស័ទជាតិវៀតណាម ក្នុងដែនដីកូសាំងស៊ីន ដែលមានចំនួនច្រើនជាងគេនោះ។ នៅសម័យនោះ ព្រំដែនប្រទេសនីមួយៗចេះតែប្រែប្រួល រហូតទាល់តែគេមិនអាចដឹងច្បាស់ថា ប្រទេសណាមានដីត្រឹមណាឡើយ។ នៅឆ្នាំ ១៨០២ លោក យ័រដាន់ (Jourdain) ដែលមកពីប្រទេសបារាំងដល់បាត់ដំបង។ លោករស់នៅក្នុងក្រុងនោះបានពីរឆ្នាំ។

លោកសរសេរថា៖

*«ខ្ញុំទេសនាជាភាសាព័រទុយហ្គាល់ រាល់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យធំៗ ពេលល្ងាចខ្ញុំនាំគេសូត្រធម៌ និងបង្ហាត់ចម្រៀងឲ្យយុវជនយុវនារី ចាំជាប់នូវជីវភាពរបស់សន្តបុគ្គល និងប្រវត្តិក្នុងគម្ពីរផង។ គួរឲ្យស្តាយណាស់ ដោយក្រុមគ្រួសារបរិស័ទមានគ្នាតិចយ៉ាងនេះ គឺមានតែ ២១០ នាក់ទេ ហើយសុទ្ធសឹងតែ ជាអ្នកជាប់ជំពាក់បំណុលគេ។ ពួកគេកំសត់ទុគ៌តនិងជាប់កំណែនកិច្ចការសាធារណៈផង...។ គ្រីស្តបរិស័ទទាំងនោះ សុទ្ធតែចេះភាសាព័រទុយហ្គាល់គ្រប់ៗគ្នា*(២៤)។

ពីរឆ្នាំបន្ទាប់មក គ្មានបូជាចារ្យណាម្នាក់ នៅក្រុងបាត់ដំបងទៀតឡើយ។ នៅឆ្នាំ ១៨០៩ សាសនទូតម្នាក់នៅប្រទេសសៀមសរសេររឿងដែលលោកឮគេនិយាយអំពីព្រះសហគមន៍នៅបាត់ដំបងនោះថា៖

*«តាំងពីពេលដែលមានបូជាចារ្យមក កិរិយាមារយាទរបស់គ្រីស្តបរិស័ទ មិនខុសប្លែកពីកិរិយាមារយាទរបស់អ្នកកាន់សាសនាដ៏ទៃទៀតប៉ុន្មានទេ។ ដូនជីទាំងប៉ុន្មានអស់សង្ឃឹមយ៉ាងខ្លាំង ចំពោះអវត្តមានដ៏យូររបស់លោកបូជាចារ្យ។ ដូនជីទាំងនោះស្ទើរតែទ្រាំលែងបាន ចំពោះឧបសគ្គផ្សេងៗ ដែលពួកគាត់កំពុងជួបប្រទះ។ ដូនជីទាំងនោះ ត្រូវសម្រេចចិត្ត ឬទៅនៅដែនដីកូសាំងស៊ីន ឬទៅទីដ៏ទៃៗទៀត...។ ចំណែកគ្រីស្តបរិស័ទខ្មែរវិញ ពួកគេហាក់បីដូចជា មិនសូវជាព្រួយប៉ុន្មានពីរឿងគ្មានបូជាចារ្យនេះទេ ព្រោះពួកគេធ្លាប់ទៅហើយ។ ពួកគេនាំគ្នាធ្វើពិធីបុណ្យផ្សេងៗដោយខ្លួនឯង ក្នុងបុណ្យមហោឡារិក ពួកគេរៀបពិធីទាំងអស់ រហូតដល់ដង្ហែព្រះកាយផង។ ចំពោះពិធីបុណ្យខ្មោចវិញ ពួកគេធ្វើដោយខ្លួនឯងបេះបិទ*

*ដូចពេលមានបូជាចារ្យដែរ។ ការទាំងអស់ហ្នឹង គង់តែបណ្តាលឲ្យពួកគេឃ្លាតចាកពីជំនឿជាពុំខាន...»*(២៥)

គ្រីស្តបរិស័ទនៅបាត់ដំបង ប្រហែលជាបណ្តាលឲ្យអស់លោកបូជាចារ្យ ដែលទទួលបន្ទុកអប់រំជំនឿ តាមលំនាំរបស់មហាសន្និបាតក្រុងត្រេនតូ ឆ្ងល់ឬទាស់ចិត្តមែន។ ប្រសិនបើគ្រីស្តបរិស័ទប្រព្រឹត្តដូច្នេះក្នុងសម័យឥឡូវនេះវិញ មុខជាត្រូវទទួលការសរសើរជាពុំខាន ព្រោះពួកគេមានយោបល់មុនគេ។ គ្រីស្តបរិស័ទនៅបាត់ដំបងទទូចសុំហើយសុំទៀត ឲ្យមានបូជាចារ្យមកណែនាំពួកគេ។ នៅឆ្នាំ ១៨០៩ លោកឡាបាតែត (Labartette) ដែលជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា និងដែនកូសាំងស៊ីនយល់ថា លោកមិនអាចសម្រេចចិត្តចាត់សាសនាទូតម្នាក់ឲ្យទៅរស់នៅជាមួយគ្រីស្តបរិស័ទដែលមានគ្នាតិចពេកនោះឡើយ។ លោកសរសេរថា៖

*«នៅប្រទេសកម្ពុជា មានតែទូន្មានឲ្យគ្រីស្តបរិស័ទធ្វើពិធីជ្រមុជទឹកឲ្យកូនក្មេង ដែលកំពុងដក់ចង្ការមាន់តែប៉ុណ្ណោះ។ គ្រីស្តបរិស័ទក៏ចូលចិត្តធ្វើបុណ្យជ្រមុជទឹកបែបនេះដែរ។ រហូតមកដល់ពេលនេះ ខ្ញុំតែងតែចាត់បូជាចារ្យម្នាក់ ទៅសួរសុខទុក្ខនិងណែនាំគ្រីស្តបរិស័ទទាំងនោះ មួយឆ្នាំម្តងៗ ។ ខ្ញុំយល់ថាធ្វើដូច្នេះគ្រប់គ្រាន់ហើយ»*(២៦) ។

នៅឆ្នាំ ១៨២៣ គ្រីស្តបរិស័ទបាត់ដំបងនាំគ្នាទៅជួបលោកផ្លូរ៉ង្ស (Flarens) ដែលជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសសៀម សុំឲ្យលោកចាត់បូជាចារ្យម្នាក់មកណែនាំពួកគេ។ ប៉ុន្តែ លោកឆ្លើយតបមកវិញថា លោកពុំអាចចាត់បូជាចារ្យមកបានទេ ពីព្រោះគ្មាននរណាម្នាក់នៅជាមួយលោកឡើយ។ *«គ្រីស្តបរិស័ទទាំងនោះ បានត្រឡប់មកបាត់ដំបងវិញទាំងទឹកភ្នែក»* (២៧) ។

នៅខែវិច្ឆិកា ឆ្នាំ ១៨៣៨ លោកអភិបាលព្រះសហគមន៍ចាត់លោក យ៉ូហាន ក្លូតមីស (Jean Claude Miche) និងលោកឌុយក្លូ (Duclos) ឲ្យទៅបាត់ដំបង។ លោកមីសកើតនៅក្រុងសាំងឌីយេ (Saint-Dié) នាប្រទេសបារាំង។ លោកមកដល់ក្រុងបាងកកនៅឆ្នាំ ១៨៣៧។ នៅទីនោះ លោករៀនអក្សរនិងភាសាខ្មែរ ហើយលោកស្គាល់ព្រះអង្គម្ចាស់ខ្មែរព្រះនាមអង្គឌួង ដែលរស់នៅក្នុងវាំងក្រោមការ គ្រប់គ្រងរបស់ព្រះចៅសៀម។ ក្រោយពីបានរៀនភាសាខ្មែរសព្វគ្រប់ និងបានបោះពុម្ពសៀវភៅធំសំខាន់ៗ

ជាភាសាខ្មែររួចហើយ សាសនទូតទាំងពីរនាក់ក៏ចេញទៅនៅបាត់ដំបង។ ក៏ប៉ុន្តែលោកទាំងពីរពុំបានរស់នៅទីនោះយូរទេ។

ព្រះអង្គម្ចាស់អែម ដែលជាប់ឃុំឃាំងនៅរាជវាំងបាងកក ត្រូវជាព្រះអនុជរបស់ព្រះបាទអង្គច័ន្ទ ជាព្រះមហាក្សត្រប្រទេសកម្ពុជា។ ទ្រង់មានបំណងរត់មកកាន់មាតុប្រទេសវិញជាមួយជនជាតិខ្មែរជាច្រើនទៀត ដែលរស់នៅប្រទេសសៀម ដើម្បីរំដោះខេត្តបាត់ដំបងយកមកវិញ។ ព្រះអង្គរត់ចេញម្តងហើយ តែត្រូវបរាជ័យ។ ក្រោយមកគឺចំពេលបុណ្យណូអែលឆ្នាំ ១៨៣៩ ព្រះអង្គរត់ចេញហើយយាងមកក្រុងបាត់ដំបង។ ទ្រង់បានបញ្ចុះបញ្ចូលប្រជាជននៅក្រុងបាត់ដំបង ប្រជាជនក៏តាមព្រះអង្គគ្រប់ៗគ្នា។ គ្រីស្តបរិស័ទក៏តាមព្រះអង្គដែរ ដោយមានទាំងនាយកព្រះសហគមន៍ ឈ្មោះរាម ពុទ្ធាជាអ្នកដឹកនាំផង។ ទាហានរបស់ព្រះអង្គ អែម បានដុតក្រុងចោល ដើម្បីកុំឲ្យប្រជាជនត្រឡប់ចូលក្រុងវិញ តែកងទ័ពសៀមដេញតាមពួកអ្នករត់ចេញ ហើយប្លន់ និងវាយកម្ទេចក្រុងនោះ អស់គ្មានសល់។ ទាហានសៀមចាប់បានពួកអ្នកបះបោរមួយចំនួននៅព្រំដែនកូសាំងស៊ីន ហើយកៀរយកទៅបាងកកវិញ។ កងទ័ពវៀតណាម ក៏ចាប់ពួកអ្នកបះបោរបានមួយចំនួនធំដែរ នៅក្នុងនោះមានទាំងព្រះអង្គម្ចាស់អែម និង ពុទ្ធាផង។ ពួកវៀតណាមបានសម្លាប់រាមពុទ្ធចោល ហើយនាំយកព្រះអង្គម្ចាស់អែម ទៅឃុំឃាំងនៅខេត្តមាត់ជ្រូក។ ទ្រង់សោយទិវង្គតនៅទីនោះក្នុងឆ្នាំ ១៩៤១។ ពួកឈ្លើយសង្គ្រាមដែលមានគ្រីស្តបរិស័ទជាច្រើននោះ បានបែកខ្ញែកគ្នាអស់។ ចំណែកលោកមីស និងលោកឱយក្លូ វិញ ពេលព្រះអង្គម្ចាស់អែមនាំគ្រីស្តបរិស័ទ និងក្រុមបះបោរចេញ ពីបាត់ដំបងនោះ លោកទាំងពីរពុំបានទៅតាមទេ ហើយវិលត្រឡប់ទៅបាងកកវិញ រួចក៏អញ្ជើញទៅក្រុមម៉ាការទៅ។

ពីឆ្នាំ ១៨៤១ ដល់ឆ្នាំ ១៨៤៦ ប្រទេសកម្ពុជាលែងជារដ្ឋឯករាជ្យ ព្រះរាជាណាចក្រមួយភាគធំត្រូវវៀតណាមលេប និងមួយភាគទៀតត្រូវប្រទេសសៀមត្រួតត្រា។ ព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា ហាក់ដូចជាសាបសូន្យដែរ។ ការខំប្រឹងប្រែងទាំងឡាយអស់សាសនទូត អស់រយៈមួយសតវត្សមកហើយនោះ ក៏ដូចជារលត់រលាយអស់ដែរ។

(១) ប្រទេសវៀតណាមបានវាយដណ្តើមយកប្រទេសចម្ប៉ានៅចុងសតវត្សទី ១៥ ជាពិសេស ក្រោយពីពួកចាមត្រូវបរាជ័យនៅឆ្នាំ ១៤៧០ ។ ពួកទាហាន-កសិករវៀតណាម បានចូលមកនៅក្នុងព្រះរាជាណាចក្រចម្ប៉ា ហើយសម្លាប់ ឬដេញប្រជាជនទាំងនោះ ឲ្យទៅនៅព្រៃ។ ប្រទេសចម្ប៉ា

ត្រូវវៀតណាមយកជាផ្លូវការនៅឆ្នាំ ១៧៥២។ ពួកចាមចំនួនប្រមាណជា ២៥០.០០០ នាក់ បានរត់ភៀសខ្លួនមកនៅប្រទេសកម្ពុជា។ សព្វថ្ងៃ នៅវៀតណាមមាននៅសល់ប្រជាជនចាមចំនួនប្រមាណ ៥០.០០០ នាក់ដែរ។ ពួកគេរស់នៅក្នុងភូមិភាគផារ៉ាង (Pharang) ដែលជារាជធានីចាស់នៃប្រទេសចាម។

(២) ចំពោះសម័យនោះ សូមមិត្តអ្នកអានមើលសៀវភៅរបស់លោក A.Dauphin-Meunier, "Historie du Cambodge" PUF, 1968, pp.82-87 និងសៀវភៅរបស់លោក Pierre Fistié, "La Thailande", PUF, Paris 1971, p.29-34. ឬក៏សៀវភៅរបស់លោក André Masson, Historie du Vietnam, PUF, Paris, 1972, pp.22-47.

(៣) លោកឧញ៉ា ប៉ុក ជាជីតាលួតរបស់ពួកអ្នកដឹកនាំពិធីការនៅក្នុងវាំងភ្នំពេញ និងរបស់បងប្អូនត្រកូល "ជួន" ទាំងបីនាក់ដែលជាសមាជិករបស់អង្គការជាន់ខ្ពស់ខ្មែរក្រហម។

(៤) អំណាចវៀតណាម បានធ្វើឲ្យខ្មែរឈឺចាប់ខ្លាំងណាស់ ហើយបន្សល់ទុកនូវអនុស្សាវរីយ៍ដ៏សែនជូរចត់រហូតមកទល់សព្វថ្ងៃនេះ។

(៥) កាលពីដើមព្រះរាជាណាចក្រអង្គរលាតសន្ធឹងនៅលើផ្ទៃដីមួយភាគធំនៃជ្រោយឥណ្ឌូចិន ហើយមានប្រជាជនចំនួនប្រមាណជាង ១៥ លាននាក់។ នៅឆ្នាំ ១៨៤៥ ព្រះរាជណាចក្រខ្មែរមានផ្ទៃដីប្រហែល ២/៣ នៃផ្ទៃដីប្រទេសកម្ពុជាសព្វថ្ងៃ ហើយមានមនុស្សចំនួនប្រហែល ៨០០.០០០ នាក់។

(៦) តាំងពីសតវត្សទី ១៦ មក អ្នកកាន់អំណាចវៀតណាមមានអាកប្បកិរិយារឹងត្អឹង បង្ករឿងចំពោះគ្រីស្តបរិស័ទកាតូលិកនៅតុងកឹង និងនៅដែនកូសាំងស៊ីន។ គេយល់ថា គ្រីស្តបរិស័ទបណ្តាលឲ្យអំណាចរបស់គេចុះទន់ខ្សោយ។ នៅសតវត្សទី ១៨ ពួកអ្នកកាន់អំណាចនៅតុងកឹងកាន់តែធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទខ្លាំងឡើងៗ។ ផ្ទុយទៅវិញ នៅដែនដីអណ្ណាម និងដែនកូសាំងស៊ីន គ្រីស្តបរិស័ទរស់នៅដោយសុខសន្តិភាព ហើយរាជវង្ស ង្វៀង រាប់រកអស់លោកសាសនទូត យ៉ាងសមរម្យ។ លោកពីញ៉ូដឺបេអែន បានជួយព្រះចៅអធិរាជ យ៉ាឡុង ឲ្យឈ្នះសង្គ្រាមប្រឆាំងពួកតៃសុន។ ក៏ប៉ុន្តែ ក្រោយពីព្រះចៅអធិរាជនេះសោយទិវង្គតទៅ ព្រះចៅអធិរាជមិញម៉ាង ទឺឌុក (Tu Duc ១៨៤៧-១៨៨៣) បានធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័តគ្មានឈប់ឈរសោះ។ អាជ្ញាធរបារាំងឆ្លៀតឱកាសនេះ ធ្វើអន្តរាគមន៍យោធាក្នុងឆ្នាំ ១៨៥៨ ។

(៧) Jounal du P. Levavasseur, cité in Launay, op.cit., II, p.384.

(៨) លិខិតដកស្រង់ចេញពីសៀវភៅរបស់លោក Launay, op.cit., II, pp.438-439.

(៩) Launay, op.cit., II, p.412

(១០) កំណត់ហេតុប្រចាំថ្ងៃរបស់លោក ឡឺវ៉ាវ៉ាស័រ cité in Launay, op.cit., II, pp.418-425

(១១) នៅសម័យនោះ កំពង់ស្វាយ ជាភូមិធំមួយដ៏សំខាន់ស្ថិតនៅខាងជើងក្រុងកំពង់ធំ។ នៅក្នុងភូមិនោះ ព្រះមហាក្សត្រខ្មែរទាំងពួង តែងឲ្យពួកគួយលត់ដែកធ្វើកាំភ្លើង សម្រាប់កង

ទំពរបស់ព្រះអង្គគឺដែកដែលគេយកពីភ្នំដែក។

(១២)ការធ្វើពិធីជ្រមុជទឹកឲ្យក្មេងៗបែបនេះ ប្រហែលជាមកពីទ្រឹស្តីខាងទេវវិទ្យាមួយ ស្តីអំពី «បាបពីកំណើត» និងទ្រឹស្តីអំពីពិធីជ្រមុជទឹកដែលគេតែងហៅថា «បុណ្យលាងបាប» គឺត្រូវធ្វើបុណ្យលាងបាបនេះជាដាច់ខាត ដើម្បីទទួលការសង្គ្រោះ។ នៅសម័យនោះ គ្រីស្តបរិស័ទតែងជឿថា ក្មេងណាពុំបានទទួលពិធីជ្រមុជទឹកទេ ក្មេងនោះនឹងត្រូវទៅដល់ត្រឹមតែ "ជាយនៃឋានសួគ៌" (Lumbes) ។ ដូច្នេះហើយ បានជាគេខំធ្វើពិធីជ្រមុជទឹកឲ្យក្មេងៗ ដែលកំពុងដកចង្កាមាន់ ដើម្បីឲ្យក្មេងៗទាំងនោះ បានទទួលការសង្គ្រោះជានិរន្តរ៍។

(១៣)បូជាចារ្យជាតិអាស៊ីជាច្រើន បានទទួលការអប់រំនៅក្នុង "វិទ្យាល័យ" នេះ។ ក្រៅពីលោកដូណូ (Dono) ជាជនជាតិជប៉ុនដែលត្រូវគេធ្វើឃាដនៅពញាឮ ក្នុងឆ្នាំ ១៧១៧ នោះ មានលោកប៉េរេស (Perez) ជាកូនកាត់ ឪពុករបស់លោកជាតិព័រទុយហ្គាល់ និងម្តាយជាតិសៀម។ លោកទទួលបន្ទុកជាអភិបាលព្រះសហគមន៍ពីឆ្នាំ ១៦៩១ ដល់ឆ្នាំ ១៧២៨។ លោកនីកូឡាលីហ្គួរ (Nigolas Ligur) ដែលនៅប្រទេសកម្ពុជាពីឆ្នាំ ១៧៥២ ដល់ឆ្នាំ ១៧៦៣ និងលោកសិលាឡង់ស៊ើន័រ ពីឆ្នាំ ១៧៧៦ ដល់ឆ្នាំ ១៧៩៥។

(១៤)"*ពាម* " ជាឈ្មោះកំពង់ផែខ្មែរ នៅជាប់ឈូងសមុទ្រសៀម ដែលពួកវៀតណាមឲ្យឈ្មោះថា "ហាទៀង" ហើយដែលពួកចិនហៅថា "កង់កាវ" (Cancao)។ នៅចុងសតវត្សទី ១៧ ពួកចិនប្រមាណជាបីពាន់នាក់ បានភៀសខ្លួនមកនៅប្រទេសកម្ពុជា។ ពួកចិនទាំងនោះ ត្រូវគេដេញចេញពីប្រទេសរបស់ខ្លួន ដោយសារមានបដិវត្តន៍នៅក្នុងរាំង។ ចិនម្នាក់ឈ្មោះ ម៉ាក់គុយ (Mac Cuu) រកស៊ីមានស្តុកស្តម្ភជាងគេនៅភូមិភាគពាមនេះ ហើយត្រួតត្រាតំបន់នោះផង។ ព្រះមហាក្សត្រប្រទេសកម្ពុជា ព្រះនាមព្រះបាទអែម (១៧១០-១៧២២) បានពឹងប្រទេសវៀតណាម ក្នុងការទប់ទល់នឹងគូប្រជែងរបស់ព្រះអង្គ។ រីឯគូប្រជែងនោះបានពឹងលើពួកសៀម។ ព្រះមហាក្សត្រអែម បានប្រគល់ឲ្យលោក ម៉ាក់គុយ ការពារឆ្នេរសមុទ្រខ្មែរ នៅតាមឈូងសមុទ្រសៀម។ លោកម៉ាក់គុយនេះ មានកូនប្រុសម្នាក់ឈ្មោះ ម៉ាក់ ធាន ទុយ។ ពេលលោកធាទុយ ឃើញថា មានបើក "វិទ្យាល័យ" មួយ នៅក្នុងស្រុកដែលគាត់គ្រប់គ្រង និងមានគ្រីស្តបរិស័ទពីកូសាំងស៊ីន ចូលមកជ្រកកោននៅក្នុងស្រុកនោះផង គាត់យល់ថា ពួកគេទទួលស្គាល់អំណាចរបស់គាត់ហើយ។ លោកយល់ទៀតថា គាត់មានឥទ្ធិពលកាន់តែខ្លាំងឡើងៗ អាចតទល់ជាមួយព្រះមហាក្សត្រប្រទេសកម្ពុជាបាន។

(១៥)លោកពីញ៉ូដឺបែន ជានាយកវិទ្យាល័យនៅតំបន់ហុងដាត ជិតហាទៀង គឺនៅក្នុងដែនដីដែលលោក ម៉ាក់ធានទុយ គ្រប់គ្រងនោះ។ ពេលក្រោយមក អ្នកកាន់អំណាចស្រុកនោះ បានចាប់លោកឃុំឃាំង ព្រោះមានគេប្តឹងមួលបង្កាច់។ នៅឆ្នាំ ១៧៦៩ ប្រជាជនខ្មែរបានបះបោរប្រឆាំងនឹងអំណាចរបស់ម៉ាក់ធានទុយនោះ ហើយបានដុតវិទ្យាល័យនេះចោល។ លោកពីញ៉ូដឺបេអែន

រត់គេចរួចជាមួយសិស្សរបស់លោកមួយចំនួនធំ ទៅក្រុងប៉ុងឌីសេរីនាប្រទេសឥណ្ឌា។ រីឯសិស្ស ជាតិសៀមវិញ គេទៅនៅភូមិគុកងួនជាមួយលោកឡឺវ៉ាស័រ ។

នៅឆ្នាំ ១៧៧៤ នាក្រុងម៉ាជ្រាស (Madras) ប្រទេសឥណ្ឌា លោកពីញ៉ូដឺបេអែន ទទួលបន្ទុកជាអភិបាលព្រះសហគមន៍ បន្តពីលោកពីហ្គែល។ គេតែងលោកថា «លោកអជ្រង់ (Mgr d'Aran)» គឺដោយយោងទៅតាមឈ្មោះទីស្នាក់ការ អភិបាលព្រះសហគមន៍របស់លោកនោះឯង។ លោកបានត្រឡប់មកហាទៀង រួចលោកក៏មកនៅបន្ទាយលង្វែក។ លោក Pianet, (op.cit.,p.400) សរសេរថា៖ «*ព្រះមហាក្សត្រទ្រង់សព្វព្រះហឫទ័យខ្លាំងណាស់ ដោយឃើញលោកអភិបាលព្រះសហគមន៍មកនៅជិតព្រះរាជវាំងដូចអស់លោកអភិបាលព្រះសហគមន៍មុនៗនោះដែរ។ ព្រះអង្គបានទទួលលោកអភិបាលព្រះសហគមន៍យ៉ាងរាក់ទាក់កកក្ដៅ និងដោយមេត្រីភាពជាទីបំផុត*»។

លោកដឺបេអែន តាំងទីស្នាក់ការរបស់លោកនៅភូមិប្រាំបីឆោម ហើយបានបង្កើតវិទ្យាល័យជាថ្មីម្តងទៀត ដោយមានលោកម័រវ៉ង់ជួយបង្រៀន និងមានសិស្សចំនួន ១២ នាក់។ នៅខែកញ្ញា ១៧៧៥ លោកបានយល់ព្រមតាមពាក្យអង្វររបស់លោកម៉ាក់ធានទុយ ហើយចាកចេញពីលង្វែកទៅនៅហាទៀងម្ដងទៀត។ នៅគ្រានោះ ពួកតៃសុន កំពុងច្បាំងពាសពេញប្រទេស។ លោកម៉ាក់ធានទុយសន្យាថា នឹងការពារលោកសាសនទូត ព្រមទាំងគ្រីស្តបរិស័ទទាំងអស់។ លោកអភិបាលបានសរសេរអំពីរឿងនេះថា៖ «*ព្រះមហាក្សត្រប្រទេសកម្ពុជាផ្ញើសារមកខ្ញុំ ហើយអញ្ជើញខ្ញុំឲ្យឡើងទៅព្រះរាជវាំងវិញ។ លោក ម៉ាក់ធានទុយ ដែលត្រួតត្រានៅកង់ការ (Cancao) បានជួយខ្ញុំគ្រប់បែបយ៉ាង។ គាត់ក៏អង្វរខ្ញុំឲ្យនៅជាមួយលោកដែរ ហើយជំទាស់ដាច់ខាត មិនឲ្យខ្ញុំធ្វើដំណើរទៅកម្ពុជាវិញឡើយ(...)។ ខ្ញុំដឹងច្បាស់ថា បំណងរបស់លោកជារឿងនយោបាយទេ ក៏ប៉ុន្តែ បំណងនោះអាចផ្តល់ផលប្រយោជន៍ដល់កិច្ចការប្រកាសដំណឹងល្អដែរ*» ។

គ្រីស្តបរិស័ទនៅដែនកូសាំងស៊ីន ដែលត្រូវគេធ្វើទុក្ខបុកម្នេញ បានរត់ចូលទៅនៅហាទៀង។ នៅសម័យនោះ លោកពីញ៉ូដឺបេអែន បានប្រាស្រ័យទាក់ទងជាមួយនឹងព្រះអង្គម្ចាស់ង្វៀងអាញ់ ដែលនៅពេលក្រោយបានឡើងធ្វើជាព្រះចៅអធិរាជវៀតណាមព្រះនាមយ៉ាឡុង។ នៅឆ្នាំ ១៧៧៦ លោកឡឺគ្លែរណែនាំវិទ្យល័យនៅហាទៀងនេះ។ ក៏ប៉ុន្តែ នៅឆ្នាំ ១៧៧៨ ព្រះមហាក្សត្រប្រទេសកម្ពុជា បានច្បាំងតទល់នឹងលោកម៉ាក់ធានទុយ។ កងទ័ពព្រះមហាក្សត្របានវាយកម្ទេចវិទ្យាល័យ សម្លាប់លោកឡឺគ្លែរ និងកូនសិស្ស ៤ នាក់ សម្លាប់ដូនជី វៀតណាម ៧ នាក់ និងគ្រីស្តបរិស័ទជាច្រើន ព្រមទាំងបានដុតផ្ទះនិងដុតព្រះវិហារផង។ ទាំងគ្រូទាំងសិស្សវិទ្យាល័យ ក៏ត្រាច់ចរទៅនៅដែនកូសាំងស៊ីន រត់គេចពីពួកតៃសុន ទាំងពួកនៅតាមទូកជាញយដង គឺ ត្រាច់រង្គត់ ជាមួយលោកពីញ៉ូដឺបេអែន និងបូជាចារ្យ ពីរបីនាក់ទៀត។ ក្នុងអំឡុងបីបួនឆ្នាំក្រោយមកគេ តាំងវិទ្យាល័យ នោះជាថ្មី នៅចន្ទបុិន ប្រទេសសៀម ដោយមានលោកលីយ៉ូជានាយក។

ក្រោយមក នៅឆ្នាំ ១៨០៨ គេតាំងវិទ្យាល័យនេះនៅកោះប៉េណាង (Penang) ជាកោះមួយ ភាគខាងជើងប្រទេសម៉ាឡេស៊ី។ វិទ្យាល័យនេះបានគ្រឡប់ទៅជាទេវវិទ្យាល័យភូមិភាគ សម្រាប់ទ្វីបអាស៊ី។ យុវជនខ្មែរជាច្រើននាក់បានសិក្សានៅទេវវិទ្យាល័យនេះ។ ក្នុងចំណោមសិស្សទាំងនោះមានតែម៉ាកសែលទ្រឿងចំរើន (Marcel Truong Chamroeun) ម្នាក់ទេ ដែលបានទៅជាបូជាចារ្យនៅឆ្នាំ ១៩៧៣ ។

(១៦)លិខិតចុះថ្ងៃទី ២៤ មិថុនា ឆ្នាំ ១៧៧៤ ស្រង់ចេញពីសៀវភៅ Launay, op.cit., III.p.64.

(១៧)លិខិតរបស់លោកហ្វូលៃ ចុះថ្ងៃទី ២៤ ខែមិថុនា ១៧៧៤ Launay, op.cit., III,p.64. ។ ក្នុងឆ្នាំ ១៧៩០ អស់លោកសាសនទូតបានចេញដំណើរពីដែនដីកូសាំងស៊ីន ទៅប្រកាសដំណឹងល្អចំពោះអ្នកស្រុកភ្នំម្តងទៀត តែគេទទួលបរាជ័យសាជាថ្មី។ ដល់ឆ្នាំ ១៨៥២ ទើបគេប្រកាសដំណឹងល្អចំពោះអ្នកស្រុកភ្នំបានសម្រេចដោយជោគជ័យ។

(១៨)វចនានុក្រមនេះ ជាគ្រឹះសម្រាប់អ្នករៀននៅពេលក្រោយៗមកទៀត។ គេបកប្រែជាភាសាខ្មែរ-បារាំង នៅសម័យលោក មីស គឺប្រហែលនៅឆ្នាំ ១៨៥០ ។

(១៩)កំណត់ហេតុប្រចាំថ្ងៃ របស់លោកឡឺវ៉ាវ៉ាស័រ ដកស្រង់ចេញពីសៀវភៅ Launay, op.cit., pp. 438-439 ។

(២០)លិខិតចុះថ្ងៃទី ១២ កក្កដា ១៧៦៩ ដកស្រង់ចេញពីសៀវភៅ Launay, op.cit., p, 425.

(២១)Launay, op.cit., 232-233.

(២២)Launay, op.cit., III, p.348.

(២៣)A.Dauphin Meunier, op.cit., p.103.

(២៤)លិខិតរបស់លោកយ័ដាន់ (Jourdain) ស្រង់ចេញពីសៀវភៅ Launay, op.cit., II, p. 445-447.

(២៥)លិខិតរបស់លោករ៉ាបូ (Rabeau) ផ្ញើទៅលោកលីយ៉ូ (Liot) ស្រង់ចេញពីសៀវភៅ Launay, op.cit., III, p.448.

(២៦)Launay, op.cit., III, pp. 447-448.

(២៧)Pianet, op.cit., p. 591. នៅឆ្នាំ ១៨៤២ លោកប៉ាល់ឡឺក្រូវ៉ា (Pallegroix) ដែលជាអភិបាលព្រះសហគមន៍ទទួលបន្ទុកប្រចាំប្រទេសសៀម សុំឲ្យនាយកទេវវិទ្យាល័យនៅប៉ារីស ចាត់សាសនទូតទៅបាត់ដំបង ដើម្បីណែនាំគ្រីស្តបរិស័ទខ្មែរ។ លោកគុយអេណូ (Cuenot) ដែលជា អភិបាលព្រះសគមន៍ទទួលបន្ទុកដែនកូសាំងស៊ីន និងកម្ពុជា បានជំទាស់នឹងពាក្យទាំងនេះ។ លោកសរសេរទៅនាយកទេវវិទ្យាល័យថា៖ «*បើប្រសិនមានសាររបស់សម្តេចប៉ាប ដាក់ប្រទេសកម្ពុជាឲ្យស្ថិតនៅក្រោមការ ណែនាំរបស់អភិបាលប្រចាំប្រទេសសៀមនោះ សូមមេត្តាចម្លងសារនោះផ្ញើមកខ្ញុំផង*»។

# ជំពូកទី ៦

# អភិបាលព្រះសហគមន៍មុនរាជវាំងឧដុង្គ

សេចក្តីប្រៀនប្រដៅ ដែលសម្តេចប៉ាបបានប្រកាសនៅឆ្នាំ ១៦៥៩ បញ្ជាយ៉ាងជាក់លាក់ ឲ្យជៀសវាងក្នុងការជ្រៀតជ្រែកក្នុងរឿងនយោបាយរបស់ប្រទេស ដែលអស់លោកទៅនៅ។ សម្តេចប៉ាប បានបញ្ចេញពាក្យប្រៀនប្រដៅនេះ ដើម្បីឲ្យអស់លោកទាំងនោះ បានរួចផុតពីឥទ្ធិពលរបស់មហាអំណាចព័រទុយហ្គាល់ និងអេស្ប៉ាញ ដែលត្រួតត្រាពិភពលោកទាំងមូលក្នុងសម័យនោះ។ ក៏ប៉ុន្តែ ការប្រកាសដំណឹងល្អរបស់អស់លោកតែងតែជាប់ជំពាក់ទៅក្នុងរឿងនយោបាយ ដូចកិច្ចការទាំងប៉ុន្មានរបស់មនុស្សទាំងពួងដែរ។ អស់លោកអភិបាលពុំអាចធ្វើមិនដឹងមិនឮ ចំពោះសភាពការណ៍នយោបាយបានទេ។ ជួនកាល អស់លោកបានខិតខំសម្រួលរឿងនយោបាយនោះថែមទៀតផង ដើម្បីជាប្រយោជន៍ដល់ប្រទេសដែលអស់លោកកំពុងរស់នៅដែរ។

ព្រះមហាក្សត្រប្រទេសកម្ពុជា ស្ទើរតែគ្រប់ព្រះអង្គ តែងតែសម្តែងព្រះហឫទ័យប្រោសប្រណីគោរព និងអនុគ្រោះចំពោះលោកអភិបាលព្រះសហគមន៍ទាំងប៉ុន្មាន និងចំពោះបព្វជិតទាំងឡាយ ដូចទ្រង់បានសម្តែងចំពោះបព្វជិតមកពីប្រទេសព័រទុយហ្គាល់ ឬប្រទេសអេស្ប៉ាញកាលពីដើមដែរ។ ព្រះមហាក្សត្រទាំង នោះប្រហែលជាឈ្វេងយល់ថា ព្រះអង្គនឹងអាចទទួលជំនួយខាងនយោបាយ និងយោធា តាមរយៈបូជា ចារ្យទាំងឡាយ ដែលទ្រង់ទទួលដោយរាក់ទាក់នោះ។ ទ្រង់ត្រូវការជំនួយទាំងនោះ ជាចាំបាច់សម្រាប់ការពារប្រទេសរបស់ព្រះអង្គ។ ម្យ៉ាងទៀត គ្រីស្តបរិស័ទមិនមានឥទ្ធិពលអ្វីខ្លាំងទៅលើប្រជាពលរដ្ឋរបស់ព្រះអង្គ និងមិនអាចបណ្តាលឲ្យប្រជារាស្ត្រប្រេះឆាបានឡើយ ពីព្រោះប្រជារស្ត្រ សឹងមានជំនឿស៊ប់ទៅលើព្រហ្មញ្ញសាសនានិងពុទ្ធសាសនា។ ទោះបីព្រះមហាក្សត្រទាំងឡាយកាន់ពុទ្ធសាសនាក៏ដោយ ក៏ទ្រង់តែងតែគោរពបូជាចារ្យរបស់សាសនាឯទៀតៗដែរ និងធ្លាប់ចំណាយព្រះរាជទ្រព្យសម្រាប់សង់វិហារសាសនាទាំងនោះផង។ ចំណែកឯសាសនទូតវិញ លោកតែងទាក់ទង យ៉ាងជិតស្និទ្ធជាមួយអ្នកកាន់អំណាច

ទាំងឡាយ ព្រោះអស់លោកគិតថា ព្រះរាជាអាចអនុគ្រោះ និងការពារគ្រីស្តបរិស័ទទាំងអស់បាន។ ដូច្នេះ ទោះបីសាសនទូតទាំងនោះ ពុំមានបំណងចូលឡូកឡំក្នុងរឿងនយោបាយក៏ដោយ ក៏អស់លោកបានចូលជាញឹកញយដែរ ព្រោះលោកទាំងនោះតែងរួមរស់យ៉ាងជិតស្និទ្ធជាមួយនឹងប្រជាជន ហើយចែករំលែកវាសនារបស់ប្រជាជននោះផង។ ជួនកាលសាសនទូតបានប្រព្រឹត្តហួសពីភារកិច្ចផ្សាយសាសនារបស់អស់លោកផង(១) ។

«**សូមបុរេសេចារាំងកុំចុះទីអនុគ្រោះគមន៍យាធានាឡើយ** »

នៅឆ្នាំ ១៨៤៥ ប្រជាជនខ្មែរបានបះបោរប្រឆាំង នឹងពួកឧត្តមសេនីយ៍ និងពួកមន្ត្រីវៀតណាម ដែលប្រមាថមើលងាយខ្មែរហួសហេតុនោះ។ ប្រទេសសៀមបានបញ្ជូនកងទ័ពមកជួយខ្មែរ តែគ្មានកងទ័ពណាបានទទួលជ័យជំនះពិតប្រាកដទេ។ ដូច្នេះ នៅពេលនោះ ព្រះចៅប្រទេសសៀមនិងព្រះចៅប្រទេសវៀតណាមបានមូលមតិគ្នាអភិសេកព្រះអង្គម្ចាស់អង្គឌួង ធ្វើជាព្រះមហាក្សត្រនៃប្រទេសកម្ពុជា។ តាមកិច្ចព្រមព្រៀងរវាងសៀមនិងវៀតណាមនោះ ប្រទេសទាំងពីរមានសិទ្ធិត្រួតត្រាលើប្រទេសខ្មែរ និងបានលេបយកទឹកដីខ្មែរដែលខ្លួនវាយយកបាន ក្នុងរវាងហាសិបឆ្នាំមុន ធ្វើជាកម្មសិទ្ធរបស់ខ្លួនរហូត។

តែព្រះអង្គឌួង មិនចាញ់បោកសៀមនិងវៀតណាមទេ ទ្រង់ជ្រាបច្បាស់ថាសៀមត្រួតមើលព្រះអង្គ ហើយវៀតណាមក៏នៅតែគំរាមវាយនគរព្រះអង្គដែរ។ ព្រះបាទអង្គឌួងមានព្រះបំណង ចង់សុំការគាំទ្រពីប្រទេសអង់គ្លេស ឬពីប្រទេសបារាំង ដើម្បីបានឯករាជ្យមកជូនមាតុភូមិវិញ។ នៅសម័យនោះ កងទ័ពអង់គ្លេសបានចូលមកនៅក្នុងប្រទេសភូមាហើយ រីឯបារាំងវិញ ពួកគេមាននាវាបើកបរក្នុងដែនសមុទ្រឥណ្ឌូចិន រកផ្លូវចូលទៅប្រទេសចិនដែរ។ ដូច្នេះ ព្រះអង្គត្រូវប្រើកលល្បិចដើម្បីបំភាន់ព្រះចៅនៃប្រទេសជិតខាងទាំងពីរ។ ទ្រង់នឹកចាំដល់លោក យ៉ូហាន ក្លូត មីស ( Jean Claude Miche ) ដែលទ្រង់បានស្គាល់តាំងពីព្រះអង្គនៅជាព្រះរាជកុមារ នៅឯរាជវាំងក្រុងបាងកកម្ល៉េះ។ ទ្រង់ឈ្វេងយល់ថា ដោយលោកបូជាចារ្យមីស នេះចេះនិយាយភាសាខ្មែរផងនោះ លោកនឹងអាចជួយធ្វើអន្តរាគមន៍បានយ៉ាងប្រសើរ ក្នុងការទាក់ទងជាមួយរដ្ឋអំណាចបារាំង។

ចំណែកឯលោក យ៉ូហាន ក្លូតមីសវិញ លោកបានចាកចេញពីបាត់ដំបងនៅឆ្នាំ ១៨៤០

ទៅនៅក្រុង ម៉ាឡាកា ប្រទេសម៉ាឡេស៊ី។ លោកតាបែរ (Taberd) ដែលជាអភិបាលព្រះសហគមន៍ទទួលបន្ទុកដែនកូសាំងស៊ីន និងប្រទេសកម្ពុជា អញ្ជើញលោកមីសឲ្យត្រឡប់ចូលមកកម្ពុជាវិញ ហើយចាត់លោកឲ្យទៅប្រកាសដំណឹងល្អដល់ជនភាគតិចដែលរស់នៅតាមជួរភ្នំអណ្ណាម។ អ្នកកាន់អំណាចវៀតណាមបានចាប់លោក និងបូជាចារ្យឯទៀតៗដាក់គុក ហើយលោកត្រូវគេកាត់ទោសប្រហារជីវិតថែមទៀតផង។ ដោយមានកប៉ាល់បារាំងមួយគ្រឿងឈ្មោះហេរ៉ូអ៊ីន (Héroïne) បានមកចត នៅកំពង់ផែទូរ៉ាន (ដាណាង) អាជ្ញាធរវៀតណាមក៏ដោះលែងលោកឲ្យរួច។ ព្រះបាទអង្គឌួងបានប្រមូលគ្រីស្តបរិស័ទជាកូនកាត់ខ្មែរ-ព័រទុយហ្គាល់ ដែលសល់ពីស្លាប់ដោយសារសង្គ្រាមឲ្យនៅមួយកន្លែង ដើម្បីទាក់ទាញចិត្តលោកមីសឲ្យសុខចិត្តត្រឡប់មកប្រទេសកម្ពុជាវិញ។ ទ្រង់ក៏បានបង្កើតភូមិពញាឮជាថ្មីឡើងវិញ គឺនៅត្រង់កន្លែងភូមិផ្ទោលចាស់។ ព្រះមហាក្សត្រចាត់គ្រីស្តបរិស័ទខ្មែរ ឲ្យទៅរកលោកមីសនៅដែនកូសាំងស៊ីន។ នៅទីនោះលោកមីសត្រូវពួកវៀតណាម តាមឃ្លាំមើលជាប់ជានិច្ច។ ពេលលោកមីស មកដល់ប្រទេសកម្ពុជាវិញ ព្រះបាទអង្គឌួងទទួលលោកយ៉ាងអធិកអធម។ លោកមីសស្នាក់នៅពញាឮក្បែរព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា។ នៅឆ្នាំ ១៨៤៨ ក្នុងលិខិតមួយផ្ញើជូនមិត្តរបស់លោកម្នាក់ លោកមីសបានរ៉ាយរ៉ាប់អំពីព្រះបាទអង្គឌួង ដែលបានទទួលលោកយ៉ាងរាក់ទាក់និងយ៉ាងកក់ក្តៅជាទីបំផុត លោកក៏មានការចាប់អារម្មណ៍ប្លែកខ្លះដែរ។ ពេលសន្ទនាជាមួយលោក ព្រះបាទអង្គឌួងបានបង្ហាញឲ្យលោកដឹងថា ព្រះអង្គមានព្រះបំណងបញ្ជូនជនជាតិខ្មែរខ្លះ ឲ្យទៅសិក្សានៅប្រទេសបារាំង។ ព្រះអង្គសុំឲ្យលោក មីស តែងលិខិតថ្វាយទៅព្រះមហាក្សត្របារាំង ក្នុងនាមព្រះអង្គ ក៏ប៉ុន្តែលោកមីសបានឆ្លើយដោះដៃដោយយកលេសថា លោកពុំមែនជាអ្នករាជការ ឬអ្នកនយោបាយទេ។ លោកជូនយោបល់ថ្វាយព្រះមហាក្សត្រថា សូមព្រះអង្គសរសេរព្រះសារលិខិតដោយផ្ទាល់ព្រះអង្គវិញ ហើយលោកសន្យាថា នឹងជួយបកប្រែព្រះរាជសារនេះថ្វាយ។ លោកអភិបាលព្រះសហគមន៍ យល់ពីព្រះបំណងរបស់ព្រះមហាក្សត្រ នៅពេលដែលព្រះមាតារបស់ព្រះអង្គជម្រាបលោកថា៖ «*វត្តមានរបស់ពួកអឺរ៉ុបនៅប្រទេសកម្ពុជា គឺពិតជាធ្វើឲ្យពួកវៀតណាមខ្លបខ្លាច*»។ លោកបានបញ្ចប់លិខិតរបស់លោក ដោយបញ្ជាក់ពីយោបល់របស់លោកផ្ទាល់ថា៖ «*ដើម្បីសេចក្តីសុខរបស់យើង និងរបស់អ្នកទើបចូល*

*គ្រីស្តសាសនាសូមកុំឲ្យប្រទេសបារាំងធ្វើអន្តរាគមន៍យោធាអ្វីឡើយ*»(២) ។

ថ្ងៃទី ២០ កក្កដា ឆ្នាំ ១៨៥២ លោកមីសបានសសេរលិខិតមួយច្បាប់ ទៅជូនលោកកុងស៊ុលបារាំង នៅសិង្ហបុរី ដើម្បីជម្រាបលោកឲ្យជ្រាប អំពីព្រះរាជបំណងរបស់ព្រះមហាក្សត្រខ្មែរ ដែលចង់ទាក់ទងជាមួយលោក។ ថ្ងៃទី ១០ ធ្នូ លោកកុងស៊ុលបានឆ្លើយតបមកវិញ តាមរបៀបដោះដៃយករួចខ្លួន និងសុំឲ្យលោកអភិបាលព្រះសហគមន៍បកប្រែលិខិតរបស់លោកថ្វាយព្រះរាជាវិញ។ ថ្ងៃទី ២៣ មករា ឆ្នាំ ១៨៥៣ លោកមីសបានសសេរលិខិតថ្មីមួយច្បាប់ទៀត ទៅជូនលោកកុងស៊ុល ទាំងបរិយាយអំពីហេតុដែលនាំឲ្យលោកមិនព្រមឲ្យជនជាតិបារាំង ធ្វើអន្តរាគមន៍យោធាក្នុងឆ្នាំនៅប្រទេសកម្ពុជាផង។ លោកបានអះអាងថា ក្នុងឋានៈជាបូជាចារ្យ លោកពុំព្រមធ្វើនយោបាយទេ ហើយអន្តរាគមន៍យោធារបស់ប្រទេសបារាំង នឹងរំលោភលើកិច្ចព្រមព្រៀងរវាងប្រទេសឲ្យសៀម និងប្រទេសកម្ពុជាវៀតណាម ស្តីអំពីប្រទេសកម្ពុជា។ អន្តរាគមន៍នេះ នឹងបណ្តាលឲ្យខូចប្រយោជន៍គ្រីស្តសាសនា ព្រោះអាចបណ្តាលឲ្យ មានការធ្វើទុកបុកម្នេញចំពោះគ្រីស្តបរិស័ទពុំខាន។ ម្យ៉ាងទៀត ការដែលព្រះមហាក្សត្រសុំឲ្យប្រទេសបារាំងជួយធ្វើអន្តរាគមន៍នេះ ពុំមែនមកពីទ្រង់សព្វព្រះហឫទ័យនឹងប្រទេសបារាំង ឬក៏ទ្រង់មានព្រះហឫទ័យអនុគ្រោះចំពោះគ្រីស្តសាសនាទេ គឺគ្រាន់តែជារឿងនយោបាយប៉ុណ្ណោះ។ ទ្រង់ជ្រាបច្បាស់ថា៖ «*វត្តមានពួកយើងនៅទីនេះ នឹងធ្វើឲ្យពួកវៀតណាមខ្លាច*»។ ព្រះរាជាបានជួយគ្រីស្តបរិស័ទក៏ពិតមែន ក៏ប៉ុន្តែ ទ្រង់ប្រើអំណាចផ្តាច់ការ ហើយទ្រង់ចង់ឲ្យគេធ្វើតាមព្រះរាជបញ្ជានៅគ្រប់ហេតុការណ៍ទាំងស្រុង។

ថ្ងៃទី ១៤ ឧសភា ឆ្នាំ ១៨៥៣ ដោយមានលោកមីសជួយបកប្រែផង ព្រះបាទអង្គឌួង បានសរសេរព្រះរាជសារថ្មីមួយច្បាប់ទៀត ផ្ញើទៅថ្វាយព្រះចៅណាប៉ូលេអុងទី ៣ (Napoléon III) ដើម្បីបញ្ជាក់ថ្វាយព្រះចៅឲ្យទ្រង់បានជ្រាបថា សាសនទូតបារាំងទាំងឡាយរស់នៅដោយសុខសាន្ត។ ទ្រង់ក៏បានទូលថ្វាយព្រះចៅណាប៉ូលេអុងទី ៣ សាជាថ្មីអំពីពួកសៀមនិងពួកវៀតណាមដែលធ្វើទុកបុកម្នេញប្រជាជនខ្មែរយ៉ាងខ្លាំងនោះ។ ព្រះមហាក្សត្របានប្រគល់ព្រះរាជសារនោះឲ្យខ្មែរកាតូលិកពីរនាក់ ឈ្មោះកុយដឺម៉ុងតីរ៉ូ និងប៉ែន នាំយកទៅជូនកុងស៊ុលបារាំងនៅសិង្ហបុរី។ គេក៏បាននាំយកសួយសារអាករទៅជាមួយផង គឺមានកុយរមាសបួន ជ័ររង្គ ៣០០ គ.ក. និងស្កអំពៅ ៣០០គ.ក. និងម្រេច ៣០០ គ.ក. ។ ព្រះរាជសារនេះ ពុំបានទទួលចម្លើយអ្វីឡើយ ។

ពីរឆ្នាំក្រោយមក ក្នុងខែវិច្ឆិកា ឆ្នាំ ១៨៥៥ ព្រះចៅអធិរាជប្រទេសបារាំងបានបញ្ជាឲ្យលោកដឺម៉ុងទីញី (De Montigny) ជារដ្ឋមន្ត្រីបំពេញភារកិច្ចនៅប្រទេសសៀម និងនៅប្រទេសចិន ចុះសន្ធិសញ្ញាជំនួញជាមួយនឹងប្រទេសសៀម។ រួចលោកត្រូវទៅក្រុងទូរ៉ាន (ដាណាង) ដើម្បីស្តីបន្ទោសអ្នកកាន់អំណាចវៀតណាម ដែលធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ។ ក្រុងបាងកក លោកដឺម៉ុងទីញីគិតថា ព្រះមហាក្សត្រសៀមមិនជំទាស់ចំពោះ «*វត្តមានជនជាតិបារាំងជាអ្នកជិតខាងឡើយ*»។ លោកបាន ទាំងទូលស្នើព្រះមហាក្សត្រសៀមថា ឲ្យប្រទេសបារាំងយកកោះខ្មែរឈ្មោះកោះឧត (Phu Quoc) នោះថែមទៀតផង។ ដោយឃើញព្រះចៅនៅសៀម លោកយល់ច្រឡំស្មានថា ព្រះចៅមិនជំទាស់ទេ ហើយលោក ដឺម៉ុងទីញី ក៏ហ៊ានរហូតដល់សុំព្រះចៅសៀម ឲ្យទ្រង់ធ្វើព្រះរាជសារមួយច្បាប់ថ្វាយព្រះមហាក្សត្រអង្គឌួង ឲ្យស្តេចអង្គឌួងនេះ ចុះសន្ធិសញ្ញាជាមួយប្រទេសបារាំង ដូចសន្ធិសញ្ញាដែលប្រទេសសៀមទើបនឹងបានជាមួយប្រទេសបារាំងនេះដែរ។ លោកភ្លេចទាំងគិតថា ធ្វើដូច្នេះ បានសេចក្តីថា ប្រទេសបារាំងមុខជាត្រួតត្រាប្រទេសកម្ពុជា ជំនួសប្រទេសសៀមទេ។

នៅខែតុលា ឆ្នាំ ១៨៥៦ លោក ដឺម៉ុងទីញីមកដល់ប្រទេសកម្ពុជា ចុះនៅកំពង់ផែកំពត។ លោកមីសបានថ្វាយដំណឹងនេះ ដល់ព្រះបាទអង្គឌួងឲ្យទ្រង់ជ្រាប។ ព្រះមហាក្សត្របានបញ្ជាឲ្យគេរៀបចំដំណាក់មួយ សម្រាប់ទទួលទូតប្រទេសបារាំង ដោយមានជំនួយពីលោកមីស និងពីលោកហេស្រ្តេត (Hestret) ផង។ លោកហេស្រ្តេតជាបូជាចារ្យទទួលបន្ទុកព្រះសហគមន៍នៅកំពត។ ក៏ប៉ុន្តែ ដោយទ្រង់បារម្ភខ្លាចព្រះមហាក្សត្រសៀមទ្រង់ព្រះពិរោធ ព្រះបាទអង្គឌួងមិនបានយាងទៅទទួលទូតនោះ ដោយព្រះអង្គផ្ទាល់ទេ។ ពេលនោះ លោកដឺម៉ុងទីញីបានតាក់តែង «*អនុសញ្ញាពាណិជ្ជកម្មនិងសាសនា*» មួយ។ លោកបានផ្ញើអនុសញ្ញានោះ ទៅថ្វាយព្រះបាទអង្គឌួងតាមរយៈលោកហេស្រ្តេតសុំព្រះអង្គឡាយព្រះហស្តលេខា។ លោកហេស្រ្តេតយល់ថា បេសកកម្មនេះពិបាកដោះស្រាយ លោកក៏សុំលោកអូសូឡី (Aussoleil) ឲ្យទៅជាមួយ។ សាសនទូតទាំងពីរនាក់សុំគាល់ព្រះមហាក្សត្រផ្ទាល់។ ផ្ទុយទៅវិញ ព្រះអង្គបានទទួលលោកទាំងពីរ នៅចំពោះមុខនាម៉ឺនសព្វមុខមន្ត្រីទាំងអស់នៅក្នុងវាំង មានទាំងមន្ត្រីសៀមជាច្រើននៅជាមួយផង។ ព្រះរាជាទ្រង់មានព្រះបន្ទូលក្រេវក្រោធចំពោះលោកដឺម៉ុងទីញី និងចំពោះបារាំងជាទូទៅដើម្បីបំភាន់កុំឲ្យរាជការសៀមភ័យ។ ស្អែកឡើងព្រះអង្គប្រគល់ព្រះរាជសារមួយផ្ទាល់

ព្រះអង្គ ឲ្យលោកហេស្រ្គេត ដើម្បីផ្ញើទៅថ្វាយព្រះចៅណាប៉ូលេអុងទី ៣ ។ ក្នុងព្រះរាជសារនោះ ទ្រង់ប្ដឹងអំពីពួកវៀតណាម ដែលធ្វើទុក្ខបុកម្នេញប្រជាជនខ្មែរ ហើយសុំជំនួយពីប្រទេសបារាំង ដើម្បីឲ្យព្រះអង្គមានលទ្ធភាពដណ្ដើមយកខេត្ត ដែលបាត់បង់ទៅហើយនោះមកវិញ។

បេសកកម្មរបស់លោកដឺម៉ុងទីញីទទួលបរាជ័យ ហើយបណ្ដាលឲ្យគ្រីស្ដបរិស័ទនៅប្រទេសកម្ពុជា និងគ្រីស្ដបរិស័ទនៅខេត្តបាត់ដំបង ដែលស្ថិតនៅក្រោមការត្រួតត្រារបស់សៀម ជួបនូវការលំបាក។ ក៏ប៉ុន្ដែ ទុក្ខលំបាកទាំងនោះ ធូរស្រាលជាងទុក្ខលំបាកដែលគ្រីស្ដបរិស័ទបានជួបប្រទះនៅឯវៀតណាមនោះ។

លោកមីសបានជូនដំណើរលោកដឺម៉ុងទីញីទៅខេត្តទូរ៉ាន (ដាណាង) ។ ពេលលោកមីសត្រឡប់វិញ លោកអញ្ជើញទៅគាល់ព្រះបាទអង្គឌួង ដែលទន្ទឹងរង់ចាំមើលផ្លូវលោក។ លោកអភិបាលព្រះសហគមន៍ ស្ដីបន្ទោសព្រះរាជាជាខ្លាំង ចំពោះការដែលព្រះអង្គមានព្រះបន្ទូលប្រមាថដល់លោកហេស្រ្គេតនិងលោកអូសូឡីនោះ។ ព្រះមហាក្សត្រទ្រង់តបទៅលោកវិញថា ព្រះអង្គសព្វព្រះហឫទ័យនឹងលោកអភិបាលព្រះសហគមន៍ ហើយនឹងសាសនទូតទាំងឡាយ រួចទ្រង់បន្ថែមថា៖ «*តើលោកឲ្យខ្ញុំធ្វើយ៉ាងដូចម្ដេច បើព្រះចៅប្រទេសសៀមបានផ្ញើសារមកគំរាមខ្ញុំ ខារខាំងខ្ញុំ មិនឲ្យចុះសន្ធិសញ្ញាជាមួយប្រទេសបារាំង...។ ប្រសិនជាលោកបានអញ្ជើញមកផ្ទាល់ ប្រហែលជាយើងទាំងពីរនាក់អាចដោះស្រាយកិច្ចការហ្នឹងបានដោយស្រួល*» ។

ថ្ងៃទី ១៧ កុម្ភៈ ឆ្នាំ ១៨៥៩ ពួកបារាំងវាយលុកបន្ទាយព្រៃនគរ ហើយចាប់ផ្ដើមវាយយកដែនដីកូសាំងស៊ីន។ លោកឧត្ដមនាវី រីហ្គោលដឺហ្សឺនូយី (Amiral Rigault de Genouilly) ជាមេបញ្ជាការដឹកនាំកងទ័ពបារាំងទាំងនោះ។ ព្រះបាទអង្គឌួងសុំឲ្យលោកមីសបកប្រែព្រះរាជសារមួយច្បាប់ ស្នើចងសម្ព័ន្ធមេត្រីជា មួយឧត្ដមនាវីនោះ ដោយផ្ដល់យោបល់ថា ឲ្យកងទ័ពខ្មែរវាយយកខេត្តមាត់ជ្រូក និងខេត្តហាទៀង [៣] ។ លោកអភិបាលព្រះសហគមន៍ប្រកែក ពុំព្រមបកប្រែថ្វាយព្រះអង្គទេ។ លោកជ្រាបថាពួកអ្នកយុទ្ធសាស្រ្តបារាំងនឹងសប្បាយចិត្ត ដោយព្រះរាជាខ្មែរវាយប្រហារពួកវៀតណាមពីក្រោយខ្នងដូច្នេះ។ ក៏ប៉ុន្ដែ លោកយល់ថា បើពឹងពាក់ប្រទេសកម្ពុជា ដើម្បីត្រួតត្រាដែនកូសាំងស៊ីនដូច្នេះ មិនសមសោះ។ ម្យ៉ាងទៀតលោកយល់ថា សម្ព័ន្ធមេត្រីបែបនេះ

នឹងបណ្ដាលឲ្យ ពួកវៀតណាមវាយលុកប្រទេសកម្ពុជាវិញ ព្រមទាំងធ្វើឲ្យគ្រីស្ត បរិស័ទវិនាសហើនហោចជាពុំខាន។

បន្ទាប់ពីវៀតណាមច្បាំងឈ្នះមក ការទាក់ទងរវាងព្រះបាទអង្គឌួង និងលោកមីស មានសភាពអាប់អួរតានតឹងជាខ្លាំង។ លោកអភិបាលព្រះសហគមន៍ បានសរសេរ ជម្រាបនាយកទេវវិទ្យាល័យម្នាក់នៅក្រុងប៉ារីសថា៖

*«បើប្រសិនជាយើងពុំមានជនជាតិបារាំងនៅជិតទេ ឬក៏ប្រសិនបើប្រទេសបារាំង មិនចុះសន្ធិសញ្ញាជាមួយប្រទេសកម្ពុជាទេនោះ យើងទ្រាំទ្រនៅស្រុកនេះលែងកើត ហើយ គឺយើងពិបាកជាងវដ្ដអំណាចធ្វើទុកបុកម្ទេញ ដោយចេញមុខទៅទៀត។ ព្រះមហាក្សត្រចាស់ជរាអង្គនេះ រកតែឱកាសធ្វើឲ្យយើងឈឺចាប់ពុំខានឡើយ។ ក្នុងគ្រាដំបូងនៃសង្គ្រាមនៅដែនកូសាំងស៊ីន ស្ដេចអង្គនេះធ្វើល្អនឹងយើងណាស់។ តែតាំងពីព្រះអង្គស្ដាប់ និងជឿតាមពួកមន្ត្រីវៀតណាម ដែលទូលព្រះអង្គថា ពួកវាវាយឈ្នះ គ្រប់សមរភូមិនោះមក ព្រះអង្គបានបង្ខំគ្រីស្ដបរិស័ទដែលបាន ដង្ហែព្រះអង្គទៅកំពត ឲ្យដាក់បាតតាមព្រះពុទ្ធសាសនា។ ព្រះអង្គបង្ខំគេទាំង បំពានទៅលើព្រះកិច្ចសន្យា ដែលព្រះអង្គបានធ្វើជាមួយខ្ញុំកាលពីពីរឆ្នាំមុនថា៖ «មិនត្រូវបង្ខិតបង្ខំគ្រីស្ដបរិស័ទឲ្យធ្វើតាមព្រះពុទ្ធសាសនាឡើយ»។ ជួនកាល ស្ដេចបើកហិបអីវ៉ាន់របស់យើង ហើយពេលហិបនោះមកដល់ផ្ទះយើង តែងតែ មានបាត់នេះបាត់នោះពុំខានឡើយ។ តើរបៀបដូច្នេះឬ ដែលគេហៅថាមិត្តភាព នោះ? ហ៊ឺ! នេះគឺជានឹមដែលសង្កត់ខ្ញុំធ្ងន់ណាស់!។ ដោយគ្មានអ្វីជាទីពឹង ខ្ញុំត្រូវតែ ខាំមាត់សង្កត់ចិត្តបៀមទុក្ខ ហើយនៅស្ងៀមមិនស្រដី។ ខ្ញុំខំធ្វើយ៉ាងនេះ ដើម្បីជា ប្រយោជន៍ដល់គ្រីស្ដសាសនាតែប៉ុណ្ណោះ។ ប្រសិនបើមិនគិតពីសាសនាទេ ខ្ញុំប្រាកដជាទ្រាំមិនបាននិងអ្នកកាន់អំណាចផ្ដាច់ការរបៀបនេះ តាំងពី យូរយារមកហើយ...*[៤] ។

**គ្រីស្តបរិស័ទបម្រើព្រះមហាក្សត្រដោយចិត្តស្មោះស្ម័គ្រ**

ព្រះបាទអង្គឌួងទ្រង់សោយទិវង្គត នាថ្ងៃទី ៨ តុលា ឆ្នាំ ១៨៦០។ ព្រះអង្គម្ចាស់វត្តី ជាព្រះរាជបុត្រច្បងបានឡើងស្នងសោយរាជ្យ ដោយយកព្រះនាមថា "*ព្រះនាមនរោត្តម*" គឺជាព្រះនាមដែលព្រះចៅសៀមបានដាក់ថ្វាយ។ ព្រះរាជាជ្រើសយកគ្រីស្ដបរិស័ទបីនាក់ ឲ្យធ្វើជាមហាមន្ត្រី។ ព្រះមហាក្សត្រថ្មីតែងតែមានទំនាក់ទំនងល្អជាមួយលោកមីស។

លោកមីសបានសរសេរទៅជម្រាបនាយកទេវវិទ្យាល័យ នៅក្រុងប៉ារីសថា៖

*«ខ្ញុំមានទំនាក់ទំនងល្អជាមួយព្រះករុណាជាអម្ចាស់ថ្មី។ ក៏ប៉ុន្តែ ខ្ញុំមិនទុកព្រះហឫទ័យព្រះអង្គទេ!។ ព្រះមហាក្សត្រអង្គនេះ ទ្រង់ជ្រាបថា ព្រះចៅប្រទេសសៀម ដែលត្រួវត្រួតលើព្រះអង្គ ស្រឡាញ់និងគោរពខ្ញុំ។ នេះជាហេតុដែលព្រះបាទនរោត្តមគោរពខ្ញុំ និងរាប់អានខ្ញុំនោះ។ ខ្ញុំយល់ថា ព្រះអង្គម្ចាស់ឯទៀតៗ ដែលជាព្រះអនុជ ក៏មានព្រះទ័យដូច្នេះដែរ។ ពេលថ្មីៗនេះ ព្រះអង្គម្ចាស់ក្មេងជាងគេ ដែលត្រូវព្រះចៅសៀមឃុំឃាំងនៅឯបាងកក បានត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ដើម្បីធ្វើព្រះរាជពិធីថ្វាយព្រះភ្លើងបរមសពព្រះបិតា។ ព្រះអង្គម្ចាស់នេះ ប្រញាប់ប្រញាល់មកសួរសុខទុក្ខខ្ញុំ ហើយខ្សិបដាក់ត្រចៀកខ្ញុំ ដោយឥតអៀនខ្មាស់ថា៖ «ថ្ងៃណាលោកចង់ឲ្យខ្ញុំបានឡើងសោយរាជ្យ ថ្ងៃនោះខ្ញុំនឹងបានទៅជាស្ដេចនៃប្រទេសកម្ពុជា»។ ខ្ញុំតបទៅវិញថា ខ្ញុំពុំមានអំណាចអ្វីនៅប្រទេសកម្ពុជាសោះឡើយ ខ្ញុំពុំចូលប្រឡូកនឹងរឿងនយោបាយទេ ខ្ញុំមានករណីយកិច្ចតែមួយគត់ គឺបង្ហាត់បង្រៀនគ្រីស្ដបរិស័ទ និងណែនាំអ្នកទាំងនោះ ឲ្យចេះគោរពបម្រើព្រះជាម្ចាស់ ព្រមទាំងគោរពបម្រើ ព្រះមហាក្សត្រ ដោយចិត្តស្មោះស្ម័គ្រ។ ជាអកុសលចំពោះខ្ញុំ ព្រះចៅប្រទេសសៀមទ្រង់ជឿជាក់ថា ខ្ញុំមានអំណាចពេញទីនៅប្រទេសកម្ពុជា។ ប្រហែលមកពីហេតុនេះហើយ ទើបព្រះអង្គរាប់អានខ្ញុំនោះ។ ខ្ញុំបានខិតខំបំភ្លឺព្រះអង្គ កុំឲ្យទ្រង់យល់ច្រឡំតទៅទៀត...។ តាមពិត នៅទីនេះ ខ្ញុំគ្មានអំណាចអ្វីសោះឡើយ ក៏ប៉ុន្តែ ខ្ញុំពិបាកចិត្តជាទីបំផុត ព្រោះថា នៅប្រទេសសៀម គេជឿថា នៅប្រទេសកម្ពុជា ខ្ញុំធ្វើអ្វីក៏បានដែរ ហើយនៅប្រទេសកម្ពុជាវិញ គេជឿ ជាក់ថា ខ្ញុំអាចក៏សុំអ្វីបានទាំងអស់ដែរពីព្រះចៅសៀម។ ប្រសិនបើចេះឆ្លៀតទាញយកផលប្រយោជន៍ យើងមុខជានឹងរកប្រយោជន៍បានច្រើន ក៏ប៉ុន្តែ បើយើងភ្លាំងភ្លាត់តែបន្តិចនោះ យើងមុខជានឹងខាតបាត់បង់អស់»*(៥)។

គ្រីស្តបរិស័ទបាន «*បម្រើព្រះមហាក្សត្រដោយចិត្តស្មោះស្ម័គ្រ*» មែន។ គ្រាដែលព្រះបាទនរោត្តម ឡើងគ្រងរាជ្យ ព្រះអង្គម្ចាស់ស៊ីវុត្ថាជាព្រះអនុជរបស់ព្រះអង្គ បានបះបោរប្រឆាំងព្រះអង្គ។ គ្រាដំបូងព្រះអង្គម្ចាស់ស៊ីវុត្ថាច្បាំងឈ្នះ ហើយបានបង្ខំព្រះបាទនរោត្តមឲ្យយាងត្រឡប់ទៅកាន់ព្រះរាជវាំងសៀមវិញ ទាំងយកនូវលំពែងរាជ្យ និងព្រះខ័នរាជ្យ គឺគ្រឿងសម្រាប់សោយរាជ្យទៅជាមួយផង។ ព្រះអង្គម្ចាស់ស៊ី សុវត្ថិជាព្រះអនុជទី ២ បានច្បាំងនឹងព្រះអង្គម្ចាស់ស៊ីវុត្ថាតទៅទៀត។ ពេលនោះ លោកមីសបានបញ្ជាឲ្យ

គ្រីស្ដបរិស័ទកាតូលិកទាំងឡាយ កាន់អាវុធច្បាំងគាំទ្រព្រះបាទនរោត្តម។ លោកអភិបាលព្រះសហគមន៍ បានណែនាំពួកចាម និងពួកជ្វា ដែលកាន់សាសនាអ៊ីស្លាម ឲ្យជួយគាំទ្រព្រះបាទនរោត្តមផងដែរ គឺលោកបានសន្យាជាមួយពួកគេថា នឹងត្រឡប់ទ្រព្យសម្បត្តិ ព្រមទាំងឋានន្តរស័ក្តិឲ្យគេវិញ (ព្រះបាទអង្គឌួង បានដកហូតយកទ្រព្យសម្បត្តិ និងយសស័ក្តិពីពួកគេ កាលពីឆ្នាំ ១៨៥៨ ព្រោះពួកនេះបានបះបោរប្រឆាំង នឹងព្រះរាជអំណាច)។ លោកក៏បញ្ចុះបញ្ចូល ទាហានបារាំងផុតកំណែនប្រាំនាក់ ដែលគាំទ្រព្រះអង្គម្ចាស់ស៊ីវុត្ថា ឲ្យមកធ្វើជាមេបញ្ជាការលើកងទ័ព ដែលស្មោះត្រង់នឹងព្រះរាជាវិញ។ គេបានវាយក្រុមបះបោរ និងព្រះអង្គម្ចាស់ស៊ីវុត្ថា ដេញរហូតដល់ភាគខាងខេត្តក្រចេះ។ ពីរបីឆ្នាំក្រោមក ព្រះអង្គស៊ីវុត្ថាក៏ចូលទិវង្គតនៅទីនោះទៅ។

បន្ទាប់ពីបានជ័យជំនះលើពួកអ្នកបះបោរមក លោកមីសស៊ុំលោកកុងស៊ុលប្រទេសបារាំងនៅក្រុងបាងកក ធ្វើអន្តរាគមន៍សុំព្រះរាជអនុញ្ញាតពីព្រះចៅសៀម យាងព្រះបាទនរោត្តម មកមាតុភូមិវិញ តាមកប៉ាល់។ ព្រះចៅសៀមទ្រង់មានព្រះហឫទ័យសោមនស្សរីករាយជាទីបំផុត ដោយលោកមីសស៊ុំដូច្នេះ គឺហាក់ដូចជាលោកបញ្ជាក់ថា ព្រះអង្គមានសិទ្ធិត្រួតត្រាលើប្រទេសកម្ពុជា។ ទ្រង់អនុញ្ញាតតាមពាក្យសុំ ហើយបញ្ជាឲ្យគេដង្ហែព្រះបាទនរោត្តមមកកំពត។ ព្រះមហាក្សត្រខ្មែរយាងចូល ព្រះរាជធានីឧដុង្គ ក្នុងខែ មីនា ឆ្នាំ ១៨៦២។

ក្នុងពេលជាមួយគ្នានោះ កងទ័ពបារាំងយកដែនកូសាំងស៊ីនទៅទៀត។ លោកឧត្តមនាវី សារនែរ (Amiral Charner) ធានាថ្វាយព្រះបាទនរោត្តមថា ប្រទេសបារាំងស្វែងរកសន្តិភាព ហើយពុំមានបំណងនឹងវាយយកប្រទេសកម្ពុជាឡើយ។ ចំណែកឯព្រះមហាក្សត្រខ្មែរវិញ ព្រះអង្គមានព្រះបំណងនឹងចុះកិច្ចព្រមព្រៀងនយោបាយជាមួយនឹងប្រទេសបារាំង ក៏ប៉ុន្តែ ទ្រង់ភ័យខ្លាចព្រះចៅប្រទេសសៀមរករឿង។ លោកឌូដាត៍ដឺឡាគ្រេ (Doudart de Lagrée) មានភារកិច្ចទាក់ទងជាមួយព្រះចៅប្រទេសកម្ពុជា។ ដោយមានជំនួយពីលោកមីសផង ព្រះបាទនរោត្តមក៏យល់ពីអត្ថប្រយោជន៍ ដាក់ប្រទេសកម្ពុជានៅក្រោមអាណាព្យាបាលបារាំង ហើយទ្រង់បានឡាយព្រះហស្តលេខាលើអនុសញ្ញាព្រមព្រៀងមួយជាមួយលោកឌូដាត៍ដឺឡាគ្រេ។ បន្ទាប់ពីឡាយព្រះហស្តលេខាជាមួយបារាំងរួច ព្រះនរោត្តមឡាយព្រះហស្តលេខាលើសន្ធិសញ្ញាថ្មីម្តងទៀត ជាមួយប្រទេសសៀម។ សន្ធិសញ្ញាថ្មី នោះធ្វើឲ្យព្រះអង្គធ្លាក់ទៅក្រោមអំណាចប្រទេសសៀមវិញ។

ម្យ៉ាងទៀត ព្រះនរោត្តម ត្រូវយាងទៅក្រុងបាងកក ដើម្បីទទួលមកុដរាជ្យផង។ ពេលនោះ លោកឌូដាត៌ ដឺឡាគ្រេ ទូលព្រះអង្គថា បើទ្រង់យាងទៅបាងកកវិញ ពួកបារាំងនឹងចូលវាយលុកកាន់កាប់ព្រះរាជធានីរបស់ព្រះអង្គ មាននាវាចម្បាំងប្រដាប់ដោយកាំភ្លើងធំពីរគ្រឿង និងទាហាន ១៥០ នាក់ មកចតនៅផែកំពង់ហ្លួង។ វត្តមាននៃទាហាន និងនាវាទាំងពីរគ្រឿងនោះគំរាមកំហែងព្រះអង្គ។ លោកមីស ឃាត់ព្រះរាជាមិនឲ្យយាងចេញពីព្រះរាជវាំង តែព្រះអង្គមិនព្រមស្តាប់នរណាសោះ។ ពេលព្រះអង្គយាងចេញពីក្រុងឧដុង្គបានបីបួនគ.ម. ព្រះរាជាបានឮស្នូរសន្ធឹកកាំភ្លើងធំ ហើយទ្រង់យាងត្រឡប់មកវិញយ៉ាងប្រញាប់។ ព្រះអង្គក៏ព្រមឡាយព្រះហស្តលេខាលើសន្ធិសញ្ញាអាណាព្យាបាលនោះទៅ។ សន្ធិសញ្ញានោះ បានរៀបចំតាំងពីថ្ងៃទី ១២ រហូតដល់ថ្ងៃទី ១៧ មេសា ឆ្នាំ ១៨៦៣ ហើយមាន ១៩ មាត្រា។ មាត្រាទី ១៥ ចែងថា៖

> *«សាសនទូតកាតូលិកទាំងឡាយ មានសិទ្ធិប្រកាសផ្សាយគ្រីស្តសាសនា។ ដោយ មានការអនុញ្ញាត ពីរាជរដ្ឋាភិបាលខ្មែរ អស់លោកអាចសង់វិហារ សង់ទេវវិទ្យាល័យ សង់សាលារៀន សង់មន្ទីរពេទ្យ សង់វត្តអារាម ហើយនឹងអាចសង់អាគារសាសនាផ្សេងៗទៀត នៅគ្រប់ទីកន្លែងនៃព្រះរាជាណាចក្រកម្ពុជាផង»។*

បន្ទាប់មក ព្រះចៅប្រទេសសៀមសព្វព្រះហឫទ័យបញ្ជូនព្រះខ័នរាជ្យ និងលំពែងជ័យមកថ្វាយព្រះបាទនរោត្តមវិញ។ ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ១៨៦៤ ព្រះបាទនរោត្តមទទួលព្រះរាជាភិសេក ជាព្រះមហាក្សត្រប្រទេសកម្ពុជាយ៉ាងឱឡារិក ដោយមានទាំងតំណាងប្រទេសបារាំង និងប្រទេសសៀមចូលរួមក្នុងពិធីនោះផង។

ពីរឆ្នាំក្រោយមក គឺនៅឆ្នាំ ១៨៦៦ ព្រះរាជាបានតាំងព្រះរាជធានីនៅភ្នំពេញ ទ្រង់ក៏សុំគ្រីស្តបរិស័ទ នៅពញាឮឲ្យមករស់នៅភ្នំពេញជាមួយព្រះអង្គដែរ។ ព្រះអង្គបានប្រគល់ដីនៅខាងជើងព្រែកហ្លួង ឲ្យគ្រីស្តបរិស័ទទាំងនោះសង់ផ្ទះនៅ។ គឺអ្នកទាំងអស់នេះឯងហើយ ដែលបានបង្កើតភូមិគ្រីស្តបរិស័ទ ដែលមានឈ្មោះជាប់រហូតមកទល់ឆ្នាំ ១៩៧៥ ថា "ហូអាឡង់ (Hoaland) " ឬ "ព្រះមាតា" ដែលខ្មែរច្រើន ហៅថា "ភូមិមាន់ចែ" ( ព្រោះមានរូបមាន់នៅលើកំពូលព្រះវិហារ )។

អ្នកបច្ចេកទេសខាងប្រវត្តិវិទ្យា យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសកម្មភាពនយោបាយរបស់លោកមីស។ ប៉ុន្តែ ក៏មិនត្រូវភ្លេចថា សកម្មភាពចម្បងរបស់លោក និងការងាររបស់អស់លោកសាសនទូតគឺការកសាងព្រះសហគមន៍។

នៅឆ្នាំ ១៨៤៦ ប្រទេសវៀតណាម និងប្រទេសសៀម បានចុះកិច្ចព្រមព្រៀងមួយដើម្បីត្រួតត្រាប្រទេសកម្ពុជា។ តាមកិច្ចព្រមព្រៀងនោះ ព្រះបាទអង្គឌួង និងព្រះមហាក្សត្រវៀតណាម ព្រមទាំងព្រះចៅសៀម បានលើកលែងទោសឲ្យអស់អ្នកជាប់ទាក់ទិននៅក្នុងព្រឹត្តិការណ៍ ដែលលកើតមានឡើង ប៉ុន្មានឆ្នាំកន្លងមកនោះ។ អាស្រ័យហេតុនេះ ទើបក្រុមគ្រីស្តបរិស័ទបាត់ដំបងដែលបែកខ្ញែកខ្ចាត់ខ្ចាយនាឆ្នាំ ១៨៤០ ព្រោះតែសង្គ្រាមនោះ បានវិលត្រឡប់ចូលក្រុងរបស់ខ្លួនវិញ។ តែក្រុងបាត់ដំបងនេះ ស្ថិតនៅក្រោមការកាន់កាប់របស់សៀម។

ព្រះសហគមន៍ប្រើព្រំដែនភូមិភាគសាសនា តម្រូវទៅតាមស្ថានភាពថ្មី។ កាលពីមុនគឺឆ្នាំ ១៨៤៤ លោកគុយអេណូ (Cuénot) ដែលទទួលតំណែងបន្តពីលោកតាប៉ែរ បានចែកភូមិភាគព្រះសហគមន៍នៅកូសាំងស៊ីននិងនៅកម្ពុជាជាពីរផ្នែក។ ខេត្តទាំង ៦ នៃដែនកូសាំងស៊ីនក្រោម(៦)និងប្រទេសកម្ពុជាត្រូវបានបញ្ចូលជា "*ភូមិភាគព្រះសហគមន៍កូសាំងស៊ីនខាងលិច*" ។ លោក ឡឺហ្វែរ និងបូជាចារ្យបារាំងបីនាក់ គឺ លោកមីស លោកឌុយក្លូ លោកហ្វុងតែន ព្រមទាំងបូជាចារ្យជាអ្នកដែនកូសាំងស៊ីន ១៦ នាក់ទៀត ជាសហការីទទួលបន្ទុកលើភូមិភាគកូសាំងស៊ីនក្រោមនោះ។ នៅឆ្នាំ ១៨៥០ លោកឡឺហ្វែរ បានចែកភូមិភាគនេះជាថ្មីម្តងទៀត គឺលោកប្រគល់ឲ្យលោកមីស ដែលជាអភិបាលឧបការី ទទួលបន្ទុកប្រទេសកម្ពុជានិងប្រទេសលាវ។ លោកមីសមិនសូវពេញចិត្តនឹងការបែងចែករបៀបនេះទេ ព្រោះតាមការសង្កេតរបស់លោក ជនជាតិខ្មែរមិនចូលគ្រីស្តសាសនាទេហើយនៅថ្ងៃមុខប្រទេសកម្ពុជា នឹងលែងធ្វើជាជម្រកសម្រាប់សាសនទូត និងគ្រីស្តបរិស័ទ ដែនកូសាំងស៊ីនទៀត ប្រសិនបើរដ្ឋអំណាចដែនដីនេះ ធ្វើទុកបុកម្នេញពួកគេទៀតនោះ។ លោកសរសេរថា៖

> *«ខ្ញុំសូមជម្រាបដោយត្រង់ថា របៀបបែងចែកដែលបានធ្វើមកហើយនេះ ខ្ញុំមិនពេញចិត្តសោះ(...)។ ចំពោះប្រទេសកម្ពុជា គ្រប់គ្នាដឹងច្បាស់ណាស់ទៅហើយថា*

*ពុំមាននរណាចង់ចូលគ្រីស្តសាសនាឡើយ។ ប្រហែលជាប្រទេសលាវ គ្រាន់បើជាងទេដឹង? ប្រជាជនខ្មែរនិងលាវ មានប្រកពតែមួយ អ្នកស្រុកកាន់ពុទ្ធសាសនាយ៉ាងហ្មត់ចត់និងយ៉ាងមុតមាំដូចគ្នា។ នៅលើផែនទី គេឃើញប្រទេសកម្ពុជាជាប់នឹងប្រទេសលាវពីខាងជើង ហើយគេក៏ស្មានថា ប្រទេសទាំងពីរនេះ នឹងអាចទៅជាភូមិភាគសាសនាយ៉ាងល្អប្រសើរបាន គិតដូច្នេះ គឺភ័ន្តច្រឡំទាំងស្រុងហើយ ព្រោះឆ្លងចុះឡើងពីប្រទេសកម្ពុជាទៅប្រទេសលាវនោះពិបាកណាស់»។*

លោកមីស មានបំណងចង់ភ្ជាប់ខេត្តបីរបស់ដែនកូសាំងស៊ីនក្រោម គឺខេត្តនៅខាងលិចទន្លេមេគង្គ (ខេត្តមាត់ជ្រូក ខេត្តវិញឡុង និងសុកទ្រាំង) ទៅក្នុងភូមិភាគព្រះសហាគមន៍កម្ពុជាវិញ។ លោកមានបំណងដូច្នេះ ព្រោះលោកចង់ឲ្យមាន "*ក្របខ័ណ្ឌស្នូលមួយ ដើម្បីបង្កើតក្រុមគ្រីស្តបរិស័ទអណ្ណាម*"(៧)។

គ្រានោះ លោកអភិបាលព្រះសហាគមន៍ មានបូជាចារ្យពីរនាក់ធ្វើជាសហការី គឺលោកម៉ារីឡូរ៉ង់ ក័រឌីយេ (Marie Laurent Cordier) និងលោកលុយអូសូឡី (Louis Aussoleil) ពេលក្រោយមក មានបូជាចារ្យឯទៀតៗមកជួយលោកទាំងពីរនោះ គឺនៅឆ្នាំ ១៨៤៩ មានលោកសាលប៊ុយយឺរ៉ូ (Charles Bouilleveaux) នៅឆ្នាំ ១៨៥០ មានលោកអេដស៊ីលវ៉េស្ត្រ (Edme Sylvestre) នៅឆ្នាំ ១៨៥៤ មានលោកអារសែនហេស្រ្តេត (Arséne Hestret) នៅឆ្នាំ ១៨៥៧ មានលោកយ៉ូហានបាទីស្តបារ៉ូ (Jean-Baptist Barreau) ជាដើម បើរាប់តែអស់លោកដែលមានឈ្មោះល្បីជាងគេនោះ។ គ្រីស្តបរិស័ទ ដែលរស់នៅពញាឮ និងនៅបាត់ដំបងមានគ្នាប្រហែល ៦០០ នាក់ ហើយក្នុងចំណោម គ្រីស្តបរិស័ទទាំងនោះ ភាគច្រើនជាកូនកាត់ខ្មែរ-ព័រទុយហ្គាល់(៨)។ មានគ្រីស្តបរិស័ទដែនកូសាំងស៊ីនមួយចំនួន ដែលរត់គេចពីការធ្វើទុក្ខបុកម្នេញ បានមករួមរស់ជាមួយអ្នកទាំងអស់នោះផងដែរ។

នៅខែមករាឆ្នាំ ១៨៥០ លោកក័រឌីយេ ដែលទទួលបន្ទុកលើព្រះសហាគមន៍បាត់ដំបងមួយឆ្នាំមកហើយនោះ សរសេរទៅជម្រាបអស់លោកនាយកទេវវិទ្យាល័យនៅក្រុងប៉ារីសថា៖

*«ខ្ញុំបានធ្វើពិធីជ្រមុជទឹកជូនជនជាតិខ្មែរពេញវ័យ បានតែពីរនាក់ប៉ុណ្ណោះ គឺស្ត្រីម្នាក់និងបុរសម្នាក់។ ដូចអស់លោកជ្រាបស្រាប់ហើយថា ខ្មែរព្រងើយកន្តើយនឹងគ្រីស្តសាសនាជ្រុលហួសហេតុ រកនិយាយមិនកើត(...)។ មានហេតុមួយទៀតដ៏*

*សំខាន់ ដែលខារខាំងជនជាតិខ្មែរមិនឲ្យចូលជាគ្រីស្តបរិស័ទបាន គឺមកពីប្រជាជនដ៏កំសត់នេះ មួយភាគធំជាប់ជាទាសាទាសីគេ។ ឧបមាថា មេគ្រួសារមួយជំពាក់គេ ៨០ ឬ ១០០ គ្រណោត ដោយគាត់ពុំអាចសងគេបានទេនោះ ម្ចាស់បំណុលរឹបអូសយកទាំងខ្លួនគាត់ ទាំងកូនប្រពន្ធគាត់ មកធ្វើជាខ្ញុំបម្រើ។ ប្រសិនប គាត់ស្លាប់ទៅ ម្ចាស់បំណុលដ៏ព្រៃផ្សៃនេះ គាមទារបំណុលពីកូនៗតទៅទៀត។ កូនៗទាំងនោះទៅជាកម្មសិទ្ធិរបស់ម្ចាស់បំណុលនេះតៗគ្នា រហូតដល់ទៅចៅ ចៅទួត។ល។ ទាល់តែមានអ្នកចិត្តធម៌ជួយលោះបំណុលឲ្យ ទើបគ្នាអាចរួចផុតពីជាទាសីទាសាគេ។ នៅស្រុកខ្មែរងាយនឹងជំពាក់បំណុលគេណាស់ ព្រោះថា បើនរណាម្នាក់ចងការគេ ១០ ណោត ហើយប្រសិនបើគេពុំអាចសងរួចអស់ក្នុងអំឡុង មួយឆ្នាំទេ ចំនួនទឹកប្រាក់នេះ នឹងកើនឡើងទ្វេរមួយជាពីរ រាល់ៗឆ្នាំតទៅ...»*[៩] ។

តាមពិត ការជាប់ជាទាសាទាសី ជាគ្រោះមហន្តរាយមួយដ៏ធំ គួរឲ្យឈឺចាប់នៅក្នុងសង្គមខ្មែរតាំងពី ច្រើនសតវត្សមកហើយ។ មានមនុស្សជាច្រើនជាប់ជាទាសាទាសីព្រោះជំពាក់បំណុលគេ។ មានអ្នកខ្លះទៀតជាជនជាតិភាគតិចរស់នៅស្រុកភ្នំ ត្រូវគេប្លន់ចាប់យកទៅលក់ ធ្វើជាទាសាទាសីថែមទៀត។ សាសនទូតជាច្រើន ជាពិសេស លោក បារ៉ូ បានលោះជនអភ័ពនោះមួយចំនួនធំ[១០] ។

លោក មីស បានសរសេរទៅជម្រាបអស់លោកនាយកទេវវិទ្យាល័យនៅក្រុងប៉ារីស មានសេចក្តីប្រហាក់ប្រហែលនឹងគំនិតលោក ក័រឌីយេ ដែរថា៖

*«អ្នកដែលរស់នៅប្រទេសកម្ពុជា បានពីរបីឆ្នាំនឹងយល់ច្បាស់ថា គ្មាននរណា អាចនាំជនជាតិខ្មែរឲ្យចូលគ្រីស្តសាសនាឡើយ លើកលែងតែដោយលោះទាសករ ដែលជំពាក់បំណុលគេចេញ។ ប៉ុន្តែ មធ្យោបាយនេះវែងឆ្ងាយ ហើយត្រូវចំណាយប្រាក់អស់ច្រើនដែរ»*[១១]។

តាមពិត មានហេតុផលផ្សេងទៀត ដែលរារាំងជនជាតិខ្មែរ មិនឲ្យទៅជាគ្រីស្តបរិស័ទ គឺអស់លោកបូជាចារ្យមិនសូវយល់អំពីពុទ្ធសាសនា។ សាសនទូតតែងចាត់ពុទ្ធសាសនាទុកជា "*ជំនឿអកុសល* " ហើយអស់លោកមិនសូវទាំងគោរពព្រះពុទ្ធថែមទៀតផង។ លើសពីនេះទៅទៀត អស់លោកចាត់ព្រះពុទ្ធទុកជា "*អាទិទេពមួយអង្គ* " ហើយដែលលោក ក័រឌីយេ "*ចង់ប្រយុទ្ធតទល់ជាមួយ* " ផង។

លោកមីសដែលជាអភិបាលព្រះសហគមន៍ បានគិតអំពីជនជាតិខ្មែរតាមមតិទូទៅក្នុងសម័យនោះដែរ។ លោកបារ៉ូ បានត្អូញត្អែរថា៖ "*លោកអភិបាលយល់ឃើញថា ការយកចិត្តទុកដាក់ណែនាំខ្មែរ ឲ្យចូលគ្រីស្តសាសនា គឺជាការអត់ប្រយោជន៍*" (១២)។ ទោះជាយ៉ាងណាក៏ដោយ ក៏លោកបារ៉ូនៅតែខិតខំភារកិច្ចជាសាសនទូត ទាំងមានជំនឿមុតមាំដែរ។ លោកសរសេរថា៖

> *«ខ្ញុំសូមសារភាពចំពោះលោកថា ខ្ញុំស្រឡាញ់ប្រទេសកម្ពុជា មិនមែនមកពីប្រទេសនេះស្រួលរស់នៅនោះទេ គឺមកពីករណីកិច្ចរបស់ខ្ញុំតែប៉ុណ្ណោះ។ គេពេបជ្រាយដាក់ខ្ញុំ ព្រោះតែខ្ញុំនិយាយថា "ជនជាតិខ្មែរអាចចូលគ្រីស្តសាសនាបាន" ។ តែលោកត្រូវជ្រាបថា ក្នុងឆ្នាំ ១៨៦៣ ក្នុងរយៈពេលប្រាំបីខែកន្លងមកនេះ មានមនុស្សពេញវ័យសូមទទួលការអប់រំខាងជំនឿជារៀងរាល់ថ្ងៃឥតឈប់ឈរឡើយ។ បើគិតតែក្នុងភូមិតូចរបស់យើងឈ្មោះពញាឮនេះ មានគ្រួសារថ្មីចំនួនម្ភៃ បានសុំចូលគ្រីស្តសាសនា។ ពីថ្ងៃអាទិត្យមុននេះ ខ្ញុំបានធ្វើពិធីជ្រមុជទឹកឲ្យបុរសពីរនាក់ ហើយនៅថ្ងៃអាទិត្យក្រោយ ខ្ញុំនឹងធ្វើពិធីនេះ ឲ្យបុរស ១៥ ឬ ១៦ នាក់ទៀត ដោឥតមាន គិតពួកអ្នកដែលខ្ញុំបានអប់រំរួចមកហើយនោះឡើយ...*(១៣)។

នៅឆ្នាំ ១៨៦៣ លោកបារ៉ូ នាំគ្រីស្តបរិស័ទថ្មីៗ ចំនួន ៨០ នាក់ ពីភូមិពញាឮទៅតាំងទីលំនៅ នៅភូមិមាត់ក្រសាស់ចម្ងាយប្រមាណម្ភៃគ.ម. ខាងត្បូងភ្នំពេញ។ ភូមិមាត់ក្រសាស់ស្ថិតនៅលើត្រើយខាងកើតទន្លេមេគង្គ ហើយដីមានជីជាតិល្អណាស់។ នៅទីនោះលោកបូជាចារ្យបានអប់រំជំនឿជនជាតិខ្មែរជាច្រើនដែរ។ លោកសរសេរថា៖

> *«នៅពេលឥឡូវនេះ មានជនជាតិខ្មែរ៨នាក់ប្រុងចូលគ្រីស្តសាសនា។ ពេលមុនខ្ញុំបានធ្វើពិធីជ្រមុជទឹកឲ្យជនជាតិខ្មែរ ៩ នាក់(...)។ សូមកុំឲ្យយល់ច្រឡំថា ជនជាតិខ្មែរចង់ចូលគ្រីស្តសាសនាច្រើនគ្នានោះឡើយ(...)។ មានអ្នកសុំទទួលការអប់រំជំនឿពីខ្ញុំមិនដាច់ ហើយពីរ ឬបីខែម្តង ខ្ញុំធ្វើពិធីជ្រមុជទឹកឲ្យ មនុស្សពេញវ័យ ១០ ឬ១៥នាក់។ បើនិយាយពីលុយកាក់ ខ្ញុំមានការខ្វះខាតច្រើន(...)»* (១៤)។

នៅឆ្នាំ ១៨៦៥ គឺពីរឆ្នាំកន្លះបន្ទាប់ពីបានបង្កើតព្រះសហគមន៍មាត់ក្រសាស់មក លោកបារ៉ូប្រកាសថា៖ "*បានធ្វើពិធីជ្រមុជទឹកឲ្យមនុស្សជាង ១០០ នាក់ ហើយនៅសល់*

*៣៤ នាក់ទៀត ដែលកំពុងទទួលការអប់រំជំនឿ*"។ លោកបារ៉ូបានសាងសាលារៀនមួយនិងអប់រំគ្រូបង្រៀនម្នាក់ ព្រមទាំងបង្ហាត់បង្រៀនគ្រីស្តបរិស័ទខ្មែរម្នាក់ ឲ្យទទួលបន្ទុកអប់រំជំនឿគ្រីស្តសាសនាថែមទៀតផង។ លោកបារ៉ូ ក៏ចាត់យុវតីខ្មែរបួននាក់ទៅព្រៃនគរ ដើម្បីឲ្យនាងទទួលការអប់រំធ្វើជាដូនជី។

លោកបូជាចារ្យឯទៀតៗ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះលោកបារ៉ូ ដែលហ៊ានសង្ឃឹមថា "*នឹងបានទទួលលទ្ធផលល្អនោះ*" ព្រោះលោកទាំងនោះនឹកគិតតាមតិទូទៅដែលថា គ្មានសង្ឃឹមនាំជនជាតិខ្មែរចូលគ្រីស្តសាសនាឡើយ។ លោកបារ៉ូបានសរសេរតបទៅអស់លោកវិញថា៖

> *«ខ្ញុំយល់ឃើញថា ចិត្តខ្ញុំជាប់ជំពាក់នឹងខ្មែរច្រើនជាប់ជំពាក់នឹងពួកវៀតណាម ព្រោះពួកវៀតណាមមានបូជាចារ្យ និងអ្នកទទួលបន្ទុកអប់រំជឿគ្រីស្តសាសនាជាច្រើននាក់ នៅឯដែនកូសាំងស៊ីននោះ។ ខ្ញុំឃើញថា គេទាក់ទាញពួកវៀតណាមបាន ដោយចែកស្រូវអង្ករនិងចែកជំនួយផ្សេងៗឲ្យ។ ចំណែកឯជនជាតិខ្មែរវិញ គឺមានតែយើងប៉ុណ្ណោះទេ។ បើយើងខ្វល់ខ្វាយតែនឹងពួកវៀតណាម គឺដូចជាយើងទុកឲ្យខ្មែរនៅកំព្រាជាពុំខានឡើយ។ ដូច្នេះ ទើបព្រះជាម្ចាស់បានចងយើងជាប់ទៅនឹងជនជាតិខ្មែរ ដើម្បីឲ្យធ្វើអ្វីៗបាននៅប្រទេសកម្ពុជា លុះត្រាតែយើងឧស្សាហ៍ធ្វើដំណើរចុះឡើងក្នុងប្រទេសនេះ។ តែផ្ទុយទៅវិញ យើងនៅមួយកន្លែងឥតមានកម្រើកសោះ...»*(១៥)។

កាលលោកបារ៉ូ ទើបមកដល់ប្រទេសកម្ពុជា លោកចង់ឲ្យជនជាតិបារាំងផ្តល់ជំនួយយោធាឲ្យខ្មែរ លុះត្រាតែជនជាតិខ្មែរព្រមចូលគ្រីស្តសាសនា។ បីបួនឆ្នាំក្រោយមក ដោយឃើញឥរិយាបថរបស់ជនជាតិបារាំងនៅប្រទេសកម្ពុជា លោកក៏មានយោបល់ផ្ទុយទៅវិញ។ លោកយល់ថា វត្តមានរបស់ជនជាតិបារាំង និងការគ្រួតត្រារបស់បារាំង លើប្រទេសកម្ពុជា គឺជាឧបសគ្គដ៏ធំថ្មីមួយទៀត រារាំងការផ្សព្វផ្សាយជំនឿគ្រីស្តសាសនានេះ ព្រោះជនជាតិបារាំងទាំងនោះ មិនសូវរវីរវល់នឹងគ្រីស្តសាសនាទេ ហើយប្រព្រឹត្តអំពើផ្តេសផ្តាសថែមទៀតផង...(១៦)។ ទោះជាយ៉ាងណាក៏ដោយ ទាំងលោកបារ៉ូក្តី ទាំងលោកមីសក្តី លោកមិនយល់ច្រឡំអំពីជនជាតិខ្មែរ ដែលចូលគ្រីស្តសាសនានោះឡើយ។ មានអ្នកខ្លះ ចូលដោយឃើញថា ព្រះមហាក្សត្រមានព្រះមេត្តាធម៌ចំពោះគ្រីស្តសាសនា

ដូច្នេះគេចង់បានប្រយោជន៍ផ្ទាល់ខ្លួន ដូចលោកមីសបានសរសេរក្នុងឆ្នាំ ១៨៦៤ ស្រាប់៖

*«ជនជាតិខ្មែរ មិនសូវស្អប់ខ្ពើមគ្រីស្តសាសនា ដូចពីអតីតកាលមកទេ។ ប្រជាជនខ្មែរនៅគ្រប់ទីកន្លែងទាំងអស់ដឹងថា ព្រះរាជាមានព្រះហឫទ័យល្អចំពោះយើង។ ពួកគេដឹងថា ព្រះរាជាទ្រង់មានគម្រោងប្រគល់ព្រះរាជបុត្រទាំងពីរ ឲ្យខ្ញុំអប់រំឲ្យខ្ញុំធ្វើពិធីជ្រមុជទឹកថ្វាយ ព្រមទាំងឲ្យខ្ញុំបង្រៀនឲ្យចេះដឹង ព្រោះព្រះរាជាមានព្រះរាជបំណងចង់ឲ្យព្រះរាជបុត្រទាំងពីរមានលក្ខណៈដូចជាជនជាតិបារាំង។*

*ព្រះអង្គបានប្រទានព្រះរាជសារមួយមកឲ្យយើង មានប្រថាប់ត្រាព្រះសង្ហាររបស់ព្រះអង្គ និងត្រារបស់នាហ្មឺនសព្វមុខមន្ត្រីផង។ ក្នុងព្រះរាជសារនោះ ទ្រង់អនុញ្ញាតឲ្យយើងមានសិទ្ធិទេសនា ផ្សាយសាសនារបស់ព្រះយេស៊ូគ្រីស្ត នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រទាំងមូល។ ទ្រង់អនុញ្ញាតឲ្យ ប្រជារាស្ត្រទាំងអស់មានសិទ្ធិចូលគ្រីស្តសាសនានេះដោយសេរី។ ក៏ប៉ុន្តែ សូមអស់លោកកុំសន្និដ្ឋានថា ជនជាតិខ្មែរចង់ចូលគ្រីស្តសាសនាគ្រប់គ្នានោះឲ្យសោះ!។ ដរាបណាពុំមានព្រះអង្គម្ចាស់ខ្លះ ឬក៏នាហ្មឺនធំៗខ្លះចូលគ្រីស្តសាសនាជាគំរូទេ ប្រជាជនខ្មែរនៅតែអៀនប្រៀននឹងចូលគ្រីស្តសាសនា ព្រោះគេខ្លាចនាយចៅហ្វាយរបស់គេមិនសប្បាយចិត្ត។ ក្នុងចំណោមអ្នកដឹកនាំទាំងនោះ យើងសង្កេតឃើញថា មាននាហ្មឺនជាច្រើនខិតខំដោយស្ងាត់ៗ ធ្វើឲ្យអ្នកចូលគ្រីស្តសាសនាថ្មីៗបែកចេញពីជំនឿវិញ[(១៧)]។*

បើទុកជាមានការរឹករជ្រួលច្របល់ផ្នែកនយោបាយយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍ខ្មែរបានកើតឡើងរួចទៅហើយ តាំងពីមុនសម័យអាណាព្យាបាលបារាំងមកម្ល៉េះ។ ក៏ប៉ុន្តែ ដោយគ្រីស្តបរិស័ទវៀតណាមច្រើនកកកុញ ចូលមករស់នៅក្នុងប្រទេសកម្ពុជា ជនជាតិខ្មែរស្ទើរតែគ្រប់គ្នាមើលពុំដឹងថាមានព្រះសហគមន៍ខ្មែរសោះឡើយ។

(១) លោកពីញ៉ូដឺបេអែន ជាអភិបាលព្រះសហគមន៍ ទទួលបន្ទុកដែនកូសាំងស៊ីន និងប្រទេសកម្ពុជា ពីឆ្នាំ ១៧៧១ ដល់ ១៧៩៩។ លោកបានធ្វើសកម្មភាពនយោបាយយ៉ាងសំខាន់ ថ្វាយព្រះចៅអធិរាជវៀតណាម ព្រះនាមយ៉ាឡុង គ្រាដែលព្រះចៅនេះឡើងសោយរាជ្យនៅឆ្នាំ ១៨០២ នោះ។ លោកបានគាំទ្រព្រះចៅអធិរាជ យ៉ាងឡុង ព្រោះលោកយល់ឃើញថា លោកជួយកសាងសន្តិភាពនៅក្នុងប្រទេស និងផ្តល់សេចក្តីដល់ប្រជាពលរដ្ឋ ជាពិសេស សេចក្តីសុខដល់គ្រីស្តបរិស័ទ។

ព្រះបាទ យ៉ាឡុង ឆ្លៀតពេលដែលព្រះអង្គម្ចាស់ខ្មែរទាស់ទែងវាយប្រហារគ្នា បានលើកទ័ពវាយលុកចូលប្រទេសកម្ពុជា។ គ្រានោះ លោកពីញ៉ូ ខិតខំឃាត់ព្រះចៅកុំឲ្យវាយ ហើយអង្វរព្រះអង្គយ៉ាងហោចណាស់ឲ្យមេត្តា កុំធ្វើបាបពួកគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ទុកជាសញ្ញានៃមិត្តភាពរបស់ព្រះអង្គ។ ព្រះចៅអធិរាជយល់ព្រមតាមពាក្យអង្វរនេះ ដោយដាក់ល័ក្ខខ័ណ្ឌមួយគឺថា ទាល់តែមានបូជាចារ្យវៀតណាមម្នាក់ទៅជាមួយកងទ័ព ដើម្បីនឹងបង្ហាញពួកគ្រីស្តបរិស័ទដល់កងទ័ពនោះ។ ក្រោយមកទៀត ប្រជាជនក្នុងខេត្តមួយ ដែលកងទ័ពព្រះចៅអធិរាជទើបវាយយកបានថ្មីៗ បានបះបោរប្រឆាំងនឹងវៀតណាម។ ព្រះចៅយ៉ាឡុង ទ្រង់បញ្ជាឲ្យសម្លាប់ពួកអ្នកបះបោរទាំងនោះ និងឲ្យដុតបំផ្លាញស្រូវចោល។ ទ្រង់បញ្ជូនទាហាន ៨.០០០ នាក់ ឲ្យទៅបង្ក្រាបការបះបោរនោះ។ ពេលលោកពីញ៉ូបានជ្រាបរឿងនេះ លោករត់ទៅព្រះរាជវាំងអង្វរព្រះចៅអធិរាជឲ្យប្រោសប្រណី។ ទោះបីព្រះអង្គ ទ្រង់ក្រេវក្រោធខ្លាំងយ៉ាងណាក៏ដោយ ក៏ព្រះចៅយ៉ាឡុងអត់អោនតាមពាក្យអង្វរនោះ ហើយព្រះអង្គក៏ចេញបញ្ជាមិនឲ្យសម្លាប់ប្រជាជន មិនឲ្យបង្ហូរឈាម(Piant.op.cit., p.467)។

ដោយលោកអភិបាលព្រះសហគមន៍ទទួលបន្ទុកប្រទេសកម្ពុជា និងដែនកូសាំងស៊ីនគាំទ្រព្រះចៅអធិរាជវៀតណាមនោះ លោកត្រូវទទួលរងពាក្យរិះគន់យ៉ាងជូរចត់ អំពីលោកអភិបាលព្រះសហគមន៍ប្រទេសសៀម ដែលប្រឆាំងនឹងការវាតទឹកដីរបស់ប្រទេសវៀតណាម។ អស់លោកនាយកទេវវិទ្យាល័យនាក្រុងប៉ារីស និងសហការីសម្តេចប៉ាប ក៏រិះគន់ចំពោះការទាក់ទិនក្នុងរឿងនយោបាយនេះដែរ ព្រោះអស់លោកយល់ថា ជារឿងបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ព្រះសហគមន៍។

បន្ទាប់ពីព្រះចៅ យ៉ាឡុង សោយទិវង្គតទៅ ព្រះចៅអធិរាជមិញម៉ាង (១៨២០-១៨៤១) ចាប់ផ្តើមធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទទៀត។ ឧបរាជ ឡេវ៉ាន់ឌៀត (Le Van Duyet) ដែលត្រួតត្រាលើដែនកូសាំងស៊ីន ហើយដែលជាអតីតមិត្តរួមអាវុធរបស់លោកពីញ៉ូ បានប្រកែកពុំព្រមធ្វើតាមព្រះរាជបញ្ជារបស់ព្រះចៅអធិរាជឡើយ។ ក្រោយពេលព្រះឧបរាជ ឡេវ៉ាន់ឌៀត ចូលព្រះទិវង្គតទៅ ព្រះចៅអធិរាជក៏ចាប់ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ នៅដែនកូសាំងស៊ីន តទៅទៀត។

(២) Pierre Lamant, "*Les Prémices des relations politiques entre le Cambodge et de France vers le milieu du XIXé* " , in "Revue Française d'Historie d'Outre-Mer", Tome LXXII N°267, 1985, p.167 et sq.

(៣) Khin Sok, Le Cambodge entre le Siam et le Vietnam de 1775 à 1860, Thèse de Doctorat d'Etat, 1988, p.188 et sq.

(៤) Lettre à M. Libois, Directeur à Paris, Archives MEP, Vol. 765, N° 54.

(៥) Lettre à MM. les Directeur de Paris, Archives MEP, Vol. 765, N° 80.

(៦) ខេត្តមាត់ជ្រូក និងខេត្តហាទៀង ស្ថិតនៅខាងលិចទន្លេមេគង្គ ចំណែកឯខេត្តមេសរ បារៀ ព្រៃនគរ និង បៀងហ្វារ ស្ថិតនៅខាងកើតទន្លេ។

(៧) លិខិតជូនទៅអស់លោកនាយកទេវវិទ្យាល័យ។ Archives des MEP, Vol.755. N° 59. នៅឆ្នាំ ១៨៦១ ។

(៨) នៅឆ្នាំ ១៨៦០ លោកបារ៉ូឲ្យចំនួនគ្រីស្តបរិស័ទដូចតទៅ៖ «*ក្នុងព្រះសហគមន៍របស់យើងមានជនជាតិខ្មែរ ៤០០នាក់ វៀតណាម ៣០០ នាក់ និងចិន ៣៦ នាក់ ហើយសូមមើលចុះ យើងមានសាសនទូតតែ ៦ ឬ ៧ នាក់ប៉ុណ្ណោះ*» ។

Letter au Supérieur des MEP, Archives MEP, Vol.765, N° 70.

(៩) Lettre à M.Albrand, Archives MEP, Vol.755, N° 49.

(១០)អំពីទាសភាពសូមអាន៖ A.Forest, Le Cambodge et la Colonisation française, Paris 1980, pp. 342-355. លុះត្រាតែដល់ឆ្នាំ ១៨៩៧ ទើបតាមព្រះរាជបញ្ញត្តិឲ្យលុបបំបាត់ទាសភាពជាផ្លូវការ។

(១១)លិខិតជូនទៅអស់លោកនាយកនៅក្រុងប៉ារីស Archives MEP, Vol.765, N° 80.

(១២)លិខិតជូនទៅលោក Abbé Faurie, Archives MEP, Vol.765, N° 73.

(១៣)Lettere à M.Albrand, Archives MEP, Vol.765, N° 112.

(១៤)លិខិតជូនទៅលោកនាយកទេវវិទ្យាល័យ នៅក្រុងប៉ារីសទាំងអស់។ Archives MEP, Vol.765, N° 119.

(១៥)លិខិតជូនទៅលោកអាល់ប្រង់ Archives MEP, Vol.765, N° 129.

(១៦)លិខិតជូនទៅលោកនាយកទេវវិទ្យាល័យ នៅក្រុងប៉ារីសទាំងអស់ Archives MEP, Vol.765, N° 70 និងជូនទៅលោកអាល់ប្រង់ Vol.765, N° 129 et 142.

(១៧)លិខិតជូនទៅអស់លោកនាយកទេវវិទ្យាល័យនៅប៉ារីស Archives MEP, Vol.765, N° 118.

## ជំពូកទី៧

# គ្រីស្ទបរិស័ទវៀតណាមនៅប្រទេសកម្ពុជា

នៅឆ្នាំ ១៨៦៣ ប្រទេសបារាំងមកត្រួតត្រាលើប្រទេសកម្ពុជា។ បន្ទាប់មក ក្នុងឆ្នាំ ១៨៦៧ តំណាងប្រទេសបារាំង និងប្រទេសសៀមបានចុះហត្ថលេខាលើសន្ធិសញ្ញាមួយទទួលស្គាល់ថា ប្រទេសសៀមមានសិទ្ធិពេញទីលើខេត្តអង្គរ និងខេត្តបាត់ដំបង ព្រមទាំងមានសិទ្ធិកាន់កាប់ខេត្តម្លូរព្រៃ និងខេត្តទន្លេរពៅទៀត។ ក្នុងសម័យនោះ "សន្តិភាពបារាំង" កើតមាននៅប្រទេសកម្ពុជា។

ប៉ុន្តែ សន្តិភាពនេះ គ្រាន់តែជាសម្បកក្រៅប៉ុណ្ណោះ។ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាណាព្យាបាលបារាំងនោះបានបន្តិច នៅឆ្នាំ ១៨៦៤ អាចារ្យស្វា ជាព្រះរាជវង្សម្នាក់ បានដឹកនាំចលនាបះបោរប្រឆាំងនឹងកងទ័ពបារាំងយ៉ាងខ្លាំង។ កងទ័ពបារាំងបង្ក្រាបពួកបះបោរទាំងនេះបាន។ បន្ទាប់មក មានការបះបោរថ្មីមួយទៀតគឺ ពីឆ្នាំ ១៨៦៥ ដល់ឆ្នាំ ១៨៦៧ ជនជាតិព៉ាដេម្នាក់ឈ្មោះពោរកំបោ បានបំបះបំបោរប្រជា រាស្ត្រនៅខេត្តក្រចេះ ខេត្តបាភ្នំ ខេត្តឧដុង្គ និងខេត្តកំពង់ធំ ឲ្យងើបឡើងប្រឆាំងបារាំង។ ព្រះសង្ឃព្រមទាំងអ្នកស្រែចម្ការបានគាំទ្រ ពោរកំបោនេះយ៉ាងសកម្ម។ តែពោរកំបោ ត្រូវគេសម្លាប់បានក្នុងពេលប្រយុទ្ធ ហើយសន្តិភាពបានកើតមានឡើងវិញនៅទូទាំងប្រទេស។ ប៉ុន្តែ ពួកជំទាស់អាណានិគមរង់ចាំតែឱកាសល្អ ដើម្បីងើបឡើងប្រឆាំងជាថ្មីម្តងទៀត។

នៅឆ្នាំ ១៨៨៤ លោក សាល ថុំសុន (Charles Thomson) ជាទេសាភិបាលនាដែនកូសាំងស៊ីន បានបង្ខំព្រះបាទនរោត្តមឲ្យឡាយព្រះហស្តលេខា លើអនុសញ្ញាមួយស្តីអំពីការដកហូតអំណាចនយោបាយ ដែលព្រះអង្គមានលើព្រះរាជាណាចក្រ។ ព្រឹត្តិការណ៍នេះ បណ្តាលឲ្យប្រជាជនខ្មែរបះបោរឡើងដោយ មានព្រះបាទនរោត្តមគាំទ្រ

ដោយសម្ងាត់ផង[១]។ បីឆ្នាំក្រោយមក រដ្ឋាភិបាលបារាំងទទួលស្គាល់កំហុសរបស់លោក ចុំ សុន និងផ្ទេរអំណាចថ្វាយទៅព្រះរាជាវិញ។ ចម្បាំងក៏បានស្ងប់ស្ងាត់ទៅ។

ចាប់ពីពេលនោះមក សន្តិភាពបានកើតមានឡើងវិញ នៅក្នុងរាជាណាចក្រកម្ពុជាទាំងមូល។ ជម្លោះផ្ទៃក្នុងរវាងរាជវង្សានុវង្ស និងការកាប់សម្លាប់គ្នាពីសតវត្សមុនៗនោះក៏បានស្ងប់រលត់ទៅដែរ។ បន្ទាប់ពីកងទ័ពបារាំង និងកងទ័ពសៀម បានប៉ះទង្គិចគ្នាជាច្រើនលើកមក នៅឆ្នាំ ១៩០២ ប្រទេសបារាំង បានរំដោះខេត្តស្ទឹងត្រែង និងខេត្តទន្លេរពៅជូនប្រទេសកម្ពុជាវិញ។ នៅឆ្នាំ ១៩០៧ បារាំងយកបានខេត្តអង្គរ និងបាត់ដំបងជូនប្រទេសកម្ពុជាទៀតទៀត។ ចាប់ពីពេលនោះម អាណានិគមបារាំង[២] បានកាន់កាប់ប្រទេសកម្ពុជាដោយឥតមានរឿងជាមួយជនជាតិខ្មែរទេ គឺបានសុខរហូតទៅដល់ដើមសង្គ្រាមលោកលើកទីពីរ។

ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំង អស់រយៈពេល ៩០ឆ្នាំ។ ក្នុងរយៈពេលនោះ ព្រះសហគមន៍នៅប្រទេសកម្ពុជារីកដុះដាលឡើង ក៏ប៉ុន្តែ ដោយព្រះសហគមន៍នេះជាប់ទាក់ទិននឹងពួកវៀតណាមជ្រុលហួសពេក ប្រជាជនខ្មែរប្រឆាំងនឹងព្រះសហគមន៍នេះជាច្រើនលើកច្រើនសា។

### សកម្មភាពបះបោរនៃក្រុមពោរកំបោ

ពោរកំបោបានប្រមូលអ្នកស្រែចម្ការ និងព្រះសង្ឃ ដើម្បីប្រយុទ្ធប្រឆាំងនឹងអាណាព្យាបាលបារាំង។ ក្នុងរយៈពេលពីរឆ្នាំ (១៨៦៥-១៨៦៧) ពួកបះបោរបានវាយព្រះសហគមន៍កាតូលិកបីកន្លែង គឺព្រះសហគមន៍នៅមាត់ក្រសាស់ ព្រះសហគមន៍នៅពញាឮ និងព្រះសហគមន៍នៅបាណាម។

នៅមាត់ក្រសាស់ ពួកគេបានចាត់គ្នាគេឲ្យទៅជួយលោក បារ៉ូ ជាបូជាចារ្យប្រចាំភូមិនោះ និងដាក់កំហិតឲ្យលោកចេញពីទីនោះភ្លាម។ លោកបូជាចារ្យជូនដំណឹងនេះទៅមន្ត្រីបារាំងប្រចាំការនៅភ្នំពេញ។ មន្ត្រីនេះបញ្ជូននាវាកាំភ្លើងធំមួយឲ្យមកទទួលលោកនាំទៅរាជធានី។ ប៉ុន្តែ ដោយនាវានោះពុំអាចដឹកយក គ្រួសារគ្រីស្តបរិស័ទទាំងឡាយបាន លោកសម្រេចចិត្តនៅនឹងកន្លែង។ នៅថ្ងៃទី ៩ មករា ឆ្នាំ ១៨៦៧ ពេលលោកកំពុងបង្ហើយអភិបូជា ពួកបះបោរមួយក្រុមបានចូលមកក្នុងព្រះវិហារចាប់លោក

សម្លាប់ចោលទៅ។ ពួកឃាតករកាត់ក្បាលលោក ដោតនៅលើបង្គោលមួយរួចដុតសព លោក។ ពួកនោះប្លន់យកទ្រព្យ គ្រឿងសក្ការៈនិងដុតព្រះវិហារចោល។ ឃាតកម្មនេះ បណ្ដាលឲ្យគ្រីស្ដបរិស័ទខ្មែរច្រួលច្របល់ជាខ្លាំង។ ពួកគេក៏បែកខ្ញែកគ្នាទៅអស់ ដោយ ពួកគេខ្លាចពួកបះបោរធ្វើទុក្ខបុកម្នេញដែរ។ បីបួនថ្ងៃក្រោយមក ពួកបះបោរបានចាប់ គ្រីស្ដបរិស័ទខ្មែរពីរនាក់។ ពួកគេបានបង្ខំអ្នកទាំងពីរនោះ ឲ្យបោះបង់ជំនឿរបស់ខ្លួន ចោល ក៏ប៉ុន្ដែ អ្នកទាំងពីរបដិសេធមិនព្រមធ្វើតាម ហើយក៏ត្រូវគេសម្លាប់ចោលទៅ[៣] ។ នៅពញាឮពួកបះបោរបានដុតព្រះវិហារ និងដុតផ្ទះសម្បែងរបស់គ្រីស្ដបរិស័ទចោល។ បន្ទាប់មក គ្រីស្ដបរិស័ទជាកូនកាត់ខ្មែរ-ព័រទុយហ្គាល់នាំគ្នារត់ទៅនៅភ្នំពេញរួមជាមួយ នឹងញាតិសន្ដាន ដែលរស់នៅលើដី ដែលព្រះរាជាទើបនឹងប្រទានឲ្យគេថ្មីៗនោះ។ ចំណែកឯគ្រីស្ដបរិស័ទជាតិវៀតណាម ៣០០ នាក់ ដែលជាចំណុះជើងព្រះវិហារ ពញាឮដែរនោះ គេនាំគ្នាទៅតាំងទីលំនៅឯភូមិមាត់ក្រសាស់ នៅកន្លែងដែលគ្រីស្ដ បរិស័ទខ្មែរបោះបង់ចោល។

លោកបារ៉ូយល់ឃើញថា ពួកអ្នកបះបោរមានបំណង "*កម្ទេចគ្រីស្ដសាសនាឲ្យ រលាយផុតអស់ពីទឹកដីកម្ពុជា សូម្បីតែឈ្មោះគ្រីស្ដបរិស័ទក៏មិនឲ្យមានដែរ*"[៤] ។ តាម ពិតយើងអាចសន្និដ្ឋានថា ពួកនេះបានប្រព្រឹត្ដអំពើដ៏ឃោរឃៅប្រឆាំងនឹងគ្រីស្ដសាសនា នេះ មកពីព្រះសហគមន៍កាតូលិកមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះរាជា និងជាមួយ អាណានិគមបារាំងនោះ។ កាលពីបួនឆ្នាំមុនលោកមីសសរសេរថា៖

> *«សព្វថ្ងៃនេះ ជនជាតិខ្មែរទាំងអស់ដឹងថា គេពុំអាចប៉ះសរសៃសក់ពួក គ្រីស្ដបរិស័ទ បានដោយមិនទទួលទោសវិញឡើយ»* [៥] ។

ម្យ៉ាងទៀត យើងអាចនឹកថា ពួកបះបោរបំផ្លិចបំផ្លាចសហគមន៍មាត់ក្រសាស់ និងបាណាម ប្រហែលបណ្ដាលមកពីគំនុំសងសឹករបស់អ្នកភូមិជិតខាង ដូចលោកមីសបាន សរសេរក្នុងឆ្នាំ ១៨៦៤ ថា៖ "*ទោះបី ពួកមន្ដ្រីច្រណែនលោភលន់ ខំតវ៉ាយ៉ាងណាក៏ដោយ*" ក៏ព្រះរាជាបានប្រទានដីព្រះវិហារមាត់ក្រសាស់ឲ្យលោកបារ៉ូ។ កាលពីដើម "*ពួកបះ បោរដាំដំណាំលើដីនោះ*" តែឥឡូវនេះពួកនោះឥតហ៊ានមកនៅលើដីនោះ វិញឡើយ។

> *«ពួកអស់លោកនាហ្មឺន និងព្រះសង្ឃរកគ្រប់មធ្យោបាយ ដើម្បីដេញខ្ញុំ ចេញពីទីនេះ។ តែព្រះរាជាទ្រង់ពុំបានព្រះសណ្ដាប់ពាក្យរបស់អ្នកខាងណោះ*

*ឬអ្នកខាងណោះឡើយ ព្រះករុណាជាម្ចាស់ ទើបនឹងហាមប្រាមអស់លោក កុំឲ្យនិយាយពីរឿងនេះទៀត បើហ៊ាននិយាយនឹងត្រូវរំពាត់ផ្ដៅ*[៦] »។

ចំណែកសហគមន៍គ្រីស្តបរិស័ទនៅបាណាមវិញ មានសុទ្ធតែពួកកូសាំងស៊ីន។ គ្រីស្តបរិស័ទបានមក តាំងពីឆ្នាំ ១៨៦៣ ដូចពួកគ្រីស្តបរិស័ទកូសាំងស៊ីនមួយចំនួនទៀត ដែលបានមកតាំងទីលំនៅឯឬស្សីកែវ ខាងជើងទីក្រុងភ្នំពេញក្នុងឆ្នាំដដែលនោះ។ ពេលនោះ ព្រះរាជាបានប្រទានដីមួយកន្លែង ដែលប្រជាពលរដ្ឋបោះបង់ចោល ជូនលោកមីស ដើម្បីឲ្យពួកកូសាំងស៊ីនចំនួន ១២០០ នាក់ តាំងទីលំនៅ។ គ្រីស្តបរិស័ទទាំងនេះ បានរត់ភៀសខ្លួន ព្រោះរដ្ឋអំណាចវៀតណាមធ្វើទុក្ខបុកម្នេញពួកគេខ្លាំងណាស់។

លោកអភិបាលព្រះសហគមន៍យល់ច្បាស់ ពីរឿងហេតុដែលនឹងកើតមានឡើងនៅពេលអនាគត។ លោកសរសេរទៅលោកនាយកទេវវិទ្យាល័យ ក្រុងប៉ារីស នាថ្ងៃទី ១៥ កុម្ភៈ ឆ្នាំ ១៨៦៣ ស្រាប់៖

*«យើងត្រូវស៊ូ ដើម្បីថែរក្សាកន្លែងដ៏ល្អនេះឲ្យបានគង់វង្ស។ មានវត្តបីស្ថិតនៅលើដីរបស់យើង។ ដោយសន្តិភាពកើតមានវិញហើយ លោកសង្ឃបានប្រើគ្រប់មធ្យោបាយ ដើម្បីដណ្ដើមយកដីនេះវិញ។ ព្រះសង្ឃបានយកមន្ត្រីធ្វើជាឈ្នាន់ ដើម្បីទទួចសុំព្រះរាជាអនុគ្រោះ។ ព្រះរាជាពិបាកដោះស្រាយយ៉ាងខ្លាំង ដោយព្រះអង្គចេះតែខ្លាចលោកសង្ឃ និងពួកមន្ត្រី ក៏ប៉ុន្តែ ព្រះអង្គខ្លាចខ្ញុំជាងខ្លាចពួកអស់លោកទៅទៀត ព្រោះព្រះអង្គជ្រាបថា ប្រសិនបើពុំមានខ្ញុំទេនោះ ព្រះអង្គពិតជាពុំបានវិលមកឃើញប្រទេសកម្ពុជាវិញឡើយ។ មកទល់ពេលនេះ យើងមានជ័យជំនះហើយតែចាំមើលទៅមុខទៀត តើវានឹងទៅជាយ៉ាងណា*[៧]»។

ការបង្ករបង្កើតសហគមន៍គ្រីស្តបរិស័ទសាសនារបៀបបុរាណនេះ គង់តែនឹងបណ្ដាលឲ្យកើតមានរឿងរ៉ាវ ក្នុងពេលអនាគតជាពុំខាន។

**ព្រះសហគមន៍ក្លាយទៅជាព្រះសហគមន៍របស់ជនជាតិបរទេស**

ពោរកំបោ បានបំផ្លាញគ្រីស្តសាសនា ដោយទស្សនៈជាតិនិយមមកធ្វើជាឈ្នាន់។ ក្នុងឆ្នាំបន្ទាប់មក មនោសញ្ចេតនាស្នេហាជាតិនេះ កាន់តែមាន

ឥទ្ធិពលខ្លាំងឡើងៗ ដោយជនជាតិវៀតណាមចូលមករស់នៅក្នុងប្រទេសកម្ពុជាកាន់តែច្រើនឡើងៗនោះ។

ជនជាតិវៀតណាមបានចូលមករស់នៅដែនកូសាំងស៊ីន តាំងពីចុងសតវត្សទី ១៦ មកម៉្លេះ។ អ្នករត់ចូលមករស់នៅស្រុកខ្មែរមានចំនួនកាន់តែច្រើនឡើងៗ ក្នុងសតវត្សក្រោយទៀត។ បន្តិចម្តងៗ ពួកវៀតណាមកាន់កាប់អាណាខេត្តកម្ពុជាភាគអាគ្នេយ៍ទាំងមូល។ ចម្បាំងរវាងខ្មែរ និងវៀតណាម នៅសតវត្សទី ១៨ និង ដើមសតវត្សទី ១៩ បានបណ្តាលឲ្យខ្មែរនិងវៀតណាមចង់គំនុំនឹងគ្នា កាន់តែស្វិតស្វាញខ្លាំងឡើងថែមទៀត។ ម៉្យាងទៀតពេលប្រទេសបារាំងត្រួតត្រាលើជ្រោយឥណ្ឌូចិននោះ បារាំងបង្រួបបង្រួមភូមិភាគទាំងប្រាំនៃឥណ្ឌូចិន ដាក់នៅក្រោមអាណានិគមតែមួយ ដោយគ្មានកំណត់ព្រំដែនឡើយ[៨] ។ ដូច្នេះ ជនជាតិវៀតណាមចេញពីស្រុករបស់ខ្លួន ទៅរស់នៅស្រុកដទៃទៀតបានដោយងាយ។ ម៉្យាងទៀត បារាំងតែងប្រោសប្រណីដល់ជនជាតិវៀតណាម ដែលមានគ្នាច្រើនជាងគេ ហើយដែលចេះដាក់ខ្លួនចុះញ៉ មជាងជនជាតិឯទៀតៗ។ នៅប្រទេសកម្ពុជាអស់លោកបារាំង តែងតែយកពួកវៀតណាម ឲ្យធ្វើការនៅតាមក្រសួងនានា ឬក៏ធ្វើការនៅតាមផ្ទះរបស់អស់លោក ជាជាងយកជនជាតិខ្មែរ។ ពួកវៀតណាមប៉ិនប្រសប់ធ្វើការផ្ទះ និងជាងផ្សេងៗ ដូច្នេះពួកនេះមានការធ្វើនៅគ្រប់ទីកន្លែង។ អាណានិគមនិយមបារាំងបានយកកម្មករវៀតណាមជាច្រើន មកធ្វើការនៅក្នុងប្រទេសកម្ពុជា ព្រោះអស់លោកយល់ថា ពួកវៀតណាមពូកែធ្វើការជាងជនជាតិឯទៀតៗ[៩]។ វត្តមានរបស់ជនជាតិវៀតណាម ដែលមានចំនួនកាន់តែច្រើនឡើងៗនៅក្នុងប្រទេសកម្ពុជា គង់តែបណ្តាលឲ្យកើតមានវិបត្តិនៅពេលក្រោយជាពុំខាន។

កាលពីដើមដំបូង ជនជាតិខ្មែរ ឬក៏ខ្មែរកូនកាត់ព័រទុយហ្គាល់ ជាស្នូលនៃព្រះសហគមន៍កាតូលិក។ នៅ ឆ្នាំ ១៦៦៥ មានគ្រីស្តបរិស័ទកូសាំងស៊ីនតែ ៤0 នាក់ប៉ុណ្ណោះ នៅលើត្រើយខាងលិចនៃទន្លេមេគង្គ។ ក្នុងអំឡុងពីរសតវត្សបន្ទាប់មក មានគ្រីស្តបរិស័ទមកពីដែនកូសាំងស៊ីនចំនួនបីបួនរយនាក់ទៀត មករស់នៅជាមួយពួកគេនោះ។ គ្រានោះចំនួនគ្រីស្តបរិស័ទជាតិវៀតណាមនៅមានតិចនៅឡើយទេ។ ពីឆ្នាំ ១៨៥៨ ដល់ឆ្នាំ ១៨៦២ គឺនៅក្នុងរជ្ជកាលព្រះចៅអធិរាជវៀតណាម ទុយ ឌុក អាជ្ញាធរដែនកូសាំងស៊ីន ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទជាខ្លាំង ហើយគ្រីស្តបរិស័ទដែនកូសាំងស៊ីនជាច្រើនភៀសខ្លួនមកនៅ

ប្រទេសកម្ពុជា។ នៅខែតុលា ឆ្នាំ ១៨៦១ លោកមីសសរសេរថា៖

*«តាំងពីមួយខែមកហើយ គ្រីស្តបរិស័ទកូសាំងស៊ីនក្រោមរាប់រយនាក់រត់មក ដល់ពញាឮនេះ។ ពួកគេត្រូវមន្ត្រីវៀតណាមធ្វើទុក្ខបុកម្នេញ រួចនៅតាមផ្លូវត្រូវ ក្រុមចោរប្លន់វាយដណ្តើមយកទ្រព្យអស់ទៀត។ អ្នកទាំងនោះរត់មករកយើង ព្រោះគ្មាចង់បានសេចក្តីសុខ ដែលពួកគេបាត់បង់ទៅហើយនៅក្នុង មាតុភូមិរបស់ខ្លួននោះ។ ជារៀងរាល់ថ្ងៃ ខ្ញុំចែកអង្ករឲ្យជនអភ័ព្វទាំងនោះ ចំនួនពី ៨០០ ទៅ ៩០០ នាក់។ ពួកគេគ្មានយកអ្វីមកប្រទេសកម្ពុជា ក្រៅពីដៃនិងជើងទទេ ទៅប៉ុណ្ណោះ*[១០] ។

ម្យ៉ាងទៀត លោកអភិបាលព្រះសហគមន៍ មិនចាញ់បោកគំនិតមិនល្អរបស់អ្នកខ្លះ ដែលចង់ចូលគ្រីស្តសាសនានោះឡើយ។ លោកសរសេរអំពីបញ្ហានេះថា៖

*«តាំងពីពេលដែលពួកវៀតណាមជឿថា ប្រទេសបារាំងមុខជានឹងកាន់កាប់ប្រទេសខ្មែររហូតទៅនោះ ពួកគេជាច្រើនចង់ចូលគ្រីស្តសាសាន...»*។

ក្រោយពីការចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង-វៀតណាម នាឆ្នាំ ១៨៦៣ មក មានជនជាតិវៀតណាមជាច្រើន សុំចូលគ្រីស្តសាសនាជាបន្តបន្ទាប់។ តាមសន្ធិសញ្ញានោះ ព្រះចៅអធិរាជវៀតណាម ទ្រង់ប្រោសប្រទានសេរីភាពផ្នែកសាសនា ដល់គ្រីស្តបរិស័ទកាតូលិកនៅប្រទេសវៀតណាម។ ក្នុងឆ្នាំ ១៨៦៣ ពួកកូសាំងស៊ីនមួយក្រុមមកតាំងទីលំនៅឯឫស្សីកែវ ខាងជើងព្រះវិហារ "ព្រះមាតា" នាក្រុងភ្នំពេញ។ ក្នុងឆ្នាំ ១៨៦៤ ពួកកូសាំងស៊ីនមួយក្រុមទៀតមកនៅបាណាម។ នៅឆ្នាំ ១៨៦៧ ពួកអ្នកនេសាទខ្លះកសាងភូមិមួយនៅជ្រោយចង្វារ ទល់មុខក្រុងភ្នំពេញ។ ពួកនោះបានដាក់ឈ្មោះភូមិរបស់ខ្លួនថា "Xom Bien" គឺ ភូមិ "សមុទ្រ"។ ក្រុមគ្រីស្តបរិស័ទចំណុះជើងព្រះវិហារទាំងបីនោះ ចេះតែទទួលគ្រីស្តបរិស័ទវៀតណាមមកដល់ថ្មីៗ ឲ្យស្នាក់នៅជាបណ្តោះអាសន្ន រួចក្រោយមក ទើបអ្នកមកដល់ថ្មីទាំងនោះ បែកចេញទៅបង្កើតសហគមន៍ន៍កាតូលិកនៅកន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជា។

ក្នុងឆ្នាំ ១៨៦៩ ស្របទៅតាមសំណូមពររបស់លោកមីស សម្តេចប៉ាបបានដកប្រទេសលាវចេញពី ការរបស់អភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា មកដាក់ក្រោមការត្រួតត្រារបស់អភិបាលព្រះសហគមន៍ប្រទេសសៀមវិញ[១១]។ ផ្ទុយទៅវិញ សម្តេចប៉ាបបានបញ្ចូលខេត្តដែនកូសាំងស៊ីនទាំងពីរ គឺខេត្តហាទៀង និងខេត្តមាត់ជ្រូក

ដែលស្ថិតនៅខាងលិចទន្លេមេគង្គ ឲ្យមកនៅក្រោមការណែនាំរបស់លោកអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជាវិញ។ លោកអូសូឡីដែលទទួលបន្ទុកលើព្រះសហគមន៍ប្រចាំប្រទេស កម្ពុជាក្នុងពេលនោះ(១២) សរសេរថា៖

*«ការភ្ជាប់ខេត្តទាំងពីរនៃដែនកូសាំងស៊ីននឹងកម្ពុជា មុខជាធ្វើឲ្យសកម្មភាពគ្រីស្តសាសនានៅប្រទេសកម្ពុជារីកចម្រើនឡើងវិញជាពុំខាន»។*

សកម្មភាពគ្រីស្តសាសនារីកចម្រើនមែន ព្រោះនៅចន្លោះពីឆ្នាំ ១៨៦៩ និង ១៨៨៤ គ្រីស្តបរិស័ទវៀតណាម បានបង្កើតព្រះសហគមន៍ចំនួន ២០ ទៀត (១៣) ។

របៀបបង្កើតសហគមន៍ន៍គ្រីស្តសាសនាងាយស្រួល គឺសាសនទូតរកដីធ្លី សម្រាប់ចែកឲ្យអ្នកស្ម័គ្រចិត្តមកតាំងទីលំនៅ។ អ្នកស្ម័គ្រចិត្តទាំងនោះ ច្រើនជាជនជាតិវៀតណាមដែលជាគ្រីស្តបរិស័ទ ឬ ដែលចង់ចូលគ្រីស្តសាសនា។ ធម្មតានៅដីនោះគ្មានមនុស្សនៅទេ ហើយស្ថិតនៅក្រៅតំបន់មានប្រជាជនរស់នៅ ជួនកាលជាដីព្រះរាជាប្រទានឲ្យ ឬក៏ជាដីដែលរដ្ឋអំណាចបារាំងចែកចាយឲ្យ ជួនកាលទៀត ជាដីដែលសាសនទូតចេញប្រាក់ទិញយកតែម្តង។

នៅសម័យនោះ គ្រីស្តបរិស័ទអាចប្រតិបត្តិតាមជំនឿរបស់ខ្លួនបាន លុះត្រាតែផ្តុំគ្នាជា "បណ្តុំគ្រីស្តបរិស័ទ" នៅជុំវិញព្រះវិហាររបស់ខ្លួន។ ដោយរស់នៅយ៉ាងដូច្នេះ ទើបពួកគេផុតពីការពារពេបជ្រាប អំពីសំណាក់ជនរួមជាតិដែលកាន់សាសនាដ៏ទៃ។ ចំពោះគ្រីស្តបរិស័ទខ្មែរ គេគេចផុតពីអំណាចរបស់អ្នកតា ដែលជាម្ចាស់ស្រុកនោះ គឺជាការមួយចាំបាច់ណាស់។ ការប្តូរសាសនាមិនគ្រាន់តែជាការផ្លាស់ប្តូរជំនឿខាងចិត្តគំនិតប៉ុណ្ណោះទេ គឺត្រូវប្តូរកន្លែងរស់នៅថែមទៀត។ នៅសម័យនោះគេ ហៅពួកអ្នកកាន់សាសនាដ៏ទៃថា "ក្រៅសាសន៍" ។ គ្រីស្តបរិស័ទតែងចេញពីភូមិកំណើតទៅរស់នៅក្នុងភូមិ "កាតូលិក" ហើយគេនិយមហៅគ្នីគ្នាថា "អ្នកក្នុងសាសន៍" ។ ជនជាតិវៀតណាមដែលចូលមកនៅស្រុកខ្មែរថ្មីៗ ហើយគ្មានដីធ្លី អាចផ្លាស់ប្តូរទីកន្លែងបានស្រួលជាងជនជាតិខ្មែរម្ចាស់ស្រុកដែលមានដីធ្លីតាំងពីដូនតាមកហើយនោះ។

សាសនទូតជាច្រើន តែងបង្កើតក្រុមសហគមន៍ទៅតាមអំពីចិត្តរបស់លោក ដោយឥតមានក្រែងរអែងអ្នកកាន់អំណាចខ្មែរសោះ។ អស់លោកជ្រើសរើសដីធ្លីមួយកន្លែងដោយមានការយល់ព្រមពីអ្នករដ្ឋការបារាំង ក្រោយមកអស់លោកដាក់ឈ្មោះភូមិរបស់

គ្រីស្តបរិស័ទ ឬក៏សម្រេចយកឈ្មោះដែលពួកវៀតណាមបានដាក់រួចមកហើយ នៅពេលពួកគេមកតាំងទីលំនៅ។ ឈ្មោះភូមិទាំងនោះ ជួនកាលជាឈ្មោះវៀតណាម ជួនកាលជាឈ្មោះតាមគ្រីស្តសាសនា "Thanh Gia" មានន័យថា "ព្រះឈើឆ្កាង" "Thanh Mau" មានន័យថា "ព្រះមាតា" "Ba Vua" មានន័យថា "ស្តេចទាំងបី" ឬជួនកាលទៀត ជាឈ្មោះក្លាយមកពីឈ្មោះខ្មែរ ដូចជា "ម៉ាក់តាបា" ដែលក្លាយមកពី "មាត់ក្រសាស់"។ រាជការខ្មែរពុំស្គាល់ឈ្មោះទាំងនោះទេ តែព្រះសហាគមន៍កាតូលិក ក៏ធ្លាប់ប្រើឈ្មោះទាំងនោះរហូតមកទល់នឹងឆ្នាំ១៩៧០។ នេះជាសញ្ញាមួយបញ្ជាក់ថា ព្រះសហាគមន៍ដាច់ឆ្ងាយពីប្រជាជនខ្មែរទូទៅ។

សាសនទូតទាំងអស់ធ្លាប់ចាត់ចែងសហាគមន៍គ្រីស្តបរិស័ទ តាមរបៀបគ្រប់គ្រងភូមិវៀតណាម គឺមានក្រុមប្រឹក្សាព្រឹទ្ធាចារ្យ គឺ "ភ្នាក់ងារ" តាមភាសាវៀតណាមហៅថា "Qui Chuc" ហើយមានអ្នកខ្លះ ហៅថា "អ្នកណែនាំថ្នាក់ទីពីរ" ដែរ។ លោកឡឺហ្វែរ និងលោកមីស បញ្ជាក់ភារកិច្ចរបស់អ្នកអប់រំទាំងនោះ នៅក្នុងសេចក្តីរាយការណ៍របស់លោក នាឆ្នាំ ១៨៥០ ថា៖

*«អ្នកណែនាំ ជាមេគ្រួសារដែលមានឥទ្ធិពលខ្លះ នៅក្នុងក្រុមគ្រីស្តបរិស័ទ។ មុខងាររបស់អ្នកទាំងនោះ គឺរក្សារបៀបរៀបរយ ដោះស្រាយទំនាស់និងបញ្ហាផ្សេងៗ ដែលកើតមានឡើងក្នុងព្រះសហាគមន៍។ អ្នកនោះធ្វើជាអធិបតីនៅក្នុងអង្គប្រជុំ និងនៅពេលរៀបមង្គលការ នៅពេលពេលណាគ្មានបូជាចារ្យ។ គេលាបប្រេងអ្នកជំងឺ ហើយកំដរមនុស្សនៅពេលជិតស្លាប់។ បើនិយាយឲ្យខ្លីទៅ អ្នកណែនាំទាំងពីរនោះ បំពេញកិច្ចការជំនួសបូជាចារ្យតាមឱកាសហុចឲ្យ។ យើងមានមនុស្សបែបនេះទាំងអស់ ៣០០ នាក់ ដោយខ្ញុំរាប់តែអ្នកដែលមានប្រយោជន៍ប៉ុណ្ណោះ»*[១៤]។

សាសនទូតភាគច្រើន យកចិត្តទុកដាក់តែនឹងជនជាតិវៀតណាម ព្រោះពួកនេះមានគ្នាច្រើន។ ពេលធ្វើដំណើរក្នុងប្រទេសកម្ពុជា សាសនទូតតែងរក "កូនចៅនៃប្រទេសអណ្ណាម ដែលវង្វេងព្រាត់ប្រាស់ "ដូចលោកឡាសា(Lazard) ដែលបង្កើតក្រុមគ្រីស្តបរិស័ទជាច្រើនអនេកនោះ បានកត់ត្រាទុក។

បន្តិចម្តងៗ សាសនទូតដែលទទួលបន្ទុកព្រះសហាគមន៍ប្រចាំប្រទេសកម្ពុជា ទៅរស់នៅដែនកូសាំងស៊ីនអស់ ព្រោះជាកន្លែងដែលមានគ្រីស្តបរិស័ទច្រើនជាងគេ[១៥]។

នៅឆ្នាំ ១៨៧២ លោកអូសូឡី ដែលទទួលការខុសត្រូវលើព្រះសហគមន៍ បានតាំងទីនៅឯកោះគូឡាវយៀង (Culao Gieng) គឺកោះមួយស្ថិត នៅតាមដងទន្លេមេគង្គប៉ែកខាងក្រោម។ កោះគូឡាវយៀងនេះ ក៏ក្លាយជាមជ្ឈមណ្ឌលមួយដ៏ធំសំខាន់បំផុតរបស់ព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា។ លោកអូសូឡីបានសង់សាលារៀនមួយនិងសង់ទេវវិទ្យាល័យមួយនៅកោះនោះ។ ថ្ងៃទី ១២ ខែមករា ឆ្នាំ ១៨៧៦ ដូនជីនៃក្រុមគ្រួសារព្រះឧបការគុណពីភូមិព័រជើ (Congrégation de la Providence de Portieux) មកដល់កោះគូឡាវយៀងដែរ បព្វជិតាទាំងអស់តាំងទីចាត់ការរបស់ខ្លួននៅទីនោះ បន្ទាប់មក សង់អគារកូនកំព្រាមួយ មន្ទីពេទ្យសម្រាលកូនមួយ សាលារៀនមួយ មន្ទីពេទ្យមួយ និងសាលាអប់រំដូនជីមួយ។

ព្រះសហគមន៍ខ្មែរទាំងបី (ភ្នំពេញ បាត់ដំបង និងមាត់ក្រសាស់) ដែលជាដើមកំណើតរបស់ព្រះសហគមន៍ប្រទេសកម្ពុជា បានលិចកប់បាត់ទៅក្នុងចំណោមពួកកាតូលិកវៀតណាម ដែលបានចូលមករស់នៅប្រទេសកម្ពុជាកាន់តែច្រើនឡើងៗនោះ។ រហូតមកទល់នឹងឆ្នាំ ១៨៧៨ បូជាចារ្យទទួលបន្ទុកក្រុមគ្រីស្តបរិស័ទវៀតណាមនៅភូមិឫស្សីកែវតែងទៅជួយណែនាំក្រុមគ្រីស្តបរិស័ទខ្មែរភូមិ "ព្រះមាតា" នាក្រុងភ្នំពេញ។ បន្ទាប់មកបូជាចារ្យទទួលបន្ទុកនៅជ្រោយចង្វារ (Xom Bien) មើលខុសត្រូវលើគ្រីស្តបរិស័ទភូមិ "ព្រះមាតា" នេះ រហូតដល់ឆ្នាំ ១៨៨៣។

ម្យ៉ាងទៀត បូជាចារ្យទទួលបន្ទុកនៅជ្រោយចង្វារនេះ ក៏បានមើលខុសត្រូវលើសហគមន៍បាត់ដំបង រហូតដល់ឆ្នាំ ១៨៨៤។ ចំណែកឯសហគមន៍មាត់ជ្រូកក្រសាស់វិញគ្រានោះ ស្ថិតនៅក្រោមការដឹកនាំរបស់បូជាចារ្យទទួលបន្ទុកពួកវៀតណាម ដែលបានមកតាំងទីលំនៅលើដីដែលគ្រីស្តបរិស័ទខ្មែរបោះបង់ចោល ក្នុងសម័យពោរកំបោនោះ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏លោកក័រឌីយេ (Cordier) ដែលជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា នៅឆ្នាំ ១៨៨៣ និងលោកគ្រូសហ្ស៊ែក (Grosgeoges) ដែលបន្តតំណែងពីលោកក័រឌីយេនោះ បានជ្រើសយកក្រុមសហគមន៍ "ព្រះមាតា" ធ្វើជាទីស្នាក់ការរបស់លោក។ លោកទាំងពីរជ្រើសរើសភូមិខ្មែរនេះ សបញ្ជាក់ឲ្យដឹងថា លោកនៅតែនឹកគិតដល់គ្រីស្តបរិស័ទខ្មែរ។

**ការបះបោររបស់ជនជាតិខ្មែរចំពោះបារាំងសេស និងចំពោះពួកវៀតណាម**

ក្នុងឆ្នាំ ១៨៨៥ ជនជាតិខ្មែរស្មានថា ក្នុងព្រះសហគមន៍មានសុទ្ធតែជនជាតិវៀតណាមទាំងអស់។ ដូច្នេះហើយ បានជាក្នុងពេលអ្នកជាតិនិយមបះបោរប្រឆាំងអាណានិគមបារាំង ពួកគេឆ្លៀតឱកាសវាយក្រុមសហគមន៍គ្រីស្តបរិស័ទ ដែលស្ថិតនៅឆ្ងាយពីទីក្រុង។ អ្នកបះបោរទាំងនោះថា ក្នុងព្រះសហគមន៍មានសុទ្ធ តែជនបរទេស គឺបារាំង និងវៀតណាម ។

*«នៅស្វាយរៀង ពួកអ្នកបះបោរបានសម្លាប់លោកហ្គុយយ៉ូម៉ារ (Guyomar) ដែលជាសាសនទូតក្មេងម្នាក់ និងភ្នាក់ងារគយបារាំងម្នាក់ទៀត។ ពួកគេសម្លាប់ជនជាតិវៀតណាម និងដេញពួកនោះចេញពីប្រទេស ព្រោះជាសត្រូវសួពូជ និងជាសម្ព័ន្ធមិត្តរបស់បារាំង។ ពួកគេដុតបំផ្លាញព្រះវិហារទាំងអស់ចោល និងវាយកម្ទេចក្រុមគ្រីស្តបរិស័ទ។*

*មានតែគ្រីស្តបរិស័ទវៀតណាម នៅមាត់ក្រសាស់និងបាណាមទេ ដែលពួតដៃគ្នាការពារខ្លួនបាន។ លោកប៊ូស៊ុត (Bouchut) ដែលជាបូជាចារ្យទទួលបន្ទុកស្រុកព្រែកត្រែងនៅខាងត្បូងក្រុងភ្នំពេញ បានរួចខ្លួនយ៉ាងអស្ចារ្យ ដោយលោករុំខ្លួននឹងកន្ទេល ហើយដេកពួននៅក្នុងទូកមួយ...(១៦)។*

នៅស្វាយរៀង កំពង់ត្របែក ព្រែកពោធិ បាណាម និងនៅតំបន់ភាគអាគ្នេយ៍ទាំងមូលនៃប្រទេសកម្ពុជា ពួកបះបោរបានសម្លាប់ជនជាតិវៀតណាមអស់ជាច្រើន(១៧)។ ក្នុងចំណោមជនជាតិវៀតណាមទាំងនោះ មានគ្រីស្តបរិស័ទមួយចំនួនធំដែរ។ គ្រីស្តបរិស័ទវៀតណាមជាច្រើន បានបែកខ្ញែកគ្នាអស់ អ្នកខ្លះវិលត្រលប់ទៅដែនកូសាំងស៊ីនវិញ។ គ្រានោះ លោកឡាសា (Lazard) ដែលនៅជាមួយក្រុមគ្រីស្តបរិស័ទបឹងកាជោត (Thanh Mau) នៅខាងជើងស្ទឹងត្រង់បានរួចខ្លួនដោយសារប្រើមធ្យោបាយមួយដ៏អស្ចារ្យ គឺលោកបញ្ជាឲ្យគ្រីស្តបរិស័ទរុះវិហារ រុះផ្ទះលោក និងផ្ទះរបស់ពួកគេ យកឈើសង់ក្បូនដ៏ធំសម្បើមមួយ បណ្តែតនៅកណ្តាលទន្លេមេគង្គ។ លោកនិងគ្រីស្តបរិស័ទទាំងឡាយរស់នៅលើក្បូនដ៏ធំនោះជាច្រើនខែ។

ការបះបោរនៅឆ្នាំ ១៨៨៥ បានបណ្តាលឲ្យគ្រីស្តបរិស័ទឈឺចាប់យ៉ាងខ្លាំង ក៏ប៉ុន្តែមិននាំឲ្យគេត្រិះរិះឲ្យបានដិតដល់អំពីមូលហេតុដែលបង្កើតរឿងនេះទេ។ ម្យ៉ាង

ទៀត ព្រះសហគមន៍ក៏គ្មានសមត្ថភាពនឹងឃាត់ជនជាតិវៀតណាម មិនឲ្យចូលមករស់នៅក្នុងប្រទេសកម្ពុជាបានដែរ។ គ្រីស្តបរិស័ទវៀតណាមពេលនោះ មានចំនួនច្រើនជាងគ្រីស្តបរិស័ទខ្មែរក៏ពិតមែន ក៏ប៉ុន្តែ បើប្រៀបធៀបទៅនឹងចំនួនជនជាតិវៀតណាមទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជា គ្រីស្តបរិស័ទវៀតណាមមានតែ ៧ ទៅ ៨ ភាគរយប៉ុណ្ណោះ[១៨]។ ព្រះសហគមន៍នៅតែប្រព្រឹត្តទៅតាមសភាពការណ៍ នាសម័យនោះ។ សេចក្តីរាយការណ៍ឆ្នាំ ១៩០១ បញ្ជាក់ឲ្យដឹងច្បាស់ថា "*ជនជាតិវៀតណាមចូលមកនៅតំបន់ទន្លេសាបកាន់តែច្រើនឡើងៗឥតឈប់ឈរ* "។ ឆ្នាំក្រោយៗមកទៀត សហគមន៍កាតូលិកវៀតណាម បានកើតឡើងជាបន្តបន្ទាប់ ក៏ប៉ុន្តែ មិនសូវមានចំនួនច្រើនដូចរាប់សិបឆ្នាំមុននោះទេ[១៩]។

ដោយមានជនជាតិវៀតណាមច្រើននៅក្នុងព្រះសហគមន៍ ជនជាតិខ្មែរយល់ឃើញថា ព្រះសហគមន៍ ជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសត្រូវស្ទួពូជរបស់ខ្លួន។ ទោះបីព្រះសហគមន៍ខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះជនជាតិខ្មែរក៏ដោយ ក៏ការខំប្រឹងប្រែងនេះ មិនសូវបានទទួលលទ្ធផលប៉ុន្មានទេ។ រហូតមកទល់នឹងសព្វថ្ងៃនេះ ជនជាតិខ្មែរតែងហៅព្រះវិហារគ្រីស្តសាសនាថា "អុងកូ"[២០] គឺជាវិហារ និងជាសាសនារបស់ជនជាតិបរទេស ដែលពួកគេស្អប់ជាទីបំផុតនោះ។

---

(១)«*ថ្ងៃទី១ មករា ឆ្នាំ ១៨៨៥ មន្ត្រីរដ្ឋការបារាំងជាច្រើនដែលមកពីដែនកូសាំងស៊ីន ចាប់ផ្តើមកាន់កាប់ក្រសួងទាំងអស់នៅប្រទេសកម្ពុជា។ នៅថ្ងៃទី ៦ មករា ព្រះបាទនរោត្តមទ្រង់ចេញបញ្ជាឲ្យប្រជាពលរដ្ឋបះបោរដេញបរទេសចេញ។ ទ្រង់មានព្រះបន្ទូលផ្តាំផ្ញើ ឲ្យសម្លាប់ពួកអឺរ៉ុប និងពួកវៀតណាមចោលទាំងអស់*» (Journal du P.Lazard, Archives Evêchê de Phnom-Penh, cité en V.Rollin, “Histrorie de la Mission du Cambodge” I,p.65.

(២)A.Forest, op.cit.,sous-titre.

(៣)Launay, Histoire générale des MEP, tome III, p.480-482 et note du P.Vauzell. នៅឆ្នាំ ១៨៨០ សហគមន៍ន៍នេះមានគ្រីស្តបរិស័ទខ្មែរ ១៧០ នាក់ និងវៀតណាម ៤៣០ នាក់។ គ្រីស្តបរិស័ទទាំងនោះ បានតាំងទីលំនៅដីដែលជនជាតិខ្មែរកាន់កាប់ពីមុន។

(៤)លិខិតជូនទៅលោកម៉ែ Trés Rév. Mére, Achives MEP, Vol.76, nº 145.

(៥)Lettre à MM. Les Directeurs, Archives MEP, Vol.165, nº 94.

( ៦ )Lettre au P.Albrand, Archives MEP, Vol.765, nº 126.

( ៧ )Lettres Communes 1863, p. 24.

( ៨ )Cambodge, Cochinchine ( ចុះចូលក្រោមអំណាចបារាំង តាមសន្ធិសញ្ញា ឆ្នាំ ១៨៦២ ), Annam ( 1867 ), Tonkin ( 1874 et 1885 ). Laos ( 1888, 1893, 1902, 1904, 1905, 1925 ).

( ៩ )ក្នុងឆ្នាំ ១៩៣០ ក្រុមហ៊ុនមួយនៅកោះត្រល់ បានទាក់ទងជាមួយលោកអភិបាលព្រះសហគមន៍ប្រចាំប្រទេសវៀតណាម ដើម្បីឲ្យបានគ្រួសារគ្រីស្តបរិស័ទមកធ្វើការក្នុងកោះនោះ។ "លោកមុយណាហ្គោរី ( Munagori ) ដែលជាអភិបាលព្រះសហគមន៍នៅបួយជូ ( Bui Chu ) ក៏ប្រញាប់ប្រញាល់បញ្ជូនមនុស្សចំនួន ២១៧៥ នាក់ទៅឲ្យក្រុមហ៊ុននោះ។ នៅក្នុងចំណោមអ្នកទាំងនោះ មានក្មេង ៧០០ នាក់ ។ ក្រុមហ៊ុនឲ្យពួកអ្នកមកដល់ថ្មីៗនោះ តាំងទីលំនៅតាមឆ្នេរសមុទ្រ។ "( Lettres Communes ឆ្នាំ ១៩៣០ ) ។ បន្ទាប់ពីពួកចោរចូលប្លន់មកគ្រួសារទាំងនោះ បានបែកខ្ញែកគ្នាអស់គ្រួសារខ្លះត្រឡប់ទៅនៅប្រទេសវៀតណាមវិញ។

នៅពេលបង្កើតក្រុមហ៊ុនចម្ការកៅស៊ូ បារាំង ពួកអ្នកជ្រើសរើសកម្មករបានផ្ញើរូបថតព្រះវិហារដែលគេបានសង់រួចហើយ នៅក្នុងចម្ការទាំងនោះ ជូនគ្រីស្តបរិស័ទក្នុងតំបន់ក្រីក្រនៃប្រទេសវៀតណាម ដើម្បីឲ្យគ្រីស្តបរិស័ទតំបន់នោះ សុខចិត្តចូលមកនៅដោយចិត្តកក់ក្តៅ ព្រោះពួកគេអាចប្រតិបត្តិតាមជំនឿរបស់ខ្លួនទៅទៀតបាន។

( ១០ )Lettre à MM. Les Direteurs de Paris, Archives MEP, Vol.765, nº 88 et 94.

( ១១ )ប្រទេសលាវជាដែនដីដែលជនជាតិអឺរ៉ុបពុំស្គាល់ទេ។ ថ្វីបើលោកមីសត៉ាយ៉ាងណាក៏ដោយ ក៏សម្តេចប៉ាបបានបញ្ចូលប្រទេសនេះ ទៅនៅក្រោមការត្រួតត្រារបស់អភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា។ នៅឆ្នាំ ១៨៥២ លោកមីសបានចាត់លោកក័រឌីយេ (Cordier) និងលោកប៊ឺរេ (Beuret) ឲ្យទៅនៅកន្ទុយគោ នាត្រើយខាងជើងទន្លេសេកុងទល់មុខស្ទឹងត្រែង។ លោកអភិបាលព្រះសហគមន៍ផ្ទាល់ អញ្ជើញទៅទីនោះក្នុងឆ្នាំ ១៨៥៣ ដើម្បីប្រៀនប្រដៅគ្រីស្តបរិស័ទ។ លោកប៊ឺរេស្លាប់នៅទីនោះ ហើយលោកក័រឌីយេវិលត្រឡប់មកវិញ ព្រោះលោកមានជំងឺ។ ក្នុងឆ្នាំ ១៨៥៧ លោកអូសូឡឺ និងលោកស៊ីលវេស្ត្រទៅនៅស្ទឹងត្រែង ក៏ប៉ុន្តែលោកទាំងពីរមិនបាននៅជាប់ទេ ព្រោះមានជំងឺ។ ក្នុងឆ្នាំ ១៨៥៨ លោកបារ៉ូ និងលោកទ្រីយ៉ែរ (Trière) ទៅនៅស្ទឹងត្រែងវិញ តែលោកទ្រីយ៉ែរស្លាប់នៅទីនោះ ហើយលោកបារ៉ូក៏វិលត្រឡប់មកពញាឮវិញ ព្រោះលោកមានជំងឺដែរ។ លោកបានទទួលបន្ទុកជាបូជាចារ្យក្នុងភូមិពញាឮនោះ មុននឹងកសាងសហគមន៍មាត់ក្រសាស់។ នៅសម័យនោះ ភាគខាងត្បូងនៃប្រទេសលាវ គឺតំបន់ដែល

សាសនទូតតែងចេញចូលនោះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជាណាចក្រលាវ។ តំបន់នេះធ្លាក់មកនៅក្រោមការត្រួតត្រារបស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៩០៤ មក។

(១២)លិខិតជូនទៅលោកអូស៊ូហ្វ (M.Osouf, Archives MEP, Vol. 765, nº 151). លោកអូសូឡីបានទទួលបន្ទុក "ជានាយកក្រុមសាសនទូតប្រចាំប្រទេសកម្ពុជា" នៅក្នុងឆ្នាំ ១៨៦៩ ក្នុងពេលដែលលោកមីស ទទួលភារកិច្ច ជាអភិបាលព្រះសហគមន៍ប្រចាំដែនកូសាំងស៊ីន ជំនួសលោកឡឺហ្វែរ។ នៅឆ្នាំ ១៨៧៤ លោកក័រឌីយេ ទទួលតំណែងជាអភិបាលព្រះសហគមន៍ប្រចាំដែនកូសាំងស៊ីនជំនួសលោកមីស។ ហើយនៅឆ្នាំ ១៨៨២ លោកទទួលបន្ទុកជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា។

(១៣)លោកកុម (Cambes) ជាបូជាចារ្យទទួលបន្ទុកសហគមន៍គ្រីស្តបរិស័ទនៅបាណាម។ លោកបានតែងតាំងសហគមន៍ជាច្រើន មានក្រុមគ្រីស្តបរិស័ទព្រែកក្របៅ ជាភាសាវៀតណាមថា "Vinh Phuoc" ក្នុងឆ្នាំ ១៨៧៧ ក្រុមគ្រីស្តបរិស័ទស្វាយរៀង "តាហោ" ក្នុងឆ្នាំ ១៨៧៨ តាឡុកក្នុងឆ្នាំ ១៨៧៩ ត្រពាំងភ្លោះ (Vinh Loi) ក្នុងឆ្នាំ ១៨៨០ កំពង់ត្របែក ឆ្នាំ ១៨៨២ និងក្រុមគ្រីស្តបរិស័ទអានញ៉ុន ឆ្នាំ ១៨៨៣។ លោកមីសនែរ (Misner) ដែលជាបូជាចារ្យទទួលបន្ទុកក្រុមគ្រីស្តបរិស័ទជ្រោយចង្វារ បានបង្កើតក្រុមគ្រីស្តបរិស័ទពីរនៅក្នុងខេត្តបាត់ដំបង គឺក្រុមគ្រីស្តបរិស័ទអង្គង់សរ "តាអំ" ក្នុងឆ្នាំ ១៨៨១ និងខ្សាច់ពោយក្នុងឆ្នាំ ១៨៨២។ ក្នុងឆ្នាំ ១៨៨០ លោកឡាសា បង្កើតក្រុមគ្រីស្តបរិស័ទផ្លូវត្រី (Hô Tru) វាលធំ បារ៉ែន ព្រែកពោធិ នាត្រើយទន្លេមេគង្គខាងត្បូងភ្នំពេញ។ នៅឆ្នាំ ១៨៨១ លោកបានបង្កើតក្រុមគ្រីស្ត បឹងកាជោត (Thanh Mau) ។ ពីឆ្នាំ ១៨៨២ ដល់ឆ្នាំ ១៨៨៤ លោកបានបង្កើតក្រុមគ្រីស្តបរិស័ទ ប៊ូកៃ កំពង់ចាម ពាយជីលាំង កាហេ (ជីហែ) ឆ្លូង ក្រចេះ នៅតាមដងទន្លេមេគង្គខាងជើងក្រុងភ្នំពេញ។

(១៤)សេចក្តីរាយការណ៍ឆ្នាំ ១៨៥០។

(១៥)ក្នុងឆ្នាំ ១៨៧០ មានគ្រីស្តបរិស័ទ ៨.០០០ នាក់ នៅដែនកូសាំងស៊ីន និង ២.៨០០ នាក់នៅប្រទេសកម្ពុជា ហើយច្រើនតែវៀតណាម។

(១៦)កំណត់ប្រចាំថ្ងៃរបស់លោកឡាសា (Jouranl du P.Lazard, cité en Rollin, op. Cit,. I, p. 65)

(១៧)ក្នុងគ្រាបះបោរឆ្នាំ (១៨៨៥-១៨៨៧) ជនជាតិខ្មែរប្រដាប់អាវុធ ៣០០ នាក់ បានវាយប្រហារពួកគ្រីស្តបរិស័ទវៀតណាមនៅបាណាម។ រដ្ឋអំណាចបារាំងបានប្រគល់កាំភ្លើង ២៥ ដើម ឲ្យគ្រីស្តវៀតណាមទាំងនោះ វាយរុញច្រានពួកបះបោរខ្មែរវិញ។ ចំណែកក្រុមគ្រីស្តបរិស័ទពាមជរវិញ ពួកគេមានកាំភ្លើង ២០ ដើម សម្រាប់ការពារខ្លួន។ ការវាយច្បាំងគ្នាដូច្នេះ បានធ្វើឲ្យខ្មែរចងគំនុំនឹងពួកវៀតណាម និងគ្រីស្តបរិស័ទកាន់តែខ្លាំងឡើងថែមទៀត។

(១៨)ស្ថិតិនៅឆ្នាំ ១៩៧០។ ក្នុងសម័យមុនៗ គ្មានធ្វើស្ថិតិឲ្យបានច្បាស់លាស់ទេ។

(១៩)ក្នុងឆ្នាំ ១៨៩៥ លោកប្រូដោម (Prodhomme) បង្កើតក្រុមគ្រីស្តបរិស័ទនៅកញ្ជរ ក្នុងខេត្ត ពោធិសាត់។ ក្នុងឆ្នាំ ១៨៩៧ លោកប៊ូសូ (Bousseau) បង្កើតក្រុមគ្រីស្តបរិស័ទបឹងក្រាញ់ នៅជិតកញ្ជរ។ លោក ប៉ូលម៉ារតាំង (Paul Martin) បានរៀបចំក្រុមគ្រីស្តបរិស័ទ ត្រើយទន្លេមេគង្គឡើងវិញ គឺក្រុមគ្រីស្តបរិស័ទដែលលោកឡាសាបានបង្កើត ហើយដែលពួកបះបោរបានបំផ្លាញចោលនាឆ្នាំ ១៨៨៥ គឺនៅជ្រោយក្របៅ និងព្រែកអញ្ចាញ (Ba Vua) ក្នុងឆ្នាំ ១៩០១ ពាមផ្កាយម្រេច ក្នុងឆ្នាំ ១៩០៥ ព្រែកកាហេក្នុងឆ្នាំ ១៩០៦ និងក្រុមគ្រីស្តបរិស័ទពាមជីកង នៅឆ្នាំ ១៩០៨។ នៅឆ្នាំ ១៩០០ លោកអរវ៉ីយើ (Arvieu) តែងតាំងក្រុមគ្រីស្តបរិស័ទកំពង់ត្របែកឡើងវិញ ហើយនៅឆ្នាំ ១៩០៦ លោកបង្កើតក្រុមគ្រីស្តបរិស័ទ ប្រឡាយមាសនៅមាត់ច្រាំងទន្លេសាប។ តាមពិតក្នុងអំឡុងឆ្នាំ ១៩០០-១៩៣០ មានសង់ព្រះវិហារនៅគ្រប់ទីរួមខេត្ត (កំពង់ស្ពឺ កំពង់ឆ្នាំង សៀមរាប កំពង់ធំ កំពង់ចាម ព្រៃវែង តាកែវ) ដោយមិនទាំងមានគ្រីស្តបរិស័ទផង។

(២០)ជាពាក្យវៀតណាមដែលមានន័យថា "ជីទូត"។ ពួកវៀតណាមហៅអស់លោកសាសនទូតជាទម្លាប់ថា "អុងកូ! អុងកូ!" ។

# ជំពូកទី ៨

# ព្រះសហគមន៍សម្រាប់ប្រទេសកម្ពុជា

លោកឡាសា (Lazard) ជាសាសនទូតប្រចាំប្រទេសកម្ពុជាតាំងពីឆ្នាំ ១៨៧៨។ លោកបានបង្កើតសហគមន៍គ្រីស្តបរិស័ទវៀតណាមច្រើនជាងគេ។ នៅឆ្នាំ ១៩០២ លោកសរសេរលិខិតមួយទៅជូនអស់លោកនាយកទេវវិទ្យាល័យ នៅក្រុងប៉ារីស។ ក្នុងចំណោមសាសនទូត ១១ នាក់ ដែលនៅប្រទេសកម្ពុជា នៅសម័យនោះ មានសាសនទូត ៩នាក់ បានចុះហត្ថលេខានៅខាងក្រោមលិខិតនោះ។ សាសនទូតម្នាក់ ព្រមចុះហត្ថលេខាដែរ តែមិនយល់ស្របនៅគ្រប់ជំពូកទេ មានតែសាសនទូតម្នាក់គត់ ដែលមិនព្រមចុះហត្ថលេខា។ ក្នុងលិខិតនោះ អស់លោកសាសនទូតសុំផ្តាច់ខេត្តពីរនៃដែនកូសាំងស៊ីន ចេញពីបន្ទុកអភិបាលព្រះសហគមន៍ប្រចាំក្រុងប្រទេសកម្ពុជា គឺខេត្តពីរដែលសម្តេចប៉ាបបានបញ្ចូលមកក្នុងព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា កាលពីឆ្នាំ ១៨៦៩។ អស់លោកសាសនទូតយល់ឃើញថា សេចក្តីសម្រេចរបស់សម្តេច ដូចជា "*សំបុត្រមរណភាពសម្រាប់ជនជាតិខ្មែរដ៏អភ័ព្វ គឺទាំងព្រះជាម្ចាស់ ទាំងមនុស្ស រួមគ្នាប្រឆាំងនឹងជនជាតិខ្មែរ...*"។ សាសនទូតទាំងនោះយល់ឃើញច្បាស់ថា ចំនួនគ្រីស្តបរិស័ទវៀតណាមដ៏ច្រើនសន្ធឹកនៅក្នុងព្រះសហគមន៍ នាំឲ្យមានការលំបាកក្នុងការប្រកាសដំណឹងល្អដល់ជនជាតិខ្មែរ។ កាលពីដើមសាសនទូតទាំងអស់ដែលមកដល់ប្រទេសកម្ពុជា ត្រូវតែរៀនភាសាខ្មែរជាដាច់ខាត តែឥឡូវនេះ ភាសាខ្មែរនៅត្រឹមជា "*ជាមុខវិជ្ជារៀនបន្ថែមតាមក្រោយ*" ទៅវិញ។ អស់លោកដែលចុះហត្ថលេខាក្នុងលិខិតនោះ តវ៉ាទៀតថា ពេលនេះសហគមន៍គ្រីស្តបរិស័ទខ្មែរបានក្លាយជា "*ភាគតូចមួយរបស់ព្រះសហគមន៍គ្រីស្តបរិស័ទវៀតណាម*" តែប៉ុណ្ណោះ [១]។

**មានគ្រីស្តបរិស័ទខ្មែរនៅប្រទេសកម្ពុជានៅឡើយ**

ក្នុងសម័យអាណានិគមបារាំង បុគ្គលិកព្រះសហគមន៍ភាគច្រើនបានជួយណែនាំជនជាតិវៀតណាម ប៉ុន្តែ មានសាសនទូតជាច្រើននៅតែមានចិត្តជាប់ជំពាក់នឹងប្រជាពលរដ្ឋខ្មែរ ហើយនិងវប្បធម៌ខ្មែរដែរ។ ទោះបីគ្រីស្តបរិស័ទខ្មែរមានចំនួនតិចយ៉ាងណាក៏ដោយ ក៏នៅក្នុងព្រះសហគមន៍ប្រទេសកម្ពុជាតែងតែមានជនជាតិខ្មែរជានិច្ច។

នៅឆ្នាំ ១៨៦៦ លោកហេស្រេត (Hestret) សរសេរថា មានគ្រីស្តបរិស័ទខ្មែរបួនប្រាំនាក់នៅឯកំពត។ នៅក្នុងសេចក្តីរាយការណ៍ប្រចាំឆ្នាំ ១៨៨២ មានកត់ថា នៅខេត្តតាកែវមានខ្មែរប្រាំគ្រួសារ "*គ្រួសារចុះឈ្មោះចង់ទទួលការអប់រំខាងគ្រីស្តសាសនា* "។ លោកយ៉ូលី (Joly) ដែលជាអ្នកធ្វើសេចក្តីរាយការណ៍ នោះសរសេរថា៖ "*នៅពេលឥឡូវនេះ មានយុវជនខ្មែរពីរនាក់អាយុប្រហែលម្ភៃឆ្នាំ ស្នាក់នៅផ្ទះខ្ញុំ*"។ *ម្នាក់រៀនធម៌ឆាប់ចេះណាស់ ហើយក៏ចាប់ផ្តើមយល់គោលសំខាន់ៗ នៃទ្រឹស្តីគ្រីស្តសាសនា* "(២)។ នៅដែនកូសាំងស៊ីន លោកឌែរវ៉ាល់ (Derval) រាយការណ៍អំពីគ្រួសារខ្មែរជាច្រើន នៅក្នុងភូមិភាគមាត់ជ្រូកសុំចូលគ្រីស្តសាសនា៖ "*ខ្មែរ ៥២ នាក់ បានទទួលពិធីជ្រមុជទឹករួចហើយ*"។ ក៏ប៉ុន្តែ នៅក្នុងសេចក្តីរាយការណ៍ឆ្នាំ ១៨៨២ ដដែលនោះ លោកដូចជាចាត់ទុកគ្រីស្តបរិស័ទខ្មែរនៅដែនកូសាំងស៊ីន ទាំងនោះជាជនជាតិភាគតិច។ ចំពោះជនជាតិខ្មែរទាំងនោះគួរតែ "*ឲ្យមានសាសនទូតចល័តខ្លះ សម្រាប់ណែនាំនិងថែរក្សាពួកគេ ដើម្បីបង្កើតក្រុមគ្រីស្តបរិស័ទតូចៗ ដែលនិយាយភាសាផ្សេងៗគ្នា* "។

ធម្មតា ជនជាតិខ្មែរចូលគ្រីស្តសាសនាម្នាក់ម្តងៗ ឬមួយគ្រួសារម្តងៗ មិនដែលមានជនជាតិខ្មែរច្រើនចូលគ្រីស្តសាសនា នៅពេលជាមួយគ្នាទេ ហើយពេលនោះក៏គ្មានព្រះសហគមន៍សម្រាប់ទទួល និងណែនាំពួកគេដែរ។ ជាហេតុបណ្តាលឲ្យអ្នកទើបនឹងចូលគ្រីស្តសាសនាថ្មីៗ ពុំអាចនឹងកាន់ជំនឿឲ្យស្ថិតស្ថេរគង់ វង្សយូរអង្វែងបានឡើយ។ នៅឆ្នាំ ១៨៩២ លោកសាសនទូតអ៊ីយ៉ុង (Hion) រស់នៅក្នុងខេត្តអង្គរ ជាខេត្តដែលស្ថិតនៅក្រោមការត្រួតត្រារបស់សៀម បានអញ្ជើញទៅមើលភូមិពាមសីម៉ា ស្ថិតនៅត្រង់ពាមព្រែកសង្កែ។ លោកបង្កើតសហគមន៍តូចមួយនៅអន្លង់សរ "តាអំ" ដែលមានសុទ្ធតែគ្រីស្តបរិស័ទខ្មែរ៖

*«ក្នុងពេលនេះ មានគ្រួសារខ្មែរ ៣០ គ្រួសារ ។ ក្មេងៗចេះអានទៅហើយ*

*ចំណែកមនុស្សធំវិញ បានរៀនចេះសូត្រធម៌ ហើយនិងចេះគោលសំខាន់ៗ នៃជំនឿគ្រីស្តសាសនាស្ទើរតែទាំងអស់»។*

ប៉ុន្តែ នៅឆ្នាំ ១៨៩៣ ពេលប្រទេសបារាំងប្រុងប្រៀបច្បាំងនឹងប្រទេសសៀម ដើម្បីដណ្តើមយកខេត្តអង្គររបស់ខ្មែរ ដែលសៀមកាន់កាប់នោះមកវិញ ពួកសៀមបាបានកៀបសង្កត់គ្រីស្តបរិស័ទខ្មែរ ដោយគេនឹកថា គ្រីស្តបរិស័ទទាំងនោះ ចូលដៃចូលជើងជាមួយនឹងអាណានិគមបារាំង ព្រោះបូជាចារ្យសុទ្ធតែជនជាតិបារាំងទាំងអស់។ លោកអ៊ីយ៉ុង សរសេរពីបញ្ហារនេះថា៖

*«មានគ្រួសារថ្មីចំនួន ១៦ គ្រួសារ បានសុំចូលគ្រីស្តសាសនា ហើយចំនួនអ្នកកំពុងទទួលការអប់រំចូលគ្រីស្តសាសនាមានមិនតិចជាង ១៤០ នាក់ឡើយ។ តែពីរបីអាទិត្យមុននេះ គ្រាន់តែគេឃើញពួកសៀមសង់បន្ទាយមនុស្សទាំងភូមិភិតភ័យច្រួលច្របល់ជាខ្លាំង ហើយមានប្រជាជនចំនួន ១៣ គ្រួសាររត់ចេញទៅដោយស្ងាត់ៗ។ ខ្ញុំត្រូវចាត់វិធានការទប់ទល់ ដើម្បីខាររខាំងកុំឲ្យអ្នកឯទៀតៗរត់»* [៣]។

លោកប៊ូសសូ (Bousseau) ជាបូជាចារ្យណែនាំក្រុមគ្រីស្តបរិស័ទកញ្ជរ ធ្វើសេចក្តីរាយការណ៍ អំពីព្រះសង្ឃមួយអង្គមានព្រះជន្ម ២៥ ព្រះវស្សា។ លោករស់នៅក្នុងវត្តតាំងពីអាយុ ៧ ឆ្នាំលោកមានពុទ្ធដីកាថា ក្នុងបីយប់តៗគ្នា លោកយល់សប្តិឃើញ គេមកប្រាប់លោកឲ្យទៅរកបូជាចារ្យកាតូលិកម្នាក់ ចាក់ទឹកពីកូនដបតូចមួយស្រោចឲ្យលោក។ ព្រះសង្ឃនេះបានធ្វើដំណើរអស់រយៈពេលបីអាទិត្យទើបមកដល់ភ្នំពេញ ហើយក៏បានជួបនឹងលោកប៊ូសសូ។ លោកមានពុទ្ធដីកាអំពីរឿងរបស់លោក ជូនលោកប៊ូសសូ ហើយក៏ចាប់រៀនធម៌ ព្រមទាំងរៀនគោលសំខាន់ៗនៃជំនឿសាសនាផង។

*«លោករៀនដោយយកចិត្តទុកដាក់។ នៅក្នុងចំណោមអ្នកដែលកំពុងទទួលការអប់រំខាងជំនឿ សូម្បីតែអ្នកប្រុងប្រៀបខ្លួនទទួលបុណ្យជ្រមុជទឹកនិងអ្នកដែលមានប្រាជ្ញាជាងគេក៏ដោយ គេពុំសូវប្រទះឃើញអ្នក ដែលខិតខំសង្វាតដូចលោកឡើយ។ ក៏ប៉ុន្តែ ការយល់សប្តិបែបនេះ ដំណើរស្វែងរកដូច្នេះ ការកែប្រែចិត្តគំនិតនេះ ហាក់ដូចជាប្លែកអស្ចារ្យពេក ទាំងសាសនទូត ទាំងគ្រីស្តបរិស័ទ ក៏មានការសង្ស័យដែរ។ ហេតុនេះហើយទើបលោកប៊ូសសូយល់ថាគួរធ្វើពិសោធន៍លចិត្តបុរសក្មេងនេះមើល។ លោកបានធ្វើពិសោធន៍លចិត្តលោកនោះជាច្រើនលើកច្រើនសារ តែបុរសនោះទ្រាំទ្របានដោយអត់ធ្មត់។*

*អស់អ្នកស្រុកដែលធ្លាប់ស្គាល់លោកតាំងពីមុនមក មកថ្វាយបង្គំលោក ហើយអង្វរលោកសុំឲ្យត្រឡប់ទៅកុដវិញ។ ព្រះសង្ឃជាច្រើនដែលធ្លាប់រៀនសូត្រជាមួយលោកកាលពីមុនតែងប្រមាថលោក និងមានខ្លះកំហែងគំរាមលោក។ លោកស្តាប់ដោយខន្តី និងមិនជជែកតវ៉ាអ្វីទាំងអស់ លោកគ្រាន់តែឆ្លើយថា៖ "ឥឡូវនេះ ខ្ញុំជាគ្រីស្តបរិស័ទ ខ្ញុំចង់កាន់គ្រីស្តសាសនារហូតដល់ពេលស្លាប់ សូមអញ្ជើញធ្វើតាមខ្ញុំទៅ »* ⁽៤⁾។

**«ភូមិពុនង» ឬការទាមទារសេរីភាព**

ក្នុងឆ្នាំ ១៨៩៨ លោកឡាសាបានបង្កើតក្រុមគ្រីស្តបរិស័ទ "ព្នង" នៅភូមិក្តុល ត្រើយខាងកើតទន្លេមេគង្គ ខាងត្បូងក្រូចឆ្មារ។ លោកសរសេរថា៖

> *«ប្រជាពលរដ្ឋទាំងនោះ មានប្រាំពីរសញ្ជាតិផ្សេងពីគ្នា រួមគ្នាបង្កើតជាក្រុមគ្រីស្ត បរិស័ទមួយ។ ក្នុងនោះមានជនជាតិលាវ ជនជាតិអ៊ីណាន់ដែលមកពីក្រុងហ្វេ ជនជាតិស្ទៀង ជនជាតិខាស ជនជាតិរ៉ាដេស ជនជាតិខ្មែរ និងជនជាតិចាម។ សាសន៍ទាំងនោះ និយាយភាសារៀងៗខ្លួន តែនាំគ្នាសូត្រធម៌ជាភាសាខ្មែរ»* ⁽៥⁾។

ក្នុងចំណោមអ្នកទាំងនោះ ភាគច្រើនជាអតីតទាសកររបស់ពួកជ្វា ដែលជា "*មហាចោរកែជួញមនុស្ស*" ហើយរបស់ចៅកែខ្មែរនិងចិនដែរ។ ចៅកែទាំងនោះ តែងនាំគ្នាចេញប្លន់ចាប់មនុស្សដែលរស់នៅ តាមជួរភ្នំអាណ្ណាម។ លោកឡាសាទាស់ចិត្តជាខ្លាំងនឹងជំនួញមនុស្សបែបនេះ។ ទោះបីមានរដ្ឋការ បារាំងមកនៅត្រួតត្រាប្រទេសកម្ពុជា ហើយក៏ដោយ ក៏នៅតែមានអ្នកធ្វើជំនួញបែបនេះដែរ។ លោកតែងតែស្តីបន្ទោសយ៉ាងខ្លាំងអំពីរឿងនេះដល់មន្ត្រីបារាំងដែលប្រចាំការនៅប្រទេសលាវ ក្នុងពេលមន្ត្រីនេះយកកប៉ាល់មកចតនៅ មុខព្រះវិហារភូមិក្តុលនោះ។

មន្ត្រីនោះ នាំពាក្យតវ៉ារបស់លោក និងពាក្យតវ៉ារបស់អ្នកដទៃទៀត បញ្ជូនទៅលោកប៉ូលឌូមែរ (Paul Doumer) ដែលជាទេសាភិបាលនៅព្រៃនគរ។ ពាកយតវ៉ាទាំងនោះ បានលទ្ធផលល្អ គឺនៅឆ្នាំ ១៨៩៧ លោកទេសាភិបាលបានប្រកាសក្រិត្យច្បាប់មួយចែងថា "*ទាសករទាំងអស់ ដែលត្រូវគេលួចចាប់មកក្តី គេ លក់ក្តី ត្រូវមានសេរីភាពឡើងវិញ*" ។ លោកឡាសាបានធ្វើសេចក្តីរាយការណ៍ថា ៖

*«ពេលចាប់ជនអភ័ព្វទាំងនោះ ពួកឈ្មួញបានបំបែកពួកគេឲ្យចេញពីគ្រួសាររបស់ខ្លួន។ ពួកគេរស់នៅជិតៗភូមិក្តុលនេះ។ ខ្ញុំបានប្រាប់អ្នកទាំងនោះថា ពួកគេមានសេរីភាពហើយ។ តែពួកគេពុំព្រមជឿខ្ញុំទេ។ ពីរបីថ្ងៃក្រោយមក មានពួកគេគ្មានសម្លៀកបំពាក់ កាយស្ទើរតែអាក្រាត ព្រោះម្ចាស់របស់គាត់បានដកហូតយកសម្លៀកបំពាក់អស់។ មុនដំបូង ខ្ញុំបានរកសម្លៀកបំពាក់មកគ្របដណ្តប់ខ្លួនប្រាណឲ្យគេ រួចខ្ញុំបានចែកចំណីអាហារឲ្យគេ និងផ្តល់គ្រឿងសម្ភារៈសម្រាប់ធ្វើកូនខ្ទមជ្រក។ ឥឡូវនេះ អ្នកទាំងនោះបង្កើតភូមិមួយ ពួកគេសប្បាយ និងរីករាយជាខ្លាំង ព្រោះមានសេរីភាពហើយ។ ខ្ញុំទៅមាត់ក្រសាស់អញ្ជើញគ្រូបង្រៀនម្នាក់ឈ្មោះគ្រូចាប ឲ្យមកបង្រៀនជនទាំងនោះនិងណែនាំពួកគេ ឲ្យទទួលពិធីជ្រមុជទឹកបាន»* [៦]។

នៅឆ្នាំ ១៨៩៨ លោកអារីយើ (Arvieu) ធ្វើដំណើរទៅរកពួកកួយ ជាជនជាតិខ្មែរភាគតិច ដែលរស់នៅក្នុងតំបន់ស្ថិតនៅត្រង់ព្រំដែនខេត្តសៀមរាប និងខេត្តកំពង់ធំ។ ប៉ុន្តែ លោកវិលត្រឡប់មកវិញជាប្រញាប់ ព្រោះលោកមានជំងឺជាទម្ងន់។

**«សុបិនស្ថានសួគ៌» របស់ជនជាតិចាមនិងជនជាតិខ្មែរ**

នៅឆ្នាំ ១៩០៣ ចាមពីរនាក់មករកលោកឡាសា ហើយពោលថា ខ្លួនមានបំណងទៅជាគ្រីស្តបរិស័ទ ពួកគេចង់ដូច្នេះ ព្រោះអ្នកទាំងពីរនាក់បានឮសូរសំឡេងមួយដែល "ជំរុញចិត្តរបស់គេ" ឲ្យទៅរកបូជាចារ្យ ខាងគ្រីស្តសាសនា និងឲ្យធ្វើតាមសេចក្តីប្រៀនប្រដៅរបស់បូជាចារ្យនោះ។ ចាមម្នាក់ឈ្មោះម៉ាត់ពោលថា៖

*«ក្នុងអារម្មណ៍ខ្ញុំ ខ្ញុំឃើញដូចជាពន្លឺមួយ ហើយឮសំឡេងប្រាប់ថា ឲ្យខ្ញុំមករកលោក។ ខ្ញុំលង់លក់ទៅក្នុងសំឡេងអាថ៌កំបាំងនេះ អស់ពេញមួយថ្ងៃទើបបានដឹងខ្លួនធម្មតាឡើងវិញ»។*

លោកឡាសាមិនព្រមជឿរឿងនេះទេ។ លោកបានបញ្ចេញអាកប្បកិរិយាម៉ឺងម៉ាត់ដាក់ចាមទាំងពីរនាក់នោះ ក៏ប៉ុន្តែ អ្នកទាំងពីរចេះតែទទូចមករៀនអធិដ្ឋាន និងថ្វាយបង្គំព្រះជាម្ចាស់តាមរបៀបពួកគេ ដែលនាំឲ្យពួករៀតណាមឆ្ងល់ជាខ្លាំង។ លោកក៏

យល់ព្រមឲ្យចូលជាគ្រីស្គបរិស័ទ។ លោកចាត់ឲ្យគេទៅនាំគ្រួសាររបស់គេមក។ ដប់ប្រាំថ្ងៃក្រោយមក ចាមទាំងពីរនាក់បានត្រឡប់មកវិញ ថែមទាំងនាំគ្រួសារថ្មីពីរគ្រួសារមកជាមួយផង។ ពួកគេទាំងអស់គ្នា បានទៅតាំងទីលំនៅ នៅបឹងកាជោតក្នុងភូមិរបស់ពួកកាតូលិកវៀតណាម។ តែពួកគេពិបាករស់នៅក្នុងចំណោមពួកវៀតណាមណាស់ ព្រោះទំនៀមទម្លាប់និងរបៀបរស់នៅរបស់ជនជាតិទាំងពីរ ខុសគ្នាខ្លាំងពេក។ ដូច្នេះហើយបានជាក្នុងឆ្នាំ ១៩០៦ គ្រួសារចាមទាំងបួន ព្រមទាំងគ្រួសារខ្មែរពីរគ្រួសារទៀតដែលពួកចាមបាននាំមកនោះ នាំគ្នាទៅតាំងទីលំនៅឯស្ពឺ ជិតចម្ការអណ្តូង។ លោកឡាសាដាក់ឈ្មោះកន្លែងនោះថា "*ស្ថានសួគ៌*"។ ប៉ុន្តែ ដោយព្រះសហាគមន៍ពុំបានជួយណែនាំក្រុមគ្រីស្គបរិស័ទដ៏តូចនេះក៏រលាយសូន្យក្នុងអំឡុងបីបួនឆ្នាំក្រោយមក[៧]។

ប្រសិនបើយើងអានសេចក្តីរាយការណ៍ប្រចាំឆ្នាំរបស់ព្រះសហាគមន៍ យើងមុខជាភ្ញាក់ដោយសង្កេតឃើញថា ចំនួនគ្រីស្គបរិស័ទខ្មែរចេះតែកើនឡើងៗជាលំដាប់។ ឆ្នាំ ១៩០៣ លោកប៊ូស៊ុត (Bouchut) សរសេរអំពីលោកគូឌែ (Coudert) ដែលទើបនឹងទទួលមរណភាពទៅនោះថា៖ "*ក្នុងរយៈពេលកាល ១៤ ឆ្នាំ កន្លងមកនេះ លោកគូឌែរបានខិតខំដោយគ្មានសំចៃ ក្នុងការប្រកាសដំណឹងល្អចំពោះជនជាតិខ្មែរ តែការខំប្រឹងប្រែងនេះមិនបានលទ្ធផលច្រើនឡើយ។ លោកបានណែនាំ អ្នកចូលសាសនាថ្មី បានជាងមួយរយនាក់ប៉ុណ្ណោះ*"[៨]។ ក្នុងឆ្នាំ ១៩០៦ លោកដាល់ (Dalle) ធ្វើពិធីជ្រមុជទឹកឲ្យជនជាតិខ្មែរដែនកូសាំង ស៊ីនបាន ២៨ នាក់។ នៅឆ្នាំ ១៩១០ " *នៅព្រះវិហារធំក្រុងភ្នំពេញ លោកប៊ែរណា* (Bernard) *បានធ្វើបុណ្យជ្រមុជទឹកជូនមនុស្សធំ ៤៦ នាក់។ ដែលក្នុងចំណោមនោះមានខ្មែរ ៣២ នាក់*"។ លោកប៊ែរណា សរសេរថា៖ "*អ្នកចូលគ្រីស្គសាសនាទាំងនោះជាជាតិខ្មែរសុទ្ធ។ ទាំងថ្មី ទាំងចាស់ ឥឡូវនេះមានចំនួនលើស ១៥០ នាក់។ ពួកគេបានបង្កើតភូមិតូចមួយដែលនឹងចាក់ឫសបន្តិចម្តងៗជាមួយនឹងក្រុមគ្រីស្គបរិស័ទខ្មែរចាស់* "។ នៅឆ្នាំ ១៩១៤ លោកដាវីឌ (David) អប់រំព្នងនិងខ្មែរចំនួន ២០ គ្រួសារឲ្យទទួលបុណ្យជ្រមុជទឹក។

តាមពិតជនជាតិខ្មែរពិបាកចូលគ្រីស្គសាសនាមែន ព្រោះក្នុងសង្គមខ្មែរប្រជាពលរដ្ឋម្នាក់ៗខ្លាចខុសប្លែកពីអ្នកដ៏ទៃទៀត។ ជនជាតិខ្មែរទូទៅតែងចោទប្រកាន់គ្រីស្គបរិស័ទខ្មែរថាជា "ជនក្បត់ជាតិ"។ ដោយប្រើពាក្យ "សាសន៍" មានន័យថា "ជាតិ" ផងនិង "សាសនា" ផង។ ហេតុនេះអ្នកដែលកាន់ "សាសនា" ផ្សេងពីពុទ្ធសាសនាត្រូវចោទថាជាជនក្បត់ "សាសន៍" ខ្មែរដែរ។

នៅឆ្នាំ ១៩១៦ លោកដាវីឌរៀបរាប់អំពីគ្រីស្តបរិស័ទនៅឆ្លូងថា៖

*«ពេលមានបាតុកម្មមួយ ខ្មែរប្រាំគ្រួសារនាំគ្នារត់ចេញពីព្រះសហគមន៍ទៅបាត់។ ខ្ញុំពុំហ៊ានធ្វើពិធីជ្រមុជទឹកឲ្យអ្នកឯទៀតៗទេ ព្រោះខ្ញុំខ្លាចថា ក្រោយពីបានទទួលពិធីនេះរួច អ្នកទាំងនោះរត់ទៅទៀត។ ចាប់ពីពេលនេះតទៅ ឮខ្ញុំត្រូវបង្ខំឲ្យជនជាតិខ្មែរ ដែលសុំចូលគ្រីស្តសាសនា តទៅទៀតឲ្យរៀនសូត្រយូរជាងជនជាតិដទៃ ដើម្បីលចិត្តគេមើល»*(១០)។

ប៉ុន្តែ នៅឆ្នាំ ១៩១៧ លោកដាវីឌបានធ្វើពិធីជ្រមុជទឹកឲ្យជនជាតិខ្មែរនៅឆ្លូង ចំនួន ៥៨ នាក់ ដែលហ៊ានទប់ទល់នឹងពាក្យរិះគន់ពីសំណាក់ជនរួមជាតិរបស់ខ្លួននោះ។ ក្នុងឆ្នាំដដែលនោះ នៅភ្នំពេញ លោកប៉ែរណោបានធ្វើពិធីជ្រមុជទឹកឲ្យខ្មែរ ៣៥ នាក់ ក្នុងឆ្នាំ ១៩២៩ នៅបាតដំបង លោកហ្គាតឺលេ (Gatelet) បានបង្កើតក្រុមគ្រីស្តបរិស័ទថ្មីមួយក្រុមមាន ៣០ គ្រួសារខ្មែរ។ ពួកគេទើបរត់មកពីដែនកូសាំងស៊ីនថ្មី (១១)។

នៅឆ្នាំ ១៩៣៣ លោកអារម៉ង់(Armange) តាំងទីលំនៅឯមង្គលបុរី។ លោកទទួលបន្ទុកក្រុមគ្រីស្តបរិស័ទវៀតណាម នៅជិតនោះនិងក្រុមគ្រីស្តបរិស័ទភូមិចំណោម ដែលកើតឡើងនៅឆ្នាំ ១៩១០ គឺមានគ្រីស្តបរិស័ទចំនួន ១៧៧ នាក់ ក្នុងនោះមានខ្មែរ ១១៦ នាក់ដែរ។ លោកទិញស្រែនៅខ្នាចរមាស ដើម្បីឲ្យគ្រីស្តបរិស័ទខ្មែរ ៥០ នាក់ មកពីចំណោមតាំងទីលំនៅ។ លោកមានការលំបាកច្រើន ព្រោះអ្នកស្រុកដែល បញ្ចាំស្រែឲ្យលោក ចេះតែរករឿងនិងធ្វើបាបលោក រហូតដល់បង្ខំលោកឲ្យចាកចោលភូមិភាគនោះទៅទៀត(១២)។

**ភូមិពាមខ្ញែរ**

មានជនជាតិវៀតណាមមួយក្រុមរស់នៅភូមិកល់មេឃនៅតាមដងស្ទឹងសែន ចម្ងាយដប់ប្រាំគ.ម. ប៉ែកឦសានទីរួមខេត្តកំពង់ធំ។ ពួកនោះជាពួកអ្នកធ្លាប់ជាប់ទោស ហើយរត់គេចពីអាជ្ញាធរវៀតណាម និងពីរដ្ឋអំណាចបារាំង បាននាំគ្នាមកតាំងទីនៅ នៅកណ្តាលព្រៃប្រហែលនៅក្នុងឆ្នាំ ១៨៧០ ។ ក្នុងចំណោមពួកនោះ មានអ្នកខ្លះជាគ្រីស្តបរិស័ទ។ ប្រមាណជាឆ្នាំ ១៩១០ លោកសិលាហ្គេសដុង (Pierre Guesdon) ទៅណែនាំពួកទាំងនោះ។ នៅឆ្នាំ ១៩១៦ លោកធ្វើពិធីជ្រមុជទឹកឲ្យយុវនារីខ្មែរម្នាក់ ឈ្មោះនាង ឈឿម អ៊ន

ដែល បានរៀបការជាមួយបុរសម្នាក់ឈ្មោះប៉ាល់។ ទោះបីនៅសម័យនោះ ពុំទាន់មានផ្លូវថ្នល់ក៏ដោយ ក៏ជនជាតិខ្មែរដែលរស់នៅក្នុងភូមិភាគនេះ ឧស្សាហ៍មកលេងផ្ទះលោកជាញឹកញាយ ព្រោះស្ទឹងសែនជាផ្លូវសម្រាប់ទៅមកយ៉ាងស្រួល(១៣)។ ជនជាតិខ្មែរទាំងនោះចេះតែបន្ទោសលោកថា៖ "*ម្ដេចក៏លោកមិនជួយខ្មែរផង?*" លោកបូជាចារ្យចាប់អារម្មណ៍នឹងពាក្យនេះ ហើយសម្រេចចិត្តនាំខ្មែរប្រាំគ្រួសារមកតាំងទីលំនៅក្នុងភូមិកំពង់គ ចម្ងាយ ១២ គ.ម. ប៉ែកខាងនិរតីទីរួមខេត្តកំពង់ធំ។ ពួកវៀតណាមបួនប្រាំគ្រួសារស្នឹងរានដីនៅកន្លែងនោះបានប្រហែលដប់ហិតា គឺនៅត្រង់ម្ដុំ"អូរលោវ" លើត្រើយស្ទឹងខាងជើង។ គ្រីស្ដបរិស័ទខ្មែរទើបនឹងមកដល់ថ្មីបានសង់ទីលំនៅត្រើយស្ទឹងខាងត្បូង នៅខាងក្រោមអូរលោវបន្តិច។ កន្លែងនោះសុទ្ធជាព្រៃឫស្សីបន្លា នៅរដូវប្រាំងមានថ្លុក ត្រពាំងជាច្រើន ហើយមានហ្វូងក្របីព្រៃ ខ្ទីង និងដំរី ព្រមទាំងអណ្តើក និងពស់ផង។ នៅរដូវវស្សាភូមិភាគទាំងមូលលិចបាត់ជាច្រើនម៉ែត្រទៅក្នុងទឹកលើកលែងតែទីទួលត្រើយស្ទឹងទាំងពីរចេញ។

នៅឆ្នាំ ១៩១៨ លោកហ្គេសដុងសុំដីមួយកន្លែងពីរដ្ឋការបារាំង។ នៅឆ្នាំ ១៩២១ រដ្ឋការបារាំងយល់ព្រមជូនលោកនូវដីចំនួនបីរយហិតា គឺដីថ្មី ដែលមិនទាន់មាននរណាធ្វើអាជីវកម្មនៅឡើយទេ។ សាសនទូតឯទៀតៗ និងលោកអភិបាលព្រះសហគមន៍ ចេះតែទូន្មានលោកកុំឲ្យទៅនៅកន្លែងនោះ។ បន្តិចម្ដងៗ បងប្អូនញាតិសន្តានរបស់គ្រួសារខ្មែរទាំងប្រាំគ្រួសារដែលបានមកនៅទីនោះតាំងពីដំបូង ក៏នាំគ្នាមកនៅទីនោះដែរ។ ពេលមានបុណ្យម្ដងៗ ពួកគេតែងទៅវត្ត។ លោកសិលាហ្គេសដុង តែងធ្វើដំណើរចេញពីភូមិនេះជាញឹកញយ ព្រោះលោកមានភារកិច្ចណែនាំក្រុមគ្រីស្ដបរិស័ទផ្សេងៗ ជាច្រើនទៀត ដូចជានៅកល់មេឃ កំពង់ធំ និងសៀមរាប។ ដោយលោកមិនសូវបាននៅជាប់ដូច្នេះ លោកក៏នាំគ្រួសារគ្រីស្ដបរិស័ទមួយពីភ្នំពេញ ឲ្យមកនៅទីនោះ គឺគ្រួសារលោកគ្រូជប់។ រាល់ល្ងាចអ្នកភូមិតែងមកស្ដាប់លោកគ្រូវពន្យល់ និងសាកសួរគាត់អំពីគ្រីស្ដសាសនា។ គាត់បើកសាលារៀនមួយតូច ដើម្បីបង្រៀនអក្សរខ្មែរបង្រៀនធម៌ និងចម្រៀងគ្រីស្ដសាសនាដល់ពួកក្មេងៗទាំងនោះដែរ។ ពេលត្រឡប់ទៅផ្ទះវិញ ក្មេងៗក៏បង្រៀនសេចក្ដីទាំងអស់ ឲ្យឪពុកម្ដាយរបស់គេតទៅទៀត។ ប៉ុន្មានឆ្នាំក្រោយមក អ្នកភូមិទាំងនោះ ក៏សុំចូលជាគ្រីស្ដបរិស័ទ។ នៅឆ្នាំ ១៩៣៤ លោកហ្គេសដុងអញ្ជើញលោកអភិបាលព្រះសហគមន៍ អ៊ែរហ្គុត (Hergtt) ឲ្យមកធ្វើពិធីជ្រមុជទឹកឲ្យ តែលោក

អភិបាលមិនព្រមអញ្ជើញមកទេ ព្រោះលោកពុំជឿថា ជនជាតិខ្មែរអាចចូលគ្រីស្តសាសនាឡើយ។ ដូច្នេះលោកហ្គេដុង និងលោកដាវីឌ ដែលមានភារកិច្ចណែនាំថែរក្សាគ្រីស្តបរិស័ទនៅឯឆ្លូងនោះ ក៏ធ្វើពិធីជ្រមុជទឹកឲ្យមនុស្សធំចំនួន ១០៥ នាក់ រួចមកបានធ្វើពិធីជ្រមុជទឹកឲ្យយុវជន និងយុវនារី ហើយនៅទីបំផុតធ្វើឲ្យកុមារាកុមារី។ គ្រីស្តបរិស័ទកំពង់គនេះ ត្រឡប់ទៅជាគ្រីស្តបរិស័ទដែលមានចំនួនច្រើនជាងគេ ក្នុងចំណោមគ្រីស្តបរិស័ទខ្មែរទាំងអស់នៅប្រទេសកម្ពុជា ។

### សាសនទូតយកចិត្តទុកដាក់នឹងភាសាខ្មែរ

សាសនទូតជាច្រើនបានយកចិត្តទុកដាក់ចំពោះភាសា និងវប្បធម៌ខ្មែរជាច្រើនជាជាងនាំជនជាតិខ្មែរចូលគ្រីស្តសាសនា។ កាលពីមុន នាចុងសតវត្សទី ១៨ លោកឡឺវ៉ាវ៉ាសសឺរ (Levavasser) បានតែង "*វចនានុក្រមខ្មែរ-ឡាតាំង* "។ នៅឆ្នាំ ១៨៧៤ លោកអែម៉ូនីញេ (Aymonier) ដែលជាសាស្ត្រាចារ្យ បង្រៀនភាសាខ្មែរនៅអនុវិទ្យាល័យសម្រាប់អ្នករដ្ឋការបារាំងបានបោះពុម្ពផ្សាយវចនានុក្រមបារាំង-ខ្មែរមួយទៀត។ ក្រៅពីលោកម៉ូរ៉ា (Mourra) លោកហ្សូណូ (G.Jeanneau) លោកប៉ានណឺជេ (A.Pannetier) លោកហ្ស៊កម៉ាស្ពេរ៉ូ (Georges Maspéro) ដែលជាអ្នកបច្ចេកទេសខាងអក្សរសាស្ត្រខ្មែរ (១៤) មានសាសនទូតបីរូបទៀត ដែលមានកេរ្តិ៍ឈ្មោះនៅក្នុងការស្រាវជ្រាវនិរុត្តិវិទ្យាខ្មែរ គឺលោកហ្គេសដុង លោកប៉ែរណា និងលោកតង់ដា។

### លោកម៉ារីយ៉ូសែបហ្គេសដុង ( Marie Joseph Guesdon )

លោក ម៉ារីយ៉ូសែប ហ្គេសដុង (១៥) កើតនៅឆ្នាំ ១៨៥២ នៅប៉ាល់លុយអូ ជិតលុយសុង (Palluau Luçon)។ លោកចូលទេវវិទ្យានៅក្រុងប៉ារីសឆ្នាំ ១៨៧២។ ពីរឆ្នាំក្រោយមក លោកចុះកប៉ាល់ទៅប្រទេសកម្ពុជា។ ក្នុងអំឡុងបីឆ្នាំ លោកទទួលបន្ទុកណែនាំក្រុមគ្រីស្តបរិស័ទនៅដាវនឿក (Dau Nuoc) នាដែនកូសាំងស៊ីន រួចមកនៅឆ្នាំ ១៨៧៩ លោកធ្វើជាសាស្ត្រាចារ្យក្នុងទេវវិទ្យាល័យនៅគូឡាវយៀង (Culao Gieng) ។

លោកជាបុគ្គលប្លែកពីគេ ព្រោះលោកលែងបំពេញមុខងារជាបូជាចារ្យ ដើម្បីចូលទៅនៅក្នុងវត្តព្រះពុទ្ធសាសនា។ លោកខិតខំស្រាវជ្រាវពិនិត្យ និងអានឯកសារភាសារខ្មែរទាំងអស់ ដែលលោកអាចរកបាន។ បន្ទាប់មក លោកបានវិលត្រឡប់មក

ប្រទេសបារាំងវិញ ហើយក៏ទទួលមរណភាព នៅឯទីក្រុងប៉ារីស នាថ្ងៃ ទី ៣១ តុលា ឆ្នាំ ១៩៣៤ ។

ទស្សនាវដ្ដីអន់ត្រូប៉ូស (Anthropos)[១៦] សរសេរអំពីលោកថា៖ "*ពុំមានអ្នកប្រាជ្ញជាតិអឺរ៉ុបណាម្នាក់ អាចប្រៀបផ្ទឹមនឹងលោកបានឡើយ នៅឯប្រទេសខ្មែរក៏គ្មាន ហើយនៅទ្វីបអឺរ៉ុបយើងក៏គ្មានដែរ* " ។ លោកបានបន្សល់ទុកនូវស្នាដៃជាច្រើន ជាពិសេសវចនានុក្រម "*សៀវភៅបារាំង-ខ្មែរ* " "*វចនានុក្រម-ខ្មែរ* " មានពីរក្បាល "*វចនានុក្រមបារាំង-ខ្មែរ-បាលី* " ហើយនៅទីបញ្ចប់ "*សង្ខេបវចនានុក្រមខ្មែរ* "[១៧]។ វចនានុក្រមទាំងនោះ មានពាក្យច្រើនណាស់ គឺបង្ហាញឲ្យដឹងថា លោកហ្គេសដុង (Guesdon) ស្គាល់វប្បធម៌ខ្មែរច្បាស់លាស់ជាទីបំផុត។ វចនានុក្រមទាំងនេះ មិនគ្រាន់តែមានពាក្យច្រើនសន្ធឹកប៉ុណ្ណោះទេ គឺមានសេចក្ដីអធិប្បាយយ៉ាងក្បោះក្បាយ ចំពោះពាក្យនីមួយៗ ជាពាក្យសាមញ្ញធម្មតា ជាពាក្យស្លោក ឬជាឃ្លាផ្សេងៗ ដកស្រង់ចេញពីសៀវភៅជាច្រើន ដែលលោកបានអានពេលលោកនៅរត្ត មកបញ្ជាក់ថែមទៀតផង។ តែអក្ខរាវិរុទ្ធប្លែកពីសម័យឥឡូវ ព្រោះក្នុងសម័យនោះ ភាសាខ្មែរមិនទាន់មានការឯកភាពគ្នានៅឡើយ។ ជួនកាលលោកពន្យល់ពាក្យខ្លះទៅតាមន័យសម័យនោះ។ ទោះបីជាវចនានុក្រមទាំងនោះបង្ហាញនូវចំណេះដ៏ខ្ពង់ខ្ពស់របស់លោកក៏ដោយ ក៏អ្នកឯកទេសភាសាខ្មែរនៅសម័យនោះ បានរិះគន់លោកយ៉ាងខ្លាំង។ អ្នកទាំងនោះចោទកំហុសរបស់លោក ដោយយករឿងសីលធម៌មកធ្វើជាលេស ជាជាងគិតពីរឿងវិទ្យាសាស្ត្រ។

លោកហ្គេសដុង បានបោះពុម្ពផ្សាយសៀវភៅចំនួន ៣៧ ច្បាប់ផ្សេងៗទៀត គឺមានសៀវភៅរឿងព្រេង សៀវភៅអប់រំ សៀវភៅខាងព្រះពុទ្ធសាសនា។ ក្នុងចំណោមស្នាដៃរបស់លោកទាំងនោះ មានរឿង "*ព្រះវេស្សន្តរ* " រឿង "*ពិលាបសោកស្ដាយរបស់ព្រះកន្សែសារពេជ្រ* " ពាក្យ "*សម្រាំង ៦០០ សុភាសិត* " "*សេចក្ដីអត្ថាធិប្បាយគម្ពីរ ៥០កណ្ឌ* "។ លោកបានបង្កើតពុម្ពចល័តអក្សរខ្មែរ ដើម្បីបោះពុម្ពសៀវភៅទាំងនោះ។ លោកមិនគ្រាន់តែមានចំណេះវិជ្ជាខាងអក្សរសាស្ត្រប៉ុណ្ណោះទេ គឺលោកបានគូរផែនទីខេត្តពាមជរ ខេត្តលឹកដុក (Luc Doc) និងខេត្តក្រៀនស្វាយថែមទៀតផង។ លោកធ្វើផែនដីទាំងនោះ តាមសំណូមពរ របស់លោកអគ្គទេសាភិបាលបារាំង។

ក្នុងឋានៈជាបូជាចារ្យ លោកហ្គេសដុងបានសរសេរសៀវភៅ ស្ដីអំពីគ្រីស្ដសាសនា

មួយចំនួន៖ "*ព្រះគម្ពីរដំណឹងល្អ*" ជាសៀវភៅអត្ថបទសម្រាំងសម្រាប់សូត្រថ្ងៃអាទិត្យ និង សៀវភៅ "*ផ្កាត្រៃ*" គឺជាធម៌ទេសនាមួយចំនួន។ នៅឆ្នាំ ១៩០៩ លោកបានបោះពុម្ព សៀវភៅមួយ ដែលមានចំណងជើងថា "*ទេសនាប្រាំបី*" គឺជាសៀវភៅពន្យល់ពីគោល ជំនឿសំខាន់ៗនៃគ្រីស្តសាសនា និពន្ធដោយលោកអាឡិចសង់ឌឺរ៉ូដ ហើយដែលលោក ឡង់ហ្សឺន័របានបកប្រែជាភាសាខ្មែរ។ លោកក៏បានបោះពុម្ពសៀវភៅមួយទៀត ក្រោម ចំណងជើងថា "*សំបុត្រព្រះបណ្ដាំ*" ពន្យល់អំពីគោលជំនឿសំខាន់ៗនៃគ្រីស្តសាសនា ឲ្យកាន់តែស្រួលយល់ ព្រមទាំងកូនសៀវភៅមួយ ដែលមានកត់ធម៌សម្រាប់សូត្រ ទាំងព្រឹក ទាំងល្ងាច។

**លោក យ៉ូហាន-បាទីស្ត ប៊ែរណា** ( Jean Baptish Bernard )

លោក យ៉ូហាន-បាទីស្ត ប៊ែរណា ប្អូនលោកហ្គេសដុង ១៤ ឆ្នាំ។ លោកកើតនៅឃុំ ឡឺពុយខេត្តអូតល័រ (Le Puy, Haute-Loire) នៅឆ្នាំ ១៨៨៧ លោកបានចូលទេវវិទ្យាល័យ នៅក្រុងប៉ារីស។ លោកបានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ ១៨៩២ ហើយបានទៅណែនាំ ក្រុមគ្រីស្តបរិស័ទនៅខេត្តបាត់ដំបង។ ក្នុងឆ្នាំ ១៨៩៤ លោកអញ្ជើញទៅពាមសេម៉ា ជាមួយនឹងលោកអ៊ីយ៉ុង (Hion) ។ នៅឆ្នាំ ១៨៩៦ លោកសង់ព្រះវិហារបាត់ដំបង រួច ក្នុងឆ្នាំបន្ទាប់មក លោកសាងព្រះវិហារភ្នំពេញ ក្នុងភូមិ "ព្រះមាតា" (Hoaland)។ នៅឆ្នាំ ១៩២៨ អស់លោកបូជាចារ្យជ្រើសរើសលោក ឲ្យធ្វើជាភូឈួយលោកអភិបាល អ៊ែរកុត (Hergott) ។ ការជ្រើសរើសនេះ បង្ហាញឲ្យឃើញថា សាសនទូតឯទៀតៗ ទុកចិត្តលោក។ លោកទទួលមរណភាពនៅភ្នំពេញ នៅថ្ងៃទី ៣០ មេសា ឆ្នាំ ១៩៣៩ ។

លោក ប៊ែរណា ជាប់នាមនៅក្នុងប្រវត្តិសាសនា នៅប្រទេសកម្ពុជា។ លោកជា អ្នកការពារជនជតិខ្មែរ យ៉ាងស្វិតស្វាញ និងជាអ្នកនិពន្ធ "*វចនានុក្រមខ្មែរ-បារាំង*" ដំបូងបង្អស់ មាន ៤៣២ ទំព័រ ។ វចនានុក្រមនេះ ចេញពីរោងពុម្ពហុងកុងក្នុងឆ្នាំ ១៩០២ គឺចេញមុនវចនានុក្រមរបស់លោកហ្គេសដុងពីរឆ្នាំ។ វចនានុក្រមនេះ ប្រើអក្សរឡាតាំង តែសរសេរដោយដៃ។ លោកបានរៀបពាក្យខ្មែរតាមលំដាប់អក្សរឡាតាំង។ លោក ប៊ែរណាបង្កើតវចនានុក្រមនេះសម្រាប់ឲ្យជនជាតិអឺរ៉ុប ដែលទាក់ទងជាមួយខ្មែររាល់ថ្ងៃ ប្រើប្រាស់ប៉ុណ្ណោះ គឺជាវចនានុក្រមដែលមានច្រើនតែពាក្យធម្មតា ជួនកាលក៏មានពាក្យ

គ្រាមភាសាដែរ។ ពាក្យទាំងនេះ បង្ហាញឲ្យឃើញថា លោកប៉ែរណា ស្និទ្ធស្នាលជាមួយនឹងប្រជាជនសាមញ្ញអស់ពេលជាយូរអង្វែង។ លោកបានសរសេរអារម្ភយ៉ាងវែងចំនួន ៤៥ ទំព័រ ដាក់នៅខាងដើមវចនានុក្រមរបស់លោក អធិប្បាយអំពីអក្សរនិងវេយ្យាករណ៍ខ្មែរ។

**លោក សាំងឌុល យ៉ូសែប តង់ដា** ( Sindulphe Josehp Tandart )

លោក សាំងឌុល យ៉ូសែប តង់ដា កើតនៅឃុំអូសសុង ខេត្តអារដែន (Aussonce), Ardennes) ក្នុងឆ្នាំ ១៨៧៧។ ក្រោយពីបានរៀនសូត្រនៅទេវវិទ្យាល័យនៅក្រុងប៉ារីស លោកអញ្ជើញមកប្រទេសកម្ពុជា នាថ្ងៃទី ១ សីហា ឆ្នាំ ១៩០០ ។ លោកមានភារកិច្ចណែនាំសហគមន៍គ្រីស្តបរិស័ទនៅបាត់ដំបង។ នៅទីនោះ លោករៀនភាសាខ្មែរជាមួយលោក យ៉ូហាន-បាទីស្ត ប៉ែរណា ដែលបានមកដល់ប្រទេសខ្មែរតាំងពី ១៣ ឆ្នាំមុននោះ។ លោកតង់ដាបានបង្កើតក្រុមគ្រីស្តបរិស័ទខ្មែរថ្មីពីរ នៅគង់រៀន និងនៅភូមិថ្មី ហើយលោក "*មានបំណងបង្កើតក្រុមគ្រីស្តបរិស័ទជាច្រើនថែមទៀតផង*" ដូចមានសរសេរក្នុងសេចក្តីរាយការណ៍ក្នុងឆ្នាំ ១៩០២ ស្រាប់។ នៅឆ្នាំ ១៩០៥ លោកមកនៅភ្នំពេញ។ ក្នុងឆ្នាំ ១៩១០ លោកបោះពុម្ពផ្សាយ "*វចនានុក្រមបារាំង-ខ្មែរ*" មួយមាន ២២៤៤ ទំព័រ ហើយចែកចេញជាពីរភាគ។ វចនានុក្រមនោះ បោះពុម្ពនៅហុងកុង។ តែនៅឆ្នាំ ១៩១៤ លោកត្រឡប់ទៅប្រទេសបារាំងវិញ ព្រោះជាប់កំណែនធ្វើទាហាន។ នៅឆ្នាំ ១៩១៩ កាលសង្គ្រាមចប់សព្វគ្រប់ហើយ លោកសុំលាលែងមុខតំណែងជាបូជាចារ្យ ហើយចាប់តែងសៀវភៅឡើងវិញ។

អ្នកសរសេរអារម្ភកថាវចនានុក្រមរបស់លោក ចាត់លោកទុកជា "*អ្នកធ្វើការច្រើន* " ។ លោកតង់ដា បានកែសំណៅដើមរបស់លោកឡើងវិញទាំងអស់ ហើយដាក់ពាក្យពេចន៍ជាច្រើនបន្ថែមទៀត។ នៅក្នុងការព្រាងដំបូងរបស់លោក លោកបានប្រើអក្សរឡាតាំងតាមលំដាប់អក្សរអឺរ៉ុប ដូចលោក ប៉ែរណាដែរ។ តែក្រោយមក លោកកែឡើងវិញទាំងអស់ ដោយសរសេរអក្សរខ្មែរមួយជួរ និងអក្សរឡាតាំងមួយជួរ។

លោក តង់ដា ទទួលមរណភាពនៅក្រុងនីស (Nice, France) ក្នុងជន្មាយុ ៥៤ ឆ្នាំ ។ លោក យ៉ូហាន បាទីស្ត ប៉ែរណា ដែលជាប្រិយមិត្តរបស់លោកសម្រេចចិត្តបោះពុម្ពផ្សាយ

វចនានុក្រម ដែលលោកតង់ ដា បានសរសេរនោះ។ នៅឆ្នាំ ១៩៣៣ គេបោះពុម្ពផ្សាយ "*វចនានុក្រមខ្មែរ-បារាំ* " របស់លោកតង់ដាជាពីរក្បាលមាន ២៤៦៨ ទំព័រនៅក្រុងប៉ារីស។ សាលាបារាំងចុងបូព៌ា (Ecole Français d'Extrême Orient) សរសើរចំណេះវិជ្ជាដ៏ជ្រៅជ្រះរបស់អ្នកនិពន្ធវចនានុក្រមនោះ នៅក្នុងសារពត៌មានឥណ្ឌូចិន។ វចនានុក្រមនេះមានពាក្យច្រើនជាងវចនានុក្រមរបស់លោកហ្គេសដុង ក៏ប៉ុន្តែ ពុំមានពន្យល់ពាក្យទេ ឧទាហរណ៍មកសំអាងក៏គ្មានដែរ។ ទោះជាយ៉ាងណាក៏ដោយ "*វចនានុក្រមតង់ដា* " នេះ នៅតែមានតម្លៃដ៏លើសលប់សម្រាប់អ្នកឯកទេសខាងភាសាខ្មែរសម័យក្រោយ។

**ការបកប្រែព្រះគម្ពីរ**

អស់លោកអភិបាល ដែលជួបជុំគ្នាក្នុងមហាសន្និបាតក្រុងត្រែនតូ (Concile de Trente) ប្រឆាំងនឹង របៀបគ្រីស្តបរិស័ទប្រូតេស្តង់ ដែលបកស្រាយគម្ពីរទៅតាមការយល់ឃើញរបស់គេម្នាក់ៗ។ ដូច្នេះមហាសន្និបាតនោះ ដាក់លក្ខខ័ណ្ឌខ្លះសម្រាប់ឲ្យគ្រីស្តបរិស័ទអានព្រះគម្ពីរប៊ីប(១៨)។ សាសនទូតនិយមបង្រៀនធម៌ និងគោលធម៌សំខាន់ៗនៃគ្រីស្តសាសនាជាជាងបង្រៀនគម្ពីរហើយគ្រីស្តបរិស័ទ តែងស្តាប់អត្ថបទគម្ពីរ និងសេចក្តីអធិប្បាយក្នុងពេលថ្វាយអភិបូជា នៅថ្ងៃអាទិត្យប៉ុណ្ណោះ។ លោកហ្គេសដុងបានបកប្រែអត្ថបទសម្រាប់សូត្រជារៀងរាល់ថ្ងៃអាទិត្យ។

ក្នុងឆ្នាំ ១៩២៣ លោកគ្រូអារធួរ ល.ហាម៉ុន (Arthur L.Hammond) និងភរិយាដែលជាជនជាតិអាមេរិចកាំង និងជាសមាជិកក្រុមជំនុំផ្សាយដំណឹងល្អ អញ្ជើញមកពីព្រៃនគរហើយមកនៅភ្នំពេញ។ លោក ដាវីឌ វ.អេលីសុន (David W.Ellison) និងភរិយា ក៏អញ្ជើញទៅនៅបាត់ដំបង។ ក្រុមជំនុំប្រកាសដំណឹងល្អ បានប្រគល់ភារកិច្ចឲ្យលោកហាម៉ុន ប្រែព្រះគម្ពីរ និងឲ្យលោកអេលីសុនបើកសាលាបង្រៀនព្រះគម្ពីរប៊ីប ឲ្យបានឆាប់ៗ។ គ្រីស្តបរិស័ទកាតូលិកនៅបាត់ដំបងម្នាក់ បានជួយលោកហាម៉ុន ឲ្យបកប្រែគម្ពីរ។ គម្ពីរសម្ព័ន្ធមេត្រីថ្មីនោះចប់ក្នុងឆ្នាំ ១៩៣៤។ ក្នុងឆ្នាំ ១៩៤០ លោកក៏បកប្រែចប់គម្ពីរប៊ីបទាំងមូល។ បន្ទាប់មក នៅឆ្នាំ ១៩៥៤ សមាគមនអង់គ្លេស និងបរទេសរបស់ព្រះគម្ពីរប៊ីប (British and Foreign Bible Society) បានបោះពុម្ពផ្សាយគម្ពីរនេះ តាមទម្រង់ដូចសព្វថ្ងៃ គឺក្រោយពីគនណៈកម្មាធិការបកប្រែមួយ ដែលមានសមាជិកជាខ្មែរ និងជាអង់គ្លេស-អាមេរិចកាំងពិនិត្យឡើងវិញជាច្រើនលើកច្រើនសាមក។

ចំណែកលោកអេលីសុនវិញ លោកចាប់ផ្តើមបង្រៀននៅសាលាព្រះគម្ពីរប៊ីប នាក្រុងបាត់ដំបង តាំងពីឆ្នាំ ១៩២៥ ម៉្លេះ។ និស្សិតប្រាំនាក់បានមកចុះឈ្មោះរៀន ហើយនិស្សិតបួននាក់សិក្សាចប់ និងទទួល សញ្ញាប័ត្រ ទៅជាអ្នកគង្វាល គឺលោក ចៅ វ៉ូច លោក ទ្រី ហុក លោក នាក់ ហាម និងលោក សុក ឈួម។ ក៏ប៉ុន្តែ រដ្ឋបាលបារាំងមិនពេញចិត្តនឹងសាលារៀននេះទេ រករឿងចង់បិទសាលាចោល។ តែនាយកសាលា និងរដ្ឋការបារាំងបានជជែកសម្រុះសម្រួលគ្នា ហើយរឿងនេះក៏ស្ងប់ស្ងាត់ទៅ។ តែក្នុងឆ្នាំ ១៩៣០ គណៈការដាយ (Cao Dai) បានបង្កើតការរីករវ [១៩] ហើយព្រះរាជាទ្រង់ចេញព្រះរាជក្រិត្យមួយហាមមិនឲ្យមានសាសនាទាំងអស់ "*លើកលែងតែសាសនាជាតិពីរចេញ គឺពុទ្ធសាសនា និងសាសនាកាតូលិក* " ។ រាជការ ករឿងគ្រូគង្វាលខ្មែរ ហើយចាប់គ្រូគង្វាលម្នាក់ឃុំឃាំង។ ប៉ុន្តែក្រោយមក រឿងនេះក៏ស្ងប់ស្ងាត់ទៅ ហើយអស់លោកអ្នកប្រកាសដំណឹងល្អមានសិទ្ធទេសនាតទៀតបាន ព្រមទាំងបង្កើតសហគមន៍តូចៗជាច្រើនផង។ មានគ្រួសារខ្មែរពីរគ្រួសារ ដែលចូលក្រុមជំនុំប្រកាសដំណឹងល្អ បានសង់វិហារតូចមួយនៅក្បាលជ្រូ ចម្ងាយ ១០ គ.ម. ខាងជើងក្រចេះ។ អ្នកគង្វាលម្នាក់ទៀត បានបង្កើតក្រុមគ្រីស្តបរិស័ទតូចៗពីរបី នៅក្នុងភូមិភាគសៀមរាប។

អ្នកផ្សាយដំណឹងល្អទាំងនោះ ជាសមាជិកក្រុមអង់គ្លេស-អាមេរិចកាំង ដែលតែងតែបកស្រាយគម្ពីរ តាមរបៀបតឹងរឹងបន្តិច។ ពួកគេប្រកាន់ពុទ្ធសាសនា ជាហេតុបណ្តាលឲ្យជនជាតិខ្មែរ ដែលធ្លាប់យល់ច្រឡំ រឹតតែយល់ច្រឡំថែមទៀតថា គ្រីស្តសាសនាគ្មានការអត់ឱនចំពោះសាសនាដទៃទេ។

**ការប្រកាសដំណឹងល្អដល់ជនជាតិចិន**

នៅប្រទេសកម្ពុជាព្រះសហគមន៍ក៏យកចិត្តទុកដាក់ ចំពោះអាណិកជនចិនដែរ។ តាំងពីមុនសម័យអាណានិគមនម៉្លេះ អាណិកជនជាច្រើនបានចូលគ្រីស្តសាសនា។ ក៏ប៉ុន្តែ គ្រីស្តបរិស័ទចិនទាំងនោះរួមគ្នា ជាក្រុមតូចៗ ហើយរស់នៅដាច់ស្រយាលតែឯង។

ក្នុងឆ្នាំ ១៨៥០ នៅបាត់ដំបង ចិនប្រាំនាក់ទទួលបុណ្យជ្រមុជទឹក ហើយមានចិនកំពុងទទួលការអប់រំខាងគ្រីស្តសាសនាជាច្រើននាក់ទៀត។ នៅឆ្នាំ ១៨៦០ លោកហេស្រ្តេតជាបូជាចារ្យទទួលបន្ទុក ក្រុមគ្រីស្តបរិស័ទកំពត ធ្វើសេចក្តីរាយការណ៍ថា នៅក្នុងចំណោម

គ្រីស្តបរិស័ទចំនួន ២០០ នាក់ ដែលលោកគ្រប់គ្រងមានចិនបួនប្រាំនាក់។ ក្នុងឆ្នាំដដែលនេះ នៅកោះសូទិនជិតក្រុងកំពង់ចាម លោកបារ៉ូទាក់ទងជាមួយនឹងគ្រីស្តបរិស័ទចិនចំនួនពីប្រាំបីទៅដប់គ្រួសារ។ លោកគិតថា គួររៀនភាសាចិនទៀត។ ក្នុងឆ្នាំបន្ទាប់ៗមកទៀត ចិនដែលនៅកោះសូទិនទាំងនោះ បានមកនៅពញាឮ រួចក៏មកនៅភ្នំពេញ។

ក្នុងឆ្នាំ ១៨៦៣ លោកមីសកត់សម្គាល់ថា មានចិនចូលគ្រីស្តសាសនាជាច្រើន។ ក៏ប៉ុន្តែលោកអភិបាលមិនយល់ច្រឡំពីមូលហេតុ ដែលនាំឲ្យចិនទាំងនោះចង់ចូលឡើយ៖

*"នៅកំពតមានចិនជាច្រើន ដែលមករកសាសនាយើង។ យើងបានជួយពួកចិនមែន។ ការនេះ ធ្វើឲ្យចិនទាំងនោះមករកយើង។ ពួកចិនទាំងនោះយល់ថាពួកគេអាចពឹងពាក់លើយើងបាន៖ នៅពញាឮនេះ ក្រុមគ្រីស្តសាសនាយើងកើនចំនួនឡើងទ្វេមួយជាពីរ។ គួរឲ្យស្តាយណាស់ ព្រោះថាអ្នកចង់ចូលសាសនាថ្មីភាគច្រើនសុទ្ធតែរកប្រយោជន៍ផ្ទាល់ខ្លួន។ ពួកគេឃើញ អ្នកកាន់អំណាចចូលចិត្តនិងគោរពយើង គេឃើញកប៉ាល់បារាំងចេញចូលមកកន្លែងយើង និងបោះយុថ្កានៅមុខផ្ទះរបស់យើង។ ដូច្នេះ ពួកគេយល់ថា យើងជាអ្នកធំ ហើយចិត្តគំនិតរបស់គេនៅដដែលមិនប្រែប្រួលសោះ!។ ពេលគេជួបប្រទះការលំបាក ឬពេលកើតមានអសន្តិសុខ ពួកគេរត់មកជ្រកកោននឹងយើងគ្រប់គ្នា ដូចជាមករកទីជម្រកដ៏កក់ក្តៅ តែពួកគេទុកចិត្តតែមួយរយៈពេលដ៏ខ្លី ទម្រាប់សន្តិសុខកើតមានឡើងវិញ [២០]។*

ក្រោយមកទៀត គឺក្នុងឆ្នាំ ១៩០៤ មានធ្វើពិធីជ្រមុជទឹកឲ្យជនជាតិចិនមួយចំនួននៅព្រែកត្រែងខាងត្បូងភ្នំពេញព្រមទាំងនៅតាខ្មៅ។ លោកប៊ូស៊ុតធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំដូចតទៅ៖

*"មូលហេតុដែលទាក់ទាញពួកចិនស្លូតត្រង់ ឲ្យចូលគ្រីស្តសាសនាច្រើនជាងគេ គឺគេប្រាថ្នាគេច ឲ្យផុតពីភាពវឹកវរនៅក្នុងសមាគមចិននានា ហើយនិងចង់រកស៊ីដោយសុខក្សេមក្សាន្ត [២១] ។*

ចាប់តាំងពីឆ្នាំ ១៩០៤ មក លោកហ្គីសបេ (Guibé) ទទួលបន្ទុកមើលការខុសត្រូវលើគ្រីស្តបរិស័ទចិន នៅប្រទេសកម្ពុជា។ បន្ទាប់ពីបានរៀនភាសាចិននៅប្រទេសចិនមកក្នុងឆ្នាំ ១៩០៦ នៅជីហែ (ទល់មុខ កោះសូទិន) និងនៅផ្សារភ្នំពេញ។ លោកបានអប់រំចិន ១៤០ នាក់ដែលសុំចូលគ្រីស្តសាសនាក្នុងឆ្នាំ ១៩០៦ [២២]។

មុនសង្គ្រាមលោកលើកទី ១ គ្រីស្តបរិស័ទនៅប្រទេសកម្ពុជា មានចំនួនប្រហែល ៣៦.០០០ នាក់។ ក្នុងចំណោមនេះ ខ្មែរមានប្រហែល ៣.៥០០ នាក់ វៀតណាម ៣២.៥០០ នាក់ និងចិន ៥០០ នាក់ ហើយនិងមានសាសនទូតដប់បីនាក់ ព្រមទាំងបូជាចារ្យវៀតណាមដប់បីនាក់ដែរ ជាអ្នកទទួលបន្ទុកព្រះសហគមន៍នេះ (២៣) ។ នៅសម័យនោះ ប្រទេសកម្ពុជាមានប្រជាជនទាំងអស់ប្រហែល ៣ លាននាក់ប៉ុណ្ណោះ ។

ទោះបី គ្រីស្តសាសនមាននៅប្រទេសកម្ពុជាយូរយារណាស់មកហើយក៏ដោយ ហើយគ្រីស្តបរិស័ទខ្មែរក៏មានចំនួនច្រើនគួរសមដែរក៏ដោយ ក៏ជនជាតិខ្មែរទូទៅ មិនសូវស្គាល់គ្រីស្តសាសនាទេ។ គេហៅភូមិទាំងឡាយដែលគ្រីស្តបរិស័ទ ខ្មែររស់នៅថា "ភូមិបារាំង" និងហៅបូជាចារ្យទាំងឡាយថាជា "*លោកសង្ឃបារាំង* " ឬក៏ថា "*លោកសង្ឃរាជបារាំង* " លើកលែងតែក្នុងភូមិភាគបាត់ដំបងចេញ ព្រោះនៅទីនោះគេប្រើពាក្យ "ប៉ាទ្រី" (patri) (ជាពាក្យព័រទុយហ្គាល់តាំងពីយូរលង់មកហើយ) សម្រាប់ហៅបូជាចារ្យ។ កាលពីដើម គេហៅគ្រីស្តសាសនាថាជា "*សាសនាពួកបារាំង* " ទៅវិញ។ ដោយមានប្រជាជនវៀតណាមជាច្រើនចូលមករស់នៅក្នុងប្រទេសកម្ពុជា និងដោយជនជាតិបារាំងរបបអាណានិគមនិយមលើប្រទេសកម្ពុជា ជនជាតិខ្មែរតែងតែយល់ថា គ្រីស្តសាសនាជាសាសនាបរទេស។ តែទោះជាយ៉ាងណាក៏ដោយ ក៏សាសនទូតចាត់ចែង និងចាត់គ្រឹះព្រះសហគមន៍យ៉ាងមាំសម្រាប់អនាគតដែរ។

---

( ១ ) Archive MEP, Doc 96, Vol. 766.

( ២ ) Lettres communes, 1893, p. 24.

( ៣ ) Lettres communes, 1893, pp.192-193. នៅបាត់ដំបង ពួកសៀមមានឥរិយាបថផ្សេង៖" *កាលពីមុន លោកទេសាភិបាលថ្មី និងមន្ត្រីសៀមទាំងប៉ុន្មានរករឿងយើងជាខ្លាំង(...)។ ក៏ប៉ុន្តែ រដ្ឋអំណាចសៀមបានកោះហៅលោកទាំងនោះ ឲ្យទៅក្រុងបាងកក។ នៅទីនោះ អស់លោកពិតជាបានទទួលបញ្ជាឲ្យឃោគយល់ដល់យើងពុំខាន បានជាពេលមន្ត្រីជាន់ខ្ពស់ទាំងនោះត្រឡប់មកវិញ គេប្ដូរឥរិយាបថខុសពីមុន គឺគេមកសួរសុខទុក្ខយើង ហើយនិយាយថា៖ "មកទល់ពេលនេះ យើងមិនបានយល់ច្បាស់។ ដូច្នេះហើយ បានជាយើងមានធ្វើអំពើមិនគប្បីចំពោះលោក។ ឥឡូវនេះ យើងយល់ច្បាស់ហើយ។ ម្យ៉ាងទៀត បើអស់លោកត្រូវការអ្វីសូមប្រាប់មកយើងចុះ យើងនឹងរក*

*ជូនលោកពុំខានឡើយ* " ។ (សំបុត្ររួម ឆ្នាំ ១៨៩៥ ទំព័រ ២៣៥)។ មន្ត្រីសៀមបានជូរឥរិយាបថ ដូច្នេះ គឺមកពីគេខ្លាចប្រទេសបារាំងខឹងនឹងពួកមន្ត្រីសៀម ដែលធ្វើបាបអស់លោកសាសនទូត ហើយវាយយកប្រទេសគេតែម្តង។

(៤) Lettres communes, 1898, p. 183.

(៥) Joural du P. Lazard, cité par V. Rollin, op. Cit. I, pp.71-72. គេឲ្យឈ្មោះភូមិនោះថា "*ភូមិព្នង* " ជាឈ្មោះរបស់ក្រុមមនុស្សមួយក្រុមនៅលើជួរភ្នំអណ្ណាម។ ឈ្មោះនេះក្លាយទៅជាឈ្មោះសម្គាល់ពូជជនជាតិភាគតិចទាំងអស់ ដែលជនជាតិខ្មែរប្រើសំដៅអស់អ្នកនៅលើភ្នំទាំងអស់។ ជនជាតិខ្មែរច្រើនប្រើពាក្យនេះ ជាពាក្យបន្ទុះបង្អាប់គ្នា គឺមានន័យថា "*សាហាវព្រៃផ្សៃ* " ថែមទៀត ។

(៦) កំណត់ហេតុប្រចាំថ្ងៃរបស់លោកឡាសា។ ក្រុមគ្រីស្តសាសនានេះ នៅគង់វង្សរហូតមកដល់សព្វថ្ងៃ(ឆ្នាំ ១៩៩៧) ។

(៧) Joural du P. Lazard, cité par Rollin, op.cit. II, p.20.

(៨) Lettres communes, 1903. p.201.

(៩) Lettres communes, 1909. "*ក្រុមគ្រីស្តបរិស័ទចាស់* " គឺពួកគ្រីស្តបរិស័ទ "*ព្រះមាតា* " (Hoaland) ដែលជាកូនចៅរបស់ខ្មែរកាត់ព័រទុយហ្គាល់ ។

(១០) Lettres communes, 1916, p.317.

(១១) ក្រោមក គេហៅជនជាតិខ្មែរនៅដែនកូសាំងស៊ីនថា "*ខ្មែរកម្ពុជាក្រោម* " ។ ជនជាតិវៀតណាមបានលេបយកទឹកដីរបស់គេ និងធ្វើទុក្ខបុកម្នេញពួកគេយ៉ាងខ្លាំង ជាហេតុបណ្តាលឲ្យខ្មែរកម្ពុជាក្រោមជាច្រើនរត់គៀសខ្លួនមកជ្រកកោននៅប្រទេសកម្ពុជា ។

(១២) ការទិញដីធ្លីបង្កើតជាភូមិឲ្យគ្រីស្តបរិស័ទរស់នៅនោះ បណ្តាលឲ្យកើតរឿងរ៉ាវពុំចេះចប់ឡើយ ហើយបណ្តាលឲ្យជនជាតិខ្មែរកាន់តែឃ្លាតឆ្ងាយពីព្រះសហគមន៍ទៅទៀត។

(១៣) គេបានធ្វើផ្លូវជាតិលេខ ៦ នៅក្នុងអំឡុងឆ្នាំ ១៩៣០-១៩៣៥។ ហេតុនេះ នៅសម័យនោះ តាមផ្លូវទឹកគេជិះទូក ហើយតាមផ្លូវគោកវិញ គេជិះសេះ ឬរទេះគោ។ ដូច្នេះ កំពង់ធំ និងកល់មេឃ ដែលស្ថិតនៅតាមដងស្ទឹងសែនជាភូមិមានសកម្មភាពរស់រវើក។

(១៤) ក្នុងចំណោមស្នាដៃសំខាន់ៗ យើងអាចលើកយកមករាប់បាន លោក អែម៉ូនីញេ បានតែង "*វចនានុក្រមបារាំង-ខ្មែរ* " មាន ១៨៣ ទំព័រ ព្រៃនគរ ឆ្នាំ ១៨៧៤ និង "*វេយ្យាករណ៍ខ្មែរ* " មាន ៩២ ទំព័រ ព្រៃនគរ ឆ្នាំ ១៨៨៩។ លោកម្ញ៉ាតែង "*វចនានុក្រមបារាំង-ខ្មែរ និងខ្មែរ-បារាំង* " ប៉ារីស ឆ្នាំ ១៨៧៨។ គេសរសេរវចនានុក្រមទាំងនេះ ជាអក្សរឡាតាំង ដោយរៀបពាក្យតាមលំដាប់អក្សរបារាំង។ លោកហ្សាណូ (G.Jeanneau) បានបោះពុម្ពផ្សាយ "*វិធីសរសេរអក្សរខ្មែរ* " មាន ២៦៩ ទំព័រប៉ារីស ឆ្នាំ ១៨៩៨។ លោកហ្សកម៉ាស្ពេរ៉ូ បាននិពន្ធ "*វេយ្យាករណ៍ខ្មែរ* "

សរសេរដោយដៃ មាន ៤៨៧ ទំព័រ ប៉ារីស ឆ្នាំ ១៩១៥។ លោកប៉ាន់ណឺជេ (A.Pannetier) បានិពន្ធ "*សន្ទានុក្រមបារាំង-ខ្មែរ*" អាវីញ៉ុង (Avignon) ក្នុងឆ្នាំ ១៩០៧ ។

(១៥) កុំច្រឡំនឹងលោកសិលាហ្គេសដុង ដែលបានបង្កើតភូមិកំពង់គ ហើយដែលបានមកដល់ប្រទេសកម្ពុជាជិត ៤០ ឆ្នាំក្រោយលោក ។

(១៦) "*សន្ទានុក្រមបារាំង-ខ្មែរ*" មាន ៧៤០ ទំព័រ បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩០៤ "វចនានុក្រមបារាំង-ខ្មែរ " ពីរភាគមាន ១៩៨២ ទំព័រ បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៣០ និង "*វចនានុក្រមបារាំង-ខ្មែរ-បាលី*" មាន ២៣៧ ទំព័រ ។ "*សង្ខេបវចនានុក្រមខ្មែរ*" មាន ២៩៦ ទំព័រ ។

(១៨) នេះពុំមែនមានន័យថា អស់លោកសាសនទូតឥតជំពាក់ចិត្តនឹងព្រះគម្ពីរប៊ីបនោះឡើយ! ជារៀងរាល់ថ្ងៃ អស់លោកតែងសូត្រទំនុកតម្កើង និងអានអត្ថបទគម្ពីរតាមលំដាប់លំដោយ។ អស់លោកត្រូវអានផ្នែកមួយយ៉ាងវែងនៃព្រះគម្ពីរប៊ីបផងដែរ។ អស់លោកសាសនទូតតែងយកសៀវភៅខ្លះជាប់នឹងខ្លួន គឺព្រះគម្ពីរប៊ីប និងសៀវភៅស្តីអំពីទេវវិទ្យា សៀវភៅធម្មវិន័យសម្រាប់ប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត (Imitation de JésusChrist) ព្រមទាំងគោលធម៌សំខាន់ៗ។

(១៩) ក្នុងឆ្នាំ ១៩២៦ នៅព្រៃនគរ ពួកកៅដាយ (Cao Dai) បង្កើតគណៈចម្រុះមួយ ហើយគោរពទាំងព្រះគ្រីស្ត ព្រះពុទ្ធ យ៉ូហាន យ៉ាកុប រូស្សូ (Jean Jacques Rousseau) និងវិចទ័រអ៊ុយហ្គោ (Victor Hugo)។ ទីស្នាក់ការធំនៃគណៈនេះ ស្ថិតនៅតៃនិញខេត្តចូវដុក (Chaudoc) ។ គណៈកៅដាយមានសាខានយោបាយ និងយោធាដែលប្រឆាំងយ៉ាងសកម្មនឹងរដ្ឋអំណាចបារាំង។

អ្នកចង់ស្គាល់ប្រវត្តិព្រះសហគមន៍ដំណឹងល្អនៅប្រទេសកម្ពុជា សូមអាន «In Their Dwellings. A. History of forty years of Missions in Cambodia» បោះពុម្ពនៅប្រទេសកម្ពុជា (ឥតមានឈ្មោះអ្នកនិពន្ធ និងឥតមានថ្ងៃខែឆ្នាំទេ) ។

(២០) Lettres communes, 1863, p.24.

(២១) Lettres communes, 1904. ពួកចិនមានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយប្រទេសកម្ពុជា តាំងពីយូរលង់មកហើយ។ ក្រៅពីចិន ៣០០០ នាក់ ដែលបានមកដល់ប្រទេសកម្ពុជាជាមួយលោកម៉ាក់គួ (នៅចុងសតវត្សទី ១៧ ចិនឯទៀតៗជាច្រើន ក៏មកតាំងទីលំនៅក្នុងប្រទេសខ្មែរដែរ។ ក្នុងចំណោមអ្នកទាំងនោះ មានមួយចំនួនធំធ្វើស្រែចម្ការ ជាពិសេសដាំម្រេចនិងស្រូវ។ និងជនជាតិចិនភាគច្រើនប្រកបរបរធ្វើជំនួញ នៅតាមភូមិ និងក្រុងនានា។ ចិនមួយចំនួនធំមករស់នៅក្នុងប្រទេសកម្ពុជាក្រោយពីលោក ម៉ៅសេទុង ទទួលជ័យជំនះនាឆ្នាំ ១៩៤៩ ។

ក្នុងឆ្នាំ ១៩៧០ គ្រីស្តបរិស័ទមានសមាជិក ១០០ នាក់នៅបាត់ដំបង និងប្រហែល ៨៥០

នាក់នៅភ្នំពេញ។ អ្នកចង់សិក្សាអំពីសហាគមន៍ចិននៅប្រទេសកម្ពុជា សូមអាន Willian E. Willmott, "The Chrisese in Cambodia", Vancouver, 1967.

(២២) Lettres communes, 1893, pp.192-193.

(២៣) គ្រាន់តែខេត្តពីរនៅដែនកូសាំងស៊ីន គឺខេត្តហាទៀង និងខេត្តមាត់ជ្រូក មានមនុស្ស ដល់ទៅ ៥ លាននាក់ទៅហើយ។ នៅក្នុងចំនួននេះ មានគ្រីស្តបរិស័ទ ១០០.០០០ នាក់។ ខេត្តទាំង ពីរនោះនៅក្រោមការណែនាំរបស់អភិបាលព្រះសហាគមន៍ភ្នំពេញដែរ។

# ជំពូកទី ៩

# ព្រះសហគមន៍ក្នុងសម័យអាណានិគម

អាណានិគមបារាំងសន្តិភាពដល់ប្រទេសកម្ពុជាបានយូរអង្វែង។ នៅពេលនោះ ព្រះសហគមន៍ចាក់គ្រឹះយ៉ាងមាំនៅក្នុងស្រុក ស្របតាមរបៀបចាត់ចែងគ្រីស្តសាសនា នាសម័យនោះ ។

## បូជាចារ្យខ្មែរដើមដំបូង

នៅឆ្នាំ ១៦៥៩ សម្តេចប៉ាប ផ្តាំលោកអភិបាលព្រះសហគមន៍ថា ភារកិច្ចច្បងរបស់អស់លោក គឺអប់រំយុវជនឲ្យធ្វើជាបូជាចារ្យ។ អស់លោកអភិបាលព្រះសហគមន៍បានបង្កើត "វិទ្យាល័យ" តូចមួយនៅប្រទេសកម្ពុជា។ ប៉ុន្តែនៅឆ្នាំ ១៧៨២ គឺបីបួនឆ្នាំក្រោយពេលលោក ឡឺវ៉ាវ៉ាសសឺរ (Levavasseur) ទទួលមរណភាព កងទ័ពសៀមចូលវាយលុកប្រទេសកម្ពុជា ហើយកម្ទេចចោល "វិទ្យាល័យ" តូច ដែលលោកបានបង្កើតនោះ។ ក្នុងអំឡុងជិតមួយសតវត្ស ពុំមានឯកសារណាមួយរៀបរាប់អំពីការអប់រំបូជាចារ្យ នៅប្រទេសកម្ពុជាសោះ ហើយនៅសម័យនោះ ព្រះសហគមន៍នៅប្រទេសកម្ពុជាមិនទាន់មានបូជាចារ្យខ្មែរនៅឡើយទេ។ ក្នុងឆ្នាំ ១៨៧២ លោកអូសូឡឺ (Aussoliel) ដែលជានាយកក្រុមសាសនទូត បានបង្កើតទេវវិទ្យាល័យមួយ នៅកោះគូឡាវយៀង (Culao Giang) នាដែនកូសាំងស៊ីន។ នៅឆ្នាំ ១៨៧៣ មានសិស្សចំនួន ១០ នាក់ រៀននៅក្នុងទេវវិទ្យាល័យនេះ ឆ្នាំ ១៨៧៦ មានសិស្សចំនួន ៤១ នាក់។ ក្នុងឆ្នាំ ១៨៨៨ សិស្សជាតិ វៀតណាម ៣ នាក់ទទួលមុខងារជាបូជាចារ្យ។ ដោយជនជាតិវៀតណាមានចំនួនច្រើនជាងខ្មែរ នៅក្នុងព្រះសហគមន៍ប្រទេសកម្ពុជានោះ នៅក្នុងវិទ្យាល័យនេះមានសុទ្ធតែកូនសិស្សជាតិវៀតណាមទាំងអស់។ ដូច្នេះ យុវជនខ្មែរពុះអាចចូលទៅក្នុង ទេវវិទ្យាល័យនេះបានឡើយ ដូចលោកឡាសា បានសរសេរនៅឆ្នាំ ១៩០២ ថា៖

*«ខ្ញុំពុំអាចចាត់កូនខ្មែរឲ្យទៅសិក្សាក្នុងទេវវិទ្យាល័យ នាដែនកូសាំងស៊ីនបានឡើយ។ ខ្ញុំបានចាត់ឲ្យទៅម្ដង ជាពីរដងរួចមកហើយ តែឥតប្រយោជន៍ទេ ហើយនាំឲ្យអស់សង្ឃឹមប៉ុណ្ណោះ។ នៅពេលកូនខ្មែរទាំងនោះរស់នៅជាមួយកូនវៀតណាម កូនខ្មែរទាំងនោះពុំអាចរស់នៅទីនោះបានឡើយ។ គេបង្ខំឲ្យវាប្តូរសម្លៀកបំពាក់ និងប្តូរទម្លាប់ប្រពៃណីរបស់វាផង។ វាត្រូវនិយាយភាសាវៀតណាម ត្រូវរៀន ត្រូវសរសេរភាសាវៀតណាម ហើយត្រូវរស់នៅក្នុងចំណោមពូជសាសន៍ ដែលវាស្អប់ខ្ពើម និងដែលស្អប់វាថែមទៀតផង។ ដូចនេះ យើងពុំមានសង្ឃឹមថា ថ្ងៃណាមួយនឹងមាន អ្នកបន្តុកអប់រំគ្រីស្តសាសនា ឬមានបូជាចារ្យខ្មែរសោះឡើយ»*(១)។

នៅឆ្នាំ ១៩១២ លោកប៊ូស៊ុត (Bouchut) ដែលជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា ប្រហែលបានយល់ឃើញដូច្នេះដែរ បានជាលោកសម្រេចថា នឹងកសាងទេវវិទ្យាល័យនៅភ្នំពេញវិញ។ ក៏ប៉ុន្តែ សង្គ្រាមសកលលោកទីមួយ បណ្ដាលឲ្យលោកគ្មានប្រាក់កាស សង់ទេវវិទ្យាល័យនោះភ្លាមតាមបំណងទេ។ សិស្សចំនួន ២០ នាក់ ចូលរៀនលើកទីមួយ នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ ១៩១៧ តែសិស្សទាំងនោះ សុទ្ធតែជនជាតិវៀតណាមទាំងអស់។ ទេវវិទ្យាល័យនេះ មានសិស្សរៀនជាប់ជាប្រចាំបានប្រហែលម្ភៃឆ្នាំ នៅឆ្នាំ ១៩៣៩ គឺបីខែបន្ទាប់អំពីសង្គ្រាមសកលលោកទី ២ ផ្ទុះឡើង ទេវវិទ្យាល័យនេះត្រូវបិទទ្វារ ព្រោះខ្វះសាស្ត្រាចារ្យ។ សិស្សទាំងឡាយក៏ទៅបញ្ចប់ការសិក្សារបស់ខ្លួននៅឯទេវវិទ្យាល័យ នាក្រុងហាណូយ (Séminaire Saint Sulpice de Hanoï) ។

ពីឆ្នាំ ១៨៨៨ ដល់ឆ្នាំ ១៩៣៩ ទេវវិទ្យាល័យនៅប្រទេសកម្ពុជា អប់រំបូជាចារ្យបានចំនួន ១១៥ នាក់ សុទ្ធតែជាជនជាតិវៀតណាមទាំងអស់។ ក្នុងចំណោមបូជាចារ្យទាំងនោះ មានតែ ៣៤ នាក់ទេ ដែលមានដើមកំណើតនៅប្រទេសកម្ពុជា អ្នកឯទៀតមានដើមកំណើតនៅដែនកូសាំងស៊ីន ។

### បព្វជិតទទួលបន្ទុកអប់រំគ្រីស្តសាសនា

ព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា ពុំបានបង្កើតក្រុមបូជាចារ្យជាតិខ្មែរ ស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតត្រេនតូ (Concile de Trente) ដែលតម្រូវឲ្យបូជា

ចារ្យសិក្សាយូរអន្លាយពេក ព្រមទាំងតម្រូវបូជាចារ្យឲ្យបួសផង។ ដូច្នេះ លោកបូជាចារ្យជាច្រើនបានអប់រំ "*អ្នកណែនាំ*" ដើម្បីជួយអស់លោកក្នុងការបង្រៀនលទ្ធិគ្រីស្តសាសនា។ អ្នកទទួលបន្ទុកបង្រៀនទាំងនោះ រួមធ្វើការជាមួយនឹងចាស់ទុំ ដែលទទួលខុសត្រូវលើក្រុមគ្រីស្តបរិស័ទនានាផង។ សេចក្តីរាយការណ៍ឆ្នាំ ១៨៥០ បញ្ជាក់អំពីមុខងាររបស់ "*អ្នកណែនាំថ្នាក់ទីមួយ*" ដែលមានគ្នាចំនួន ១២ នាក់ដូចតទៅនេះ៖

> *«អ្នកណែនាំថ្នាក់ទីមួយ ជាយុវជនដែលទទួលការអប់រំឲ្យចេះជជែក ចេះវែកញែក ចេះពន្យល់ ហើយដែលអាចបង្ហាត់បង្រៀនពួកអ្នកចង់ចូលគ្រីស្តសាសនាបាន ព្រមទាំងក្មេងៗ និងគ្រីស្តបរិស័ទល្ងង់ផង។ អ្នកទាំងនោះ រស់នៅក្នុងបន្ទុករបស់ព្រះសហគមន៍ទាំងស្រុង ហើយចេញទៅធ្វើការគ្រប់ទិសទី គឺទៅទីណាដែលគេអាចធ្វើការបានផល»* (២) ។

"អ្នកណែនាំ" ទាំងនោះត្រូវទទួលការអប់រំនៅនឹងកន្លែង ដោយធ្វើការផងនិងសិក្សាផង ហើយគ្មានសិក្សាតាមលំដាប់ថ្នាក់ ឬតាមមុខសញ្ញាពិសេសអ្វីឡើយ។ ក្នុងឆ្នាំ១៩០៦ លោកពីយ៉ាណេ (Pianet) ដែលជាបូជាចារ្យទទួលបន្ទុកណែនាំក្រុមគ្រីស្តបរិស័ទបាណាមសម្រេចចិត្តថា នឹងបង្កើតសាលាសម្រាប់អ្នកបង្រៀន "*អ្នកណែនាំ*" នៅក្បែរព្រះវិហារបាណាម។ លោកដឹកនាំសាលានេះ រហូតដល់លោកទទួលមរណភាព នាឆ្នាំ ១៩១៥ ។ បន្ទាប់មកលោកប្លុកដេ (Blondet) ទទួលតំណែងបន្តអំពីលោក។

> *«គេតែងជ្រើសរើសអ្នកណែនាំទាំងនោះ ក្នុងចំណោមគ្រីស្តបរិស័ទជំទង់ៗ ចំណុះ ជើងព្រះវិហារទាំងឡាយ។ ព្រះសហគមន៍អប់រំអ្នកទាំងនោះ ក្នុងអំឡុងពីរឬបីឆ្នាំ មុននឹងឲ្យពួកគេធ្វើកិច្ចការសន្សាបម្រើព្រះសហគមន៍យ៉ាងតិចបីឆ្នាំ។ បន្ទាប់មក អ្នកណែនាំទាំងនោះមានសិទ្ធិត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញ ដើម្បីរៀបការប្រពន្ធឬក៏មានសិទ្ធិបំពេញការងាររបស់គេតទៅទៀត។ អ្នកណែនាំមិនគ្រាន់តែ ជាអ្នកស្រឡាញ់ព្រះជាម្ចាស់យ៉ាងស្មោះស្ម័គ្រប៉ុណ្ណោះទេ គឺអ្នកណែនាំទាំងនោះ ត្រូវនៅលីវ ហើយត្រូវប្រគល់ខ្លួនទាំងស្រុងចំពោះក្រុមគ្រីស្តបរិស័ទដែលផ្គត់ផ្គង់ខ្លួន។ តែអ្នកណែនាំភាគច្រើន ពុំអាចទ្រាំរស់បែបនេះយូរបានឡើយ សូម្បីតែក្នុងរវាងបីឆ្នាំក៏ពុំបានដែរ។ អ្នកណែនាំមួយចំនួន ច្រើនចាកចោលមុខតំណែងរបស់ខ្លួនក្នុងអំឡុងមួយឆ្នាំក្រោយ ឬមានខ្លះក្នុងពីរបីខែក៏មានដែរ»*(៣) ។

តាំងពីមានបង្កើតសាលាអប់រំ "អ្នកណែនាំ" មក មានគ្នា ១៣៧ នាក់ បានទទួលការអប់រំគ្រប់បីឆ្នាំ និងបម្រើក្រុមគ្រីស្តបរិស័ទគ្រប់ចំនួនបីឆ្នាំដែរ។ មានយុវជន ៥៤ នាក់ បានដកពាក្យសន្យារបស់ខ្លួនមុនពេលកំណត់។ ដោយមានគ្នាជាច្រើនបោះបង់ដូច្នេះ ទើបនៅឆ្នាំ ១៩៣២ លោកអ៊ែរកុត (Hergott) អភិបាលព្រះសហគមន៍ ក៏កែប្រែស្ថាប័ន "អ្នកណែនាំ" នេះ ឲ្យទៅជាក្រុមគ្រួសារបព្វជិតប្រចាំភូមិភាគ។ បព្វជិតទាំងនោះត្រូវធ្វើកិច្ចសន្យាជាប់ជាស្ថាពរក្នុងគ្រួសារ ដែលមានឈ្មោះថា "ក្រុមព្រះញាតិវង្ស" (Frères de la Sainte Famille)។ លោកអភិបាលព្រះសហគមន៍សរសេរគម្រោងការរបស់លោកជូនទៅសម្តេចប៉ាប មានសេចក្តីដូចតទៅ៖

> *«គ្រីស្តបរិស័ទ ដែលយើងចាត់ឲ្យរៀនគោលសំខាន់ៗនៃគ្រីស្តសាសនា សុទ្ធសឹងតែជាយុវជនទាំងអស់។ ដោយអ្នកណែនាំទាំងនោះ នៅក្មេងពេក ដូច្នេះប្រជាជនចាស់ៗ មិនសូវទុកចិត្តលើគេឡើយ។ សូម្បីតែពួកដែលចង់ចូលគ្រីស្តសាសនាជាច្រើន ក៏ដកខ្លួនថយដែរ ព្រោះគ្រូបង្ហាត់ពួកគេ នៅក្មេងពេក។ ប្រសិនបើអ្នកណែនាំទាំងនោះជាបព្វជិតវិញ គង់តែពួកគេមានឥទ្ធិពលអាចធ្វើឲ្យគ្រីស្តបរិស័ទចូលចិត្ត។ គេអាចទាក់ទាញអ្នកគ្មានជំនឿឲ្យចូលគ្រីស្តសាសនាបាន ព្រោះបព្វជិតនោះបានទទួលការអប់រំត្រឹមត្រូវ ពូកែនិយាយ មិនគិតតែប្រយោជន៍ផ្ទាល់ខ្លួន ហើយប្រព្រឹត្តិតែអំពើល្អ។ យើងស្វែងរកអ្នកជំនួយ ដ៏ប្រសើរបែបនេះ តាំងពីយូរឆ្នាំមកហើយ។ ឥឡូវនេះ យើងសង្ឃឹមថាអ្នកទាំងនោះ អាចជួយយើងក្នុងកិច្ចផ្សាយគ្រីស្តសាសនា ចំពោះអ្នកកាន់សាសនាដទៃបាន»*[៤]។

ក្នុងឆ្នាំ ១៩៣៩ លោកសាបាល់លីយេ (Chabllier) ជាអភិបាលព្រះសហគមន៍ថ្មី បានប្រគល់មុខងារ ដឹកនាំក្រុមគ្រួសារបព្វជិតនេះឲ្យលោកយ៉ូសែបវុលីយេ (Joseph Vulliez) គឺលោកដាក់ភារកិច្ចភារកិច្ច "*ត្រូវធ្វើឲ្យក្រុមគ្រួសារដែលទើបនឹងកើតឡើង មានលក្ខណៈស្របទៅតាមគោលដៅយ៉ាងសមរម្យ* " ដោយអប់រំពួកគេ ឲ្យមានការទាក់ទងជាមួយព្រះជាម្ចាស់យ៉ាងស្និទស្នាល និងឲ្យចេះវិជ្ជាផ្សេងៗទៀតជ្រៅជ្រះផង។

ក្នុងឆ្នាំ ១៩៤៣ អ្នកណែនាំដែលជាគ្រហស្ថបាត់អស់គ្មានសល់ ហើយមុខតំណែងណែនាំនេះ ត្រូវបព្វជិតរ៉ាប់រងជំនួសទាំងស្រុង។ បព្វជិតទាំងនោះជាជនជាតិវៀតណាមស្ទើរតែទាំងអស់។

**ក្រុមគ្រួសារបុត្រីព្រះនាងម៉ារី**

តាំងពីយូរមកហើយ ព្រះសហគមន៍តែងយកចិត្តទុកដាក់បង្កើតវិជ្ជាស្ថាន សម្រាប់ដូនជី។ ក្នុងឆ្នាំ ១៧៧២ លោកឡឺវ៉ាវ៉ាសឺរ (Levavasseur) បានបង្កើតសាខារបស់ក្រុមគ្រួសារ "នាងប្អូរផ្ដាច់នឹងឈើឆ្កាងព្រះយេស៊ូ" នៅឯភូមិប្រាំបីឆោម។ ក្រុមនាងទាំងនោះបានបង្រៀនក្មេងៗ និងពួកអ្នកសុំចូលគ្រីស្តសាសនា។ ក៏ប៉ុន្តែ បន្ទាប់ពីពួកសៀមចូលវាយលុកកម្ទេចភូមិចោលមក បព្វជិតាទាំងនោះរត់ចេញទៅបាត់ដំបង។ ដោយគ្មានបូជាចារ្យគាំទ្រហើយដោយគ្មាននរណាចូលក្រុមគ្រួសារនេះទៀត ក្រុមគ្រួសារនោះ ក៏រលត់រលាយបាត់ទៅ។

ប្រមាណជាឆ្នាំ ១៨៥០ លោកមីសបង្កើតក្រុមគ្រួសារ នាងប្អូរផ្ដាច់នឹងឈើឆ្កាងព្រះយេស៊ូ ក្នុងទម្រង់ជា "*សមាគមរបស់នាងព្រហ្មចារី ដែលស្ម័គ្រចិត្តរស់នៅរួមគ្នាដោយធ្វើកិច្ចសន្យាជារៀងរាល់ឆ្នាំ* " លោកចាត់យុវនារីបួននាក់ឲ្យទៅទទួលការអប់រំពីបព្វជិតានៅឯកែម៉ុង នាដែនកូសាំងស៊ីន ដើម្បីរៀបចំបង្កើតសមាគមនេះ រួចលោកកសាងអារាមដូនជីមួយនៅឯពញាឮ។ ក្នុងឆ្នាំ ១៨៥៩ កងទ័ពវៀតណាមធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទនៅដែនកូសាំងស៊ីន ហើយកម្ទេចអារាមដូនជីនៅគូឡាវយៀងចោល។ បព្វជិតាដែលបានរួចជីវិត ក៏មករស់នៅជាមួយនឹងយុវនារីទាំងបួននាក់ ដែលនៅឯពញាឮ។ ក្នុងឆ្នាំ ១៨៦៧ ពួកពោរកំបោដុតបំផ្លាញភូមិគ្រីស្តបរិស័ទ និងព្រះវិហារនៅពញាឮចោល ជាហេតុបណ្ដាលឲ្យដូនជីផ្លាស់អារាម មកនៅរួមជាមួយគ្រីស្តបរិស័ទវៀតណាម នៅឫស្សីកែវខាងជើងភ្នំពេញវិញ។ ក្នុងឆ្នាំ ១៩១០ ពួកបងស្រីទាំងឡាយកាន់កាប់គ្រឹះស្ថានសម្រាប់ថែរក្សាកូនកំព្រាមួយ ហើយនិងសាលាកុមារីរបស់គ្រីស្តបរិស័ទចំណុះជើងព្រះវិហារឫស្សីកែវព្រមទាំងសាលារៀនប្រាំទៀតក្នុងសហគមន៍គ្រីស្តបរិស័ទ តាមភូមិឯទៀតៗផង។

ពីឆ្នាំ ១៩១៥ ដល់ឆ្នាំ ១៩៤០ មានយុវនារីចំនួន ១១៥ នាក់ ស្ម័គ្រចិត្តធ្វើជាបព្វជិតា ក៏ប៉ុន្តែ បព្វជិតា ៧៥ នាក់ដកពាក្យសន្យានោះចេញ ហើយត្រឡប់ទៅរស់នៅជាគ្រីស្តបរិស័ទសាមញ្ញធម្មតាវិញ។ ដោយឃើញថាមានបព្វជិតាជាច្រើនបោះបង់ពាក្យសន្យាដូច្នេះ ក្នុងឆ្នាំ ១៩៤៣ លោកសាបាល់លីយេក៏កែប្រែសមាគមនោះឲ្យទៅជា "*ក្រុមគ្រួសារភូមិភាគកាតូលិក នៃបុត្រីព្រះនាងម៉ារី* " (Congrégation diocésaine des Filles de Marie)។ បព្វជិតាទាំងនោះ ត្រូវចុះកិច្ចសន្យាថាបួសជាប់រហូត [៥] ។

**ក្រុមគ្រួសារបងស្រីនៃព្រះឧបការគុណ**

ក្នុងឆ្នាំ ១៨៧៥ តាមសេចក្តីសុំរបស់លោកក័រឌីយេ (Cordier) ជានាយកក្រុមសាសនទូតប្រចាំប្រទេសកម្ពុជា នៅសម័យនោះ មានបព្វជិតាប្រាំមួយនាក់នៃក្រុមគ្រួសារ "*ព្រះឧបការគុណនៅព័រជើ*" (Providence de Portieux) បានមកដល់ប្រទេសកម្ពុជា (៦)។ បព្វជិតាទាំងនោះ ចុះនៅព្រៃនគរ ហើយធ្វើដំណើរឆ្ពោះទៅគូឡាវយៀង ដែលជាទីស្នាក់ការរបស់លោកអភិបាលព្រះសហគមន៍ប្រចាំភូមិភាគក្នុងគ្រានោះ។ ដូនជីទាំងនោះរៀនភាសាវៀតណាម។ ដូច្នេះហើយបានជាក្នុងពេលក្រោយ បព្វជិតាទាំងនោះ ធ្វើសកម្មភាពសម្រាប់ជនជាតិវៀតណាមតែប៉ុណ្ណោះ។

ក្រោយពេលមកដល់បានបន្តិច បងស្រីទាំងនោះបង្កើតកន្លែងថែរក្សាទារកមួយ នៅគូឡាវយៀង សម្រាប់ទទួលយកទារកដែលអ្នកស្រុកលះបង់ចោល។ ក្រោយមក ដូនជីក៏បង្កើតគ្រឹះស្ថានកូនកំព្រាមួយ មន្ទីរសម្រាលកូនមួយ សាលារៀនមួយ មន្ទីរសុខភាពមួយ មន្ទីរពេទ្យមួយ ព្រមទាំងគេហដ្ឋានធ្វើជាទីចាត់ការរបស់ខ្លួនផង។ បងស្រីទាំងនោះធ្វើដូច្នេះ ស្របទៅតាមការទូន្មានរបស់លោកយ៉ូហាន ម៉ារតាំងម៉ូយ (Jean Martin Moyë) ដែលបានបង្កើតក្រុមបព្វជិតាទាំងនោះ។ បួនឆ្នាំក្រោយមក បព្វជិតាទាំងនោះបង្កើតសាលាមួយ ដើម្បីអប់រំយុវនារីឲ្យធ្វើជាបព្វជិតាតទៅទៀត។ ពីឆ្នាំ ១៨៨០ ដល់ឆ្នាំ ១៩២៥ សាលានេះអប់រំបានដូនជីចំនួន ១៣៣ នាក់ សុទ្ធជាស្ត្រីវៀតណាមទាំងអស់ ។

ព្រះសហគមន៍នៅប្រទេសកម្ពុជា តែងទាក់ទងជាមួយជនជាតិវៀតណាមច្រើនជាងទាក់ទងជាមួយជនជាតិខ្មែរ។ ដូច្នេះបព្វជិតាក៏បញ្ចេញសកម្មភាពរបស់ខ្លួន នៅដែនកូសាំងស៊ីនប្រកបដោយជោគជ័យយ៉ាងសម្បើម(៧) នៅសម័យនោះ ស្រុកមិនទាន់ស្រួលបួលនៅឡើយ ហើយរចនាសម្ព័ន្ធខាងអនាម័យក៏មិនសូវមានទៀតផង។ ដូច្នេះដូនជីទាំងនោះមានឈ្មោះល្បីរន្ទឺខ្លាំងអស្ចារ្យ។ មានដូនជីម្នាក់ឈ្មោះ ភេលីស៊ីយែនព័រូ (Félicienne Poirot) មានឈ្មោះល្បីជាងគេ ឮរន្ទឺហួសដែនកូសាំងស៊ីនទៅទៀត។ នាឆ្នាំ ១៩៥៦ សៀវភៅរៀនអានមួយ បោះពុម្ពផ្សាយដោយក្រសួងអប់រំជាតិកម្ពុជាមានមេរៀនពីរបរិយាកាសអំពីសកម្មភាពប្រកបដោយសប្បុរសធម៌របស់បព្វជិតានេះ (៨)។

អស់លោកជាអ្នកទទួលខុសត្រូវលើព្រះសហគមន៍ សុំឲ្យក្រុមគ្រួសារព្រះឧបការគុណនេះ ទៅតាំងទីនៅលើទឹកដីកម្ពុជាជាបន្ទាន់ដែរ។ ក្នុងឆ្នាំ ១៨៨១ បព្វជិតាពីរនាក់

ចេញពីគូឡាវយៀងមកកាន់ក្រុងភ្នំពេញ។ ព្រះបាទនរោត្តមបានទទួលដូនជីទាំងពីររូបនេះយ៉ាងរាក់ទាក់ក្រៃលែង ដូចមានសេចក្ដីរាយការណ៍ថា៖

*«ព្រះករុណាទទួលបព្វជិតាទាំងពីរនោះយ៉ាងរាក់ទាក់ និងដោយព្រះហឫទ័យសោមនស្សមេត្រីក្រៃលែង ទ្រង់សព្វព្រះហឫទ័យជាខ្លាំង ដោយទ្រង់ជ្រាបថាដូនជីទាំងពីរមានបំណងឲ្យព្រះរាជធានីរបស់ព្រះអង្គ មានសហមាគមសង្គ្រោះដែរ។ ព្រះអង្គអញ្ជើញដូនជីទាំងពីរ ឲ្យជ្រើសរើសដីតាមចិត្តប្រាថ្នា ហើយទ្រង់សន្យាថានឹងប្រគល់ដីនោះជូន»* (៩) ។

ដូច្នេះ នៅចុងឆ្នាំ ១៨៨១ បងស្រីទាំងឡាយនៃក្រុមគ្រួសារព្រះឧបការគុណ បានកសាងមន្ទីរសម្រាប់ថែរក្សាទារកមួយ និងមន្ទីរពេទ្យមួយនៅភ្នំពេញ រួចមកកសាងគ្រឹះស្ថានកូនកំព្រាមួយ និងមន្ទីរសម្រាប់ទទួលមនុស្សចាស់ជរាមួយដែរ។

ពេលពួកអ្នកជាតិនិយមបះបោរគឺពីឆ្នាំ ១៨៨៥ ដល់ ១៨៨៧ រដ្ឋបាលបារាំងបានបង្កើត "*រថគិលានុបដ្ឋាកសង្គ្រោះមួយសម្រាប់អ្នកជំងឺ ទាំងទាហាន ទាំងស៊ីវិល ហើយបានសុំឲ្យក្រុមបព្វជិតាមកជួយផង* "។ រថគិលានុបដ្ឋាកសង្គ្រោះនោះ ក្លាយទៅជាមន្ទីរពេទ្យក្រុងដែលក្រោយមកមានឈ្មោះថា "មន្ទីរពេទ្យព្រះកេតុមាលា"(១០)។ ក្នុងឆ្នាំ ១៨៨៩ បព្វជិតាបង្កើត "*សមាគមសង្គ្រោះស្ត្រីកូនកាត់* " ហើយនិងកសាងអាគារមួយសម្រាប់ទទួលក្មេងៗជាកូនជនជាតិអឺរ៉ុបឥតទីពឹង។ ក្រោយមកទៀត "*សមាគមក្រាវែល* " (Fondation Gravelle) បានទទួលបន្ទុកលើសមាគមសង្គ្រោះនេះជំនួសដូនជី(១១) ។

ក្នុងឆ្នាំ ១៩០៥ តាមសេចក្ដីសុំរបស់លោកអភិបាលព្រះសហគមន៍ទទួលបន្ទុកភូមិភាគបព្វជិតាបីបួននាក់ទៅរស់នៅបាត់ដំបង។ តាមទម្លាប់នៅសម័យនោះ បព្វជិតាទាំងនោះបានបង្កើតមន្ទីរ សម្រាប់ថែរក្សាទារកមួយ គ្រឹះស្ថានសម្រាប់ទទួលកុមារកំព្រាមួយ និងមន្ទីរទទួលមនុស្សចាស់ជរាមួយ។ ប៉ុន្តែដោយខេត្តបាត់ដំបងនេះ ស្ថិតនៅក្រោមការត្រួតត្រារបស់សៀមនៅឡើយ ហើយមានខ្មែររស់នៅច្រើនជាងគេផងនោះ ស្ថាប័នទាំងប៉ុន្មានរបស់ដូនជីមានដំណើរមិនស្រួលដូចស្ថាប័នសម្រាប់ជនជាតិវៀតណាមនៅដែនកូសាំងស៊ីនទេ៖

*«កិច្ចការមានដំណើរទៅមុខទាំងលំបាក ក្នុងអំឡុងប៉ុន្មានឆ្នាំនេះ ចំនួនអ្នកជំងឺប្រែប្រួលពី ៦០ ទៅ ១០៦នាក់។ ក្នុងបច្ចុប្បន្ននេះ (១៩២៥) មានក្មេងតែ*

*១៦ នាក់រស់នៅក្នុងមន្ទីរកុមារកំព្រា។ ក្នុងឆ្នាំនេះ មានធ្វើពិធីជ្រមុជទឹកឲ្យក្មេង ៧៥ នាក់ និងឲ្យមនុស្សធំ ១១ នាក់តែប៉ុណ្ណោះ។ គេចូលចិត្តទទួលយកសគុណអំពីសប្បុរសធម៌តាមបែបគ្រីស្តសាសនា ក៏ប៉ុន្តែ ដោយហេតុពួកគេមានជំនឿអកុសល គេខ្លាចពិធីជ្រមុជទឹក»*[១២] ។

បព្វជិតាប្រហែលជាមិនបានប៉ាន់ប្រមាណថា វប្បធម៌របស់ជនជាតិខ្មែរខុសស្រឡះនឹងវប្បធម៌របស់ជនជាតិវៀតណាមឡើយ គឺជនជាតិខ្មែរមិនងាយបោះបង់ចោលកូនឬមនុស្សចាស់ឡើយ។ ម្យ៉ាងទៀត ចំពោះជនជាតិវៀតណាម កាលណាគេចូលគ្រីស្តសាសនា គេបានផលប្រយោជន៍គឺបានដីនៅ។ ផ្ទុយទៅវិញ ចំពោះជនជាតិខ្មែរដែលចូលគ្រីស្តសាសនាត្រូវទទួលផលវិបត្តិទៅវិញ គឺត្រូវចេញពីក្របខ័ណ្ឌជីវិត តាមព្រះពុទ្ធសាសនាហើយត្រូវគេចោទថា ក្បត់មហាគ្រួសារខ្មែរថែមទៀតផង។

**ការមែល "ព្រះមាតាជាទីសង្ឃឹមរបស់យើង"** (Carmel Notre-Dame de l'Espérance)

នាចុងសតវត្សទី ១៩ និងដើមសតវត្សទី ២០ ព្រះសហគមន៍ទាំងមូលកោតសរសើរគោលគំនិតរបស់គណៈដូនជី "ការមែល" មកពីឈ្មោះល្បីរបស់បព្វជិតា សន្តី ថេរ៉េសា ដឺលីស៊ីយើ (១៨៧៣-១៨៩៧ Sainte Thérèse de Lisieux)។ បព្វជិតាថេរ៉េសានេះនៅក្មេងតែមានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះលោក ថេអូផាន វេណា (Théophane Vénard) ដែលធ្វើមរណសាក្សីក្នុងឆ្នាំ ១៨៦១។ លោកវេណានេះ ជាបូជាចារ្យក្នុងចំណោមបូជាចារ្យនៃទេវវិទ្យាល័យក្រុងប៉ារីស។ គេយកលិខិតរបស់លោកទៅផ្សាយយ៉ាងទូលំទូលាយ នៅក្នុងឯកសារនៃក្រសួងប្រកាសផ្សាយជំនឿ។ នាងថេរ៉េសា បានប្តេជ្ញាចិត្តថា នឹងដាក់ខ្លួនទៅជា "*ប្អូនស្រីធម៌* " របស់សាសនទូតម្នាក់ គឺលោកអាដុលរូឡង់ (Adolphe Rouland)។ នាងបានទាក់ទងជាមួយលោកតាមសំបុត្រ រហូតដល់ពេលលោកទទួលមរណភាព។ អស់លោកសាសនទូទនៃក្រុមទេវវិទ្យាល័យនាក្រុងប៉ារីស ទទួលឥទ្ធិពលពីសន្ត យ៉ូហាន ដែលគោរពព្រះឈើឆ្កាង (Saint Jean de la Croix) ហើយគោលគំនិតអស់លោកប្រហាក់ប្រហែលនឹងគោលគំនិតរបស់គណៈដូនជីការមែល ដែលបានទទួលឥទ្ធិពលពីបព្វជិតា សន្តីថេរ៉េសាដាវីឡា (Sainte Thérèse d'Avila) ។ មុនពេលទទួលមរណភាពបន្តិច បងស្រីថេរ៉េសាស្ម័គ្រចិត្តទៅបង្កើតអារាមដូនជី ការមែល នៅក្រុងព្រៃនគរផង គឺជាអារាមទីមួយនៅក្នុងភូមិភាគនេះ។

លោកប៊ុស៊ុតពេញចិត្តទៅសម្រាកអារាមការមែលនេះ យូរៗម្តង។ ក្នុងឆ្នាំ ១៩១២ លោកជម្រាបនាយកអារាមនោះថា លោកមានបំណងឲ្យដូនជីការមែលមួយក្រុម មកនៅក្នុងស្រុកដែលលោកទទួលការខុសត្រូវ តែចាំលោកសង់ទេវវិទ្យាល័យរួចហើយសិន។ លោកពែរ៉ូស (Perros) ជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសសៀម ក៏មានបំណងចង់តាំងអារាមការមែលនៅក្នុងព្រះសហគមន៍របស់លោកដែរ។ ក៏ប៉ុន្តែ សង្គ្រាមលោកលើកទីមួយ ធ្វើឲ្យគម្រោងការរបស់លោកមិនបានសម្រេចទាន់ពេលវេលាឡើយ។

ទីបំផុត នាឆ្នាំ ១៩១៩ បព្វជិតខាងអារាម ការមែល ព្រៃនគរដប់នាក់ មានលទ្ធភាពអាចអញ្ជើញមកកាន់ភ្នំពេញបាន មានបព្វជិតាជាតិវៀតណាម ៨ នាក់ និងបព្វជិតាជាតិអឺរ៉ុប ២ នាក់ ជាអាទិ៍អ្នកម្តាយអានដឺយេស៊ូ (Anne de Jésus) ដែលជាបព្វជិតាពីការមែលសាំងព្រីយើ (Saint Brieuc) ហើយដែលជានាយក អារាមការមែលនៅព្រៃនគររហូតដល់ឆ្នាំ ១៩១៨។ បព្វជិតាការមែលអារាម នៅជិតព្រះវិហារជ្រោយចង្វារទល់មុខភ្នំពេញ នៅលើដីមន្ត្រីវៀតណាមម្នាក់ឈ្មោះ ហោ ធៀង បានប្រគល់ជូន។ មន្ត្រីវៀតណាមនេះ ជាអតីតមេឡូត៍នេសាទទន្លេសាប និងជាមេភូមិផង។

ក្រុមការមែលលូតលាស់យ៉ាងឆាប់រហ័ស ហើយក៏បង្កើតបានអារាមផ្សេងៗទៀត។ ខែ កញ្ញា ឆ្នាំ ១៩២៥ បព្វជិតាពីអារាមការមែលភ្នំពេញ ១៤ នាក់ ចេញទៅបង្កើតអារាមការមែលនៅបាងកក។ ក្រុមដូនជី ការមែលបាងកក ក៏បង្កើតអារាមការមែលសឹង្ហបុរី (១៩៣៨) រួចមកក៏បង្កើតការមែលនៅចន្ទបុរី ប្រទេសសៀម (១៩៥២)។ ក្នុងឆ្នាំ ១៩៣៦ បព្វជិតការមែលភ្នំពេញប្រាំមួយនាក់ទៀត ចេញទៅសាងអារាមនៅយុនណាភូ (ជុងគីង) ប្រទេសចិន ដែលនៅគង់វង់រហូតដល់បដិវត្តន៍ចិន នាឆ្នាំ ១៩៤៩។

## បព្វជិតជាគ្រូបង្រៀននៅសាលាគ្រីស្តសាសនា

សេចក្តីណែនាំឆ្នាំ ១៦៥៩ បានទូន្មានឲ្យលោកអភិបាលបើកសាលារៀន "*គ្រប់ទីកន្លែង*" ព្រោះថា ការអប់រំទាំងផ្លូវលោក និងទាំងផ្លូវគ្រីស្តសាសនា មានសារសំខាន់ជាទីបំផុត។ ក្នុងឆ្នាំ ១៩០៦ ស្របទៅតាមគំនិតរបស់ជនជាតិបារាំងម្នាក់ ឈ្មោះលោកបូ (Beau) ដែលជាអភិបាលខេត្តបាត់ដំបង បព្វជិតនៃក្រុមគ្រួសារ "*បងប្រុសនៃសាលាគ្រីស្តសាសនា*" បានមកបើកសាលារៀនមួយនៅបាត់ដំបង។ សាលានេះសង់នៅលើដីដែលលោកប៉ៃកណាបានប្រគល់ឲ្យ ហើយធ្វើពីស្លឹកត្នោត។ ពេលចាប់ផ្តើមបង្រៀន

មានសិស្សចំនួន ៦៧ នាក់។ បន្ទាប់មក មានសិស្សចំនួន ១៦៣ នាក់។ ប៉ុន្តែ ដល់ឆ្នាំ ១៩១០ លោកទេសាភិបាលក្លូប៊ុយកូស្គី (Klobukosky) សម្រេចអនុវត្តតាមច្បាប់បារាំងថ្មី ដែលហាមមិនឲ្យបព្វជិតបង្រៀននោះ ហើយសាលារៀននោះក៏បិទទ្វារទៅ។

បងៗដែលជាគ្រូ ក៏ចេញទៅនៅភ្នំពេញ ព្រោះនៅរាជធានីភ្នំពេញគេអនុវត្តតាមច្បាប់ថ្មីនោះដែរ តែមិនសូវជាតឹងរ៉ឹងប៉ុន្មានទេ។ លោកប៊ូស៊ុត បានកសាងសាលារៀនពីរ ចាំទទួលបងៗទាំងនោះ គឺសាលារៀនមួយមានឈ្មោះថា "*សាលាសន្តសិលា* " (Ecole Saint Pierre) ស្ថិតនៅជិតទីចាត់ការរបស់លោក ទទួលកូនសិស្សរៀនដោយឥតគិតថ្លៃ សាលាមួយទៀតនៅជិតផ្សារមានឈ្មោះថា "*សាលាមីស* " ដែលតម្រូវឲ្យបង់ថ្លៃការសិក្សា។ លោកប៊ូស៊ុតដាក់ឈ្មោះ "*សាលាមីស* " ដូច្នេះ ដោយមានបំណងលើកកិត្តិយស និងរំឭកដល់វិញ្ញាណក្ខ័ន្ធលោកអភិបាលពីសម័យមុន។ លោកសម្ពោធសាលានេះនៅថ្ងៃទី ១ មីនា ឆ្នាំ ១៩១១ ដោយមានសិស្សចំនួនតែ ៩ នាក់ ក្នុងសាលាមួយ និង ៥ នាក់នៅក្នុងសាលាមួយទៀត។ ថ្ងៃទី ២០ ធ្នូ សាលាមីសមានសិស្សចំនួន ២០០ នាក់ ហើយចំនួនសិស្សចេះតែកើនច្រើនឡើងៗ រហូតទាល់តែលើសពី មួយពាន់នាក់ក្នុងឆ្នាំ ១៩២២។

*　　*

*

ក្នុងអំឡុង ៩០ ឆ្នាំនៃអាណាព្យាបាលបារាំង សាសនទូតបានតែងតាំង និងចាត់ចែងព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា ស្របតាមរបៀបបែបបទប្រពៃណីរបស់ព្រះសហគមន៍ទូទៅក្នុងសកលលោក និងស្របទៅតាមទេវវិទ្យាសម័យនោះ។ អ្នកស្ម័គ្រចិត្តចូលគ្រីស្តសាសនា តែងទទួលផលប្រយោជន៍ខ្លះៗ យ៉ាងហោចណាស់ក៏បានប្រយោជន៍ខាងផ្លូវចិត្តគឺ "*សង្គ្រោះព្រលឹង* " របស់គេ។ ពួកគេក៏បានប្រយោជន៍ខាងសម្ភារៈខ្លះដែរ។ សាសនទូតតែងប្រមូលអ្នកជឿធ្វើជា "ក្រុមគ្រីស្តបរិស័ទ" ស្របទៅតាមប្រព័ន្ធសង្គមខ្មែរ គឺបែបវត្តអារាមខ្មែរដែរ។ គ្រីស្តបរិស័ទដែលរស់នៅដាច់ស្រយាលពីគ្រីស្តបរិស័ទឯទៀតៗ ពិបាកប្រតិបត្តិតាមជំនឿរបស់ខ្លួនណាស់។ ម្យ៉ាងទៀត ការប្រមូលគ្រីស្តបរិស័ទឲ្យរស់នៅ

ជាក្រុមៗដូច្នេះ ក៏ធ្វើឲ្យប្រទេសជាតិមានការលូតលាស់ដែរ ព្រោះក្នុងសម័យនោះ គ្រីស្តបរិស័ទត្រូវរានព្រៃ ធ្វើស្រែចម្ការចិញ្ចឹមជីវិត។ ពួកគេរស់នៅជាប់លាប់មួយកន្លែង មិនដូរចុះឡើងដូចពីសម័យមុនៗទេ។ ពួកគេក៏មានជីវភាពរស់នៅសមរម្យ អ្នកក្រីក្រ មានសិទ្ធិអាចរៀនសូត្របាន និងមានសិទ្ធិទៅពេទ្យព្យាបាលរោគបានផង។ ក្រុមគ្រួសារ បព្វជិតទាំងឡាយ បានកសាងគ្រឹះស្ថានសម្រាប់កុមារកំព្រា កសាងមន្ទីរពេទ្យ និងសាលា រៀន។ល។ សាសនទូតធ្វើទានដូច្នេះ តាមគោលការណ៍ណែនាំគ្រីស្តបរិស័ទក្នុងសម័យ នោះ។ គោលការណ៍ទាំងនេះ ក៏មកពីរបៀបរិះគិតអំពីពិភពលោក និងអំពីសភាពការ នយោបាយ។ ប៉ុន្តែ ព្រះសហគមន៍បង្ហាញមុខមាត់ធំពេក មិនសមស្របតាមចំនួនគ្រីស្ត បរិស័ទខ្មែរទេ។ គ្រីស្តបរិស័ទមានចំនួនតែ ០,០១ ភាគរយ ក្នុងចំណោម ជនជាតិខ្មែរទាំង មូល។ យើងឃើញថា ក្នុងព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា មានគ្រីស្តបរិស័ទជាតិ វៀតណាមជាច្រើនអនេកទៅវិញ ទោះបីជាអស់លោកសាសនទូតខិតខំបង្កើតក្រុមគ្រីស្ត បរិស័ទនានាក្នុងគោលបំណងទាក់ទាញជនជាតិខ្មែរទូទៅក៏ដោយ។ ដូច្នេះយើងអាច សន្និដ្ឋានថា ព្រះសហគមន៍រារាំងផ្លូវមិនឲ្យជនជាតិខ្មែរ មានលទ្ធភាពចូលគ្រីស្ត សាសនាបានឡើយ។

(១) Archives MEP, Vol. 766, doc. 96.

(២) សេចក្តីរាយការណ៍ឆ្នាំ ១៨៥០ របស់លោកឡឺហ្វែរ និងលោកមីស។ ឯកសាររបស់ទេវវិទ្យាល័យ ក្រុងប៉ារីស ក្បាលទី ៧៥៥ លេខ ៥៤។ "*អ្នកណែនាំថ្នាក់ទីពីរ* គឺជាចាស់ទុំ ជាគ្រីស្តបរិស័ទ ទទួលមើលខុសត្រូវលើក្រុមគ្រីស្តបរិស័ទចំណុះជើងព្រះវិហារមួយ។

(៣) Joseph Vulliez, Revue des MEP “Epiphanie”, Juillet 1963.

(៤) ដូចគ្នា។

(៥) ក្នុងឆ្នាំ ១៩៦៧ "ក្រុមគ្រួសារបត្រីព្រះនាងម៉ារី" មានបព្វជិតាចំនួន ៧៨ នាក់ និងយុវនារីដែល រៀបចំខ្លួនចូលបួសចំនួន ៤០ នាក់។ ក្នុងចំណោមបព្វជិតាទាំងអស់នេះ មានបព្វជិតាខ្មែរតែពីរនាក់ ប៉ុណ្ណោះទេ ម្នាក់មានម្តាយខ្មែរនិងឪពុកបារាំងកាត់ខ្មែរ និងម្នាក់ទៀតជាកូនចៅឆ្ងាយរបស់ជនជាតិ ព័រទុយហ្គាល់។ ក្រុមគ្រួសារនេះទទួលបន្ទុកសាលាបឋមសិក្សាពីរ នៅឫស្សីកែវ (ភ្នំពេញ) និងនៅ កំពង់ចាម ព្រមទាំងសាលាអប់រំខាងគ្រីស្តសាសនាចំនួន ១៩ តាមក្រុមគ្រីស្តបរិស័ទនៅតាមខេត្ត។

(៦) លោកយ៉ូហានម៉ារតាំង ម៉ូយ (បារាំង) បានបង្កើតក្រុមគ្រួសារនេះឡើង នៅឆ្នាំ ១៧៦២។ លោក

ជាបូជាចារ្យក្នុងភូមិភាគសាំងឌីយេ (St. Dié)។ "*ដោយហេតុថាលោកខ្លោចចិត្តអាណិតអាសូរចំពោះក្មេងៗអនាថា និងល្ងិតល្ងង់*" នៅក្នុងភូមនានានៃខេត្តវ៉ូល (Vosges) លោកបង្កើតក្រុមគ្រួសារបព្វជិតសម្រាប់បង្រៀននៅតាមស្រុកស្រែទាំងឡាយ។ នាងហ្វ្រេស ដឺម៉េស (Fresne de Metz) បានជួបលោកក្នុងកិច្ចបង្កើតនេះ ហើយក្រុមគ្រួសារនេះបានក្លាយទៅជា "ក្រុមគ្រួសារបងស្រីព្រះឧបការគុណា" (Congrégation des Soeurs de la Providence)។ បន្ទាប់ពីបានបំពេញភារកិច្ចជាបូជាចារ្យអស់រយៈ ប្រាំពីរឆ្នាំ នៅសាំងឌីយេមក លោក យ៉ូហានម៉ារតាំងម៉ូយ បានចូលទេវវិទ្យាល័យនៅក្រុងប៉ារីសហើយត្រូវគេចាត់ទៅប្រទេសចិន។ នៅប្រទេសនោះ លោកបានបង្កើតក្រុមគ្រួសារ "*កុមារសង្គ្រោះ* " ដែលប្រមូលផ្តុំយុវនារីចិន ដើម្បីទទួលទារក ដែលអ្នកស្រុកបោះបង់ចោលនិងបង្កើតសាលារៀន។ ពេលលោកត្រឡប់មកប្រទេសបារាំងវិញ ព្រោះមានជំងឺ ពួកបដិវត្តន៍បារាំងនិរទេសទៅក្រុងត្រេវ (Trêves, Allemagne) ។ លោកទទួលមរណភាពនៅទីនោះ នាឆ្នាំ ១៧៩៣។ ក្នុងឆ្នាំ ១៨១២ ក្រុមបព្វជិតាតាំងទីចាត់ការរបស់ខ្លួននៅប៉កជើក្នុងខេត្តវ៉ូស ( បារាំង ) ។ ដូនជីទាំងនោះ មានឈ្មោះល្បីរន្ទឺ ជាពិសេសនៅក្នុងភាគខាងកើតនៃប្រទេសបារាំង ក្នុងប្រទេសបែលស៊ិកហើយនិងក្នុងប្រទេសអ៊ីតាលី។ សង្គ្រាមឆ្នាំ ១៨៧០ បណ្តាលឲ្យដូនជីឃ្លាតចេញពីភូមិភាគរបស់ខ្លួន។ ដូច្នេះបព្វជិតាមួយចំនួននៅទំនេរ ហើយប្រុងប្រៀបទទួលភារកិច្ចផ្សេងៗទៀត។ ដោយយោលទៅលើចំណងមេត្រីភាព រវាងទេវវិទ្យាល័យនៅប៉ារីស និងអ្នកបង្កើតក្រុមគ្រួសារប៉កជើ លោកវើលរ៉ូល (Verrolles) ដែលជាអភិបាលព្រះសហគមន៍ប្រចាំភូមិភាគសេឈន់ នៃប្រទេសចិន និងលោកក័រឌីយេដែលទទួលបន្ទុកប្រទេសកម្ពុជា ក៏សុំឲ្យដូនជីទាំងនោះមកជួយធ្វើការក្នុងភូមិភាគដែលលោកណែនាំ។

( ៧ ) ក្នុងឆ្នាំ ១៨៧៦ ស្របទៅតាមសំណូមពររបស់លោកសាសនទូតទាំងប៉ុន្មាន បព្វជិតាទាំងនោះ សង់ទារកដ្ឋានមួយ និងគ្រឹះស្ថាន សម្រាប់កុមារកំព្រាមួយនៅខេត្តមាត់ជ្រូក។ ក្នុងឆ្នាំ ១៨៧៨ ដូនជីបានបង្កើតទារកដ្ឋានមួយគ្រឹះស្ថានសម្រាប់កុមារកំព្រាមួយ និងមន្ទីរសង្គ្រោះមួយ នៅខេត្តផ្សារដែក។ ក្នុងឆ្នាំ ១៨៨៨ ពួកគេសង់ទារកដ្ឋានមួយ គ្រឹះស្ថានសម្រាប់កុមារកំព្រាមួយ មន្ទីរពេទ្យមួយ និងអាគារអប់រំមួយនៅខេត្តស្រុកត្រាំង។ ក្នុងក្រុងស្រុកត្រាំងនេះ គ្រាន់តែក្នុងឆ្នាំ ១៩២៥ ប៉ុណ្ណោះ ចំនួនអ្នកជំងឺមាន ៤.៨៩៥ នាក់ មានស្ត្រីសម្រាលកូនចំនួន ៤៥៧ នាក់ ទារកដ្ឋានបានទទួលទារកចំនួន ៥១១ នាក់។ បព្វជិតាទាំងនោះ បានធ្វើពិធីជ្រមុជទឹកឲ្យមនុស្សធំ ចំនួន ១១៦ នាក់។ ចាប់តាំងពីឆ្នាំ ១៩០៧ មករដ្ឋបាលបារាំង សុំឲ្យបព្វជិតាទទួលបន្ទុកនៅមន្ទីរពេទ្យស្រុកកាន់ថូ (Cantho) ឆ្នាំ ១៩០៧ បាក់លី (Bac Lieu) និងឡុងសៀន (Long Xuyen) ឆ្នាំ ១៩០៩ រ៉ាយ៉ា (Rach Già) ឆ្នាំ ១៩២១ និងផ្សារដែក (Sadec) ឆ្នាំ ១៩៣២ ។

( ៨ ) "*វិជ្ជាខេមរភាសាអាទិកដ្ឋាន*" ។ រោងពុម្ពព្រះរាជវាំងភ្នំពេញឆ្នាំ ១៩៥៦ ទំព័រ ១៣៦-១៤០។

(៩) "ខួបហាសិបឆ្នាំ (១៨៧៦-១៩២៦)។ ពួកបងស្រីនៃក្រុមគ្រួសារព្រះឧបការគុណ នៅព័រជើ" ប៉ារីស ឆ្នាំ ១៩២៦ ទំព័រ ៥១-៥២។

(១០) ឆ្នាំ ១៩០៤ ប្រទេសបារាំងបានចេញដំណើរជំទាស់នឹងសាសនា។ បន្ទាប់មក ក្នុងឆ្នាំ ១៩១០ រដ្ឋការបារាំងដេញបព្វជិតា ទាំងឡាយពីមន្ទីរពេទ្យព្រះកេតុមាលា។ ដូនជីទាំងនោះ ត្រូវហៅមកវិញក្នុងឆ្នាំ ១៩៤១ ហើយពីរបីឆ្នាំបន្ទាប់ពីប្រទេសកម្ពុជាបានឯករាជ្យមក គេដេញបព្វជិតាទាំងឡាយ ហើយស្តាយបព្វជិតាដែលត្រូវគេដេញចេញដូច្នេះ។ គ្រូពេទ្យនាយកនិយាយទៅកាន់បងស្រីជានាយិកាទទួលបន្ទុកក្រុមគ្រួសារដូនជីនោះថា៖ "*បើបងស្រីចង់អញ្ជើញត្រឡប់មកវិញសូមអញ្ជើញមកចុះ។ ខ្យល់ព្យុះផុតទៅហើយ*"។ ក៏ប៉ុន្តែ បព្វជិតាជាប់ធ្វើការតាមមន្ទីរពេទ្យឯកជនហើយ។ ក្នុងសម័យសាធារណរដ្ឋខ្មែរមន្ទីរពេទ្យព្រះកេតុមាលានេះក្លាយទៅជាមន្ទីរពេទ្យទាហាន។

(១១) សមាគមនៃជនជាតិបារាំង ដែលសុខចិត្តធ្វើការគ្មានយកកម្រៃ បានក្មេងៗកូនកាត់អឺរ៉ុប-អាស៊ីឲ្យទៅសិក្សានៅប្រទេសបារាំង រួចក៏ត្រឡប់ប្រទេសកម្ពុជាវិញ។ លោក ក្រាវែល (Gravelle) ជានាយក ធនាគារឥណ្ឌូចិន បានរៀបការជាមួយស្ត្រីខ្មែរម្នាក់ ហើយបានកូនជាច្រើន។ លោកបរិច្ចាកទ្រព្យសម្បត្តិរបស់លោកឲ្យដល់កូនកាត់ អឺរ៉ុប-អាស៊ីដែលគ្មានទីពឹង។

(១២) "ខួបហាសិបឆ្នាំ..." ទំព័រ ៦២ ។

# ជំពូកទី ១០

## ព្រះសហគមន៍ប្រទេសអេកម្ពុជាក្នុងសង្គ្រាមឥណ្ឌូចិន

តាំងពីឆ្នាំ ១៩៣៧ មក ប្រទេសជប៉ុនច្បាំងចេញមុខប្រឆាំងនឹងប្រទេសចិន ហើយកាន់កាប់ភាគខ្លះនៃ ប្រទេសនេះទៀតផង។ ប្រទេសបារាំង និងប្រទេសអង់គ្លេស គាំទ្រលោកជាងកៃជៀកដែលច្បាំងទប់ទល់ នឹងពួកជប៉ុន។ ប្រទេសបារាំង និងប្រទេសអង់គ្លេសតែងផ្តល់ជំនួយយោធាដល់ប្រទេសចិន តាមផ្លូវស្រុក តុងកឹង។ ថ្ងៃទី ១៩ ឧសភា ១៩៤០ គឺពីរថ្ងៃក្រោយលោកសេនាប្រមុខបារាំង ឈ្មោះប៉េតាំង យល់ព្រមចុះចាញ់ពួកអាល្លឺម៉ង់ នៅទ្វីបអឺរ៉ុប ប្រទេសជប៉ុនព្រមានប្រទេសបារាំង។ ហើយបីបួនថ្ងៃ បន្ទាប់មក កងទ័ពជប៉ុនក៏ចូលកាន់កាប់ស្រុកតុងកឹង។ ក្នុងខែកក្កដា កងទ័ពជប៉ុនមកដល់ប្រទេសកម្ពុជា។ ថ្ងៃទី ៣០ សីហា រដ្ឋាភិបាលបារាំងដែលចុះចាញ់ពួកអាល្លឺម៉ង់ទទួលស្គាល់ថា "*ប្រទេសជប៉ុនត្រូវការចុងបូព៌ាប្រទេសជាចាំបាច់*" ។ ក្នុងខែកញ្ញា រដ្ឋាភិបាលបារាំងអនុញ្ញាតឲ្យកប៉ាល់ជប៉ុនមានសិទ្ធិចូលមកចតនៅកំពង់ផែហៃផុង (Haiphon) ហើយនិងមានសិទ្ធិប្រើប្រាស់វាលយន្តហោះទាំងប៉ុន្មាននៅឥណ្ឌូចិន។ ដោយរដ្ឋាភិបាលបារាំងអនុញ្ញាតឲ្យកងទ័ពជប៉ុនប្រើប្រាស់មូលដ្ឋានបារាំងដូច្នេះ រាជរដ្ឋាភិបាលជប៉ុនក៏ព្រមឲ្យបារាំងមានសិទ្ធិត្រួតត្រាឥណ្ឌូចិនតទៅទៀត។ កងទ័ពបារាំងក៏មានសិទ្ធិធ្វើដំណើរទៅមកបានដោយសេរី ហើយទេសាភិបាលបារាំងក៏អាចត្រួតត្រារាជរដ្ឋាភិបាលខ្មែរតទៅទៀត។

ចាប់ពីឆ្នាំ ១៩៤០ មក ប្រទេសសៀមចាប់ផ្តើមវាយលុកប្រទេសកម្ពុជា។ ក្នុងខែមករា ឆ្នាំ ១៩៤១ កងទ័ពជើងទឹកបារាំងកម្ទេចកងនាវាចរសៀមចោលអស់ នៅក្បែរកោះឆាង។ តែប្រទេសជប៉ុនប្រើអំណាចបង្ខំប្រទេសបារាំងឲ្យប្រគល់ខេត្តខ្មែរពីរ គឺខេត្តបាត់ដំបង និងខេត្តសៀមរាប ព្រមទាំងទឹកដីភាគខ្លះខេត្តស្ទឹងត្រែង និងខេត្តកំពង់ធំ ឲ្យទៅប្រទេសសៀម។ ពេលនោះ ប្រទេសសៀមក៏ដូរឈ្មោះថា "*ថៃឡង់ដ៍*" ជាឈ្មោះ

បញ្ជាក់ពីបំណងរបស់គេ ចង់ឲ្យជនជាតិថៃទាំងអស់ដែលរស់នៅក្នុងរដ្ឋជិតខាងមកនៅក្រោមអំណាចរបស់ពួកគេ។

ព្រឹត្តិការណ៍នេះ បណ្ដាលឲ្យប្រជាពលរដ្ឋខ្មែរលិចស្រឹមទៅក្នុងទុក្ខវេទនារកទីបំផុតគ្មាន។

ក្នុងអំឡុងសង្គ្រាមប្រាំឆ្នាំនោះ សាសនទូតជាច្រើន ត្រូវជាប់កំណែន ហើយអត់មានសាសនទូតថ្មីមកប្រទេសកម្ពុជាទៀតឡើយ។ ដូច្នេះក្រុមគ្រីស្ដបរិស័ទគ្មាននរណាណែនាំទេ ហើយគ្មានការរីកចម្រើនឡើយ។ នៅក្រុងភ្នំពេញអ្នកកាន់អំណាចជប៉ុន រឹបអូសយកអាគារទាំងឡាយរបស់ព្រះសហគមន៍កាតូលិក ដើម្បីឲ្យកងទ័ពជប៉ុនស្នាក់អាស្រ័យ។ លោក សាបាល់លីយេ (Chaballier) សរសេរថា៖ "*ទោះបីពួកជប៉ុន សន្យាថាគោរពព្រះវិហារទេវវិទ្យាល័យក៏ដោយ ក៏ពួកគេនៅតែយកព្រះវិហារនោះធ្វើជាឃ្លាំងដាក់អាវុធដែរ ហើយថែមទាំងបំផ្លិចបំផ្លាញវិហារនេះយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀតផង* " [១]។ គេហដ្ឋានរបស់លោកអភិបាលមួយផ្នែកក្លាយទៅជាការិយាល័យសម្រាប់យោធាជប៉ុន។ នៅពញាឮ ពួកជប៉ុនសាងសិលាចារឹកមួយ  ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធគ្រីស្ដបរិស័ទជាជនរួមជាតិគេដែលបានភៀសខ្លួនចូលមកនៅប្រទេសកម្ពុជា នាសតវត្សទី ១៧ នោះ [២]។

សាសនទូតបារាំង ដែលមិនជាប់កំណែនហើយដែលនៅស្រុកស្រែ បានទទួលការអនុញ្ញាតឲ្យនៅនឹងកន្លែង។ នៅខេត្តខ្មែរទាំងបួនដែលសៀមទើបនឹងកាន់កាប់នោះ រាជការថៃបានបង្ខំប្រជាជនខ្មែរ ឲ្យនិយាយភាសាថៃ និងស្លៀកសម្លៀកបំពាក់តាមប្រពៃណីថៃដែរ។ អាជ្ញាធរថៃអនុញ្ញាតឲ្យគោរពពុទ្ធសាសនា ជាសាសនាជាតិតែមួយ ពួកគេបង្ខំសាលាការៀនតូលិកទាំងឡាយ ឲ្យទទួលយកគ្រូដែលពួកគេជ្រើសរើសឲ្យ។

ជនជាតិបារាំងមួយចំនួនតូចខំទប់ទល់នឹងជប៉ុន ដែលចូលមកកាន់កាប់ឥណ្ឌូចិន ហើយបង្កើតជាក្រុមតស៊ូ។ បន្ទាប់ពីលោកដឺហ្គោល (De Gaulle) រំដោះក្រុងប៉ារីសបានក្នុងឆ្នាំ ១៩៤៤ ពួកតស៊ូនេះបានបញ្ចេញសកម្មភាពប្រឆាំងនឹងជប៉ុន កាន់តែមមាញឹកឡើងថែមទៀត។ បណ្ដាលឲ្យកងទ័ពជប៉ុន វាយយកបន្ទាយបារាំងទាំងឡាយនាថ្ងៃទី ៩ មីនា ឆ្នាំ ១៩៤៥ ដោយខ្លាចក្រែងកងទ័ពបារាំងងើបប្រឆាំងនឹងពួកគេ។ ដូច្នេះ កងទ័ពជប៉ុនក៏យកដែនឥណ្ឌូចិនទាំងមូលមកកាន់កាប់តែម្ដង។ ថ្ងៃបន្ទាប់មក កងទ័ពជប៉ុនប្រកាសថាប្រទេសកម្ពុជាជាប្រទេសឯករាជ្យ។ ចាប់តាំងពីថ្ងៃពី ២២ មីនា អាណិកជនបារាំងទាំងអស់

ត្រូវកងទ័ពជប៉ុនឃុំឃាំងទុកនៅក្នុងជំរំមួយ ដែលមានទាំងគេហដ្ឋានរបស់លោកអភិបាលព្រះសហគមន៍ផង។

ក្នុងរយៈពេលដ៏សែនវេទនានោះ កាលណាឱកាសហុចឲ្យ ជនជាតិតែងខិតខំការពារជនជាតិបារាំង ទោះបីបារាំងទាំងនោះមានមុខតំណែងណាក៏ដោយ ក៏ជនជាតិខ្មែរពុំព្រមប្រគល់បារាំងទាំងនោះ ឲ្យអ្នកកាន់អំណាចជប៉ុនឡើយ ផ្ទុយទៅវិញ ពួកគេខំលាក់បំពួនអ្នកទាំងនោះហើយយកចិត្តទុកដាក់ការពារជីវិតពួកគេផង។

ចំណែកសាសនទូតដែលរស់នៅតាមខេត្ត អស់លោកអាចនៅនឹងកន្លែងបាន។ ផ្ទុយទៅវិញ នាថ្ងៃទី ២៩ ឧសភា ឆ្នាំ ១៩៤៥ រដ្ឋអំណាចជប៉ុនហាមសាសនទូតទាំងអស់ដែលនៅភ្នំពេញ មិនឲ្យចេញពីផ្ទះរបស់អស់លោកជាដាច់ខាត។ តែកងទ័ពជប៉ុនអនុញ្ញាតឲ្យបព្វជិតា ដែលជាបុគ្គលិកមន្ទីរពេទ្យមានសិទ្ធិចេញចូលបានធម្មតា ព្រោះពួកគេចាត់ទុកដូនជីទាំងនោះ ជាប្រជាពលរដ្ឋរបស់ប៉ុរីវ៉ាទីកង់។ លោកសាបាល់លីយេសរសេរដូចតទៅ៖

> *«ក្រោយមកបន្តិច ពួកជប៉ុនហាមឃាត់មិនឲ្យអ្នកស្រុកចេញចូលទៅក្នុងជំរំឃុំឃាំងនោះឡើយ។ បព្វជិតាវៀតណាមមានសេចក្តីក្លាហានដ៏ខ្លាំងក្លា ហើយមានចិត្តកក្តីតស៊ូដ៏ធំធេង។ ជាញឹកញយ ដូចជីទាំងនោះប្រថុយជីវិតលបចូលក្នុងជំរំឆ្លងកាត់ពួកជប៉ុន ដើម្បីយកស្បៀងមកឲ្យយើង»។*

ថ្ងៃទី ១៥ សីហា ឆ្នាំ ១៩៤៥ ប្រទេសជប៉ុនចុះចាញ់សង្គ្រាម ប៉ុន្តែ នៅប្រទេសកម្ពុជា ការជ្រួលច្របល់ចេះតែមានតទៅទៀតមួយរយៈ។

ថ្ងៃទី ២០ សីហា អ្នកកាន់អំណាចជប៉ុនកោះហៅលោក ដារីឌ ដែលជាបូជាចារ្យប្រចាំក្រុមគ្រីស្តបរិស័ទនៅឆ្លូង ឲ្យទៅក្រុងក្រចេះ។ ដោយលោកធ្លាប់ទាក់ទង នឹងអ្នកកាន់អំណាចទាំងនោះ លោកក៏អញ្ជើញទៅ ដោយឥតព្រួយបារម្ភអ្វីឡើយ។ ថ្ងៃទី ២២ សីហា ឆ្នាំ ១៩៤៥ ទាហានជាតិវៀតណាមម្នាក់សម្លាប់លោកចោល តាមបញ្ជារបស់ភ្នាក់ងារអាវុធហត្ថជប៉ុនម្នាក់ ដែលពុំព្រមទទួលបរាជ័យដូចប្រទេសខ្លួន។

## ពួកអ្នកជាតិនិយមវាយប្រហារព្រះសហគមន៍

ក្នុងខែកញ្ញា ឆ្នាំ ១៩៤៥ ឧត្តមសេនីយ៍ឡឺក្លែរ (Général Leclerc) វាយដណ្ដើមយកប្រទេសកម្ពុជាមកវិញ ដើម្បីជាប្រយោជន៍ដល់ប្រទេសបារាំង។ កងទ័ពបារាំងចាប់លោកនាយករដ្ឋមន្ត្រី សឺន ង៉ុកថាន់ ដែលពួកជប៉ុនបានលើកបន្តុកឲ្យដឹកនាំប្រទេសកម្ពុជា មុននឹងពួកគេដកថយចេញទៅ។ លោកឡឺក្លែរតែង តាំងព្រះបាទនរោត្តមសីហនុ(៣) ជាព្រះមហាក្សត្រកម្ពុជាវិញ។ ព្រះមហាក្សត្រទ្រង់ធ្វើអន្តរាគមន៍ជួយលោក សឺន ង៉ុកថាន់ ដែលជាប់គុកនៅស្រុកបារាំងឲ្យត្រឡប់មកស្រុកកំណើតវិញ។ ក៏ប៉ុន្តែ លោកសឺន ង៉ុកថាន់ ទៅរស់នៅប្រទេសថៃ ហើយពីប្រទេសថៃនោះ លោក ថាន់ ដឹកនាំពួក "*ខ្មែរឥស្សរៈ*" ឬ "*ខ្មែរសេរី*" ប្រយុទ្ធតទល់នឹងអំណាចព្រះជារាជាផង តទល់នឹងអាណានិគមបារាំងក្នុងស្រុកផង។ គ្រានោះ ប្រទេសថៃគាំទ្រពួកឥស្សរៈនេះ ដូច្នេះអសន្តិសុខក៏កើតមានឡើងពេញប្រទេសកម្ពុជា។ ពួកឥស្សរៈនេះ បានចងសម្ព័ន្ធជាមួយនឹងពួក "*វៀតមិញ*" (៤) ដែលប្រយុទ្ធប្រឆាំងនឹងបារាំងទាមទារឯករាជ្យសម្រាប់ប្រទេសវៀតណាម។

ចាប់តាំងពីប្រទេសជប៉ុនចុះចាញ់មក ពួកវៀតណាមដែលតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំង ធ្វើទុក្ខព្រះសហគមន៍ដែរ។

នៅភ្នំពេញ "*គេបិទបដានៅជិតព្រះវិហារ អំពាវនាវឲ្យគ្រីស្តបរិស័ទ លែងទទួលអគ្គសញ្ញាពីដៃរបស់សាសនទូតបារាំង និងលែងចូលរួមក្នុងអភិបូជារបស់លោកទាំងនោះផង។ ការរឹករវនេះកើតមានឡើងតែក្នុងរយៈពេល ១៥ ថ្ងៃប៉ុណ្ណោះ*"។

នាខែសីហា ឆ្នាំ ១៩៤៥ នៅដែនកូសាំងស៊ីន ទាហានទ័ពព្រៃចូលលុកទេវវិទ្យាល័យនៅកោះគូឡាវយៀង ហើយចាប់បូជាចារ្យបារាំងឃុំឃាំងអស់រយៈបីខែ។ ថ្ងៃទី ២១ វិច្ឆិកា ពួកទ័ពព្រៃដុតបំផ្លាញអារាម ដូនជីរបស់ក្រុមគ្រួសារព្រះឧបការគុណ ដុតទាំងគេហដ្ឋានលោកអភិបាលព្រះសហគមន៍ ទាំងសាលារៀនរបស់ក្រុមគ្រីស្តបរិស័ទ និងដុតទេវវិទ្យាល័យដែរ។ លោកសាបាល់លីយេសរសេរថា៖ «*អាគារទាំងអស់នៅ សល់តែជញ្ជាំងទទេ គឺអ្វីៗទាំងអស់រលាយបាត់បង់សូន្យទៅហើយ*»។ ដូនជីបារាំងទាំងឡាយត្រូវគេចាប់យកទៅ ហើយពីរខែក្រោយមក ទើបកងទ័ពជើងទឹកបារាំងរំដោះដូនជីទាំងនោះបានមកវិញ។ «*ដូនជីវៀតណាម ហើយនិងកុមារកំព្រាស្រីៗដ៏ច្រើនសន្ធឹក ដែលបែកខ្ញែកគ្នាក្នុងគ្រាដំបូង ត្រូវកប៉ាល់ទាហានជើងទឹកមួយ ទទួលយកមកក្រុងភ្នំពេញវិញ*»។ បន្ទាប់ពីការបំផ្លិច

បំផ្លាញនេះ និងបន្ទាប់ពីអសន្តិសុខកើតពេញដែនកូសាំងស៊ីនមក ក្រុមគ្រួសារព្រះឧបការគុណក៏មកតាំងទីនៅឯភ្នំពេញ។ អារាមដូនជីសង់ក្នុងឆ្នាំ ១៩២៣ បានឡើងទៅជាគ្រឹះស្ថានទីចាត់ការរបស់ដូនជីនិងធ្វើជាអគារសម្រាប់អប់រំដូនជីថ្មីៗ ដែលទទួលយកយុវនារីពីមណ្ឌលព្រះសហគមន៍ទាំងមូល។

នៅប្រទេសកម្ពុជា ពួកឥស្សរៈក៏ព្យាបាទគ្រីស្តបរិស័ទដែរ។ ថ្ងៃទី ៩ ធ្នូ ឆ្នាំ ១៩៤៦ រដ្ឋាភិបាលបារាំងបង្ខំប្រទេសសៀម ឲ្យប្រគល់ខេត្តទាំងប៉ុន្មានដែលពួកគេរឹបអូសនៅឆ្នាំ ១៩៤១ នោះ មកប្រទេសខ្មែរវិញ។ ក្នុងពេលជាមួយគ្នានោះ ខ្មែរសេរីដុតបំផ្លាញភូមិគ្រីស្តបរិស័ទវៀតណាមនៅខ្សាច់ពោល ចម្ងាយ ៨ គ.ម. ខាងត្បូងបាត់ដំបង ហើយសម្លាប់មនុស្សនៅភូមិនោះអស់ចំនួន ៥០ នាក់។ អ្នកភូមិឯទៀតៗបានរួចជីវិត ដោយសារពួកទាហានបារាំងធ្វើអន្តរាគមន៍ទាន់។ «*ប្រសិនទាហានមកដល់យឺតបន្តិច ពួកឥស្សរៈប្រាកដជាសម្លាប់រង្គាលគ្រីស្តបរិស័ទ ដែលពួនផ្តុំគ្នានៅក្នុងព្រះវិហារនោះ ចោលទាំងអស់*» ។

ចាប់តាំងពីឆ្នាំ ១៩៤៦ មក ពួកឥស្សរៈនិងពួកវៀតមិញបង្ករអសន្តិសុខពេញទូទាំងប្រទេស។ ជាពិសេស ពួកនោះធ្វើទុក្ខទោសដល់ក្រុមគ្រីស្តបរិស័ទកាតូលិកវៀតណាមដែលជាបណ្តុំជនបរទេសស្រុកខ្មែរ ហើយដែលពួកគេសង្ស័យថា ជារបាំងការពារបារាំងប្រឆាំងនឹងកុម្មុយនិស្តទៀតផង។ ព្រះវិហារទាំងប៉ុន្មាន ដែលស្ថិតនៅតាមដងទន្លេមេគង្គ (ពាមលង្វែក ប៉ែកខាងលើភ្នំពេញ និងមាត់ក្រសាស់ ផ្លូវត្រី វាលធំ នៅខាងក្រោយភ្នំពេញ) ត្រូវពួកគេដុតបំផ្លាញចោលទាំងអស់។ គ្រីស្តបរិស័ទចំនួន ៤២ នាក់ ត្រូវពួកគេសម្លាប់ ឬដុតទាំងរស់ក្នុងផ្ទះតែម្តង។ ទាំងគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទ ភ័យស្លន់ស្លោនាំគ្នាភៀសខ្លួនចូលភូមិកាតូលិកភ្នំពេញ។ លោកអភិបាលព្រះសហគមន៍[៥] សរសេរថា៖ «ពេលនោះយើងត្រូវចិញ្ចឹមមនុស្សចំនួន ៣.៨០០ នាក់»។ ព្រះវិហារប្រឡាយមាស នៅជិតកំពង់ឆ្នាំង ក៏ត្រូវពួកគេបំផ្លាញខ្ទេចខ្ទីដែរ ក្រុមគ្រីស្តបរិស័ទទាំងប៉ុន្មាននៅលើត្រើយទន្លេតូច ប៉ែកខាងត្បូងនៃប្រទេសកម្ពុជាក៏រលាយសូន្យដែរ។ ក្រុមគ្រីស្តទូបរិស័ទបាណាមបានការពារខ្លួនដោយរៀបចំជាកងស្វ័យត្រាណដូចពីសម័យមុនៗដែរ។

លោកសាបាល់លីយេបង្ខំគ្រីស្តបរិស័ទវៀតណាមដែលមកពីតំបន់មាត់ជ្រូក ឲ្យប្រឡប់ទៅភូមិរបស់ខ្លួនវិញ គឺនៅជិតប៉ុស្តិ៍ទាហាន។ តែពួកគេពិបាកនឹងតាំងទីលំនៅ

ជាថ្មីឡើងវិញ ព្រោះថាគ្រីស្តបរិស័ទចេះតែភ័យខ្លាច។ ម្យ៉ាងទៀត ខ្មែរដែលកាន់កាប់អំណាចនៅនឹងកន្លែងប៉ងឲ្យជនបរទេសទាំងនោះចេញឲ្យអស់តែម្តង។

ពួកឥស្សរៈវៀតមិញក៏ធ្វើទុក្ខក្រុមគ្រីស្តបរិស័ទខ្មែរនៅតាមខេត្តដែរ ពួកគេធ្វើទុក្ខទាំងអ្នកនៅខាងក្រុមប្រកាសដំណឹងល្អ ទាំងគ្រីស្តបរិស័ទកាតូលិកដែរ។ នៅភូមិភាគសៀមរាប ពួកគេសម្លាប់គ្រូគង្វាល យ៉ាន់ និងចាស់ទុំម្នាក់ឈ្មោះ យៀង។ នៅសម័យនោះលោកវ៉ឺណេ(Venet) ជាបូជាចារ្យទទួលបន្ទុកក្រុមគ្រីស្តបរិស័ទកំពង់គ[៦] ។ ក្នុងឆ្នាំ ១៩៥១ ពេលលោកនៅក្រៅភូមិឈ្មោះ ទ្រី ដែលទទួលបញ្ជាពីមេឥស្សរៈដ៏ល្បីល្បាញ គឺដាបឈួនពានដឹកនាំពួកឥស្ស៊ូមួយក្រុម មានគ្នា ១០០ នាក់ ចូលលុកភូមិ។ ពួកគេវាយកម្ទេចព្រះវិហារវាយបំបែករូបបដិមានៅក្នុងវិហារនោះ និងហែកអាវជាយសម្រាប់បូជាចារ្យចោល។ គ្រូអ៊ុនតា អ៊ឹម សាម៉េត ព្រមទាំងតា សែម យុត ខិតខំតស៊ូ តែត្រូវពួកឥស្សរៈវាយដំយ៉ាងខ្លាំង ហើយអ្នកភូមិខ្លះទៀតត្រូវរបួសធ្ងន់។ អ្នកស្រុកដែលឃើញទិដ្ឋភាពនោះ និយាយថា៖ «ឈាមហូរសស្រាក់ពីច្រមុះ ពីត្រចៀករបស់អ្នកទាំងនោះ»។ គ្រីស្តបរិស័ទឯទៀតៗ បានរួចជីវិតដោយបានរត់ទៅពួនក្នុងគុម្ពប្របុសនៅជុំវិញភូមិ។ ពួកឥស្សរៈទាំងនោះត្រឡប់ចូលមកក្នុងភូមិជិតខាងជាច្រើនដង ប៉ុន្តែឥតមានចូលមកក្នុងកំពង់គទៀតទេ។ ពួកគេគ្រាន់តែប្រាប់គ្រីស្តបរិស័ទឲ្យរត់ចេញពីភូមិ ហើយចូលមកខាងពួកគេ។ ពួកវៀតមិញក៏លាក់ខ្លួននៅក្នុងព្រៃរនាមជិតនោះដែរ ហើយពួកគេតែងខិតខំទាក់ទងជាមួយពួកវៀតណាម ដែលរស់នៅភូមិស្តិបិទមាស ភូមិអូរតាសេក ភូមិបាត់ទូក និងភូមិកលមេឃ។ ពួកវៀតមិញនេះ តែងចាត់អ្នកស៊ើបការទៅភូមិនីមួយៗ ដើម្បីស្តាប់និងយកពត៌មាន។ អភិបាលខេត្តកំពង់ធំកោះហៅមនុស្សប្រុសដប់នាក់ពីភូមិកំពង់ក ទៅក្រុងកំពង់ធំ ដើម្បីបង្ហាត់បង្រៀនអ្នកទាំងនោះឲ្យចេះប្រើអាវុធ។ រួចហើយអាជ្ញាធរប្រគល់ដល់ពួកគេនូវកាំភ្លើងប្រាំដើម គ្រាប់បែកដៃ និងលួសបន្លា ដើម្បីយកទៅរៀបចំជាកងស្វ័យត្រាណការពារភូមិរបស់ខ្លួន។ ប្រុសៗធ្វើការពារថ្ងៃ ហើយយាមពេលយប់។ ថ្ងៃមួយពួកវៀតមិញ ១២ នាក់ បន្លំធ្វើជាអ្នកមករកទិញជ្រូក ហើយក្រសោរយកកាំភ្លើងអស់។

ក្នុងឆ្នាំ ១៩៥១ លោកសាបាល់លីយេ សរសេរដូចជាអស់សង្ឃឹមជាខ្លាំង៖

*«សព្វថ្ងៃនេះ មានតែបណ្តុំគ្រីស្តបរិស័ទនៅភ្នំពេញនិងនៅបាត់ដំបងប៉ុណ្ណោះទេដែលរស់នៅដោយសុខសាន្ត។ ចំណែកនៅកន្លែងដទៃទៀត ពួកវៀតមិញ ពួក*

*ឥស្សរៈ និងពួកចោរប្លន់ ធ្វើឲ្យអ្នកស្រុកភ័យរន្ធត់។ ស្ថានការណ៍សព្វថ្ងៃនេះ បណ្តាលឲ្យជាតិសាសន៍ទាំងពីរកាន់តែមិនចូលចិត្តគ្នាជាខ្លាំងឡើងៗ ខ្ញុំស្ទើរតែហ៊ានថា មានការស្អប់ខ្ពើមគំនុំចងពៀរគ្នាផង»*(៧)។

*«យើងត្រូវភ័យខ្លាចពួកវៀតមិញ ពួកឥស្សរៈ ពួកចោរប្លន់ និងកងទ័ពពេញច្បាប់ទៀតផង។ នៅខាងក្រៅទីក្រុងពិបាកចៀសឲ្យផុតពីគ្រោះថ្នាក់ទាំងនេះណាស់។ មន្ត្រីរដ្ឋការខ្លះចេះគិតគូរ គិតតែខំធ្វើឲ្យប្រទេសរបស់ខ្លួនបានសន្តិភាព។ ផ្ទុយទៅវិញ មានខ្លះទៀតច្បាស់ជាគេពុំចូលចិត្តយើងទេ ពីព្រោះគ្រីស្តបរិស័ទភាគច្រើនជាជនជាតិវៀតណាម ហើយនៅក្នុងចំណោមគ្រីស្តបរិស័ទវៀតណាមនោះ ក៏មានអ្នកចូលចិត្តវៀតមិញថែមទៀតផង។ យើងខ្នះខ្នែងប្រមូលគ្រីស្តបរិស័ទវៀតណាមឲ្យមករស់នៅជុំវិញប៉ុស្តិ៍ទាហាន ដើម្បីនឹងការពារគេឲ្យផុតពីពួកឥស្សរៈ។ ប៉ុន្តែពេលនោះ ជនជាតិខ្មែរឆ្លៀតឱកាសពួកគ្រីស្តបរិស័ទវៀតណាមចេញដូច្នេះក៏នាំគ្នាដណ្តើមយកដីធ្លីរបស់គេអស់តែម្តង»*(៨)។

ក្នុងសេចក្តីរាយការណ៍ឆ្នាំ ១៩៥២ មានចែងថា៖ *"ឆ្នាំនេះសឹងធូន់ធ្ងរ និងតានតឹងណាស់។ មានពាក្យឃោសនាថា៖"ដីខ្មែរត្រូវបានទៅខ្មែរ"។ ការឃោសនានេះ ធ្វើឲ្យស្ថានភាពរបស់ពួកវៀតណាមនៅក្នុងព្រះរាជាចក្រកម្ពុជា លំបាកជាងនៅដែនកូសាំងស៊ីនទៅទៀត។ បណ្តុំគ្រីស្តបរិស័ទចំនួន ១៨ ក្រុមត្រូវគេដេញចេញ តាមបញ្ជាអ្នកកាន់អំណាចទាហាន។ ពួកអ្នកស្រុកចូលកាន់កាប់ដីធ្លី និងផ្ទះសម្បែងគ្រីស្តបរិស័ទទាំងនោះភ្លាម។ លោកសាបាល់លីយេ បានផ្ញើសេចក្តីរាយការណ៍មួយយ៉ាងវែង ទៅថ្វាយព្រះមហាក្សត្រស្តីអំពីស្ថានភាពព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា។ តាំងពីពេលនោះមក រដ្ឋបាលថ្នាក់លើរកយុត្តិធម៌ និងអនុគ្រោះកាន់តែច្រើនឡើង ក៏ប៉ុន្តែ ក្រុមគ្រីស្តបរិស័ទដែលត្រូវគេដេញចេញ នៅតែពុំអាចយកដីជាកម្មសិទ្ធិរបស់ខ្លួនមកវិញបានឡើយ។ ដូច្នេះពួកគេរស់នៅមិនបានដូចធម្មតាឡើយ ហើយយើងក៏ពុំអាចចូលទៅក្រុមគ្រីស្តបរិស័ទនោះបានទៀតផង*(៩)។

ស្ថានភាពនេះមានរហូតមកទល់នឹងថ្ងៃទី ៩ វិច្ឆិការ ឆ្នាំ ១៩៥៣ ជាកាលបរិច្ឆេទដែលប្រទេសបារាំងបញ្ចប់អាណាព្យាបាលរបស់ខ្លួននៅលើប្រទេសកម្ពុជា គឺបន្ទាប់ពី "*រាជបូជនីយកិច្ចទាមទារឯករាជ្យ* " ដឹកនាំដោយព្រះបាទនរោត្តមសីហនុមក។ បន្ទាប់ពីរដ្ឋអំណាចលើកលែងទោសពួកឥស្សរៈជាច្រើនលើកច្រើនគ្រាមក (១៩៤៧ ១៩៤៨ ១៩៤៩

និង១៩៥៤) ព្រះអង្គម្ចាស់នរោត្តមចន្ទរង្សីដែលជាមេឥស្សរៈ ក៏សព្វព្រះហឫទ័យចុះចូលនឹងព្រះបាទនរោត្តមសីហនុ។ ពួកឥស្សរៈឯទៀតៗក៏សុខចិត្តចុះចូលដែរ(១០) ។

កិច្ចព្រមព្រៀងក្រុងហ្សឺណែវ ដែលបានចុះហត្ថលេខា នាថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៥៤ បានបញ្ចប់សង្គ្រាមនៅឥណ្ឌូចិនទៅ។ សន្តិភាពបានកើតមានឡើងវិញនៅប្រទេសកម្ពុជាក្នុងរយៈពេល ១៦ ឆ្នាំ ។

---

(១) សេចក្ដីរាយការណ៍ សរសេរដោយលោក សាបាល់លីយេក្នុង "លិខិតរួម ១៩៤០-៤៥" បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៤៨ ទំព័រ ៧៨។ សេចក្ដីស្រង់យកមកបញ្ជាក់ ដែលមានជាបន្ទាន់ទៅទៀត គឺសុទ្ធតែដកចេញអំពីសេចក្ដីរាយការណ៍ដដែលនេះ។

(២) បន្ទាប់ពីវាយយកប្រទេសកម្ពុជាបាន អ្នកកាន់អំណាចបារាំងក៏សាងវិមានតូចមួយនៅត្រង់កន្លែងសិលាចារិក ដើម្បីរំឭកដល់វិញ្ញាណក្ខន្ធរបស់លោកពីហ្គើល និងរបស់គ្រីស្តទូតបារាំងទាំងឡាយ។

(៣) ប្រទេសបារាំងបានជ្រើសរើសយកព្រះអង្គម្ចាស់នរោត្តមសីហនុ លើកឲ្យឡើងសោយរាជ្យលើប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៤១។

(៤) “Viêt Nam Doc Lap Dong Ming” (Viêt Ming) ឬក៏ថា "*បក្សសម្ព័ន្ធ ដើម្បីឯករាជ្យរបស់ប្រទេសវៀតណាម* "។ បក្សសម្ព័ន្ធនេះប្រមូលផ្ដុំបក្សអ្នកជាតិនិយមជាច្រើន។ ក្នុងចំណោមបក្សទាំងទាំងនោះ បក្សកុម្មុយនិស្តឥណ្ឌូចិនដែលមាន ង្វៀង អាយ កុក (ហូជីមិញ) ជាអ្នកបង្កើតមានសកម្មភាពខ្លាំងជាងគេ ។

(៥) លិខិតរួមឆ្នាំ ១៩៤៩ ទំព័រ ១០៤ ។

(៦) ទេវវិទ្យាល័យនៅក្រុងប៉ារីស យល់ព្រមឲ្យសាសនទូតចំនួន ៣៧ នាក់ ចេញដំណើរទៅឥណ្ឌូចិនក្នុងឋានៈជាបូជាចារ្យទទួលបន្ទុកណែនាំទាហានបារាំង។ នេះជាមធ្យោបាយដើម្បីឲ្យសាសនទូតឆាប់បានចេញដំណើរទៅដែនដីអាស៊ីបាន។ រឿងនេះបណ្ដាលឲ្យមានការឈឺចាប់ច្រើន ហើយសាសនទូតជាច្រើនក៏បោះបង់ចោលមុខងារបូជាចារ្យទៅ។ ក្នុងចំណោមបូជាចារ្យដែលទៅនោះ មានលោករ៉ូប៉ែ វ៉ឺណេ (Robert Venet) ម្នាក់ដែរ។ លោកវ៉ឺណេ និទានថា «*ការបរបាញ់សម្លាប់មនុស្សបែបនេះធ្វើឲ្យខ្ញុំឈឺចាប់ណាស់ ហើយនិងធ្វើឲ្យខ្ញុំពិបាកទ្រាំទ្រណាស់។ ខ្ញុំបានជម្រាបលោកបូជាចារ្យ ជាអគ្គនាយកខ្ញុំ ពីអ្វីៗទាំងអស់ដែលខ្ញុំបានគិត និងបានឃើញ ហើយការនេះធ្វើ*

*ឲ្យខ្ញុំបានធូរទ្រូងខ្លះ។ ខ្ញុំបានរួចផុតពីកំណែនយ៉ាងឆាប់មុនការគ្រោងទុក ខ្ញុំក៏ទៅកាន់ប្រទេសកម្ពុជាភ្លាម។ ចំពោះខ្ញុំ ប្រទេសកម្ពុជា និងជនជាតិខ្មែរ ប្រសើរជាងអ្វីៗទាំងអស់ ហើយខ្ញុំបានប្រកែកពុំព្រមរៀនភាសាវៀតណាមឡើយ។ ដោយខ្ញុំប្រកែកជាញឹកញយពេក ហើយដោយលោកអភិបាលព្រះសហគមន៍សាបាល់លីយេ មិនដឹងរកមធ្យោបាយណាទៀត លោកក៏ចាត់ខ្ញុំឲ្យទៅកំពង់គ។ លោកប្រគល់ក្រុមគ្រីស្តបរិស័ទវៀតណាមបីក្រុម នៅប៉ែកខាងជើងប្រទេសកម្ពុជា ឲ្យខ្ញុំណែនាំ។ ពួកវៀតណាមទាំងនោះ ចេះនិយាយភាសាខ្មែរបានល្អណាស់។ ខ្ញុំបានបង្រៀនកូនក្មេងវៀតណាមឲ្យចេះអានចេះសរសេរ និងចេះសូត្រធម៌ជាខ្មែរ»* ។

(៧) លិខិតរួម ១៩៥០ ទំព័រ ៨៣។

(៨) លិខិតរួម ១៩៥១ ទំព័រ ៨១។

(៩) សេចក្តីរាយការណ៍ឆ្នាំ ១៩៥២ ទំព័រ ៥៣។

(១០) ព្រះបាទនរោត្តមសីហនុ បានតែងតាំងលោកដាបឈួន ជាអភិបាលខេត្តសៀមរាប។ លោកដាបឈួននេះទៅកំពង់ធំ ហើយចាត់គេឲ្យទៅអញ្ជើញលោករ៉ុណេ មកជួបគាត់។ លោកដាបឈួនសុំទោសលោក រ៉ុណេ អំពីអំពើអាក្រក់ដែលកូនចៅគាត់ឈ្មោះទ្រី បានប្រព្រឹត្ត ព្រមទាំងស្នើសងជំងឺចិត្តផង។ លោក រ៉ុណេ ពុំព្រមយកជំងឺចិត្តនោះទេ។

## ជំពូកទី ១១

# គុីរសុតបរិស័ទខុមរណៃនាំពុះហគមន៍បុរចាំបុរទេសកម្ពុជា

ពីឆ្នាំ ១៩៥៣ ដល់ ១៩៧០ សន្តិភាពបានកើតមានឡើងវិញនៅប្រទេសកម្ពុជា។ ជីវភាពរស់នៅរបស់ប្រជាជនតាមស្រែចម្ការមានការរីកចម្រើនជឿនលឿន ហើយប្រែប្រួលម្យ៉ាង គឺមកទល់នឹងសម័យនោះ យុវជននៅប្រទេសកម្ពុជាមិនសូវបានទទួលឥទ្ធិពលពីបស្ចឹមប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនប៉ុន្មានទេ តែក្នុងសម័យថ្មីនេះ ពួកគេចូលចិត្តរស់នៅទីក្រុង ហើយចូលចិត្តរបៀបរស់នៅតាមបែបអ្នកក្រុងផង(១)។

ក្នុងអំឡុង ១៧ ឆ្នាំ សម្តេច នរោត្តម សីហនុ បានកាន់កាប់ព្រះរាជអំណាចដាច់មុខតែមួយព្រះអង្គឯង។ ប្រទេសបារាំងបានលើកព្រះអង្គម្ចាស់ សីហនុ ឲ្យឡើងសោយរាជ្យក្នុងឆ្នាំ ១៩៤១។ នាថ្ងៃទី ២ មីនា ឆ្នាំ ១៩៥៥ ទ្រង់ផ្ទេររាជ្យថ្វាយទៅព្រះបិតា ព្រះនាមព្រះអង្គម្ចាស់សុរាម្រឹត។ ព្រះអង្គម្ចាស់សីហនុឈ្វេងយល់ថា ដោយដាក់រាជ្យយ៉ាងនេះ ទ្រង់នឹងមានសេរីភាពចូលប្រឡូកក្នុងឆាកនយោបាយ។ ព្រះអង្គម្ចាស់ សីហនុ ឲ្យអ្នកស្រុកហៅព្រះអង្គថា "សម្តេចឪ" ហើយទ្រង់ក៏បង្កើតគណៈបក្ស «*សង្គមរាស្ត្រនិយម*» ដែលលេចមុខលេចមាត់ជាងគេ ក្នុងដំណើរនយោបាយរបស់ប្រទេស ក្នុងអំឡុង ១៥ ឆ្នាំ។ បក្សនេះមានប៉ាវចនា «*ជាតិ សាសនា រាជបល្ល័ង្គ*» ដែលជាគ្រឹះដ៏មាំមួននៃរបបនយោបាយនេះ។

អ្នកជាតិនិយមខ្មែរ ដែលទាមទារឯករាជ្យបាននោះ បណ្តាលឲ្យអាណិកជនវៀតណាម (ប្រហែល ៤០០.០០០ នាក់) ដែលរស់នៅក្នុងប្រទេសកម្ពុជាមានការលំបាកកាន់តែខ្លាំងឡើងៗ៖ អាណិកជនវៀតណាមទាំងឡាយត្រូវតែកាន់អត្តសញ្ញាណប័ណ្ណជាជនជាតិបរទេស ដើម្បីមានសិទ្ធិរស់នៅតទៅទៀត និងអាចរកស៊ីក្នុងប្រទេសកម្ពុជាបាន។ ពួកគេក៏ត្រូវបង់ពន្ធផ្ទាល់ខ្លួនប្រចាំឆ្នាំដែរ។ ម្យ៉ាងទៀត អ្នកជាតិនិយមវៀតណាមបាន

ជម្រុញអាណិកជនវៀតណាមដែលរស់នៅប្រទេសកម្ពុជាមួយភាគ ត្រឡប់ទៅកាន់ទឹកដីរបស់ដូនតាខ្លួនវិញ (ចំនួនប្រហែល ២០.០០០នាក់)។ ក្នុងចំណោមអាណិកជនវៀតណាមទាំងនោះ មានអ្នកមានក្របខ័ណ្ឌ និងសិប្បករមួយចំនួនធំផងដែរ។

អ្នកជាតិនិយមខ្មែរខិតខំពង្រឹងព្រះពុទ្ធសាសនាឲ្យចម្រើនលូតលាស់។ របបសង្គមរាស្ត្រនិយមរបស់សម្ដេច សីហនុ មានឈ្មោះថា «*សង្គមនិយមពុទ្ធសាសនា*»។ តែទោះជាយ៉ាងណាក៏ដោយ ក៏សាសនាឯទៀតៗ (អ៊ីស្លាម គ្រីស្ដសាសនា) ត្រូវអាជ្ញាធរអនុញ្ញាតឲ្យបន្តសកម្មភាពដោយអនុគ្រោះដែរ ហើយទំនាក់ទំនងរវាងបរិស័ទរបស់សាសនាផ្សេងៗ សុទ្ធសឹងល្អប្រសើរជាទូទៅ។

ក្នុងឆ្នាំ ១៩៥៩ រាជការអនុញ្ញាតឲ្យយកភាសាខ្មែរទៅប្រើដោយខានពុំបាននៅបឋមសិក្សា ហើយភាសាដទៃទៀតត្រូវហាមដាច់ខាត (គឺភាសាបារាំង វៀតណាម ឬចិន)។ បន្ទាប់មកនៅក្នុងឆ្នាំ ១៩៦៧ រាជការក៏បញ្ជាឲ្យយកភាសាខ្មែរទៅប្រើនៅមធ្យមសិក្សាដែរ ក៏ប៉ុន្តែ ភាសាបារាំងនៅតែជាភាសាសម្រាប់ឧត្តមសិក្សា ដដែល។ គេក៏បញ្ជាឲ្យប្រើភាសាខ្មែរជំនួសភាសាបារាំងនៅក្នុងកិច្ចការរដ្ឋបាលដែរ។ ដូច្នេះហើយ បានជាមានចាត់តាំងគណៈកម្មការជាតិមួយសម្រាប់បង្កើតពាក្យថ្មីៗ កាន់តែច្រើនឡើងៗ ដើម្បីប្រើប្រាស់តាមសេចក្ដីត្រូវការ។ គេបង្កើតពាក្យថ្មីទាំងនោះចេញមកពីភាសាបាលី ឬសំស្ក្រឹត ហើយគណៈកម្មការថ្មីនេះ មានឈ្មោះថា "*គណៈកម្មការខេមរយានកម្ម*"។ ម្យ៉ាងទៀត សម្ដេចមានបំណងចង់ឲ្យជនជាតិខ្មែរទាំងអស់ ចេះអានចេះសរសេរអក្សរជាតិផង ដូច្នេះ នៅចុងឆ្នាំ ១៩៦០ មហាចលនាអនក្ខរកម្មនេះ បានទទួលមេដាយមាសពីអង្គការយូណេស្កូ។

មកទល់នឹងសម័យនោះ កូនខ្មែរជាច្រើន ជាពិសេសក្មេងៗនៅស្រុកស្រែចម្ការទៅរៀននៅសាលាវត្ត រីឯក្មេងៗតាមទីក្រុងខ្លះ បានរៀននៅសាលាមធ្យមសិក្សាខ្លះៗដែលដឹកនាំដោយជនជាតិបារាំង។ ក្នុងសម័យសម្ដេចសីហនុ ក្រសួងអប់រំជាតិមានការរីកចម្រើនលូតលាស់យ៉ាងលឿន។ គេកសាងសាលាបឋមសិក្សា អនុវិទ្យាល័យវិទ្យាល័យ និងសកលវិទ្យាល័យច្រើនសន្ធឹក[២]។ ការរីកច្រើនមធ្យសិក្សា និងឧត្តមសិក្សាបានធ្វើឲ្យវណ្ណៈ"*បញ្ញវន្តផុនស្មើរ*" កើតឡើងតាមពាក្យរបស់សម្ដេចសីហនុផ្ទាល់។ បញ្ញវន្តទាំងនោះរកកន្លែងធ្វើការពុំបានទេ ទាំងក្រសួងរាជការ ទាំងរោងចក្រ ព្រោះនៅប្រទេស

កម្ពុជា ឧស្សាហកម្មមិនទាន់រីកចម្រើនខ្លាំងនៅឡើយទេ។ ម្យ៉ាងទៀត ពួកអ្នករៀនសូត្រទាំងនោះពុំព្រមធ្វើស្រែឡើយ។ ដោយឥតការ ធ្វើដូច្នេះ ពួកគេជាច្រើននាំគ្នាមួម៉ៅ ហើយក៏បណ្ដាលខ្លួនទៅតាមឃោសនារបស់ពួកបដិវត្តន៍។

ក្នុងអំឡុងពេល ១៦ ឆ្នាំ នៃសម័យឯករាជ្យ សេដ្ឋកិច្ចជាតិលូតលាស់ និងរីកចម្រើនយ៉ាងខ្លាំង ដូចក្នុងឆ្នាំ ១៩៦០ ប្រទេសបារាំងបានផ្ដល់ជំនួយឲ្យប្រទេសកម្ពុជាកសាងកំពង់ផែក្រុងព្រះសីហនុ។ តាមរយៈកំពង់ផែនេះ ប្រទេសកម្ពុជាអាចធ្វើជំនួញជាមួយប្រទេសផ្សេងៗទៀតក្នុងពិភពលោកតាមផ្លូវសមុទ្របាន ដោយមិនបាច់ឆ្លងកាត់តាមប្រទេសវៀតណាមដូចពីមុនៗឡើយ។ មានផ្លូវថ្នល់មួយប្រវែង ២៦៧ គ.ម. កសាងឡើងដោយជំនួយសហរដ្ឋអាមេរិក ព្រមទាំងផ្លូវរទេះភ្លើងដោយសារជំនួយបរទេស ជាពិសេសជំនួយពីប្រទេសចិន មានរោងចក្រតម្បាញ រោងចក្រផលិតគ្រឿងបរិភោគ រោងចក្រស៊ីម៉ង់ត៍នៅចក្រីទីង រោងចក្រធ្វើកែវ រោងចក្រធ្វើស្រាបៀរ រោងចក្រចម្រាញ់ប្រេងកាត រោងចក្រធ្វើក្រដា។ល។ ដោយសន្តិភាពមានគ្រប់គ្រាន់ អ្នកស្រែចម្ការអាចប្រកបរបរកសិកម្មបានដោយស្រួល និងផលិតបានភោគផលច្រើនទៀតផង ឈ្មួញក៏ដឹកនាំស្រូវទៅលក់នៅប្រទេសក្រៅកាន់តែច្រើនឡើងៗជាលំដាប់ដែរ។

ក៏ប៉ុន្តែ កម្រិតជីវភាពប្រជាជននៅតាមទីក្រុង និងប្រជាជននៅស្រុកស្រែ ចេះតែឃ្លាតឆ្ងាយពីគ្នា ហើយស្រុកស្រែចម្ការមិនចម្រើនលូតលាស់ ដូចនៅទីក្រុងទេ។ ក្នុងសង្គមខ្មែរលេចចេញការបែងចែកវណ្ណៈ ហើយកម្រិតជីវភាពរស់នៅក៏កាន់តែខុសគ្នាខ្លាំងឡើងថែមទៀត។ អំពើពុករលួយ បញ្ហាបក្សពួកនិយម និងគ្រួសារនិយមហួសហេតុ ក្លាយទៅជាជំងឺស៊ីរូងផ្ទៃក្នុង។

នៅសម័យនោះ ប្រទេសចិន សហភាពសូវៀត និងសហរដ្ឋអាមេរិក ខិតខំលាតសន្ធឹងឥទ្ធិពលរបស់ខ្លួននៅទ្វីបអាស៊ី។ រីឯសម្ដេចសីហនុវិញ ទ្រង់ខ្វល់ខ្វាយតែនឹងធ្វើតាមគោលនយោបាយរបស់ព្រះអង្គ គឺ«*ឯករាជ្យ អព្យាក្រឹត្យ បូរណភាពទឹកដី*»។ អាស្រ័យដោយហេតុនេះ ទោះបីប្រទេសសៀមទាមទារយកទឹកដីខ្មែរ និងទោះបីជាប្រទេសកម្ពុជានៅជាប់ប្រទេសវៀមណាមដែលកំពុងមានសង្គ្រាមក៏ដោយ ក៏ព្រះអង្គបានរក្សាប្រទេសកម្ពុជាឲ្យនៅជា "*កោះសន្តិភាព*" ដែរ។

ប្រទេសថៃនៅតែអាឡោះអាល័យខេត្តបាត់ដំបង សៀមរាប និងឧត្តរមានជ័យ ដែលបារាំងបានបង្ខំឲ្យប្រគល់មកប្រទេសកម្ពុជាវិញ កាលពីឆ្នាំ ១៩៤៦ នោះនៅឡើយ។ ហេតុនេះហើយ បានជាបន្ទាប់ពីគាំទ្រពួកឥស្សរៈកាលពីសម័យមុនៗមក ប្រទេសថៃនៅតែគាំទ្រកងកុម្មង់ដូ "*ខ្មែរសេរី*" ដែលចូលលុកលុយប្រទេសខ្មែរ។ ក្នុងឆ្នាំ ១៩៦២ តុលាការអន្តរជាតិក្រុងឡាអេ (La Haye) បានកាត់ថា ប្រទេសថៃគ្មានសិទ្ធិទាម ទារប្រាសាទព្រះវិហារទៀតឡើយ។ គ្រានោះ ប្រទេសថៃ និងប្រទេសកម្ពុជាក៏ផ្តាច់ទំនាក់ទំនងទូតទៅ។

នៅប្រទេសវៀតណាម នាចុងឆ្នាំ ១៩៦០ ភាពវឹកវរចលាចលបានកើតមានឡើងសាជាថ្មី។ ពួក "*វៀតកុង* " គឺពួកកុម្មុយនិស្តវៀតណាមខាងត្បូង ចាប់ផ្តើមវាយប្រឆាំងអ្នកកាន់អំណាចខាងត្បូង(៣) ។ អ្នកកាន់អំណាចវៀតណាមខាងត្បូងសុំជំនួយពីសហរដ្ឋអាមេរិក ឲ្យមកជួយតទល់នឹងពួកកុម្មុនីស្ត។ ចំណែកឯប្រទេសវៀតណាមខាងជើងដែលមានប្រទេសចិន និងសហភាពសូវៀតជួយគាំទ្រផង ក៏ចូលទៅជួយពួកវៀតកុងដែលនៅវៀតណាមខាងត្បូង។ នៅឆ្នាំ ១៩៦០ សង្គ្រាមផ្ទុះឡើងជាថ្មី។ ពួកទាហានអាមេរិកមានបំណងជម្រុញរដ្ឋាភិបាលប្រទេសកម្ពុជា ឲ្យចូលខាងពួកគេ ក៏ប៉ុន្តែសម្តេចសីហនុ ប្រកែកពុំព្រមចូលជាមួយ អាមេរិកកាំងជាដាច់ខាត។ ព្រះអង្គមានព្រះបន្ទូលថា៖ «*ពួកអាមេរិកកាំងទាក់ទាញពួកកុម្មុនីស្ត ដូចស្ករនិងស្រមោច*»។ ក្នុងឆ្នាំ ១៩៦៣ ទ្រង់ផ្តាច់ចំណងទូតជាមួយសហរដ្ឋអាមេរិក ហើយនិងជាមួយប្រទេសវៀតណាមខាងត្បូង។ កងទ័ពអាមេរិក និងវៀតណាមខាងត្បូងក៏គាំទ្រពួក "ខ្មែរសេរី" ដើម្បីវាយប្រហារប្រទេសកម្ពុជាដែរ។ ក្នុងឆ្នាំ ១៩៦៥ ទ្រង់ទាត់ជំនួយសហរដ្ឋអាមេរិកចោល។ ផ្ទុយទៅវិញ ទ្រង់អនុញ្ញាតឲ្យទាហានវៀតណាមខាងជើងតាំងទីជម្រកនៅក្នុងទឹកដីខ្មែរតាមបណ្តោយព្រំប្រទល់ខ្មែរ វៀតណាម។ ព្រះអង្គធ្វើដូច្នេះ ស្របទៅតាមគោលការណ៍ "*អព្យាក្រឹតសកម្ម* " របស់ព្រះអង្គ។ ព្រះអង្គអនុញ្ញាតឲ្យចិន និងសូវៀតដឹកអាវុធកាត់ប្រទេសកម្ពុជា តាមកំពង់ផែក្រុងព្រះសីហនុ ទៅឲ្យទាហានវៀតកុងនិងវៀតណាមខាងជើង។ រដ្ឋាភិបាលខ្មែរយកពន្ធពីការដឹកឆ្លងកាត់នេះ។ ចំណូលប្រាក់ដែលបានមកពីការហូតពន្ធនេះ សម្តេចយកទៅជួយផ្គត់ផ្គង់រដ្ឋាភិបាលដែលមានការខ្វះខាតថវិកាបន្ទាប់ពីទាត់ជំនួយអាមេរិកកាំងចោលទៅនោះ។ ចាប់តាំងឆ្នាំ ១៩៦៩ មក យន្តហោះអាមេរិកកាំង ទម្លាក់គ្រាប់បែក ទៅលើទីជម្រកនានារបស់កងទ័ពវៀតកុង នៅប្រទេសកម្ពុជា តាមសេចក្តីសុំរបស់សម្តេច សីហនុ។

នៅខាងក្នុងប្រទេស មានបក្សពីរប្រភេទជំទាស់នឹងសម្តេចនរោត្តមសីហនុ។ ពួកខាងឆ្វេងមាន "*ប្រជាជន*" ដែលប្រមូលផ្តុំអតីតខ្មែរវៀតមិញ ព្រមទាំងពួកបញ្ញវន្តខាងឆ្វេងដែលបានទទួលការអប់រំនៅក្រុងប៉ារីស[៤]។ ចាប់តាំងពីឆ្នាំ ១៩៦២ មក ក្រុមនគរបាលបានដេញតាមពួកអ្នកដឹកនាំបក្សខាងឆ្វេង ហើយសមាជិកខ្លះនៃបក្សនេះបានរត់ចូលព្រៃ។ សម្តេច សីហនុ ហៅពួកខាងឆ្វេងថា "*ខ្មែរក្រហម*"។ ពួកខ្មែរក្រហមទាំងនោះ តែងអប់រំប្រជាជនស្រុកស្រែចម្ការឲ្យភ្ញាក់ស្មារតី។ ចាប់ពីឆ្នាំ ១៩៦៧ មក ពួកគេនាំគ្នាបះបោរវាយកងយោធពលខេមរភូមិន្ទ ក្នុងភូមិភាគបាត់ដំបង កំពង់ចាម និងរតនគីរី។

មានបក្សជំទាស់មួយប្រភេទទៀត គឺពួកខាងស្តាំ ដែលប្រមូលផ្តុំអ្នកនយោបាយ និងពួកអ្នកជំនួញ ដែលពិបាកទ្រាំទ្រនឹងអំណាចផ្តាច់ការរបស់សម្តេច សីហនុ។ ជាពិសេសពួកគេពិបាកទ្រាំទ្រ នឹងសម្តេច សីហនុ ដែលអនុញ្ញាតឲ្យពួកវៀតកុង កាន់កាប់ទឹកដីខ្មែរមួយចំណែក។ ម្យ៉ាងទៀត ពួកគេក៏នឹកស្តាយជំនួយពីសហរដ្ឋអាមេរិក ដែលសម្តេចបានទាត់ចោលនោះដែរ។ ដោយមានមេទាហានអាមេរិក នៅព្រៃនគរ ជួយគាំទ្រដោយលួចលាក់ រដ្ឋសភាខ្មែរបានទម្លាក់សម្តេច សីហនុ ចេញពីមុខតំណែង នាថ្ងៃ ១៣ មីនា ឆ្នាំ ១៩៧០[៥]។ ប្រទេសកម្ពុជាក៏លិចស្រឹមទៅក្នុងសង្គ្រាម។

## អភិបាលព្រះសហគមន៍នៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាបានឯករាជ្យនៅថ្ងៃ ៩ វិច្ឆិការ ឆ្នាំ ១៩៥៣ ពីរឆ្នាំក្រោយមក គឺនៅថ្ងៃទី ២០ កញ្ញា ឆ្នាំ ១៩៥៥ សម្តេចប៉ាបបានផ្តាច់ខេត្តកូសាំងស៊ីន ចេញអំពីការត្រួតត្រារបស់លោកអភិបាលព្រះសហគមន៍កម្ពុជា។ ចាប់ពីពេលនោះមក លោកអភិបាលព្រះសហគមន៍កម្ពុជា មានបន្ទុកណែនាំគ្រីស្តបរិស័ទត្រឹមតែ ក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ។ បានសេចក្តីថា មណ្ឌលលោកត្រួតត្រានោះ រួញមកនៅតែពាក់កណ្តាល ហើយចំនួនគ្រីស្តបរិស័ទនៅសល់ស្ទើរតែពុំបានមួយភាគបីនៃចំនួនទាំងអស់ផង។ បើនិយាយអំពីចំនួនបូជាចារ្យដែលកើតក្នុងស្រុកវិញ គឺមិនបានដល់ពាក់កណ្តាលនៃចំនួនបូជាចារ្យទាំងអស់ទេ ហើយសុទ្ធតែជនជាតិវៀតណាមថែមទៀត[៦]។ បន្ទាប់ពីប្រទេសវៀតណាមបានឯករាជ្យមក មានបូជាចារ្យវៀតណាមចំនួន ១៣ នាក់ ដែលមានចិត្តគំនិតជាអ្នកជាតិនិយមត្រឡប់ទៅមាតុភូមិប្រទេសវិញ ដោយនាំទាំងគ្រីស្តបរិស័ទវៀតណាមរាប់ពាន់នាក់ទៅជាមួយផង។

ការកម្រិតព្រំដែនថ្មីនេះ បាននាំឲ្យព្រះសហគមន៍ប្រទេសកម្ពុជាភ្ញាក់ស្មារតី ដូចលោក រ៉ាបាល់ឡង់ (Raballand) ដែលជាអភិបាលព្រះសហគមន៍ថ្មីសរសេរថា៖

*«ឥឡូវនេះ យើងមានភារកិច្ចប្រកាសដំណឹងល្អសម្រាប់តែប្រជាជនខ្មែរប៉ុណ្ណោះ។ យើងត្រូវ តែខិតខំទៅរកប្រជាជនខ្មែរ ដោយពុំមានធ្វេសប្រហែសឡើយ»*[៧] ។

តាមស្ថានការណ៍នយោបាយថ្មីនេះ ជនជាតិវៀតណាមពិបាកធ្វើដំណើរទៅប្រទេសកម្ពុជាណាស់។ ដូច្នេះហើយ បានជាស្ថាប័នព្រះសហគមន៍កម្ពុជាទាំងប៉ុន្មានដែលនៅដែនកូសាំងស៊ីនក៏ត្រូវផ្លាស់មកតាំងនៅប្រទេសកម្ពុជាវិញ។ ឧទាហរណ៍ក្នុងឆ្នាំ ១៩៦១ ពួកបងស្រីនៃក្រុមគ្រួសារព្រះឧបការគុណដែលរស់នៅប្រទេសកម្ពុជា បានក្លាយទៅជាក្រុមគ្រួសារដែលមានសិទ្ធិពេញលេញដាច់ចេញពីពួកអ្នកដឹកនាំនៅប្រទេសវៀតណាម។ បងស្រី ម៉ារីអាឡូឌីនិក (Mari Alodie Nicq) បានទទួលភារកិច្ចជានាយកទីមួយនៃក្រុមគ្រួសារនេះប្រចាំប្រទេសកម្ពុជា។

## អ្នកទទួលខុសត្រូវជាតិខ្មែរចោប់ផ្តើមលេចមុខលេចមាត់

ថ្ងៃទី ៧ វិច្ឆិកា ឆ្នាំ ១៩៧៥ នាព្រះវិសាលវិហារភ្នំពេញដែលគេទើបនឹងសង់រួចថ្មីៗ[៨] មានប្រារព្ធពិធីតែងតាំងបូជាចារ្យខ្មែរមួយនាក់ គឺលោក ស៊ីម៉ុង ឆែម យ៉េន។ លោកជាបូជាចារ្យខ្មែរដំបូងគេបង្អស់ក្នុងប្រវិត្តិព្រះសហគមន៍កាតូលិកតាំងពីដើមរៀងមក។ លោក យ៉េន កើតឆ្នាំ ១៩២៨ នៅខេត្តបាត់ដំបង ក្នុងត្រកូលគ្រីស្តបរិស័ទក្រីក្រ។ ពេលលោកទទួលបុណ្យជ្រមុជទឹក លោកទទួលនាមថា "*ស៊ីម៉ុង* "។ លោកជាបុត្រទីពីរក្នុងគ្រួសារមួយដែលមានកូនប្រាំនាក់។ កាលនៅក្មេង កុមារនេះបានរៀនចិញ្ចឹមលលក និងនេសាទត្រី ព្រោះឪពុកមានមុខរបរជាអ្នកនេសាទ។ កាលអាយុបាន ៧ ឆ្នាំ កុមារ យ៉េនរៀនភាសាវៀតណាមជាមួយនឹងពួកដូនជីក្រុមឧបការគុណ ដែលមើលការខុសត្រូវនៅមន្ទីរពេទ្យកូនកំព្រាជិតផ្ទះគាត់។ កុមារយ៉េន រៀនភាសាវៀតណាមដូច្នេះ ដើម្បីឲ្យមានសមត្ថភាពអាចទៅបន្តការសិក្សានៅអនុវិទ្យាល័យ គូឡាវយៀង នាដែនកូសាំងស៊ីនបាន។ ក្នុងឆ្នាំ ១៩៣៩ លោកហ្គេតឺឡេ (Gâtelet) ដែលជាបូជាចារ្យណែនាំក្រុមគ្រីស្តបរិស័ទនៅបាត់ដំបង បានជ្រើសរើសកុមារនេះ និងគូកនប្រាមួយនាក់ទៀត ឲ្យទៅរៀននៅគូឡាវយៀង។ នៅសាលានោះ មានកូនខ្មែរដែលកើតនៅដែនកូសាំងស៊ីនពីរ បីនាក់ដែរ។ ដោយមាន

សិស្សវៀតណាមច្រើនលើសលុប កុមារយ៉េន ត្រូវផ្លាស់ខោអាវខ្មែរ បែរទៅពាក់អាវផាយតាមរបៀបជនជាតិវៀតណាម ហើយត្រូវនិយាយតែភាសាវៀតណាមប៉ុណ្ណោះ។ លោកសាបាល់លីយេដែលជាអភិបាល ព្រះសហគមន៍ភ្នំពេញ ហើយដែលមាន "*ចិត្តជាខ្មែរ*" ពេលអញ្ជើញមកសាលានោះម្តងៗ លោកតែងប្រជុំកូនខ្មែរ ដើម្បីនិយាយសំណេះសំណាលដោយចិត្តប្រោសប្រណីដ៏ជ្រាលជ្រៅ។

ក្នុងឆ្នាំ ១៩៤៥ ពួកវៀតមិញបានដុតអនុវិទ្យាល័យនេះចោល។ កុមារយ៉េន ក៏មករៀននៅក្រុងភ្នំពេញ ព្រោះលោក សាបាល់លីយេ បានតាំងអនុវិទ្យាល័យនៅភ្នំពេញវិញ។ បីបួនឆ្នាំក្រោយមក គូកនដែលរៀនជាមួយកុមារយ៉េន ចាកចោលអនុវិទ្យាល័យដោយចិត្តឯង ព្រោះមានហេតុផ្ទាល់ខ្លួន។ កូនសិស្សមួយចំនួនទៀត ដែលចង់បន្តការសិក្សាទៅមុខ ត្រូវគេដេញចេញពីសាលា ព្រោះមានការប៉ះទង្គិចសៅហ្មងជាមួយនឹងសិស្សវៀតណាម ដែលរៀនជាមួយគ្នា។

ដូច្នេះលោកសាបាល់លីយេ បានកត់សម្គាល់ឃើញថា "*នៅប្រទេសកម្ពុជា ការអប់រំយុវជនខ្មែរឲ្យទៅ ជាបូជាចារ្យពុំកើតទេ*»។ គ្មាននរណាអាចអប់រំសិស្សខ្មែរជាមួយសិស្សវៀតណាមបានឡើយ ព្រោះចិត្តគំនិតខ្មែរ និងកូនវៀតណាម ខុសគ្នាឆ្ងាយណាស់ ហើយចេះតែប៉ះទង្គិចគ្នា។ អាស្រ័យហេតុនេះហើយ បានជាលោកអភិបាលសម្រេចចិត្តបញ្ជូនយុវជនខ្មែរ ដែលចង់ទៅជាបូជាចារ្យឲ្យទៅរៀននៅស្រុកបារាំង នាក្រុងម៉ុងប៉ីលីយេ (Montpellier) ព្រោះលោកស្គាល់អ្នកណែនាំព្រះសហគមន៍នៅទីនោះ។ ដូច្នេះនៅឆ្នាំ ១៩៤៧ យុវជនយ៉េនក៏ទៅរៀននៅក្នុងអនុវិទ្យាល័យសាំងរ៉ូក (Petit Séminaire Saint Roch) នាក្រុងម៉ុងប៉ីលីយេ។

នៅទីនោះ មានកូនខ្មែរម្នាក់ទៀតចូលមករៀនជាមួយដែរ គឺកុមារប៉ូលទេពអ៊ីមដែលចាប់ផ្តើមរៀនពី ថ្នាក់ទី ៧។ យុវជន ប៉ូលទេពអ៊ីម ជាកូនរបស់គ្រូពេទ្យខ្មែរម្នាក់ម្តាយជាកូនកាត់បារាំង វៀតណាម។ ពេលកុមារនេះអាយុ ១៣ ឆ្នាំ គេឲ្យទៅចូលរួមក្នុងការប្រជុំកាយរឹទ្ធិអន្តរជាតិ នៅម៉ូរសង់ (Moissan)។ ក្នុងពេលប្រជុំនោះ កុមារអ៊ីម ប្រាប់ថា«*ខ្ញុំប្រាថ្នាចង់ធ្វើជាបូជាចារ្យ*» ហេតុនេះហើយ បានជាគេបញ្ជូនកុមារប៉ូល អ៊ីម ឲ្យទៅរៀនជាមួយស៊ីម៉ុងឆែមយ៉េន។ បន្ទាប់មក អនុវិទ្យាល័យសាំងរ៉ូកបានទទួលយុវជនខ្មែរជាច្រើនទៀត មានជាអាទិ៍ លោក យ៉ូសែប ឆ្មារសាឡាស់ដែលបានមករៀននៅឆ្នាំ ១៩៥២។

យុវជន ស៊ីម៉ុង ឆែម យ៉េន បានប្រឡងជាប់មធ្យមសិក្សាប័ត្រ គឺជាស្នាដៃដ៏ប្រសើរដែលខ្មែរមិនសូវមាននៅសម័យនោះ។ យុវជន យ៉េន ក៏បន្តការសិក្សាផ្នែកទស្សនវិជ្ជានិងទេវវិទ្យា នៅទេវវិទ្យាល័ អ៊ីស៊ីឡេមូលីណូ (Grand Séminaire d'Issy les Moulineaux) ជិតក្រុងប៉ារីស។ ពេលសិក្សាចង់ហើយ លោកយ៉េន ត្រឡប់មកប្រទេសកម្ពុជាវិញ ហើយលោកសាបាល់លីយេ តែងតាំងលោកជាបូជាចារ្យ គឺជាបូជាចារ្យខ្មែរដើមដំបូងគេបង្អស់។

លោកប៉ូល ទេពអ៊ីម និងលោកយ៉ូសែប ឆ្មារសាឡាស់ បានសិក្សាតាមរបៀបដដែល។ ក៏ប៉ុន្តែ បន្ទាប់ពីលោកប៉ូល ទេពអ៊ីមបានទទួលមុខងារជាបូជាចារ្យ នៅឯមហាវិសាលវិហារក្រុងប៉ារីស ក្នុងឆ្នាំ ១៩៥៩ មក លោកទៅបន្តការសិក្សាទេវវិទ្យា នៅសកលវិទ្យាល័យអង់ហ្សេលីគូម ក្រុងរ៉ូម (Université Angelicum de Rome) ហើយលោកវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ ១៩៦២។ លោកយ៉ូសែប ឆ្មារសាឡាស់ ដែលមានអាយុតិចជាងលោក ប៉ូលទេពអ៊ីម ៥ ឆ្នាំ ទទួលការតែងតាំងជាបូជាចារ្យនៅឆ្នាំ ១៩៦៤ ។ ប្អូនប្រុសរបស់លោក សាឡាស់ ឈ្មោះ យ៉ូសែប ឆ្មារសាឡឹម បានរៀននៅប្រទេសកម្ពុជារហូតចង់មធ្យមសិក្សា រួចក៏ទៅបន្តការសិក្សាខាងផ្នែកទស្សនវិជ្ជានិងទេវវិទ្យា នៅអ៊ីស៊ី ឡេម៉ូលីណូដូចបងៗដែរ។ លោកសាឡឹម បានទៅជាបូជាចារ្យ នៅឆ្នាំ ១៩៦៧។ បងប្អូន ឆ្មារសាឡាស់ និងសាឡឹម ទាំងពីរនាក់នេះកើតនៅភ្នំពេញ។ ឪពុកម្ដាយលោកជាគ្រីស្ដបរិស័ទខ្មែរមានដើមកំណើតនៅភូមិមាត់ក្រសាស់។

ចំណែកឯសិស្សវៀតណាម ដែលកើតនៅស្រុកខ្មែរវិញ ពួកគេទទួលការអប់រំនៅឯទេវវិទ្យាល័យព្រៃនគរ។ តាំងពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៦៤ មានសិស្សវៀតណាមបួននាក់បានទៅជាបូជាចារ្យ។ ចាប់ពីឆ្នាំ ១៩៦៤ មក ដោយស្ថានការណ៍នយោបាយតានតឹងពិបាកចេញចូលទៅប្រទេសវៀតណាម  សិស្សវៀតណាមដែនៅប្រទេសកម្ពុជាទទួលការអប់រំនៅភ្នំពេញតែម្ដង។ ជាដំបូងសិស្សទាំងនោះ រៀននៅក្នុងគេហដ្ឋានរបស់លោកអភិបាល រួចទៅរៀននៅទេវវិទ្យាល័យថ្មី ដែលបានសង់រួចក្នុងខែមីនា ឆ្នាំ ១៩៦៦។ សិស្សវៀតណាមពីរនាក់ និងសិស្សចិនម្នាក់ បានទទួលការតែងតាំងជាបូជាចារ្យ ក្នុងឆ្នាំ ១៩៦៩។ សិស្សខ្មែរម្នាក់ឈ្មោះ ម៉ារសែល ទ្រឿង ចំរើន ដែលជាចៅរបស់មន្ត្រីខ្មែរម្នាក់នៅដែនកូសាំងស៊ីនបានទៅរៀននៅទេវវិទ្យាល័យ ប៉េណាង (Pénang) នាប្រទេសម៉ាឡេស៊ី។ លោកទ្រឿង ចំរើន

បានទទួលការតែងតាំងជាបូជាចារ្យនៅភ្នំពេញ ក្នុងឆ្នាំ ១៩៧៣ ។

លោកអភិបាលក៏ខិតខំឲ្យគ្រីស្តបរិស័ទមានសមត្ថភាព អាចបំពេញភារកិច្ចផ្សេងៗជាចាំបាច់ក្នុងព្រះសហគមន៍ដែរ។ សាលាអប់រំគ្រូបង្រៀនលទ្ធិគ្រីស្តសាសនានៅបាណាម បានប្រែក្លាយទៅជាក្រុមគ្រួសារបព្វជិត ដែលមានតែជនជាតិវៀតណាមប៉ុណ្ណោះ។ ដូច្នេះហើយបានជាក្នុងឆ្នាំ ១៩៦៥ លោករ៉េ ម៉ុងគូអ៊ែរ៉ុង (Raymond Cauëron) និងលោកយ៉ូសែប ឆ្មារសាឡាស់បានបង្កើតសាលាអប់រំគ្រូបង្រៀនលទ្ធិគ្រីស្តសាសនាមួយនៅបាត់ដំបងសម្រាប់យុវជនខ្មែរ។ យុវជនទាំងនោះរៀនព្រះគម្ពីរ រៀនគរុកោសល្យ និងរៀនសីលធម៌ផង។ កាលរៀនបានពីរអាទិត្យហើយ យុវជនទាំងនោះត្រឡប់ទៅភូមិកំណើតដើម្បីអនុវត្តតាមការរៀនសូត្ររបស់ខ្លួន។ លោកបូជាចារ្យទាំងពីរចាប់ផ្តើមអប់រំយុវជនខ្មែរបួននាក់រហូតបានចប់មួយវគ្គ រួចនៅក្នុងឆ្នាំបន្ទាប់មក ទើបលោកបន្តអប់រំយុវជនប្រាំមួយនាក់ទៀត។

នៅមង្គលបុរី កំពត ភ្នំពេញ មានបើកសាលាសម្រាប់អប់រំយុវនារីខ្មែរដែលរស់នៅស្រុកស្រែចម្ការ។ គេបង្រៀនយុវនារីទាំងនោះឲ្យចេះធ្វើម្ហូបអាហារ ចេះអនាម័យសម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារ ព្រមទាំងបង្រៀនឲ្យចេះវិជ្ជាទូទៅផង។ នារីគ្រីស្តបរិស័ទជាច្រើននាក់ ដែលបានរៀននៅសាលាទាំងនោះ បានទៅជាអ្នកអប់រំជំនឿគ្រីស្តសាសនា។ នៅពេលក្រោយមក សមាគម "*គ្លែរឡូហ្សី*" (Clair Logis) ទទួលបន្ទុកអប់រំយុវនារីខ្មែរនៅជ្រោយចង្វារជិតភ្នំពេញ[៩] ។

**បូជាចារ្យខ្មែរទទួលការខុសត្រូវលើព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា**

លោកអ៊ីវ៉ាមូស ជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជាបន្តពីលោក ប៉ាបាល់ឡង់។ ក្នុងឆ្នាំ ១៩៦៧ លោកអភិបាលប្រគល់ក្រុមគ្រីស្តបរិស័ទខ្មែរធំៗពីរឲ្យបូជាចារ្យខ្មែរណែនាំ គឺលោកប៉ូល ទេពអ៊ីម ទទួលបន្ទុកណែនាំក្រុមគ្រីស្តបរិស័ទភូមិ "*ព្រះមាតា*" នៅភ្នំពេញ និងលោកស៊ីម៉ុង ឆែមយ៉េន ទទួលបន្ទុកណែនាំក្រុមគ្រីស្តបរិស័ទនៅបាត់ដំបង។ បូជាចារ្យទាំងពីរនាក់នេះ មានដើមកំណើតពីក្រុមគ្រីស្តបរិស័ទ ដែលលោកត្រូវណែនាំតែម្តង។ ក៏ប៉ុន្តែ "*តាមធម្មតា មិនដែលមានព្យាការីនាម្នាក់ត្រូវគេគោរពក្នុងស្រុកកំណើតរបស់ខ្លួនឡើយ* " ។ រឿងគ្រួសារធ្វើឲ្យភារកិច្ចរបស់បូជាចារ្យទាំងពីរនោះ ជួបនឹងឧបសគ្គជាច្រើន។

លោក វ៉ាមូស មានបំណងចង់ឲ្យជនជាតិខ្មែរណែនាំព្រះសហគមន៍ និងចង់ឲ្យកិច្ចការប្រកាសដំណឹងល្អ មានកការសម្របសម្រួលកាន់តែល្អប្រសើរឡើងៗនៅទូទាំងប្រទេស។ ដូច្នេះហើយ បានជាក្នុងឆ្នាំ ១៩៦៨ លោកសុំសម្ដេចប៉ាបបំបែកព្រះសហគមន៍នៅប្រទេសកម្ពុជាជាបីមណ្ឌល។ មណ្ឌលភ្នំពេញស្ថិតនៅក្រោមការដឹកនាំរបស់លោកវ៉ាមូសដដែល។ មណ្ឌលនេះមានខេត្តកណ្ដាល កំពង់ស្ពឺ តាកែវ កំពត កំពង់សោម កោះកុង។ មណ្ឌលទីពីរ មានខេត្តបាត់ដំបង កំពង់ឆ្នាំង ពោធិសាត់ ឧត្ដរមានជ័យ ព្រះវិហារ សៀមរាប និងខេត្តកំពង់ធំ។ លោកប៉ូលទេពអ៊ីមសុត្ថា ទទួលបន្ទុកណែនាំព្រះសហគមន៍នៅបាត់ដំបងនេះ[១០] ។ មណ្ឌលទីបី លាតសន្ធឹងទៅលើខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង ក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី។ មណ្ឌលនេះណែនាំដោយលោក អង់ដ្រេ ឡឺស៊ូអែហ្វ (André Laesouëf) ដែលមានទីស្នាក់ការនៅក្រុងកំពង់ចាម។ មណ្ឌលទាំងបីនោះមានចំនួនប្រជាជនប្រហែលគ្នា គឺប្រហែលពីរលាននាក់ក្នុងមណ្ឌលនីមួយៗ។ មណ្ឌលភ្នំពេញមានគ្រីស្តបរិស័ទ ប្រហែលពីរពាន់នាក់ និងបូជាចារ្យម្ភៃនាក់។ មណ្ឌលបាត់ដំបងមានគ្រីស្តបរិស័ទប្រហែលមួយម៉ឺននាក់ និងបូជាចារ្យប្រាំបីនាក់។ មណ្ឌលកំពង់ចាមមានគ្រីស្តបរិស័ទប្រហែលពីរម៉ឺននាក់ និងបូជាចារ្យដប់ប្រាំនាក់។

ម៉្យាងទៀត ដើម្បីឲ្យស្របទៅតាមគោលសំខាន់ៗចេញពីមហាសន្និបាតវ៉ាទីកង់ទី ២ នាឆ្នាំ ១៩៦៤ លោក វ៉ាមូស និងលោកអភិបាលព្រះសហគមន៍ទាំងបួននាក់ នៃប្រទេសលាវ (វៀងចន្ទ ហ្លួង ព្រះបាង ថាខែក និងប៉ាក់សេ) រួបរួមគ្នាជា «*ក្រុមអភិបាលព្រះសហគមន៍ប្រទេសកម្ពុជាលាវ* » ។ ការរួបរួមនេះផ្ដល់ឲ្យលោកអភិបាលទាំងប្រាំនាក់មានលទ្ធភាពពិចារណារួមគ្នា អំពីបញ្ហាណែនាំព្រះសហគមន៍ និងប្រជាពលរដ្ឋដែលមានវប្បធម៌ប្រហាក់ប្រហែលគ្នា។

***

បន្ទាប់ពីស្ថិតនៅក្រោមអាណាព្យាបាលបារាំងអស់រយៈពេល ៩០ឆ្នាំមក ប្រទេសកម្ពុជាបានទទួលឯករាជ្យ។ ព្រះសហគមន៍ប្រទេសកម្ពុជាមានជនជាតិខ្មែរទទួលខុសត្រូវកាន់តែច្រើនឡើងៗជាលំដាប់ បានសេចក្ដីថា ព្រះសហគមន៍នេះរឹងដៃរឹងជើងហើយ។ ព្រះសហគមន៍ប្រទេសកម្ពុជា ក៏ខិតខំធ្វើតាមគោលការណ៍សំខាន់ៗ ដែលចេញពីមហាសន្និបាតវ៉ាទីកង់ទី ២ ថែមទៀត។ មហាសន្និបាតនោះ បានប្រកាសថា៖ «*ព្រះសហគមន៍*

*មានគ្រឹះមាំពិតប្រាកដក្នុងស្រុកមួយ លុះត្រាតែមានអភិបាល មានបូជាចារ្យ និងមាន ឧបដ្ឋាក ចេញពីព្រះសហគមន៍ប្រចាំស្រុកនោះតែម្តង ពោលគឺឲ្យមានអស់លោកដែល ស្ម័គ្របម្រើបងប្អូនរបស់ខ្លួន។ យ៉ាងនេះហើយព្រះសហគមន៍ថ្មីថ្មោកអាចទទួលខុស ត្រូវដោយខ្លួនឯងហើយមានក្រុមបូជាចារ្យរបស់ខ្លួនផ្ទាល់»*(១១) ។

លោកអភិបាលបានអប់រំគ្រីស្តបរិស័ទ ដែលរស់នៅប្រទេសកម្ពុជាទាំងអស់ ឲ្យសុខ ចិត្តទទួលខុសត្រូវ លើព្រះសហគមន៍ដែរ។ គ្រីស្តបរិស័ទទាំងនោះ ខិតខំសម្តែងជំនឿ របស់ខ្លួនឲ្យបានស្របទៅតាមវប្បធម៌ និងប្រពៃណីជាតិផង។

---

(១) ក្នុងឆ្នាំ ១៩៧០ អ្នកបច្ចេកទេសស្មានថា ប្រជាជនប្រទេសកម្ពុជាមានចំនួន ៨លាននាក់។ ៨០% នៃប្រជាជនជាអ្នកធ្វើស្រែចម្ការ។ ក្រុងភ្នំពេញមានមនុស្សចំនួន ៦០០.០០០ នាក់។ ក្រុងឯទៀតៗ មាន ប្រហែល ២០០.០០០ នាក់។ គ្រានោះ ប្រជាជនចំនួនពាក់កណ្តាលមានអាយុតិចជាងម្ភៃឆ្នាំ។ ប្រជាជននេះកើនចំនួនឡើង ២,១% ក្នុងមួយឆ្នាំ។ តាំងពីបានឯករាជ្យមក ក្រុងទាំងឡាយចេះតែ ទាក់ទាញប្រជាពលរដ្ឋឲ្យចូលមករស់នៅ ហើយចេះតែរីកធំឡើង។ ចំពោះបញ្ហាប្រជាជននេះ សូមមើលសៀវភៅរបស់លោកមីកូស៊ី (J. Migozzi, “Cambodge: faits et problèmes de Population”, Paris 1973.

(២) តាមស្ថិតិផ្លូវការប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៦៦ មានក្មេងអាយុពី ៦ ទៅ ១១ ឆ្នាំ ចំនួន ១.១៧៤.០០០ នាក់។ មានក្មេង ៨៤៦.១៨១ នាក់ (គឺ ៧២%) រៀននៅក្នុងសាលាបឋមសិក្សារដ្ឋ ៣.៧២០ សាលា និងក្នុងសាលាឯកជន ៣៤២ សាលា។ វិទ្យាល័យ និងអនុវិទ្យាល័យមានចំនួន ១៥០ គ្រូបង្រៀន ចំនួន ៣.៣៥៤ នាក់ និងសិស្សចំនួន ៨៧.៧២៧ នាក់ (ក្នុងចំណោមយុវជនទាំងអស់ ពីអាយុ ១២ ទៅ ១៨ ឆ្នាំ មានចំនួន ១.០៩៥.១០២) ។ ផ្នែកឧត្តមសិក្សាមានមហាវិទ្យាល័យ ចំនួន ៣៧ និស្សិត ចំនួន ៧.៦៦០ នាក់ និងសាស្ត្រាចារ្យចំនួន ៨១៤ នាក់។

(៣) ក្នុងពេលធ្វើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ គេបានចែកប្រទេសវៀតណាមជាពីរ គឺប្រទេសវៀតណាមខាងជើង ជាប្រទេសកុម្មុយនិស្ត មានហាណូយជារដ្ឋធានី។ ប្រទេសវៀតណាម ខាងត្បូងនៅខាងលោកសេរី មានព្រៃនគរជារដ្ឋធានី។

(៤) គេចាត់លោក ទូ សាមុត ទុកជាអ្នកបង្កើតបក្សកុម្មុយនិស្តកម្ពុជា ជាបក្សកើតឡើងនៅប្រទេសខ្មែរស្របតាមឥទ្ធិពលរបស់ពួកកុម្មុយនិស្តវៀតណាម។ លោក ទូ សាមុត បាត់ខ្លួនក្នុងឆ្នាំ ១៩៦២ ហើយលោក សាឡុត ស (ដែលពេលក្រោយមកឈ្មោះថា "ប៉ុល ពត" ) ក៏ឡើងជាអ្នកដឹកនាំបក្ស។ អ្នកដឹកនាំ "*ខ្មែរក្រហម*" ដែលគេស្គាល់ច្រើនជាងគេ នាសម័យនោះ គឺលោកចៅសេង លោកខៀវសំផន លោកហ៊ូ យន់ លោកហ៊ូ នឹម។ មេដឹកនាំទាំងនោះសុទ្ធតែបានទទួលការអប់រំលទ្ធិកុម្មុយនិស្ត និងរៀនឧត្តមសិក្សានៅប្រទេសបារាំង។ បន្ទាប់ពីបានធ្វើជារដ្ឋមន្ត្រីក្នុងរដ្ឋាភិបាលរបស់សម្តេចសីហនុ មក លោកចៅសេងបានភៀសខ្លួនមកនៅស្រុកបារាំង ហើយបីនាក់ទៀតត្រូវរត់ចូលព្រៃក្នុងឆ្នាំ ១៩៦៧ ។

(៥) ចំពោះជំពូកប្រវត្តិសាស្ត្រនេះ សូមអាន «កំពែងឫស្សី» របស់អ្នកស្រី អែសមេរ៉ាល់ដាលូស៊ីយ៉ូលី ("Le Mur de Bambou", Esmerada Luciolli, Paris 1988. Introduction historique de F.Pondchaud). ដើម្បីឲ្យបានដឹងច្បាស់គ្រប់គ្រាន់ទៅទៀត សូមអាន "Derriè le sourire Khmer", par Charles Meyer, Paris, 1971 ឬ "Des courtisans aux partisans", de Serge Thion et J. C1. Pomonti, Paris 1971.

(៦) សេចក្តីរាយការណ៍ ឆ្នាំ ១៩៥៥ ទំព័រ ៥០ ល ។ មុនការបែងចែកមណ្ឌលព្រះសហគមន៍ប្រទេសកម្ពុជា មានគ្រីស្តបរិស័ទចំនួន ១២៦.០០០ នាក់ ហើយស្ទើរតែជាជនជាតិវៀតណាមទាំងអស់។ កាលនោះប្រជាជនខ្មែរមានចំនួនប្រហែល បួនលានកន្លះ។ បុគ្គលិកមណ្ឌលនោះ មានសាសនទូត ២៥ នាក់ ពីសហគមន៍ក្រុងប៉ារីស បូជាចារ្យវៀតណាម ៧៧ នាក់ អ្នកទទួលការអប់រំ ធ្វើជាបូជាចារ្យ ១៧ នាក់ និង បព្វជិតនៃក្រុមគ្រួសារព្រះឧបការគុណចំនួន ១៥៣ នាក់។

(៧) សេចក្តីរាយការណ៍ឆ្នាំ ១៩៥៦ ទំព័រ ៥៣។ លោក រ៉ាបាល់ឡង់ បានទទួលតំណែងជាអភិបាលព្រះសហគមន៍ ក្នុងឆ្នាំ ១៩៥៦ តអំពីលោកសាបាល់លីយេ។ លោកលាលែងអំពីតំណែងក្នុងឆ្នាំ ១៩៦២ ដោយមានសុខភាពមិនល្អ។ សម្តេចប៉ាបតែងតាំង លោក អ៊ីវ រ៉ាមូស ដែលមានជន្មាយុ ៣៣ ឆ្នាំ ឲ្យកាន់តំណែងបន្ត។

(៨) លោកអ៊ែរកុត បានគ្រោងការណ៍សង់វិសាលវិហារថ្មីនៃក្រុងភ្នំពេញ។ លោកនេះក៏ឲ្យគេសង់គេហដ្ឋានលោកអភិបាលថ្មីដែរ។ លោក សាបាល់លីយេ បានផ្តើមសង់ព្រះវិហារក្នុងឆ្នាំ ១៨៥១ ហើយលោក រ៉ាបាល់ឡង់ សង់បង្ហើយក្នុងឆ្នាំ ១៩៦២។ វិសាលវិហារនេះជំនួសព្រះវិហារចាស់ គឺព្រះវិហារ "*ព្រះមាតា*" ។ *សំណង់ធ្វើក្នុងពេលរីករវល់ខ្លាំងដូច្នេះ ហាក់ដូចជាបង្ហាញសេចក្តីក្លាហានមោះមុតពេក ក៏ប៉ុន្តែគេត្រូវតែធ្វើទៅហើយ*។ (លោកសាបាល់លីយេ ចង់ឲ្យសង់ព្រះវិហារតូចជាងនេះ)។

*«ប្រសិនបើសំណង់នេះ មិនមានធ្វើទេ ដីដ៏ធំល្អនាកណ្តាលក្រុងនឹងកែងបានជា កម្មសិទ្ធិរបស់ព្រះសហគមន៍ទៅហើយ។ នៅពេលសង្គ្រាមដូច្នេះ ការសង់ព្រះវិហារបានហើយស្រេចនេះ*

*គឺជាសញ្ញានៃសេចក្ដីសង្ឃឹម និងនៃសេចក្ដីទុកចិត្ត លើអនាគតរបស់ប្រទេស និងរបស់ព្រះសហគមន៍ដែរ។ បល្ល័ង្កមានលក្ខណៈធំសម្បើមណាស់។ អាគារមានបណ្ដោយ ៨០ ម. ទទឹង ៣៦ ម. (ត្រង់តួកាត់ទទឹង) ២៣ ម. (ត្រង់លំហក្នុង) ហើយប្រាង្គទាំងពួងមានកំពស់ ៦០ ម.។ គេបានវាយបង្គប់បង្គោលស៊ីម៉ង់ ដាក់ដែកប្រវែង ១៣ ម. អស់ចំនួន ៣២៨ ដើម្បីពង្រឹងគ្រឹះ»។* (សេចក្ដីរាយការណ៍ឆ្នាំ ១៩៥២ ទំព័រ ៥៣-៥៤)។ ប្រាក់កាសសម្រាប់សង់ មួយភាគបានមកពីរដ្ឋាភិបាលបារាំងចេញសងការខូចខាតក្នុងសង្គ្រាមឥណ្ឌូចិន។ វរជនច្រើន ទាំងបារាំងទាំងខ្មែរ មានទាំងក្រុមព្រះរាជវង្សានុវង្សដ៏ច្រើនផង បានជួយធ្វើវិភាគទានសម្រាប់សំណង់នេះ។ ជួងទាំងប្រាំ ដែលសហគ្រាសប៉ាកា នៅក្រុងអាណឹស៊ី (Paccard d'Annecy) នាប្រទេសបារាំងបានចាក់ពុម្ពធ្វើរួចហើយនោះ ក៏មកដល់ក្រុងព្រៃនគរក្នុងខែមករា ឆ្នាំ ១៩៥៥។ គេនាំចូលបង្អួចកញ្ចក់ពណ៌មកពីប្រទេសបែលស៊ីក។ គេធ្វើជាតំណាងព្រះមហាក្សត្រ ទាំងតំណាងប្រទេសបារាំងម្នាក់ ចូលរួមផង។ ពិធីនោះ ចាត់ទុកដូចជាការសម្ពោធវិសាលវិហារដែរ។

(៩)«*គ្លែឡូហ្សុី* » ជាសមាគមដែលថេរ៉េសា ក័រនី (Thérè Cornille) បានបង្កើតក្នុងឆ្នាំ ១៩៥៤ ដើម្បីជួយសង្គ្រោះយុវនារីក្រីក្រ ដែលមានបញ្ហាស្មុគស្មាញផ្ទាល់ខ្លួនក្នុងគ្រួសារ ឬក្នុងសង្គម។

(១០)លោក ប៉ូល ទេព អ៊ីម និងលោក អង់ជ្រេ ឡឺស៊ូអ្វែ ជា «*បូជាចារ្យទទួលភារកិច្ចណែនាំព្រះសហគមន៍* » (Préfet apostolique) គឺជាបូជាចារ្យ ដែលកាន់កាប់មុខនាទីទាំងអស់របស់ព្រះសហគមន៍ តែឥតបានទទួលអគ្គសញ្ញា តែងតាំងជាអភិបាលព្រះសហគមន៍ទេ។ បូជាចារ្យនេះពុំមានអំណាចតែងតាំងអ្នកឯទៀតទៅជាបូជាចារ្យបានឡើយ។ បើប្រសិនមានការចាំបាច់សម្ដេចប៉ាបអាចហូតងារនេះ ពីបូជាចារ្យនោះបាន។

(១១)ក្រឹត្យស្ដីអំពី «សកម្មភាពរបស់ព្រះសហគមន៍ជាសាសនទូត» ។

## ជំពូកទី ១២

# ព្រះសហគមន៍មានលក្ខណៈជាខ្មែរ

ក្នុងខែតុលា ១៩៦២ នៅក្រុងរ៉ូម អស់លោកអភិបាលព្រះសហគមន៍ជួបជុំគ្នា ជាមហាសន្និបាតវ៉ាទីកង់ទី ២។ អស់លោកចាប់អារម្មណ៍ខ្លាំងនឹងមនុស្សលោកសព្វថ្ងៃ ដោយចិត្តស្រឡាញ់ ហើយអំពាវនាវព្រះសហគមន៍ឲ្យ "*រួមសេចក្តីសប្បាយ និងរួមសេចក្តីសង្ឃឹម*" ជាមួយមនុស្សលោកបច្ចុប្បន្នកាលនេះឲ្យចែករំលែក "*សេចក្តីទុក្ខព្រួយ និងសេចក្តីបារម្ភរបស់ពួកគេ ជាពិសេសរបស់អ្នកក្រីក្រតោកយ៉ាក និងរបស់អស់អ្នកដែលរងទុក្ខវេទនា*" ។ "*ដូច្នេះ ព្រះសហគមន៍នឹងទទួលស្គាល់ថា ខ្លួនរួមសាមគ្គីយ៉ាងជិតស្និទ្ធជាមួយនឹងមនុស្សជាតិគ្រប់ប្រភេទ តាមប្រវត្តិរបស់មនុស្សជាតិនេះថែមទៀតផង* "(១)។ មហាសន្និបាតអំពាវនាវឲ្យគ្រីស្តបរិស័ទទទួលស្គាល់សាសនាទុកដូចជា "*មធ្យោបាយសម្រាប់ដោះស្រាយប្រស្នាដ៏អាថ៌កំបាំងនៃវាសនារបស់មនុស្ស*" គឺចាត់សាសនទូតទាំងប៉ុន្មានមក "*ជាផ្លូវជាទ្រឹស្តី និងក្បួនច្បាប់សម្រាប់ណែនាំជីវិតមនុស្សទាំងពួង និងជាពិធីផ្សេងៗផង*"។ "*សាសនានានាតែងអប់រំមនុស្សឲ្យស្គាល់រស្មីនៃសេចក្តីពិត ដែលបំភ្លឺមនុស្សគ្រប់ៗរូប*"។ មហាសន្និបាត ចាត់ទុកព្រះពុទ្ធសាសនាទៅក្នុងចំណោម "*សាសនាទាំងឡាយដែលធ្វើឲ្យវប្បធម៌រីកចម្រើន ហើយខិតខំដោះស្រាយបញ្ហាវាសនាមនុស្សដូចគ្នា ដោយបង្កើតទ្រឹស្តីខ្ពស់ប្រណីត មកពន្យល់យ៉ាងច្បាស់លាស់ផង*"(២)។

ចំពោះព្រះសហគមន៍ប្រចាំប្រទេសកម្ពុជាវិញ ការប្រៀនប្រដៅរបស់មហាសន្និបាត "វ៉ាទីកង់ទី២" នេះ គឺមិនខុសប្លែកពី "*សេចក្តីណែនាំ*" ឆ្នាំ ១៦៥៩ ដែលគ្រីស្តបរិស័ទជាច្រើនបំភ្លេចចោលទៅហើយ ខុសប្លែកតែសម័យប៉ុណ្ណោះ។ ក្នុងសម័យបច្ចុប្បន្ន ការសិក្សាព្រះគម្ពីរប៊ីបវិទ្យាសាស្ត្រនិងមនុស្សសាស្ត្របានចម្រើនឡើង នាំឲ្យសាសនទូតស្គាល់ព្រះពុទ្ធសាសនាច្បាស់ជាងពេលមុនៗ ដូច្នេះ សាសនទូតអាចអនុវត្តតាម "*សេចក្តីណែនាំ*" ទាំងនោះបាន។

មហាសន្និបាតបានតែងឯកសារទីមួយ គឺឯកសារស្តីអំពីពិធីបុណ្យផ្សេងៗ អំពីរបៀបគ្រីស្តបរិស័ទត្រូវអនុវត្ត និងគោរពជំនឿរបស់ខ្លួន។ ឯកសារនោះ ប្រៀនប្រដៅគ្រីស្តបរិស័ទឲ្យប្រើភាសាប្រទេសនីមួយៗ គឺភាសាដែលប្រជាជននិយាយជាប្រក្រតីជំនួសភាសាឡាតាំង។ តាំងពីឆ្នាំ ១៩៦៤ មក ក្រុមគ្រីស្តបរិស័ទនៅប្រទេសកម្ពុជាជាច្រើនតែងធ្វើពិធីបុណ្យផ្សេងៗ ជាភាសាខ្មែរទាំងស្រុង។ មានគណៈកម្មាធិការមួយដែលមានបូជាចារ្យខ្មែរនិងបារាំងជាសមាជិក តែងបកប្រែអត្ថបទគម្ពីរនិងធម៌សំខាន់ៗ។ គណៈកម្មាធិការនោះ តែងសួរយោបល់របស់ព្រះសង្ឃព្រះពុទ្ធសាសនា ដែលជំនាញខាងអក្សរសាស្ត្រខ្មែរ។ ក្នុងឆ្នាំ ១៩៦៦ លោកអភិបាលបញ្ជាឲ្យប្រើភាសាខ្មែរ ក្នុងព្រះវិហារទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យសហគមន៍គ្រីស្តបរិស័ទទៅជាសញ្ញាសម្គាល់ថា មនុស្សគ្រប់ជាតិសាសន៍ នៅក្នុងព្រះរាជាណាចក្រអាចចូលរួមក្នុងមហាគ្រួសារគ្រីស្តបរិស័ទបាន។

លោកអភិបាលប្រៀនប្រដៅឲ្យធ្វើ "*ខេមរយានកម្មខាងពិធីបុណ្យ*" នេះ សម្រាប់តែធម៌សូត្រជាប្រក្រតីក្នុងអភិបូជាប៉ុណ្ណោះ។ នៅប្រទេសកម្ពុជាក៏ដូចជានៅក្នុងប្រទេសឯទៀតៗដែរ មានគ្រីស្តបរិស័ទជាច្រើនប្រឆាំងនឹងការប្រើភាសាសាមញ្ញក្នុងពិធីបុណ្យនេះ ព្រោះពួកគេមិនចង់បោះបង់ ចោលធម៌ដែលពួកគេធ្លាប់ចាំតាំងពីក្មេងមក ជាធម៌ដែលពួកគេចាត់ថា ត្រឹមត្រូវ និងធ្វើឲ្យមានឯកភាពក្នុងព្រះសហគមន៍(៣) ។ បងប្អូនខ្មែរកាតូលិកជាច្រើនយល់ថា ខេមរយានកម្មនាំឲ្យបោះបង់ភាសាឡាតាំងចោល ពោលគឺបោះបង់ចោលភាសាដ៏ពិសិដ្ឋរបស់គេដើម្បីយកភាសារបស់ពួក "*ក្រៅសាសន៍*" មកប្រើថែមទៀត។ ផ្ទុយទៅវិញ ពុទ្ធសាសនិកជននៅតែសូត្រធម៌របស់គេជាភាសាបាលីដដែល។ រីឯគ្រីស្តបរិស័ទវៀតណាមវិញ ពួកគេនឹកគិតថា ភាសាខ្មែរគឺជាភាសាដែលគេមិនសូវចេះ ជាភាសារបស់ប្រជាជនដែលពួកគេមើលងាយនិងស្អប់។ ពួកគេយល់ទៀតថា ភាសាខ្មែរជាភាសារបស់រដ្ឋបាល ដែលចាត់ទុកពួកគេជាជនបរទេសជានិច្ច ហើយដែលគាបសង្កត់ពួកគេយកប្រាក់ថែមទៀតផង។ មកទល់នឹងពេលនេះ ក្រុមបូជាចារ្យជាតិបារាំង និងជាតិវៀតណាមភាគច្រើន ប្រកាសដំណឹងល្អចំពោះតែជនជាតិវៀតណាមប៉ុណ្ណោះ ហើយក្រុមបូជាចារ្យមួយភាគធំពុំសូវចេះនិយាយនិងសរសេរខ្មែរទេ។

តែទោះជាយ៉ាងណាក៏ដោយ ក៏មានបូជាចារ្យបារាំងមួយចំនួនដែលមានវ័យចំណាស់បន្តិច យកចិត្តទុកដាក់រៀនភាសាខ្មែរគួរឲយ្យសរសើរ តែជួនកាលមិនបានសម្រេចដូចបំណងឡើយ។ សូម្បីតែដូនជី ការមែល ដែលសុទ្ធសឹងជាជនជាតិវៀតណាម និងមានវ័យ

ចំណាស់ទៅហើយក៏តែងធ្វើពិធីបុណ្យផ្សេងៗ ជាភាសាខ្មែរដែរ!។

ផ្ទុយទៅវិញ អស់សាសនទូតដែលមានវ័យក្មេង រៀនភាសាខ្មែរងាយស្រួលជាងអស់លោកចាស់ៗ។ ពេលសាសនទូតថ្មីៗមកដល់ប្រទេសកម្ពុជា អស់លោកត្រូវរៀនភាសាខ្មែរជាដាច់ខាតក្នុងរយៈពេលបីឆ្នាំដំបូង។ ដូច្នេះ សាសនទូតថ្មីតែងសៀវភៅខាងគ្រីស្តសាសនាបានមួយចំនួនធំដែរគឺក្នុងឆ្នាំ១៩៦៤ លោកហ្វ្រង់ស្វ័រម៉ង់ហ្សែល (François Mangel) និពន្ធប្រវត្តិរបស់ព្រះគ្រីស្ត ដោយមានិស្សិតខ្មែរពីរនាក់ជាអ្នកកាន់ព្រះពុទ្ធសាសនាជួយផង។ សៀវភៅនេះមានចំណងជើងថា "*គ្រីស្តសករាជឆ្នាំសូន្យ* " ហើយមានសរសេរតាមបែបអក្សរសិល្ប៍នាសម័យនោះ។ នៅឆ្នាំដដែលនោះ លោកប៉ូលទេពអ៊ឹម សូមឲ្យសាស្រ្តាចារ្យភាសាខ្មែរម្នាក់បកប្រែសៀវភៅ "*ជីវប្រវត្តិរបស់ព្រះយេស៊ូ រចនាដោយរូបភាព* " (La vie de Jésus illustrée) របស់លោកទីវ៉ូលលីយេ (Thivollier) ។ ក្នុងឆ្នាំ ១៩៦៨ លោក ហ្វ្រង់ស្វ័រប៉ុងសូដ៏ (François Ponchaud) បកប្រែ "កូនសៀវភៅសម្រាប់អប់រំគោលសំខាន់ៗរបស់គ្រីស្តសាសនា" (Petit Catéchisme) សម្រាប់ក្មេងៗ។ បន្ទាប់មក ក្នុងឆ្នាំ ១៩៦៩ លោកនិពន្ធសៀវភៅអប់រំគោលសំខាន់ៗនៃគ្រីស្តសាសនាមួយទៀត តាមសេចក្តីណែនាំថ្មីៗដែលព្រះសហគមន៍ប្រទេសបារាំងសម្រេចឲ្យប្រតិបត្តិតាម។ ក្នុងឆ្នាំក្រោយៗមកទៀត លោកបកប្រែគម្ពីរគម្ពីរដំណឹងល្អនិងអត្ថបទ សម្រាំងនៃព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ព្រមទាំងតែងអត្ថាធិប្បាយព្រះគម្ពីរប៊ីបថែមទៀតផង។

ក្នុងឱកាសបុណ្យណូអែលឆ្នាំ ១៩៦៨ ព្រះសហគមន៍បានផ្សាយព្រឹត្តិប័ត្រតូចមួយជាបួនភាសា (ខ្មែរ វៀតណាម ចិន បារាំង) ចំនួនពីរម៉ឺនច្បាប់ ដើម្បីចែកចាយឲ្យអ្នកដែលមកលេងបុណ្យគ្រីស្តសាសនានោះ។ កាសែត (Réalités Cambodgiennes) របស់រដ្ឋាភិបាលខ្មែរ បានស្រង់យកវគ្គខ្លះនៃសារបុណ្យណូអែល មកចុះផ្សាយក្នុងទំព័រពិសេសនៅលើក្របនៃកាសែតនោះមករូបភាពពីកំណើតព្រះគ្រីស្ត រចនាតាមបែបខ្មែរសុទ្ធ។

តាមពិតទៅ ភាសាគ្រាន់តែជាមធ្យោបាយដំបូង ដើម្បីឲ្យគ្រីស្តបរិស័ទខ្មែរបញ្ចេញជំនឿរបស់ខ្លួនឲ្យកាន់តែស្របទៅតាមវប្បធម៌ខ្មែរប៉ុណ្ណោះ។

នៅឆ្នាំ ១៩៦៧ នៅក្រុងបាត់ដំបង លោកស៊ីម៉ុង ឆែម យ៉េន ស្នើឲ្យគ្រីស្តបរិស័ទខ្មែរ លើកយកបុណ្យរំឭកវិញ្ញាណក្ខន្ធមរណបុគ្គលរបស់អ្នកដែលចែកស្ថានទៅហើយមកធ្វើនៅថ្ងៃត្រូវនឹងភ្ជុំបិណ្ឌ ដែលជាបុណ្យធំរបស់ជនជាតិខ្មែរ។ ការនេះធ្វើឲ្យគ្រីស្តបរិស័ទ

ខេត្តបាត់ដំបងសប្បាយរីករាយជាខ្លាំង។ ពីរឆ្នាំក្រោយមកសម្តេចប៉ាបអនុញ្ញាតជាផ្លូវការឲ្យលើកថ្ងៃបុណ្យនេះមកធ្វើនៅពេលបុណ្យភ្ជុំបិណ្ឌខ្មែរ។ ក្រុមគ្រីស្តបរិស័ទ "ព្រះមាតា" នាក្រុងភ្នំពេញនៅរុញរាណាស់ ព្រោះពួកគេជាប់ជំពាក់នឹងទម្លាប់ចាស់ គេយកចិត្តទុកដាក់ថែរក្សាប្រពៃណីរបស់ដូនតាឲ្យគង់វង្ស។ ក្រោយមកទៀត អស់លោកអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជាជម្រាបសម្តេចប៉ាបថា តើគួរលើកយកថ្ងៃបុណ្យណូអែលមកធ្វើនៅថ្ងៃដែលស្របទៅតាមថ្ងៃព្រះពុទ្ធសាសនាឬទេ? អស់លោកក៏ពិភាក្សាគ្នាសូមផ្លាស់ប្តូរពេលធ្វើ "បុណ្យចម្លង" (Pâques) ដែរ ព្រោះធម្មតាបុណ្យដ៏ធំជាងគេនេះមានធ្វើចំពេលថ្ងៃបុណ្យចូលឆ្នាំខ្មែរ។ ប៉ុន្តែ សម្តេចប៉ាប សុំឲ្យពិនិត្យពិចារណាឲ្យបានល្អិតល្អន់ថែមទៀត លោកក៏សុំឲ្យអភិបាលព្រះសហគមន៍នៅប្រទេសកម្ពុជាទាក់ទងជាមួយអស់លោកអភិបាលព្រះសហគមន៍ប្រទេសថៃ ព្រោះថាប្រទេសនេះតែងជួបប្រទះនឹងបញ្ហានេះដែរ។

គេកសាងព្រះវិហារថ្មីៗទៀត ស្របទៅតាមគំរូបែបផែនសិល្បៈ "ខ្មែរថ្មី" ដែលជាសិល្បៈយកលំនាំតាម ស្ថាបត្យករ វណ្ណ ម៉ូលីវណ្ណ និងលុយបានហាប់។ លោកទាំងពីរនាក់នេះ បានខំសម្រួលឲ្យអាគារទំនើបៗ មានលក្ខណៈពិសេស ដូចសំណល់ក្នុងសម័យអង្គរ។ លោក ម៉ូរីសឡឺគូតួ (Mâurice Lecoutour) ជាស្ថាបត្យករ បានគូរប្លង់សម្រាប់សាងព្រះវិហារកំពង់គ និងព្រះវិហារឆ្លូង។ លោកយ៉ូហានអ័រហាដូបែរី (Jean Ahadoberry) សាងព្រះវិហារមួយទៀត នៅក្រុងព្រះសីហនុ។ បីបួនឆ្នាំក្រោយមកទៀត លោកទេពអ៊ីមសុំឲ្យគេគូរឆាកប្រវត្តិរបស់ព្រះយេស៊ូ ជាប់នឹងខ្លោងពិដានរបស់ព្រះវិហារចាស់ នៅក្រុងបាត់ដំបងជារបៀប គូរចម្លងតាមគំរូផាត់ពណ៌បែបពុទ្ធប្បវត្តិ ដែលលំអវត្តអារាមទាំងពួង។ ក្រុមយុវជនភូមិ "ព្រះមាតា" ក្រុងភ្នំពេញ យករឿងនិទានជាច្រើន អំពីព្រះយេស៊ូមកសម្តែងជាឆាកតាមរបៀបបែបប្រពៃណីល្ខោនខ្មែរសុទ្ធសាធ។

នៅកំពត លោកយ៉ូហាន អ័ដូប៉ែរី បង្កើតរោងដេរប៉ាក់និងគំនូរខ្មែរមួយ។ នៅក្នុងលំនៅលោកបូជាចារ្យ និងក្នុងព្រះវិហារទាំងឡាយ មានតាំងរូបព្រះនាងម៉ារីពបុត្រដោយរចនាតាមរូបទេពអប្សរ ដែលជាទេពធីតាសិល្បៈអង្គរ។ បន្តិចម្តងៗ រូបគំនូរបែបទេពអប្សរទាំងនោះដណ្តើមយកកន្លែងរបស់រូបព្រះនាងម៉ារី ដែលរចនាតាមបែបបូរាណរបស់អ៊ីតាលី។ ក្នុងឆ្នាំ ១៩៦៥ ព្រះសង្ឃអញ្ជើញលោកយ៉ូហានអ័ហាដូប៉ែរី

ឲ្យចូលរួមក្នុងពិព័រណ៍សិល្បៈសាសនា ដែលលោកបានតាក់តែងឡើងក្នុងវត្តធំនៃក្រុងកំពត។ រដ្ឋមន្ត្រីក្រសួងធម្មការ បានសរសើរលោកអ័ហាប៉ែរីនេះជាខ្លាំង។ នៅឆ្លូងលោកម៉ូរីសឡឺគូតូ បានបង្កើតរោងចម្លាក់ឈើខ្លឹមមួយ ហើយលោកក៏ទទួលពាក្យសរសើរដ៏ខ្លាំងក្លាអំពីសម្ដេចសីហនុ និងអំពីភ្ញៀវទាំងឡាយរបស់ព្រះអង្គ។

**សន្តសាគររោម**

នៅប្រទេសកម្ពុជាមានវត្តអារាមជាច្រើន ហើយដែលកាន់ប្រពៃណីព្រះពុទ្ធសាសនានោះ គួរឲ្យមានលោកសង្ឃកាតូលិកមកចែករំលែកពិសោធន៍របស់អស់លោក ជាមួយលោកសង្ឃខាងពុទ្ធសាសនា។ ក្រុមគ្រួសារបព្វជិតគណៈបេណេឌីចតាំ (Bénédictins) យកចិត្តទុកដាក់កាន់គ្រីស្តសាសនា តាមរបៀបព្រះសង្ឃព្រះពុទ្ធសាសនា។

ក្នុងខែឧសភា ១៩៥២ បព្វជិតគណៈបេណេឌីចតាំងជាតិបារាំងបួននាក់ នៅអារាមឡាព្យែរគីវៀរ (La Pierre qui Vire) គឺលោកអែរណេស ឌ្រូអេ (Ernest Drouet) លោកយ៉ូហានបាទីស្តនីកូឡា (Jean-Bapriste Nicolas) លោកហ្វេលិច ប្រេវ៉ូស (Félix Prévost) និងលោកស៊ីរីយ៍ រូហ្សឺល (Cyrille Rougeul) មកដល់ប្រទេសកម្ពុជា ដោយមានបព្វជិតជាតិវៀតណាមម្នាក់ ឈ្មោះ ម័រ (Maur) មកជាមួយផង។ អស់ លោកចេញដំណើរពីប្រទេសបារាំង ក្នុងឆ្នាំ ១៩៥០ ហើយបានតាំងទីលំនៅខេត្តវិញឡុង នាប្រទេសវៀតណាម រួចមកនៅប៊ិញដាយនាដែនកូសាំងស៊ីន។ កន្លែងនោះជាតំបន់ចាញ់ បណ្ដាលឲ្យអស់លោកជួបប្រទះការលំបាកជាច្រើន។ ដោយចៃដន្យបព្វជិតទាំងនោះបានជួបនឹងលោកសាបាល់លីយេ ដែលជាអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា។ លោកអភិបាលក៏អញ្ជើញអស់លោកឲ្យមកតាំងទីលំនៅក្នុងភូមិភាគរបស់លោក។ លោកបាននិយាយបញ្ជាក់ជម្រាបជិតទាំងនោះថា៖ "*ប្រទេសកម្ពុជា ជាស្រុកដែលមានលោកសង្ឃជាច្រើន។ ជនជាតិខ្មែរនឹងស្រឡាញ់គ្រីស្តសាសនា លុះត្រាតែមានលោកសង្ឃកាតូលិក។ ចំណែកខាងយើងជាបូជាចារ្យវិញ យើងពុំអាចទទួលលទ្ធផលល្អឡើយ* " ។ កាលពីមុនបព្វជិតទាំងនោះ គិតតាំងទីនៅកូឡាវយៀង តែក្រោយមក បែរជាចេញដំណើរទៅនៅកែបវិញ។ កែបនេះជាភូមិនៅជាប់មាត់សមុទ្រចម្ងាយ ១៧៥ គ.ម. ពីក្រុងភ្នំពេញ។ នៅទីនោះ សាសនាទូតម្នាក់ឈ្មោះលោកកុលឡូ (Collot) បានប្រគល់ផ្ទះជូនបព្វជិតគណៈបេណេឌីចតាំងទាំងនោះ។

យុវជនវៀតណាមនៅដែនកូសាំងស៊ីនប្រាំបីនាក់ មកជាមួយបព្វជិតបារាំងទាំងនោះ។ អស់លោកក៏ចាប់រានព្រៃដាំដំណាំ សង់អាគារ នេសាទត្រី ហើយនិងចិញ្ចឹមជ្រូកមាន់ទា ដើម្បីចិញ្ចឹមជីវិត។ បព្វជិតនិងយុវជនទាំងនោះបង្កើតអារាមមួយនៅមាត់សមុទ្រ ហើយដាក់ឈ្មោះថា "*សន្តសាគរារាម*" គឺវត្តនាឆ្នេរសមុទ្រដ៏ក្បែរមកក្បាន្ត។

យុវជនឯទៀតៗ ទាំងវៀតណាម ទាំងចិន ហើយនិងយុវជនខ្មែរ ចំនួនដប់ពីរនាក់ មកសុំស្នាក់អាស្រ័យនៅក្នុងអារាមនោះ។ ជារៀងរាល់ឆ្នាំ មានពីបីទៅប្រាំបីនាក់មកសុំស្នាក់នៅ។ លោកសង្ឃបារាំងអប់រំអ្នកទាំងនោះ ឲ្យចេះទាំងវិជ្ជាទូទៅ ទាំងគ្រីស្តសាសនា ដោយមានបព្វជិតគណៈបេណេឌីចតាំង មកពីប្រទេសបារាំងជួយបង្រៀនផង។ លោកសង្ឃរាជវត្តដំណាលអំពីប្រវត្តិសន្តសាគរារាម ដោយសង្ខេបដូចតទៅ៖

> *"ក្មេងវត្តច្រើនគ្នា នៅបានតែពីរ ឬបីឆ្នាំប៉ុណ្ណោះ រួចវានឹកស្រុកកំណើត ក៏សុំត្រឡប់ទៅផ្ទះវិញ។ ប្រហែលវាធុញទ្រាន់នឹងរបៀបរស់នៅដដែលៗរបស់យើង ឬក៏ចង់រៀនសូត្រខាងផ្លូវលោកីយតទៅទៀត។ ក្មេងៗដែលមកពីភូមិកំពង់គនៅមិនទាំងបានមួយអាទិត្យផង ព្រោះពួកវានឹកស្រណោះគោក្របី។ យុវជនបីនាក់មកពីភូមិក្រូចឆ្មារសុទ្ធសឹងមានកម្លាំងកាយមាំមួនល្អ តែបែរជាចុះចាញ់ខាងបញ្ញា ទោះបីយើងបង្រៀនពួកវាតិចតួចក៏ដោយ"* (៤)។

មានតែយុវជនពីរនាក់ទ្រាំរស់នៅរហូតទាល់តែបានបួស ហើយទទួលមុខងារជាបូជាចារ្យថែមទៀត នាថ្ងៃទី ២៩ មិថុនា ឆ្នាំ ១៩៦៥ គឺយុវជនប៉ែរណា ឈឹម ជុនសរ ជនជាតិខ្មែរមានដើមកំណើតនៅបាត់ដំបង និងលុយ វ៉ង ជនជាតិវៀតណាម កើតនៅដែនកូសាំងស៊ីន។ យុវជនខ្មែរជាច្រើនទៅជាបព្វជិតដែរ គឺលោកដានី សេង និម្មិត លោកអង់ដ្រេ រដ្ឋ រំដួរ លោកមីសែល សួង។

នាខែកុម្ភៈ ឆ្នាំ ១៩៧០ ក្រុមគ្រួសារបព្វជិតនៅកែបមានលោកសង្ឃបារាំងប្រាំបួនអង្គ លោកសង្ឃខ្មែរបួនអង្គ លោកសង្ឃវៀតណាមប្រាំអង្គ លោកសង្ឃចិនមួយអង្គ និងយុវជនសាមណេរដែលកំពុងរៀនធម៌ជាងដប់នាក់។ ក្នុងចំណោមជាងដប់នាក់នេះ មានខ្មែរបីនាក់ផង។ លោកសង្ឃរាជសរសេរទៀតថា៖

> *"យើងបានរកឃើញរបៀបរស់នៅយ៉ាងសមរម្យ គឺយើងដូចជាគ្រួសារមួយដែលចេះរួមសាមគ្គីគ្នា។ យើងយកភាសាបារាំងមកនិយាយក្នុងក្រុមគ្រួសារ ដើម្បី*

ឲ្យមានឯកភាព។ យើងនិយាយភាសាបារាំងបែបនេះ ប្រហែលជាយើងចង់ឲ្យមានការងាយស្រួលពេកទេដឹង។ យើងយកភាសាខ្មែរ និងភាសាវៀតណាមមកប្រើបន្តិចម្តងៗ នៅក្នុងពិធីបុណ្យផ្សេងៗ។

យើងបានរិះគិតពិភាក្សាគ្នាពីការតែងតាំងបព្វជិត សម្រាប់តែមួយរយៈពេលប៉ុណ្ណោះ គឺតាមរបៀបព្រះសង្ឃខាងពុទ្ធសាសនា។ ក៏ប៉ុន្តែ បើតាមក្បួនច្បាប់របស់សន្តបេណោឌីកតូ ដែលជាអ្នកបង្កើតវិន័យសម្រាប់អ្នកបួសក្នុងគ្រីស្តសាសនា យើងពុំអាចទទួលអ្នកបួសសម្រាប់តែមួយរយៈពេលដូច្នេះបានឡើយ។ ដូច្នេះ យើងត្រូវរកមធ្យោបាយដោះស្រាយ ដើម្បីធ្វើឲ្យយុវជនខ្មែរដែលមានបំណងបួសតែមួយរយៈពេលនោះអាចមករស់នៅជាមួយយើងបាន។

យើងមកប្រទេសកម្ពុជា ដោយមានបំណងតែងតាំងវត្តអារាម កាន់តាមវិន័យដូចដែលយើងធ្លាប់បានកាន់រួចមកនៅឯប្រទេសបារាំងនោះ និងប្រតិបត្តិសព្វគ្រប់ទាំងអស់។ តែបន្ទាប់មក មិនយូរប៉ុន្មានយើងបានកែសម្រួលវិន័យខ្លះ ដែលមានជាប់លក្ខណៈអឺរ៉ុបខ្លាំងពេក។ ក៏ប៉ុន្តែ យើងមិនបានគិតថា នឹងសម្រួលឲ្យទៅតាមរបៀបបួសរបស់លោកសង្ឃខ្មែរឡើយ ព្រោះយើងយល់ឃើញថា វិន័យរបស់សន្តបេណោឌីកតូកើតចេញមកពីប្រពៃណីបព្វជិតសកល តាំងពីប្រពៃណីរបស់បព្វជិតនៅវាលរហោឋាននាប្រទេសអេស៊ីប តាំងពីប្រពៃណីឥណ្ឌាមានព្រហ្មញ្ញសាសនា និងពុទ្ធសាសានផង។ នៅទ្វីបអាស៊ីព្រះសង្ឃត្រូវតែមានស្បង់ចីពរ។ ដូច្នេះ យើងត្រូវតែពាក់អាវផាយតាមប្រពៃណីក្រុម គ្រួសាររបស់យើង។ ក្រុមយើង បានសាកល្បងផ្លាស់ពណ៌អាវផាយនោះ ក៏ប៉ុន្តែ មិនព្រមផ្លាស់ ទ្រង់ទ្រាយឲ្យបានដូចស្បង់ចីពរនៃព្រះសង្ឃពុទ្ធសាសនាឡើយ។

បើប្រៀបធៀបបព្វជិតខាងព្រះពុទ្ធសាសនាទៅនឹងបព្វជិតខាងគ្រីស្តសាសនា យើងសង្កេតឃើញថា មានវិន័យដូចគ្នា គឺត្រូវដាក់ខ្លួនជាអ្នកក្រីក្រ ត្រូវតមកាមគុណ និងត្រូវស្តាប់បង្គាប់របស់សង្ឃរាជ។ ព្រះសង្ឃខាងពុទ្ធសាសនាតែងគោរពប្រតិបត្តិតាមគុណធម៌ទាំងបីយ៉ាងនោះដូចយើងដែរ។ តាមពិតទៅ យើងត្រូវទទួលស្គាល់ថា យើងចាញ់ព្រះសង្ឃក្នុងរឿងតម យើងទទួលទានបាយបីដងក្នុងមួយថ្ងៃ ដើម្បីមានកម្លាំងពលំមាំមួនធ្វើការចិញ្ចឹមជីវិត។ អ្នកស្រុកសង្កេតឃើញថា យើងខុសប្លែកឆ្ងាយពីព្រះសង្ឃពុទ្ធសាសនាត្រង់យើងធ្វើការចិញ្ចឹមជីវិតនោះ។ អស់អ្នកភូមិតែងហៅយើងថា "លោកសង្ឃដែលធ្វើការ" ។ យើងទាំងសងខាងដូចគ្នាម្យ៉ាងទៀត

គ្រង់យើងរស់នៅរួមគ្នាយ៉ាងប្រិតប្រៀប គឺត្រូវចេះអត់ឱនគ្នា អំណត់អត់ទ្រាំ និងសន្តោសគ្នាទៅវិញទៅមក។ យើងមានកម្មទោសដូចគ្នា។ យើងក៏យកចិត្តទុកដាក់និងពេញចិត្តស្មិងស្មាធិ៍សមាធិដូចគ្នា ព្រមទាំងចូលចិត្តសំបូងសង្រួងដូចគ្នាដែរ។ របៀបរស់នៅរបស់ព្រះសង្ឃខាងពុទ្ធសាសនាលើកទឹកចិត្តយើង ឲ្យកាន់តាមវិន័យរបស់យើងដោយចិត្តស្មោះត្រង់ថែមទៀត។

យើងរស់នៅតាមរបៀបដូចគ្នាមែន ក៏ប៉ុន្តែ អត្ថន័យនៃជីវិតរបស់យើងទាំងសងខាងខុសគ្នា ស្រឡះតែម្តង។ តាមក្បួនច្បាប់របស់សន្តបេណេឌីកតូ បព្វជិតជាអ្នកស្វែងរកព្រះជាម្ចាស់ ហើយបញ្ញត្តិទាំងអស់ដែលមានចែងនៅក្នុងក្បួនច្បាប់នេះ ណែនាំលោកឲ្យដើរទៅតាមគន្លងត្រឹមត្រូវ ដើម្បីឲ្យបានស្គាល់ព្រះគ្រីស្តកាន់តែច្បាស់ឡើង។ រីឯវិន័យខាងពុទ្ធសាសនាវិញ លោកសង្ឃខិតខំតមនិងស្មិងស្មាធិ៍ធ្វើសមាធិដើម្បីរម្ងាប់ចិត្ត និងឲ្យបានចូលនិព្វាន។ ម្យ៉ាងទៀត ពុទ្ធបរិស័ទចាត់ទុកព្រះសង្ឃថា "ស្រែបុណ្យ" ហើយព្រះសង្ឃនេះមានមុខងារណែនាំពុទ្ធបរិស័ទអាចឈានទៅរកបរមសុខបាន។ រីឯខាងព្រះសហគមន៍កាតូលិកវិញ បព្វជិតជាសញ្ញាសម្រាប់បង្ហាញទិសដៅទៅរកព្រះជាម្ចាស់។

បន្តិចម្តងៗ យើងមានចិត្តចង់និយាយសន្ទនាជាមួយលោកសង្ឃ។ កាលដើមដំបូង យើងនឹកគិតតាមយោបល់របស់លោកសាសនទូតក្នុងសម័យនោះ គឺយើងចាត់ទុកព្រះពុទ្ធសាសនាថា ជាឧបសគ្គរាំងជំនឿគ្រីស្តសាសនាយើងមិនឲ្យរីកចម្រើនឡើង។ ដូច្នេះហើយ បានជាយើងគ្មានគិតគូររកជួយពិភាក្សាជាមួយនឹងព្រះសង្ឃឡើយ យើងក៏មិនយកចិត្តទុកដាក់នឹងទ្រឹស្តីរបស់លោកសង្ឃទាំងនោះដែរ។ យើងបានបើកឱសថាល័យមួយដែលផ្តល់ឱកាសល្អ ឲ្យមានការប្រស្រ័យទាក់ទងគ្នាជាលើកដំបូងគឺព្រះសង្ឃតែងមករកសុំថ្នាំពេទ្យ។ យើងក៏តែងទៅលេងសួរសុខទុក្ខព្រះសង្ឃទាំងនោះដែរ។ ក៏ប៉ុន្តែ ព្រះសង្ឃក្មេងៗនៅវត្តកែបពុំអាចពន្យល់អំពីព្រះពុទ្ធសាសនា ឲ្យយើងចេះដឹងឡើយ។ ព្រះសង្ឃទាំងនោះបានតែសូត្រតាមគ្មានយល់ធម៌ឲ្យបានច្បាស់ឡើយ។ នៅក្នុងវត្តគ្មានឃើញនរណាម្នាក់ ស្មិងស្មាធិ៍ធ្វើសមាធិឡើយ។ ក៏ប៉ុន្តែ មានព្រះសង្ឃចាស់វស្សាមួយអង្គ ដែលរស់នៅជាតាបស នៅក្នុងព្រៃមានរបៀបល្អណាស់ ព្រោះលោកធ្វើតាមឱវាទទូន្មានរបស់ព្រះពុទ្ធជានិច្ច។

យើងនិងអ្នកភូមិរាប់អានគ្នាទៅវិញទៅមក។ អ្នកភូមិទាំងនោះកាន់ព្រះពុទ្ធ

សាសនា ខ្ជាប់ខ្ជួនល្អណាស់ ហើយថែមទាំងស្រឡាញ់ព្រះសង្ឃ ដែលតែងនិមន្ត មកបិណ្ឌបាត្ររាល់ព្រឹក។ អ្នកទាំងនោះតែងទទួលជនបរទេសមានយើងជាដើម ដោយគ្មានខ្លាចអ្វីឡើយ។ ពួកគេក៏ហ៊ានសុំយើងជួយគេ ហើយពួកគេក៏មិនរួញរា នឹងជួយយើងវិញដែរ។ យើងតែចូលរួមក្នុងពិធីបុណ្យរបស់អ្នកភូមិ ជាពិសេស ពេលមានអ្នកស្លាប់យើងចូលរួមក្នុងពិធីបុណ្យរបស់ពួកគេដែរ។ យើងក៏សិក្សា អំពីទំនៀមទម្លាប់ប្រពៃណីខ្មែរ។ ទំនាក់ទំនងនេះ ធ្វើឲ្យយើងកាន់តែជិតស្និទ្ធ នឹងអ្នកភូមិទាំងនោះថែមទៀត។

យើងបានទទួលយុវជនខ្លះឲ្យស្នាក់អាស្រ័យនៅជាមួយយើង ដូចព្រះសង្ឃក្នុង វត្តនានាតែងទទួលដែរ គឺយុវជនដែលពុំមានកន្លែងស្នាក់នៅក្នុងពេលសិក្សា។ យុវជនទាំងនោះមានចិត្តស្មោះត្រង់ល្អ គួរឲ្យស្រឡាញ់រាប់អាន ហើយពួកគេក៏ បានសុំឲ្យយើងបង្ហាត់គ្រីស្ដសាសនាឲ្យគេស្គាល់។ យុវជនម្នាក់ឈ្មោះណូអែល សូង បានចាប់អារម្មណ៍នឹងគ្រីស្ដសាសនា រហូតដល់សុំទទួលពិធីបុណ្យជ្រមុជទឹក ផង។ យុវជនឯទៀតៗសុំរស់នៅជាបព្វជិតដូចយើង ទោះបីពួកគេពុំបានសុំចូល គ្រីស្ដសាសនាក៏ដោយ។ ក្នុងរយៈពេលបីបួនខែចុងក្រោយដែលយើងស្នាក់នៅកែប ពុទ្ធសាសនិកជនមួយក្រុមតែងចូលរួមសូត្រធម៌ទាំងព្រឹក ទាំងល្ងាចជាមួយយើង។ យើងឲ្យពួកគេស្លៀកពាក់សដូចសាមណេរ តាមវិន័យក្រុមគ្រួសាររបស់យើង។ សាមណេរទាំងនោះ មិនមែនជាគ្រីស្ដបរិស័ទទេ តែគេបានតែងចម្រៀងលើកតម្កើង ព្រះជាម្ចាស់ជាច្រើនបទព្រមទាំងបានតែងទំនុកតម្កើងជាច្រើនផង។ ម្យ៉ាងទៀត យើងបានទទួលយុវជនឲ្យស្នាក់នៅ និងអប់រំពួកគេ ស្របទៅតាមក្បួន ច្បាប់របស់សន្តបេណោឌីកតូ។

គួរឲ្យឆ្ងល់ និងនឹកស្ដាយណាស់ ពុទ្ធសាសនិកជនយល់អំពីរបបៀបរស់នៅរបស់ យើងច្បាស់ជាងគ្រីស្ដបរិស័ទខ្មែរ ដែលតែងប្រកាន់ចំពោះព្រះពុទ្ធសាសនា។ គ្រីស្ដបរិស័ទទាំងវៀតណាម ទាំងខ្មែរ ស្រឡាញ់រាប់អានយើងណាស់ ក៏ប៉ុន្តែ មាន គ្នាតិចទេ ដែលស្គាល់យើង។ មិនដែលមានក្រុមគ្រីស្ដបរិស័ទណា សុំមកសំណាក់ ធម៌នៅក្នុងអារាមសោះឡើយ។ ការនេះប្រហែលជា មកពីយើងរស់នៅឆ្ងាយ ពីក្រុងពេក និងមកពីភាពស្ងប់ស្ងាត់របស់យើង។ អារាមរបស់យើងនៅចម្ងាយបី បួនគ.ម.ពីភូមិចាមមួយ ដែលកាន់សាសនាអ៊ិស្លាម។ យើងពុំសូវបានទាក់ទង ជាមួយចាមទាំងនោះទេ ហើយពួកគេក៏មិនសូវទាក់ទងជាមួយយើងដែរ។

លោក យ៉ូហាន បាដ្រេ (Jean Badré) បព្វជិតបារាំង ដែលបានមកនៅជាមួយក្រុមបព្វជិតសន្ត សាគរារាមតាំងពីដើមទីមក។ លោកបានខិតខំបង្កើតអារាមមួយដែលកាន់វិន័យស្រេបនឹងប្រពៃណីខ្មែរជាងវត្តសន្តសាគរារាមនេះ។ លោកនឹកគិតថា ធ្វើរបៀបនេះអាចអប់រំយុវជនឲ្យទៅជាបព្វជិត ក៏ប៉ុន្តែ នាំឲ្យពួកគេឃ្លាតឆ្ងាយពីវប្បធម៌ ព្រមទាំងទម្លាប់របស់ខ្លួនបាន។ លោកចង់ឲ្យបព្វជិតទាំងនោះរស់នៅតាមរបៀបសាមញ្ញធម្មតា ដោយឥតមានគិតចង់បានតំរេះវិជ្ជាជ្រៅជ្រះ ឬវណ្ណៈខ្ពស់ក្នុងសង្គមឡើយ។ ដូច្នេះ លោកក៏ចេញទៅតាំងទីលំនៅឯភូមិចំណោមខេត្តបាត់ដំបង ដែលមានក្រុមកាតូលិកដ៏តូចមួយ។ លោកធ្វើស្រែរួមជាមួយនឹងអ្នកស្រុក ហើយរស់នៅតាមរបៀបអ្នកក្រីក្រ។ លោកប្រមូលបានយុវជនស្រុកស្រែប្អូនប្រាំនាក់ដែលចូលចិត្តរស់នៅជាបព្វជិត ឲ្យមកនៅជាមួយលោក[៥]។

**ព្រះសហគមន៍ចាប់អារម្មណ៍នឹងសហគមន៍ខ្មែរ**

ក្នុងអំឡុងប៉ុន្មានឆ្នាំខាងក្រោយនៃព្យាបាលបារាំង មន្ទីរសិក្សាកាតូលិកតែងទទួលក្មេងជាតិវៀតណាមជាច្រើនឲ្យចូលរៀន។ បន្ទាប់ពីប្រទេសកម្ពុជាបានឯករាជ្យមក មន្ទីរសិក្សាទាំងនោះបើកទ្វារចំហរទទួលក្មេងៗឯទៀត ឲ្យចូលរៀនដែរ។

ច្បាប់សិក្សាធិការឆ្នាំ ១៩៥៩ បញ្ជាឲ្យប្រើភាសាខ្មែរនៅក្នុងគ្រប់សាលា ក្នុងព្រះរាជាណាចក្រទាំងមូល។ ពេលនោះ សាលារបស់ក្រុមគ្រីស្តបរិស័ទភាគច្រើនក៏ប្រែក្លាយទៅជា "*សាលាអប់រំគ្រីស្តសាសនា*" ទៅវិញ ព្រោះច្បាប់ថ្មីនោះអនុញ្ញាតឲ្យប្រើភាសាវៀតណាមតទៅទៀតបាន ក្នុងការបង្រៀនគោលសំខាន់ៗនៃ គ្រីស្តសាសនាប៉ុណ្ណោះ។ ដូច្នេះ ក្នុងសាលាទាំងនោះ គេបង្រៀនជាភាសាវៀតណាមចាប់ពីពេលនោះរហូតមក ហើយក្មេងៗជាតិវៀតណាមត្រូវជ្រើសរើស ឬមួយទៅរៀននៅសាលាសិក្សាសាធារណៈខ្មែរ ឬមួយនៅរៀនបន្តិចបន្តួចជាភាសាវៀតណាមក្នុងសាលាព្រះសហគមន៍។ រដ្ឋការបានបង្ខំក្មេងវៀតណាមភាគច្រើនឲ្យ ទៅរៀនក្នុងសាលាអប់រំគ្រីស្តសាសនា ព្រោះសាលាធារណៈពុំអាចទទួលពួកវាបានទាំងគ្នាឡើយ។ ម្យ៉ាងទៀត មានតែជនជាតិខ្មែរប៉ុណ្ណោះដែលមានសិទ្ធិចូលរៀននៅសាលារដ្ឋ ហើយជនជាតិវៀតណាមពុំឲ្យអាចចូលជាតិខ្មែរបានទេ។

តែគ្រួសារខ្មែរអ្នកមានវិញ ចូលចិត្តឲ្យកូនរៀននៅសាលាមធ្យមសិក្សាកាតូលិកណាស់។ នៅក្រុងភ្នំពេញ ក្នុងអំឡុងឆ្នាំហុកសិប សាលាមីសទទួលយកសិស្សបានត្រឹម

១៧០០ នាក់។ ចំណែកសាលាប្រូវីដង់ (ឧបការគុណ) ទទួលបានត្រឹម ១៤០០ នាក់។ កាលពីដើម សាលាទាំងនេះទទួលយកសិស្សគ្រីស្តបរិស័ទជាបឋម តែក្នុងសម័យឯករាជ្យ គេក៏ទទួលយកសិស្សដែលពុំចូលគ្រីស្តសាសនាដែរ។ ជាងពីរភាគបីនៃសិស្សសាលាប្រូវីដង់ មិនមែនជាគ្រីស្តបរិស័ទទេ។ សិស្សទាំងនោះ ភាគច្រើនជាកូនចិនឬកូនវៀតណាម ព្រោះសិស្សទាំងនោះពុំអាចចូលរៀនក្នុងសាលារដ្ឋបានឡើយ។ អ្នកណែនាំគ្រីស្តសាសនា បានចាត់ទុកសាលាមីស និងសាលាប្រូវីដង់ ជាសាលាសម្រាប់នាំឥទ្ធិពលនៃដំណឹងល្អ ព្រោះក្នុងសាលាទាំងអស់នោះ គេអប់រំក្មេងយ៉ាងជ្រៅជ្រះល្អ ហើយគេបង្រៀនសាសនា និងគេមានទំនាក់ទំនងល្អជាមួយនឹងសាស្ត្រាចារ្យ។

ក្នុងឆ្នាំ ១៩៥៩ ពួកបងស្រីនៃក្រុមគ្រួសារព្រះឧបការគុណកសាងសាលារៀនមួយ នៅកែប នាឆ្នេរសមុទ្រជិតអារាមរបស់បព្វជិតគណៈបេណេឌីចតាំង សម្រាប់ឲ្យយុវនារីប៉ែតសិបនាក់នៅស្នាក់អាស្រ័យ។ "*ដូនជីអាចទទួលសេចក្តីអនុញ្ញាតឲ្យសាងបាន លុះត្រាតែដូនជីទទួលយុវនារីខ្មែរឲ្យស្នាក់នៅ ហើយលុះត្រាតែអ្នកគ្រូទទួលបន្ទុកអប់រំមានសញ្ជាតិបារាំងឬអឺរ៉ុប និងមិនឲ្យមានអ្នកគ្រូជាតិវៀតណាម ឬចិន បង្រៀនឡើយ សូម្បីជាដូនជីចិន ឬវៀតណាមក៏មិនបានដែរ*"(៦)។

ទេវវិទ្យាល័យតូច បានប្រែក្លាយទៅជាសាលាមធ្យមសិក្សាទៅហើយ ហើយទទួលសិស្សខ្មែរឲ្យចូលរៀន។ រីឯចំនួនយុវជនវៀតណាមដែលចង់ទៅជាបូជាចារ្យ ក៏ថយចុះអស់ បន្ទាប់ពីខេត្តរបស់ដែនកូសាំងស៊ីន បានផ្តាច់ចេញពីមណ្ឌលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា។

សាលាមធ្យមសិក្សាទាំងនោះ ទទួលតែកូនរបស់ពួកអ្នកមាន កូនរបស់អ្នកជំនួញ ឬក៏កូនរបស់អ្នករាជការ។ ក្នុងឆ្នាំ ១៩៦២ ពួកបងប្រុសនៃសាលាគ្រីស្តសាសនាបានបើកសាលារៀនបង្រៀនឥតគិតថ្លៃមួយ នៅទឹកល្អក់ ជាសង្កាត់អ្នកក្រនៅភ្នំពេញ។ ជារៀងរាល់ឆ្នាំ សាលនេះទទួលសិស្សខ្មែរចំនួនមួយរយហាសិបនាក់។

ក្នុងអតីតកាល អស់សាសនទូតរស់នៅដាច់ពីសង្គមខ្មែរ។ ការបើកសាលារៀនដ៏ច្រើននេះ ធ្វើឲ្យព្រះសហគមន៍មានការប្រាស្រ័យទាក់ទងជាមួយជនជាតិខ្មែរ ច្រើនជាងពីសម័យមុនៗ។ បូជាចារ្យម្នាក់ដែល បង្រៀនខាងសាសនានៅអនុវិទ្យាល័យនារីរាយការណ៍

ថា៖ "*ការបង្រៀនសាសនាតាមរបៀបថ្មីនេះ បានធ្វើឲ្យយើងមានឱកាសស្គាល់ចិត្តគំនិតរបស់ពួកយុវជនដែលជ្រួតជ្រាបខាងព្រះពុទ្ធសាសនា* " ។

**មនៅវក្នុខមុសាវ**

ពីដើម សាសនទូតជាច្រើននាក់តែងប្រៀនប្រដៅគ្រីស្តបរិស័ទ ឲ្យគោរពប្រតិបត្តិតាមវិន័យ ឲ្យឧស្សាហ៍ធ្វើពិធិបុណ្យផ្សេងៗ និងឲ្យទទួលអគ្គសញ្ញាផង។ អស់លោកយកចិត្តទុកដាក់ប្រៀនប្រដៅដូច្នេះ គឺធ្វើទៅតាមទម្លាប់គ្រីស្តសាសនាខាងបស្ចឹមប្រទេសដែលមានរាប់រយឆ្នាំមកហើយ។ អស់លោកក៏ប្រៀនប្រដៅដូច្នេះ ស្របទៅតាមចិត្តគំនិតរបស់ពុទ្ធបរិស័ទ និងតាមទស្សនៈពួកជនជាតិអាស៊ីទូទៅដែរ។ ប៉ុន្តែ ការចម្រើនផ្នែកឧស្សាហកម្ម នាសតវត្សទី ១៩ និងវិបត្តិផ្សេងៗ ដែលកើតមានឡើងក្នុងដំណើរប្រវត្តិសាស្ត្របានបណ្តោយឲ្យព្រះសហគមន៍បស្ចឹមប្រទេស ជាពិសេស ព្រះសហគមន៍ប្រចាំប្រទេសបារាំងច្របូកច្របល់ និងប្រែរបៀបប្រៀនប្រដៅគ្រីស្តសាសនា គឺព្រះសហគមន៍នោះ តែងដាស់តឿនគ្រីស្តបរិស័ទឲ្យកសាងពិភពថ្មី ប្រកបដោយយុត្តិធម៌ និងភាពរភាព។ ព្រះសហគមន៍បានបង្កើត "*ចលនាសកម្មភាពកាតូលិក* " ដើម្បីប្រែសង្គមមនុស្ស ឲ្យបានស្របទៅតាមព្រះសហគមន៍របស់ព្រះជាម្ចាស់។

សាសនទូតជំនាន់ក្រោយៗ យល់ស្របតាមមតិជាសកលនៃមហាសន្និបាតបុរីវ៉ាទីកង់ទី ២ នេះ ហើយក៏អនុវត្តន៍តាមសេចក្តីណែនាំទាំងនោះ ថែមទៀតផង។

លោកហ្វ្រង់ស្វ័រ ម៉ង់ហ្ស៊ែលៃ (François Mangel) តែងបង្រៀនទស្សនវិជ្ជានៅវិទ្យាល័យបារាំងឈ្មោះ "វិទ្យាល័យ ដេកាត" (Lycée Descartes) និងនៅទេវវិទ្យាល័យតូច។ អាគារសិក្សាទាំងនេះអប់រំសិស្សពូកែៗខាងភាសាបារាំងមួយភាគធំរបស់ប្រទេសកម្ពុជា។ ក្នុងឆ្នាំ ១៩៥៩ ស្របទៅតាមសេចក្តីណែនាំរបស់លោក រ៉ាបាល់ឡង់ លោកម៉ង់ហ្ស៊ែលៃ បានបង្កើត "*គ្រឹះស្ថាននិស្សិតខ្មែរ* " ។ លោកទទួលនិស្សិតចំនួនសែបសិបនាក់ ដែលជាកូនចៅអ្នកក្រមកពីខេត្តនានាមករៀនសូត្រនៅភ្នំពេញ ឲ្យស្នាក់អាស្រ័យក្នុងគ្រឹះស្ថាននោះ។ និស្សិតក្រៗ ជាច្រើនពុំមានមធ្យោបាយណាក្រៅពីនៅវត្តឡើយ គឺរស់នៅ និងរៀនសូត្រទាំងលំបាក។ គ្រឹះស្ថាននិស្សិតខ្មែរ បានផ្តល់លទ្ធភាពឲ្យនិស្សិតទាំងនោះរៀនចប់ ហើយបានទទួលមុខតំណែងធំៗក្នុងរដ្ឋាភិបាលជាបន្តបន្ទាប់ ហើយធ្វើឲ្យសង្គមខ្មែរទទួលស្គាល់ព្រះសហគមន៍តាមរបៀបថ្មី ខុសប្លែកពីការយល់ឃើញរបស់គេពីសម័យមុនៗ។

ក្នុងឆ្នាំ ១៩៦២ ដោយមានមិត្តខ្មែរ និងបារាំងខ្មែរជួយផង លោក ម៉ង់ហ៊្សលៃ សរសេរព្រឹត្តិប័ត្របញ្ចេញយោបល់ បោះពុម្ពផ្សាយពីរខែម្តងសម្រាប់គ្រីស្តបរិស័ទ។ លោកមានបំណងធ្វើឲ្យគ្រីស្តបរិស័ទបានដឹងរឿងផ្សេងៗ នៅក្នុងលោកទាំងផ្តល់ពត៌មានអំពីព្រះសហគមន៍ឯទៀតនៅក្នុងពិភពលោក ជាពិសេស អំពីព្រះសហគមន៍នៅទ្វីបអាស៊ី។ ដោយមានអ្នកកាសែតម្នាក់ជួយផង លោកបានធ្វើឲ្យព្រឹត្តិប័ត្រនោះក្លាយទៅជាសារពត៌មានដែលមានចំនងជើងថា "*អ្នកនាំសារ* " ហើយមានដាក់លក់នៅគ្រប់តូប។ "*អ្នកនាំសារ* " ដាស់តឿនអ្នកអាន ឲ្យរិះគិតពិចារណាអំពីការរស់នៅក្នុងប្រទេសកម្ពុជា គឺមានលើកយកបញ្ហាគ្រួសារ ការអប់រំនយោបាយមកពិនិត្យ និងដោះស្រាយ។ កាសែតនេះនិយាយមានខ្លឹមសារល្អ មានទម្រង់បែបគួរឲ្យចាប់ចិត្ត ហើយក៏ធ្វើឲ្យមានរសជាតិមួយថ្មីផ្ទុយស្រឡះនឹងការសម្របសម្រួល ហៃអើជាទូទៅរបស់កាសែតទាំងឡាយនៃប្រទេសកម្ពុជា។

លោក ផ្ការ ជាឧស្សាហករម្នាក់កាន់គ្រីស្តសាសនា តែងសរសើរវិចារណកថាក្នុងកាសែត "*អ្នកនាំសារ* " នេះ ហើយបានធានាការខុសត្រូវនៅចំពោះមុខអ្នកកាន់អំណាចខ្មែរ។ ក៏ប៉ុន្តែ ការហ៊ានលើកយកបញ្ហាប្រទេសជាតិមករិះគិត និងបញ្ចេញយោបល់ដោះស្រាយ គឺហាក់ដូចជាពុះពារប្រឆាំងនឹងអំណាចផ្តាច់ការឥតព្រំដែនរបស់សម្តេចសីហនុ។ សម្តេចអនុគ្រោះនិងប្រណីគ្រីស្តបរិស័ទ លុះត្រាតែគ្រីស្តបរិស័ទទាំងនោះគិតគូរតែពីពិធីបុណ្យ ឬពីកិច្ចការសង្គ្រោះជនក្រីក្រប៉ុណ្ណោះ។ បើគ្រីស្តបិរស័ទហ៊ានរិះគិតពិចារណាអំពីព្រះពុទ្ធសាសនាឬអំពីនយោបាយខ្មែរបានសេចក្តីថា គេហ៊ានរំលោភលើ ពាក្យឃោសនាជាផ្លូវការ។ ឧបមាថាសារពត៌មាន "*អ្នកនាំសារ* " បានចោទបែបនេះ បណ្តាលឲ្យមានរឿងដល់អ្នកនិពន្ធជាពុំខាន។ ក្រោយពីបានចេញ ផ្សាយអស់មួយឆ្នាំមក លោកអភិបាលព្រះសហគមន៍សុំឲ្យ "*អ្នកនាំសារ* " បិទឈប់ចេញផ្សាយ។ គេតែង និយាយថា ជនជាតិខ្មែរ មិនងាយចូលគ្រីស្តសាសនាមែន ចំណែកជនបរទេសវិញ ក៏ពិបាកនឹងបញ្ចេញយោបល់ខ្លួនដែលខុសអំពីគំនិត និងយោបល់ជាផ្លូវការដែរ។

យូរៗម្តង នៅភ្នំពេញ លោក ប៉ូលទេព អ៊ីម តែងប្រជុំអ្នកទទួលខុសត្រូវខាងផ្នែកនយោបាយ ដើម្បីត្រិះ រិះពិចារណាអំពីបញ្ហាជាតិ។ ក្រុមនោះ មានឈ្មោះថា "*សន្តិភាពពីក្រុងរ៉ូម* " (Pax Romana) ។ អ្នកចូលរួមប្រជុំភាគច្រើនជាអ្នកកាន់ជើងពួក

"*ខាងឆ្វេង* " ។ នៅក្នុងចំណោមអ្នកទាំងនោះ មានលោកចៅ សេង លោក គាត ឆុន លោកជា សាន និង លោក វណ្ណ ម៉ូលីវណ្ណ[៧] ។

នៅប្រទេសកម្ពុជា ក៏ដូចនៅប្រទេសជាច្រើនទៀតនៃទ្វីបអាស៊ី មានចលនាពង្រឹង ពង្រីកជំនឿគ្រីស្តសាសនាតែពីរយ៉ាងប៉ុណ្ណោះគឺចលនា "*កងអាសាព្រះនាងម៉ារី* " (Légion de Marie) និង "*សមាគមគ្រួសារស្មោះស្ម័គ្រ* " (Association des familles réparatrices) [៨]។ ហើយមានលក្ខណៈស្របទៅនឹងចិត្តគំនិតវៀតណាម។ ក្រុមទាំងពីរ ចាត់ចែងឲ្យគ្រីស្តបរិស័ទធ្វើសកម្មភាពជាក់ស្តែង គឺនាំឲ្យគ្រីស្តបរិស័ទងាកទៅ ជួយអ្នកឯទៀតៗបានដូចជាទៅមើលអ្នកជំងឺ ជួយគ្រួសារដែលមានបញ្ហា ប្រមែ ប្រមូលគ្រីស្តបរិស័ទសំខាន់ៗ សុទ្ធតែរួមគ្នាធ្វើជា "*កងធំ*" ជាច្រើន និងមាន "*កងតូច* " សម្រាប់ជួយលោកបូជាចារ្យ ក្នុងកិច្ចណែនាំគ្រីស្តបរិស័ទ។

សាស្ត្រាចារ្យជាតិបារាំងម្នាក់ ខិតខំបង្កើតក្រុមយុវជនកម្មករគ្រីស្តសាសនា (Jeunesse Ouvrière Chrétienne, “JOC, JOCF” ) ដោយយកតម្រាប់តាមគ្រីស្ត បរិស័ទនាប្រទេសបារាំង ដែលមានឧស្សាហកម្មជឿនលឿន។ ពីរបីក្រុមបាន កើតឡើងនៅក្នុងចំណោមយុវជនវៀតណាម ក្នុងរយៈពេលមួយដ៏ខ្លី។ ក្រុមទាំង នេះ មិនស្ថិតស្ថេរគង់វង្សយូរឡើយ ហើយនៅប្រទេសកម្ពុជា សកម្មភាពកាតូលិក ពុំដែលចែងបានល្អឡើយ។ គ្រីស្តបរិស័ទខ្មែរពុំអាចយល់ភ្លាមនូវជម្រៅនៃ គ្រីស្តសាសនា ព្រោះពួកគេទទួលការអប់រំវប្បធម៌ព្រះពុទ្ធសាសនានេះ តាំងពី នៅក្មេងម្ល៉េះ ហើយមិនសូវយកចិត្តទុកដាក់នឹងកែប្រែសង្គមមនុស្សទេ។

**ការរិះគិតដ៏សនៃឈឺចាប់ខុលាចផុសា**

ក្នុងឆ្នាំ ១៩៦៨ លោកអភិបាលទាំងបី សូមឲ្យបូជាចារ្យម្នាក់ ឈ្មោះ លោក ប៊ូឡា (Boulard) មកជួយរិះគិតអំពីព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា តាម បច្ចេកទេសសង្គមវិទ្យា។ លោកអភិបាលទាំងបីសម្រេច ដូច្នេះ ដើម្បីទាញ យកផលអំពីសេចក្តីប្រៀនប្រដៅរបស់មហាសន្និបាតវ៉ាទីកង់ទី ២ ព្រមទាំង ដើម្បីតម្រែតម្រង់កិច្ចការ ណែនាំគ្រីស្តបរិស័ទឲ្យស្របទៅតាមប្រទេសជាតិផង។ បូជាចារ្យទាំងឡាយបានធ្វើអង្កេតក្នុងគ្រីស្តបរិស័ទនានា ដើម្បីឲ្យស្គាល់ស្ថាន

ភាពពិតប្រាកដរបស់ព្រះសហគមន៍ប្រទេសកម្ពុជា។

តាំងពីអតីតកាលមក សាសនទូតបានខិតខំតែងតាំងគ្រីស្តសាសនាដោយយកចិត្តទុកដាក់ ព្រមទាំងណែនាំឲ្យមានការសម្របសម្រួលទៅតាមរបៀបរបបខ្មែរផង។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ជនជាតិខ្មែរនៅតែមិនស្គាល់ព្រះសហគមន៍ដដែល។ ព្រះសហគមន៍នេះនៅតែមានលក្ខណៈបរទេស ព្រោះគ្រីស្តបរិស័ទភាគច្រើនជាជនជាតិបរទេស។ ក្រុមគ្រីស្តបរិស័ទច្រើនរស់នៅកន្លែងដាច់ស្រយាល ឬនៅតាមដងទន្លេមេគង្គ ដែលជាផ្លូវជំនួញរបស់ប្រទេសកាលពីដើម។ ដូច្នេះ ក្រុមគ្រីស្តបរិស័ទទាំងនោះក៏រស់នៅឆ្ងាយពីទីក្រុង និងឆ្ងាយពីមណ្ឌលពាណិជ្ជកម្មសម័យបច្ចុប្បន្ន។ អស់លោកដែលទទួលខុសត្រូវលើព្រះសហគមន៍ ព្រមព្រៀងគ្នាធ្វើញត្តិមួយ មានសេចក្តីសំខាន់ៗដូចតទៅ៖ «*គ្រីស្តបរិស័ទដែលរស់នៅប្រទេសកម្ពុជា* » សន្យាថានឹង «*តាំងខ្លួនជាសាសនទូតដោយប្តូរផ្តាច់* » ។ គ្រីស្តបរិស័ទម្នាក់ៗត្រូវសន្យាថា នឹងរស់នៅតាមរបៀបប្រជាពលរដ្ឋខ្មែរ ឲ្យកាន់តែខ្លាំងឡើងៗ និងឲ្យកាន់តែជ្រៅទៅៗ។ ត្រូវយកភាសាខ្មែរមកប្រើឲ្យបានច្រើនថែមទៀត ទាំងនៅក្នុងសាលា និងទាំងក្នុងការបង្រៀនគោលសំខាន់ៗរបស់គ្រីស្តសាសនា។ ក្នុងពិធីបុណ្យផ្សេងៗ ព្រះសហគមន៍ត្រូវគោរពទាំងទំនៀមទម្លាប់ ប្រពៃណីរបស់ប្រទេសជាតិ។ ត្រូវធ្វើសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធជាមួយអ្នកកាន់អំណាចប្រទេសជាតិ ដើម្បីធ្វើឲ្យប្រទេសជាតិបានចម្រើនដុះដាលគ្រប់វិស័យ។ នៅទីបំផុត មុនអ្វីៗទាំងអស់ត្រូវដាស់តឿនឲ្យមានគ្រីស្តបរិស័ទហ៊ានទទួលខុសត្រូវក្នុងព្រះសហគមន៍ និងក្នុងសង្គមមនុស្ស។

ក្នុងឆ្នាំ ១៩៦៩ លោកអភិបាលទាំងបីសរសេរលិខិតមួយបញ្ជាក់យ៉ាងច្បាស់លាស់អំពីស្ថានការណ៍ ព្រះសហគមន៍នៅប្រទេសកម្ពុជា ហើយចេញបញ្ជាយ៉ាងជាក់លាក់ថែមទៀត។ អស់លោកបានអំពាវនាវ ចំពោះគ្រីស្តបរិស័ទទាំងឡាយ ជាពិសេសចំពោះគ្រីស្តបរិស័ទវៀតណាម ទាំងអង្វរករសុំឲ្យឈប់រស់នៅដាច់តែឯង ឆ្ងាយពីសង្គមខ្មែរដូច្នេះ។ បើពុំនោះទេ "*ក្នុងពេលឆាប់ៗ សង្គមខ្មែរនឹងបោះបង់យើងចោល ដូចរបស់ដែលគេមិនត្រូវការ* " (៩) ។ សោកនាដកម្មដែលកើតមានឡើងនៅប្រទេសកម្ពុជា នាឆ្នាំ ១៩៧០ ជាភស្តុតាងបញ្ជាក់ថាសេចក្តីរិះគិតរបស់អស់លោកពិតជាត្រឹមត្រូវមែន។

(១) ធម្មនុញ្ញ "អំណរសប្បាយ និងសេចក្តីសង្ឃឹម" (Gaudium et Spes) សេចក្តីផ្តើម។

(២) ឯកសារ "Nostra Aetate", I, c ; 2, b-c-d.

(៣) តាំងពីយូរយារណាស់មកហើយ គ្រីស្តបរិស័ទខ្មែរប្រើភាសាខ្មែរ ដើម្បីសូត្រធម៌ជាប្រក្រតិក្នុងអភិបូជា។ អត្ថបទគម្ពីរ ដែលគេយកមកសូត្រ ជាអត្ថបទរបស់គម្ពីរប្រែដោយលោក ហា ម៉ុង។ ក្នុងពេលដែលបូជាចារ្យសូត្រធម៌ប្រសិទ្ធិព្រះកាយជាភាសាឡាតាំង គ្រីស្តបរិស័ទសូត្រធម៌ជាភាសាខ្មែរ។ អស់លោកចាស់ទុំចេះអានតែអក្សរ "កុកងឺ" (Quoc Ngu) គឺភាសាខ្មែរសរសេរជាអក្សរឡាតាំង។

(៤) លិខិតរបស់លោកសង្ឃរាជ ព្រះនាមអ៊ែរណេស ដ្រូអេរ ដែលសរសេរមកនិពន្ធសៀវភៅនេះ។ លោក វ៉ីណេ ដែលជាបូជាចារ្យទទួលបន្ទុកព្រះសហគមន៍កំពង់គ ចាត់ក្មេងប្រុសៗប្រាំនាក់ឲ្យមកនៅក្នុងអារាមជាមួយលោក ដ្រូអេ។ លោក វ៉ីណេ មានប្រសាសន៍ថា៖ «*១៥ ថ្ងៃក្រោយមក ក្មេងទាំងនោះត្រឡប់មកភូមិវិញ ហើយមួយខែកន្លងមក ក្មេងបីនាក់ទៀតក៏រត់មកដែរ។ ក្មេងទាំងនោះត្រឡប់មកវិញទៅមកវិញ មកពីរាល់ថ្ងៃសុក្របព្វជិតទាំងឡាយតែងយកខ្សែពួរចងរឹតចង្កេះ ឲ្យវាយគ្នាទៅវិញទៅមក ទៅតាមវិន័យរបស់ក្រុមគ្រួសារអស់លោក។ ក្មេងៗដែលមកពីសង្គមផ្សេងមិនយល់ការនេះ ហើយពោលជម្រាបថា លោកវាយគ្នានឹងខ្សែពួរយើងភ័យណាស់។ យើងមិនចង់នៅផ្ទះដែលមានមនុស្សវាយគ្នាដូច្នេះឡើយ!។ នៅវត្តកំពង់គ ក្មេងៗទាំងនោះពុំដែលឃើញហេតុការណ៍ដូច្នេះសោះ!* » ។

(៥) ក៏ប៉ុន្តែ សង្គ្រាមឆ្នាំ ១៩០ បានរំលាយការខិតខំរបស់លោក បាជ្រេ។ ក្នុងឆ្នាំក្រោយៗមក ការខិតខំទាក់ទងពុទ្ធបរិស័ទមានធ្វើបន្តទៅទៀត ហើយបានកាន់តែល្អប្រសើរឡើង។ ក្នុងឆ្នាំ ១៩៧៣ ទោះបី អស់លោកមានកិច្ចការជាបន្ទាន់ព្រោះសង្គ្រាមក៏ដោយ ក៏អស់លោកបូជាចារ្យបានប្រជុំគ្នាអស់រយៈពេលប្រាំថ្ងៃ ដើម្បីសិក្សាអំពីការប្រៀនប្រដៅរបស់ព្រះពុទ្ធ។ លោក ម៉ារសែលឡូ សាហ្គូ (Marcello Zago) ដែលជាបូជាចារ្យប្រចាំក្រុងវៀងចន្ទ ប្រទេសលាវ បានដឹកនាំអង្គប្រជុំនោះមានសាស្ត្រាចារ្យជាពុទ្ធសាសនបណ្ឌិតបីនាក់ បានចូលរួមប្រជុំផងដែរ។ អស់លោកទាំងបីមានសេចក្តីរីករាយខ្លាំង ដោយឃើញថា គ្រីស្តបរិស័ទកាតូលិកយកចិត្តទុកដាក់ នឹងការពិសោធន៍ ខាងព្រះពុទ្ធសាសនា និងពុំមានបំណងប្រឆាំងនឹងព្រះពុទ្ធសាសនាឡើយ។ ដោយបានស្គាល់ពុទ្ធសាសនាកាន់តែច្បាស់ គ្រីស្តបរិសទក៏ផ្តើមរករស្មី "*ពន្លឺនៃសេចក្តីពិត* " ដែលមានក្នុងសាសនាដទៃ ហើយយកចិត្តទុកដាក់ពន្យល់ពុទ្ធសាសនិកជនអំពីសាសនារបស់ព្រះគ្រីស្ត តាមរបៀបងាយយល់។

(៦) សេចក្តីរាយការណ៍ក្រុងប៉ារីសឆ្នាំ ១៩៥២ ទំព័រ ៧៥។ នៅពេលរៀនសូត្រក្នុងសាលា ប្រូវីដង់ នារីខ្មែរ ខ្លះបានដូរឈ្មោះតាមប្រពៃណីគ្រីស្តសាសនា។ ក្នុងចំណោមអ្នកទាំងនោះ មានអ្នកម្នាង "ស៊ុយ សាន" អ្នកម្នាង "ម៉ូនីក" ។ល។

(៧) លោក ចៅ សេង ជារដ្ឋមន្ត្រីក្រសួងអប់រំជាតិ។ សម្តេចសីហនុចោទលោកថាជាកុម្មុយនិស្ត។ លោកក៏ភៀសខ្លួន ទៅនៅប្រទេសបារាំង រួចចាប់ពីឆ្នាំ ១៩៧៦ មក លោកចូលទៅធ្វើការជាមួយពួកខ្មែរក្រហម។ លោកស្លាប់នៅក្នុងមន្ទីរឃុំឃាំងរបស់ខ្មែរក្រហម។ លោក គាត ឆុន ឡើងជារដ្ឋមន្ត្រីឧស្សាហកម្ម ទាំងក្នុងសម័យសម្តេចសីហនុ ទាំងក្នុងសម័យខ្មែរក្រហមទៀត ជារដ្ឋមន្ត្រីហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា។ លោក ជា សាន ជាគ្រីស្តបរិស័ទម្នាក់ ហើយជាអគ្គរដ្ឋទូតរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានៅក្រុងមូស្គូ។ ពួកខ្មែរក្រហមក៏បានសម្លាប់លោកចោលដែរ។ លោក វណ្ណ ម៉ូលីវណ្ណ ជាស្ថាបត្យករ សព្វថ្ងៃជាជនភៀសខ្លួន នៅប្រទេសស្វីស។ ចំពោះសកម្មភាពរបស់លោក ប៉ូលទេព អ៊ីម សូមអានសៀវភៅ Milton Osborne, "Before Kampuchea, preludes of tragedy", Londres-Sydney- Boston 1979, chapter 7, portraits 2, the Priest, pp. 67-68.

(៨) "*កងអាសារបស់ព្រះនាងម៉ារី*" ជាចលនាគោរពវិន័យសាសនាម្នាក់ហ្មត់ចត់ ដែលជាជាតិអៀរឡង់ឈ្មោះហ្វ្រង់ឌុហ្វ (Frank Duff) បានបង្កើតក្នុងឆ្នាំ ១៩២១ តាមគំនិតរបស់សន្ត លុយគ្រីញ៉ុងដឺម៉ុងហ្វ័រ (Saint Louis Grigon de Monfort) ។ "*សៀវភៅកងអាសា*" (Manuel légionnaire) បង្ហាញដល់ក្រុមសមាជិកនូវវិន័យប្រាប់របៀបអានគម្ពីរ របៀបអធិដ្ឋាន អង្វរនិងធ្វើសកម្មភាព។ "*សមាគមគ្រួសារស្មោះស្ម័គ្រ*" (ជាភាសាវៀតណាមថា Hoi Phat Ta) ប្រមូលផ្តុំគ្រួសារទាំងឡាយដែលស្រឡាញ់ស្មោះស្ម័គ្រចំពោះព្រះយេស៊ូ ស្របទៅតាមគំនិតខាងដើមសតវត្សទី ២០ ។ គ្រួសារទាំងឡាយចាត់ចែង ឲ្យមានពេលធ្វើពិធីផ្សេងៗ ខាងសាសនា និងដាក់វេនគ្នាសូត្រធម៌នៅផ្ទះនីមួយៗផង។ ប្រភេទសមាគមនសាសនាទាំងពីរនោះ ដែលគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ដាក់ឈ្មោះថា "*សកម្មភាពកាតូលិក*" ។

(៩) លិខិតរបស់លោកបូជាចារ្យឆ្នាំ ១៩៦៩ ទំព័រ ១១ ។

## ជំពូកទី ១៣

# ឆ្លើយសង្គ្រាមរាលរាលនៅប្រទេសកម្ពុជា

ថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០ វេលាម៉ោងមួយរសៀល ដូចក្រឡាប់ផែនដីខ្មែរ គឺលោកឧត្តមសេនីយ៍លន់ នល់ ទម្លាក់សម្តេចព្រះនរោត្តមសីហនុចេញពីតំណែង។ សហរដ្ឋអាមេរិក ទទួលស្គាល់របបថ្មីរបស់លោកលន់ នល់ភ្លាម ព្រោះសហរដ្ឋយល់ឃើញថា របបថ្មីនេះអាចជួយគេជាសម្ព័ន្ធមិត្ត នៅក្នុងសង្គ្រាមច្បាំងជាមួយវៀតណាមខាងជើងនិងពួកវៀតកុង (ពួកកុម្មុយនិស្តវៀតណាមខាងត្បូង) ដែលតាំងទ័ពនៅ ក្នុង "*ជម្រក*" លើទឹកដីខ្មែរ តាមបណ្តោយព្រំដែនប្រទេសកម្ពុជា-វៀតណាម។ ថ្ងៃទី ២៣ មីនា សម្តេច សីហនុ អំពាវនាវពីក្រុងប៉េកាំង ឲ្យអ្នកស្រុកស្រែរត់ចូលព្រៃ។ ទ្រង់ក៏បង្កើត "រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា" ដើម្បីវាយប្រយុទ្ធនឹងអ្នកដណ្តើមអំណាច។

រដ្ឋាភិបាលថ្មីនៅក្រុងភ្នំពេញ បានបញ្ជាពួកកុម្មុយនិស្តវៀតណាម ឲ្យចាកចេញពីទឹកដីខ្មែរ ក្នុងរយៈពេល ៤៨ ម៉ោង។ ពួកទាហានកុម្មុយនិស្តវៀតណាមឆ្លើយតបវិញ ដោយចូលលុកលុយស្រុកខ្មែរ ធ្វើឲ្យកងទ័ពរបស់ឧត្តមសេនីយ៍ លន់ នល់ កើតចលនាចលច្របូកច្របល់។ ពួកទាហានកុម្មុយនិស្តវៀតណាមទាំងនោះអះអាងថា សម្តេចសីហនុសុំឲ្យពួកខ្លួនចូលមកវាយដណ្តើមយកតំណែងដឹកនាំប្រទេសថ្វាយព្រះអង្គវិញ។

ក្នុងខែឧសភា និងខែ មិថុនា ឆ្នាំ ១៩៧០ កងទ័ពអាមេរិកកាំង និងកងទ័ពវៀតណាមខាងត្បូងចូលមក ប្រទេសកម្ពុជា ដើម្បីដេញពួកកុម្មុយនិស្តវៀតណាមចេញពីទីជម្រក នៅលើទឹកដីខ្មែរ។ អាស្រ័យដោយហេតុនេះ ប្រទេសកម្ពុជាក៏លិចស្រឹមទៅក្នុងសង្គ្រាម សម្លាប់បងប្អូនឯងអស់រយៈប្រាំឆ្នាំ។ ដោយមានពួក អាមេរិកាំងជួយគាំទ្រផង ពួកទាហាន "*នៃសាធារណរដ្ឋ*" របស់លោកឧត្តមសេនីយ៍ លន់ នល់ កាន់កាប់ទីក្រុងនានា។ ចំណែកឯពួកវៀតកុង និងពួកវៀតណាមខាងជើង កាន់កាប់និងគ្រប់គ្រងស្រុកស្រែចម្ការ។ បន្ទាប់មក ពួក"*ខ្មែរក្រហម*" គឺពួកកុម្មុយនិស្តខ្មែរ

ដែលបានទទួលការហ្វឹកហ្វឺន និងការអប់រំពីពួកវៀតណាមខាងជើង ហើយដែលមានប្រទេសចិនជួយគាំទ្រផង បានកាន់កាប់បន្តពីពួកវៀតកុង(១)។

"**កាប់យួន**"

លោកឧត្តមសេនីយ៍ លន់ នល់ អុជអាលធ្វើឲ្យគំនុំចងពៀររវាងខ្មែរ វៀតណាម ដែលមានមករាប់សតវត្សហើយនោះ ឆេះឆាបខ្លាំងឡើងថែមទៀត ដើម្បីប្រមូលប្រជាពលរដ្ឋឲ្យគាំទ្ររដ្ឋាភិបាលរបស់លោក។ ថ្ងៃទី ៨ មីនា លោកចាត់ចែងឲ្យធ្វើបាតុកម្មនៅខេត្តស្វាយរៀង ហើយថ្ងៃទី ១១ មីនា មានបាតុកម្មនៅភ្នំពេញ។ កំហឹងឆាបឆេះឡើងបណ្ដាលឲ្យប្រជាជនខ្មែរលែងយល់អ្វីទាំងអស់ ចាប់ពីពេលនោះមក ប្រជាជនខ្មែរចាត់ជនជាតិវៀតណាមទាំងអស់ដែលរស់នៅប្រទេសកម្ពុជា ទុកជា "*វៀតកុង*" ។

ក្នុងព្រះសហគមន៍ មានជនជាតិវៀតណាមជាច្រើន។ ដូច្នេះ ប្រជាជនខ្មែរភាគច្រើនស្មានថា ពាក្យ "*កាតូលិក*" និងពាក្យ "*វៀតណាម*" មានន័យដូចគ្នា។ មានពាក្យស្លោកជាភាសាបារាំងបិទនៅតាមផ្លូវដែលសរសេរថា៖ «បរាជ័យទៅពួកយួន!=A bas les Viêts! » (គេសរសេរអក្សរ "T" ជារាងឈើឆ្កាង)។ ពាក្យស្លោកខ្លះទៀតជាភាសាខ្មែរ មានសេចក្ដីថា"កាប់យួន"។ តាំងពីមានបាតុកម្មលើកដំបូងម្ល៉េះ ប្រជាជនខ្មែរវាយកម្ទេចភូមិជាច្រើន ដែលមានគ្រីស្ដបរិស័ទវៀតណាមរស់នៅ។ ថ្ងៃទី ១១ មីនា វេលាម៉ោងដប់យប់ គេបំផ្លាញព្រះវិហារតូចនៅចម្ងាយ ប្រាំ គ.ម. ខាងជើងក្រុងភ្នំពេញ ទាំងពង្រាត់ពង្រាយព្រះកាយព្រះគ្រីស្ដនៅលើដី និងគរប្រដាប់ប្រដាសម្រាប់ធ្វើពិធីបុណ្យ នៅមុខព្រះវិហារ ហើយដុតកម្ទេចចោល។ គេវាយបំបែកអាសនៈ ហើយបោចរោចគ្រឿងអគ្គីសនីចោលទៀតផង។ ថ្ងៃទី ១២ គេកម្ទេចព្រះវិហារធំនៅឫស្សីកែវចោល ថ្ងៃទី ១៧ ព្រះវិហារកំពង់ត្របែក ថ្ងៃទី ១៨ ព្រះវិហារនាក់លឿង។ គេពុំហ៊ានកម្ទេចព្រះវិហារនៅភូមិកាតូលិក "ព្រះមាតា"ទេ ព្រោះលោកស័ក្តិប្រាំក្រូចសំរេច ដែលជាខ្មែរកាតូលិកចូលធ្វើអន្តរាគមន៍ការពារព្រះវិហារនោះ ដោយចិត្តអង្គអាច។

បន្ទាប់ពីរដ្ឋសភាបានទម្លាក់សម្ដេចសីហនុចោល និងបន្ទាប់ពីពួកវៀតកុងបានចូលលុកប្រទេសកម្ពុជាមក រដ្ឋាភិបាលខ្មែរនៅតែសង្ស័យគ្រីស្ដបរិស័ទ។ អស់លោកចង់រុករើឆែកឆេរព្រះវិហារទាំងអស់ ព្រោះអស់លោកជឿជាក់ថា វិហារទាំងនោះសុទ្ធតែជាទីជម្រកសម្រាប់

ពួកវៀតកុង និងជាឃ្លាំងទុកគ្រាប់រំសេវផង។ ជួនកាលយន្តហោះឃោជាខ្មែរទម្លាក់គ្រាប់បែក កម្ទេចព្រះវិហារចោលតែម្តង។ ដូចជានៅថ្ងៃទី ១២ មេសា កប៉ាល់ហោះកម្ទេចព្រះវិហារព្រែកក្របៅ ថ្ងៃទី ២៩-៣០ ព្រះវិហារកាហោ ថ្ងៃទី ៦ ឧសភា ព្រះវិហារបាណាម ថ្ងៃទី ៩ ឧសភា ព្រះវិហារសៀមរាប ចុងខែឧសភា ព្រះវិហារបឹងកាជោត ដើមខែសីហា ព្រះវិហារខ្សាច់ប្រឆេះនិងព្រះវិហារជាច្រើនទៀត នៅពេលខាងក្រោយជាបន្តបន្ទាប់មក។ ថ្ងៃទី ១៩ មេសា ក្រសួងអប់រំជាតិបញ្ជាឲ្យ "*បិទសាលាឯកជនបរទេសទាំងអស់ ទាំងសាលាចិន សាលាវៀតណាម ទាំងសាសនាផង*"។ គំនុំចងពៀរជាតិសាសន៍ក៏បង្កើតឲ្យជនជាតិខ្មែរចង់សម្លាប់ពួកវៀតណាមយ៉ាងឆាប់រហ័ស៖

- ថ្ងៃទី ១០ មេសា នៅទីប្រជុំជនប្រសូតក្នុងខេត្តស្វាយរៀង ទាហានខ្មែរចាប់ជនស៊ីវិលវៀតណាមប្រហែល ១៥០ នាក់ ទាំងប្រុស ទាំងស្រី ទាំងកូនក្មេងយកទៅឃុំទុកក្នុងទីលានមួយដែលមានលួសបន្លាព័ទ្ធជុំវិញ រួចបាញ់រះសម្លាប់អ្នកទាំងនោះចោលទៅ។ នៅក្នុងចំណោមជនអភ័ព្វទាំងនោះមានគ្រីស្តបរិសទរាប់សិបនាក់។
- ថ្ងៃទី ១២ មេសា នៅភ្នំពេញទាហានខ្មែរចាប់ផ្តើមចាប់ជនជាតិវៀតណាម។ ជាដំបូងគេចាប់ពួកវៀតណាមនៅក្រុមគ្រីស្តបរិស័ទ ចំណុះជើងព្រះវិហារសន្តីអាណ្ណា (Sainte Anne) ដែលជាព្រះវិហារជាប់ នឹងវិហារ "ព្រះមាតា" នៅជិតរោងចក្រអគ្គីសនី: គេយកប្រុសៗទៅឃុំទុកនៅជំរំមួយ ឯពោធិ៍ចិនតុង រីឯស្រីៗឃុំនៅស្នងការដ្ឋានកណ្តាលរបស់ក្រុមនគរបាល។ ពេលកណ្តាលអាធ្រាត្រ យប់ថ្ងៃទី ១២-១៣ ខែមេសា ទាហានខ្មែរឡោមព័ទ្ធភូមិជ្រោយចង្វារ ជាភូមិដែលមានសុទ្ធតែជនជាតិវៀតណាមកាតូលិករស់នៅ។ ទាហានចាប់ប្រុសៗទាំងអស់ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង ទៅបង្ខំឲ្យឡើងនាវាផ្ទុកទំនិញ រួចនាវានោះបើកចេញទៅទិសខាងត្បូង។ ទៅបានប្រហែល ៣០ គីឡូម៉ែត្រពួកទាហានចាប់ប្រុសៗវៀតណាមទាំងនោះចងស្លាបសេក និងបញ្ជាឲ្យចេញតម្រៀបជួរម្តងដប់នាក់ៗ នៅខាងក្រៅកប៉ាល់ ហើយបាញ់សម្លាប់ចោលទាំងអស់គ្មានសល់ឯសាកសពទាំងនោះក៏ធ្លាក់ចុះក្នុងទឹក។ អ្នករួចរស់ជីវិតបីបួននាក់បាននិយាយថា គ្រីស្តបរិសទខ្លះយល់ថា ពួកគេមិនអាចគេចផុតពីសេចក្តីស្លាប់ក៏ចាប់ ច្រៀងបទចម្រៀងសាសនា ទាំងបញ្ជាក់ជំនឿយ៉ាងអស្ចារ្យគួរឲ្យសរសើរ។ ទាហានបានដាក់អ្នកឯទៀតៗនៅត្រើយខាងកើតនៃទន្លេមេគង្គហើយសម្លាប់គេក្នុងថ្ងៃជាបន្តបន្ទាប់មក។ ពីថ្ងៃទី ១០ ដល់ ១៥ មេសា សាកសពរាប់ពាន់អណ្តែតនៅលើទន្លេមេគង្គត្រង់កំពង់ចម្លងសាឡាងនាក់លឿង។ ក្នុងចំណោម

សាកសពទាំងនោះ មានគ្រីស្តបរិស័ទពីភូមិជ្រោយចង្វារចំនួន ៥១៤ នាក់។ នៅពេលនោះ និងនៅក្នុងថ្ងៃជាបន្តបន្ទាប់មកទៀត ទាហានខ្លះទៀតចាប់រំលោភ ស្រីមេម៉ាយ និងយុវនារី ដែលរស់នៅឯជ្រោយចង្វារតែលគោល ឥតទីពឹងតាមអំពើចិត្តរបស់ខ្លួន។

- ថ្ងៃទី ១៣ មេសា កងទ័ពខ្មែរឡោមព័ទ្ធភូមិកាតូលិកវៀតណាម ឈ្មោះសំរោងធំនៅជិតនាក់លឿងដោយឃាត់មិនឲ្យនាំគ្រឿងបរិភោគចូលឡើយ។ ថ្ងៃទី ១៤ គេចាប់ជនជាតិវៀតណាមស្រុកកោះធំ យកទៅឃុំទុកក្នុងរោងចក្រតម្បាញ រ៉ែង ហ្គរ នៅឯចាក់អង្រែ ខាងត្បូងភ្នំពេញ។ ថ្ងៃទី ១៥ គេចាប់គ្រួសារវៀតណាមពីមាត់ក្រសាស់ មកឃុំក្នុងរោងចក្រនេះជាមួយនឹងពួកកោះធំ។ ក្នុងថ្ងៃដដែលនេះ បន្ទាប់ពីពួកវៀតកុងបានក្រុងតាកែវមក ទាហានខ្មែរបាញ់សម្លាប់ជនស៊ីវិលវៀតណាម ដែលរស់នៅក្នុងក្រុងតាកែវនោះ ប្រហែល ២៥០ នាក់ នៅនឹងទីផ្សារតែម្តង។
- ថ្ងៃទី ២៣ នៅស្រុកស្អាង ឧត្តមសេនីយ៍មេបញ្ជាការកងទ័ពខ្មែរដែលមានឪពុកជាជនជាតិហ្វីលីពីន និងម្តាយជាតិវៀតណាមហើយជាកាតូលិកថែមទៀត ចាប់ជនស៊ីវិលវៀតណាមចំនួន ១០០ នាក់ ដែលភាគច្រើនជាកាតូលិក ធ្វើជាខែលមកដាក់នៅចន្លោះកងទ័ពខ្មែរ និងកងទ័ពវៀតកុង។

លោកឡឺម៉ែត្រ (Mgr Lemaître) ជាប្រតិភូរបស់សម្តេចប៉ាប អញ្ជើញមកពីក្រុងព្រៃនគរពីថ្ងៃទី ១៣ មេសា ម្ល៉េះ។ ដោយលោកឡឺម៉ែត្រនេះ និងសហគមន៍អន្តរជាតិធ្វើអន្តរាគមទាហានឈប់សម្លាប់រង្គាលជនជាតិវៀតណាម ក៏ប៉ុន្តែពួកគេនៅតែមើលងាយធ្វើបាបជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាតទៅទៀត ពួកគេនៅចាប់ជនជាតិវៀតណាម ក្នុងអំឡុងជាច្រើនខែបន្តទៅទៀត។ នៅកំពង់ចាមលោកឡឺស៊ូអែហ្វ (Mgr Lesouëf) បានទៅជួបលោកអ៊ិន តាំ ដែលជាអភិបាលខេត្តថ្មី សុំឲ្យលោកទុកជីវិតជនជាតិវៀតណាមដែលរស់នៅក្នុងខេត្តនេះ។ ពេលនោះលោកប៉ុង សូដ៍ ក៏ជួលកប៉ាល់ផ្ទុកទំនិញមួយយ៉ាងធំ ទៅដឹកពួកវៀតណាមកាតូលិក ដែលមានចំនួនច្រើនក្នុងចំណោមប្រជាជនវៀតណាមនៃខេត្តនោះ។ រដ្ឋអំណាចបានប្រមូលជនជាតិវៀតណាមទាំងនោះនៅកីឡាដ្ឋានក្រុងកំពង់ចាម ក្រោមកិច្ចរក្សាការពាររបស់យោធា។ ចំណែកឯជនជាតិវៀតណាមដែលនៅភាគត្បូងប្រទេស ពោលគឺនៅជិតព្រំប្រទល់វៀតណាម គេក៏រត់ទៅកាន់មាតុប្រទេសរៀងៗខ្លួន។

ចលនាបំបាត់ពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម បណ្ដាលឲ្យប្រទេសវៀតណាមខាងត្បូងមានការឈឺចាប់ជាខ្លាំង។ ថ្ងៃទី ២៦ មេសា គណៈប្រតិភូវៀតណាមមួយពីព្រៃនគរ មកចរចារសុំយកជនជាតិ វៀតណាមដែលរស់នៅប្រទេសកម្ពុជា ទៅមាតុប្រទេសវិញ។ ថ្ងៃទី ១០ ឧសភា កងនាវាដឹកនាំទំនិញមួយកង ដោយមានកប៉ាល់ចម្បាំងជូនដំណើរផង ចេញពីប្រទេសវៀតណាមឡើងទៅដល់កំពង់ចាម តាមទន្លេមេគង្គ។ កងនាវានោះ បានដឹកយកជនជាតិវៀតណាម ដែលទាហានឃុំឃាំងនៅក្នុងកីឡាដ្ឋានត្រឡប់ទៅវិញ និងដឹកយកអ្នកខ្លះទៀតដែលគេឃុំនៅភ្នំពេញដែរ។

រដ្ឋអំណាចបានប្រមូលផ្ដុំជនជាតវៀតណាម ដែលនៅសល់ក្នុងប្រទេសកម្ពុជាទាំងអស់ ដើម្បីដេញចេញបន្តិចម្ដងៗទៅប្រទេសវៀតណាមវិញ។ រដ្ឋាភិបាលយកព្រះវិហារ និងអាគារឯទៀតៗរបស់ព្រះសហគមន៍ នៅភ្នំពេញជាជំរំជនភៀសខ្លួន។ ដូច្នេះ គេប្រមូលជនជាតិវៀតណាមចំនួន ១៥.៨០០ នាក់ ដាក់នៅក្នុងអាគារទាំងឡាយរបស់ក្រុមដូនជីឧបការគុណ ១៩.៧០០ នាក់ ដាក់នៅក្នុងបរិវេណជិតអាគារព្រះវិហារឫស្សីកែវ និង ១៣.២៣០ នាក់ ដាក់នៅក្នុងទេវវិទ្យាល័យតូច។ បើនិយាយតែពីជំរំសំខាន់ៗតែប៉ុណ្ណោះ។ ដោយអាគារទាំងឡាយតូចចង្អៀតពេក មនុស្សភាគច្រើនស្នាក់នៅក្នុងទីធ្លា និងក្នុងសួនដោយជ្រកក្រោមកំណាត់ប្លាស្ទិច។ គ្រួសារនីមួយៗបានកន្លែងរស់នៅបីបួនម៉ែត្រក្រឡាប៉ុណ្ណោះ។ ដូច្នេះ នៅភ្នំពេញមានជនភៀស ខ្លួនវៀតណាម ចំនួន ៧០.០០០ នាក់ស្នាក់នៅក្នុងជំរំទាំងនោះ។ រីឯនៅតាមខេត្តនានាវិញ រដ្ឋអំណាចប្រមូលផ្ដុំជនជាតិវៀតណាមចំនួន ១៥០.០០០ នាក់ គឺនៅកំពង់ចាម ប៉ោយប៉ែត កំពង់ឆ្នាំង នៅពោធិ៍សាត់។ល។ ការដឹកជញ្ជូនសហគមន៍វៀតណាមត្រឡប់ ទៅមាតុប្រទេសវិញ បន្តរហូតដល់ថ្ងៃទី ១៥ ខែសីហា ជាថ្ងៃកំណត់ជាផ្លូវការឈប់ដឹកទៀត [២]។

### សម្ពុរសធម៌ និងការម្ពុរភោន់ពូជសាសន៍

តាំងពីទាហានផ្ដើមគ្រញីបចាប់ជនជាតិវៀតណាមមកម្ល៉េះ ព្រះសហគមន៍កាតូលិកប្ដេជ្ញាចិត្តខំធ្វើឲ្យរដ្ឋអំណាចខ្មែរអាណិតជនទាំងនោះ កុំឲ្យគេវេទនាពេក។ ជាបឋមគួរសរសើរនូវសេចក្ដីក្លាហានរបស់គ្រីស្ដបរិស័ទខ្មែរនៅចំណោម គឺពួកគេហ៊ានប្រថុយជីវិត ដើម្បីរៃប្រមូលអង្ករយកទៅចែកជនជាតិវៀតណាមជាប់ឃុំឃាំងនៅមង្គលបូរី។ នៅក្នុងវត្តត្របែក ព្រះសង្ឃពុទ្ធសាសនាក៏ប្រថុយទទួលដូនជីវៀតណាម

ឲ្យស្នាក់អាស្រ័យនៅក្នុងវត្តដែរ ក្រោយពីពួកទាហានបានដុតបំផ្លាញព្រះវិហារ និងភូមិដែលមានគ្រីស្តបរិស័ទវៀតណាមរស់នៅ។

បន្ទាប់មក អស់លោកបូជាចារ្យ បព្វជិត និងបព្វជិតាបារាំង ជាពិសេសបព្វជិត និងបព្វជិតា នៅភ្នំពេញដែលមានគ្នាចំនួនដប់នាក់ បានខ្នះខ្នែងជួយជនភៀសខ្លួនទាំងនោះ។ រដ្ឋាភិបាលគ្មានបានចាត់វិធានការអ្វី សម្រាប់ពួកវៀតណាមដែលជាប់ឃុំទាំងនោះទេ ចំណីអាហារក៏គ្មានថ្នាំព្យាបាលជំងឺដែរ។ អ្នកកាន់អំណាចមានដល់ទៅជំទាស់មិនឲ្យអ្នកដទៃជួយថែមទៀតផង ទោះបីជាជំនួយបែបណាក៏ដោយ។ ថ្ងៃមួយ ដោយដឹងថាជនភៀសខ្លួនរងទុក្ខវេទនាខ្លាំងពេក លោកអេមីលដេតុម (Emile Des tombes) លែងទ្រាំទ្របានទៀត ក៏បើកឡានជំផ្ទុកគ្រឿងបរិភោគទម្លាយរបាំងទាហានដែលហាមឃាត់មិនឲ្យចូលទៅក្នុងរោងចក្រចាក់អង្រែ។ តាំងពីយូរថ្ងៃមកហើយ ជនជាប់គុករាប់ពាន់នាក់គ្មានអ្វីបរិភោគសោះឡើយ។ ម្យ៉ាងទៀត ទោះបីពេលនោះជារដូវក្តៅហែង ហើយពួកគេរស់នៅគរជើងលើគ្នាក្នុងរោងចក្រធ្វើអំពីស័ង្កសីក៏ដោយ ក៏ពួកគេគ្មានទឹកប្រើប្រាស់ដែរ គ្មានពន្លឺ និងខ្យល់អាកាសចេញចូលទៀត។ មានខ្យល់ត្រជាក់ចូលម្តងៗ តែនៅពេលទាហានបើកទ្វារបញ្ចេញខ្មោចប៉ុណ្ណោះ។ នៅក្នុងជំរំឯទៀតៗ ក៏មិនជាស្រួលជាងនេះឡើយ ដោយទាហានដែលយាមគុក តែងលួចចាប់រំលោភស្រីៗទៀត។ ពួកទាហានទាំងនោះចាត់ទុការលួចការរំលោភបែបនេះ ជាជ័យជំនះលើសត្រូវវៀតកុង។

ព្រះសហគមន៍កាតូលិកបានផ្តើមគំនិតបង្កើត "*គណៈកម្មធិការជួយជនរងគ្រោះដោយសង្គ្រាម*" ។ "*គណៈកម្មការសង្គហៈ* "នេះ បានសុំឲ្យគណៈរដ្ឋមន្ត្រីទទួលស្គាល់។ ព្រះសហគមន៍ក៏បានអញ្ជើញតំណាងសាសនាគឯទៀតៗ ឲ្យចូលរួមជាមួយផងដែរ ប៉ុន្តែពុទ្ធសាសនិកជន និងអ្នកកាន់សាសនាអ៊ីស្លាមមិនព្រមទទួលសេចក្តីអញ្ជើញនេះទេ។ លោកយ៉ូហានក្លាវ៉ូ (Jean Clavaud) ខាងក្រុមជំនុំប្រកាសដំណឹងល្អក៏បានចូលរួមជាមួយដែរ។ វេជ្ជបណ្ឌិតខ្មែរម្នាក់ឈ្មោះតាន់ហៀន ធ្វើជាប្រធានគណៈកម្មការសង្គហៈនោះ ហើយលោក អេមីល ដេតុម ជាអគ្គលេខាធិការ។

រហូតមកទល់នឹងពេលរដ្ឋមន្ត្រីខ្មែរនិងវៀតណាម ធ្វើកិច្ចព្រមព្រៀងនាដើមខែឧសភា មានតែគណៈកម្មការសង្គហៈនេះទេ ដែលទំនុកបម្រុងជំរំទាំងនោះ។ គណៈកម្មការសង្គហៈទិញអង្ករត្រីងៀត និងបន្លែបង្កាផ្សេងៗផ្គត់ផ្គង់ជនភៀសខ្លួនទាំងនោះ។ ថវិការចំណាយ គឺជាប្រាក់ជំនួយដែលបានមកពីក្រុមប្រឹក្សាពិភពលោក នៃព្រះសហគមន៍ទាំងឡាយ ពីអង្គការទំនុកបម្រុងគ្រីស្តសាសនានានា មានជាអាទិ៍ "អង្គការ មេត្តាករុណាធម៌ អន្តរជាតិ (Caritas Internationalis) "អង្គការកាតូលិកសម្រាប់ជួយសង្គ្រោះ (Catholic Relief Service)" ដែលជាអង្គការអាមេរិក។

គណៈកម្មការសង្គហៈសង្គ្រោះ បានបើកមន្ទីរពេទ្យសង្គ្រោះជាបន្ទាន់ សម្រាប់ជនភៀសខ្លួន។ តាំងពីខែ ឧសភាមក គឺក្រោយពីមានធ្វើកិច្ចព្រមព្រៀងជាមួយវៀតណាម រដ្ឋាភិបាលខ្មែរសុំព្រះសហគមន៍ឲ្យបន្តកិច្ចការតទៅទៀត រួមជាមួយនឹងគណៈកម្មាធិការដែលរដ្ឋាភិបាលទើបនឹងបង្កើតឡើង សម្រាប់ជួយជនភៀសខ្លួន។ អង្គការកាតូលិកទទួលបន្ទុកមណ្ឌលប្រាំមួយនៅភ្នំពេញ ហើយរដ្ឋទទួលបន្ទុកមណ្ឌលប្រាំមួយទៀត។ ក្នុងគ្រាដំបូងរដ្ឋាភិបាលមានមន្ទិលសង្ស័យនឹងគណៈកម្មការសង្គហៈ តែក្រោយមកបែរទៅជាមានបរិយាកាសស្រឡាញ់រាប់អានគ្នាយ៉ាងពិតប្រាកដ។

**«បើបុរសិនជាគ្រាប់ពូជស្រូវសាឡីមិនស្លាប់បាត់បង់ទេនោះ... »**

លោក វ៉ាំងសង់រ៉ូឡាំង (Vincent Rollin) និងលោកហ្វ្រង់ស័រក្លូដែល ( François Claudel) បានបូជាជីវិត នៅក្នុងកិច្ចបម្រើជនជាតិវៀតណាម។

ជារៀងរាល់ថ្ងៃ អស់លោកបូជាចារ្យបារាំងតែងចេញពីក្រុងភ្នំពេញ ទាំងយកជំនួយផ្សេងៗ ទៅចែកជនជាតិវៀតណាម ដែលកងទ័ពឡោមព័ទ្ធជាប់នៅក្នុងភូមិរបស់ខ្លួន ឬដែលគេប្រមូលផ្តុំនៅក្នុងជំរំនានា។ ថ្ងៃទី ៥ ឧសភា លោកវ៉ាំងសង់រ៉ូឡាំង (Vincent Rollin) អាយុ ៣២ ឆ្នាំ មានដើមកំណើតនៅម៉ុងតូបង់ (Montau ban) ទទួលបន្ទុកទៅជួយយកអាសាជនភៀសខ្លួនទាំងឡាយនៅមាត់ក្រសាស់ ចម្ងាយ ១៥ គីឡូម៉ែត្រ ខាងត្បូងក្រុងភ្នំពេញត្រើយខាងកើតទន្លេមេគង្គ។ លោកហ្វ្រង់ស័រក្លូដែល ( François Claudel) ជាអ្នក ស្រុកវ៉ូស (Vosges) អាយុ ៥០ ឆ្នាំ ។ លោកត្រូវទៅជួយសង្គ្រោះជនជាតិវៀតណាម ដូចគ្នា នៅឯសំរោងធំ នាត្រើយខាងលិចនៃទន្លេមេគង្គ ជិតនាក់លឿង។ បន្ទាប់ពីលោក

វ៉ាំងសង់រ៉ូឡាំង ត្រឡប់មកពីក្រសាស់វិញ បូជាចារ្យទាំងពីរអញ្ជើញទៅសំរោងធំជាមួយគ្នា។ លោកពិសាបាយជាមួយលោកថោង សូវ៉ាត ជាបូជាចារ្យវៀតណាមទទួលបន្ទុកក្រុមគ្រីស្តបរិស័ទនៅទីនោះ រួចហើយក៏អញ្ជើញទៅនាក់លឿងដែលបានធ្លាក់ទៅក្នុងកណ្តាប់ដៃពួកវៀតកុង ចំនួនបីបួនថ្ងៃមកហើយ។ លោក ក្លូ ដែលប្រាថ្នាយកប្រាក់ និងថ្នាំពេទ្យបន្តិចបន្តួចទៅជូនលោក ហ្គូអាំង (Gouin) និងលោកយ៉ូសែបប៉ារ៉េ (Joseph Parais) ដែលជាបូជាចារ្យបារាំងទទួលបន្ទុកបម្រើក្រុមគ្រីស្តបរិស័ទបាណាម។ ក៏ប៉ុន្តែពួកវៀតកុងចាប់លោកទាំងពីរនាក់នៅត្រង់ត្រឡែង កែងផ្លូវលំព្រៃកដាច់ ចង់មុខលោក ហើយនាំយក ទៅទីបញ្ជាការរបស់ពួកគេនៅក្នុងវត្តព្រៃកទន្លាប់។ លោក ជាប់នៅទីនោះពីរថ្ងៃទាំងជាប់ចំណងនិងចងមុខជិតជានិច្ច។ បន្ទាប់មកពួកវៀតកុងនាំលោកទៅត្រើយខាងកើតនៃទន្លេមេគង្គ។ គ្រីស្តបរិសទបាណាមបានឃើញលោកទាំងពីរនាក់ដើរកាត់ទីនោះ។ ពួកវៀតកុង ដែលបណ្តើរលោកប្រកាសថា ពួកគេបាញ់ធ្លាក់កប៉ាល់ហោះអាមេរិក ហើយចាប់បានអ្នកបើកយន្តហោះពីរនាក់។ ពួកគេនាំលោកទៅដីក្រហមនាត្រើយស្ទឹងស្លូត ខាងកើតព្រៃកក្របៅ។ គេទុកលោកបូជាចារ្យទាំងពីរនាក់ ឲ្យនៅជាមួយពួកទាហានខ្មែរដែលគេចាប់ជាឈ្លើយ ពេលវាយយកនាក់លឿងបាន។ ថ្ងៃទី ១០ ឧសភា កងទ័ពវៀតណាមខាងត្បូងវាយយកនាក់លឿងបានមកវិញ។ ពេលនោះ ពួកវៀតកុងក៏សម្លាប់លោកបូជាចារ្យទាំងពីរ និងទាហានខ្មែរដែលអ្នកស្រុកចោទថា បានប្រព្រឹត្តបទល្មើសផ្សេងៗ។ យុវជន រ៉ែន ដែលពីដើមធ្វើជាអ្នកអប់រំជំនឿនៃគ្រីស្តសាសនា ហើយបានចូលបម្រើកងទ័ពក៏ជាប់ជាឈ្លើយនៅទីនោះដែរ តែគាត់បានរត់រួច។

លោក វ៉ាំងសង់រ៉ូឡាំង បានសរសេរនៅក្នុងបណ្តាំរបស់លោកថា៖ «*តាំងពីដើមរៀងមកខ្ញុំមានបំណងចង់ស្លាប់ក្នុងវ័យក្មេង។ បំណងនេះ ប្រហែលជាមកពីខ្ញុំគិតតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះទេដឹង គឺមកពីខ្ញុំចង់គេចឲ្យផុតពីការទទួលខុសត្រូវ ពីការលំបាកវេទនា នៅក្នុងជីវិតក៏ថាបានដែរ។ តាមពិតបំណងនេះ គឺមកពីខ្ញុំប្រាថ្នាឲ្យឆាប់បានទៅជិតព្រះជាម្ចាស់ផងដែរព្រោះថា ខ្ញុំបានបូជាជីវិតខ្ញុំចំពោះព្រះអង្គហើយ*»។

គ្រីស្តបរិស័ទវៀតណាមមួយចំនួន មិនយល់ហេតុដែលទាក់ទាញចិត្តលោក ឲ្យស្រឡាញ់ជនជាតិខ្មែរខ្លាំងម្លេះ ហើយក៏ចេះតែនាំគ្នាបន្ទោសលោកថា លោកមិនស្រឡាញ់ពួកគេទេ។ នៅក្នុងលិខិតនោះ លោករ៉ូឡាំងសរសេរផ្តាំមិត្តរបស់លោកថា៖ «*បើប្រសិនជាលោកអាចនិយាយជាមួយពួកគេបាន សុំប្រាប់គ្រីស្តបរិស័ទវៀតណាមថា ខ្ញុំស្រឡាញ់*

*បងប្អូនខ្មែរលើសគេ ព្រោះព្រះអម្ចាស់ និងព្រះសហគមន៍បានចាត់ខ្ញុំមក សម្រាប់អ្នកទាំងនោះ។ តែការស្រឡាញ់បងប្អូនខ្មែរដូច្នេះ គឺមិនមែនបានន័យថា ខ្ញុំមិនស្រឡាញ់បងប្អូនវៀតណាមទេ។ ប៉ុន្តែ តាមពិត ខ្ញុំស្រឡាញ់បងប្អូនខ្មែរជាងគេ ព្រោះគ្នាគ្មានពំនឹងនៅក្នុងព្រះសហគមន៍»*[៣] ។

**ទុក្ខរបស់ព្រះសហគមន៍**

សង្គ្រាមទើបតែកើតឡើងបានប្រាំមួយខែប៉ុណ្ណោះ ព្រះសហគមន៍ប្រចាំប្រទេសកម្ពុជាក៏ជួបប្រទះនឹងទុក្ខយ៉ាងខ្លាំងដែរ។

* ក្នុងខែមីនា ឆ្នាំ ១៩៧០ គ្រីស្តបរិសទនៅប្រទេសកម្ពុជា មានចំនួន ៦៥.០០០ នាក់។ ប្រាំមួយខែក្រោយមក នៅសល់គ្នាស្ទើរមិនបាន ៧.០០០ នាក់ផង គឺមានគ្រីស្តបរិស័ទខ្មែរប្រហែល ៣.៥០០ នាក់ ហើយក្នុងចំណោមគ្រីស្តបរិស័ទខ្មែរទាំងនោះ មាន ៩០០ នាក់ រស់នៅក្នុង "*តំបន់រំដោះ*" ថែមទៀតផង។ គ្រីស្តបរិស័ទចិនមានពី ៨០០ ទៅ ១០០០ នាក់រស់នៅក្នុងក្រុងភ្នំពេញ ឬនៅបាត់ដំបង ហើយគ្រីស្តបរិស័ទវៀតណាម មាន ៣.០០០ ទៅ ៤.០០០ នាក់ ច្រើននៅភ្នំពេញ។
* កាលពីមុន ភូមិភាគកាតូលិកទាំងបីមានបូជាចារ្យចំនួន ៦១ នាក់។ ប្រាំមួយខែក្រោយមក មានបូជាចារ្យតែ ១៩ នាក់ប៉ុណ្ណោះ គឺមានបូជាចារ្យខ្មែរបីនាក់ (ក្នុងបីនាក់នេះ មានទាំងលោកអភិបាលព្រះសហគមន៍បាត់ដំបងម្នាក់ផង) សាសនទូតបរទេស ១៦ នាក់ (ក្នុង ១៦ រូបនេះ មានលោកអភិបាលពីរនាក់ ១១ នាក់ផង)។ មានយុវជនខ្មែរម្នាក់បានបញ្ចប់ការរៀនសូត្រនៅប៉េណាង។ មានសាសនទូត ១១ នាក់ ត្រឡប់ទៅប្រទេសបារាំងវិញ ព្រោះអស់លោកមានវ័យចាស់ហើយ។ មានបូជាចារ្យ ២៤ នាក់ (វៀតណាម ១២ នាក់ បារាំង ១១ នាក់ ចិនម្នាក់) តាមគ្រីស្តបរិស័ទទៅប្រទេសវៀតណាម[៤]។ ក្នុងឆ្នាំ ១៩៧២ សមាជិកម្នាក់នៃសមាគមមិត្តសម្លាញ់ព្រះយេស៊ូជាជាតិចិនតៃវ៉ាន់ គឺលោកស្ដេផានវ៉ង់ (Etienne Wang) មកដឹកនាំសហគមន៍ចិនអស់រយៈពេលពីរឆ្នាំ។ សមាជិកសមាគមព្រះយេស៊ូម្នាក់ទៀត ដែលជាជនជាតិបាសអេស្ប៉ាញ គឺលោកលុយបូឡុំប៊ូរូ (P.Luis Bolumburu) ដែលមកអំពីតៃវ៉ាន់ដែរនោះ មកជំនួស លោក វ៉ង ហើយនៅធ្វើការរហូតដល់ខែមីនា ឆ្នាំ ១៩៧៥។ ក្នុងឆ្នាំ ១៩៧៣ លោក ប៉ែរណា ប៉ែរសេ (Benard Berger) ដែលមកពីប្រទេសបារាំង[៥] ទទួលតំណែងបន្តអំពី លោកអង់ ទាន់វ័រពុំង (Antoine Voirin) ដែលជាជនជាតិបារាំង ដូចលោកដែរ

សម្រាប់បម្រើក្រុមគ្រីស្តបរិស័ទជនជាតិអឺរ៉ុប ចំណុះវិសាលវិហារ។

* បព្វជិតាជាង ២០០ នាក់ នៃក្រុមគ្រួសារទាំងពីរគឺ "*ក្រុមគ្រួសារបុត្រីព្រះនាងម៉ារី*" និង "*ក្រុមគ្រួសារបព្វជិតានៃព្រះឧបការគុណ* " ត្រូវគេដេញទៅប្រទេសវៀតណាម ឬក៏ទៅប្រទេសបារាំង។ មានតែបព្វជិតា ៤១ នាក់ប៉ុណ្ណោះ ស្ម័គ្រចិត្តនៅប្រទេសកម្ពុជា គឺមានបព្វជិតាខ្មែរ ៩ នាក់ ចិន ៥ នាក់ វៀតណាម ២០ នាក់ និងបារាំង ៧ នាក់។ ដូនជីទាំងនេះ នៅក្នុងក្រុមគ្រួសារបព្វជិតានៃព្រះឧបការគុណទាំងអស់គ្នា។
* បូជាចារ្យព្រមទាំងបព្វជិតវៀតណាម និងចិនត្រូវចាកចេញពី "*សន្តសាគរារាម* " នោះទៅ ហើយក្នុងវត្តអារាមនោះ នៅសល់តែលោកសង្ឃបូជាចារ្យ ៨ អង្គគង់នៅ ( ខ្មែរ ១ អង្គបារាំង ៧ អង្គ ) ព្រមទាំងបព្វជិតខ្មែរបីអង្គ។
* នៅក្នុងអារាមការមែលឈ្មោះ "*ក្រុមគ្រួសារព្រះនាងជាប្រភពនៃសេចក្តីសង្ឃឹម* (Notre Dame d'Espérance)" មានដូនជី ២១នាក់ នៅតទៅទៀត គឺដូនជីវៀតណាម ១៩ នាក់ បារាំង ២នាក់។ បងស្រីវៀតណាម ៨ នាក់ បានត្រឡប់ទៅប្រទេសវៀតណាមហើយ។ បព្វជិតាវៀតណាមឯទៀតៗពោលថា៖ "*យើងត្រូវតែនៅដើម្បីរួមសុខទុក្ខជាមួយប្រជាពលរដ្ឋខ្មែរ ទាំងអង្វរព្រះជាម្ចាស់ និងថ្វាយទុក្ខលំបាករបស់ប្រជាជននេះផង* " ។ អារាមការមែលនៃក្រុមបព្វជិតាគណៈនេះ ស្ថិតនៅក្នុងភូមិជ្រោយចង្វារ គឺភូមិដែលបានទទួលរងគ្រោះ ដោយពួកទាហានព័ទ្ធគ្រញឹបចាប់ប្រុសៗសម្លាប់ កាលពីថ្ងៃទី ១៣ មេសា ឆ្នាំ ១៩៧០ នោះ។ ក្នុងចំណោមបព្វជិតាទាំងនោះ មានដូនជីម្នាក់បាត់បង់សមាជិកគ្រួសារអស់ ៤១ នាក់ ក្នុងរាត្រីដ៏ទារុណនោះ ក៏ប៉ុន្តែ គាត់ស្ម័គ្រចិត្តនៅប្រទេសកម្ពុជាដើម្បីអង្វរព្រះជាម្ចាស់ឲ្យប្រជាជនខ្មែរ។ គួរឲ្យសរសើរមែន! ។
* ក្រុមគ្រួសារបងប្រុស "*ព្រះញាតិវង្ស* " ដែលមានសមាជិកសុទ្ធតែវៀតណាម ទៅប្រទេសវៀតណាមវិញ តាំងពីកើតសង្គ្រាមម្ល៉េះ។ រដ្ឋអំណាចបានបិទសាលា "*ក្រុមបងប្រុសនៃសាលាគ្រីស្តសាសនា* " ពួកបងប្រុសជាតិវៀតណាម ក៏ចេញទៅប្រទេសវៀតណាមពួកបងប្រុសជាតបារាំងនិងជាតិម៉ិកស៊ិក ក៏ទៅស្រុកដទៃផ្សេងៗទៀត។

ដូច្នេះ ព្រះសហាគមន៍ប្រទេសកម្ពុជាបាត់ដំបងបរិស័ទស្ទើរតែទាំងអស់។ តែទោះបីព្រះសហាគមន៍ចុះទន់ខ្សោយក៏ដោយ ក៏ព្រះសហាគមន៍ខំប្រមូលកម្លាំង ទប់ទល់នឹងព្រឹត្តិការណ៍ដែលនឹងកើតមកតទៅទៀត។

(១) ចំពោះផ្នែកនេះសូមមើលសៀវភៅ Charles Meyer, op.cit, ou Serge Thion et J-C1. Pomonti, op. Cit.

(២) រដ្ឋអំណាចដេញជនជាតិវៀតណាមចេញពីប្រទេសកម្ពុជាតទៅទៀត ក្នុងអំឡុងជាច្រើនខែ។ ឧទាហរណ៍ នាថ្ងៃទី ១២ កញ្ញា ឆ្នាំ ១៩៧០ រដ្ឋអំណាចបញ្ជូនគ្រីស្តបរិស័ទវៀតណាមនៅស្តីបិទមាស ខេត្ត កំពង់ធំ ចំនួន ១៨០ នាក់ មកឃុំក្នុងវត្ត ការវជាយ នៅក្រុងភ្នំពេញ។ គ្រីស្តបរិស័ទកាតូលិក វៀតណាម កល់មេឃ ចំនួន ១.៨០០ នាក់មកនៅជាមួយពួកអ្នកស្តីបិទមាសនោះ ក្នុងខែតុលា។ ក្រុមសហគមន៍កាតូលិកកល់មេឃនេះ ត្រូវស្លាប់ចំនួន ១៥ នាក់ និងមានអ្នករបួសជាច្រើន ក្នុងគ្រា ដែលខ្មែរនិងវៀតកុងច្បាំងគ្នា។ ពួកវៀតកុងបានសម្លាប់អ្នកដឹកនាំក្រុមគ្រីស្តបរិស័ទទាំងអស់ចោល ព្រោះគាត់មិនព្រមគោរពធ្វើតាមបញ្ជារបស់ពួកវៀតកុង ហើយនាំគ្រីស្តបរិស័ទរត់ចោលភូមិចូល មកក្រុងកំពង់ធំ។ នៅចុងខែតុលារដ្ឋអំណាចដេញគ្រីស្តបរិស័ទទាំងនោះទៅប្រទេសវៀតណាម ទាំងអស់គ្នា។

(៣) សៀវភៅស្តីអំពី "គំនិតរបស់លោកវ៉ាំងសង់រ៉ូឡាំង សាសនទូតនៅប្រទេសកម្ពុជា" "Carnets Spirituels de Vincent Rollin, Père missionnaire du Cambodge", Tèqui Paris 1980, p.6.

(៤) នៅក្នុងចំណោមលោកទាំងនោះ គេឃើញមានលោកយ៉ូសែប វុលលីយេ (Jeseph Vulliez) ដែលបាន បំពេញមុខងារជំនួស លោកអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជាកាលពីមុន ហើយដែល បានទទួលបន្ទុកណែនាំក្រុម "បងប្រុសនៃព្រះញាតិវង្ស" (Frères de la Sainte Famille)។ នៅ ប្រទេសវៀតណាមលោកបូជាចារ្យខ្លួនគ្មានសំចៃកម្លាំង ដើម្បីរៀបចំឲ្យគ្រីស្តបរិស័ទវៀតណាមដែល មកពីប្រទេសកម្ពុជាមានកន្លែងរស់នៅស្រួលបួល។ ពួកវៀតកុងបានសម្លាប់លោកចោលនៅថ្ងៃ ទី ១៦ មេសា ឆ្នាំ ១៩៧៥ នៅជិតថោងញឹក ជាភូមិដែលលោកបានបង្កើត។

(៥) បូជាចារ្យ Fidei Donum ជាបូជាចារ្យដែលគេចាត់ឲ្យទៅធ្វើការតែមួយរយៈនៅដែនដី ក្នុង បន្ទុករបស់លោកអភិបាលព្រះសហគមន៍។ ដូច្នេះ គេចាត់បូជាចារ្យទាំងនោះ តាមចំណងជើងសារ របស់សម្តេចប៉ាបពីយ៉ូ ទី ១២ (Pie XII) ចុះថ្ងៃទី ២១.៤.៧០ ដែលតែងតាំងឲ្យព្រះស ហគមន៍ទាំងឡាយធ្វើសហប្រតិបត្តិការបែបនេះ ។

## ជំពូកទី ១៤

# «គ្មានសចេក្តីស្រឡាញ់ឯណាឲ្យខ្លាំងជាង...»

ពេលសង្គ្រាមផ្ទុះឡើង ក្នុងចំណោមភូមិភាគកាតូលិកទាំងបីនៅប្រទេសកម្ពុជា គ្រីស្តបរិស័ទភូមិភាគកំពង់ចាម ត្រូវរងគ្រោះនិងខូចខាតច្រើនជាងគេ។ តាំងពីមុនព្រឹត្តិការណ៍ឆ្នាំ ១៩៧០ ម្ល៉េះ ខេត្តទាំងឡាយដែលនៅជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម បានទទួលរងគ្រោះដោយយន្តហោះអាមេរិកទម្លាក់គ្រាប់បែក(១)។ រួចមក ខេត្តទាំងនោះធ្លាក់ទៅក្រោមអំណាចពួក "អ្នករំដោះ" ជាបន្តបន្ទាប់ មុនដំបូង គឺពួកទាហានវៀតណាមខាងជើង បន្ទាប់មក គឺកងទ័ពអាមេរិក-វៀតណាមខាងត្បូង ដែលដេញតាមពួកវៀតណាមខាងជើង និងក្រោយមកទៀត គឺពួកខ្មែរក្រហម។

នៅចុងខែមីនា ឆ្នាំ ១៩៧០ ស្ថានការណ៍នយោបាយបានប្រែប្រួលយ៉ាងខ្លាំង។ អស់លោកបូជាចារ្យនៅខាងជើងនៃភូមិភាគ បានរួមប្រជុំគ្នានៅក្រោមការណែនាំរបស់លោក ឡឺស៊ូអែហ្វ ដែលជាអភិបាលព្រះសហគមន៍ (Mgr Lesouëf)។ អស់លោកសម្រេចចិត្តថានឹងនៅជាមួយក្រុមគ្រីស្តបរិស័តរហូត ទោះបីជាពួកវៀតកុងចូលមកក៏ដោយ។ អស់លោកសង្កេតឃើញថា នៅប្រទេសវៀតណាមពួកអ្នកបដិវត្តមិនសម្លាប់ លោកបូជាចារ្យទេ ដូច្នេះអស់លោកយល់ថា នៅប្រទេសកម្ពុជាពួកវៀតកុងមុខជាមុខជាមិនសម្លាប់លោកដែរ។ តែចំពោះបញ្ហានេះ អស់លោកភ្លេចគិតអំពីយុទ្ធសាស្រ្តពួកកុម្មុយនិស្ត គឺតាមការឃោសនារបស់ពួកកុម្មុយនិស្ត សង្គ្រាមនៅប្រទេសកម្ពុជា ជាសង្គ្រាមអ្នកស្រែចម្ការបះបោរប្រឆាំងលោក លន់ នល់ ដែលកាន់អំណាចផ្តាច់ការតែប៉ុណ្ណោះ ឥតមានការជ្រៀតជ្រែកពីវៀតកុងឡើយ។ ហេតុនេះ ពួកវៀតកុងត្រូវកម្ទេចចោលសាក្សីទាំងអស់ ជាពិសេសកម្ទេចជនបរទេសតែម្តង។ មានជនជាតិអឺរ៉ុប និងអាមេរិក ២៩ នាក់ ដែលជាអ្នកកាសែត និងបូជាចារ្យបាត់បង់ជីវិតនៅពេលនោះ។

លោក ណូអែល ក្រាណិច (Noël Grannec) ជាបូជាចារ្យទទួលបន្ទុកក្រុមគ្រីស្តបរិស័ទនៅត្រពាំងស្វាយភ្លោះ តាំងពីមួយឆ្នាំមកហើយ។ ភូមិត្រពាំងស្វាយភ្លោះស្ថិតនៅចម្ងាយ ២០ គីឡូម៉ែត្រ ខាងត្បូងនាក់លឿង។ ពួកកុម្មុយនិស្តវៀតណាមបានដេញលោកក្រាណិចចេញពីប្រទេសវៀតណាមខាងជើងរួចម្តងមកហើយ។ ក្រោយមក លោកក្រាណិចទទួលបន្ទុកបម្រើក្រុមគ្រីស្តបរិស័ទក្នុងចម្ការកៅស៊ូជប់។ ថៅកែចម្ការកៅស៊ូ ខឹងនឹងលោកជាញឹកញយ ព្រោះលោកចេះតែការពារពួកកម្មករវៀតណាម ដែលធ្វើការប្រហែលនឹងពួកកម្មករអឺរ៉ុប នាសតវត្សទី១៩[២] នោះ។ តាំងពីដើមឧសភា ពួកវៀតកុងកាន់កាប់តំបន់នាក់លឿងទាំងមូល តែលោក ណូអែលក្រាណិច តែងធ្វើដំណើរទៅមក ដូចជាគ្មានព្រួយបារម្ភអ្វីឡើយ។ ប្រហែលជានៅចុងខែឧសភា ឬដើមខែមិថុនា ទាហានវៀតកុងបួននាក់ឃាត់ចាប់លោក នៅចម្ងាយ ៣-៤ គីឡូម៉ែត្រ ពីព្រះវិហាររបស់លោក។ ពួកគេនាំលោកទៅទីបញ្ជាការធំរបស់គេនៅដីក្រហម។ ពេលពួកវៀតកុងចាប់លោកនោះ គ្រីស្តបរិសទវៀតណាមម្នាក់ឈរមើល បានប្រាប់ពួកគេឲ្យដឹងថា ជនបរទេសជាបូជាចារ្យទេ ហើយសុំកុំឲ្យគេចងស្លាបសេកលោកដូចអ្នកទោសឯទៀតៗ។ ពួកវៀតកុងក៏ដឹងជាក់ច្បាស់ថា លោកក្រាណិច នេះជានរណាដែរ។ បីបួនថ្ងៃក្រោយមក ពួកគេសម្លាប់លោកចោល។

លោកយ៉ូហានកាដួរ (P.Jean Cadour) មានដើមកំណើតពីខេត្តប្រឺតាញ (Bretagne) មានជន្មាយុ ៣៥ ឆ្នាំ ពេលវឹកវរកើតឡើង លោកសម្រេចចិត្តនៅជាមួយក្រុមគ្រីស្តបរិស័ទនាក្រុងក្រចេះ ចម្ងាយ ៣៥០ គ.ម. ពីក្រុងភ្នំពេញ។ ពួកវៀតកុងវាយយកក្រុងនេះបាននៅថ្ងៃទី ៦ ឧសភា ។ បីបួនថ្ងៃមុន លោកកាដួរបានទៅស្នួល ចម្ងាយប្រហែល ៨០ គ.ម. នៅប៉ែកខាងអាគ្នេយ៍ ជិតព្រំប្រទល់វៀតណាម ដើម្បីនាំដូនជីបីនាក់ជាបព្វជិតា ដែលលោកទទួលបន្ទុកថែរក្សា ឲ្យមកក្រចេះជាមួយលោក។ លោកយល់ថា លោកអាចនាំបព្វជិតាទាំងនោះ រួមជាមួយនឹងបព្វជិតាពីរនាក់ទៀត ដែលនៅក្រចេះចូលទៅក្រុងកំពង់ចាមតាមកប៉ាល់បាន។ ក្រោយពីពួកវៀតកុងវាយយកក្រុងក្រចេះមក ពួកគេបញ្ជាឲ្យអ្នកក្រុងទាំងអស់ចេញទៅនៅស្រុកស្រែចម្ការ។ បព្វជិតាទាំងឡាយក៏ចេញទៅទិសខាងជើង គឺទៅស្រុកសំបូរនៅចម្ងាយ ១០ គ.ម.។ ដូនជីទាំងនោះ ដូរសម្លៀកបំពាក់របស់គាត់ យកខោអាវស៊ីវិល ហើយក៏ដាក់ខ្លួនបម្រើជនជាតិខ្មែរម្នាក់ដែលទទួលពួកគាត់ឲ្យស្នាក់អាស្រ័យនៅផ្ទះជាមួយ ព្រមទាំងធ្វើការនៅវាលស្រែដូចស្ត្រីសឯទៀតៗនៅក្នុង

ភូមិ។ ចំណែកឯលោកកាដួរវិញ លោកនៅក្នុងក្រចេះដដែល ក៏ប៉ុន្តែ លោកចាកចេញពីផ្ទះរបស់លោក គឺលោកតែងប្រយ័ត្នប្រយែង ដោយទៅសំរាន្តផ្ទាល់ដីនៅក្រោមផ្ទះរបស់គ្រីស្តបរិស័ទឈ្មោះភួង ដែលជាអ្នកទទួលខុសត្រូវលើក្រុមសហគមន៍។ នាថ្ងៃទី ៦ កក្កដា វេលាម៉ោង ៥ ល្ងាច ខ្មែរក្រហមចំនួនដែលជាសម្ព័ន្ធមិត្តរបស់ពួកវៀតកុងមក "*អញ្ជើញ* " លោកបូជាចារ្យឲ្យទៅតាមពួកគេ។ ក្រោយមក អ្នកភូមិខ្លះបានឃើញលោកត្រូវគេចងមុខជិត និងចងស្លាបសេកផង។ ប្រហែលគេសម្លាប់លោកចោលក្នុងរវាងបីបួនថ្ងៃក្រោយមក។

លោកសិលា រ៉ាប៉ាំង (Pierre Rapin) ជាបូជាចារ្យទទួលបន្ទុកគ្រីស្តបរិស័ទចំណុះជើងព្រះវិហារភូមិខ្សាច់ប្រឆេះ ស្ថិតនៅចម្ងាយ ៥០ គ.ម. ខាងជើងកំពង់ចាម។ ភូមិខ្សាច់ប្រឆេះ ជាបណ្តុំក្រុមគ្រីស្តបរិស័ទខ្មែរដ៏តូចមួយ ដែលនៅជិតគ្រីស្តបរិស័ទវៀតណាមរាប់ពាន់នាក់។ លោករ៉ាប៉ាំង កើតនៅ ភូមិប៊ូពែរ ខេត្ត វ៉ែងដេ (Boupère, Venée) ក្នុងគ.ស. ១៩២៦។ លោកទទួលមុខងារបូជាចារ្យក្នុងជន្មាយុ ៣០ ឆ្នាំ។ លោកចូលចិត្តដាំដំណាំនិងចិញ្ចឹមសត្វ ជាហេតុនាំឲ្យលោកបង្កើតសហករណ៍ចិញ្ចឹមដង្កូវនាងមួយ នៅត្រពាំងស្វាយភ្លោះ ជាភូមិដែលលោករស់នៅមុននឹងមកនៅភូមិក្តុល។ នៅក្តុលមានបូជាចារ្យវៀតណាមម្នាក់ មានដើមកំណើតនៅបាណាមឈ្មោះ សិលា ឡេវ៉ាន់ ខឹង នៅជាមួយលោក។ លោកឡេវ៉ាន់ខឹង បានទទួលមុខងារជាបូជាចារ្យ កាលពីខែ មិថុនា ឆ្នាំ ១៩៦៩ កន្លងមក រួចលោកបានមករៀនភាសាខ្មែរនៅភូមិក្តុល។ ពេលពួក វៀតកុងចូលលុកលុយក្នុងខែឧសភា លោកសិលារ៉ាប៉ាំង អញ្ជើញទៅក្រុងកំពង់ចាម ដើម្បីសួរយោបល់លោកអភិបាលព្រះសហគមន៍។ ក្រោយពីបានត្រិះរិះពិចារណាជាមួយលោកអភិបាលមក លោកក៏សម្រេចចិត្តត្រឡប់ទៅជួបក្រុមគ្រីស្តបរិស័ទលោកវិញ ដើម្បីសួរយោបល់ពួកគេ។ "*គ្រីស្តបរិស័ទចង់ឲ្យខ្ញុំនៅជាមួយពួកគេ សូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ចុះ* "។ ពាក្យទាំងនេះ គឺជាសារចុងក្រោយរបស់លោក។ បីបួនថ្ងៃក្រោយមក ពួកវៀតកុងឡោមព័ទ្ធក្រុមគ្រីស្តបរិស័ទចំណុះជើងព្រះវិហាររបស់លោក។

នៅដើមខែសីហា កងទ័ពអាកាសសាធារណរដ្ឋខ្មែរ ទម្លាក់គ្រាប់បែកលើព្រះវិហារនិងលើផ្ទះរបស់លោក ព្រោះគេសង្ស័យថាពួកខ្មែរប្រើព្រះវិហារនិងផ្ទះលោកធ្វើជាទីសម្រាប់សង្កេតពិនិត្យ។ បូជាចារ្យទាំងពីរនាក់ក៏មកនៅក្នុងខ្ទមស្លឹកមួយជិតនោះ ហើយបន្តចិញ្ចឹម

មាន់ដើម្បីលៀងជីវិត ដូចដែលលោកបានធ្វើមួយឆ្នាំរួចមកហើយ តាមចលនាអភិវឌ្ឍន៍សហគមន៍។ លោកយកនំប៉័ងដែលលោកបានធ្វើដោយខ្លួនលោកផ្ទាល់ និងយកស្រាទំពាំងបាយជូរដែលលោកបានសន្សំទុកមកថ្វាយអភិបូជា។ បូជាចារ្យម្នាក់ធ្វើស្រាសំប៉ាញពីរដបមកជូនលោកទាំងពីរ ដោយលាក់ដបស្រានោះបង្កប់នៅក្នុងដើមចេក ហើយមានរទេះគោដឹកមកដោយសុខសាន្ត។ ជួនកាលកម្មាភិបាលវៀតកុងអនុញ្ញាតឲ្យបូជាចារ្យទាំងពីរជិះកង់ធ្វើដំណើរនៅក្នុងតំបន់បាន។ លោក សិលា ឡេវ៉ាន់ ឌឹង ក៏ទទួលអនុញ្ញាតទៅសួរសុខទុក្ខគ្រីស្តបរស័ទនៅឆ្លូង និងនៅក្រចេះបានប្រាំដង។ ក្នុងខែកញ្ញា ឆ្នាំ ១៩៧០ បព្វជិតាវៀតណាមស្រុកស្នួលបីនាក់ ដែលបានភៀសខ្លួនមកនៅក្រុងក្រចេះនោះ ក៏មកនៅភូមិក្តុលជាមួយបូជាចារ្យទាំងពីរដែរ។ ក្នុងអំឡុងពីរឆ្នាំ កម្មាភិបាលអនុញ្ញាតឲ្យដូនជីបង្រៀនក្មេងៗនៅក្នុងសាលាស្លឹកមួយ។

នាដើមឆ្នាំ ១៩៧២ ស្ថានការណ៍នយោបាយបានចុះដុនដាបយ៉ាងគំហុក ប្រហែលជាមកពីរឿងខ្មែរក្រហម និងវៀតកុងវាយគ្នាយ៉ាងខ្លាំងក្លាហើយ។ កម្មាភិបាលភូមិទារអត្ថបទគម្ពីរសម្រាប់សូត្រក្នុងអភិបូជា និងធម៌ទេសនារបស់លោកពិនិត្យមើលជាមុន ហើយហាមមិនឲ្យបព្វជិតជិតាបង្រៀនគ្រីស្តសាសនាតទៅទៀតឡើយ។ នៅថ្ងៃទី ២៥ មករា ឆ្នាំ ១៩៧២ ស្រាប់តែលោក មីសែលតាន់ ទទួលមរណភាពទៅ។ លោកតាន់នេះជាបូជាចារ្យវៀតណាមទទួលបន្ទុកបម្រើក្រុមគ្រីស្តបរិស័ទបឹងកាជោត ស្ថិតនៅត្រើយខាងលិចនៃទន្លេមេគង្គទល់មុខនឹងក្តុល[៣]។ ក្នុងថ្ងៃជាមួយគ្នានោះ លោកសិលា ឡេវ៉ាន់ ឌឹង អញ្ជើញទៅសួរទុក្ខគ្រីស្តបរិស័ទនៅក្រុងចក្រចេះ។ នៅវេលាម៉ោង ៥ ល្ងាច ពួកវៀតកុងបាន "*អញ្ជើញ*" លោកឲ្យទៅតាមពួកគេ។ លោកដឹងខ្លួនថា ជីវិតលោកមុខជាអន្តរាយជាពុំខាន ដូច្នេះលោកក៏យកអាវបំពង់របស់បូជាចារ្យមកពាក់។ ពួកវៀតកុងនាំលោកទៅឃុំក្នុងសាលារៀនមួយ រួចយកទៅឃុំក្នុងផ្ទះមួយចម្ងាយប្រហែល ២ គ.ម. នៅខាងជើងទីក្រុង។ ក្នុងយប់ថ្ងៃទី ១១ មីនា ពួកគេនាំលោកទៅទាំងចងស្លាបសេក។ នៅថ្ងៃបន្ទាប់ស្ត្រីគ្រីស្តបរិស័ទម្នាក់ ដែលតែងយកចំណីអាហារបន្តិចបន្តួចទៅជូនលោក ឃើញបុរសម្នាក់ពាក់អាវបំពង់របស់លោកបូជាចារ្យ ក៏ប៉ុន្តែ បុរសនោះ មិនមែនជាលោកឌឹងទេ! ប្រហែលជាគេបានសម្លាប់លោកចោលក្នុងពេលយប់នោះទៅហើយ។

ក្នុងយប់ថ្ងៃទី ២៣-២៤ កុម្ភៈ ឆ្នាំ ១៩៧២ គ្រាប់មីនដែលពួកវៀតកុងដាក់នៅជិតផ្ទះស្លឹកលោកសិលា វ៉ាបាំង ផ្ទុះឡើង បណ្តាលឲ្យលោកដែលសម្រាន្តក្នុងផ្ទះនោះត្រូវ

របួសជាទម្ងន់។ គ្រីស្តបរិស័ទគ្រាលោកបូជាចារ្យទៅគិលានដ្ឋានក្រូចឆ្មារ នៅចម្ងាយ ១០ គ.ម. ពីភូមិក្តុល។ ពេលរសៀលពួករៀតកុង មកជួយដឹកលោកទៅមន្ទីរពេទ្យដែលនៅឯកណ្តាលព្រៃ។ នៅម៉ោង ៧ យប់ ពួកគេនាំសាកសពលោកបូជាចារ្យមកវិញ។ តាមពាក្យរបស់គ្រីស្តបរិស័ទ ពេលលោកបូជាចារ្យត្រូវរបួសយ៉ាងធ្ងន់នោះ មុននឹងឲ្យគេលែងលោកទៅ លោកនិយាយប្រាប់ពួកគេថាៈ "*សូមកុំសងសឹកនឹងពួកជនដែលបានសម្លាប់ខ្ញុំ។ ខ្ញុំអត់ទោសឲ្យអ្នកទាំងនោះ ខ្ញុំក៏អង្វរព្រះជាម្ចាស់ សូមទ្រង់ព្រះមេត្តាអត់ទោសឲ្យពួកគេផងដែរ* " ។

ដូច្នេះនៅក្នុងភូមិភាគកាតូលិកកំពង់ចាមទាំងមូលគ្មានបូជាចារ្យទៀតទេ។ បូជាចារ្យប្រាំនាក់ទទួលអនិច្ចកម្ម ប្រាំនាក់ចេញទៅប្រទេសវៀតណាមជាមួយពួកគ្រីស្តបរិស័ទវៀតណាម និងពីរនាក់ទៀតភៀសខ្លួនមកនៅភ្នំពេញ។ នៅសល់តែលោកអង់ដ្រេឡឺស៊ូអែហ្វ ជាអភិបាលម្នាក់ឯងគត់។ ក្នុងក្រុងកំពង់ចាម នៅសល់គ្រួសារគ្រីស្តបរិស័ទតែបី ឬបួនគ្រួសារប៉ុណ្ណោះ ហើយនៅឯមន្ទីរពេទ្យឃ្លង់ត្រើង ចម្ងាយប្រហែល ១២ គ.ម. ខាងលិចទីរួមខេត្តក៏នៅសល់គ្រីស្តបរិស័ទចំនួនបីបួនគ្រួសារដែរ។ នៅនាក់លឿង គ្រីស្តបរិស័ទចំនួនសែសិបគ្រួសារត្រឡប់មកវិញ ក្រោយពីកងទ័ពសាធារណរដ្ឋខ្មែរវាយយកក្រុងនេះបានមកវិញ។ ប្រាំ ឬប្រាំមួយគ្រួសារទៀតរស់នៅដោយរហេមរហាមក្រៃលែងក្នុងក្រុងស្វាយរៀង។ ក្នុងខែសីហា ឆ្នាំ ១៩៧៣ ពួកខ្មែរក្រហម ដោយមានកងកាំភ្លើងធំវៀតណាមខាងជើងជួយគាំទ្រផង វាយយកក្រុងកំពង់ចាមស្ទើរតែបាន។ រួចមកកងទ័ពរដ្ឋាភិបាលវាយយកក្រុងនេះមកវិញ។ ក្នុងចម្បាំងគ្នានោះ ផ្ទះជាច្រើនត្រូវឆេះ និងខូចខាតខ្ទេចខ្ទី។ ពេលដកថយទៅវិញ ពួកខ្មែរក្រហមកៀរបង្ខំប្រជាជនដែលធ្លាក់ក្នុងកណ្តាប់ដៃពួកគេ ពោលគឺមនុស្សប្រហែល ៥០.០០០ នាក់ឲ្យចេញទៅនៅជនបទ។ មនុស្សឃ្លង់នៅត្រើង មានចំនួនប្រហែល ១២០០ នាក់ ក៏បែកខ្ញែកគ្នាអស់ ហើយភាគច្រើននាំគ្នាមកសុំទាននៅក្រុងភ្នំពេញ។

ចាប់តាំងពីពេលនោះមក ក្រុងកំពង់ចាមអាចទាក់ទងជាមួយរដ្ឋធានីភ្នំពេញបានតែតាមរយៈផ្លូវអាកាសប៉ុណ្ណោះ។ មានមនុស្សជ្រកនៅក្នុងក្រុងចំនួន ២០.០០០ នាក់។ ប្រជាជនភាគច្រើនជាអ្នកស្រែដែលរត់គេចពីសង្គ្រាម។ មួយចំនួនធំទៀត គឺជាស្ត្រីមេម៉ាយ និងក្មេងកំព្រា ជាគ្រួសារទាហានដែលបាត់បង់ជីវិតនៅក្នុងសមរភូមិ ឬក៏បាត់ខ្លួនក្នុងពេលច្បាំងគ្នា។ លោកឡឺស៊ូអែហ្វ ជួយទំនុកបម្រុងជនរងគ្រោះទាំងនោះ ដោយរួមជាមួយអ្នកណែនាំ

ក្រុមគ្រីស្តបរិស័ទក្រុមជំនុំប្រកាសដំណឹងល្អ និងអ្នកកាន់អំណាចខេត្តដែរ។ លោកនៅទីនោះរហូតដល់ថ្ងៃទី ៣ មេសា ឆ្នាំ ១៩៧៥ ទើបលោកសុខចិត្តមកកាន់ក្រុងភ្នំពេញ ដោយជិះកប៉ាល់ហោះតូចមួយរបស់អង្គការមនុស្សធម៌ ដែលលោករ៉ាមូសចាត់ឲ្យមកទទួលលោកជាបន្ទាន់។

«**យើងមិនដឹងសូត្រធម៌បែបនេះឡើយ**»

ខេត្តបាត់ដំបងដែលនៅឆ្ងាយពីប្រទេសវៀតណាមជាងគេ នៅតែជាជង្រុកស្រូវនៃប្រទេសកម្ពុជាជានិច្ច។ ដូច្នេះ ខេត្តនេះក៏គេចផុតពីចម្បាំងបានខ្លះ ព្រោះពួកខ្មែរក្រហមក៏ត្រូវការស្រូវដែរ។ លោកអភិបាលខេត្តសេក សំអៀត ជាបុគ្គលពុករលួយជាងគេក្នុងរបបសាធារណរដ្ឋ តែងទាញយកកម្រៃបានយ៉ាងច្រើនក្នុងការធ្វើជំនួញគ្រប់បែបយ៉ាងជាមួយនឹងពួកបដិវត្ត ថ្វីបើលោកមានភារកិច្ចវាយកម្ទេចពួកនោះក៏ដោយ។ ពួកបដិវត្តក៏ទុកឲ្យភូមិភាគបាត់ដំបងនេះមានសន្តិភាពដែរ។

បន្ទាប់ពីរដ្ឋការបានដេញជនជាតិវៀតណាមមក អស់លោកបូជាចារ្យដែលតែងបម្រើជនជាតិវៀតណាមក៏ចេញទៅដែរ។ ព្រះសហគមន៍បាត់ដំបងនៅសល់តែក្រុមសហគមន៍ខ្មែរបីប៉ុណ្ណោះ គឺក្រុមសហគមន៍បាត់ដំបង ក្រុមសហគមន៍ចំណោម និងក្រុមសហគមន៍កំពង់គ។ មានបូជាចារ្យបារាំងបីនាក់នៅធ្វើការអមលោក ទេពអ៊ុម ដែលជាអភិបាលព្រះសហគមន៍។

គ្រានោះ ខេត្តបាត់ដំបងមានសន្តិភាព។ ផ្ទុយទៅវិញ ខេត្តកំពង់ធំដែលស្ថិតនៅក្រោមការត្រួតត្រារបស់អភិបាលព្រះសហគមន៍បាត់ដំបង ទទួលរងគ្រោះដូចតំបន់ឯទៀតៗនៅទូទាំងប្រទេសដែរ។ ពោលគឺត្រូវពួកខ្មែរក្រហមវាយលុកខ្ទេចខ្ទី និងកងទ័ពសាធារណរដ្ឋវាយតបវិញ។ ក្នុងខែ ឧសភា ឆ្នាំ ១៩៧០ ទាហានវៀតណាមខាងជើង ពីរពាន់នាក់ខិតខំវាយលុកទីរួមខេត្តកំពង់ធំ តែវាយយកមិនបាន ហើយត្រូវទទួលបរាជ័យនៅចំពោះមុខអ្នកការពារក្រុងដ៏អង់អាចក្លាហាន និងដ៏ស្វិតស្វាញផង។ ក្នុងខែ កញ្ញា កងទ័ពសាធារណរដ្ឋឡើងតាមដងស្ទឹងសែនចាប់តាំងពីទន្លេសាបរហូតទៅដល់ក្រុងកំពង់ធំ។

ក្នុងអំឡុងប៉ុន្មានខែដើមដំបូង ពេលសង្គ្រាមទើបនឹងផ្ទុះឡើង គ្មានដំណឹងអ្វីអំពីលោករ៉ូប៊ែ វ៉ឺណេ(Robert Venet)។ លោកវ៉ឺណេ ជាបូជាចារ្យម្នាក់ មានឈ្មោះល្បីក្នុងចំណោម

អស់លោកសាសនទូតនៅប្រទេសកម្ពុជា។ លោកបានពុះពារគ្រប់ឧបស័គ្គ និងបានធ្វើការឥតស្រាកស្រាន្តក្នុងអំឡុងម្ភៃបីឆ្នាំ ដើម្បីបង្កើតក្រុមសហគមន៍កំពង់គ ដែលមានមនុស្សជិតប្រាំបួនរយនាក់ ក្នុងឆ្នាំ ១៩៧០។

ថ្ងៃអាទិត្យទី ២៧ មិថុនា ឆ្នាំ ១៩៧០ វេលាម៉ោងព្រឹកលោកបូជាចារ្យចុះទៅវាយជួង ដើម្បីប្រមូលបរិស័ទឲ្យមកជួបជុំគ្នាថ្វាយអភិបូជា។ ពេលនោះស្រាប់តែមាន "*ទាហានរំដោះ* " វៀតណាមខាងជើងដប់បីនាក់ចាប់លោក។ នាយទាហានវៀតណាមខាងជើងដែលនៅក្មេងល្អក់ យកក្រមាសូត្ររបស់លោកមកចងស្លាបសេកលោក។ គ្រីស្តបរិស័ទខ្មែរបីបួននាក់ចូលមកជួយលោក ហើយក៏ត្រូវពួកគេចាប់ចងដូចលោកដែរ។ បន្តិចក្រោយមក បុរសម្នាក់ឈ្មោះ ថោង មកដល់។ បុរសនេះជាអ្នកទទួលបន្ទុកបង្រៀនគ្រីស្តសាសនា ហើយតែងនេសាទត្រីនៅពេលយប់ ព្រោះក្នុងពេលថ្ងៃគប្បីពួនដើម្បីចៀសវាងកប៉ាល់ហោះបាញ់រះ។ គាត់ស្រែកថា "*សូមកុំប៉ះពាល់លោកឪពុកខ្ញុំ* "។ ដោយគាត់មានដើមកំណើតជាវៀតណាម ពួកវៀតណាមខាងជើងមិនចងដៃគាត់ដូចអ្នកឯទៀតៗឡើយ។ ពួកទាហានវៀតណាមខាងជើងឲ្យប្រជាជនដែលជាប់ចំណងទាំងនោះ ឡើងជិះកាណូតរបស់ក្រុមគ្រីស្តបរិស័ទ ហើយឈ្មោះ ថោង ក៏ទៅជាមួយគេដោយចិត្តគាត់។ ពួកទាហានវៀតណាមខំបញ្ឆេះកាណូតតែមិនឆេះសោះ។ ថោងក៏មកជួយបញ្ឆេះកាណូតនោះ ហើយបើកតាមបញ្ជារបស់ពួកទាហានយួន រហូតដល់ផាត់សណ្តាយនាមាត់ទន្លេសាប។

ក្នុងអំឡុង ១២ ថ្ងៃ ពួកអ្នកជាប់ទោសរស់នៅក្នុងព្រៃជាមួយនឹងពួកអ្នកបដិវត្តវៀតណាម ដោយគ្មានមុង ហើយត្រូវធ្វើតាមរបបតឹងរ៉ឹងរបស់ពួកគេ។ ក្នុងពេលនោះ អ្នកកាន់អំណាចកុម្មុយនិស្តញុះញង់ជនជាតិខ្មែរ ទាំងគ្រីស្តបរិស័ទ ទាំងអ្នកដទៃ ឲ្យចោទប្រកាន់លោកបូជាចារ្យ ដើម្បីឲ្យក្រុមសហគមន៍របស់លោកផ្ទាល់សម្លាប់លោកចោលតែឥតបានការ។ ថ្ងៃទី ១០ កក្កដា ពួកទាហានវៀតណាមខាងជើងនាំលោកមកកំពង់គវិញ ហើយផ្ញើលោកឲ្យមនុស្សម្ភៃនាក់ផារ៉ាប់រងមើលលោក។ ពីរឬបីថ្ងៃម្តង នាយទាហានវៀតណាមខាងជើងមកសួរចម្លើយលោក ដោយនិយាយភាសាបារាំងល្អឥតខ្ចោះ។

ពេលនោះ យន្តហោះសាធារណរដ្ឋខ្មែរទម្លាក់គ្រាប់បែកលើស្រុកស្រែគ្មានឈប់ឈរ។ មានតែភូមិកំពង់គ និងព្រះវិហារដ៏ល្អក្នុងភូមិនោះទេដែលគ្មានត្រូវគ្រាប់ ព្រោះពួកអ្នក

បើកកប៉ាល់ហោះចម្បាំងដឹងថាលោករ៉ឺណេ នៅទីនោះ។ ការនេះនាំឲ្យពួកខ្មែរក្រហម ចោទលោកថា លោកជាភ្នាក់ងារសម្ងាត់របស់ក្រុមស៊ើបការណ៍ សេ.អ៊ី.អា.! ខ្មែរក្រហម នៅតំបន់នោះបាននិយាយឲ្យលោកបូជាចារ្យដឹងថា ពួកវៀតណាមមិនសម្លាប់លោក ទេនោះ នៅពេលពួកគេឡើងត្រួតត្រាភូមិភាគទាំងមូល ពួកគេមិនប្រណីលោកឡើយ។ ថ្ងៃទី ១៣ កញ្ញា ឆ្នាំ ១៩៧០ កងទ័ពជើងទឹកនៃសាធារណរដ្ឋខ្មែរធ្វើប្រតិបត្តិការ សឹកឡើងតាមដងស្ទឹងសែនសំដៅទៅរំដោះក្រុងកំពង់ធំ។ ពួកទាហាន លន់ នល់ បាន "*អញ្ជើញ* " លោករ៉ឺណេ ដោយបង្ខំឲ្យទៅតាមពួកគេ។ ដោយហេតុដូច្នេះ អស់អ្នកដែលជានាខុសត្រូវចំពោះលោកអាចនិយាយប្រាប់ពួកទាហានវៀតណាម ខាងជើង ដោយគ្មានកុហកថាពួកសាធារណរដ្ឋបានចាប់លោកយកទៅដោយចោទ លោកថា លោកធ្វើការឲ្យពួកកុម្មុយនិស្ត។

ចាប់តាំងពីខែកញ្ញា ឆ្នាំ ១៩៧០ មក ពោលគឺបន្ទាប់ពីលោករ៉ឺណេចេញទៅផុតទៅ ខ្មែរ ក្រហមវាយលុកភូមិកំពង់គជាញឹកញយ។ ក្នុងអំឡុងមួយឆ្នាំកន្លះ ភូមិនេះជាមូលដ្ឋាន ដ៏រឹងមាំមួយ ដែលតស៊ូប្រឆាំងទប់ទល់នឹងពួកខ្មែរក្រហមបាន។ តែក្នុងខែមីនា ឆ្នាំ ១៩៧១ ដោយនឿយណាយនឹងភាពតានតឹងដែលមានជាប់ជាប្រចាំនោះ គ្រីស្តបរិស័ទចំនួន ២៥០ នាក់ ប្រថុយជិះទូករត់តាមស្ទឹងសែន និងតាមទន្លេសាបមកភ្នំពេញ។ នៅទីនោះ ពួកគេ បានជួបនឹងលោកឪពុក រ៉ឺណេ វិញ។ ក្នុងខែមិថុនា ឆ្នាំ ១៩៧២ ពួកបដិវត្ត ខ្មែរក្រហមចំនួន ២.០០០ នាក់ ឡោមព័ទ្ធភូមិកំពង់គ បង្ខាំងភូមិនោះមិនឲ្យទាំងមនុស្ស ទាំងសត្វ ទៅរកទឹកឯព្រែកបាន។ ពួកអ្នកការពារភូមិដាច់ទឹកយ៉ាងខ្លាំងរហូតដល់ទៅផឹកទឹក នោមរបស់ខ្លួន ហើយត្រូវបង្ខំចិត្តចុះចាញ់ ព្រោះតែស្រេកទឹកពេក។

ខ្មែរក្រហមដុតភូមិចោល តាមទម្លាប់របស់ពួកគេតាំងពីដើមរៀងមក។ ពួកគេចាប់ អ្នកភូមិជាឈ្លើយរួចនាំទៅតំបន់ស្រុកលើ ពោលគឺតំបន់ស្ទោង ដើម្បីបង្ខំអ្នកទាំងនោះ ឲ្យលើកទំនប់ និងជីកប្រឡាយ។ គេបង្ខំអ្នកភូមិកំពង់គនោះ ឲ្យចូលរួមក្នុងពិធី បុណ្យព្រះពុទ្ធសាសនានៅតាមវត្តនានា ដើម្បីធ្វើឲ្យអ្នកទាំងនោះ រលាយចូលទៅក្នុង ប្រជាជនដែលមានបែបផែនតែមួយដូចគ្នា។ នៅសម័យនោះ ពួកខ្មែរក្រហមមិនទាន់ ហាមឃាត់មិនឲ្យធ្វើបុណ្យនៅឡើយទេ។ លោកតា សោម ជាចាង់ទុំម្នាក់នៅក្នុងភូមិ បានរាយការណ៍ថា៖ "*ក្នុងពេលដែលលោកសង្ឃសូត្រធម៌ ខ្ញុំសូត្រធម៌ "ឱព្រះបិតា" និង*

*សូត្របទ* " *ខ្ញុំសូមក្រាបសំពះព្រះនាងម៉ារីយ៉ា* " ។ អ្នកដែលបានរស់រួចជីវិតបាន ពោលថា៖ "*យើងខ្ញុំពុំដែលបានសូត្រធម៌ច្រើនដូចពេលនោះឡើយ* " ។

ចំណែកឯអស់អ្នកទទួលខុសត្រូវខាងគ្រីស្តសាសនា ត្រូវខ្មែរក្រហមសម្លាប់ចោល ព្រោះ អ្នកទាំងនោះ ជាអ្នកចេះដឹង ឬមានអំណាចខ្លះៗតែប៉ុណ្ណោះ។ លោក ឈឿង ជុន ដែលទទួលបន្ទុកអប់រំគ្រីស្តសាសនា បានជីករណ្តៅសម្រាប់កប់ខ្លួនឯង មុននឹងត្រូវព្រនង់ស្លាប់។ ខ្មែរក្រហមចងជើងទាំងពីររបស់លោកយ៉ូសែប ម៉មសារូ ដែលជាអ្នកទទួលបន្ទុកអប់រំគ្រីស្តសាសនាម្នាក់ទៀត ហើយព្យួរនឹងមែកឈើមួយ រួចពួកនារីយោធាខ្មែរក្រហមវាយគាត់នឹងរំពាត់ផ្តៅទាល់តែស្លាប់ ព្រមទាំងជេប្រទេចគាត់ថែមទៀតផង។

ក្នុងខែ មករា ឆ្នាំ ១៩៧៤ អ្នកស្រែចំនួនបួនម៉ឺននាក់រត់គេចចេញពីតំបន់ខ្មែរក្រហម ហើយភៀសខ្លួនមកនៅកំពង់ធំ។ ក្នុងចំណោមអ្នកទាំងនោះ មានគ្រីស្តបរិស័ទដែលបានរួចរស់ជីវិតពីកំពង់គប្រហែលប្រាំរយនាក់ផង។ ជនភៀសខ្លួនទាំងនោះតាំងទីលំនៅចម្ងាយបីបួនគីឡូពីកំពង់ធំ ត្រើយខាងឆ្វេងនៃស្ទឹងសែន អ្នកខ្លះទៀតនៅឯព្រែកស្បូវ នៅកំពង់រទេះនៅអូរកន្ថែ ហើយនាំគ្នាធ្វើស្រែជាថ្មីឡើងវិញ ក្រោមកិច្ចការពាររបស់កងទ័ពសាធារណរដ្ឋខ្មែរ។ គ្រីស្តបរិស័ទទាំងនោះសាងព្រះវិហារតូចមួយធ្វើអំពីឈើ ហើយចូលរួម យ៉ាងសកម្មក្នុងការជួយដល់ជនភៀសខ្លួនឯទៀតៗ។ ថោង ដែលជាអ្នកទទួលបន្ទុកអប់រំគ្រីស្តបរិស័ទទទួលភារកិច្ចចែកអំណោយ នំប៉័ងចំនួន ១២.០០០ដុំ ក្នុងមួយថ្ងៃ ព្រមទាំងចែកអាហារឲ្យអ្នកក្រីក្រផង។ អ្នកកាន់អំណាចខេត្តតែងស្ញើចសរសើរភក្តីភាព និងសេចក្តីសុចរិតរបស់គ្រីស្តបរិស័ទ។

---

(១) អំពីការទម្លាក់គ្រាប់បែករបស់អាមេរិក មុនឆ្នាំ ១៩៧០ សូមអានសៀវភៅរបស់លោក William Schawcross, "Une tragédie sans importance" , Paris 1970.

(២) ក្នុងពេលដែលលោកហូជីមិញទទួលមរណភាពទៅ លោកក្រាណិចសុខចិត្តថ្វាយអភិបូជា អង្វរព្រះជាម្ចាស់ឲ្យមហាបុរសនោះ តាមសេចក្តីសុំរបស់គ្រីស្តបរិស័ទវៀតណាម។

(៣) លោក មីសែលតាន់ នេះជាអតីត "*បងប្រុសក្រុមព្រះញាតិវង្ស* " នៅបាណាម។ លោកសុំរៀនតទៅទៀត ហើយបានទទួលមុខងារជាបូជាចារ្យក្នុងឆ្នាំ ១៩៦៨ ។ លោកអភិបាលចាត់លោកឲ្យទៅបម្រើក្រុមគ្រីស្តបរិស័ទបឹងកាជោត (Thánh Mau) ពេលពួកវៀតកុងចូលមក លោកសម្រេចចិត្តនៅនឹងកន្លែង។

# ជំពូកទី ១៥

## ព្រះសហគមន៍សាមគ្គីជាមួយនឹងពួកអ្នកក្រខ្សត់ជាងគេ

ក្នុងអំឡុងប្រាំឆ្នាំសង្គ្រាម ក្រុងភ្នំពេញដូចជាបន្ទាយមួយដ៏ធំ ដែលខ្មាំងឡោមព័ទ្ធជាប់។ មួយភាគបីនៃចំនួនប្រជាជនទាំងអស់ក្នុងប្រទេសទាំងមូល ភៀសខ្លួនមករស់នៅក្រុងនោះ។ គ្រប់កងទ័ពដែលច្បាំងគ្នា ហាក់ដូចជាចូលដៃគ្នា ដើម្បីធ្វើបាបប្រជាជននៅស្រុកស្រែចម្ការ គឺមុនដំបូងមានពួកវៀតកុង រួចបន្ទាប់មកពួកខ្មែរក្រហមដែលប្លន់ចាប់ចងអ្នកស្រែ ហើយកៀរបង្ខំពួកគេឲ្យទៅរស់នៅក្នុងព្រៃ ទុកដូចជាឈ្លើយសង្គ្រាម។ កប៉ាល់ហោះសាធារណរដ្ឋទម្លាក់គ្រាប់បែកទៅលើភូមិនានាគ្មានប្រណី ឲ្យតែមានលិចព្ទពត៌មានថា មានវៀតកុងម្នាក់ ឬខ្មែរក្រហមម្នាក់នៅក្នុងភូមិ ពួកគេទៅទម្លាក់គ្រាប់បែកកម្ទេចភូមិនោះភ្លាម។ ពួក "*សម្ព័ន្ធមិត្ត*" វៀតណាមខាងត្បូង សងសឹកនឹងអំពើមនុស្សឃាតដែលពួកទាហានសាធារណរដ្ឋ លន់ នល់ បានប្រព្រឹត្តទៅលើជនរួមជាតិរបស់គេកាលពីឆ្នាំ ១៩៧០ ថែមទៀត។ ពួកសម្ព័ន្ធមិត្តនោះចាប់ស្ត្រីខ្មែររំលោភ សម្លាប់ចោល ឬទម្លាក់គ្រាប់បែកកម្ទេចភូមិ ដោយឥតញញើតអ្វីឡើយ។ បន្ទាប់ពីសហរដ្ឋអាមេរិក និងវៀតណាមខាងជើងចុះកិច្ចព្រមព្រៀងនៅក្រុងប៉ារីស នាថ្ងៃទី ២៨ មករា ឆ្នាំ ១៩៧៣ មក កប៉ាល់ហោះអាមេរិកដែលដកថយចេញពីប្រទេសវៀតណាម ក៏តាំងទម្លាប់គ្រាប់បែកជញ្រ្ជាំលើប្រទេសកម្ពុជា ដើម្បីបង្ខំខ្មែរក្រហមឲ្យចុះចាញ់។ លោកគីស៊ីងគ័រ (Kissinger) យល់ឃើញថា ដោយទម្លាក់គ្រាប់បែកជញ្រ្ជាំលើស្រុកខ្មែរដូច្នេះ លោកអាចដកទ័ពអាមេរិកចេញពីថ្លុកឈាមវៀតណាមដោយឥតមានគ្រោះថ្នាក់ ព្រោះពួកវៀតកុង វៀតកុងខាងជើងលែងមាន "ជម្រក" នៅក្នុងទឹកដីខ្មែរទៀតហើយ។ គួរឲ្យអស្ចារ្យណាស់! លោក គីស៊ីងគ័រនេះ ទៅជាអ្នកបានទទួលរង្វាន់ណូបែល ផ្នែកកសាងសន្តិភាព។

ដូច្នេះ យូរៗទៅ ក្រុងភ្នំពេញក៏ក្លាយទៅជាក្រុងមួយ ដែលមានប្រជាជនច្រើនហួសប្រមាណ។ ប្រជាជនទាំងនោះភាគច្រើនតែជាជនភៀសខ្លួនដោយសង្គ្រាម រងទុក្ខលំបាកវេទនា និងកំសត់ទុគ៌តពេកក្រៃ។ អ្នកស្រែចម្ការដែលឃ្លាតចាកពីស្រុកភូមិតែងគ្រាច់ចរច្រប់ព្រោះគ្មានការងារធ្វើគ្រួសារបែកបាក់ព្រាត់ប្រាសអស់។ មានស្ត្រីមេម៉ាយនិងក្មេងកំព្រារាប់ពាន់នាក់ អ្នកជំងឺ មនុស្សត្រូវរបួសឬកំបុកដៃជើងរាប់ពុំអស់ មានមនុស្សកើតឃ្លង់ចំនួនជាងមួយពាន់នាក់ ។ល។ កាលពីដើម គេចាត់ទុកក្រុងភ្នំពេញជាឋានសួគ៌នៅចុងបូព៌ាប្រទេស។ ក្នុងពេលកើតសង្គ្រាម ក្រុងនេះក្លាយទៅជាទីប្រជុំជនក្រីក្រដ៏ធំធេងមួយ មានប្រជាជនជាងពីរលាននាក់រស់នៅ។ ពួកគេតាំងទីនៅគ្រាប់កន្លែង ឲ្យតែគេអាចនៅកើត ពោលគឺនៅជាមួយញាតិមិត្ត នៅតាមវត្ត នៅលើចិញ្ចើមថ្នល់ នៅក្នុងជំរំ និងនៅក្នុងភូមិដែលពួកគេបានកសាងឡើងភ្លាមៗ ជុំវិញក្រុង។

ជនក្រីក្រទាំងនោះ ព្រួយបារម្ភ និងតានតឹងក្នុងចិត្តជាប្រចាំ ព្រោះគ្រាប់រ៉ូកែត ឬគ្រាប់កាំភ្លើងធំ ដែលខ្មែរក្រហមផ្លោងយ៉ាងសន្ធឹកសន្ធាប់ចូលភ្នំពេញ បណ្ដាលឲ្យស្លាប់និងហិនហោចវេទនាជាខ្លាំង។ ឧទាហរណ៍ យប់ថ្ងៃទី ២០ ទៅ ២១ មេសា ឆ្នាំ ១៩៧២ មនុស្សបីរយនាក់ ដែលនៅជាយក្រុងជិតគេហដ្ឋានលោកអភិបាលព្រះសហគមន៍ ទទួលមរណភាពដោយគ្រាប់ផ្លោងចូល។ ក្នុងឆ្នាំ ១៩៧៤ សង្កាត់មួយទៀតត្រូវភ្លើងឆេះខ្ទេចដោយត្រូវគ្រាប់កាំភ្លើងធំខ្មែរក្រហម គឺគ្រាប់ដែលពួកនោះ បានទិញពីពួកទាហានសាធារណរដ្ឋ!។

នៅសម័យនោះ សេដ្ឋកិច្ចមិនមានសកម្មភាពអ្វីទាំងអស់ ដូច្នេះជនភៀសខ្លួនពិបាករកស្បៀងអាហារបរិភោគខ្លាំងណាស់។ រដ្ឋការពុករលួយស៊ីសំណូក និងធ្វើអ្វីបានតាមចិត្តដូចសុភាសិតថា៖ "*អ្នកធំស៊ីធំ អ្នកតូចស៊ីតូច*" ។ ប្រាក់រៀលចេះតែចុះថ្លៃ រីឯតម្លៃទំនិញចេះតែឡើងថ្លៃហួសកម្រិត។ ប្រជាជនរស់រានមានជីវិតទៅមុខទៀតបាន ដោយសារតែស្បៀងដែលរដ្ឋាភិបាលសហរដ្ឋអាមេរិក ផ្ដល់មកឲ្យតែប៉ុណ្ណោះ។ ជំនួយស្បៀងទាំងនោះដឹកមកតាមកងនាវា ដែលឡើងតាមទន្លេមេគង្គ។ ជាញឹកញយខ្មែរក្រហមវាយបិទផ្លូវទន្លេនេះ ហើយកងទ័ពសាធារណរដ្ឋខ្មែរត្រូវវាយបើកវិញ។ ចាប់តាំងពីខែមករាឆ្នាំ ១៩៧៥ មក ការដឹកនាំតាមទន្លេនេះត្រូវខ្មែរក្រហមកាត់ផ្ដាច់ទាំងស្រុង។ នៅសល់តែផ្លូវអាកាសពីក្រុងបាងកកប៉ុណ្ណោះ សម្រាប់នាំអង្ករមកចិញ្ចឹមមនុស្សជាច្រើនលាននាក់នៅភ្នំពេញ។ សកម្មភាពនយោបាយលិចស្រឹមទៅក្នុងជម្លោះបក្សពួក ឬជម្លោះបុគ្គល ហើយប្រជាជនរស់នៅក្នុងក្រុងរកអនាគតភ្លឺស្វាងពុំឃើញឡើយ។

នៅក្នុងមហាទុក្ខវេទនានេះ មធ្យោបាយដែលព្រះសហគមន៍ធ្លាប់តែអនុវត្តន៍ជារៀងដរាបមក បែរទៅជាគ្មានន័យ និងគ្មានប្រយោជន៍ផង។ បានសេចក្តីថា ព្រះសហគមន៍ត្រូវគិតគូរបម្រើប្រជាជនរងគ្រោះទាំងនោះតាមរបៀតថ្មី។ អាគារជាច្រើនរបស់ព្រះសហគមន៍លែងមានប្រយោជន៍សម្រាប់គ្រីស្តសាសនាទៀតឡើយ។ រដ្ឋាភិបាលបានខ្ចីទេវវិទ្យាល័យ សាលារៀន និងអាគារអប់រំបព្វជិតា ធ្វើជាជំរំសម្រាប់ទទួលជនរង គ្រោះដោយសង្គ្រាម។ រដ្ឋអំណាចក៏យកអាគារខ្លះទៀតធ្វើជាមន្ទីពេទ្យ ឬក៏ធ្វើជាផ្ទះសម្រាប់និស្សិតក្រីក្រ ដែលបែកឆ្ងាយពីគ្រួសារ។ បើទុកជាមានការតវ៉ាជំទាស់ពីលោកអភិបាលព្រះសហគមន៍ក៏ដោយ ក៏រដ្ឋាភិបាលបានយកអាគារខ្លះ ឲ្យកងទ័ពធ្វើជាបន្ទាយ។

«**អាពច្ចុលថៃ្ងនូវដ៏បុរសីរបំផុតរបស់ពួកអ្នកក្រខ្សត់**»

បន្ទាប់ពីបានជួយជនជាតិវៀតណាម ដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែរដេញចេញនោះ "*គណៈកម្មាការសង្គហៈ ទំនុកបម្រុង និងជួយដល់ជនរងគ្រោះដោយសង្គ្រាម*" បានប្រឈមមុខចំពោះសេចក្តីក្រខ្សត់ ដែលកាន់តែមានច្រើនឡើងៗនៅក្រុងភ្នំពេញ និងនៅតាមខេត្តនានា។ ប៉ុន្តែ ព្រះសហគមន៍តែងតែរិះគិតអំ ពីសកម្មភាពគណៈកម្មការសង្គហៈនេះ ដោយទៀងទាត់។ លោកអេមីលដេតុម ដែលជាអគ្គលេខាធិការរបស់គណៈកម្មាការសង្គហៈតែងយកចិត្តទុកដាក់ធ្វើឲ្យសកម្មភាពរបស់គណៈកម្មការសង្គហៈនេះ បានទៅជាសកម្មភាពរបស់គ្រីស្តបរិស័ទប្រចាំប្រទេសកម្ពុជាពិត។ លោកមិនចង់ឲ្យគណៈកម្មការសង្គហៈក្លាយទៅជាអង្គការមនុស្សធម៌មួយដែលគ្រាន់តែចែកជំនួយរបស់អង្គការឯទៀតៗនោះឡើយ។

គណៈកម្មការសង្គហៈតែងយកចិត្តទុកដាក់ចង់ឲ្យក្រសួងនានា ចេះទទួលខុសត្រូវក្នុងការជួយជនភៀសខ្លួន ដោយមិនព្រមធ្វើការជំនួសក្រសួងទាំងនោះឡើយ ថ្វីបើក្រសួងទាំងនោះចង់ឲ្យធ្វើជួសក៏ដោយ។ គណៈកម្មការសង្គហៈខិតខំធ្វើការរួមជាមួយក្រសួងទាំងនោះ តាមលទ្ធភាពដែលអាចធ្វើកើត សូម្បីតែធ្វើទៅបានផលតិចជាងធ្វើដោយខ្លួនឯងផ្ទាល់ក៏ដោយ។ គណៈកម្មការសង្គហៈនេះបានចេញវិន័យ ហើយប្រកាន់ខ្ជាប់ជានិច្ចថា មិនត្រូវជួយជ្រោមជ្រែងសកម្មភាពរបស់ក្រសួងទាំងនោះ ហើយបើឱកាសហុចឲ្យ ត្រូវដាសតឿនក្រសួងទាំងនោះៗ ឲ្យចេះទទួលខុសត្រូវលើបញ្ហាផ្សេងៗថែមទៀត។

គោលដៅរបស់គណៈកម្មការសង្គហៈ មិនត្រឹមតែបំពេញសេចក្តីត្រូវការជាបន្ទាន់ប៉ុណ្ណោះទេ លើសពីនេះទៅទៀត គឺអប់រំមនុស្សទូទៅជាគ្រីស្តបរិស័ទក្តីឬជាអ្នកកាន់សាសនាផ្សេងទៀតក្តី ឲ្យចេះរួមសាមគ្គីជាមួយនឹងអស់អ្នកដែលក្រខ្សត់ជាងខ្លួន។ ទោះបីជាមានសេចក្តីត្រូវការជាបន្ទាន់ក៏ដោយ ក៏គណៈកម្មការសង្គហៈចូលចិត្តបង្កើតកម្មវិធីអភិវឌ្ឍន៍សហគមន៍ជាមុន ព្រោះជាកម្មវិធីដែលធ្វើឲ្យមនុស្សមានសេចក្តីថ្លៃថ្នូរឡើងវិញ ដោយជៀសវាងមិនឲ្យគេក្លាយទៅជាអ្នកសុំទាន រង់ចាំតែទទួលជំនួយនោះឡើយ។ ព្រះសហគមន៍ក៏មានបំណងធ្វើឲ្យជំនួសទាំងនោះ បានទៅជា"*សញ្ញាសម្គាល់អំពីព្រះរាជ្យនៃព្រះជាម្ចាស់ ពោលគឺជាសញ្ញាអំពីរបៀបរស់នៅថ្មី តាមព្រះឱវាទរបស់ព្រះគ្រីស្ត។ គណៈកម្មការសង្គហៈ ត្រូវតែសួរខ្លួនឯង សួរហើយសួរទៀតថា តើការជួយទាំងនេះពិតជាស្របទៅតាមដំណឹងល្អរបស់ព្រះយេស៊ូឬទេ?*" (១)។

អាស្រ័យហេតុនេះនេះហើយ បានជាគណៈកម្មការសង្គហៈ ទទូចសុំឲ្យគ្រីស្តបរិស័ទទាំងអស់យល់ច្បាស់ថា ខ្លួនសុទ្ធតែទាក់ទិនក្នុងការជួយនេះ។ គណៈកម្មការបានស្នើសុំឲ្យក្រុមជំនុំប្រកាសដំណឹងល្អខ្មែរចូលរួមជាមួយ ក្នុងការចែកចាយអំណោយ ដើម្បីបង្ហាញឲ្យប្រជាជនខ្មែរឃើញថា គ្រីស្តបរិស័ទគ្រប់គណៈរួមគ្នា។ ក៏ប៉ុន្តែ ដោយពុំអាចនាំបងប្អូនទាំងនោះ ឲ្យឈប់ចែកព្រះគម្ពីរប៊ីបជាមួយនឹងបារអង្ករបាន និងជៀសវាងកុំយកពាក្យស្វាគមន៍ ធ្វើជាការឃោសនាខាងសាសនានោះ គណៈកម្មការសង្គហៈក៏លែងធ្វើការរួមជាមួយបងប្អូនទាំងនោះទៅ។

ជារៀងរាល់ខែ គណៈកម្មការសង្គហៈតែងប្រជុំអ្នកទទួលខុសត្រូវក្រុមគ្រីស្តបរិស័ទនានា ដើម្បីប្តូរព័ត៌មានគ្នាទៅវិញទៅមក ដើម្បីរាយការណ៍អំពីសកម្មភាពម្នាក់ៗ ដើម្បីពិចារណាអំពីអំពើសប្បុរសដែលបានធ្វើរួចមកហើយ និងដើម្បីរៀបចំកម្មវិធីតទៅទៀត។ បន្តិចម្តងៗសហគមន៍គ្រីស្តសាសនាទាំងមូលបានចូលមកជួយធ្វើការតាមជាន់ថ្នាក់ផ្សេងៗ។ គណៈកម្មការគ្រីស្តបរិស័ទចំណុះជើងព្រះវិហារប្រាំមួយក្រុមបានកើតឡើង ហើយធ្វើការរួមគ្នា ដោយមានគណៈកម្មការសង្គហៈជួយទំនុកបម្រុងផង។ អ្នកមកជួយធ្វើការមានចំនួនដល់ទៅចិតសិបនាក់ គឺបូជាចារ្យបីនាក់ សាមណេរម្នាក់ បព្វជិតាពីរនាក់ និងគ្រហស្ថហុកសិបពីរនាក់។ ក្នុងចំណោមនេះ មានតែគ្រីស្តបរិស័ទប្រាំមួយនាក់ទេដែលមានប្រាក់ខែ អ្នកឯទៀតៗធ្វើការដោយ គ្មានកម្រៃ។ ក្នុងខែមករា ឆ្នាំ ១៩៧២ គណៈកម្មការសង្គហៈបានចូលជា សមាជិករបស់អង្គការ"*មេត្តាករុណាធម៌អន្តជាតិ* " (Caritas Internationalis)។

ដូច្នេះគណៈកម្មការសង្គហៈ បានសម្តែងឲ្យឃើញថា ខ្លួនរួមកាន់តែជិតស្និទ្ធជាមួយព្រះសហគមន៍សកល (Eglise Universelle)។

**គម្រូបីចាប់ពីអារម្មណ៍ចំពោះកិច្ចការពិសេសៗខ្លះដូចតទៅ**:

- គ្រួសាររាប់រយគ្រួសារបានទទួលជំនួយរាល់ៗអាទិត្យ បន្ទាប់ពីក្រសួងសាធារណៈបានស៊ើបអង្កេត និងបន្ទាប់ពីគណៈកម្មការសង្គហៈបានចុះទៅសួរសុខទុក្ខផ្ទាល់ដល់ផ្ទះតែម្តង។ ជារៀងរាល់អាទិត្យដែរ គណៈកម្មការរបស់គ្រីស្តបរិស័ទចំណុះជើងព្រះវិហារមួយ តែងជួយមនុស្សចាស់ជរាពីររយនាក់ដែលគ្មានទីពឹង ហើយសមាជិកគណៈកម្មការទៅសួរសុខទុក្ខផង។
- ទោះបីជាក្មេងកំព្រាដោយសង្គ្រាមមានចំនួនច្រើនយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍មិនព្រមបើកអាគារសម្រាប់ទទួលក្មេងកំព្រា ដូចព្រះសហគមន៍ធ្លាប់តែបើក កាលពីសម័យមុននោះឡើយ។ ដោយយោលទៅតាមមហាប្រពៃណីរបស់ប្រជាពលរដ្ឋខ្មែរ ដែលមិនបោះបង់ចោលក្មេងកំព្រាទេនោះ ព្រះសហគមន៍យល់ឃើញថា គួរជួយគ្រួសារទាំងឡាយ ទោះបីក្រីក្រយ៉ាងណាក៏ដោយ ឲ្យទទួលយកក្មេងៗដែលឥតញាតិសន្តាន។ ជារៀងរាល់ខែ គណៈកម្មការសង្គហៈតែងផ្តល់ប្រាក់ជំនួយដល់គ្រួសារទាំងនោះ ដែលមានចំនួនរាប់រយ ហើយតែងចាត់សមាជិកឲ្យទៅសួរសុខទុក្ខដោយទៀងទាត់ផង។
- នាពេលបុណ្យណូអែលឆ្នាំ ១៩៧០ គណៈកម្មការសង្គហៈបានអំពាវនាវ សុំឲ្យគ្រីស្តបរិស័ទបរិច្ចាគប្រាក់កាស ជួយកិច្ចប្រតិបត្តិការមួយ ដែលហៅថា "*សន្លឹកមួយពាន់*" ដើម្បីទិញសន្លឹកស័ង្កសីសម្រាប់ប្រក់ផ្ទះជូនដល់ជនភៀសខ្លួនចំនួនពីររយគ្រួសារដែលគ្មានទីជម្រក។ ព្រមជាមួយនឹងអំណោយទាំងនោះ គណៈកម្មការក៏បានចាត់ចែងឲ្យមានក្រុមចម្រៀង និងក្រុមរបាំប្រជាប្រិយមកលេងកំដរ បង្កើតនូវបរិយាកាសដ៏សប្បាយរីករាយផង។
- ក្រសួងសាធារណៈ ឲ្យគណៈកម្មការសង្គហៈសង្គ្រោះទទួលបន្ទុកចែកអំណោយជាចំណីអាហារ និងថ្នាំពេទ្យឲ្យដល់គ្រួសារពីររយ។ គណៈកម្មការសង្គហៈក៏បានផ្តល់សម្ភារៈចាំបាច់សំខាន់ៗជូនដល់ជនភៀសខ្លួន ដើម្បីឲ្យពួកគេសង់ខ្ទមឬស្សីលើទីពីរទំហំដប់ហិចតានៅស្ទឹងកំបុត។ បន្ទាប់មក គណៈកម្មការសង្គហៈដឹកនាំកម្មវិធី

អភិវឌ្ឍន៍សហគមន៍ ដើម្បីកែប្រែដីទាំងនោះ ឲ្យទៅជាចម្ការដំណាំ។ មួយឆ្នាំក្រោយមក ជំរំក៏អាចផ្គត់ផ្គង់ចំណីអាហារខ្លួនឯងបានមួយភាគធំ។ នេះជាលទ្ធផលមួយគួរឲ្យចាប់អារម្មណ៍។ ពេលដែលខ្មែរក្រហមវាយលុកតំបន់នោះ អ្នករស់នៅក្នុងជំរំឯទៀតៗដែលបានទទួលផ្ទះល្អៗ ពីអង្គការអន្តរជាតិនានានាំគ្នារត់ចេញអស់ ព្រោះផ្ទះទាំងនោះ មិនមែនជាផ្ទះផ្ទាល់របស់ពួកគេទេ ហើយពួកគេក៏គ្មានមនោសញ្ចេតនាជាប់ជំពាក់នឹងដីធ្លីនោះដែរ។ ផ្ទុយទៅវិញ ពួកអ្នកស្ទឹងកំបុតនៅនឹងកន្លែង ពោលគឺពួកគេបានចាក់ឫសក្នុងដីថ្មីនោះហើយ។

- គណៈកម្មការសង្គហៈបានចាប់អារម្មណ៍ជាពិសេស ចំពោះជនមួយប្រភេទទៀតគឺពួកអ្នកកើតជំងឺឃ្លង់។ ក្នុងខែសីហា ឆ្នាំ ១៩៧៣ ភូមិត្រើងដែលមានមន្ទីរពេទ្យឃ្លង់សម្រាប់ប្រទេសកម្ពុជាទាំងមូល បានធ្លាក់ទៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម បណ្ដាលឲ្យផ្ដាច់ជំនួយជាចំណីអាហារ ឬជាថ្នាំពេទ្យទៅ។ មនុស្សកើតឃ្លង់ជាជនដែលសង្គមតែងបោះបង់ចោល ទាំងហាមមិនឲ្យប៉ះពាល់ជាដាច់ខាត។ ដូច្នេះហើយបានជាអ្នកកើតឃ្លង់រស់នៅផ្តុំគ្នា នៅក្នុងសង្កាត់ក្រខ្វក់នៃរដ្ឋធានីភ្នំពេញ ហើយរកស៊ីដើរសុំទាន។ ក្រុមគ្រីស្តបរិស័ទរបស់វិសាលវិហារ ដឹកនាំដោយលោក ប៉ែរណា ប៉ែរសេ បានទទួលបន្ទុកជួយជនក្រខ្សត់ជាងគេទាំងនោះ ដោយមានកិច្ចសហប្រតិបត្តិការពីអ្នកកាន់អំណាចក្រុងផង។ ពួកឃ្លង់បានបង្ហូរពង្រីងទឹកស្អុយចេញពីសង្កាត់ដែលពួកគេរស់នៅដែលមានសុទ្ធតែភក់ជ្រាំ។ ពួកគេក៏បង្កើតកន្លែងដងទឹកមួយ និងសង់គិលានដ្ឋានមួយផង។ ពួកគេធ្វើជំរឿនអ្នកកើតឃ្លង់ដែលនៅរាត់រាយពេញក្រុង មានចំនួនមួយពាន់ប្រាំបួននាក់។ គណៈកម្មការក៏រត់ការដើម្បីឲ្យជនទាំងនោះមានអត្តសញ្ញាណប័ណ្ណ ហើយនិងឲ្យកូនចៅពួកគេរៀនសូត្របានផង។ គេយកអតីតអាគារអប់រំដូនជីរបស់ "*ក្រុមគ្រួសារបុត្រីព្រះនាងម៉ារី* " នៅឫស្សីកែវ មកធ្វើជាមណ្ឌលព្យាបាលអ្នកជំងឺឃ្លង់ និងធ្វើជាកន្លែងសម្រាប់ឲ្យអ្នកកើតឃ្លង់រស់នៅផង។ ពួកអ្នកកើតឃ្លង់រៀបចំកន្លែងនោះដោយខ្លួនឯង ហើយពួកគេអាចរកលុយកាក់បានខ្លះៗ ដោយជួយធ្វើកិច្ចការទាំងនេះ។ បន្តិចម្ដងៗ អ្នកកើតជំងឺឃ្លង់ចាប់ផ្តើមជឿថា ពួកគេក៏ជាមនុស្សមានកិត្តិយសពេញលេញ ដូចគេដូចឯងដែរ។

គណៈកម្មការសង្គហៈមានស្មារតីខ្ជាប់ខ្ជួន គឺសុខចិត្តឲ្យគ្រីស្តបរិស័ទឬអង្គការអន្តជាតិយល់ច្រឡំអំពីគោលបំណងរបស់គេ។ ឧទាហរណ៍ ក្នុងឆ្នាំ ១៩៧៣ គណៈកម្មការ

សង្គហៈពុំព្រមទទួលយក ប្រាក់ជំនួយដ៏ច្រើនសន្ធឹកពីក្រុមជំនួយ CRS (Catholic Relief Service) ជាអង្គការសប្បុរសធម៌អាមេរិក ដែលមានធនធានច្រើនអស្ចារ្យ។ អង្គការ CRS នេះ ស្នើឲ្យព្រះសហគមន៍ទទួលបន្ទុកលើកម្មវិធីចែកអង្ករឲ្យមនុស្ស ១៥០.០០០ នាក់។ ចំនួនទឹកប្រាក់សម្រាប់កម្មវិធីនេះ មានដល់ទៅបីលានដុល្លារក្នុងមួយឆមាស ពោល គឺមានច្រើនជាងថវិការប្រចាំឆ្នាំរបស់អគ្គស្នងការដ្ឋានខ្មែរសម្រាប់ជនភៀសខ្លួន ដល់ទៅ សាបសិបប្រាំដង។ ម្យ៉ាងទៀត អង្គការនេះបានប្រាក់ទាំងនោះមកពីប្រភពដែលធ្វើឲ្យ សៅហ្មងក៏សឹងតែថាបាន ព្រោះ ៨០% នៃថវិកានេះ បានមកពីក្រសួងការបរទេសសហរដ្ឋ អាមេរិក។ ក្រុមជំនួយ CRS នេះ ទទួលមុខងារចែកជំនួយ ដែលរដ្ឋាភិបាលអាមេរិកកាំង មិនចង់ផ្ទេរទៅឲ្យរដ្ឋាភិបាលខ្មែរដោយផ្ទាល់នោះ។ នៅក្នុងសេចក្ដីរាយការណ៍ទៅ ក្រុមអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា និងប្រទេសលាវ (CELAC) នាឆ្នាំ ១៩៧៤ លោករ៉ាមូសសរសេរថា៖ "*កម្មវិធីនេះមិនត្រឹមតែហួសពីសមត្ថភាពរបស់សហគមន៍គ្រីស្ត បរិស័ទប៉ុណ្ណោះទេ គឺថែមទាំងធ្វើឲ្យសាធារណជនអាចយល់ច្រឡំថា ព្រះសហគមន៍ អាចធ្វើអ្វីៗបានតាមចិត្ត ព្រោះតែមានលុយកាក់ច្រើនហួសប្រមាណនេះ ហើយអាចចែក ចាយចំណីអាហារលោកីយពុំចេះអស់*" ។ បន្ទាប់ពី គណៈកម្មការសង្គហៈបដិសេធ ពុំព្រម ជួយមកអង្គការ CRS ក៏បើកការិយាល័យរបស់ខ្លួនផ្ទាល់នៅក្រុងភ្នំពេញ ហើយក៏នាំយក ជំនួយដ៏សន្ធឹកសន្ធាប់ទាំងនោះមក ព្រោះក្រុមនេះប៉ិនប្រសប់ក្នុងកិច្ចជួយបែបនេះស្រាប់។ ពេលថ្ងៃក្រុមជំនួយ CRS ព្យាបាលការឈឺចាប់វេទនារបស់ក្រុម CRS បែរជាធ្វើឲ្យសៅហ្មង ដល់ព្រះសហគមន៍ ព្រោះប្រជាជនខ្មែរឲ្យអាចយល់ច្រឡំថាព្រះសហគមន៍រួមជាមួយ សហរដ្ឋអាមេរិក ដែលកំពុងធ្វើសង្គ្រាមនៅប្រទេសកម្ពុជា។ ពួកគេពុំព្រមឲ្យលុបសញ្ញា ទាំងនោះចោលឡើយ។ ក្នុងឆ្នាំ ១៩៧៤ អង្គការ CRS អញ្ជើញលោក កាឌីណាល់រ៉ូសស៊ី (Rossi) ដែលមានមុខងារខ្ពង់ខ្ពស់ក្នុងព្រះសហគមន៍ ឲ្យមកទស្សនាស្នាដៃទាំងឡាយ ដែលអង្គការនេះបានសម្រេចរួចហើយ នៅប្រទេសកម្ពុជា។ កាឌីណាល់អញ្ជើញមក ដោយជិះកប៉ាល់ហោះរបស់ក្រុមស៊ើបការណ៍សម្ងាត់អាមេរិក។ ឯកអគ្គរដ្ឋទូតសហរដ្ឋ អាមេរិករៀបចំទទួលលោកដោយកិត្តិយស។ លោកអភិបាលព្រះសហគមន៍ប្រចាំប្រទេស កម្ពុជាទាំងបីនាក់ មិនព្រមចូលរួមក្នុងកម្មវិធីនោះទេ ព្រោះលោកយល់ថា មិនគប្បី ចូលរួមជាមួយទូតដែលកំពុងច្បាំងនឹងប្រទេសកម្ពុជាជាដាច់ខាត។

ព្រះសហគមន៍ក៏តែងដឹងខ្លួនជានិច្ចថា ដោយព្យាបាលរបួសពួកអ្នកកំពុងច្បាំងគ្នាតែម្ខាង គេអាចចោទប្រកាន់ថា ព្រះសហគមន៍ជាសម្ព័ន្ធមិត្តរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ព្រះសហគមន៍ក៏បានប្រឹងប្រែងទាក់ទងជាមួយនឹងពួក "*ម្ខាងទៀត* " ដែរ ក៏ប៉ុន្តែមិនបានទទួលលទ្ធផលអ្វីឡើយ។ ផ្ទុយទៅវិញ ពួកគេបានសម្លាប់បូជាចារ្យទាំងប៉ុន្មានដែលនៅក្នុងតំបន់ពួកគេត្រួតត្រាចោលអស់ ហើយពួកគេបានបំបែកបំបាក់គ្រីស្តបរិស័ទឲ្យបែកខ្ញែកគ្នាអស់ទៀត។ មានតែលោក យ៉ូហានបាដ្រេ (Jean Badré) នៅភូមិចំណោមតែម្នាក់ឯងគត់ ដែលអាចព្យាបាលអ្នកជំងឺទាំងខាងពួកខ្មែរក្រហម និងទាំងខាងពួកសាធារណរដ្ឋបាន។ រដ្ឋាភិបាលក្រុងភ្នំពេញ បានអញ្ជើញអ្នកទទួលខុសត្រូវខាងព្រះពុទ្ធសាសនា ខាងអ៊ីស្លាមសាសនា និងខាងគ្រីស្តសាសនា ឲ្យធ្វើញត្តិប្រឆាំងនឹងការបំផ្លិចបំផ្លាញ វត្ត ព្រះវិហារអ៊ីស្លាម និងព្រះវិហារគ្រីស្តសាសនា ព្រមទាំងឲ្យប្រឆាំងនឹងការសម្លាប់ព្រះសង្ឃ និងបូជាចារ្យ។ លោកអភិបាលព្រះសហគមន៍ទាំងបីនាក់បានរួបរួមជាមួយតំណាងសហគមន៍ និងសាសនាឯទៀតៗ ចុះហត្ថលេខាលើសេចក្តីថ្លែងការមួយ ដែលគ្រាន់តែសុំឲ្យមានសន្តិភាព នៅប្រទេសកម្ពុជាតែប៉ុណ្ណោះ តែមិនព្រមចុះហត្ថលេខាក្រោមអត្ថបទដែលផ្តន្ទាទោសចំពោះអំពើព្រៃផ្សៃរបស់ពួក "*ម្ខាងទៀត* " ឡើយ។ លោកធ្វើដូច្នេះ ដោយមានបំណងជៀសវាងមិនគាំទ្រក្រុមបក្សដែលយក ទុក្ខសោកវេទនារបស់ប្រជាជនមកធ្វើជាឈ្នាន់នយោបាយ និងមិនឲ្យរបបនយោបាយមួយអាចផ្តន្ទារបបនយោបាយមួយទៀតបាន ព្រោះថារបបនយោបាយណាក៏ដូចជារបបនយោបាយណាដែរ គឺគេអាចផ្តន្ទាទោសបានដូចគ្នា។ តើព្រះសហគមន៍ត្រូវធ្វើយ៉ាងណាទៅ នាកណ្តាលពិភពដ៏ឃោរឃៅនេះ ?

ព្រះសហគមន៍បានត្រឹមតែខំជួយធ្វើឲ្យទុក្ខវេទនារបស់ប្រជាជន ដែលរងគ្រោះបានស្រាកស្រាន្តខ្លះៗតែប៉ុណ្ណោះ ព្រោះសហគមន៍គ្មានសមត្ថភាពអ្វីទាំងអស់ក្នុងសង្គ្រាមនេះ ដោយគ្រីស្តបរិស័ទមានចំនួនតិចពេក ហើយភាគច្រើនមិនមែនសញ្ជាតិខ្មែរផង។ តើឲ្យជនបរទេសទឹកមាត់ប្រែយ៉ាងដូចម្តេចកើត នៅក្នុងរឿងជម្លោះបងប្អូនឯង ? ចំណែកឯគ្រីស្តបរិស័ទខ្មែរវិញ ពួកគេមិនសូវចាប់អារម្មណ៍នឹងរឿងនយោបាយទេ គេគិតតែពីរឿងជំនឿសាសនាប៉ុណ្ណោះ។

**ឆ្ពោះទៅរកអនាគត**

ស្របជាមួយនឹងការស្ងើចសរសើរពីសំណាក់ប្រជាជនខ្មែរ ចំពោះសក្ខីភាពដ៏សប្បុរសរបស់គណៈកម្មការសង្គហៈ ដែលធ្វើការមានប្រសិទ្ធិភាព និងស្ងៀមស្ងាត់ល្អ សហគមន៍គ្រីស្តសាសនានៅតែយកចិត្តទុកដាក់ពង្រីកសកម្មភាពរបស់ខ្លួននៅក្នុងសង្គមខ្មែរឲ្យកាន់តែខ្លាំងឡើងថែមទៀត។

តែព្រះសហគមន៍តែងតែគិតគូរ ចំពោះតុលារុលចូលរបស់ពួកបដិវត្ត ដែលពុំអាចប្រឆាំងទប់ទល់កើត។ បានសេចក្តីថា ព្រះសហគមន៍តែងជៀសវាងមិនគិតអំពីប្រពៃណីសាសនាខ្លាំងពេកទេ ព្រោះលទ្ធិម៉ាក្ស លេនីន មុខជាលុបបំបាត់ប្រពៃណីទាំងនោះចោលពុំខាន។ ក្រុមលោកអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា និងប្រទេសលាវគិតថាអស់លោកបូជាចារ្យបរទេសមុខជានឹងត្រូវពួកបដិវត្តដេញពីស្រុក។ ដូច្នេះ ក្រុមអភិបាលបានស្នើសម្តេចប៉ាប អនុញ្ញាតឲ្យប្រគល់មុខងារជាបូជាចារ្យទៅ មេគ្រួសារគ្រីស្តបរិស័ទខ្មែរនិងលាវ។ ក៏ប៉ុន្តែ តាមលិខិតចុះថ្ងៃទី ៧ ឧសភា ឆ្នាំ ១៩៧៤ សម្តេចប៉ាប សុំឲ្យផ្អាកករណីកិច្ចនេះសិន សុំឲ្យគិតគូរប្រគល់មុខងារជាឧបដ្ឋាកឲ្យអ្នកអប់រំគ្រីស្តសាសនាដែលមានគ្រួសារវិញ ព្រមទាំងសុំឲ្យរៀបចំបង្កើតមុខងារបម្រើព្រះសហគមន៍ថែមទៀតផង[២]។ អស់លោកបានគិតទៀតថា នៅពេលអនាគតប្រទេសកម្ពុជានឹងមានរបបគ្រប់គ្រងដូចនៅប្រទេសចិន ឬនៅប្រទេសវៀតណាមខាងជើង ក្នុងរបបទាំងពីរនេះសាសនា និងសហគមន៍នៅគង់វង្សរបៀបម្យ៉ាង។ អាស្រ័យហេតុនេះ អស់លោកខំដាស់តឿនក្រុមសហគមន៍គ្រីស្តសាសនានៅក្រុង ឲ្យទទួលបន្ទុករបស់ខ្លួនដោយខ្លួនឯងឲ្យកាន់តែច្រើនឡើងទៀត ដោយមានគណៈកម្មការអ្នកទទួលខុសត្រូវចូលរួមផង គឺធ្វើដូចក្រុមសហគមន៍នៅតាមខេត្តតែងអនុវត្តជាយូរមកហើយនោះ។

អស់លោកបូជាចារ្យខ្មែរ ទទួលបន្ទុករៀបចំ "*មហាសន្និបាត*" របស់គ្រីស្តបរិស័ទខ្មែរដើម្បីគិតគូរទទួលបន្ទុកលើព្រះសហគមន៍ក្នុងពេលអនាគត។

តាំងពីឆ្នាំ ១៩៧១ ម្ល៉េះ យុវជនប្រុសស្រីចំនួនសែសិបនាក់ ទាំងនៅលីវ ទាំងមានគ្រួសារទទួលការអប់រំឲ្យមានមុខងារផ្សេងៗក្នុងព្រះសហគមន៍ សម្រាប់ណែនាំព្រះសហគមន៍នៅពេលចប់ចម្បាំង គឺនៅពេលមានសន្តិភាពឡើងវិញ។ អ្នកទាំងនោះ មានរៀនវិជ្ជាជីវៈដែលអាចឲ្យគេផ្គត់ផ្គង់ខ្លួនគេផ្ទាល់បាន។ លោក ប៉ុងសូដ៍ អប់រំអ្នកទាំងនោះ តាមព្រះ

គម្ពីរប៊ីប ព្រោះព្រះគម្ពីរនេះជាឯកសារ ដែលគេអាចអានបានជានិច្ច ទោះបីរបបនយោបាយប្រទេសជាតិផ្លាស់ប្ដូរជាយ៉ាងដូចម្ដេចក៏ដោយ។ យុវជនទាំងនោះចាប់ផ្ដើមរៀបពិធីផ្សេងៗ "*ក្នុងគ្រួសារ*" ដែលធ្វើឲ្យគ្រីស្ដបរិស័ទ មានលទ្ធភាពចែកចាយជំនឿរបស់ខ្លួន។ នៅទីបំផុត អ្នកទាំងនោះទទួលអត្ថបទគម្ពីរប៊ីប និងអត្ថបទបង្ហាញរបៀបធ្វើពិធីបុណ្យទាំងនោះ ព្រមទាំងសេចក្ដីអត្ថាធិប្បាយជាមួយផង សម្រាប់ប្រើប្រាស់តាមត្រូវការ។

ការអប់រំអ្នកទទួលខុសត្រូវគ្រីស្ដសាសនានេះ នាំឲ្យក្រុមគ្រីស្ដបរិស័ទគណៈផ្សេងៗ និងបរិស័ទរបស់សាសនាឯទៀតៗផ្ដើមជួបគ្នា និងសន្ទនាពិភាក្សាគ្នា។ យុវជនគ្រីស្ដបរិស័ទកាតូលិក និងយុវជនក្រុមជំនុំដំណឹងល្អខ្មែរចង់រួបរួមគ្នា ត្រង់ចំណុចសំខាន់នៃជំនឿគ្រីស្ដសាសនា ដោយមិនបណ្ដាលឲ្យប្រេះឆាគ្នា។ យុវជនកាតូលិកតែងចូលរួមក្នុងពិធីនៃក្រុមជំនុំដំណឹងល្អខ្មែរ ហើយយុវជនខ្លះខាងក្រុមជំនុំដំណឹងល្អ ក៏តែងចូលរួមក្នុងអភិបូជារបស់គ្រីស្ដបរិស័ទកាតូលិកដែរ។ ចាប់តាំងពីឆ្នាំ ១៩៧៣ មក មានបង្កើតគណៈកម្មាធិការសម្រាប់ប្រែសម្រួលព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី ឲ្យឯកភាពគ្នា ក្រោមកិច្ចឧបត្ថម្ភរបស់សមាគមគម្ពីរសកល (United Bible Society)។ គណៈកម្មាធិការប្រែសម្រួលមានសមាជិកប្រាំនាក់ គឺអ្នកបកប្រែបីនាក់ អ្នករចនាមកពីក្រុមជំនុំដំណឹងល្អខ្មែរម្នាក់ និងអ្នកបច្ចេកទេសកាតូលិកម្នាក់។

តាមពិត គ្រីស្ដបរិស័ទកាតូលិកចង្អៀតចង្អល់ចិត្តខ្លះ នឹងរបៀបសាសនទូតអាមេរិក ដែលដូចជាខ្នះខ្នែងខំបញ្ចូលសាសនាខ្លាំងពេក គឺលោកទាំងនោះដូចជាមើលងាយព្រះពុទ្ធសាសនាជ្រុលហួស។ ក្នុងឆ្នាំ ១៩៦៥ ពេលប្រទេសកម្ពុជា និងសហរដ្ឋអាមេរិកផ្ដាច់ចំណងទូតឈប់ទាក់ទងគ្នា សម្ដេចសីហនុហាមអស់លោកគង្វាលអាមេរិក មិនឲ្យនៅក្នុងប្រទេសកម្ពុជាតទៅទៀតទេ។ តែចាប់ពីឆ្នាំ ១៩៧០ មក អស់លោកត្រឡប់មកប្រទេសខ្មែរវិញ។ ក្នុងឆ្នាំ ១៩៧២ ពួកគេបើកសម័យប្រជុំជាច្រើនលើក ដើម្បីប្រកាសដំណឹងល្អតាមរបៀបអាមេរិក នៅក្នុងសាលមហោស្រពធំជាងគេក្នុងរដ្ឋធានី ហើយក៏ប្រមូលបានមនុស្សរាប់ពាន់នាក់។ តាំងពីឆ្នាំ ១៩៧៣ អង្គការមនុស្សធម៌ឈ្មោះ "*ទស្សនៈពិភពលោក*" (World Vision) តាំងទីនៅក្នុងរដ្ឋធានីភ្នំពេញ ហើយតែងផ្ដល់ការងារឲ្យតែជនណាដែលទទួលពិធីជ្រមុជទឹកទេ។ គ្រប់ទីកន្លែងពួក "*អ្នកប្រកាសដំណឹងល្អ*" ចែកខិតប័ណ្ណ ឬចែកព្រះគម្ពីរប៊ីប។ ចំនួនជឿតាមគណៈគ្រីស្ដបរិស័ទក្រុមជំនុំដំណឹងល្អខ្មែរ

កើនឡើងមួយទ្វេជាពីរ គឺឡើងដល់បួនប្រាំពាន់នាក់។ ក្នុងឆ្នាំ ១៩៧៥ មានគង្វាលខ្មែរ ដប់ពីរនាក់គង្វាលអាមេរិកប្រាំនាក់ និងបារាំងពីរនាក់ដឹកនាំក្រុមជំនុំដំណឹងល្អខ្មែរនោះ។

ការអប់រំគ្រីស្តបរិស័ទ ឲ្យទទួលខុសត្រូវលើព្រះសហគមន៍ ហុចឱកាសឲ្យគ្រីស្ត បរិស័ទជួបទាក់ទងជាមួយនឹងសាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យ ព្រមទាំងជាមួយនឹង អាចារ្យខាងសាសនាអ៊ីស្លាមដែរ។ ក្នុងឆ្នាំ ១៩៧៣ នាយកសហគមន៍អ៊ីស្លាម ហើយ និងភូឈួយរបស់លោក យល់ព្រមអញ្ជើញមកនិយាយអំពីជំនឿ របស់អស់លោក ទៅកាន់ក្រុមអ្នកអប់រំគ្រីស្តសាសនា។ បន្តិចម្តងៗចំណងមិត្តភាពថ្មី ក៏កើតមានឡើង។

ក្នុងពេលសង្គ្រាមដែលបណ្តាលឲ្យប្រទេសកម្ពុជាច្រួលច្របល់ជាខ្លាំងនោះ គ្រីស្ត បរិស័ទលះបង់ចោលរបៀបគោរពសាសនាប្រពៃណី ហើយចាប់ផ្តើមមានជំនឿផ្ទាល់ ខ្លួនកាន់តែប្រសើរឡើង។ ព្រះសហគមន៍រៀបចំខ្លួនចាំទប់ទល់នឹងអនាគតដ៏សែន លំបាក ក៏ប៉ុន្តែ មិនបានជាគិតគូរឲ្យច្បាស់អំពីមហាទុក្ខវេទនា ដែលនឹងកើងមាន ឡើងនោះឡើយ។

**ឆ្ពោះទៅរក «មហាទុក្ខវេទនា»**

ថ្ងៃទី ១ មករា ឆ្នាំ ១៩៧៥ វេលាកណ្តាលអាធ្រាត្រ ខ្មែរក្រហមចាប់វាយលុកផ្តាច់ព្រ័ត ចូលក្រុងភ្នំពេញ។ ក្នុងអំឡុងបីខែបន្ទាប់មក ពួកគេព័ទ្ធកាន់តែជិតឡើងៗ តឹងឡើងៗ ជាលំដាប់។ ពួកគេកាត់ផ្តាច់ទន្លេមេគង្គ ដែលជាផ្លូវសម្រាប់នាំអង្ករមកចិញ្ចឹមប្រជាជន នៅភ្នំពេញ។ បន្ទាប់មក ពួកខ្មែរក្រហមរារាំងលែងឲ្យមានចលនាជំនួញ ពីក្រុង បាងកកតាមអាកាសយានដ្ឋានពោធិចិនតុង ដោយពួកគេបាញ់ផ្លោងគ្រាប់កាំភ្លើងធំ និង គ្រាប់រ៉ូកែតចូលវាលយន្តហោះនេះពុំឈប់ឈរ។ ពួកទាហានសាធារណរដ្ឋទទួលបរាជ័យ ជាបន្តបន្ទាប់ ហើយអំណាចរបស់រដ្ឋាភិបាលចេះតែអន់ខ្សោយ ពីមួយថ្ងៃទៅមួយថ្ងៃ។ ស្ថានទូតបរទេសទាំងឡាយបិទទ្វារជាបន្តបន្ទាប់។ ថ្ងៃទី ១២ មេសា ពួកអាមេរិក ចាកចេញពីប្រទេសកម្ពុជា។

តាំងពីដើមឆ្នាំ ១៩៧៥ ជនបរទេសនិងជនជាតិខ្មែរដែលជាអ្នកមាន រកមធ្យោបាយ រត់ចេញទៅជ្រកនៅឯបរទេស។ ក្នុងខែកុម្ភៈសម្តេចនរោត្តមសីហនុបង្គាប់ពីក្រុងប៉េកាំង មក ឲ្យជនបរទេសទាំងអស់ចាកចេញប្រទេសកម្ពុជា ព្រោះព្រះអង្គពុំអាចធានារ៉ាប់រង

ជីវិតអ្នកទាំងនោះបានឡើយ។ បីបួនថ្ងៃក្រោយមក អង្គការនៃសាសនទូតនៅក្រុងប៉ារីស សុំឲ្យអស់លោកសាសនទូត ដែលមិនកាន់មុខងារ "*ចាំបាច់*" សម្រាប់ព្រះសហគមន៍ប្រទេសកម្ពុជា អញ្ជើញត្រឡប់ទៅក្រុងប៉ារីសវិញ។ ថ្ងៃទី ១៧ មីនា ស្ថានទូតបារាំងបម្រុងយន្ត ហោះទាហានមួយឈ្មោះត្រង់សាល់ (Transal) ទុកសម្រាប់ដឹកជនជាតិបារាំងដែលប្រាថ្នាវិលត្រឡប់ទៅមាតុភូមិវិញ។

បីបួនថ្ងៃមុននេះ នាក្រុងភ្នំពេញមានបើកសម័យប្រជុំអស់លោកបូជាចារ្យ។ បូជាចារ្យម្នាក់ៗ ត្រូវបញ្ជាក់អំពីបំណងរបស់ខ្លួនថា ទៅ ឬនៅ។ បូជាចារ្យបីនាក់ដែលមិនសូវមានទំនាក់ទំនងជាមួយជនជាតិខ្មែរ សុំត្រឡប់មាតុភូមិវិញ។ បូជាចារ្យឯទៀតៗ សម្រេចចិត្តថានៅនឹងកន្លែង  ដោយអស់លោកធ្លាប់រួមសុខទុក្ខជាមួយបងប្អូនខ្មែរតាំងពីយូរឆ្នាំមកហើយ  អស់លោកពុំអាចសម្រេចចិត្តលះបង់ចោលបងប្អូនខ្មែរក្នុងកាលៈទេសៈដ៏លំបាកដូច្នេះបានឡើយ។

ក្រុម "*គ្លែរឡូហ្ស៊ី* " (Clair Logis) សុខចិត្តនៅដូចអស់លោកបូជាចារ្យដែរ។ លោកសង្ឃបេណេឌីកតូ ឲ្យអស់បងៗដែលមានស្មារតីឆាប់ញាប់ញ័រវិលទៅប្រទេសបារាំងវិញ ហើយលោកសង្ឃបារាំងប្រាំមួយអង្គទៀតសម្រេចចិត្តថា  មិនបែកចេញពីបងៗខ្មែរឡើយ ទោះសភាពការណ៍ទៅជាយ៉ាងណាក៏ដោយ។ បព្វជិតាភាគច្រើនខាងក្រុមគ្រួសារឧបការគុណសម្រេចចិត្តនៅដូចគ្នា តែបព្វជិតានាយិកាបញ្ជូនដូនជីក្មេងៗជាងគេ ទៅស្រុកបារាំងឲ្យទៅបន្តការសិក្សា។ ថ្ងៃទី ៤ មករា លោករ៉ាមូស សម្រេចចិត្តបញ្ជូនបព្វជិតា គណៈកាមែលទៅក្រុងបាងកក ព្រោះបព្វជិតាទាំងនោះសុទ្ធតែជាជនជាតិវៀតណាមនិងបារាំង ហើយភាគច្រើនមានវ័យចាស់ណាស់ទៅហើយ ឬពិការទៀតផង។ ពុំគប្បីទុកបព្វជិតាទាំងនោះឲ្យនៅរងទុក្ខវេទនាឡើយ[៣]។ ចំណែកឯគង្វាលខាងក្រុមជំនុំដំណឹងល្អខ្មែរសម្រេចចិត្តដកខ្លួនថយទៅវិញ ប្រហែលជាអស់លោកយល់ថា លែងមានមុខងារជាចាំបាច់ទៀតហើយ ព្រោះមានជនជាតិខ្មែរទទួលខុសត្រូវដឹកនាំក្រុមជំនុំបានទៅហើយ។

នៅ ឬ ទៅ? អស់លោកបូជាចារ្យ បព្វជិត និងបព្វជិតាខ្មែរ ត្រូវឆ្លើយនឹងសំណួរនេះផងដែរ។ បូជាចារ្យវ័យក្មេងជាងគេ គឺលោកម៉ារសែល ទ្រឿងចំរើន បញ្ជាក់ថាគួរតែនៅដោយពោលថា អស់លោកបានថ្វាយខ្លួនទៅព្រះជាម្ចាស់ហើយ! មិនគួរគប្បីរកកន្លែងជ្រកពួនសម្ងំយកសុខក្នុងពេលមានកើតវេទនាដូច្នេះឡើយ។ អស់លោកបានអង្វរ

ព្រះជាម្ចាស់ជួយបំភ្លឺ រួចអស់លោកអ្នកបួសបានសម្រេចចិត្តថា នៅទាំងអស់គ្នា អស់លោកអ្នកបួសនោះក៏បានបូជាជីវិតទាំងអស់ដែរ។ យូរបន្តិចក្រោយមក នាថ្ងៃទី ១១ មេសា អ្នកអប់រំគ្រីស្តសាសនាជាតិចិនម្នាក់ គឺលោកសិលាឡាំ សម្រេចថាទៅ។ លោក ឡាំ នេះទទួលបន្ទុកលើជនជាតិចិន ក្រោយពីលោកបូជាចារ្យខាងសមាគមព្រះយេស៊ូត្រឡប់ទៅមាតុប្រទេសវិញ។ គាត់បានសម្រេចចិត្តថា នឹងចាកចេញពីប្រទេសកម្ពុជាទៅហុងកុង។ ព្រឹកថ្ងៃទី ១១ មេសា គាត់ជូនដំណឹងនេះដល់លោកបូជាចារ្យ ដែលទទួលបន្ទុកអ្នកអប់រំគ្រីស្តសាសនា។ លោកបូជាចារ្យសុំឲ្យគាត់កត់សម្គាល់ថា មានតែគាត់ម្នាក់ឯងដែលនៅទទួលខុសត្រូវលើគ្រីស្តបរិស័ទក្រុងភ្នំពេញ។ លោកឡាំ ក៏សុំគិតបួនប្រាំម៉ោង។ លុះដល់ពេលល្ងាច លោកជូនចម្លើយដល់លោកបូជាចារ្យនោះថា "*ខ្ញុំនៅ*" ។ គាត់បានតស៊ូរស់នៅក្នុងរបបប៉ុលពត អស់ពេលបួនឆ្នាំ ព្រោះតែលោកមានសេចក្តីក្លាហានប្រតិបត្តិតាមជំនឿរបស់ខ្លួន[៤]។

ក្នុងពេលប្រជុំអស់លោកបូជាចារ្យខែមីនា លោកអភិបាលព្រះសហគមន៍បានសួរលោកបូជាចារ្យនីមួយៗ ឲ្យយោបល់ថា គួរហៅលោកយ៉ូសែប ឆ្មារ សាឡាស់ដែលកំពុងរៀននៅប្រទេសបារាំង ឲ្យត្រឡប់មកស្រុកវិញឬយ៉ាងណា?។ អស់លោកបូជាចារ្យផ្តល់យោបល់ថា គួរហៅលោកមកវិញ។ លើសពីការវិលត្រឡប់មកវិញនេះ មានចោទបញ្ហាតែងតាំងអភិបាលព្រះសហគមន៍ខ្មែរម្នាក់ប្រចាំក្រុងភ្នំពេញ។ អស់លោកយល់ឃើញថា ពួកខ្មែរក្រហមមុខជានឹងហាមឃាត់ជនបរទេស មិនឲ្យធ្វើអ្វីកើត ឬពួកគេចាប់អស់លោកទាំងនោះដាក់គុក ឬដេញចេញ ឬក៏សម្លាប់ចោលផង។ បើពិតជាដូច្នេះមែនសហគមន៍គ្រីស្តសាសនាមុខជានឹងលែងមានអ្នកទទួលខុសត្រូវ។ លោក សាឡាស់ ត្រឡប់មកវិញភ្លាម គឺបន្ទាប់ពីលោកបានទទួលសារទូរលេខពីលោកអភិបាលព្រះសហគមន៍។ ក្នុងពេលលោករៀបចំចេញពីទេវវិទ្យាល័យនាក្រុងប៉ារីស លោកឥតយល់ច្រឡំសោះឡើយ គឺលោកដឹងក្នុងចិត្តថា សម្តេចប៉ាបប្រាថ្នាឲ្យលោកទទួលបន្ទុកជាអភិបាលព្រះសហគមន៍ប្រទេសកម្ពុជា ក្នុងគ្រាដ៏លំបាកនេះហើយ។ ពេលចេញដំណើរ លោកនិយាយទៅកាន់មិត្តភ័ក្តិបារាំងថា៖ "*ខ្ញុំត្រឡប់ទៅប្រទេសខ្មែរវិញ ហើយស្លាប់នៅទីនោះជាពុំខាន* "។ ក្នុងពេលជាមួយគ្នានោះ លោកប៉ុលទេពអ៊ឹម ក៏កំពុងធ្វើដំណើរទៅទ្វីបអឺរ៉ុបដែរ។ ដោយលោកមិនចង់បោះបង់ចោលគ្រីស្តបរិស័ទឲ្យ នៅតែឯងក្នុងគ្រាដ៏សែនពិបាកនេះ លោក

វិលត្រឡប់ចូលមាតុប្រទេសវិញជាបន្ទាន់។ លោកដឹងហើយថា អនាគតសឹងខ្មៅងងឹត។ លោកលាមិត្តសម្លាញ់ដោយពោលថា៖ "*ក្នុងបីអាទិត្យទៀត ខ្ញុំប្រហែលជាស្លាប់ទៅហើយមើលទៅ*"។

ថ្ងៃចន្ទទី ៧ មេសា ក្រឹត្យរបស់សម្ដេចប៉ាបមកដល់ភ្នំពេញ គឺជាក្រឹត្យផ្លូវការដែលតែងតាំងលោកយ៉ូសែប ឆ្នារសាឡាស់ ជាអភិបាលសហការីរបស់អភិបាលព្រះសហគមន៍ប្រចាំភូមិភាគភ្នំពេញ។ អស់លោកគ្រោងធ្វើពិធីតែងតាំងលោកជាអភិបាលព្រះសហគមន៍ក្នុងថ្ងៃអាទិត្យទី ១៣ មេសា ដែលជាថ្ងៃចូលឆ្នាំខ្មែរតែម្តង កុំឲ្យខាតពេលវេលាច្រើន។ អ្នកទទួលខុសត្រូវក្រុមគ្រីស្តបរិស័ទខ្មែរ បានសុំឲ្យលើកពិធីនោះ ទៅធ្វើនៅថ្ងៃអាទិត្យបន្ទាប់វិញ ដើម្បីឲ្យពួកគេមានពេលរៀបចំឲ្យបានអធិកអធម។ ក៏ប៉ុន្តែ ក្នុងថ្ងៃចន្ទទី ១៤ មេសា គេដឹងថានៅតែមួយថ្ងៃពីរប៉ុណ្ណោះ ខ្មែរក្រហមមុខជាវាយយកភ្នំពេញបានជាមិនខាន ឬក៏ប្រហែលក្នុងរវាងប៉ុន្មានម៉ោងទៀតផង។ ពេលថ្ងៃត្រង់ រដ្ឋអំណាចចេញប្រកាសបិទចរាចរ។ ដូច្នេះគ្រីស្តបរិស័ទក៏ សម្រេចចិត្តធ្វើពិធីតែងតាំងលោក សាឡាស់ ជាអភិបាលក្នុងល្ងាចថ្ងៃចន្ទនោះ នៅព្រះវិហារព្រះមាតា ដែលជាទីជួបជុំរបស់ក្រុមគ្រីស្តបរិស័ទខ្មែរ។ ទោះបីជាមានបិទចរាចរក៏ដោយ ក៏បូជាចារ្យទាំងអស់ ព្រមទាំងគ្រីស្តបរិស័ទប្រហែលពីររយនាក់ ចូលរួមក្នុងពិធីតែងតាំងអភិបាលខ្មែរ លើកទីមួយនេះ។ គ្រាប់រ៉ូកែតដែលខ្មែរក្រហមឆ្លោងចូលភ្នំពេញពីរគ្រាប់ធ្លាក់នៅជិតព្រះវិហារ ហាក់ដូចជាកំណត់ពេលឲ្យពិធីចាប់ផ្ដើមឡើង។ ដោយមានលោកឡឺស៊ូអែហ្វ និងបូជាចារ្យទាំងអស់នៅអមផង លោក រ៉ាមូស ជាអភិបាលព្រះសហគមន៍តែម្នាក់ឯង ធ្វើពិធិតែងតាំងលោកឆ្នារសាឡាស់ជាអភិបាល។

ថ្ងៃទី ១៤ មេសា ឆ្នាំ ១៩៧៥ ក្រុងភ្នំពេញមានលោកអភិបាលព្រះសហគមន៍ខ្មែរម្នាក់ដែលនឹងនៅរួម ជាមួយគ្រីស្តបរិស័ទខ្មែររហូត។

---

(១) សេចក្ដីរាយការណ៍របស់លោករ៉ាមូសចុះផ្សាយក្នុងទស្សនាវដ្ដី "Echos de la Rue du Bac" , No 74, 1974.

(២) លិខិតលេខ ១៥៣៨ ចុះថ្ងៃទី ១.៤.៧៤ ឆ្លើយតបថា៖ "*រឿងដែលបានស្នើមកនោះ ដូចជាមិនទាន់ដល់ពេលទេ* " (Prout exponitur, non expedire)។ ចម្លើយរបស់ក្រសួងសម្រាប់ផ្សាយគ្រីស្តសាសនា

ផ្តល់យោបល់ឲ្យតែងតាំងឧបដ្ឋាកជាអចិន្ត្រៃយ៍ ទាំងអនុញ្ញាតឲ្យអ្នកទាំងនោះរៀបការ ជាលើកទីពីរបាន បើខ្លួនទៅជាពោះម៉ាយ។ ក្រសួងនោះឲ្យយោបល់ថា គួរបង្កើតមុខងារពិសេសដែលមានចែងនៅ តាមសារលិខិតរបស់សម្តេចប៉ាប (Ministeria quaedam) ។

(៣) បន្ទាប់មកបព្វជិតាគណៈការមែល ចេញទៅតាំងទីនៅប៊ូសស៊ុយ នាប្រទេសបែលស៊ិក (Boussu, Belgigue) ហើយនៅទីនោះរហូតដល់សព្វថ្ងៃនេះ។

(៤) សព្វថ្ងៃនេះ គាត់ជាជនភៀសខ្លួននៅស្រុកបារាំង ក្នុងភូមិភាគប៉ារីស ។

## ជំពូកទី ១៦

# ការព្រាត់ប្រាស

នៅព្រឹក "*ថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដ៏មហារុងរឿងមហាអស្ចារ្យ*" កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ ចាប់ពីម៉ោង ១១ ព្រឹកទៅ ពួកគេដេញអ្នកជំងឺនិងអ្នករបួសចេញពីមន្ទីរពេទ្យ។ នៅវេលាម៉ោង ១៣ រសៀល ពួកគេបណ្តេញប្រជាជនទាំងអស់ចេញពីទីក្រុងឲ្យទៅនៅស្រុកស្រែចម្ការ។

ក្នុងរយៈតែ ២ ឬ ៣ថ្ងៃប៉ុណ្ណោះ ភ្នំពេញក្លាយទៅជាក្រុងខ្មោច។ រីឯក្រុងបាត់ដំបងដែលជាក្រុងទី ២ និងក្រុងដទៃៗទៀត ក៏ត្រូវខ្មែរក្រហមធ្វើដូច្នេះដែរ។ ចំណែកឯជនបរទេសវិញ ពួកខ្មែរក្រហមប្រមូលផ្តុំនៅក្នុងស្ថានទូតបារាំង រួចបញ្ជូនទៅទល់ដែនខ្មែរថៃនៅថ្ងៃទី ៣០ មេសា និងនៅថ្ងៃទី ៤ ឧសភា។

ប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅក្នុងតំបន់រដ្ឋាភិបាល លន់ នល់ កាន់កាប់ រហូតដល់ឆ្នាំ ១៩៧៥ ត្រូវខ្មែរក្រហមចាត់ទុកជា "*ឈ្លើយសង្គ្រាម*" ឬ "*ប្រជាជនថ្មី*" ។

តាមទំនៀមទម្លាប់យុទ្ធសាស្ត្របុរាណខ្មែរ ពួកបដិវត្តប្រល័យពូជសាសន៍សម្លាប់អស់លោកនាយទាហាន និងអ្នករដ្ឋការជាន់ខ្ពស់នៃរបបបរាជ័យ ដោយគ្មានជំនុំជំរះឡើយ។

ចំណែក "*ប្រជាជនថ្មី*" ពោលគឺ "*ប្រជាជនរំដោះនៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥*" អង្គការរៀបចំពួកគេដូចជាកងទ័ពមួយដ៏ធំ ដើម្បី "*វាយសម្រុកបង្ករបង្កើនផល*" ។ គេធ្វើការទាំងថ្ងៃ ទាំងយប់ ទៅតាមអង្គការដាក់ទិសដោយគ្មានត្អូញត្អែរពីការនឿយហត់ និងការលំបាកឡើយ។ កងពលទាសករនេះ ត្រូវ "*ជីកប្រឡាយ លើកទំនប់*" ដើម្បីឲ្យប្រទេសកម្ពុជាមានប្រព័ន្ធប្រឡាយដូចពីសម័យអង្គរ និងដើម្បីឲ្យប្រជាជនអាច ធ្វើស្រែក្នុងមួយ

ឆ្នាំ ៣ ដង។ "*អង្គការ*" ដែលជាតំណាងបក្សនិងជា រដ្ឋបាលត្រួតត្រានិងដឹកនាំប្រជាជនក្នុងគ្រប់កិច្ចការទាំងអស់ សូម្បីតែកិច្ចការតូចតាច ក៏ "*អង្គការ*" ចាត់ចែងត្រួតត្រាដែរ។ អង្គការបង្ខំប្រជាជនឲ្យធ្វើការ ដោយមិនគិតពីការហត់នឿយ គ្មានថ្ងៃឈប់សម្រាក មិនផ្តល់ចំណីអាហារគ្រប់គ្រាន់។ ពេលឈឺគេយកតែថ្នាំបុរាណ មានឫសឈើសំបកឈើជាដើមមកព្យាបាល ដែលជាហេតុធ្វើឲ្យប្រជាជនស្លាប់ជាបន្តបន្ទាប់។

មិនតែប៉ុណ្ណោះសោត "*អង្គការ*" កាប់សម្លាប់រង្គាលប្រជាជន ដោយចោទថាជា "*អ្នកប្រឆាំងនឹងវិន័យរបស់អង្គការ*" ឬជា "*ខ្មាំង*"។ ក្នុងរយៈពេល ៣ ឆ្នាំ ៨ ខែ និង ២០ ថ្ងៃ នៃរបបដ៏សែនឃោរឃៅនេះ ប្រជាជនជិត ២ លាននាក់ ស្លាប់បាត់បង់ជីវិត[១]។

ពេលខ្មែរក្រហមចូលក្រុងភ្នំពេញ ដូនជីក្រុមគ្រួសារឧបការគុណនិងលោកសង្ឃមកពីវត្តសន្តសាគរារាម ទាំងបារាំង ទាំងខ្មែរ នៅជុំគ្នាក្នុងគេហដ្ឋានដូនជីក្រុមឧបការគុណ។ ចំណែកឯលោកបូជាចារ្យខ្មែរទាំងពីរនាក់ គឺលោកយ៉ូសែបឆ្មារ សាឡឹម និងលោកម៉ារសែល ទ្រឿង ចំរើន ព្រមទាំងលោកយ៉ូសែប ឆ្មារ សាឡាស់ ជាអភិបាលថ្មីទៅនៅជាមួយក្រុមគ្រីស្តបរិស័ទខ្មែរ ក្នុងភូមិព្រះមាតា។ រីឯបូជាចារ្យបារាំង និងក្រុមស្រីៗខាងគ្លែឡូហ្ស៊ី មកនៅជុំគ្នាក្នុងគេហដ្ឋានរបស់លោកអភិបាលវិញ។ ក្រោយពីបានរិះគិតរួមគ្នាមក អស់លោកក៏បំបែកគ្នាដូច្នេះ គឺក្នុងបំណងជៀសវាងកុំឲ្យខ្មែរក្រហមសម្លាប់គ្រីស្តបរិស័ទខ្មែរ ព្រោះថាតាមធម្មតា ពួកខ្មែរក្រហមតែងសម្លាប់ជនជាតិខ្មែរទាំងប៉ុន្មានដែលនៅជាមួយជនជាតិបរទេស។

តាំងពីព្រលឹមថ្ងៃ ១៧ មេសា មក ពួកខ្មែរក្រហមចូលទៅក្នុងវត្តដូនជីក្រុមគ្រួសារឧបការគុណ ហើយបញ្ជារឲ្យដូនជី កូនកំព្រា និងលោកសង្ឃចាកចេញពីកន្លែងនោះ។ ដូនជី និងលោកសង្ឃ ក៏ធ្វើតាមបញ្ជាពួកខ្មែរក្រហមដោយគ្មានតវ៉ា យកតែបង្វិចតូចមួយជាប់នឹងខ្លួន ធ្វើដំណើររួមជាមួយប្រជាជនខ្មែរក្រហមដេញចេញពីទីក្រុងដែរនោះ។ លោកសង្ឃរាជវត្តសាគរារាមរ៉ាយរាប់ថា៖

*«បណ្តាជនទាំងនោះដើរទាំងស្មៀមស្ងាត់ ធ្វើឲ្យយើងឆ្ងល់ជាខ្លាំង គ្មាននរណាតវ៉ាឬប្រកែកទេ គេស៊ូទ្រាំទាំងអស់គ្នា។ តែផ្ទុយនឹងបណ្តាជនដែលនៅស្ងៀមស្ងាត់នេះ ពួកខ្មែរក្រហមខ្លះដែលមានអាយុប្រហែល ១៣ ឆ្នាំ ចេះតែគំរាមកំហែង ហើយបាញ់សម្លាប់អ្នកធ្វើខុសនឹងបញ្ជារបស់គេ»។*

អស់លោកនិងដូនជី ធ្វើដំណើរទាំងលំបាកអស់រយៈពេលប្រាំថ្ងៃ ទើបមកដល់ព្រែកព្នៅ ដែលស្ថិតនៅចម្ងាយ ១២ គ.ម. ខាងជើងរដ្ឋធានីភ្នំពេញ។ នៅទីនេះ អស់លោកត្រូវបែកគ្នាជាលើកទីមួយ ព្រោះខ្មែរក្រហមដាក់ទិសឲ្យអស់លោកជាតិបារាំង ទៅនៅផ្ទះមួយផ្សេង។ លោកសង្ឃរាជព្រួយចិត្តណាស់ លោក ផ្ញើលោកសាមណេរខ្មែរពីរអង្គ ឈ្មោះ ដានីសេង និម្មិត និងអង់ជ្រេ វំជួរ ព្រមទាំងយុវជនមួយចំនួនដែលស្នាក់អាស្រ័យនៅក្នុងវត្ត ឲ្យលោកប៉ែរណា ឈឹម ឈុន សរ ដែលជាលោកសង្ឃផង និងជាបូជាចារ្យផង ជួយណែនាំ។ ចំណែកដូនជីបារាំង ក៏ខ្មែរក្រហមបំបែកចេញពីដូនជីខ្មែរនិងវៀតណាមទាំង ១៧ នាក់ដែរ។ ថ្ងៃ ២៣ មេសា ពួកបដិវត្តឲ្យរថយន្តនៃស្ថានទូតបារាំងមកប្រមូលពួកបស្ចឹមប្រទេស នាំទៅទីក្រុងភ្នំពេញវិញ។ ក្នុងចំណោមជនបរទេសទាំងនោះមានលោកសង្ឃនិងដូនជីបារាំងដែរ។

នៅថ្ងៃទី ១៧ មេសា លោកបូជាចារ្យ និងលោកអភិបាលខ្មែរទាំងបីនាក់ ឃ្លាតចេញពីក្រុមគ្រីស្តបរិស័ទព្រះមាតា គៀសខ្លួនទៅនៅគេហដ្ឋានលោកអភិបាល រង់ចាំខ្មែរក្រហមជម្លៀសប្រជាជនភ្នំពេញចេញអស់។ ប៉ុន្តែ នៅព្រឹកថ្ងៃទី ១៨ មេសា លោកទាំងបីដឹងថា បទបញ្ជារបស់ខ្មែរក្រហមតឹងរ៉ឹងណាស់គឺត្រូវតែធ្វើតាមជាដាច់ខាត។ លោកបូជាចារ្យខ្មែរលាបូជាចារ្យបារាំងដោយសេចក្តីស្ងៀមស្ងាត់តាមរបៀបខ្មែរ ហើយចាកចេញទៅទាំងផ្តែផ្តាំថា៖ "*សូមកុំបំភ្លេចពួកយើង! សូមរ៉ាយរ៉ាប់ឲ្យសកលលោកដឹងរឿងយើងផង* " ពាក្យនេះគឺជាបណ្តាំចុងក្រោយរបស់លោកអភិបាលសាឡាស់។

អង្គការជម្លៀសប្រជាជនក្រុងភ្នំពេញចេញតាមមុខព្រួញផ្សេងៗគ្នា ទៅតាមសង្កាត់ដែលគេរស់នៅ។ ដូច្នេះ គ្រីស្តបរិស័ទភាគច្រើន ត្រូវជម្លៀសទៅខាងជើងក្រុងភ្នំពេញ។ នាងសុភាព រ៉ាយរ៉ាប់ ពីទិដ្ឋភាពដ៏សែនខ្លោចផ្សារ ដែលនាងបានជួបប្រទះក្នុងពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីភ្នំពេញដូចតទៅ៖

> *«នារីកំពុងឈឺពោះប្រសូតបុត្រវេទនាខ្លាំងណាស់។ នារីកូនខ្ចីបីនាក់នៅនឹងដៃ កុមារាកុមារី ទើបចេះដើរ ចាស់ជរាពិការគ្មានទីពឹង ក៏វេទនាហួសពីការស្មាន។ អ្នកឈឺធ្ងន់ងើបមិនរួចពីគ្រែ ដែលកូនចៅមិនអាចនាំទៅជាមួយបាន កូនចៅនាំគ្នាលុតជង្គង់សុំទោសអ្នកជំងឺ លាចាកចេញទៅ ដោយទុកចោលបាយ ទឹក និងថ្នាំសង្កូវ បន្តិចបន្តួចក្បែរខ្លួនអ្នកជំងឺ។ ចំពោះអ្នកដែលអង្គការបណ្តេញឲ្យចេញហើយ*

*ដែលក្រោកមិនរួច ត្រូវយោធាបាញ់សម្លាប់នៅនឹងកន្លែង។ នៅតាមផ្លូវ ដោយភាពចង្អៀតកកកុញណែនណាន់ យើងឮសូរសម្លេងយំទ្រហឹង ព្រោះវង្វេងព្រាត់ប្រាសឪពុកម្ដាយក្រុមគ្រួសារ។ ឃើញសាកសពអ្នកជំងឺដេកស្លាប់ នៅតាមចិញ្ចើមថ្នល់ដោយគ្រាន់តែមានក្រណាត់គ្របពីលើបន្តិចបន្តួចប៉ុណ្ណោះ។ មានស្ត្រីសម្រាលកូននៅលើថ្នល់ ដោយមានតែក្រមារុំព័ទ្ធបន្តិចបន្តួចប៉ុណ្ណោះ។ មានអ្នកជំងឺដេកក្នុងអង្រឹង សែងដោយកូនក្មួយមានទឹកមុខក្រៀមក្រំ។ ព្រះសង្ឃគ្រងស្បង់ចីពរពណ៌លឿង ស្ពាយថង់យាមចេញពីវត្ត មកច្របូកច្របល់ជាមួយប្រជាជនដោយព្រះភ័ក្ត្រស្ងួតស្ងប់។*

*គ្រីស្តបរិស័ទភូមិព្រះមាតា រួមគ្នាជាបីឬបួនគ្រួសារ ដើរចេញជាមួយគេដែរ។ គ្រួសារខ្លះមានកម្លាំងទន់ខ្សោយ ត្រូវបានគ្រួសារផ្សេងៗទៀតជួយយកអាហារដោយកាន់បង្ខិចបន្តិចបន្តួចឲ្យ។ ដោយពុំបាននឹកស្មានថា មានព្រឹត្តិការណ៍ចាកចេញពីទីក្រុងដូច្នេះ គ្រួសារជាច្រើនគ្មានយកបាយមកជាមួយទេ។ បងប្អូនខ្ញុំពុំបានបរិភោគអាហារអ្វីសោះ ដោយជ្រួលច្របល់ចំពោះសភាពការណ៍នេះ ដូច្នេះពេលអង្គការបណ្ដេញចេញ យើងក៏បានដួសបាយនោះដាក់ស្រោក់ និងទឹកឆ្អិនមួយបំពង់ឫស្សីយកទៅតាមផ្លូវ។ ដោយមានបាយមួយស្រាក់នេះហើយនៅពេលល្ងាចនោះ យើងបានដួសចែកឲ្យកុមារាកុមារី ដែលហត់នឿយលំបាកហើយ ស្រែកយំដោយឃ្លានបាយនិងស្រេកទឹក។ ពេញមួយថ្ងៃនេះ យើងជាចាស់ៗមិនបានបរិភោគបាយទាំងព្រឹកទាំងល្ងាច។ ដោយអស់កម្លាំង និងងងឹតពេក យើងនាំគ្នាដេកលើចិញ្ចើមថ្នល់។ ចលនាអ៊ូអរនៅតែមានជាប់ជាប្រចាំព្រោះមានអ្នកធ្វើការជាប់រហូត។ ទៀបភ្លឺ ប្រហែលម៉ោង ៣ ឬ ៤ ទើបយើងដឹងថា យប់មិញនេះយើងបានដេកក្បែរសាកសពទាហាន ដែលស្លាប់ក្នុងពេលបាញ់ទល់គ្នាកាលពីម្សិលមិញ" ។*

បុរសម្នាក់រំឭកពីលោកសាឡាស់ ដែលនិយាយនៅច្រាំងចំរេះថា ៖

*"បងប្អូន! យើងគ្មានសង្ឃឹមនឹងបានវិលត្រឡប់មករស់នៅក្នុងក្រុងភ្នំពេញវិញទេ! គេឲ្យយើងទៅរស់នៅតាមទីជនបទធ្វើស្រែចម្ការ។ ប៉ុណ្ណោះហើយ! យើងគង់តែវេទនារហូត ទាំងបងប្អូនទាំងពួកលោក ប៉ុន្តែ យើងម្នាក់ៗត្រូវថែរក្សាជំនឿយើងទោះបីជួបការលំបាក និងវេទនាយ៉ាងណាក៏ដោយ ត្រូវឆ្លៀតឱកាសថែរក្សាជំនឿ និងផ្សាយជំនឿរបស់យើងតទៅទៀត។ បងប្អូនត្រូវសុខចិត្តបូជាជីវិតថ្វាយព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់ប្រជាជនខ្មែរទាំងមូលផង" ។*

បន្ទាប់ពីបានធ្វើដំណើរដ៏សែនលំបាកជាច្រើនថ្ងៃមក អស់លោកក៏ទៅដល់ព្រៃកញ្ចៅ។ នៅទីនោះ ប្រជាជនរាប់រយពាន់នាក់រង់ចាំអង្គការដាក់ទិសតទៅទៀត។ នាយទាហាននិងអ្នករដ្ឋការជាន់ខ្ពស់នៃរបប លន់ នល់ ត្រូវអង្គការអញ្ជើញឲ្យទៅបង្ហាញខ្លួនចំពោះរដ្ឋអំណាចថ្មី "*ដើម្បីវិលត្រឡប់ចូលទៅភ្នំពេញវិញ* " ។ គ្រីស្តបរិស័ទជាច្រើននៃព្រះសហគមន៍ព្រះមាតាធ្លាប់ធ្វើនាយទាហានមាន លោក មាស ជួន លោក កេត ជំពូក ក៏ចេញទៅបង្ហាញខ្លួនដែរ ហើយបាត់ខ្លួនរហូត។

> *«ដោយគ្រីស្តបរិស័ទគោរពថ្វាយបង្គំព្រះជាម្ចាស់ និងប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវក្រឹត្យវិន័យទាំង ១០ ប្រការរបស់ព្រះជាម្ចាស់ ដូច្នេះបងប្រុសខ្ញុំគិតថា អង្គការមិននិយាយកុហកប្រជាជនទេ "ប្រការទី ៨ កុំឲ្យនិយាយកុហក" ។ ល្ងាចមួយប្រហែលម៉ោង ៧ យប់ បងឆ្មារសាឡីបានប្រាប់យើងថា គាត់និងចន្ទ ទេវី បានទៅចុះឈ្មោះប្រាប់អង្គការរួចហើយ។ ទាំងអស់គ្នាធ្លាក់ថ្លើម តែយើងថ្វាយកិច្ចការទាំងនេះទៅព្រះអង្គ សូមព្រះអង្គសព្វព្រះហឫទ័យទទួលដោយក្តីស្រឡាញ់»។*

លោកវិរសេនីយឯក ក្រូច សំរេច ដ៏ក្លាហាន ដែលហ៊ានការពារព្រះវិហារព្រះមាតាកាលពីពេលមុនោះ ត្រូវគេសម្លាប់ចោលនៅនឹងកន្លែង។ ប៉ុន្មានថ្ងៃក្រោយមក លោកសាន ដែលមានដើមកំណើតនៅកំពង់គ ក៏ត្រូវគេសម្លាប់ចោលដែរ។

ពួកខ្មែរក្រហមឆែកឆេរគ្រប់វ៉ាន់បន្តិចបន្តួច ដែលប្រជាជនយកជាប់តាមខ្លួន ហើយប្រមូលយកសៀវភៅ ធម៌និងគម្ពីរទាំងប៉ុន្មាន សូម្បីតែគម្ពីររបស់អស់លោកបូជាចារ្យ ក៏គេយកដែរ។ លោកសាឡាស់ មានប្រសាសន៍ថា ៖ "*សូមប្រគល់ឲ្យគេទាំងអស់ទៅចុះ បើគេចង់ប្រមូលយកទាំងអស់ដូច្នេះ*" ។ ស្ត្រីម្នាក់ជាអ្នកអប់រំគ្រីស្តសាសនា ឈ្មោះ ឡាច សុខ លាក់គម្ពីរមួយក្បាល តែពួកខ្មែរក្រហមចាប់បាន ហើយបង្អត់បាយគាត់ មួយថ្ងៃ ទាំងគំរាមថា៖ "*ប្រសិនបើមិត្តឯងលាក់ម្តងទៀត មិត្តឯងត្រូវអត់បាយរហូត!* "។ ខ្មែរក្រហមបានកញ្ឆក់យកវ៉ែនតាមីញ៉ូបរបស់លោកចំរើន ដែលភ្នែកលោកមីញ៉ូបជាខ្លាំង។

> *«វាបាននិយាយថា៖ "មិត្តឯងមិនព្រមជម្រុះចោលឫកនាយទុន ជិះជាន់ប្រជាជនទេឬ?" លោកចំរើនបានសុំយកវ៉ែនតាវិញ ព្រោះលោកគ្មានវ៉ែនតាមួយទៀតជាប់តាមខ្លួនឡើយ ពួកខ្មែរក្រហមបានវាយលោកមួយស្នូកកាំភ្លើង ហើយនិយាយថា៖ "មិត្តឯងហ៊ានតថ្លៃផងឬ?" គ្រីស្ត បរិស័ទបានអង្វរអង្គការឲ្យយល់ថា លោកចំរើន*

*ងងឹតភ្នែក ចាំបាច់ត្រូវការពាក់វ៉ែនតា មិនមែនពាក់ឱ្យល្អនោះទេ ហើយនាំលោកចំរើនមកកន្លែងវិញ»។*

នៅព្រៃកញ្ចៅ លោកបូជាចារ្យទាំងបួននាក់ធ្វើពិធីអាពាហ៍ពិពាហ៍ដោយសម្ងាត់ជូនគ្រីស្តបរិស័ទជាច្រើន ដោយយកខ្សែអំពោះចងដៃបំពាក់ឱ្យគូស្វាមីភរិយាថ្មីជំនួសចិញ្ចៀនអាពាហ៍ពិពាហ៍។

*«នេះជាទិដ្ឋភាពមួយ ដែលកំសត់សម្រាប់មនុស្សលោក តែគឺជាសេចក្តីស្រឡាញ់មួយដ៏អស្ចារ្យរបស់គូស្វាមីភរិយាថ្មី និងជាទីពេញចិត្តបំផុតរបស់ព្រះបិតា។ អស់លោកក៏បានធ្វើបុណ្យលាបប្រេងជូនចាស់ជរា ពិការ និងអ្នកជំងឺធ្ងន់»។*

នៅកំពង់ចម្លងព្រៃកក្តាម ដែលស្ថិតនៅចម្ងាយដប់គ.ម. ខាងជើងភ្នំពេញ មានទូកចម្លងតែមួយគត់ សម្រាប់ឆ្លងទៅត្រើយម្ខាង។ កម្មាភិបាលខ្មែរក្រហមបំបែកគ្រួសារប្រជាជន ជម្លៀសទៅតាមចំណង់ចិត្តរបស់គេ ដោយមិនរវីរវល់ពីក្រុមគ្រួសារ ឬក្រុមមនុស្សណាទាំងអស់។ ដូច្នេះ គ្រីស្តបរិស័ទមួយភាគត្រូវជម្លៀសទៅប៉ែកខាងលិច គឺទៅខេត្តកំពង់ឆ្នាំង និងបាត់ដំបង និងមួយភាគទៀត បានឆ្លងទន្លេសាបទៅខេត្ត កំពង់ចាម និងកំពង់ធំ។ គ្រីស្តបរិស័ទដែលមានដើមកំណើតនៅកំពង់គ ក៏មានសង្ឃឹមថា នឹងបានត្រឡប់ទៅកាន់ភូមិកំណើតរបស់គេវិញ។

ក្រុមគ្រីស្តបរិស័ទ ដែលធ្វើដំណើរទៅទិសខាងលិច បានទៅដល់ស្តន់ចម្ងាយប្រហែល ៣០ គ.ម. ពីព្រៃកក្តាម ក្រោមកម្តៅថ្ងៃខែចែត្រ។ នៅក្នុងជួរដ៏វែងអន្លាយនៃប្រជាជនជម្លៀសទាំងនេះ មានមនុស្សចាស់ជរា និងក្មេងតូចៗជាច្រើនបន្តបន្ទាប់គ្នា នៅតាមបណ្តោយថ្នល់។ នៅស្តន់ រថយន្តជាច្រើននៅរង់ចាំពួកគេ អង្គការហៅអ្នកខ្លះឱ្យឡើងរថយន្តបញ្ជូនទៅតំបន់ខេត្តកំពង់ចាម ខ្លះទៀតទៅតំបន់កំពង់ធំ។ ម្នាក់ៗបារម្ភខ្លាចមិនបានទៅជួបជុំជាមួយគ្រួសាររបស់ខ្លួន។ ទោះបីអ្នកទាំងនោះខំស្រែកយំសោកអង្វរយ៉ាងណាក៏ ដោយក៏កម្មាភិបាលខ្មែរក្រហមមិនអើពើដែរ នៅពេលគេបង្ខំឱ្យឡើងឡាន គ្រួសារមួយចំនួនធំត្រូវបែកគ្នារហូត។ នាងសុភាពរ៉ាយរ៉ាប់ថា៖

*«ពេលឡានអង្គការមកដល់ អ្នកដំណើរប្រជ្រៀតគ្នាឡើងឡាន។ ដូច្នេះ នៅលើឡានគ្មានកន្លែងអង្គុយទេ អ្នកដំណើរអង្គុយជាន់លើគ្នា។ ចំពោះអ្នកជំងឺគឺត្រូវឈរព្រោះគ្មានកន្លែងស្រឡះអង្គុយទេ។ តែកុងឡានមួរម៉ៅ ចំពោះការដណ្តើមគ្នាឡើង*

*ឡាន វាក៏បើកឡានទៅមុខរឹងហើយឈប់ង៉ក់វិញភ្លាម ធ្វើឲ្យអ្នកខ្លះត្រូវធ្លាក់ពីលើឡាន និងធ្វើឲ្យយើងភ័យខ្លាចយ៉ាងខ្លាំង។ តែកុងឡានប្រហែលជាគិតថា ប្រជាជនភ្នំពេញជាហ្វូងសត្វស្រមោចហើយមើលទៅ ទើបគេធ្វើរបៀបនេះ»។*

លោកអភិបាលសាឡាស់ លោកសាឡឹម លោកចំរើន លោកប៉ែរណា បព្វជិតសាមណេរពីរអង្គ ដូនជី ៦ នាក់ និងកូនកំព្រា ៩ នាក់ ធ្វើដំណើរជុំគ្នាទៅដល់ភូមិតាំងគោក។ ពួកគេទៅស្នាក់នៅក្នុងវត្តទឹកថ្លា។ ជាសំណាងល្អ ភូមិនេះជាស្រុកកំណើតរបស់ សេង ហ៊ី ដែលត្រូវជាបងថ្លៃរបស់លោក សាឡាស់។ គាត់និយាយថា៖ "*សូមឈប់បារម្ភទៅ ទីនេះគឺជាផ្ទះរបស់ខ្ញុំ* "។ គាត់រំភើបចិត្តជាខ្លាំង ព្រោះគាត់បានជួបមីងយ៉ាត ជាម្ដាយរបស់គាត់ដែលបែកគ្នាតាំងពីស្រុកកើតសង្គ្រាមមកម្ល៉េះ។ ថ្ងៃបន្ទាប់មក គឺថ្ងៃទី ៣ ឧសភា "*ពួកឈ្លើយសង្គ្រាម* " ទាំងអស់ ត្រូវបង្ហាញខ្លួននៅចំពោះមុខការិយាល័យបី មួយសម្រាប់ទាហាន មួយទៀតសម្រាប់អ្នករដ្ឋការ និងមួយទៀតសម្រាប់កម្មករ។ តាមដំបូន្មានរបស់មីងយ៉ាត បូជាចារ្យទាំងបួននាក់ ព្រមទាំងបព្វជិតទាំងពីរនាក់ ទៅចុះឈ្មោះនៅការិយាល័យសម្រាប់អ្នករដ្ឋការថា ខ្លួនជាអតីតគ្រូបង្រៀន។ ដោយហេតុនេះលោកសាឡាស់ លោកសាឡឹម និងលោកចំរើន ត្រូវអង្គការបញ្ជូនឲ្យទៅនៅភូមិចាន់ ចម្ងាយ ២ ឬ ៣គ.ម. ពីតាំងគោក គឺជាភូមិមួយដែលពុំមានម្ហូបអាហារគ្រប់គ្រាន់ទេ។ អង្គការផ្ញើលោកទាំងបីនៅផ្ទះស្រ្តីមេម៉ាយម្នាក់ និងចាត់ស្រ្តីនេះឲ្យតាមដានផង។ នាងនេះជាប្រធាននារី និងជាប្រធានភូមិចាន់។ ដូច្នេះ ស្រ្តីនេះអាចតាមដានលោកទាំងបីបានយ៉ាងស្រួល។ ចំណែកលោកប៉ែរណា និងបព្វជិតសាមណេរពីរអង្គទៀត អង្គការបញ្ជូនឲ្យទៅនៅភូមិពង្រ។ ដូនជី និងកូនកំព្រា ទៅចុះឈ្មោះជាកម្មករ ហើយត្រូវអង្គការបញ្ជូនឲ្យទៅនៅភូមិខ្នាយទន់ដែលមានម្ហូបអាហារគួរសម។ បន្ទាប់មក ត្រូវគេជម្លៀសទៅនៅស្វាយទៀប។ គ្រានោះ យុវនារីគ្រីស្តបរិស័ទជាច្រើនរៀបការដោយសម្ងាត់ជាមួយយុវជនគ្រីស្តបរិស័ទដូចគ្នា ដើម្បីកុំឲ្យអង្គការបង្ខំឲ្យរៀបការជាមួយយោធាខ្មែរក្រហមពិការ។

ថ្វីបើត្រូវគេជម្លៀសចុះឡើងជាច្រើនដងក៏ដោយ ក៏គ្រីស្តបរិស័ទនៃក្រុងភ្នំពេញជាច្រើនបានរស់នៅផ្តុំគ្នានៅក្នុងតំបន់នេះដែរ គឺនៅម្តុំភូមិស្លី តាំងក្រសាំង ព្រែកសង្កែ និងសំរៀងជាដើម។ ពួកគេតែងជួបពួកគ្រីស្តបរិស័ទ ដែលមានកំណើតនៅភូមិកំពង់គ។ អង្គការជម្លៀសគ្រីស្តបរិស័ទកំពង់គនេះម្តងទៅហើយ កាលពីឆ្នាំ ១៩៧២ គឺពេលកងទ័ពខ្មែរក្រហមដណ្តើមយកភូមិគេបាន អង្គការខ្មែរក្រហមបានជម្លៀសពួក គេទៅតំបន់ខាងលើ

ស្ទឹងសែន ហើយនៅឆ្នាំ ១៩៧៤ ពួកគេគេចផុតពីពួកខ្មែរក្រហមរត់មករស់នៅកំពង់ធំ ដែលស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋាភិបាល លន់ នល់។ នៅខែមេសា ឆ្នាំ ១៩៧៥ ពេលខ្មែរក្រហមដណ្តើមបានជ័យជំនះ ដោយខ្លាចខ្មែរក្រហមធ្វើបាប ពួកគេនាំពួករត់ទៅនៅខាងត្បូងកំពង់ធំ។ អ្នកភូមិម្នាក់ប្តឹងអង្គការខ្មែរក្រហមឲ្យចាប់មេគ្រួសារ ៥៦ នាក់ យកទៅសម្លាប់នៅភ្នំសន្ទុក ដោយចោទថា ជាភ្នាក់ងារសេ.អ៊ី.អា. និងជាអ្នកប្រឆាំងបដិវត្តន៍។ អ្នកឯទៀតៗ បានបែកខ្ញែកគ្នាទៅរស់នៅក្នុងតំបន់តាំងគោកបារាយ និងកំពង់ថ្ម។ ជួនកាលពួកគេជួបសមាជិកគ្រួសារដែលជម្លៀសមកពីភ្នំពេញ។

**ព្រះវិហារក្នុងសម័យខ្មែរក្រហម**

អង្គការខ្មែរក្រហម ចាត់ទុកប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ និងពីក្រុងនានាថាជា"*ប្រជាជនថ្មី*" ជា "*ប្រជាជនជម្លៀស*" ជា"*ប្រជាជនរំដោះ*" ឬជា "*ឈ្លើយសង្គ្រាម*" ដូចពួកគេតែងហៅតាមវិទ្យុបដិវត្តន៍។ អង្គការបង្ខំប្រជាជនទាំងនោះ ឲ្យធ្វើការរួមក្រោមការដឹកនាំរបស់ប្រជាជនមូលដ្ឋាន ឬ "*ប្រជាជនចាស់*" គឺប្រជាជនដែលរស់នៅក្នុងរបបខ្មែរក្រហមមុនឆ្នាំ ១៩៧៥ ។ "*ប្រជាជនមូលដ្ឋាន*" ត្រូវតាមដាននិងឃ្លាំមើល "*ប្រជាជនថ្មី*" គ្រប់ពេលវេលា។

អង្គការតាមដានប្រវត្តិរូបពិតរបស់ប្រជាជនថ្មីទាំងអស់យ៉ាងស្អិតបំផុត។ គ្មានអ្វីអាចគេចផុតពីភ្នែកអង្គការដែលមាន "*ភ្នែកដូចម្នាស់*" នោះបានទេ។ ឧទាហរណ៍ ថ្ងៃមួយលោកសាឡឹមឈឺពោះ ពុំបានទៅធ្វើការ លោកនៅសម្រាកក្នុងផ្ទះ។ លោកឆ្លៀតឱកាសនោះមកអានគម្ពីរ។ កម្មាភិបាលភូមិ មកឆែកឆេរផ្ទះភ្លាម ប៉ុន្តែ រកគម្ពីរមិនឃើញ ព្រោះលោកយកទៅលាក់ក្នុងកញ្ច្រែងដេរមួយ។

ម្យ៉ាងទៀត ខ្មែរក្រហមឆ្ងល់ និងមន្ទិលសង្ស័យចំពោះរបៀបរស់នៅរបស់ដូនជីជាខ្លាំង ពួកគេថា "*ហេតុអ្វីក៏ស្ត្រីចំណាស់ៗទាំងនេះគ្មានប្តីដូច្នេះ? ប្រហែលជាប្រពន្ធរបស់នាយទាហានហើយមើលទៅ*"។ ប្រជាជនក្នុងភូមិទទួលភារកិច្ចតាមដាន និងឃ្លាំមើលដូនជីតទាំងនោះ។ ក្នុងពេលយប់មួយ ពេលប្រជុំរៀនសូត្រ កម្មាភិបាលខ្មែរក្រហមនិយាយបញ្ឆិតបញ្ឆៀងឲ្យដូនជីទាំងនោះថា "*មានខ្មាំងសត្រូវ លាក់ខ្លួននៅក្នុងចំណោមពួកយើង*"។ ប្រជាជនក្នុងភូមទូន្មានដូនជីឲ្យនិយាយថា ប្តីរបស់គាត់ស្លាប់ទៅហើយ។

នាងសុភាពបរិយាយពីការរស់នៅរបស់គ្រីស្តបរិស័ទ និងប្រជាជនជម្លៀសថា៖

> *«អង្គការបានឲ្យជនភៀសសឹកទាំងអស់ ជីកប្រឡាយ លើកទំនប់នៅវាលសរសៃ។ នៅទីនោះ អ្នកក្រុង និងអ្នកមូលដ្ឋាន ធ្វើការច្របូកច្របល់លាយឡំចូលគ្នា ដោយឲ្យអ្នកមូលដ្ឋានតាមដាន ស៊ើបការណ៍ពីអ្នកក្រុង។ យើងមិនសូវហ៊ាននិយាយរកគ្នាទេខ្លាចពួកអ្នកមូលដ្ឋានចោទយើងថា ធ្វើទំនាក់ទំនងខ្សែរយៈអ្នកក្រុង"។*

ថ្វីបើអង្គការមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយ ក៏គ្រីស្តបរិស័ទនៅតំបន់នោះចេះតែទាក់ទងគ្នាទៅវិញទៅមក កាន់តែជិតស្និទ្ធឡើងៗ។

> *«ទោះបីជាយើងមានទុក្ខព្រួយ តែយើងក៏ពេញចិត្តទៅលើកទំនប់ដែរ ព្រោះបានចេញពីភូមិដើរតាមថ្នល់ជាតិទៅវាលសរសៃ ភ្នែកយើងរំពៃក្រែងបានឃើញមិត្តភ័ក្តិ និងបានស៊ើបសួរដំណឹងរកគ្នា។ នៅការដ្ឋាន ពេលបានជួបអ្នកស្គាល់យើងធ្វើពើហាក់បីដូចជាមិនដែលបានស្គាល់គ្នា ពេលសម្រាក ១០ នាទី យើងធ្វើពុតជាទៅបត់ជើង ដាច់ឆ្ងាយពីគេឯងបន្តិច យើងនិយាយរកគ្នាពីរបីម៉ាត់តែប៉ុណ្ណោះ គឺយើងរីករាយណាស់ហើយ»។*

ថ្ងៃមួយ ពេលធ្វើដំណើរទៅធ្វើការ ពួកដូនជីជួបលោកប៉ែរណាដោយចៃដន្យ។ ពួកគាត់និយាយថា៖ "*យើងរីករាយជាខ្លាំងយើងបាននិយាយគ្នាតែ ១០ នាទី ប៉ុណ្ណោះ ហើយយើងបានបែកគ្នាទៅកាន់ភូមិដ្ឋានរៀងខ្លួនវិញ*"។

> *«ថ្ងៃមួយពេលយើងឡើងទៅធ្វើស្មៅពោត យើងបានជួបលោកម្នាក់ ដែលរស់នៅជាមួយលោកប៉ែរណា។ យើងត្រេកអរណាស់ ព្រោះបានដឹងថា លោកប៉ែរណារស់នៅភូមិអណ្តូងដា ហើយយើងបានសួរដំណឹងពីផ្លូវទៅភូមិអណ្តូងដានោះ។ ពេលសម្រាកថ្ងៃត្រង់ យើងបានធ្វើសញ្ញាដាក់គ្នា លោកចំរើន កាន់ប៊ីដុងទឹកថាទៅដងទឹក ពេលនោះ អ្នកមូលដ្ឋានបានផ្ញើប៊ីដុងទឹកឲ្យជួយដងឲ្យផង។ ក្មួយស្រីខ្ញុំពីនាក់ដើរទៅប្រមូលយកបំពង់ទាំងអស់នោះ ហើយចេញទៅជាមួយលោកចំរើន។ បន្តិចក្រោយមក ក្មួយស្រីទាំងពីរវិលមកវិញ យកបំពង់ទឹកប្រគល់ឲ្យអ្នកមូលដ្ឋាន ហើយប្រាប់ថា "ពូចំរើននៅងូតទឹក"។ យើងអង្វរក្នុងចិត្ត សូមព្រះវិញ្ញាណតម្រង់ផ្លូវលោកចំរើនឲ្យទៅរកលោកប៉ែរណាឃើញ និងរក្សាការពារ កុំឲ្យជួបកងឈ្លបឬអង្គការតាមផ្លូវ។ ដល់ពេលចាប់ផ្តើមធ្វើការ យើងភ័យព្រួយក្នុងចិត្តខ្លាចប្រធានកង*

សួរលោក ចំរើន ព្រោះមុខព្រួញដែលលោកចំរើន ធ្វើនៅចំហ យើងធ្វើយោងគ្នា ជួសមុខចំហនេះ។ យូរបន្តិចក្រោយមក លោក ចំរើន មកដល់ទាំងហត់គយូស សើចដាក់យើងព្រមទាំងងក់ក្បាលផង។ យើងអរព្រះគុណព្រះអង្គ។

លោក ប៉ែរណា លោករំជួរ លោកនិមិត្ត និង យុវជនបួននាក់ទៀត រស់នៅជាមួយគ្នា។ លោក ប៉ែរណា បានឲ្យដឹងថា នៅភូមិសំរៀងជិតភូមិអណ្តូងដាមាន គ្រួសារគ្រីស្តបរិស័ទ ដែលមានដើមកំណើតនៅកំពង់គជាច្រើនគ្រួសាររស់នៅ ហើយមានបងប្រុសជាតិវៀតណាមម្នាក់ផង គឺលោកដាមី យ៉ោង។

តាំងពីថ្ងៃនោះមក ពេលទៅរកជីកក្តួច កាប់ចេក រកដំឡូង គឺតែងចូលផ្ទះលោកប៉ែរណា និងចូលភូមិសំរៀងរួមដំណើរជាមួយគ្រួសារថុង គ្រួសារបងគិត គ្រួសារមីងសួន។ល។ ចូលព្រៃរកចេក។

រំលងប្រហែលមួយខែក្រោយមក លោកប៉ែរណា ត្រូវប្តូរទីលំនៅ ទៅនៅភូមិថ្មីមួយទៀត គឺភូមិអណ្តូងដាដែរ។

ពួកលោកតែងលួចទៅថ្វាយអភិបូជានៅផ្ទះលោកប៉ែរណា។ ពេលថ្វាយអភិបូជា ពួកខ្ញុំនារីៗ ប្រើល្បិចកល ធ្វើជាដើរបេះស្លឹកបន្លែផ្អែម (ស្លឹកឈើម្យ៉ាងអាចហូបបាន) និងរកអុសនៅក្បែរៗព្រៃ ជិតផ្ទះលោក ឃ្លាំចាំមើលក្រែងមានកងឈ្លប ឬអ្នកចម្លែក។ មធ្យោបាយទៅផ្ទះលោក ប៉ែរណា គឺយើងស្នើសំបុត្រប្រធានភូមិ ទៅរកដំឡូង ឬបេះល្ពុងនៅចម្ការ ដូច្នេះ យើងលីកាំបិតផ្គាក់ និងកូនថង់។ ពេលត្រឡប់ចូលភូមិវិញ ពួកនារីៗមានបន្លែផ្លែល្ពុងជូនកាលលោក ប៉ែរណា ឲ្យដំឡូងមីខ្លះ ដែលលោកបានគាស់នៅក្នុងព្រៃឲ្យមកយើង ដើម្បីកុំឲ្យអ្នកភូមិតាំងគោកឆ្ងល់ថា យើងទៅចម្ការមួយថ្ងៃ តែរកគ្មានបានអ្វីទាំងអស់ ចំណែកពួកលោកវិញ គឺលោកលួចកាប់កូនឈើដាក់ទុកនៅផ្ទះលោកប៉ែរណា ដូច្នេះ លោកលីកូនឈើមកផ្ទះ សម្រាប់ធ្វើជាបង្គោលរបង និងសម្រាប់ជួសជុលផ្ទះ។ ចំពោះលោកប៉ែរណាវិញ ក៏ដូចគ្នាដែរ ពេលលោកមកផ្ទះយើងថ្វាយអភិបូជា លោកសុំសំបុត្រប្រធានភូមិថា មករកត្រីនៅភូមិត្រដក់ពងខាងក្រោយភូមិតាំងគោក ដូច្នេះលោកស្ពាយលប ទ្រូ អង្រុត ឈ្នាង មកថ្វាយអភិបូជាយើងប្រើកលល្បិច ក្មួយស្រីខ្ញុំម្នាក់រែកទឹកពីអណ្តូងផ្ទះប្រធានភូមិមកផ្ទះ ដោយរំពៃមើលកងឈ្លប ក្មួយស្រីខ្ញុំម្នាក់ទៀតនិងខ្ញុំឈូសចេក

ឫក្កុចនៅមុខផ្ទះ ឪពុកខ្ញុំបិទឫស្សី នៅមាត់ទ្វារក្រោយ ម្ដាយខ្ញុំនៅចង្ក្រានរុញភ្លើងដាំទឹក។ យើងធ្វើការរៀងៗខ្លួន ទាំងសូត្រធម៌ភាវនារួមចិត្តគំនិតជាមួយលោក ថ្វាយអភិបូជា និងថ្វាយការអត់ឃ្លានទៅព្រះបិតា។

ការអត់ឃ្លានដែលយើងជួបប្រទះគឺជាមធ្យោបាយដ៏ពិសេសមួយរបស់អង្គការដើម្បីសម្លាប់"ប្រជាជនថ្មី"។ គ្រួសារនីមួយៗត្រូវដោះស្រាយតាមគ្រប់មធ្យោបាយ និងគ្រប់លទ្ធភាពទាំងអស់ដែលមាន ដើម្បីរស់។ យើងបានយកសម្លៀកបំពាក់ដែលមានជាប់មកនឹងខ្លួនខ្លះៗនោះ ទៅដោះដូរយកកាំបិទ ពូថៅ ចបកាប់ ចបជីក។ល។ សម្ភារៈទាំងអស់នេះ បានមកពីខោអាវរបស់អស់លោកទាំងបី។ ចំណែកសម្លៀកបំពាក់របស់នារីៗ អ្នកមូលដ្ឋានគេមិនព្រមយកទេ ព្រោះជាសម្លៀកបំពាក់នៅទីក្រុង (អាវវាលក អាវដៃខ្លី...)។ ពេលនោះ ពួកលោកអស់ខោអាវលើង លោកសាឡាស់នៅសល់អាវខ្លីដៃវែងមួយ ម្ដាយខ្ញុំរុះអាវវែងនោះ ហើយដេរជាខោខ្លីចែកពួកលោកស្លៀកវិញ។ ពួកលោកនៅសល់តែខោមួយ អាវមួយ សម្រាប់ស្លៀកពាក់ពេលថ្វាយអភិបូជា និងពេលមានជំងឺប៉ុណ្ណោះ។ ពេលអត់ឃ្លានខ្លាំងដូច្នេះ គ្រួសារគ្រីស្តបរិស័ទភូមិសំរោងជួយឧបត្ថម្ភយើងច្រើនណាស់ ជួនកាលខ្ញុំកាប់ចេកយ៉ាងច្រើនព្រោះ ក្នុងផ្ទះមានសមាជិកច្រើន ហើយការរកចេកមិនជាការងាយស្រួលប៉ុន្មានទេ ចម្ការចេកនៅឆ្ងាយពីភូមិណាស់ មិនមែននៅជិតដូចអ្នកសំរោងទេ គឺត្រូវធ្វើដំណើរតាំងពីម៉ោងបីភ្លឺ រហូតដល់ម៉ោង ៩ ព្រឹក ទើបដល់ចម្ការចេក ដូច្នេះខ្ញុំលោភចង់បានច្រើន តែកម្លាំងខ្លួនឯងទូលមិនរួចទេ ពេលនោះ ជួនបងគិត ជួនគ្រូចុង ជួនបងរឿន ជួនចន្ថា និង ចន្ថន នាំគ្នាជួយរំលែកសម្រាលខ្ញុំរហូតដល់ផ្លូវមកផ្ទះហួសភូមិសំរោង ទើបគេប្រគល់ឲ្យខ្ញុំទូលម្នាក់ឯង។

អង្គការបានឲ្យប្រជាជនជម្លៀស ផ្លាស់ប្ដូរផ្ទះជាញឹកញយ។ ពេលយើងសង់ផ្ទះរួច និងដាំដំណាំជិតបានផ្លែផ្កា គេឲ្យយើងប្ដូតកន្លែងរស់នៅភ្លាម។ ដូច្នេះ យើងត្រូវបោះបង់ចោលអ្វីៗទាំងអស់ ហើយយើងជួយប្រទះនូវការខ្វះខាត និងការអត់ឃ្លានជាខ្លាំង។ ដោយស្បៀងអាហារយើងនៅសល់តិចតួច យើងយកសម្លៀកបំពាក់ និងមាសទៅដូរយកស្រូវ អង្ករពីអ្នកមូលដ្ឋាន។ តែការដោះដូរនេះពុំបានគ្រប់គ្រាន់ទេ យើងត្រូវរកអ្វីផ្សេងៗទៀតមកលាយជាមួយអង្ករ។ ថ្ងៃមួយ លោកសាឡឹមទៅរកកាប់ចេកក្នុងព្រៃជាមួយក្មួយស្រីខ្ញុំ តែដោយមិនសូវស្គាល់ផ្លូវច្បាស់ក៏វង្វេងពេញព្រៃក្មួយស្រីខ្ញុំយំ ធ្វើឲ្យលោកសាឡឹមកាន់តែភ័យខ្លាំង ហើយទម្រាំតែ

*រកផ្លូវឃើញ គឺវង្វេងពេញមួយថ្ងៃ និងគ្មានបានអ្វីទាំងអស់។ លោកចំរើនទៅរកជីកក្តួចជាមួយខ្ញុំ យើងទូលក្តួចដើរកាត់ភ្លៀងធំមកផ្ទះ ឆ្លងកាត់ទឹកប្រឡាយមានជម្រៅត្រឹមទ្រូង និងត្រឹមក បណ្តែតថង់ក្តួចតាមខ្លួនកន្លែងខ្លះទឹក ជ្រៅលិចក្បាលខ្ញុំត្រូវតោងលោកចំរើន ព្រោះខ្ញុំអត់ចេះហែលទឹក ឆ្លងផុតប្រឡាយ យើងលើកថង់ក្តួចឡើងទូល ទឹកហូរពីថង់ក្តួចចូលពេញភ្នែកមុខមាត់។ មកដល់ផ្ទះវិញ លោកចំរើន និងខ្ញុំត្រូវពុលក្តួចវិះស្លាប់។ លោកសាឡាស់ទៅជីកដំឡូងព្រៃ ជាមួយក្មួយស្រីម្នាក់។ រណ្តៅដែលជីករកដំឡូងនោះមានជម្រៅប្រហែលពីរម៉ែត្រ។ ចាប់ពីថ្ងៃនោះមក លោកសាឡាស់ ចាប់ផ្តើមឈឺបន្តិចម្តងៗព្រោះលោកខំប្រឹងជីកពេក ម្យ៉ាងទៀតដោយលោកមានជំងឺបេះដូងរីកផង ការខំប្រឹងហួសកម្លាំងនេះ ធ្វើឲ្យលោកឈឺកាន់តែខ្លាំង។ ថ្ងៃមួយនោះដោយអំបិលនៅសល់តិច ដូច្នេះយើងមានការខ្វះខាតអំបិលដើម្បីបន្សាបមើមក្តួច ហើយដល់ពេលយកអង្ករក្តួចមកដាំបាយ (អង្ករក្តួចដែលធ្វើឡើងដោយស្ងោរអំបិល) យើងត្រូវពុលអស់មួយផ្ទះ។ ក្មួយស្រីខ្ញុំ ដែលហូបតិចជាងគេ កម្រិតពុលក៏តិចជាងគេដែរ បានរត់ទៅសុំប្រធានពាណិជ្ជ បានស្ករត្នោតមួយកូនចានមកដាំទឹកផឹកទាំងអស់គ្នាដើម្បីបន្សាបជាតិពុល។ ដោយការអត់ឃ្លាន លោក ប៉ែរណា មានសុខភាពកាន់តែខ្សោយទៅៗ និងធ្វើការឲ្យអង្គការមិនបានទៀងទាត់។ លោករកស្បៀងមិនសូវបានច្រើន ដូច្នេះកូនសិស្សលោកមានការអាក់អន់ចិត្ត ហើយគេក៏សុំបែកផ្ទះចេញពីលោកទៅនៅផ្ទះផ្សេង។ ពួកគេគិតថា គេនៅក្មេងមានកម្លាំងធ្វើការងារឲ្យអង្គការ ដូច្នេះគេត្រូវហូបស្រួល" ។*

ក្នុងខែមិថុនា ឆ្នាំ ១៩៧៥ ខ្មែរក្រហមអនុញ្ញាតឲ្យអាណិកជនវៀតណាមត្រឡប់ទៅមាតុប្រទេសរបស់ខ្លួនវិញ។ គ្រីស្តបរិស័ទដែលខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញមកជាកូនកាត់ខ្មែរ វៀតណាម និងចេះនិយាយភាសាវៀតណាមស្ទាត់ ឆ្លៀតឱកាសនេះរំដោះខ្លួនពីក្រញាំពួកខ្មែរក្រហម។ ក្នុងចំណោម "*ជនជាតិវៀតណាម* " ធ្វើមាតុភូមិនិវត្តទាំងនេះមានដូនជី ៨ នាក់ នៃក្រុមគ្រួសារព្រះឧបការគុណ ក្នុងនោះមាន ៤ នាក់ ជាខ្មែរសុទ្ធសាធដែរ។

*«លោកប៉ែរណាឆ្លៀតឱកាស ដែលអង្គការបញ្ជូនជនជាតិវៀតណាមឲ្យត្រឡប់ទៅស្រុកវៀតណាមវិញ និងដោយនៅស្រុកតាំងគោកនេះខ្វះខាតស្បៀងអាហារខ្លាំងផងនោះ លោកមានបំណងធ្វើដំណើរទៅខេត្តបាត់ដំបង ដើម្បីទៅរកឪពុកម្តាយលោក*

និងម្យ៉ាងទៀត លោកយល់ថា បាត់ដំបងជាជង្រុកស្រូវ ដូច្នេះទីនោះប្រាកដជាមិនខ្វះស្បៀងអាហារឡើយ។ ប្រហែលម៉ោងប្រាំមួយព្រឹក យើងឃើញលោក ប៉ែរណោ លោករំដួរ និងលោកនិមិត្តមកដល់ផ្ទះយើង ដោយមានស្ពាយទ្រូ អង្រុត ឈ្នាង...។ លោកសាឡាស់ លោកសាឡឹម និងលោកចំរើន ហាក់បានដឹងដំណឹង នេះរួចទៅហើយ ព្រោះពីម្សិលមិញលោកបានសុំឲ្យនារីៗធ្វើការនៅផ្ទះ កុំចេញរកស្បៀងទៀត។

ពួកខ្ញុំបានបំពេញការងារតាមកលល្បិច ដូចធ្លាប់ធ្វើកន្លងមក ក្នុងពេលដែលលោកប៉ែរណោ មកលេង។ ពួកលោកពិភាក្សាគ្នាមួយសន្ទុះដោយទឹកមុខស្ងួតស្ងប់។ បន្ទាប់មក ពួកលោកប្រាប់ពួកខ្ញុំឲ្យត្រៀមលក្ខណៈធ្វើការងារក្នុងកលល្បិចនេះ ទាំងរួមចិត្តគំនិតជាមួយលោក។ ពេលដែលលោកលើកនំដែលជាព្រះកាយ និងពែងដែលជាព្រះលោហិតរបស់ព្រះយេស៊ូ ហើយបន្លឺរមគ្នា "នេះជាព្រះកាយ... នេះជាព្រះលោហិត...ដែលត្រូវបូជា ដើម្បីលើកលែងទោសរំដោះបាបឲ្យអ្នករាល់គ្នានិងឲ្យមនុស្សទាំងឡាយ..." ។ សំឡេងលោកទាំងបួនបន្លឺសូរស័ព្ទតែមួយ ធ្វើឲ្យយើងរន្ធត់ និងរំភើបជាពន់ពេក។ យើងឱក្បាលគោរពព្រះកាយ និងព្រះលោហិតទាំងទឹកភ្នែកហូររហាម។

ពែងដែលធ្វើពីត្រឡោកដូង គឺលោកសាឡឹមយកជាប់ទៅតាមខ្លួនលោក ចំណែក ពែងដាក់ព្រះកាយដែលបងស្រីរំដួរឲ្យ គឺយើងបានថែរក្សារហូតមកដល់សព្វថ្ងៃ។ ពែងនេះរក្សាទុកក្នុងផ្ទះ និងប្រើប្រាស់ក្នុងពេលធ្វើអភិបូជា។

ក្រោយធ្វើអភិបូជារួចយើងហូបបាយជុំគ្នាទាំងទឹកមុខស្ងួតក្រៀមក្រំ លោកប៉ែរណោនិយាយថា៖ "ពួកខ្ញុំទៅបាត់ដំបង ដំណើរនេះមិនដឹងយ៉ាងណាទេតែយើងត្រូវបែកផ្លូវគ្នាស្វែងរកកូនចៀម យើងមិនអាចនៅផ្តុំគ្នាមួយកន្លែងដូច្នេះទេ លោកទេពអ៊ីមនិងគ្រីស្តបរិស័ទឯទៀតៗ មិនដឹងទៅជាយ៉ាងណាដែរ?" ។ ខ្ញុំបានវេចបាយលាយចេកជាមួយប្រហុកចិញ្ច្រាំគល់ស្លឹកគ្រៃ និងទឹកមួយបំពង់ទឹកត្នោតជូនលោក សម្រាប់ពិសារតាមផ្លូវ និងកាំបិតផ្គាក់មួយផង។ ប្រហែលម៉ោងប្រាំបីព្រឹក លោកចេញដំណើរ។ លោកប៉ែរណោ លោករំដួរ និងលោកនិមិត្តយំយ៉ាងខ្លាំង យើងយំទាំងអស់គ្នា។ ពេលនោះខ្ញុំស្រមៃថា គឺជាការជប់លៀងចុងក្រោយរបស់យើង»។

**ខ្ញុំសូមបូជាជីវិតខ្ញុំសម្រាប់ប្រទេសខ្មែរ**

ខ្មែរក្រហមដណ្ដើមយកក្រុងបាត់ដំបងបាន នៅថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥។ នៅថ្ងៃទី ១៨ ពួកគេប្រកាសបញ្ជាតាមឧឃោសនស័ព្ទ ឲ្យប្រជាជនចាកចេញពីទីក្រុងទៅធ្វើការនៅតាមជនបទនានា ប៉ុន្តែទាល់តែថ្ងៃ ២៤ មេសា ទើបអ្នកក្រុងត្រូវអង្គការដេញចេញ។ មុននេះ ខ្មែរក្រហមយកនាយទាហាននិងអ្នករដ្ឋការជាន់ខ្ពស់ស្ទើរតែទាំងអស់ទៅសម្លាប់ចោល នៅភ្នំធិបតី និងនៅស្រែជប៉ុន ក្បែរស៊ីសុផុន។ ចំណែកនាយទាហានតូចតាចនិងកូនទាហានរាប់រយនាក់ទៀត ត្រូវគេសម្លាប់នៅតាមថ្នល់ជាតិម៉ុំថ្មគោល។

នៅថ្ងៃអាទិត្យទី ១៣ មេសា លោកអភិបាលទេពអ៊ីម បានថ្វាយអភិបូជា ជាលើកចុងក្រោយ នៅវិហារបាត់ដំបង ទាំងធ្វើព្រះពរលើកលែងទោសផ្ដាច់បាបជាទូទៅ។ លោកជូនពរគ្រីស្តបរិស័ទទាំងអស់ ដូចសាក្សីម្នាក់រ៉ាយរ៉ាប់ថា៖ "*ថ្ងៃនេះជាថ្ងៃចុងក្រោយបង្អស់ដែលខ្ញុំប្រសិទ្ធិពរអ្នករាល់គ្នា...ខ្ញុំអ្នកលើកលែងទោសរំដោះបាបអស់អ្នកដែលនៅក្នុងវិហារនិងទាំងអ្នកដែលពុំបានមកផង*" ។

លោកអភិបាលហៅលោក យ៉ូហាន បាជ្រេ ជាបព្វជិតក្រុមវត្តសន្តសាគរារាមឲ្យមកបាត់ដំបង។ ជនបរទេសប៉ុន្មាននាក់ដែលនៅក្រុងបាត់ដំបង ត្រូវនៅចាំរថយន្តមកពីភ្នំពេញដឹកយកទៅព្រំប្រទល់ដែនថៃ។ លោកអភិបាលប្រហែលជាបានឃើញអំពើឃោរឃៅ និងឧក្រិដ្ឋកម្ម ដែលខ្មែរក្រហមបានប្រព្រឹត្តក៏ពុំដឹង ទើបនៅថ្ងៃទី ២៥ មេសា លោកអភិបាលទេពអ៊ីម ល្បងរត់ទៅប្រទេសថៃជាមួយលោកយ៉ូហានបាជ្រេ និងនារីពីរនាក់ទៀត ដែលជាអ្នកបង្ហាត់បង្រៀនគ្រីស្តសាសនា។ លោកជិះរថយន្តឡង់រ៉ូវែររបស់លោកយ៉ូហាន។ តាមសាក្សីម្នាក់ឲ្យដឹងថា គេបានឃើញរថយន្តនេះ និងអ្នកទាំងបួននាក់នៅវត្តស្តៅចម្ងាយជាង ១០ គ.ម ខាងត្បូងថ្មគោល។ នៅទីនោះ ខ្មែរក្រហមហាមឃាត់ប្រជាជនមិនឲ្យទៅមុខទៀ។

រថយន្តនេះបានបើកតាមថ្នល់រទេះទៅដល់ភូមិចំណោម។ លោកយ៉ូហានគ្មានខ្លាចខ្មែរក្រហមទេ ព្រោះគាត់ស្គាល់មនុស្សជាច្រើន។ ក្នុងពេលសង្គ្រាម គាត់បានព្យាបាលអ្នកជំងឺ និងអ្នករបួសជាច្រើន ទាំងខាងខ្មែរក្រហម ទាំងខាងរដ្ឋាភិបាលលន់ នល់។ ម្យ៉ាងទៀត គាត់បានសម្រេចចិត្តនៅជាមួយគ្រីស្តបរិស័ទ រហូតដល់ទីបញ្ចប់។

ពេលល្ងាចដែលលោកអញ្ជើញមកដល់ ឬ ពីរបីថ្ងៃក្រោយ មានជនជាតិអូស្ត្រាលីម្នាក់ ឈ្មោះ អាណាល់ ដូម៉ារីនី (Arnaldo Marini) ដែលបានរៀបការជាមួយស្ត្រីខ្មែរម្នាក់ ឈ្មោះ នាងម៉ៅ មានលំនៅឯមង្គលបុរី មកសុំជ្រកកោនជាមួយលោក។ តាមប្រភពព័ត៌មានជាច្រើន បានឲ្យដឹងថាបុរសជាតិអូស្ត្រាលីនេះធ្វើការឲ្យសេ.អ៊ី.អា។

ស្អែកឡើង ខ្មែរក្រហមពីរនាក់ជិះម៉ូតូហុងដា មករកបូជាចារ្យយើងទាំងពីរ។ ខ្មែរក្រហមម្នាក់ឡើងទៅលើផ្ទះ ហើយវាយលោកយ៉ូហានដោយជេរថា "*អាគម្រាក់ សេ.អ៊ី.អា* " ប្រហែលជាមកពីវាឃើញជនជាតិអូស្ត្រាលីនៅទីនោះក៏ពុំដឹង។ លោកបូជាចារ្យបែកឈាមពេញមុខ រួចខ្មែរក្រហមទាំងពីរនាំខ្លួនលោកយ៉ូហាន និងជនជាតិអូស្ត្រាលីនោះទៅជាមួយ។ លោកអភិបាលទេពអ៊ីម និងប្រពន្ធជនជាតិអូស្ត្រាលីនោះ ដើរតាមពីក្រោយ។ ថ្ងៃទី ៣០ មេសា សាក្សីម្នាក់ទៀតបានឃើញបុរសទាំងបី និងស្ត្រីនេះនៅសាលាស្រុក ឬនៅសាលាឃុំបត់ត្រង់។ ក្រោយមក ខ្មែរក្រហមម្នាក់ឈ្មោះសយ បានបើករថយន្តហ្ស៊ីបមកដឹកអ្នកទាំងបួនដើម្បី "*នាំទៅព្រំដែន* " ។ ទៅដល់ស្ពានឃ្មួនជិតបត់ត្រង់ សយបញ្ឈប់ឡាន ហើយឲ្យអ្នកទាំងបួនចុះទៅខាងឆ្វេងថ្នល់។ ពេលអ្នកទាំងបួនចុះទៅមាត់ស្ទឹង វាបាញ់រះពីក្រោយសម្លាប់នឹងកាំភ្លើងអាកា ៤៧។ សាកសពទាំងបួន ត្រូវគេដោះសំលៀកបំពាក់ចេញនិងទុកចោលអស់រយៈពេលជាច្រើនថ្ងៃ ដូចសាកសពឯទៀតៗ ដែលនៅឯស្រែក្នុងតំបន់នោះ។

គ្រីស្តបរិស័ទក្រុងបាត់ដំបងក៏ដូចជាប្រជាជនទាំងអស់ដែរ  ពួកគេត្រូវអង្គការដេញចេញពីក្រុង នៅថ្ងៃទី ២៤ មេសា។ ពួកគេមួយចំនួនត្រូវជម្លៀសទៅអូរមុនី។ ដូនជីពីរនាក់ គឺដូនជី សន្តីម៉ារី និងហ្សាកឹលីនដែលរស់នៅក្បែរគេហដ្ឋានលោកអភិបាលចាកចេញពីទីក្រុងជាមួយកុមារកំព្រាប្រហែល ១០ នាក់។

បន្ទាប់ពីបានធ្វើដំណើរក្រោមកំដៅថ្ងៃ និងភ្លៀងអស់រយៈពេលបួនថ្ងៃមក ពួកគេទៅដល់ភូមិអន្លង់វុននៅប្រហែល ២៥គ.ម. ពីក្រុងបាត់ដំបង។ ពួកគេរស់នៅទីនេះចំនួន ៥ ខែកន្លះ។ នៅទីនោះ ដូនជីទាំងពីរនាក់ និងកុមារកំព្រាទាំងនោះសង់ខ្ទមមួយនៅ និងចុះធ្វើស្រែដូចប្រជាជនឯទៀតៗដែរ។

នៅថ្ងៃទី ១៥ កញ្ញា ដូនជីទាំងពីរ និងពួកកុមារកំព្រាទទួលការអនុញ្ញាតពីអង្គការឲ្យត្រឡប់ទៅប្រទេសវៀតណាមវិញ។ ពួកគេដើរចម្ងាយ ៩ គ.ម. រហូតដល់អូតាគី

ទើបឡើងជិះរថយន្តទៅមង្គលបុរី។ នៅទីនោះ ពួកគេធ្វើដំណើរតាមកប៉ាល់កាត់ទន្លេសាប ទៅប្រទេសវៀតណាម។ គេទៅដល់ព្រំដែនវៀតណាម នៅថ្ងៃទី ២ តុលា ឆ្នាំ ១៩៧៥។ ប៉ុន្តែ ដូនជី ហ្សាកឺលីន ដែលមានកំណើតជាខ្មែរ និងកុមារកំព្រា ដែលសុទ្ធតែជាខ្មែរសុទ្ធសាធ ត្រូវអាជ្ញាធរវៀតណាមបញ្ជូនមកវិញ ព្រោះគេមិនទទួលជនជាតិខ្មែរទេ គេទទួលតែជនជាតិវៀតណាមប៉ុណ្ណោះ។ តាំងពីនោះមក គ្មាននរណាដឹងអំពីជោគវាសនារបស់អ្នកទាំងនេះទេ ប្រហែលខ្មែរក្រហមសម្លាប់ក៏មិនដឹង ព្រោះនៅសម័យនោះខ្មែរក្រហមសម្លាប់ប្រជាជនខ្មែរជាច្រើន ដែលពួកវៀតណាមបញ្ជូនមកវិញ។

រីឯ ដូនជីវៀតណាមបីនាក់ទៀតគឺ ដូនជី ហ្គុសស្តាវ (Gustave) ដូនជី កង់ឌីដ (Gandide) និងដូនជី សេសារីន (Césarine) ដែលធ្លាប់រស់នៅក្នុងមណ្ឌលកុមារសង្គ្រោះក្បែរវិហារ ចេញទៅជាមួយគ្រីស្តបរិស័ទនៅភូមិសំរោង។ ដូនជីទាំងនេះ បន្តភារកិច្ចជាគិលានុបដ្ឋាយិកាតទៀតនៅភូមិដូនដែវ ភូមិវត្តរកា ភូមិក្បាអូយ ហើយបង្ហាត់បង្រៀនពួកខ្មែរក្រហមឲ្យចេះវិជ្ជាទាំងនេះដែរ។ ពីរឆ្នាំក្រោយមក ដូនជីទាំងនេះ ត្រូវអង្គការបញ្ជូនទៅភូមិជំនីកក្បែរភូមិអន្លង់វិល នៅខាងត្បូងក្រុងបាត់ដំបង ហើយខ្មែរក្រហមសម្លាប់ចោលជាមួយកុមារកំព្រាម្នាក់ឈ្មោះអាជួន។ ខ្មែរក្រហមធ្លាប់សម្លាប់អ្នកបច្ចេកទេស នៅពេលណាដែលអ្នកទាំងនោះបង្ហាត់បង្រៀនពួកវាឲ្យចេះរួចហើយ។ ក្នុងឆ្នាំ ១៩៧០ ដូនជី ហ្គុសស្តាវ បានសរសេរសំបុត្រ ជម្រាបដូនជី ដែលត្រួតក្រុមគ្រួសារគាត់ថា៖ "*ខ្ញុំបានជម្រាបគ្រួសារខ្ញុំរួចសព្វគ្រប់ហើយ ខ្ញុំសុខចិត្តរស់នៅប្រទេសកម្ពុជា ហើយតស៊ូប្តូរជីវិតសម្រាប់ប្រទេសនេះ*" ។

**រូបឈើឆ្កាងនៅក្រោមសំបុកមាន់**

អង្គការពុំបានជម្លៀសគ្រីស្តបរិស័ទ នៅភូមិចំណោមចេញពីភូមិទេ។ ពួកគេរស់នៅក្នុងភូមិរបស់ខ្លួនដដែល។

> *«ខ្មែរក្រហមចូលមកក្នុងភូមិរបស់យើង។ ពួកវាកាត់ផ្តាច់ឈើឆ្កាង ដែលបុព្វបុរសយើងម្នាក់បានឆ្លាក់ជាប់នៅលើដើមឈើមួយ។ ពួកវាចង់ឲ្យយើងអារកាត់ពុះធ្វើអុសដុត តែគ្មាននរណាម្នាក់សុខចិត្តទេ។ ដូច្នេះវាធ្វើដោយខ្លួនវា។ ខ្មែរក្រហមដែលអារកាត់ពុះឈើឆ្កាង ប៉ុន្មានថ្ងៃក្រោយមកក៏ឈឺស្លាប់។*

*ពួកវាកម្ទេចរូបបដិមារបស់ព្រះនាងម៉ារី ហើយនិងជញ្ជូនយកភាជន៍សម្រាប់ធ្វើបុណ្យអភិបូជាផង។*

*ជំនឿរបស់យើងមាន មិនមែនទាល់តែមានបដិមាឬទាល់តែមានការជួបជុំគ្នាទេ។ បើវាបំផ្លាញទាំងអស់ យើងយកដួងចិត្តធ្វើជាព្រះវិហារ។ ពេលខ្មែរក្រហមចូលបំផ្លិចបំផ្លាញវិហារក្នុងភូមិ យាយម៉ាង និងយាយយ៉ុនយករូបឈើឆ្កាងទៅលាក់ក្នុងសំបុកមេមាន់ក្រោប»។*

ខ្មែរក្រហមយកវិហារធ្វើជាជង្រុកស្រូវប្រចាំសហករណ៍ក្នុងតំបន់នេះ។ ផ្ទះបាយលោកបូជាចារ្យក៏ក្លាយទៅជាផ្ទះបាយរួមប្រចាំភូមិ ហើយផ្ទះសំណាក់របស់លោកបូជាចារ្យក៏ក្លាយទៅជាកន្លែងយាយៗថែរក្សាកុមារតូចៗនៅក្នុងភូមិ។

នៅដើមឆ្នាំ ១៩៧៧ ខ្មែរក្រហមជម្លៀសប្រជាជននៅភូមិចំណោម ដែលធ្លាប់មានដីធ្លី ឬផ្ទះធំៗ ឲ្យទៅនៅភូមិអូរជួបខ្លា និងភូមិដុងត្រាញ់ខ្លា។ ប្រជាជនទាំងនេះត្រូវធ្វើការជាទម្ងន់ និងបានទទួលម្ហូបអាហារតិចតួចដូចប្រជាជនឯទៀតៗដែរ។ អ្នកឯទៀតដែលនៅក្នុងភូមិបានរុះរើផ្ទះទាំងអស់យកឈើ ដឹកទៅឆ្ងាយ។ ពួកគេសង់ខ្ទមតូចៗខ្ពស់ពីដីប្រហែលកន្លះម៉ែត្រ។ អង្គការអនុញ្ញាតឲ្យតែយាយម៉ាងម្នាក់ប៉ុណ្ណោះរស់នៅក្នុងខ្ទមមួយក្បែរព្រះវិហារ ដ្បិតគាត់ចាស់ណាស់ទៅហើយ។

# ផែកទី

## ជំពូកទី១៧

# គ្រីស្តបរិស័ទរួមស្លាប់ជាមួយព្រះយេស៊ូ

បន្ទាប់ពីលោក ប៉ែរណា ចេញទៅ ប្រហែលខែកញ្ញា ឆ្នាំ ១៩៧៥ មានប្រជាជនថ្មីជាច្រើនស្លាប់បាត់ បង់ជីវិតដោយអត់អាហារ។ លោកអភិបាលសាឡាស់ កើតរោគហើមខ្លួន និងហើយស្ងួត ដូចប្រជាជនមួយចំនួនដែរ ទាំងឪពុកលោក និងលោកសាឡឹមក៏ឈឺដូច្នេះដែរ។

នាងសុភាពរៀបរាប់ប្រវត្តិលោកបូជាចារ្យទាំងបីនាក់ ក៏ដូចជារ៉ាយរ៉ាប់អំពីទុក្ខវេទនារបស់ប្រជាជនខ្មែរទាំងមូលដែរៈ

*«យើងដោះដូរស្ករ និងបន្ទំចេកឲ្យលោកសាឡាស់ពិសា បន្ថយការហើម។ ពេលនោះ ម្ដាយប្រធាននារីភូមិចាន់ដែលលោកធ្លាប់ស្នាក់នៅក្នុងផ្ទះរបស់គាត់កាលពីថ្ងៃដំបូងបង្អស់ បានយកថ្នាំពេទ្យខ្លះ និងត្រីប្រឡាក់មកជូនលោក ហើយបញ្ចុះបញ្ចូលលោកឲ្យរៀបការជាមួយកូនស្រីគាត់ ដែលជាប្រធាននារីនោះ។ លោកសាឡាស់ប្រកែក ហើយសុំរាប់យាយទុកជាម្ដាយចិញ្ចឹមវិញ។*

*លោកសាឡាស់ហើយខ្លាំង លោកបានសុំប្រធានភូមិអនុញ្ញាតឲ្យក្រុមគ្រួសារខ្ញុំយកអង្ករពីផ្ទះ ទៅដូរយកស្ករពីភូមិគ្រើល នេះជាច្បាប់នៅភូមិតាំងគោក។ ប្រធានភូមិព្រមអនុញ្ញាតឲ្យ តែពេលដែលលោកសាឡាស់ យកអង្ករទៅដូរ យប់ឡើងគេប្រជុំប្រកាសថាៈ"លោកសាឡាស់ជាខ្មាំងបញ្ចេញអង្ករ មិនគិតថា ភូមិកំពុងខ្វះខាតអង្ករឡើយ"។ យើងហួសចិត្តជាខ្លាំង តែធ្វើម្ដេចបើមាត់គេអនុញ្ញាត ហើយមាត់គេដែរ ដែលចោទយើងជាខ្មាំងនោះ! យើងបាត់ដំណឹងពីលោក ប៉ែរណា ឈឹង។ លោក សាឡឹម តែងតែទៅរកអុសនៅភូមិសំរោង ស៊ើបដំណឹងពីគ្រីស្តបរិស័ទ។ បន្ទាប់មក ម្ដាយខ្ញុំ ឪពុកខ្ញុំ និងលោកសាឡឹមចាប់ផ្ដើមហើមទៀត តែឪពុកខ្ញុំហើមតិចជាងគេ។ គាត់បានចេញទៅដាក់ទ្រូតាមស្រែជិតៗផ្ទះ បានកំពឹស និងកូនត្រី យកមកធ្វើម្ហូប។ ថៃ្ងនៀ្យ ឪពុកខ្ញុំ មុតដៃនឹងទ្រូ ក្លាយទៅជាដំបៅរីក*

យ៉ាងធំនិងមានដង្កូវ ជាហេតុធ្វើឲ្យគាត់ឈឺចាប់យ៉ាងខ្លាំង។

លោកចំរើន និងខ្ញុំ បានសុំច្បាប់អង្គការទៅដោះដូរត្រីឆ្អើរ នៅខេត្តកំពង់ធំ។ អង្គការបានអនុញ្ញាតច្បាប់ឲ្យចំនួន ៣ ថ្ងៃ។ យើងត្រេកអរណាស់ ព្រោះយើងបានស៊ើបដំណឹង លោក ប៉ែរណា អាចស្វែងរកក្រុមគ្រួសារបងចំរើន និងស្វែងរកគ្រីស្តបរិស័ទព្រមទាំងជូនជីដែលមិនដឹងទៅទីណាផង។

ក្នុងដំណើរនោះ យើងបានជួបប្រពន្ធលោករស់ អេន ហើយបានដឹងថា លោករស់ អេន[១] ត្រូវគេយកទៅសម្លាប់ហើយ ចំណែកប្រពន្ធ និងកូន អង្គការបានឲ្យស្នាក់នៅជាបណ្តោះអាសន្នលើផ្ទះមួយ រង់ចាំអង្គការយកទៅសម្លាប់ទៀត។ យើងបានសំណាក់នៅផ្ទះម្តាយ រស់ អេន មួយយប់ យើងបានដឹងថា ដូនជី លីឌី ត្រូវអង្គការសម្លាប់ ហើយលោក ប៉ែរណា ក៏ប្រហែលត្រូវស្លាប់ដែរ ព្រោះគាត់ឮអ្នកមូលដ្ឋាន ខ្សឹបគ្នាថា អង្គការចាប់បានខ្មាំងប្រុងរត់គេចខ្លួនបីនាក់ ហើយអង្គការបានកម្ទេចនៅលើផ្លូវត្រង់ភូមិជុំ។ ឯគ្រួសារបងទ្រៀង សំរួល ប្រកប និងគ្រួសារបងទ្រៀង សំរាយ រកមិនឃើញ។

ប៉ុន្មានថ្ងៃក្រោយមក ប្រធានភូមិបានចូលមកសួរឪពុកខ្ញុំថា៖ "តាឯងម្តេចបានជាទុកកូនចៅឲ្យនៅកម្លោះក្រមុំពេញតែផ្ទះអញ្ចឹង? ហេតុអ្វីមិនឲ្យមានគ្រួសារ?" ។ ឪពុកខ្ញុំឆ្លើយថា៖ "ខ្ញុំបានបង្កើត និងចិញ្ចឹមវាមែន តែចិត្តរបស់វា ខ្ញុំមិនបានបង្កើតវាទេ។ ដូច្នេះរឿងយកគ្រួសារឬមិនយក គឺសម្រេចនៅលើចិត្តរបស់វា ខ្ញុំមិនអាចបង្ខំវាបានទេ"។ មែនហើយ! យើងដឹងថា ប្រធានកងនារីយកណ្តាល (នារីមានគ្រួសារ) បានពេញចិត្ត លោក សាឡឹម ម្យ៉ាងទៀត ប្រធានភូមិបានហៅលោក សាឡឹម សួរបញ្ជាក់ច្រើនលើកហើយ តែលោកសាឡឹមមិនព្រម។ យប់ប្រហែលម៉ោងប្រាំបី ប្រធានភូមិឲ្យកងឈ្លបមកហៅលោក សាឡឹម យើងនៅក្នុងផ្ទះភ័យណាស់។ ពួកគេនិយាយជាមួយលោក នៅទ្វាររបង ជួនតិច ជួនខ្លាំង ចុងក្រោយបង្អស់ មិនដឹងជាយ៉ាងដូចម្តេចទ យើងឮសម្លេងប្រធានភូមិនិយាយខ្លាំងៗថា៖ "រស់រើកទេតើ មានកើតជំងឺអី ហេតុអ្វីបានជាមិត្តឯងមិនព្រម?"។ លោកសាឡឹម ចូលមកក្នុងផ្ទះវិញទាំងព្រួយក្រៀមក្រំ លោកសាឡាស់ លោកចំរើន ក៏ដូចគ្នាដែរ។ ពុំដឹងលោកសាឡឹម ដោះស្រាយយ៉ាងដូចម្តេច រឿងនេះក៏ស្ងាត់ទៅវិញ។ អង្គការបានបញ្ជូនលោក សាឡឹម ឲ្យទៅរកត្រីនៅបឹងទន្លេសាប ដើម្បីផ្គត់ផ្គង់ម្ហូបឲ្យអង្គការ ពេលនោះលោកសាឡឹមស្រកហើមហើយ។

ប្រធានភូមិឈ្មោះ ព័ន្ធ ដែលមកពីភូមិភាគនិរតី មានការចាប់អារម្មណ៍មកលើ

ក្រុមគ្រួសារយើងណាស់ ជាពិសេសលោកទាំងបី ដែលមានចរិតប្លែកពីបុរសដទៃ។ ទន្ទឹមនឹងនោះដែរ វាហាក់ដូចជាស្រឡាញ់ក្មួយស្រីខ្ញុំ តែក្មួយស្រីមិនរវីរវល់អើពើជាមួយ។ ដោយក្មួយខ្ញុំមិនរវីរវល់ជាមួយ ប្រធានភូមិព័ន្ធ បានជំរុញឲ្យនាងរៀបការជាមួយយុវជនកៀសសឹកម្នាក់ ដែលបែកពីឪពុកម្ដាយ។ រៀបការតាមរបៀបអង្គការហៅ"ប្ដេជ្ញា" យើងមានការព្រួយបារម្ភខ្លាំង។ លោកទាំងបី សូត្រធម៌ឲ្យនាង លោកពុំអាចធ្វើបុណ្យឲ្យនាងបានទេ ព្រោះយើងពុំអាចសម្ដែងការពិតប្រាប់ប្ដីនាងបាន។ ប្ដេជ្ញាបានមួយអាទិត្យ នាង និងប្ដីត្រូវបែកទៅរស់នៅភូមិថ្មីឈ្មោះភូមិគាផល់។

លោក សាឡឹម បានត្រូវអង្គការព្រមានម្ដង គឺនៅពេលដែលអង្គការឲ្យកម្លាំងកៀសសឹកកាប់ដីស្រែស្ងួតស្រូវ លោក សាឡឹមនិយាយថា៖ "ធ្វើដូច្នេះ ខាតកម្លាំងមនុស្សណាស់ បំប៉នគោ ក្របី មិនឲ្យភ្ជួរស្រែ ដោយលើកថាវានឿយហត់ភ្ជួរស្រែច្រើនឆ្នាំ ឥឡូវឲ្យមនុស្សកាប់ដីស្រែស្ងួតវិញ។ ធ្វើដូច្នេះមិនត្រឹមត្រូវឡើយ"។ យប់នោះទាំងប្រធានភូមិ ទាំងកងឈ្លប ចូលមកពេញផ្ទះ ជួយមតិលោកសាឡឹម។ គេថា៖ "មិត្តមិនត្រូវនិយាយដូច្នេះទេ! ម្ដងនេះ គឺអង្គការអនុគ្រោះមិនយកទោសពៃរ៍ តែថ្ងៃក្រោយបើនិយាយដូច្នេះទៀត កង់ប្រវត្តិសាស្ត្រនឹងកិនកម្ទេច ព្រោះត្រូវយល់ថា ជនកៀសសឹកមានតែបាតដៃទទេ គ្មានគោ គ្មាក្របី ហើយមកហូបស្រូវអង្គរបស់អ្នកមូលដ្ឋាន ដែលបានដាំដុះកាលពីឆ្នាំមុន ធ្វើឲ្យអ្នកមូលដ្ឋានខ្វះខាតថែមទៀត"។

ថ្ងៃមួយ ជាថ្ងៃបុណ្យសន្ត យ៉ូសែប ដោយក្នុងផ្ទះសុទ្ធតែជាឈ្មោះ យ៉ូសែប "យូរ ឆ្មារ ឆ្មារសោឡាស់ ឆ្មារ សាឡឹម" យើងក៏បានអបអរថ្ងៃបុណ្យនេះដោយសារលោក សាឡាស់ លោកសាឡឹមនៅផ្ទះសូត្រធម៌ ចំណែកខ្ញុំ និងលោកចំរើន ទៅរកចេកនៅឯព្រៃ។ ពេលយើងទៅដល់វាលមួយ មានសុទ្ធតែផ្ការីកពេញ ហើយផ្កាទាំងនោះ មានសណ្ឋានដូចគ្នា ដែលសន្ត យ៉ូសែបកាន់ក្នុងរូបគំនូរ។ យើងកាប់បានចេកទុំលើដើមមួយស្ងង់យ៉ាងឆ្ងាញ់ ដែលកន្លងមកយើងមិនដែលប្រទះលាភយ៉ាងដូច្នេះឡើយ។ ខ្ញុំបានកាច់ផ្កានេះមកផ្ញើលោក ហើយយើងហូបចេកទុំជប់លៀងថ្ងៃបុណ្យនោះ ទាំងនឹកដល់បងប្អូនទាំងអស់ដែលមានសន្តយ៉ូសែបជាឪពុក

លោកចំរើន ក៏ចាប់ផ្ដើមហើមដែរ។ ជំងឺហើយធ្វើឲ្យអ្នកជំងឺ ធ្វើការធ្ងន់មិនបានដូច្នេះ លោក ចំរើន ត្រូវអង្គការប្រជុំជាច្រើន។ ពួកវាដឹងថា លោកចំរើនមានជំងឺខ្វាក់មាន់ (ងងឹតពេលយប់) មិនអាចធ្វើការងារពេលយប់បានទេ ហើយវ៉ែនតាលោកក៏មីញ៉ូបទៀត។ លោកចំរើន បានវ៉ែនតាមួយដែលបងគាត់ឲ្យ ទោះបីវ៉ែនតានោះ

មិនត្រូវភ្នែកគាត់ក៏ដោយ តែវាគ្រាន់បើជាងអត់ដែរ។ តែអង្គការនៅតែលើកក្នុងអង្គប្រជុំថាលោកធ្វើពុតជាខ្វាក់មាន់ ដើម្បីគេចវេះពីការងារអង្គការ មានគំនិតសន្សំសុខជិះជាន់លើពលកម្មអ្នកដទៃ។ ដោយលោកចំរើនមានទម្លាប់ច្រតចង្កេះ ដូច្នេះពេលណា លោកកាប់ដីឬធ្វើអ្វីក៏ដោយ លោកតែងតែឆ្លៀតច្រតចង្កេះ ពេលឈរនិយាយលេងក៏អញ្ចឹងដែរ។ ការនេះអង្គការបានលើកឡើងថា លោកចំរើន មិនព្រមជម្រុះចោលចរិតនាម៉ឺននិយាយស្តីសុទ្ធតែយកដៃច្រតចង្កេះ។ នៅពេលលោកចំរើនទៅដេកពេទ្យភូមិព្យាបាលជំងឺហើម នៅភូមិអូរពុះ អង្គការបានយកជនភៀសសឹកទៅសម្លាប់ចោលជាបន្តបន្ទាប់ហើយក្នុងចំណោមនោះ មានទាំងក្រុមគ្រួសារលោកចំរើនផងដែរ។ លោកចំរើនព្រួយយ៉ាងខ្លាំង ជំងឺក៏កាន់តែខ្លាំងដែរ គ្រូពេទ្យភូមិបានបញ្ជូនលោកទៅមន្ទីរពេទ្យភូមិភាគ គឺមន្ទីរពេទ្យកំពង់ចាម។ ពេលបញ្ជូនលោកចំរើនទៅដេកពេទ្យនៅកំពង់ចាម អង្គការបានប្រជុំលើកសរសើរពីគុណបំណាច់របស់បក្ស ចំពោះជនភៀសសឹក ជាក់ស្តែងមានលោកចំរើន ដែលអង្គការបានយកចិត្តទុកដាក់។ មួយខែក្រោយមក លោកចំរើនបានជាសះស្បើយ ហើយបានវិលត្រឡប់មកផ្ទះវិញ។ លោកបានបញ្ជាក់ថា នៅក្រុងកំពង់ចាមគ្មានប្រជាជនរស់នៅទេ មានសុទ្ធតែគ្រួសារអង្គការ លោកពុំបានប្រទះឃើញគ្រួសារគ្រីស្តបរិស័ទណាម្នាក់ឡើយ ហើយតាមផ្លូវ ដែលលោកធ្វើដំណើរពីដំពង់ចាមមកតាំងគោកនេះក៏ពុំបានប្រទះនរណាម្នាក់ដែរ ព្រោះអង្គការ មិនអនុញ្ញាតឲ្យប្រជាជនរស់នៅជិតផ្លូវជាតិឡើយ។

ទំនាក់ទំនងរវាងយើង និងភូមិអូរពុះ ត្រូវដាច់ដោយគ្មានគ្រីស្តបរិស័ទរស់នៅទីនោះ។ ដូច្នេះយើងនៅសល់តែភូមិសំរៀងមួយតែប៉ុណ្ណោះ តែក៏មិនសូវបានទៅមកញឹកញយឡើយ ព្រោះការងារអង្គការកាន់តែមមាញឹក គ្មានពេលសម្រាក។

ក្រោយរដូវចម្រូត អង្គការរៀបចំទិសដៅថ្មី គឺភូមិតាំងគោកត្រូវបានប្រកាសជាសហករណ៍ហូបរួមធ្វើការរួម លែងមានការងារឯកជនដើររកចេកដំឡូង។ល។ ទៀតហើយ។ គេលប់បំបាត់ចោលកម្មសិទ្ធឯកជន គឺនៅសល់តែកម្មសិទ្ធសមូភាព ហើយទាំងអស់គ្នា ត្រូវសម្រុកលើប្រពន្ធភ្លឺស្រែ ធ្វើប្រឡាយទឹកបញ្ចូលស្រែ និងដេកនៅតាមការដ្ឋាន ទំនប់ប្រឡាយទាំងអស់គ្នា លើកលែងតែតា យាយ ចាស់ៗ ដែលនៅភូមិ ធ្វើបង្គី ដងចប ដេរស្លឹក។ ឯយុវជនទាំងអស់ត្រូវគេបញ្ចូលជាកង "ចល័ត" គឺជាកងកម្លាំងពិសេស សម្រាប់ប្រយុទ្ធក្នុងសមរភូមិក្តៅៗ ឆ្ងាយៗ។ ពេលនោះ

ពួកខ្ញុំនារីៗ ត្រូវគេបញ្ជូនទៅកងចល័តភូមិ ហើយគេមិនអនុញ្ញាតឲ្យមកផ្ទះទៀតឡើយ គឺហូបដេកនៅក្នុងជួរកងចល័ត។ ចំណែកពួកលោក ក៏ត្រូវគេបញ្ជូនក្នុងក្រុមវ័យកណ្តាលដេកហូបនៅឯការដ្ឋានដែរ។ ក្នុងផ្ទះនៅសល់តែឪពុកម្តាយចាស់តែប៉ុណ្ណោះ។ ឪពុកខ្ញុំគេឲ្យធ្វើបង្គី និងធ្វើដងចប តែដោយគាត់ដំបៅដៃ ព្យាបាលមិនជា គេក៏ឲ្យគាត់នៅយាមឃ្លាំងអង្ករ។ ម្តាយខ្ញុំត្រូវមើលកូនក្មេង ដើម្បីឲ្យនារីមានកូនតូចៗចេញទៅលើកទំនប់ដែរ។ គ្រានោះគ្មាននរណានៅក្នុងផ្ទះឡើយ ហើយគ្រឿងប្រដាប់ប្រើប្រាស់ក្នុងផ្ទះក៏ត្រូវ អង្គការប្រមូលយកទៅដាក់ជាសម្បត្តិរួមទាំងអស់ដែរ ដូចជាចានឆ្នាំងជាដើម។ យើងនៅសល់តែស្លាបព្រាមួយទុកហូបបាយ នៅពេលណាគេគោះជួងហៅតែប៉ុណ្ណោះ។

យើងខ្លាចអង្គការចូលមកឆែកឆេរថង់ខោអាវ ពេលយើងទៅធ្វើការងារ មិនបានដឹងខ្លួន យើងយកឈើឆ្កាង និងចិញ្ចៀនរបស់លោក សាឡាស់ ដែលជាសញ្ញាសម្គាល់ថា លោកជាអភិបាលព្រះសហគមន៍ និងប្រអប់ដាក់ព្រះកាយ (បន្តោងខ្សែកដាក់ព្រះកាយ) របស់លោកសា ឡឹម ទៅលាក់ទុកក្រោមសំបុកមាន់ ហើយយកចំបើងទៅគរចោលពីលើបន្លំធ្វើជាបោះចោល ដើម្បីកុំឲ្យកងឈ្លបចាប់អារម្មណ៍។ គឺដោយមធ្យោបាយនេះហើយ ទើបយើងអាចរក្សាកេរ្តិ៍តំករបស់លោករហូតមកដល់សព្វថ្ងៃ។ ថ្ងៃ មួយ ក្នុងពេលឆែកឆេរផ្ទះប្រមូលយកចាន ឆ្នាំង ស្រូវ អង្ករ អង្គការបានឃើញរូបថតលោកសាឡឹម ដែលទទួលអគ្គសញ្ញាជាបូជាចារ្យនៅប្រទេសបារាំង និងរូបថតអាពាហ៍ពិពាហ៍របស់បងស្រី បងប្រុស និងប្អូនស្រី។ អង្គការពិនិត្យរូបថតយ៉ាងល្អិតល្អន់បំផុត ពេលអង្គការចេញពីផ្ទះ។ លោកសាឡឹម យករូបថតនេះទៅដុតចោល ទាំងទុក្ខព្រួយ និងសោកស្តាយជាទីបផុត។ លោក សាឡឹម ស្រឡាញ់រូបថតនេះជាអនុស្សាវរីយ៍មួយដ៏ថ្លៃថ្លា និងវិសេសវិសាលបំផុតសម្រាប់លោក ព្រោះពេលលោកទទួលអគ្គសញ្ញានេះ លោកនៅតែម្នាក់ឯងនៅប្រទេសបារាំងគ្មានឪពុកម្តាយ គឺប្រៀបដូចជាកូនកំព្រាមានតែព្រះសហគមន៍ប៉ុណ្ណោះ។ បន្ទាប់ពីឆែកឆេររួចឃើញរូបថតលោក សាឡឹម មក ទាំងអង្គការ ទាំងកងឈ្លប ទាំងអ្នកមូលដ្ឋានកំណត់ថាលោក សាឡឹម ធ្វើធំណាស់ ស្លៀកពាក់របៀបស្តេចបារាំង ព្រមទាំងស្គាល់បារាំងជាច្រើនផង។ អង្គការរកឃើញរូបថតនេះព្រោះលោក សាឡឹម លាក់ក្នុងថង់អង្ករ។

***

## **គុកអត់ជញ្ជាំង**

ពេលនោះ យើងហាក់ដូចជារស់នៅក្នុងកុកអត់ជញ្ជាំង គឺគ្មាននរណាមានសិទ្ធ ដើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយដោយគ្មានការអនុញ្ញាតឡើយ។ ពួកលោកនៅតែក្នុងជំរំការដ្ឋាន ទំនប់ ប្រឡាយ លែងមានការទាក់ទងជាមួយអ្នកភូមិសំរៀង ញឹកញយដូចមុនហើយគ្មានដំណឹងអ្វីទាំងអស់ពីគ្រីស្តបរិស័ទ។

អង្គការបានប្រកាសជ្រើសរើសចល័តតំបន់។ លោកសាឡាស់ លោកសាឡឹម និងលោក ចំរើន បានគិតគ្នាជាច្រើនថ្ងៃ។ ទីបញ្ចប់ លោកសាឡាស់ សម្រេចចូលធ្វើកងចល័តតំបន់ ព្រោះលោកនឹកសង្ឃឹមថា ចល័តតំបន់ ដែលដើរពីស្រុកមួយទៅស្រុកមួយពីខេត្តមួយទៅខេត្តមួយ ពីតំបន់មួយទៅតំបន់មួយនោះ ប្រហែលជាបានជួបគ្រីស្តបរិស័ទ អ្នកបួស ព្រមទាំងដូនជីទាំងឡាយមិនខាន។

ថ្ងៃចេញដំណើរលោកទាំងបីបានថ្វាយអភិបូជាមួយជាចុងក្រោយ។ គ្រានោះម្នាក់ៗយំយ៉ាងច្រើន នាំឲ្យការថ្វាយអភិបូជាប្រព្រឹត្តិឡើងដោយលំបាក។ នៅពេលចេញដំណើរ លោកលើកដៃជូនពរឲ្យយើងទាំងអស់គ្នា ហើយយើងក៏លើកដៃតបវិញដោយឆ្លើយថា៖ "អាម៉ែន" ទាំងទឹកភ្នែក។ ប្រធានភូមិបានចូលមកក្នុងផ្ទះ ហើយនិយាយថា៖ "កុំគិតពីគេធ្វើអ្វី គេទៅនេះបានស្រួលហើយ ហើយសម្បូរហូបណាស់មិនមែនខ្វះខាតដូចនៅផ្ទះទេ"។ ខ្ញុំនិងក្មួយស្រី គេចាត់ឲ្យទៅច្រូតស្បូវនិងប្រុយនៅវាលក្រោមសែនឆ្ងាយ ដើរកាត់វាល កាត់ព្រៃមួយថ្ងៃទើបដល់។ នៅទីនោះ ពេលថ្ងៃយើងឮសូរតែសម្រែកសត្វព្រៃ ហើយពេលយប់ឮសូរតែសម្លេងឆ្កែចចកលូ។ ខ្ញុំបានទទួលដំណឹងសុខទុក្ខពីឪពុកម្តាយខ្ញុំតាមរយៈអ្នកបរទេះ ដឹកស្បូវចុះឡើងទៅភូមិតែប៉ុណ្ណោះ។

ចប់រដូវចម្រូត ខ្ញុំនិងក្មួយខ្ញុំត្រឡប់មកភូមិវិញ ជាភ័ព្វសំណាង លោកសាឡាស់ ដែលនៅចល័តតំបន់ ក៏បានមកលេងភូមិដែរ។ លោកទើបចេញពីមន្ទីរពេទ្យ ហើយលោកបានសុំច្បាប់ពេទ្យមកលេងផ្ទះ បានបីថ្ងៃ ទើបវិលទៅកងចល័តតំបន់វិញ។ លោកបានឲ្យដឹងថា លោកទៅនេះមិនបានជួបគ្រីស្តបរិស័ទណាទេ ជួបតែយុវជនម្នាក់ប៉ុណ្ណោះដែលធ្វើចល័តតំបន់ដូចគ្នា។ ចំពោះដូនជី នឹងអ្នកបួសវិញ លោកមិនបានប្រទះឡើយ ព្រោះមិនមែនដូចកាលលោកគ្រោងទុកនោះទេ នឹកថាបានដើរទៅស្រុកគេអាច ស៊ើបសួររកគ្នីគ្នាឃើញ តាមពិតរបបគ្រប់គ្រងតែមួយគឺគុកឥតជញ្ជាំង។

ពាក់កណ្ដាលឆ្នាំ ១៩៧៧ អង្គការបានឲ្យច្បាប់ឈប់សម្រាកមួយថ្ងៃមកលេងផ្ទះ។ ខ្ញុំបានឆ្លៀតឱកាសទៅរកអុស នៅព្រៃបាណន់ ចម្ងាយ ៣ គ.ម. ពីភូមិ សម្រាប់ទុកជូនឪពុកម្ដាយប្រើប្រាស់ ពេលខ្ញុំជាប់នៅកងចល័ត។ ខ្ញុំបានជួបមិត្តម្នាក់ជាកងទ័ពតំបន់ដែរ។ ខ្ញុំសួរដំណឹងពីលោក សាឡាស់ គេប្រាប់ថា លោក សាឡាស់ស្លាប់ប្រហែលមួយអាទិត្យហើយ នៅមន្ទីរពេទ្យទឹកថ្លា។ ខ្ញុំភ័យស្លុតខ្លាំង ខ្ញុំរត់មកផ្ទះប្រាប់ដំណឹងនេះដល់ឪពុកម្ដាយលោកសាឡឹម និងលោកចំរើន។ ខ្ញុំបានទៅសុំសំបុត្រអនុញ្ញាតពីប្រធានភូមិ និងប្រធានកងចល័ត ដើម្បីទៅរកលោក សាឡាស់ នៅឯជំរំប្រមូលផ្ដុំកងចល័តតំបន់ឯភូមិរំលេង។ ប្រធានភូមិមិនអនុញ្ញាត ព្រមទាំងគំរាមខ្ញុំថា៖ "មិត្តនារីឯងដឹងពីមកណា? មិត្តនារីឯងជាខ្មាំងមកបំផុសបំផុលឬ?"។ ខ្ញុំមិនហ៊ានយំទេ ហើយខ្ញុំអង្វរសុំច្បាប់តែមួយថ្ងៃប៉ុណ្ណោះ។

បីថ្ងៃក្រោយមក ទើបប្រធានភូមិចេញលិខិតឲ្យខ្ញុំទៅរកលោក សាឡាស់ នៅភូមិរំលេង ដែលជាជំរំប្រមូលផ្ដុំកងចល័តតំបន់។ ទៅដល់ជំរំឃើញមានសភាពស្ងាត់ជ្រៀប គ្មាននរណាម្នាក់សោះ ជំរំត្រូវគេរុះរើអស់ នៅសល់តែកម្ទេចកម្ទីស្លឹកដំបូលតែប៉ុណ្ណោះ។ ខ្ញុំភ័យណាស់ ខ្ញុំបានសួរកងឈ្លបដែលក្លែងខ្លួនជាអ្នកឃ្វាលគោនៅទីនោះ គេឆ្លើយថា កងចល័តនេះបានរើជំរំផ្លាស់ទៅខេត្តក្រចេះហើយ។ ខ្ញុំវិលត្រឡប់មកពេទ្យទឹកថ្លា ហើយខ្ញុំសួរប្រធានពេទ្យ គេបានឆ្លើយថា៖ "តាឡាស់បានមកសម្រាកពេទ្យមែន តែស្លាប់ទៅហើយ"។ ខ្ញុំសួរពេទ្យថា តើគាត់មានជំងឺអ្វី? ពេទ្យឆ្លើយថា៖ "គាត់សន្លប់ គេសែងគាត់មកពេទ្យ ពេលនោះគាត់ដឹងខ្លួនវិញ គាត់ថ្ងូរថាឃ្លានបាយណាស់រួចសន្លប់ទៀត។ ពេទ្យបានដាំបបរមួយឆ្នាំង ព្រោះឃើញគាត់ខ្សោយខ្លាំងពេក ពេលគាត់ដឹងខ្លួន កាត់ហូបបបរស្ទើរតែក្របាក់ទាំងចានដោយឃ្លានពេក រហូតដល់អស់បបរមួយកូនឆ្នាំង។ ក្រោយពីហូបបបររួចគាត់ក៏ស្លាប់ទៅ។ នៅក្នុងខ្លួនគាត់មានកូនសៀវភៅមួយ សៀវភៅនោះអង្គការបានយកហើយ"។ ខ្ញុំសុំពេទ្យឲ្យបង្ហាញកន្លែងកប់សពគាត់។ ពេទ្យឆ្លើយថា៖ "អង្គការបានទុកដាក់ស្រួលបួលហើយ មិត្តឯងមិនបាច់ទៅទេ"។ ដោយសុំពេទ្យទៅកន្លែងកប់សពមិនបាន ខ្ញុំវិលត្រឡប់មកផ្ទះវិញ។ យើងកើតទុក្ខយ៉ាងខ្លាំង ព្រោះលោកព្រាត់យើងរហូត គ្មានថ្ងៃវិលត្រឡប់មកជួបយើងវិញទេ។ ក្នុងឆ្នាំ ១៩៧៨ ពេលខ្ញុំទៅលើកទំនប់ ៧ មករា នៅកំពង់ថ្ម ខ្ញុំបានជួបមិត្តម្នាក់ដែលជាកងចល័តជាមួយលោក សាឡាស់ មិត្តនោះបាននិយាយថា៖ «លោក សាឡាស់ឈឺច្រើន ព្រោះមានជំងឺ

*បេះដូងរីក និងហើមខ្លួន ហើយដោយលោកមិនអាចធ្វើការបាន គេឲ្យលោកដាក់បាយជ្រូក ជូនកាលដោយឃ្លានខ្លាំងពេក លោកយកបាយជ្រូកហូបក៏មានព្រោះតាម វិន័យរបស់អង្គការ គឺគេមិនឲ្យបបរអ្នកឈឺស្មើនឹងអ្នកធ្វើពលកម្មទេ គឺគេឲ្យតិចបំផុត និងសុទ្ធតែទឹក ដោយអង្គការប្រកាសថា អ្នកឈឺហូបមិនបានទេ អ្នកនោះឈឺពុត គឺជាខ្មាំងដែលជិះជាន់ពលកម្មគេ។ បន្ទាប់មក លោកត្រូវគេបង្ខំឲ្យទៅស្ទូងស្រូវ លោកស្ទូងបានតែបន្តិចហេវហាត់មែនទែន ស្ទូងលែងរួច លោកឡើងលើភ្លឺស្រែសម្រាក ហើយប្រធានក្រុមចល័តបញ្ជាលោកឲ្យចុះស្ទូងទៀត លោកឆ្លើយតបទៅប្រធានក្រុមនោះថា៖ "មិត្តបង ខ្ញុំងងឹតមុខណាស់ ស្ទូងមិនកើតទេ"។ ប្រធាននោះឆ្លើយថា៖ "មិត្តឯងធ្វើទៅ បើដួលគេសែង"។ លោកក៏ចុះទៅស្ទូងពេលនោះហើយដែល លោកដួលសន្លប់ក្នុងទឹក គេក៏សែងលោកយកមកមន្ទីរពេទ្យ ហើយលោកក៏ស្លាប់នៅក្នុងមន្ទីរពេទ្យនោះទៅ។»*

**ការសម្លាប់បុគ្គលដលៃគ្មានកំហុស**

ចាប់ពីឆ្នាំ ១៩៧៧ មក រដ្ឋអំណាចខ្មែរក្រហមទូទាំងប្រទេសកាន់តែឃោរឃៅឡើងថែមទៀត។ ប៉ុលពតបានរួមសហការយ៉ាងជិតស្និទ្ធជាមួយតាម៉ុក( គណៈភូមិភាគនិរតី )ដើម្បីត្រួតលើបក្សទាំងមូល។

អ្នកទាំងពីរមានបំណងធ្វើ "*បដិវត្តន៍ទី ២* "។ តាមឯកសារដែលពួកគេបានសរសេរ ពួកគេមានផែនការ កំចាត់កម្មាភិបាលខ្មែរក្រហម នៅតំបន់ផ្សេងៗទៀតចោល តាមលំដាប់លំដោយ គឺពួកគេចាប់កម្មាភិបាលរាប់ពាន់នាក់ មកធ្វើទារុណកម្មនៅក្នុងគុកទួលស្លែង រួចសម្លាប់ចោល។ ឈ្មោះ សោ ភឹម ជាគណៈភូមិភាគ បូព៌ា ដែលនៅជាប់ព្រំដែនប្រទេសវៀតណាមប្រឆាំងនឹង ប៉ុល ពត ហើយប៊ិសត្រូវប៉ុល ពត ចាប់បាន។ ទីបំផុតលោកក៏ធ្វើអត្តឃាតខ្លួនឯងទៅ។ ចំណែកនាយទាហានមួយចំនួនធំ ដែលនៅក្រោមបញ្ជារបស់លោក សោ ភឹម មានលោក ហេង សំរិន មេបញ្ជាការកងតម្រួត និងលោក ហ៊ុន សែន ជាដើម រត់គៀសខ្លួនចូល ប្រទេសវៀតណាម។ ពេលនោះ "*ប្រជាជនថ្មី* " ឬ "*ឈ្លើយសង្គ្រាម* " មួយចំនួនដែលនៅតំបន់ខាងជើងក្រុង កំពង់ចាម ត្រូវពួកខ្មែរក្រហមដឹកតាមរថយន្តយកទៅសម្លាប់ចោលដែរ។ នៅគ្រប់ទីកន្លែងអង្គការចេះតែកំចាត់ "*ខ្មាំងបង្កប់ខ្លួនក្នុងជួរកម្មាភិបាល* "។ អង្គការចេះតែចោទប្រជាជនទូទៅថា "*ក្បាលយួន ខ្លួនខ្មែរ* " ហើយសម្លាប់ខ្មែរស្លូតត្រង់អស់ច្រើនអនេក។ គ្រានោះ អង្គការចាប់គ្រីស្តបរិស័ទវៀតណាមមួយចំនួនដែលស្ម័គ្រចិត្តរស់នៅប្រទេសខ្មែរ ក្រោយឆ្នាំ ១៩៧៦។ គ្រីស្តបរិស័ទកាតូលិកខ្មែរមួយ

ចំនួន ក៏ត្រូវអង្គការចោទជា "*កា.សេ.បេ.វៀតណាម*" ឬក៏ "*សេ.អ៊ី.អា.អាមេរិក*" ដែរ។

*«ចុងឆ្នាំ ១៩៧៧ អង្គការបានប្រកាសបញ្ជូនជនភៀសសឹក ឲ្យទៅចាត់ជំរ នៅចម្ការកៅស៊ូ និងទៅនៅដីថ្មី ព្រោះភូមិស្រុកចង្អៀតណាស់ ហើយស្រូវអង្ករក៏មានតិចតួចទៀត។ ពេលល្ងាចៗ ឡានបានមកដឹកយកប្រជាជនភៀសសឹកចេញពីភូមិសូយោងដែលនៅជិតភូមិតាំងគោកទៅ ហើយជាមួយនេះ ការខ្សឹបខ្សៀវអំពីរឿងយកអ្នកថ្មីទៅសម្លាប់ ចេះតែឮតៗគ្នាក្នុងក្រុមចល័តស្រុករបស់យើង។ ប្រធានតំបន់បានមកបើកអង្គមេទិញមួយ ហើយគេក៏បានប្រកាសពីការកម្ទេចខ្មាំង។ តាមអត្ថន័យនិយាយនោះ ខ្មាំងគឺគ្មាននរណាក្រៅពីជនភៀសសឹកឡើយ សេចក្តីប្រកាសបានធ្វើឲ្យយើងព្រឺខ្លួន តក់ស្លុតយ៉ាងខ្លាំងដូចជា៖ "ត្រូវកម្ទេចទាំងពូជ ព្រោះបើ មិនដូច្នេះទេ កូនដែលនៅនឹងធ្វើការសងសឹកចំពោះបដិវត្តន៍ជាមិនខាន មិនខុស ពីស្មៅ ក្រវាញជ្រូកឡើយ បើចង់ឲ្យផុតពូជស្មៅនេះ គឺត្រូវកម្ទេចទាំងមើមទាំងឫស ព្រោះបើ ទុកតែមួយទងស្មៅនេះនឹងដុះរាលដាលពេញមួយចម្ការវិញជាមិនខាន"។ ក្រោយពីប្រធានតំបន់ធ្វើមេទិញរួចមក ខ្ញុំដេកគិតមិនឈប់ឈរ ខ្លាចការស្លាប់ ខ្លាចការបែកព្រាត់ប្រាសគ្នា ស្រមៃដល់ពាក្យអ្នកមូលដ្ឋាន ដែលនិយាយពីការ សម្លាប់ដោយវាយនឹងត្បូងចប វាយនឹងគល់ឫស្សី អារកនឹងធាងត្នោត និងបណ្តាទារុណកម្មផ្សេងៗទៀតគួរឲ្យរន្ធត់។*

*ក្រុមចល័តនារីត្រូវគេបញ្ជូន ពីការដ្ឋានវាលក្រោម ទៅនៅជិតភូមិវិញ ដើម្បីងាយស្រួលក្នុងការបញ្ជូនខ្លួនទៅជាមួយគ្រួសារ ព្រោះពេលគេបញ្ជូនឪពុកម្តាយឡើងឡានទៅនៅភូមិថ្មីនោះ ប្រធានភូមិនឹងចាត់កងឈ្លបមកហៅកូនដែលនៅចល័តឲ្យទៅជាមួយឪពុកម្តាយបានទាន់ពេលវេលា។ លោក សាឡឹម និងលោកចំរើន ព្រមទាំងជនភៀសសឹកដែលកំពុងស្ទូងស្រូវនៅវាលក្រោម ក៏ត្រូវបានធ្វើដំណើរវិលត្រឡប់មកភូមិវិញទាំងអស់គ្នាដែរ ទុកនៅទីនោះតែអ្នកមូលដ្ឋានប៉ុណ្ណោះ។ ក្នុងមួយថ្ងៃ ឬពីថ្ងៃនេះ គឺយើងរង់ចាំឈ្មោះដើម្បីឡើងឡាន។ ថ្ងៃត្រង់ ខ្ញុំឲ្យក្មួយស្រីខ្ញុំនៅចាំកន្លែង ខ្ញុំលួចរត់ពីសាលាតាំងគោក (ជំរំកងចល័តនារី) មកផ្ទះ។ ខ្ញុំបានហែក សន្លឹកសៀវភៅវចនានុក្រមខ្ចប់គ្រាប់ពូជ រនោង ត្រឡាច ល្ពៅ ប៊ីចេងមួយកូនស្លាបព្រាម្នាក់ (ប៊ីចេងដែលនៅសល់ប្រហែលកន្លះខាំ) និងថ្នាំជក់ប្រហែលកន្លះខាំម្នាក់។ ខ្ញុំបានខ្ចប់បែងចែកឲ្យលោក សាឡឹម និងលោកចំរើន ឪពុកម្តាយ ក្មួយស្រី និងខ្លួនខ្ញុំផ្ទាល់ ម្នាក់ៗមួយចំណែកៗ ដើម្បីយកទៅតាមខ្លួន ព្រោះខ្លាច*

នៅដីថ្មីយើងត្រូវបែកគ្នាទៀត ដូចកាលដែលយើងចេញពីភ្នំពេញមកនោះ។ លោកសាឡឹម និងលោកចំរើន មានទឹកមុខស្ងួត លោកបាប្រប់ថា៖ "យើងប្រហែលជាមិនបានជួបគ្នាទៀតទេ ហើយប្រហែលជាស្លាប់ទៀតផង ព្រោះតាមពាក្យខ្សឹបខ្សៀវរបស់អ្នកមូលដ្ឋាន គឺយកទៅសម្លាប់ មិនមែនឲ្យទៅរស់នៅលើដីថ្មីនោះទេ ក៏ប៉ុន្តែ តាមព្រះហឫទ័យព្រះអង្គចុះ។ រៀបចំរួចហើយ ខ្ញុំក៏លាឪពុកម្ដាយខ្ញុំ ព្រមទាំងលោកទាំងពីរវិលទៅកន្លែងចល័តវិញ ដោយយកចំណែករបស់ខ្ញុំ និងរបស់ក្មួយទៅជាមួយផង (យើងមិនបានដឹងថា តើប្រធានភូមិឲ្យខ្ញុំនិងក្មួយខ្ញុំត្រឡប់មកភូមិ ឡើងឡានជាមួយឪពុកម្ដាយ ឬក៏ឲ្យខ្ញុំនិងក្មួយខ្ញុំ ទៅផ្សេងតែពីរនាក់)។ ខ្ញុំបានសុំឲ្យម្ដាយខ្ញុំយកចំណែករបស់ក្មួយម្នាក់ទៀត ទៅឲ្យនាងនៅភូមិតាផល់ ភូមិដែលវានៅជាមួយប្ដីវា)។

ស្អែកឡើងគេឲ្យចល័ត ១០ នាក់ ឡើងទៅចម្ការដាំអំពៅ ក្នុងនោះមានខ្ញុំនិងក្មួយខ្ញុំដែរ។ ខ្ញុំនិង ក្មួយរត់មកលាឪពុកម្ដាយ និងលាលោកជាចុងក្រោយ ហើយខ្ញុំឲ្យ ក្មួយខ្ញុំទៅចម្ការមុន ចំណែកខ្ញុំលួចរត់ទៅភូមិខ្វូរថ្មីដែលប្អូនស្រីពៅរស់នៅ។ ទៅដល់ផ្ទះប្អូន ប្អូនរត់មករកខ្ញុំដោយអំណរ ព្រោះតាំងពីខ្ញុំទៅចល័តយើងមិនសូវបានជួបគ្នាទេ ដោយខ្ញុំមិនបានចេញចូលមកភូមិ។ ប្អូនស្រីពៅត្រេកអរ ព្រោះបានជួបខ្ញុំជាលើកចុងក្រោយ ដ្បិតភូមិខ្វូរថ្មីមានសុទ្ធតែជនភៀសសឹករៀបចំខ្លួនឡើងឡានទៅភូមិថ្មី ដូចលោកសាឡឹម និងលោកចំរើនដែរ។ ពេលនោះ ប្អូនស្រីខ្ញុំទើបតែសម្រាលកូនបាន ២ ខែប៉ុណ្ណោះ វាប្រមូលសណ្ដែកដែលនៅសល់កន្លះកំប៉ុងដាំបាយឲ្យខ្ញុំហូប ហើយនិយាយថា៖ "យើងបែកគ្នាលើកនេះ ប្រហែលជាបែកស្លាប់ មិនមែនបែករស់ទេ"។ ខ្ញុំឱបក្មួយស្រី(កូនស្រីច្បងរបស់ប្អូនពៅខ្ញុំ) ខ្ញុំថើបវាដោយក្ដីអាណិតអាសូរ ខ្ញុំពរកូនស្រីទី២ របស់វាដែលមានអាយុទើបតែពីរខែ ខ្ញុំយំដោយរន្ធត់ចំពោះ ការបែកគ្នានេះ។ ម៉ោង ៥ ល្ងាច ខ្ញុំត្រូវវិលទៅចម្ការឲ្យបានមុនពេលយប់ គឺមុនពេលគេប្រជុំជួរ។ ខ្ញុំលាប្អូនស្រីខ្ញុំថើបក្មួយស្រីទាំង២ ខ្ញុំយំយ៉ាងខ្លាំង គ្មាននិយាយពាក្យអ្វីបានមួយម៉ាត់ជាមួយប្អូនទេ ប្អូនខ្ញុំក៏យំដែរ វាលើកដៃលាខ្ញុំ ហើយនិយាយចេញពាក្យចុងក្រោយថា៖ "អ្នកបង អូនលាហើយ!"។ តាមផ្លូវ ខ្ញុំយំរហូតដល់ចម្ការ។ ឃើញខ្ញុំកើតទុក្ខខ្លាំង ក្មួយខ្ញុំព្រួយចិត្តណាស់ ថ្ងៃខ្លះវាឲ្យខ្ញុំធ្វើជាឈឺ ដើម្បីបានសម្រាកនៅនឹងកន្លែង ហើយទុកឲ្យវាធ្វើចម្ការតែម្នាក់ឯង ព្រោះវាឃើញខ្ញុំលួចយំពេលធ្វើការ វាខ្លាចប្រធានក្រុមឃើញ គេយកទោស។

មែនហើយ ខ្ញុំមិនអាចទប់ចិត្តរបស់ខ្ញុំមិនឲ្យរន្ធត់បានទេ ព្រោះរាល់ថ្ងៃ ចាប់ពីថ្ងៃដែលខ្ញុំមកដល់ចម្ការ ខ្ញុំឮស្នូរសន្ទឹកឡានឡើងពីចម្ការអណ្តូងនិងចម្ការលើគ្មានដាច់សោះ ហើយសន្ទឹកឡាននេះ បានញាំញីរាងកាយខ្ញុំ ដួងចិត្តខ្ញុំ គ្មានលោះមួយវិនាទីឡើយ។ ខ្ញុំនឹកទៅដល់ឪពុកម្តាយខ្ញុំដែលចាស់ជរា នឹកទៅលោកសាឡឹមនិងលោកចំរើន នឹកដល់ប្អូនស្រីដែលមានកូនស្រីតូចៗដល់ទៅពីរនាក់ មិនដឹងថាតើអ្នកទាំងនោះទៅជាយ៉ាងណាទៅហើយ?។ ខ្ញុំអង្វរព្រះជាម្ចាស់គ្មានឈប់ពេលណាទេ ទាំងពេលធ្វើការ ទាំងពេលសម្រាក ហើយខ្ញុំនិយាយតិចបំផុត ព្រោះចិត្តខ្ញុំអង្វរព្រះអង្គ។ ដើរកាត់ចម្ការកៅស៊ូ ឆ្លងទៅចម្ការពោត ខ្ញុំឃើញដើមកៅស៊ូ ខ្ញុំស្រមៃឃើញ ពាក្យប្អូនស្រីនិយាយថា៖ "គេឲ្យពួកអូនទៅចាក់ជ័រ" ។ ខ្ញុំរន្ធត់ចិត្តពេលឃើញជ័រកៅស៊ូហូរចេញពីដើម ជ័រកៅស៊ូមានពណ៌ស តែភ្នែកខ្ញុំបែរទៅជាឃើញមានពណ៌ក្រហមទៅវិញ ខ្ញុំស្រមៃឃើញថា នេះជាឈាមដែលហូរចេញពីរាងកាយជនភៀសសឹក។

ថ្ងៃមួយ ក្រោយពីដើរយ៉ាងឆ្ងាយមក ក្រុមចល័តខ្ញុំបានមកឈប់សម្រាកនៅក្នុងចម្ការកៅស៊ូ។ ពេលនោះមានម្នាក់យកខ្សែរបកទៅឆូតលើគល់កៅស៊ូ ចេញជ័ររាវ ខ្ញុំយកដៃខ្ទប់ភ្នែក ស្រែក "អូយ" ដោយភ្លេចខ្លួន។ ប្រធានភូមិមើលមុខខ្ញុំ ហើយសួរថា៖ "មិត្តឯងកើតអី?" ខ្ញុំឆ្លើយអត់រួចសោះ។ ឃើញដូច្នោះ ក្មួយខ្ញុំឆ្លើយឡើងថា៖ "មីងខ្ញុំគ្រុនក្តៅប៉ុន្មានថ្ងៃហើយ រាល់យប់គាត់ដេកមមើមមាយមិនដឹងស្អីទេ"។

សូរសន្ទឹកឡាន ឡើងទៅចម្ការអណ្តូងនិងចម្ការលើបានស្ងប់ស្ងាត់បន្តិចម្តងៗ។ ខ្ញុំចង់រត់ទៅភូមិរកមើលឪពុកម្តាយ លោកទាំងពីរ ប្អូនស្រីពៅ និងក្មួយម្នាក់ទៀតនោះ តែវិន័យនៅចម្ការតឹងតែងពេក ហើយកងឈ្លបមាននៅគ្រប់ទីកន្លែងលើដើមកៅស៊ូ លើដើមឈើធំៗ ដែលអាចឲ្យគេសម្លឹងមើលទៅទីឆ្ងាយបាន។

នៅចម្ការអស់រយៈ ៦ ខែ ខ្ញុំនិងក្មួយព្រមទាំងកងចល័តចម្ការទាំងអស់ ត្រូវរំសាយពីចម្ការឲ្យមកធ្វើស្រែវិញ។ ខ្ញុំនិងក្មួយខ្ញុំវិលត្រឡប់មកផ្ទះវិញ ដោយដើរកាត់តាមភូមិខ្វរថ្មី គឺជាភូមិដែលប្អូនស្រីពៅរស់នៅ។ យើងព្រឺខ្លួននិងតក់ស្លុតយ៉ាងខ្លាំង ព្រោះភូមិខ្វរថ្មីទាំងមូល ដែលមានជនភៀសសឹកប្រមាណ ១០០ គ្រួសារ ឥឡូវនេះឡើងស្ងាត់ជ្រងំ ផ្ទះនីមួយៗរខេករខោក ព្រោះគ្មានម្ចាស់ថែរក្សា ដំបូលនិងជញ្ជាំងផ្ទះយោលទៅតាមខ្យល់បក់បោក។ ផ្ទះណាក៏ដូចផ្ទះណាដែរ គ្មានដំណាំដាំដុះមួយទងណាឡើយ។ អ្វីៗក្រៀមស្រពោនគួរសង្វេគក្រៃលែង។

ខ្ញុំបានចូលទៅផ្ទះប្អូនខ្ញុំ តែស្ងាត់សូន្យ គ្មានអ្វីទាំងអស់ មានតែបំពង់ទឹកត្នោតដែលប្អូនខ្ញុំធ្លាប់ដាក់អំបិល ព្យួរនៅក្បែរដុំឥដ្ឋបីដុំ ផ្គុំជាមុំជើងក្រាន ហើយដែលប្អូនខ្ញុំបានដាំបាយសណ្ដែកឲ្យខ្ញុំហូបនៅថ្ងៃដែលខ្ញុំមកជួបនិងលាគ្នាជាគ្រាចុងក្រោយកាលពី ៦ ខែមុននោះ។ ខ្ញុំស្រក់ទឹកភ្នែក ខ្ញុំស្រមៃឃើញប្អូនពរកូនខ្ចី ហើយមានក្មួយស្រី កូនច្បងនៅឈរក្បែរនោះ លើកដៃគ្រវីលាខ្ញុំទាំងទឹកភ្នែកដោយពោលថា៖ "អ្នកបង ប្អូនលាហើយ!"។

មកដល់ភូមិតាំងគោក បេះដូងខ្ញុំលោតយ៉ាងចម្លែក ផ្ទះជនភៀសសឹកមួយចំនួនក៏មានទិដ្ឋភាពមិនខុសពីផ្ទះរបស់ប្អូនពៅខ្ញុំដែរ។ យើងដើរយ៉ាងលឿនមកដល់ផ្ទះទាំងចិត្តភ័យអរៗ ព្រោះឃើញដំបូលផ្ទះមិនរយីករយាក ដូចផ្ទះប្អូនខ្ញុំ តែដីភូមិក្រៀមក្រោះគ្មានដំណាំអ្វីដុះបន្តិចសោះឡើយ។ ខ្ញុំរត់ទៅសួរផ្ទះអ្នកមូលដ្ឋានរកឪពុកម្ដាយខ្ញុំ។ តាសេង ប្រាប់ថា ម្ដាយខ្ញុំនៅក្រុងស្បូវ ឪពុកខ្ញុំនៅរោងសិប្បកម្មតាៗ។ ខ្ញុំទៅរកម្ដាយខ្ញុំ ខ្ញុំឃើញគាត់អង្គុយដាច់ឆ្ងាយពីគេរូបស្គាំងស្គម ក្រងស្បូវដោយកាយវិការមួយៗយឺតៗ និងស្ងៀមស្ងាត់។ ខ្ញុំរត់ទៅឈប់មុខគាត់ ហើយស្រែកហៅ "អ្នក" (ខ្ញុំហៅម្ដាយខ្ញុំថា"អ្នក")។ ម្ដាយខ្ញុំងើបមុខឡើងសម្លឹងខ្ញុំ គាត់គ្មានឆ្លើយអ្វីទាំងអស់ ហើយគាត់ឱនមុខចុះ ក្រងស្បូវតទៅទៀត។ ខ្ញុំភ័យណាស់ ម៉ែខ្ញុំទៅជាយ៉ាងម៉េចទៅហើយ គាត់មិនស្គាល់ខ្ញុំទេឬ? ខ្ញុំចង់ទ្រហោយំ តែខ្ញុំខ្លាចអ្នកមូលដ្ឋាននៅក្បែរ។ ខ្ញុំក្ដាប់ដៃយ៉ាងណែន មាត់ខាំយ៉ាងខ្លាំង ទប់ការឈឺចាប់ កុំឲ្យធ្លាយចេញមកក្រៅនៅចំពោះមុខអ្នកមូលដ្ឋាន។ ខ្ញុំអង្គុយជិតគាត់ចាប់ដៃគាត់ដែលកំពុងក្រងស្បូវ ហើយហៅគាត់ថា៖ "អ្នក! យើងទៅផ្ទះ ខ្ញុំទើបមកពីចម្ការ ហើយប៉ែមិនទាន់មកពីរោងសិប្បកម្មទេឬ? (ហៅឪពុកខ្ញុំថា "ប៉ែ" នេះជាទម្លាប់ហៅអ្នកស្រុកភូមិព្រះមាតា)។ ចូលដល់ផ្ទះភ្លាមខ្ញុំយំតែម្ដាយខ្ញុំមិនយំទេ ក្នុងភ្នែកគាត់មានតែតំណក់ទឹកភ្នែក តែទឹកភ្នែកគាត់នេះមិនស្រក់ចុះទេ គាត់យំរីងអស់ទឹកភ្នែកហើយគ្មានសល់ទឹកភ្នែកសម្រាប់យំទៀតទេ គាត់យំរហូតក្លាយទៅជាមនុស្សស្ងៀមស្ងាត់នឹងមើលខ្ញុំលែងស្គាល់ហើយ។ ម្ដាយខ្ញុំបានដំណាលប្រាប់ខ្ញុំថា៖

«ថ្ងៃមួយ ប្រហែលជាម៉ោង ៥ ល្ងាច គេគោះជួងហូបបាយ លោកសាឡឹម លោកចំរើន និងឪពុកម្ដាយខ្ញុំ កាន់ស្លាបព្រាទៅហូបបាយ។ នៅឯរោងបាយមានឡានមួយឈប់ចាំនៅទីនោះស្រេច។ គេគោះជួងមួយទៀតហៅឲ្យប្រជុំ ហើយគេហៅឈ្មោះអ្នកដែលត្រូវឡើងឡាន។ គេឲ្យអ្នកដែលមាន ឈ្មោះទាំងប៉ុន្មានទៅយកខោអាវ

*ដើម្បីឡើងឡានជាបន្ទាន់ ដោយមិនបាច់ហូបបាយ។ "លោកសាឡឹម លោកចំរើន លាឪពុកម្ដាយចេញទៅ លោកទាំងពីរគ្មានបាយមួយគ្រាប់ក្នុងពោះសោះ។ គួរឲ្យអនិច្ចាណាស់ លោក សាឡឹម គ្មានអ្វីជាប់ខ្លួនគ្រាន់ហូបទេ បែរទៅលោកចំរើន លោកមានផ្លែពោត ក្រហមមួយផ្លែ ដាក់ទុកហូបតាមផ្លូវ" នេះជាសម្ដីរបស់ម្ដាយខ្ញុំ។*

*ព្រឹកព្រលឹមឡើង ប្អូនស្រីពរកូននៅដៃមកលុតជង្គង់ នៅចំពោះមុខឪពុកម្ដាយខ្ញុំយំហ៊ូរៗហើយ ពោលទាំងអាក់អួលថា៖ "ម៉ាក់ ប៉ា កូនសូមលាហើយ"។*

*តាមសម្ដីរបស់មីង យ៉ាត (ម្ដាយ សេង ហ៊ី ប្ដីប្អូនខ្ញុំ) បានតំណាលថា៖*

*«ពេលគ្រួសារប្អូនខ្ញុំឡើងឡាន គាត់បានទៅភូមិខ្ទថ្មី គាត់ចង់យកកូនច្បងរបស់ខ្លួនខ្ញុំទុកតែអង្គការមិនព្រម។ គាត់សែនសង្វេគពេលឃើញកូនច្បង "ឱបខ្មើយ រត់តាមម្ដាយឡើងឡានដោយសប្បាយ ព្រោះក្នុងចិត្តវា គិតថាបានឡានជិះដើរលេង»។*

លោកសាឡឹម និងលោកចំរើន ចេញទៅបាត់តាមបញ្ជារបស់អង្គការ ដូចជនជាតិខ្មែររាប់ម៉ឺនសែននាក់ទៀត ដែលគ្មានទោសកំហុសអ្វីសោះឡើយ ហើយត្រូវអង្គការវាយសម្លាប់ចោលទាំងអស់។

ក្នុងគ្រួសាររបស់ម្ដាយលោក សាឡាស់ មានសមាជិក ២៥ នាក់ បានបាត់បង់ជីវិត គឺកូនប្រុស ៤ នាក់ កូនស្រីម្នាក់ កូនប្រសារប្រុសម្នាក់ និងចៅ ១៥ នាក់។

គ្រីស្ដបរិស័ទម្នាក់ឈ្មោះ រស់ អាន ដែលមានដើមកំណើតនៅកំពង់គ ក៏បានឡើងឡានដូចលោកបូជាចារ្យទាំងពីរនាក់នេះដែរ។ ដោយដឹងថាខ្លួនថា អង្គការដឹកយកទៅសម្លាប់ គាត់សុំចុះទៅហៅម្ដាយគាត់ ដើម្បីឲ្យស្លាប់ជាមួយគ្នា។ គាត់ឈ្លោះប្រកែកយ៉ាងខ្លាំងជាមួយកម្មាភិបាលខ្មែរក្រហម ដែលមិនព្រមអនុញ្ញាតឲ្យគាត់ទៅហៅម្ដាយ។ នៅទីបំផុតមេខ្មែរក្រហមនោះក៏យល់ព្រម។ ពេលគាត់ត្រឡប់មកវិញ រថយន្តនោះក៏ចេញផុតបាត់ទៅ ហើយគាត់ក៏បានរួចជីវិតផុតពីសេចក្ដីស្លាប់។

មានគ្រីស្ដបរិស័ទខ្មែរនិងវៀតណាមជាច្រើនរងគ្រោះក្នុង "*បដិវត្តន៍ទី២* " នេះ។ គ្រីស្ដបរិស័ទឈ្មោះ ថុង ដែលលោកបូជាចារ្យ វ៉ីណេ ទុកចិត្តនោះ ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលដែរ។ គាត់ធ្លាប់បានជួយសង្គ្រោះជីវិតលោក វ៉ីណេ ក្នុងពេលដែលលោកត្រូវកងទ័ពវៀតណាមខាងជើងចាប់ខ្លួន។ នៅខែមីនា ឆ្នាំ ១៩៧៨ ខ្មែរក្រហមបានអញ្ជើញគាត់ឲ្យទៅ "រៀនសូត្រ"។ មុននឹងចេញទៅ គាត់បានលុតជង្គង់សូម លាប្រពន្ធគាត់ ហើយផ្ដែផ្ដាំថា៖ "*បងចង់ឲ្យកូនយើងម្នាក់ក្នុងចំណោមកូនទាំងប្រាំថ្វាយខ្លួនទៅព្រះអម្ចាស់*"។

បុព្វជិត ដាមីយ៉ាំង ជាតិវៀតណាមម្នាក់ ជាសមាជិកក្រុមគ្រួសារព្រះញាតិវង្សនៅបាណាម។ តាំងពីវ័យក្មេងមក គាត់យកចិត្តទុកដាក់ប្រៀនប្រដៅគ្រីស្តបរិស័ទខ្មែរយ៉ាងខ្លាំង មុនដំបូងនៅកំពង់គ បន្ទាប់មកនៅមាត់ក្រសាស់។ គាត់ព្យាយាមកសាងព្រះសហគមន៍នៅក្នុងភូមិទាំងពីរនោះ។ គាត់ក៏ត្រូវអង្គការដេញចេញ ពីក្រុងភ្នំពេញនៅថ្ងៃទី ១៨ មេសា ឆ្នាំ ១៩៧៥ រួមជាមួយគ្រីស្តបរិស័ទឯទៀតៗដែរ។ ដោយឃើញគាត់មានវ័យចំណាស់ អង្គការដាក់ទិសឲ្យចាំចម្ការចេកមួយនៅភូមិសំរៀង។ នៅពេលគាត់ជួបគ្រីស្តបរិស័ទណាម្នាក់ គាត់តែងដាស់តឿនណែនាំគេ ឲ្យកាន់តាមជំនឿរបស់ខ្លួនដោយស្មោះត្រង់។ ជារៀងរាល់ថ្ងៃ គាត់តែងតែសូត្រធម៌ឮខ្លាំងៗ។ ទោះបីយ៉ាងនេះក៏ដោយក៏គ្មានខ្មែរក្រហមណាហ៊ានធ្វើបាបគាត់ដែរ ព្រោះគាត់ចេះ តែគំរាមពួកនោះ។ គាត់ចេះតែគូរគំនូរខ្វាត់ខ្វែងនៅលើដីរបៀបព័ទ្ធសីមា និងសូត្របាលី ដែលធ្វើឲ្យខ្មែរក្រហមខ្លាចញញើត មិនហ៊ានចូលជិត។ ប៉ុន្តែ នៅដំណាច់ឆ្នាំ ១៩៧៧ ពេលពួកនិរតីឡើងកាន់អំណាចគាត់ដឹងខ្លួនថា គាត់មុខជាត្រូវគេយកទៅសម្លាប់ជាមិនខាន ព្រោះគាត់ជាជនជាតិវៀតណាម។ តែគាត់ចង់ "*ស្លាប់ស្របទៅតាមព្រះជាម្ចាស់*"។

ពេលខ្មែរក្រហមហៅគាត់ គាត់លុតជង្គង់អធិដ្ឋាន។ ខ្មែរក្រហមសម្លាប់គាត់ ហើយកប់សពគាត់នៅក្រោមដើមស្វាយមួយដើម ក្បែរចម្ការចេកដែលគាត់ចាំ។

**«ព្រះជាម្ចាស់ នាងខ្ញុំលាក់ទុកនៅក្នុងចិត្ត»**

មាត់ក្រសាស់ជាភូមិតូចមួយ នៅត្រើយខាងកើតនៃដងទន្លេមេគង្គ ចម្ងាយប្រហែល ១៥ គ.ម.ខាងត្បូងក្រុងភ្នំពេញ។ គ្រីស្តបរិស័ទដែលរស់នៅក្នុងភូមិនេះ មានជីវភាពក្រីក្រជាទីបំផុត ហើយកម្រិតវប្បធម៌ក៏ទាន់ទាបជាងគេដែរ។

លោកប៉ារូ បានបង្កើតភូមិមាត់ក្រសាស់នេះ នៅសតវត្សទី ១៩ ។ តែតាំងពីភូមិនេះកើតមក ប្រជាជនជិតខាងចេះតែធ្វើបាបគ្រីស្តបរិស័ទរហូត។ នៅឆ្នាំ ១៩៧៥ មានគ្រីស្តបរិស័ទប្រហែល ១០០ នាក់រស់នៅក្នុងភូមិនេះ។ ក្រោយថ្ងៃ ១៧ មេសា អង្គការបានប្រមូលពួកគេឲ្យនៅជុំគ្នាក្នុងវត្ត ហើយចោទថា "*អ្នកកាន់ សាសនាវៀតណាម*"។ ប៉ុន្តែអង្គការពុំបានសម្លាប់នរណាម្នាក់ទេ អង្គការបានជម្លៀសពួកគេឲ្យទៅរស់នៅកន្លែងមួយឆ្ងាយពីភូមិបន្តិចប៉ុណ្ណោះ។ ចំណែកពួកយុវជនវិញ អង្គការជម្លៀសឲ្យទៅធ្វើស្រែនៅភ្នំស្រុក ខាងជើងខេត្តបាត់ដំបង រហូតដល់ឆ្នាំ ១៩៧៩ ។

នៅឆ្នាំ ១៩៧៧ គឺពេល ប៉ុល ពត និងតាម៉ុក ឡើងកាន់អំណាច អង្គការចោទគ្រីស្តបរិស័ទជាថ្មីម្តងទៀតថា "*អ្នកកាន់សាសនាវៀតណាម*"។ សោ ភឹម ដែលជាគណៈភូមិភាគបូព៌ា បានធានារាប់រងលើគ្រីស្តបរិស័ទទាំងនោះ ហើយនាំពួកគេទៅនៅបារាំងស្នងការ ស្ថិតនៅមិនឆ្ងាយប៉ុន្មានខាងកើតភូមិចាស់។

ប៉ុន្តែនៅឆ្នាំ ១៩៧៨ អង្គការរកសម្លាប់ក្រុម សោ ភឹម។ លោក សោ ភឹម បានធ្វើអត្តឃាត ហើយកូនចៅរបស់គាត់ត្រូវអង្គការដេញចាប់។ កម្មាភិបាលដែលស្មោះត្រង់នឹងប៉ុល ពត បានចាប់គ្រីស្តបរស័ទដើម្បីសួរចម្លើយ។ ភូមិមាត់ក្រសាស់ក្លាយទៅជាមន្ទីរសន្តិសុខ ពោលគឺកន្លែងឃុំឃាំងនិងប្រហារជីវិត។

ស្រីម្នាក់នៅភូមិមាត់ក្រសាស់រ៉ាយរ៉ាប់ថា៖

> *«គេវាយសួរចម្លើយនាងខ្ញុំអស់រយៈពេលជាងបីខែ។ ពួកគេចោទនាងខ្ញុំថា ជាយួន។ ពួកគេសុំឲ្យនាងខ្ញុំសូត្រធម៌។ ខ្ញុំសូត្រធម៌ "ឱព្រះបិតា" ជាភាសាខ្មែរ។ ពួកគេមិនព្រមជឿខ្ញុំទេ គេដកសម្លៀកបំពាក់ខ្ញុំចេញហើយវាយដំទៀត។ ខ្ញុំប្រាប់ពួកគេថា៖ "មិត្តចង់សម្លាប់ខ្ញុំ ក៏សម្លាប់ចុះ តែខ្ញុំមិនមែនយួន ទេ! ខ្ញុំខ្មែរ! ខ្ញុំខ្មែរ!"។ ពួកគេសួរខ្ញុំថា៖ "មិត្តឯងលាក់ព្រះរបស់មិត្តឯងនៅឯណា?"។ ខ្ញុំឆ្លើយថា៖ "ខ្ញុំគ្មានរូបព្រះទេ! ខ្ញុំបានលាក់ព្រះរបស់ខ្ញុំនៅក្នុងចិត្តតែប៉ុណ្ណោះ"។ ពួកគេនាំខ្ញុំទៅជីករណ្តៅពេលនោះខ្ញុំអធិដ្ឋានថា៖ "ឱព្រះអម្ចាស់អើយ! សូមលើកលែងទោសរំដោះបាបឲ្យខ្ញុំផង"។ រួចពួកគេនាំខ្ញុំត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ហើយបីថ្ងៃម្តងៗពួកគេមកសួរចម្លើយខ្ញុំ។ បន្ទាប់មកពួកគេនាំប្តីខ្ញុំយកទៅ។ ចាប់ពីពេលនោះមក ខ្ញុំមិនដែលបានឃើញប្តីខ្ញុំទៀតទេ។ ក្រោយមក ពួកគេនាំខ្ញុំទៅឃុំឃាំងនៅវត្តស្វាយ។ នៅទីនោះ ពួកគេនៅតែសួរខ្ញុំដដែលៗថា៖ "មិត្តជាគ្រីស្តបរិស័ទតាំងពេលណាមក?" ខ្ញុំឆ្លើយថា៖ "តាំងពីជីដូន ជីតា ជីទួត ជីលួត ជីលា មក ពួកយើងកាន់សាសនានេះ"។ ពួកគេតបថា៖ "មិត្តឯងឆ្កួតឬបានជាចូលសាសនាយួនដូច្នេះ? ម្តេចក៏មិនកាន់សាសនាខ្មែរ?"*

នាងជាប់ឃុំឃាំងនៅបារាំងស្នងការអស់រយៈពេលជាច្រើនខែ ហើយកូននាងពីរនាក់ស្លាប់នៅក្នុងមន្ទីរឃុំឃាំងនោះ។ ពួកខ្មែរក្រហមដោះលែងនាងប៉ុន្មានខែមុនពេលកងទ័ពវៀតណាមចូលកាន់កាប់ប្រទេសកម្ពុជា។

មានគ្រួសារគ្រីស្ទបរិស័ទ ១២ គ្រួសារនៅភូមិនោះ ត្រូវពួកខ្មែរក្រហមសម្លាប់ចោល។ នាងរ៉ាយរ៉ាប់ថា៖

*«ខ្មែរក្រហមបានឆ្កាងពួកគេ រួចគេយកកណ្តៀងវះពោះពួកគេ យកថ្លើមប្រមាត់ រួចហើយយកសពទៅចោលក្នុងរណ្តៅ ជិតផ្ទះឡូវ៉េ។ ពួកគេចោទអ្នកទាំងនោះថា "ចូលសាសនាយួន" ។*

**«កូនជាទីស្រឡាញ់របស់ព្រះជាម្ចាស់»**

នៅតំបន់ផ្សេងៗ ជាពិសេសក្នុងខេត្តបាត់ដំបង ខ្មែរក្រហមមិនធ្វើបាបគ្រីស្តបរិស័ទខ្លាំងទេ។ ពួកគេមិនតាមដាន ឬធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ខ្លាំងជាងអ្នកឯទៀតៗនោះឡើយ ។ គ្រីស្តបរិស័ទរស់នៅដូចគេដូចឯង ប្រៀបដូចមេនៅក្នុងម្សៅ។ ពួកគេរស់នៅឯកោពីគ្នា ពុំអាចជួបជុំគ្នាអធិដ្ឋាន ឬអានព្រះគម្ពីរជាមួយគ្នាបានឡើយ។ គ្រីស្តបរិស័ទស្រីម្នាក់រ៉ាយរ៉ាប់ថា៖

*«ថ្ងៃអាទិត្យ យើងពុំអាចជួបជុំគ្នាអធិដ្ឋានបានទេ ប៉ុន្តែ យើងម្នាក់ៗអធិដ្ឋានរៀងៗខ្លួនក្នុងពោះ។ ទោះបីយប់ក៏យើងមិនអាចសូត្រខ្សឹបបានដែរ សូម្បីតែចង្កៀងក៏អុជមិនបានផង»។*

*ថ្ងៃមួយជាថ្ងៃអាទិត្យ ជាថ្ងៃបុណ្យធំ នាងខ្ញុំនឹកថា មុននឹងចេញទៅធ្វើការ ខ្ញុំក្រោកពីយប់មិនឲ្យកូនឃើញទេ ជួនកាលខ្លាចកូនឃើញវាទៅប្រាប់គេ ហើយគេយកយើងទៅធ្វើបាប។ នៅថ្ងៃអាទិត្យ ដឹងថាថ្ងៃហ្នឹងជាថ្ងៃអាទិត្យហើយ ខ្ញុំក្រោកពីយប់ឡើងអធិដ្ឋានរួចទៅធ្វើការ។ ដល់ថ្ងៃត្រង់នាំគ្នាអធិដ្ឋានទៀត។ ជួនកាលពេលសម្រាក ឈប់សម្រាកបានបន្តិច នាំកូនទៅកន្លែងស្ងាត់ក្នុងព្រៃក្បែរគុម្ពស្មៅធំ លុតជង្គង់ឬឈរឱបដៃ។ ជួនកាលនៅផ្ទះ យប់ឡើងមកពីធ្វើការអស់កម្លាំងពេក នាំប្តីប្រពន្ធអធិដ្ឋាន ហើយមានម្តង ដល់សូត្រៗទៅកូនឃើញវាទៅប្រាប់គេ។ ពេលនោះគេរករឿងខ្ញុំ ប៊ីសយកខ្ញុំទៅសម្លាប់ គេថាខ្ញុំហ្នឹងអត់ចោលព្រះ នៅតែមានជំនឿជាប់អញ្ចឹង ខ្ញុំថា៖*

*«មានតែព្រះជាម្ចាស់ទេ ដែលមានសេចក្តីស្រឡាញ់ រកយុត្តិធម៌ឲ្យមនុស្ស ព្រះអង្គស្រឡាញ់មនុស្សទាំងអស់ដោយគ្មានរើសមុខ ទ្រង់បានបង្កើតមនុស្ស ខ្ញុំ*

*មិនអាចចោលព្រះអង្គបានទេ ខ្ញុំសុខចិត្តស្លាប់ ទោះបីលំបាកវេទនាយ៉ាងណា ឬគេធ្វើបាបយ៉ាងណាក៏ដោយក៏ខ្ញុំសុខចិត្តស្លាប់ដែរ ខ្ញុំនៅថៃរក្សាជំនឿហ្នឹងរហូត»។*

ប្ដីនាងបញ្ឆោតខ្មែរក្រហមដូចទៅ៖

*«នៅពេលខ្លះ ដែលខ្ញុំមិនអាចអធិដ្ឋានបាន ខ្ញុំបានចាប៉ីដងវែងមួយ ខ្ញុំដេញបទបដិវត្តន៍មុន រួចខ្ញុំដេញបទសម្រាប់ព្រះវិហារ "ឱមេឃស្ងាត់សូន្យ"។ យើងអត់ហ៊ានសូត្រធម៌ទេ ដល់ដេញបទហ្នឹង ពួកគេអត់ចេះស្ដាប់ អត់ដឹងថាជាបទអ្វីទេ»។*

នាងនោះរ៉ាយរ៉ាប់បន្តទៀតថា៖

*«នៅពេលវាបង្ខំឲ្យធ្វើការ ខ្ញុំនឹកព្រះយេស៊ូខ្លាំងជាងគេ។ ពេលវាបង្អត់ខ្លាំង ពេលធ្វើការខ្លាំង ពេលហ្នឹងហើយដែលខ្ញុំនឹកព្រះអង្គ។ វេទនាខ្លាំង ទើបនឹងដល់ព្រះយេស៊ូ។ រាត្រីថ្ងៃបុណ្យណូអែល ឆ្នាំ ១៩៧៥ ខ្ញុំនឹកដល់ព្រះយេស៊ូហើយយំផងអធិដ្ឋានផង ក្រោយពេលអធិដ្ឋានរួច ដូចជាសប្បាយក្នុងចិត្ត រួចគិតថាជីវិតកើតមកតែងតែជួបទុក្ខវេទនាអញ្ចឹង នឹកឃើញធម្មតា ធ្វើការដូចជាមានកម្លាំងឡើងវិញ ដូចជាព្រះវិញ្ញាណ មកជួយកម្លាំងខ្ញុំម្យ៉ាងដែរ។ ខ្ញុំតែងនឹកសង្ឃឹមអញ្ចឹង។ ជួយកាល កាប់ៗទៅលុតជង្គង់ កាប់ដីបណ្ដើរអធិដ្ឋានបណ្ដើរ "ឱព្រះបិតាអើយ! ការកូនធ្វើទាំងអម្បាលម៉ាន ព្រះអង្គយល់ទុក្ខលំបាកកូនអស់ហើយ! វេទនាណាស់! ឈើឆ្កាងដែលព្រះអង្គឲ្យលីអញ្ចឹង ធ្ងន់ធ្ងរពេក»។*

*ខ្ញុំបង្ហាត់កូនឲ្យចាំធម៌ខ្លះ។ ថ្ងៃមួយវាលុតជង្គង់សូត្រប្រាប់យាយៗ។ យាយៗសួរថា៖ "អ្នកណាបង្រៀនឯងឲ្យធ្វើអញ្ចឹង?"។ វាឆ្លើយថា៖ "ម៉ាក់ខ្ញុំ ខ្ញុំឃើញម៉ាក់ខ្ញុំសូត្រធម៌ គាត់នឹកព្រះយេស៊ូ។ ម៉ាក់ ទូន្មានខ្ញុំឲ្យស្រឡាញ់គេ ឲ្យធ្វើចិត្តល្អនឹងគេ មានអ្វីញ៉ាំ ឲ្យចែកគេញ៉ាំផង"។ យាយតបថា៖ "ហ៊ឺ! ម៉ាក់ឯងនៅជឿអញ្ចឹងទៀត កុំធ្វើតាមម៉ាក់ឯង ម៉ាក់ឯងតិចគេយកទៅវាយចោល"។ ខ្ញុំអធិដ្ឋាននៅពេលយប់ជួនកាលងើបពីយប់អធិដ្ឋានកុំឲ្យវាឃើញ។ ខ្ញុំតែងប្រាប់កូនខ្ញុំថា៖ "នែ៎ កូនឯងកុំភ្លេចព្រះជាម្ចាស់អីណ៎ា" ពន្យល់ប្រាប់វាអញ្ចឹងឲ្យវាបានពន្លឺ និងឲ្យវាអធិដ្ឋានទៅ។*

*ក្នុងសាលាគេសួរខ្ញុំថា៖ "ម៉ែឯងនៅផ្ទះមានធ្វើអីទេ?" វាប្រាប់ថា៖ "ម៉ែខ្ញុំថ្វាយបង្គំព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ"។ តាំងពីពេលនោះមក គេរករឿងខ្ញុំ គេគំរាមខ្ញុំថា៖ "កុំធ្វើអញ្ចឹងទៀត គេជម្រុះចោលហើយ ម្ដេចក៏អ្នកឯងមិនជម្រុះ មិនព្រមតាម*

មាគ៌ាបដិវត្តន៍? តើចង់នៅសេរីដល់ណាទៀត? អត់ជម្រុះតាមគេហ្នឹង ប្រយ័ត្នគេហៅកសាងទៀត!"។

ពួកវាថា "សាសនាអាចក្រព័ត្រ" "សាសនាប្រតិកិរិយា" មិនមែនសាសនាព្រះជាម្ចាស់ទេ គ្មានព្រះស្អីទេ ពួកវាស្តីឲ្យដូចឆ្កែអញ្ចឹង។ គេដៀលសាសនា គេថា សាសនា មិនមែនល្អទេ នាំឲ្យមនុស្សខូច មកពីមនុស្សជឿសាសនាបានជាមនុស្សឆ្កួតអស់។ គេថាសាសនាយើង ជាសាសនាអាចក្រព័ត្រ។ ពួកវាខឹងនឹងខ្ញុំណាស់ វាថាខ្ញុំជាមនុស្សសក្តិភូមិ កាលណាវាដើរជួបខ្ញុំ វាថាខ្ញុំជាមនុស្សក្បត់ជាតិបម្រើបរទេស វាថាសាសនាកាតូលិកនេះមិនមែនសាសនាខ្មែរទេ ជាសាសនាបារាំង វាចោទប្រកាន់ខ្ញុំយ៉ាងធ្ងន់។ ទោះបីវាត្មេះតិះដៀលខ្ញុំធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅស្ងៀមក្នុងចិត្តឥតជ្រួលច្របល់ ជាពិសេសខ្ញុំរឹតតែសង្ឃឹមឡើង ដោយព្រះយេស៊ូរងទុក្ខលំបាក ព្រោះតែសេចក្តីស្រឡាញ់របស់ព្រះអង្គ ពេលណាខ្ញុំគិតដល់ព្រះយេស៊ូ ខ្ញុំក៏សោយចិត្តទៅ ការអស់សង្ឃឹមរបស់ខ្ញុំក្លាយទៅជាមានសង្ឃឹម និងមានជីវិតរស់ឡើងវិញ ខ្ញុំហាក់ដូចជាកើតជាថ្មី។ នេះជាមូលហេតុមួយបញ្ជាក់ឲ្យដឹងថា ព្រះអង្គជួយខ្ញុំមែន ជំនឿរបស់ខ្ញុំរឹតតែចម្រើនឡើងរហូតមកដល់សព្វថ្ងៃនេះ។

ខ្ញុំបានពន្យល់ឲ្យកម្មាភិបាល ដែលស្តីឲ្យខ្ញុំថា៖ "សាសនាកាតូលិកនៅប្រទេសណាក៏មានដែរ ជាសាសនាសកលលោក មិនមែនមានតែប្រទេសខ្មែរទេ មិនមែនសាសនាបារាំងទេ គឺនៅប្រទេសណាក៏មានសាសនាកាតូលិកដែរ"។ វាស្រែកឲ្យខ្ញុំថា៖ "ឯងកុំចេះប្រដៅអី!" ។

យើងមិនអាចជួបគ្នាបានទេ យើងគ្មានព្រះគម្ពីរ យើងមិនបង្រៀនធម៌ យើងដូចជាពិបាកអប់រំកូន។

ជារឿយៗ ខ្ញុំតែងនិយាយពីព្រះជាម្ចាស់ឲ្យយាយៗ ដែលនៅមើលកូនក្មេង ស្តាប់ដល់និយាយយូរៗទៅ ពួកគាត់ទន់ចិត្តដូចព្រះជាម្ចាស់បំភ្លឺគាត់។ យាយម្នាក់ប្រាប់ខ្ញុំថា៖ «ធ្វើម្តេចក៏ធ្វើទៅ កុំឲ្យតែកូនឯងដឹង វរៗវាទៅប្រាប់ប្រធានគេរករឿង»។ គេក៏អត់ធ្វើអ្វីខ្ញុំដែរ ហើយឆ្លៀតឱកាសហ្នឹង ខ្ញុំនិយាយម្តងបន្តិចៗឲ្យយាយៗស្តាប់ គាត់ក៏ចូលចិត្តខ្ញុំតាំងពីពេលនោះមក។ គាត់ថា៖ "មិនដែលមានអ្នកណានិយាយពិរោះដូចកូនឯងទេ"។ គាត់ដូចជាមានចិត្តជឿអញ្ចឹងដែរ។ ខ្ញុំពន្យល់តាមរបៀបដូចខ្ញុំធ្លាប់បង្រៀនអំពីព្រះយេស៊ូ គាត់ស្តាប់ខ្ញុំ។ រាល់ថ្ងៃអាទិត្យ

*គាត់ចេះនឹកដល់ព្រះយេស៊ូ ចេះធូរចិត្តដែរ ខ្ញុំថានេះមកពីព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដែលប្រទានឲ្យ"។ ខ្ញុំប្រាប់យាយៗថា៖ "មនុស្សយើងកុំអស់សង្ឃឹម ព្រះជាម្ចាស់បង្កើតយើងមក ឲ្យយើងមានជីវិតដូច្នេះ ជីវិតយើងថ្លៃថ្នូរណាស់ យើងត្រូវតស៊ូគ្រប់បែបយ៉ាង យើងមានសម្បត្តិសួគ៌មួយ"។ ខ្ញុំពន្យល់គាត់សព្វគ្រប់ គាត់ថា៖"ហ៊ឺ! ធ្វើដូចគ្រូឯងក៏ម្យ៉ាងដែរ ដូច្នេះ បើស្លាប់ទៅ ខ្ញុំក៏គ្មានស្ដាយអ្វីដែរ"។ ខ្ញុំថា៖"បើវាត្រូវការសម្លាប់យើង យើងបូជាជីវិតថ្វាយព្រះជាម្ចាស់ទៅ យើងមិនមែនរស់នៅរហូតទេ។ ព្រះអង្គប្រទានឲ្យយើងកើតមក គឺឲ្យយើងស្លាប់ដែរ តែបំណងបើស្លាប់ យើងសុខចិត្តស្លាប់ក្នុងស្នាព្រះហស្តព្រះជាម្ចាស់ចុះ!"។*

**នាងសុភាពបន្តថែមថា៖**

*«ពេលនៅបែកពីឪពុកម្ដាយ ពីពួកលោក គឺខ្ញុំចេះភ័យ ចេះខ្លាច ចេះផ្ញើជីវិតទាំងស្រុងលើព្រះម្ចាស់។ ពេលខ្ញុំធ្វើការ ខ្ញុំតែងផ្ញើកិច្ចការដែលខ្ញុំកំពុងធ្វើទៅព្រះអង្គ សូមព្រះអង្គឲ្យខ្ញុំបានស្គាល់ក្នុងព្រះអង្គ។ ពេលយាមយប់ ខ្ញុំសូត្រផ្គាំរហូតដល់ផុតម៉ោងយាម (លោកប៉ែរ ណា បានឲ្យផ្គាំធ្វើអំពីដែកតូចមួលខ្ញុំដាក់តាមខ្លួនជាប់ជានិច្ច)។ ដូច្នេះហើយ ទើបព្រះអង្គថែរក្សាខ្ញុំ មិនឲ្យខ្ញុំឃើញភាពតក់ស្លុត ភ័យខ្លាចនៅចំពោះមុខដូចអ្នកដទៃទៀត ឧទាហរណ៍ ពេលកំពុងយាមអង្គការចូលមកហៅមិត្តជិត ខាងយកទៅសម្លាប់ ធ្វើឲ្យអ្នកដែលកំពុងយាម មានការភ័យតក់ស្លុតយ៉ាងខ្លាំង។*

*នៅក្នុងកងចល័តនារី នារីភៀសសឹកទាំងអស់ទុកចិត្តលើខ្ញុំគ្រប់គ្នា ព្រោះខ្ញុំមានអាយុច្រើនជាងគេ ទោះពេលដេកក្តី ពេលសម្រាកក្តី នារីទាំងនោះតែងមកជិតខ្ញុំ ស្តាប់ការទូន្មានរបស់ខ្ញុំ ហើយពេលទៅណាមកណាគេតែងសួរយោបល់ពីខ្ញុំជានិច្ច។ ឪពុកម្ដាយនារីទាំងនោះ តែងផ្ដាំផ្ញើឲ្យខ្ញុំជួយមើលការ ខុសត្រូវចំពោះកូនគេដែរ ដូច្នេះ ខ្ញុំក្លាយទៅជាបងស្រីនារីទាំងនោះដោយមិនដឹងខ្លួន។ ទិដ្ឋភាពទាំងនេះ មិនកំបាំងពីភ្នែកប្រធានក្រុម ប្រធានកង និងប្រធានភូមិឈ្មោះ ព័ន្ធឡើយ តែពួកវារកកំហុសពួកខ្ញុំមិនឃើញ។ ពេលក្រុមចល័តនារីធ្វើការ ប្រធានភូមិ ព័ន្ធ ចូលរួមធ្វើការជាមួយជាគំរូ វាច្រើនធ្វើជិតក្បែរខ្ញុំ និងក្រុមនារីភៀសសឹក វាចង់និយាយលេងច្រើនជាមួយក្រុមនារី តែភាពនឹងនរនិងការរាប់អានរបស់ក្រុមនារីទាំងនោះចំពោះរូបខ្ញុំ បានធ្វើឲ្យវាអាក់អន់ចិត្ត។ ក្នុងអង្គប្រជុំ អង្គការបាន*

*ប្រកាសឲ្យចល័តនារីឈប់បីថ្ងៃ ទៅផ្ទះជួយដាំដំណាំឲ្យឪពុកម្ដាយតែចំពោះរូបខ្ញុំវិញ វាមិនឲ្យឈប់ទេ វាឲ្យទៅស្ទូងស្រែជម្រៅដែលមានទឹកត្រឹមទ្រូង ហើយសម្បូរឈ្លើងទៀតផង ចំណែកក្មួយស្រីខ្ញុំពីរនាក់ទៀត វាឲ្យទៅផ្ទះ។*

*មានពេលមួយនោះ អង្គការបានចាត់ខ្ញុំឲ្យទៅធ្វើការ នៅវាលក្រោមបីខែ ឆ្ងាយពីឪពុកម្ដាយ។ ធ្វើការកណ្ដាលវាលកណ្ដាលថ្ងៃ ខ្ញុំឡើងខ្មៅដូចក្អែក តែខ្ញុំមានសេរីភាពថ្វាយបង្គំព្រះជាម្ចាស់បានច្រើន ព្រោះក្រុមច្រូតស្រូវមានគ្នាតែប្រាំនាក់ប៉ុណ្ណោះ។ ពេលច្រូតយើងនៅដាច់ឆ្ងាយពីគ្នា ហៅគ្នាមិនឮ ដូច្នេះខ្ញុំស្រែកច្រៀងទំនុកតម្កើង កោតសរសើរព្រះជាម្ចាស់យ៉ាងសប្បាយរីករាយ "សិរីយស" បទ "អរុណរះ" និងបទ "ព្រះអង្គជាគង្វាល" ទោះបីជាខ្ញុំចាំមិនគ្រប់ទាំងអស់ក៏ដោយ ក៏ខ្ញុំច្រៀងនូវផ្នែកណា ដែលខ្ញុំចាំយ៉ាងរីករាយជាមួយព្រះអង្គដែរ»។*

វុឌ្ឍី ជាក្មេងប្រុសម្នាក់អាយុជាង ១០ ឆ្នាំ។ ក្មេងនេះចេះតែសូត្រធំ "*សូមក្រាបសំពះ* " និងធម៌"*ឱព្រះបិតា* " ជារៀងរាល់យប់ក្នុងមន្ទីរកុមារ។ វុឌ្ឍីនិយាយថា៖

*«ខ្ញុំយកដៃខ្ទប់មាត់កុំឲ្យនរណាឃើញ។ ខ្ញុំនឹកថា ប្រសិនបើខ្ញុំមិនសូត្រធម៌ទាំងពីរនេះជារៀងរាល់ថ្ងៃដូច្នេះទេ ខ្ញុំមុខជាភ្លេចពុំខាន ហើយក្រោយមកគ្មាននរណាបង្រៀនខ្ញុំជាថ្មីទៀតបានឡើយ»។*

គ្រីស្តបរិស័ទស្ត្រីម្នាក់ទៀតនិយាយថា៖

*«ក្នុងសម័យ ប៉ុល ពត ជំនឿរបស់ខ្ញុំមិនអន់ថយទេ គឺរឹតតែមានជំនឿខ្លាំងឡើង ដោយសារការរងទុក្ខវេទនា ជំនឿរឹតតែមានច្រើនឡើង ដូចជាភ្លឺ ដូចជាភ្លឺយល់ទៅមុខទៀត ចម្រើនឡើងដោយខ្ញុំពន្យល់គេក្នុងពេលគេរងទុក្ខវេទនាបំភ្លឺគេឲ្យមានសង្ឃឹម។*

*កាលដែលមិនទាន់វេទនា ដូចជាមិនសូវជឿប៉ុន្មានទេ ដូចជាមិនចាប់ចិត្តចាប់អារម្មណ៍ប៉ុន្មានទេ ជឿតាមតែគេទៅ។ ដល់រងទុក្ខវេទនាបានជឿសង្ឃឹមយ៉ាងមាំដូចជាចាក់ឫសចូលទៅក្នុងយ៉ាងជ្រៅ មិនអាចរលំបាន សង្ឃឹមរឹតតែទ្វេឡើងថែមទៀត។ វេទនាអញ្ចឹង ខ្ញុំមិនដែលដាក់ទោសព្រះអង្គទេ គឺ ដាក់ទោសលើអ្នកកាន់កាប់ប្រទេស មកពីអ្នកដឹកនាំពុករលួយភ្លីភ្លើពេក បានជានគរត្រូវដុនដាបតោកយាកវេទនាដល់ថ្នាក់ដូច្នេះ។ ខ្ញុំនឹកថា យើងពិតជាកូនដ៏ជាទីស្រឡាញ់របស់ព្រះបិតា ព្រោះទ្រង់ប្រោសប្រណី ប្រទានឲ្យយើងរងទុក្ខវេទនា*

*ដូចព្រះបុត្រារបស់ព្រះអង្គដែរ។*

*កាលណាយើងរងទុក្ខវេទនាខ្លាំង យើងនឹកឃើញដល់ព្រះយេស៊ូដែលរងទុក្ខវេទនាដែរ ហើយយើងសុខចិត្តលះបង់រួមទុក្ខវេទនាជាមួយព្រះអង្គ ទោះបីគេធ្វើបាបយ៉ាងណា ក៏សុខចិត្តទ្រាំទ្រដូចព្រះយេស៊ូដែរ។*

*ក្នុងសម័យនោះ យើងគ្មានគម្ពីរទេ តែខ្ញុំនៅចាំព្រះបន្ទូលខ្លះៗដូចជា៖ "ខ្ញុំជាប្រភពនៃជីវិតសម្រាប់អ្នករាល់គ្នា" "ខ្ញុំជាពន្លឺបំភ្លឺមនុស្សលោក"។ ខ្ញុំថា ព្រះអង្គជាជីវិតជាពន្លឺ ទោះបី វេទនាយ៉ាងណា ក៏មាន ព្រះអង្គជាជីវិតជាពន្លឺដែរ។ "អ្នកណារងទុក្ខវេទនា អ្នកនោះពិតជាមានសុភមង្គល អ្នកណាស្រេកឃ្លាន អ្នកនោះពិតជាមានសុភមង្គល" ក្នុងគម្ពីរខ្ញុំនឹកឃើញកន្លែងហ្នឹងច្រើនជាងគេ។*

*នៅស្រុកខ្មែរ ពេលរងទុក្ខលំបាកខ្ញុំនឹកដែរថា គ្រីស្តបរិស័ទនៅប្រទេសក្រៅៗប្រាកដជាសូមអង្វរ ព្រះជាម្ចាស់ឲ្យយើង ព្រោះមានព្រះសហគមន៍តែមួយគេមិនចោលយើងទេ ទោះជាយ៉ាងណាក៏គេ មិនបំភ្លេចយើងដែរ។*

នៅក្រៅប្រទេស អស់លោកបូជាចារ្យបារាំងជាមិត្តភ័ក្តិ ដែលធ្លាប់រួមរស់នៅជាមួយគ្រីស្តបរិស័ទខ្មែររាប់ ឆ្នាំមកហើយ បានឮសូរសម្រែករបស់គ្រីស្តបរិស័ទនិងរបស់ប្រជាជនខ្មែរដែលត្រូវខ្មែរក្រហមសម្លាប់រង្គាល។ មានតែបូជាចារ្យបារាំងទាំងនោះទេ ដែលបានបន្លឺសម្លេង និងសរសេរសៀវភៅ ដើម្បីជម្រាបមតិអន្តរជាតិឲ្យដឹងឮអំពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ប៉ុន្តែ គ្មាននរណាជឿអស់លោកទេ។

អង្គការបានសម្លាប់អ្នកទទួលខុសត្រូវក្នុងព្រះសហគមន៍កាតូលិកទាំងអស់ ព្រមទាំងគ្រូគង្វាល ១១ នាក់នៃក្រុមជំនុំដំណឹងល្អ។ វិហារទាំងប៉ុន្មានត្រូវខ្មែរក្រហមកម្ទេចចោល។ អង្គការបានបំផ្លាញវិសាលវិហារ ដ៏ធំធេងចោល ដោយដាក់គ្រាប់រំសេវផ្ទុះ។ ខ្មែរក្រហមបានប្រើនិស្សិតដែលត្រឡប់ពីស្រុកបារាំង ឲ្យវាយបំបែកផ្ទាំងថ្មទាំងនោះយកសរសៃដែកទៅធ្វើដែកគោល។ កម្ទេចថ្មនិងគ្រួស ពួកគេជញ្ជូនយកទៅដាក់ក្នុងស្រះក្បែរនោះ ឬយកទៅប្រើប្រាស់សម្រាប់កសាងទំនប់ទឹក។ កន្លែងដែលមានវិហារ "ព្រះបេះដូង" នៅកណ្ដាលក្រុងភ្នំពេញក្លាយទៅជាកន្លែងដាំដូងទៅវិញ។

នៅបាត់ដំបង ក៏ដូចជានៅភូមិព្រះមាតានាក្រុងភ្នំពេញដែរ មិនត្រឹមតែវិសាលទេ ដែលត្រូវកម្ទេចចោលនោះ សូម្បីតែទឹកលានបញ្ចុះសព ក៏គេបញ្ចុះសព ក៏គេឈូសចោលដែរ។

គ្រីស្ដបរិស័ទម្នាក់សរសេរថា៖

*«ខ្មែរក្រហមបានកម្ទេចព្រះវិហារយើងចោលអស់ វិហារធំនៅភ្នំពេញត្រូវរុះរើខ្ទេចហើយគេយកកន្លែងនោះដាំចេកដាំល្ពុង។ល។ តែពួកវាមិនអាចកម្ទេចជំនឿយើងបានឡើយ។ យើងបានកាន់ជំនឿយ៉ាងមាំមួន យើងក៏សង្ឃឹមលើព្រះជាម្ចាស់ជានិច្ច។ ម្នាក់ៗធ្វើពិធីបុណ្យទាំងឡាយ ក្នុងជម្រៅចិត្តរបស់ខ្លួនទាំងរងទុក្ខវេទនាឈឺចាប់បំផុត»។*

---

(១) លោក រស់ អេន ជាអ្នកទទួលបន្ទុកគ្រីស្ដបរិស័ទ នៅជ្រោយចង្វារ។

# ជំពូកទី ១៨

# ជនរងគ្រោះដោយបដិវត្តន៍

រដ្ឋាភិបាលវៀតណាមរៀបចំកងទ័ពរបស់ខ្លួនអស់រយៈពេលជាងមួយឆ្នាំ ដើម្បីវាយលុកប្រទេសកម្ពុជា។ កាលបានរៀបចំសព្វគ្រប់ហើយ ទាំងផ្លូវយោធា ទាំងផ្លូវនយោបាយ កងទ័ពវៀតណាមក៏វាយលុកចូលប្រទេសកម្ពុជា នៅថ្ងៃបុណ្យណូអែលឆ្នាំ ១៩៧៨។ ពួកវៀតណាមវាយកងទ័ពប៉ុល ពត ឲ្យបាក់ទ័ពខ្ចាត់ខ្ចាយ។ នៅថ្ងៃទី ៧ មករា ឆ្នាំ ១៩៧៩ ពួកគេបង្កើត "*សាធារណរដ្ឋប្រជាមានិតកម្ពុជា* " នៅទីក្រុងភ្នំពេញ ដែលមានលោក ហេង សំរិន ជាអ្នកដឹកនាំ។

ពួកបស្ចិមប្រទេសមានការភ្ញាក់ផ្អើលជាខ្លាំង ចំពោះសង្គ្រាមលើកទីមួយរវាងប្រទេសកុម្មុយនិស្តទាំងពីរនេះ ថ្វីបើមានអ្នកសង្កេតការខ្លះបានដឹងថា កងទ័ពខ្មែរក្រហមបានប៉ះទង្គិចជាមួយកងទ័ពវៀតណាមតាំងពីឆ្នាំ ១៩៧៥ មកម្ល៉េះក៏ដោយ។

នៅឆ្នាំ ១៩៧៥ បន្ទាប់ពីបានកាន់កាប់ប្រទេសទាំងមូលមក ខ្មែរក្រហមខិតខំវាយយកកម្ពុជាក្រោមវិញ។ ចំណែកប្រទេសវៀតណាម តាំងពីច្រើនសតវត្សមកហើយ គេក៏ចង់លាតសន្ធឹងឥទ្ធិពលរបស់ខ្លួនមកលើប្រទេសកម្ពុជា និងមកលើប្រទេសលាវដែរ ហើយវៀតណាមក៏ខិតខំបង្កើត "*ទំនាក់ទំនងពិសេស* " ជាមួយប្រទេសជិតខាងទាំងពីរនេះដែរ។ ប្រទេសចិនយល់ថា ប្រទេសគេស្ថិតនៅក្នុងដង្កៀប (សហភាពសូវៀតនៅខាងជើងនិងប្រទេសវៀតណាម"*តាំទ្រដោយសូវៀត* " នៅខាងត្បូង) ដូច្នេះ គេក៏ជួយខ្មែរក្រហមយ៉ាងសកម្ម ដើម្បីទប់ទល់នឹងឥទ្ធិពលរបស់សូវៀតនៅក្នុងភូមិភាគនេះ។

កងទ័ពខ្មែរក្រហមបានវាយប្រហារវៀតណាមជាច្រើនដងមកហើយ។ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ កងទ័ពវៀតណាមវាយលុកចូលប្រទេសកម្ពុជា ហើយមួយអាទិត្យ

ក្រោយមក គេក៏ដកថយចេញទៅវិញ ដោយមានប្រជាជនខ្មែរប្រមាណ ៣០០.០០០ នាក់ទៅជាមួយផង។ ពួកខ្មែរក្រហមបានចោទវៀតណាមថា ចូលមក "*ប្លន់*" យកប្រជាជនខ្មែរ រីឯវៀតណាមវិញបានប្រកាសថា គេបាន "*រំដោះ*" ប្រជាជនទាំងនោះ។ នៅថ្ងៃទី ៣ ឆ្នាំ ១៩៧៨ ខ្មែរមួយចំនួនដែលបានភៀសខ្លួនចូលប្រទេសវៀតណាមប្រកាសថា គេបង្កើត "*រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា*" ហើយពួកគេបានសុំកងទ័ពវៀតណាមឲ្យជួយ "*រំដោះ*" ប្រទេសកម្ពុជា។ ក្នុងចំណោមខ្មែរទាំងនោះ មានលោកហេងសំរិននិងកុម្មាភិបាលខ្មែរក្រហមនៅតំបន់បូព៌ាមួយចំនួន ដែលរត់ចោល ប៉ុល ពត។

សម្តេច សីហនុ បានចាកចេញពីក្រុងប៉េកាំងនៅដំណាច់ឆ្នាំ ១៩៧៥ ត្រឡប់ចូលក្រុងភ្នំពេញនិងរស់នៅក្រោមការត្រួតពិនិត្យរបស់ខ្មែរក្រហមចំនួនបីឆ្នាំ។ មុនកងទ័ពវៀតណាមដណ្តើមយកក្រុងភ្នំពេញបាន រដ្ឋាភិបាលចិនចាត់យន្តហោះមួយមកទទួលព្រះអង្គដើម្បីឲ្យទៅតវ៉ា និងការពាររបបខ្មែរក្រហម នៅមុខសភាអង្គការសហប្រជាតិ។

នៅខែកុម្ភៈ ឆ្នាំ ១៩៧៥ ប្រទេសចិនសម្រេចចិត្តបង្រៀន"*មេរៀន*" មួយ ឲ្យប្រទេសវៀតណាមដោយឲ្យយោធាចិនវាយលុកចូលតំបន់ខាងជើងប្រទេសវៀតណាម។

ក្រោយមករដ្ឋាភិបាលចិនខិតខំធ្វើឲ្យពិភពលោកទាំងមូល ថ្កោលទោសប្រទេសវៀតណាមដែលបាន "*ឈ្លានពាន*" ប្រទេសកម្ពុជា។ តាំងពីពេលនោះមក ជំនួយសេដ្ឋកិច្ចដែលវៀតណាមធ្លាប់បានទទួល ត្រូវកាត់ផ្តាច់ទម្រាំវៀតណាមដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា។ ក្នុងពេលជាមួយនេះ កងទ័ពវៀតណាមបានវាយរុញច្រានកងទ័ព ប៉ុល ពត បន្តិចម្តងៗ ឲ្យទៅនៅតាមតំបន់ព្រៃភ្នំជាប់ព្រំប្រទល់ខ្មែរ-ថៃ។ រដ្ឋអំណាចថ្មីអនុញ្ញាតប្រជាជនខ្មែរ ដែលពួកខ្មែរក្រហមបានជម្លៀសចេញពីភូមិស្រុកកាលពីគ្រាមុនឲ្យត្រឡប់ទៅនៅភូមិស្រុករបស់ខ្លួនវិញ។ បន្តិចម្តងៗគេរស់នៅជាធម្មតាឡើងវិញ។

បន្ទាប់ពីការ "*ធូរស្រាលបន្តិច*" នេះ ប្រជាជនខ្មែរជាច្រើនយល់ថា កងទ័ពវៀតណាមមិនមែនចូលមក "*រំដោះ*" ប្រទេសកម្ពុជា តែគឺមក "*កាន់កាប់ត្រួតត្រា*" ។ ប្រទេសកម្ពុជានៅតែក្រោមរបបកុម្មុយនិស្តដដែល ដូចជារថយន្តមួយដែលគេប្តូរតែអ្នកបើកបរ ហើយអ្វីៗផ្សេងទៀតគ្មានដូរទេ គឺនៅតែក្រហមដដែល។ ក្រៅពីការអាក់អន់ចិត្តតាមផ្នែកនយោបាយនេះ បញ្ហាទុរិក្សបានចោទឡើងថែមទៀត។ ចាប់ពីខែសីហា ១៩៧៩ មក

ប្រជាជនខ្មែរប្រមាណជិតពីរលាននាក់បានឆ្លងមករកស្បៀងអាហារ ដែលអង្គការសហប្រជាជាតិចែកចាយនៅតាមព្រំដែនខ្មែរ-ថៃ។ គេឃើញប្រជាជនខ្មែរបររទេះគោរាប់ពាន់នាក់មកពីគ្រប់ខេត្តទាំងអស់មកដល់ព្រំដែននោះ ហើយគេផ្ទុកស្រូវអង្ករ និងគ្រាប់ពូជផ្សេងៗត្រឡប់ទៅវិញ។ ជំនួយទាំងនេះ បានជួយស្រោចស្រង់ជីវិតប្រជាជនខ្មែរឲ្យផុតពីក្តីស្លាប់ដោយអត់អាហារ។

ប្រជាជនខ្មែរដែលប្រឆាំង នឹងរបបថ្មីនៅភ្នំពេញ តែងតាំងដោយកងទ័ពវៀតណាម បានបង្កើតចលនាតស៊ូបីក្រុម មានពួកខ្មែរក្រហមដែលមានបញ្ជាការយោធានយោបាយដូចពីមុន ហើយមានទីស្នាក់ការនៅក្បែរទល់ដែនថៃ។ មានពួក "*រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ* (FNLPK)" បង្កើតឡើងនៅឆ្នាំ ១៩៧៩ ក្រោមការដឹកនាំរបស់លោក ស៊ឺនសាន ដែលជាអតីតរដ្ឋមន្ត្រីទីមួយរបបសម្តេចសីហនុ។ ចលនាទីបីគឺ "*រណសិរ្សរួបរួមជាតិ ដើម្បីឯករាជ្យអព្យាក្រឹត្យ និងសហប្រតិបត្តិ* (FUNCINPEC)"។ ពួកបស្ចិមប្រទេសរាំរែកមិនព្រមទទួលស្គាល់របប ហេង សំរិន បន្តុបឡើងដោយកងទ័ពវៀតណាម ពួកគេក៏មិនចង់គាំទ្ររបប ប៉ុល ពត ដែរ។ ដូច្នេះ ពួកគេបានបង្ខិតបង្ខំក្រុមខ្មែរតស៊ូទាំងបីក្រុមឲ្យចូលរួមគ្នាបង្កើតជា "រដ្ឋាភិបាល ចម្រុះប្រជាធិបតេយ្យ (GCKD)" ដើម្បីឲ្យអង្គការសហប្រជាជាតិទទួលស្គាល់រដ្ឋាភិបាលនេះតទៅទៀត។

ចាប់ពីឆ្នាំ ១៩៧៥ មក ប្រជាជនខ្មែររាប់សែននាក់បានប្រឆាំងនឹងរបបខ្មែរក្រហម ហើយចាប់ពីឆ្នាំ ១៩៧៩ ពួកគេក៏ប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ប្រជាជនមួយចំនួនធំ ទាំងក្រុមៗ បានរត់ចេញពីរបបខ្មែរក្រហមភៀសខ្លួនចូលទៅប្រទេសថៃ ដើម្បីស្រោចស្រង់ជីវិត។ ក្នុងខែឧសភា ឆ្នាំ ១៩៧៤ អ្នករត់ចូលប្រទេសថៃមុនគេ គឺពួកអ្នករស់នៅតាមជាយដែនខ្មែរ ថៃ។ បន្ទាប់មក មានពួកនាយទាហាន និងអ្នករដ្ឋការជាន់ខ្ពស់នៃរបប លន់ នល់ ដែលបានគេចផុតពីសេចក្តីស្លាប់។ បានពីខែកក្កដាមក អាណិកជនចិន ដែលបាត់បង់របបរកស៊ីរបស់ខ្លួនជាអ្នកជំនួញ បានសម្រេចចិត្តរត់ចេញពីប្រទេសខ្មែរដែរ។ ក្នុងខែមករា ឆ្នាំ ១៩៧៦ មេបញ្ជាការខ្មែរក្រហមចាប់ផ្តើមកម្ទេចវណ្ណៈគ្រូបង្រៀន និស្សិត និងបញ្ញវន្ត។ អ្នកទាំងនេះ ភាគច្រើនបានរួចជីវិតដោយរត់ចេញពីប្រទេសកម្ពុជា។ នៅឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមចាប់ផ្តើមកម្ទេចកសិករ និងទាហានខ្មែរក្រហមខ្លះ។

ចាប់ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៨ ប្រជាជនខ្មែរជិត ៥ ម៉ឺននាក់បានភៀសខ្លួនចូលប្រទេសថៃ ហើយមានប្រជាជនប្រមាណ ៨ ម៉ឺននាក់ទៀតរត់ទៅប្រទេសវៀតណាម។ ប្រជាជនទាំងនេះ បានរ៉ាយរាប់ពីទុក្ខវេទនា និងជីវិតដ៏សែនអាណោចអាធម៌ ដែលពួកគេបានជួបប្រទះ តាំងពីការសម្លាប់រង្គាល រហូតដល់ការបង្ខំឲ្យធ្វើការជាទម្ងន់នោះ។ លោកបូជាចារ្យ វ៉ឺណេ (Venet) ដែលបានរស់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល ៣២ ឆ្នាំ ហើយដែលត្រូវខ្មែរក្រហមដេញចេញនៅដើមខែឧសភា ឆ្នាំ ១៩៧៥ រួមជាមួយជនជាតិបរទេសឯទៀតៗ បានសុំអ្នកដឹកនាំទេវវិទ្យាល័យនៅក្រុងប៉ារីសទៅប្រទេសថៃ ដើម្បីស៊ើបសួរដំណឹងផ្សេងៗ ពីព្រះសហគមន៍ប្រទេសកម្ពុជា។ លោកបានធ្វើដំណើរចុះឡើងទៅជាយដែនថៃ ខ្មែរ និងចូលមើលជំរំជនភៀសខ្លួនខ្មែរនានា ដែលស្ថិតនៅតាមបណ្តោយព្រំដែននោះ។ ដោយលោក វ៉ឺណេ នេះចេះភាសាខ្មែរស្ទាត់ លោកជួយផ្តល់ជំនួយផ្សេងៗឲ្យជនភៀសខ្លួនដែលក្រីក្របំផុត និងជួយលើកទឹកចិត្តដល់អ្នកដែលអស់សង្ឃឹម។ បន្ទាប់មក រដ្ឋទូតបារាំងសុំឲ្យទៅនៅប្រទេសបារាំង។ ជារៀងរាល់ថ្ងៃលោកស្តាប់វិទ្យុ ស្តាប់ជនភៀសខ្លួនដោយស្លុតរន្ធត់ នឹងការកាប់សម្លាប់រង្គាលរបស់ខ្មែរក្រហម និងពួកតម្រួតការពារព្រំដែនថៃ។ លោកបូជាចារ្យដែលចូលចិត្តប្រើពាក្យសម្តីធ្ងន់ៗ និងមិនសូវចូលចិត្តនិយាយជាមួយអ្នកកាសែតមានប្រសាសន៍ថា "*ដើម្បីធ្វើកិច្ចការនេះកើត ទាល់តែចេះឃំខ្លះទើបទ្រាំទ្រួច*"។

**ពត៌មានក្នុងខែកក្កដា**

នៅឆ្នាំ ១៩៧៩ គឺក្រោយពីកងទ័ពវៀតណាម "*រំដោះ*" ប្រទេសកម្ពុជាបានហើយ ជនភៀសខ្លួនខ្មែររត់ចូលប្រទេសថៃជាច្រើនលើកថែមទៀត។ លើកទីមួយចាប់ពីខែមករាដល់ខែមិថុនា មានអ្នកភៀសខ្លួនប្រមាណជា ៨ ម៉ឺននាក់។ ប្រទេសថៃបារម្ភនឹងជនភៀសខ្លួនដែលខ្លួនមកក្នុងទឹកដីច្រើនកុះករនេះ និងយល់ថាវៀតណាមឈ្លានពានប្រទេសថៃដោយបញ្ជូនជនភៀសខ្លួនទាំងនោះចូលមក។ ថ្ងៃទី ១៧ មិថុនា ឆ្នាំ ១៩៧៩ រដ្ឋាភិបាលថៃបានប្រើកម្លាំងបាយចាប់បង្ខំជនភៀសខ្លួននៅជំរំណងចាន់ប្រមាណ ៣៥.០០០ នាក់ និងជនភៀសខ្លួន ៥.០០០ នាក់ទៀត នៅជំរំក្បែរវត្តកក់ក្នុងក្រុងអារញ្ញ បញ្ជូនទៅប្រទេសកម្ពុជាវិញ។ ពួកអាជ្ញាធរថៃដឹកអ្នកទាំងនោះទៅភ្នំព្រះវិហារ ហើយបង្ខំពួកគេឲ្យចុះពីលើភ្នំទៅប្រទេសកម្ពុជាវិញ ដោយដើរកន្លែង

មានមីនពាសពេញ។

មតិអន្តរជាតិទិទៀនប្រទេសថៃដែលប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃនេះ ហេតុនេះប្រទេសថៃក៏ឈប់បញ្ជូនជនភៀសខ្លួនទាំងកំរោលដូច្នេះទៅ។ អង្គការ " *ស្នងការជាន់ខ្ពស់នៃ អ.ស.ប. សម្រាប់ជនភៀសខ្លួន* " (UNHCR) សុខចិត្តទទួលបន្ទុកជនភៀសខ្លួនដែលមកដល់ក្រោយ និងរៀបចំឲ្យពួកគេចេញទៅរស់នៅប្រទេសទីបីដែលសុខចិត្តទទួលពួកគេនោះ។

គ្រានោះលោក វ៉ឺណេ និងជនជាតិបរទេសប៉ុន្មាននាក់ទៀត ខិតខំជួយខ្មែរមួយចំនួនដែលបានគេចពីការចាប់បញ្ជូនទាំងបង្ខំរបស់ពួកថៃ ហើយសម្ងំលាក់ខ្លួននៅក្នុងព្រៃតាមភ្នំដងរែក ព្រមទាំងជួយសម្រាប់អ្នកទាំងនោះ ឲ្យបានចេញទៅរស់នៅឯបរទេសទៀតផង។

ចាប់ពីខែកញ្ញា ឆ្នាំ ១៩៧៩ មក មានជនភៀសខ្លួនជាងមួយលាននាក់ មករកចំណីអាហារនៅទល់ដែនថៃ ដោយមានទុរ្ភិក្សកើតនៅប្រទេសកម្ពុជា។ រីឯកងទ័ព ប៉ុល ពត ដែលបាក់ទ័ពហើយរត់មកដល់ទល់ដែនថៃ បានកៀរប្រជាជនជាច្រើនដែលគេកាន់កាប់ដូចទាសករតាំងពីវៀតណាមវាយនោះ មកទល់ដែនថៃដែរ។ នៅក្នុងព្រៃតំបន់ភ្នំកាង៉ុកក្បែរទល់ដែនខ្មែរ ថៃ ជាកន្លែងដែលកងទ័ពខ្មែរក្រហមធ្លាប់ឆ្លងកាត់ មានខ្មោចស្លាប់គរជើងលើគ្នា និងអ្នកនៅរស់មានតែដង្ហើមផ្កឹកៗមិនទាន់ដាច់ខ្យល់ស្លាប់។ ពួកខ្មែរក្រហមដែលមានកម្លាំងមាំមួននៅឡើយ បានបន្តដំណើរទៅត្បូងចូលព្រៃភ្នំ ដើម្បីបន្តការប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាម។ ចំណែកអ្នកដទៃទៀតបានត្រូវប្រមូលផ្តុំនៅស្រះកែវ នៅម៉ៃរ៉ូត និងនៅកន្លែងផ្សេងៗទៀត។ ពួកវិទ្យុទូរទស្សន៍ក្នុងពិភពលោកថតយករូបភាពប្រជាជនខ្មែរ ដែលកំពង់ស្លូឈាមស្លាប់រងគ្រោះ ដោយការឈ្លានពានរបស់វៀតណាម។ ប្រជាជនទាំងនោះដាច់ខ្យល់ស្លាប់នៅមុខអ្នកកាសែត អ្នកថតរូប និងអ្នកថតទូរទស្សន៍។ អ្នកស្រី រ៉ូស៊ីលីនការទែរ (Roselyne Carter) ជាភរិយាប្រធានាធិបតីសហរដ្ឋអាមេរិក ក៏អញ្ជើញទៅមើលទិដ្ឋភាពនេះទាំង ទឹកភ្នែក។ អង្គការអន្តរជាតិនានារួបរួមគ្នានៅគ្រប់ទិសទី ដើម្បីផ្តល់ជំនួយដល់ប្រជាជនខ្មែរដែលរងគ្រោះដោយកងទ័ពវៀតណាមឈ្លានពានទឹកដីកម្ពុជា។ តាមពិត អ្នកទាំងនោះរងគ្រោះដោយសារអំពើរឃោរឃៅហួសហេតុរបស់ខ្មែរក្រហម។ ជំនួយមួយភាគធំត្រូវកងទ័ពថៃបញ្ជូនទៅជួយកងទ័ពខ្មែរក្រហមវិញ។

ក្នុងពេលនោះ មានប្រជាជនខ្មែរមួយចំនួនធំទៀតភៀសខ្លួនមកដល់ទល់ដែនថៃ ហើយស្នាក់នៅតាមជំរំផ្សេងៗ មានជំរំណោងចាន់ បានសាមេត គោកធ្យូងជាដើម។ ប្រជាជនរាប់សិបពាន់នាក់ បន្ទាប់ពីបានឆ្លងកាត់សេចក្ដីស្លាប់ជាច្រើនដំណាក់មក ក្រោមគ្រាប់កាំភ្លើងនៃកងទ័ពវៀតណាម ខ្មែរក្រហម កងទ័ពថៃ ចម្ងាយជាង ១០ គ.ម. ពីព្រំដែន បានបើកឡើងនៅថ្ងៃទី ២១ វិច្ឆិកា។ ពួកយោធាថៃមានបំណងកែណ្ឌទាហានក្នុងចំណោមអ្នកដែលមានអាយុគ្រប់គ្រាន់ ដើម្បីធ្វើសង្គ្រាមដេញវៀតណាមឈ្លានពាន។ មានប្រជាជនខ្មែរប្រមាណ ២៥០.០០០ នាក់ មិនព្រមចូលជំរំខៅអ៊ីដាងនេះទេ គឺពួកគេសុខចិត្តរស់នៅក្នុងតំបន់តាមព្រំដែន ថ្វីបើស្ថានការណ៍នៅកន្លែងនោះមានសភាពមិនស្រួលក៏ដោយ។ ម្យ៉ាងទៀត ការស់នៅដូច្នេះ ប្រជាជនទាំងនោះអាចចេញចូលទៅក្នុងប្រទេសខ្មែរបាន ព្រោះពុំសូវមានការត្រួតពិនិត្យតឹងរ៉ឹង ហើយពួកគេអាចរត់ពន្ធបានខ្លះៗ ដើម្បីចិញ្ចឹមជីវិត។

ពេលនោះ ព្រះសហគមន៍ក្នុងសកលលោករួបរួមគ្នា ដើម្បីជួយជនភៀសខ្លួនទាំងនោះ ដោយបានបញ្ជូនដូនជីមកពីប្រទេសអ៊ីតាលី បារាំង ស្វីស អូស្ត្រាលី និងសហរដ្ឋអាមេរិកជាដើម។ ពេលត្រឡប់ទៅវិញ ដូនជីទាំងនោះបានធ្វើឲ្យមតិប្រជាជនក្នុងប្រទេសរបស់ពួកគេភ្ញាក់ស្មារតី ហើយសុខចិត្តទទួលជនភៀសខ្លួនខ្មែរ។

លោក រ៉ីណេ បន្តការជួយជនភៀសខ្លួនខ្មែរដោយស្ងៀមស្ងាត់ លោកតែងយកប្រាក់ឬសំបុត្រ ដែលបងប្អូនរបស់ជនភៀសខ្លួនផ្ញើមក យកទៅឲ្យគេនៅតាមជំរំនានា ព្រោះគ្មានអង្គការណាបំពេញភារកិច្ចនេះឡើយ។ បន្ទាប់មក គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិបំពេញកិច្ចការនេះជួសលោក ទាំងសុំឲ្យលោកធ្វើការជាមួយ។ ប៉ុន្មានឆ្នាំក្រោយមក កាកបាទក្រហមអន្តរជាតិ ចង់ឈប់បំពេញកិច្ចការនេះ និងសុំឲ្យលោកបូជាចារ្យបំពេញជំនួសតាមផ្លូវការវិញ តែលោកបដិសេធពុំព្រមទទួល ដោយលោកមានបំណងធ្វើការផ្សេងទៀត។

## គ្រីស្តបរិស័ទខ្មែររៀមគ្នាថ្វាយអភិបូជា

ជារៀងរាល់ថ្ងៃអង្គារ លោករ៉ីណេធ្វើដំណើរម្នាក់ឯង ឬជូនកាលជាមួយបូជាចារ្យម្នាក់ទៀតដែលមក ជួយលោកទៅកាន់ជំរំណោងចាន់ ឬទីសែនដែលស្ថិតនៅជាប់

ទល់ដែន។ នៅទីនោះមានគ្រីស្តបរិស័ទ មកពីបាត់ដំបងពីចំណោម និងពីទីដទៃទៀតនៅរង់ចាំលោក។ ជួនកាល អ្នកស្រុកកំពង់គបានធ្វើដំណើរដ៏សែនឆ្ងាយ មកជួបអ្នកគង្វាលរបស់គេ។ គ្រីស្តបរិស័ទទាំងនោះ នាំគ្នាអង្គុយក្រោមដំបូលស្លឹកខ្ពស់ពីដីប្រហែលមួយម៉ែត្រកន្លះ ទាំងរៀបរាប់ប្រាប់ពីសហគមន៍នៅក្នុងប្រទេស ពួកគេរាប់ចំនួនអ្នកដែលនៅរស់ គេរំឭកគុណអ្នកដែលបាត់ខ្លួន។ល។ លោកបូជាចារ្យខំលើកទឹកចិត្តអ្នកទាំងនោះ ទូន្មានពួកគេ និងផ្តល់ជំនួយ ដែលពួកគេត្រូវការចាំបាច់ មានផ្លែសន្ទូចសំណាញ់ គ្រាប់ពូជផ្សេងៗ មុង ព្រមទាំងរៀតណាមហាមឃាត់ មិនឲ្យពួកគេយកចូលទៅក្នុងប្រទេសទេ។ នៅទីបញ្ចប់ នៃការជួបជុំគ្នានេះលោកបូជាចារ្យថ្វាយអភិបូជាផ្ទាល់នឹងដី និងផ្ញើជូនព្រះកាយព្រះគ្រីស្តដល់អ្នកនៅក្នុងស្រុកតាមគ្រីស្តបរិស័ទដែលបានមកទីនោះ។ គ្រីស្តបរិស័ទទាំងនេះ លាក់ព្រះកាយនៅក្នុងប្រអប់តូចសម្រាប់ដាក់ហ្វីលថតរូបដែលគេអាចបំបាត់យ៉ាងស្រួល ពេលទាហានឆែកឆេរ។ ដូច្នេះ លោកបូជាចារ្យនិងសហគមន៍នៅតាមទល់ដែន បានប្រាស្រ័យទាក់ទងដោយសម្ងាត់ជាមួយព្រះសហគមន៍ខ្មែរនៅក្នុងប្រទេសកម្ពុជាដែរ។

«**ខ្ញុំសុខចិត្តលះបង់អ្វីៗទាំងអស់**»

ឆ្នាំ ១៩៨០ នៅជំរំខៅអ៊ីដាងមានជនភៀសខ្លួនដល់ទៅ ១៥០.០០០នាក់។ បន្ទាប់មក អាជ្ញាធរថៃចែកជំរំធំនេះទៅជាជំរំតូចៗជាច្រើនទៀត ដើម្បីងាយស្រួលក្នុងការផ្គត់ផ្គង់និងណែនាំ គឺមានជំរំកាំពុត ស្រះកែវទី២ ម៉ៃរ៉ូត និងកាប់ឆឹន។ នៅជើងភ្នំខាវអ៊ីដាងរដ្ឋអំណាចថៃទុកកន្លែងមួយ សម្រាប់សង់វិហារគ្រប់សាសនាទាំងអស់។ ក្រុមដំណឹងល្អក៏សង់អាគារប្ញស្សីមួយធំនៅទីនោះ។ ចំណែកលោក រ៉ីណេ មិនយល់ព្រមសង់វិហារនៅទីនោះទេ លោកតាំងវិហារនៅសង្កាត់មួយផ្សេងទៀត។ គ្រីស្តបរិស័ទដែលជាជនជាតិបរទេសជាច្រើននាក់តែងជួយអង្គការមនុស្សធម៌ផ្សេងៗ។ ផ្ទុយទៅវិញមានអ្នកប្រកាសដំណឹងល្អជាតិអាមេរិកឆ្លៀតឱកាសដែលជនភៀសខ្លួនជួបការលំបាកវេទនានេះ គេណ្ណែឲ្យពួកគេជឿសាសនាខ្លួន។ ពួកគេចេះតែឃោសនា "*អ្នករាល់គ្នាជួបទុក្ខលំបាកវេទនាដូច្នេះ គឺមកពីកំហុសអ្នករាល់គ្នាដែលពុំព្រមជឿចំពោះព្រះទេ ឥឡូវព្រះដាក់ទណ្ឌកម្មអ្នករាល់គ្នាហើយ!* "។ ពួកនេះបានបន្ថែមថា សញ្ញាប័ត្រនៃបុណ្យជ្រមុជទឹក ឬសញ្ញាប័ត្រអំពីការសិក្សាខាងសាសនានេះ អាចសម្រួលការចេញ

ដំណើរទៅកាន់ស.រ.អ. ។

ជនភៀសខ្លួនខ្មែរប្រហែលជាង ២៥.០០០ នាក់ ទទួលបុណ្យជ្រមុជទឹកតាមរបៀបនេះ។ ជួនកាល ពួកគេតិះដៀលព្រះសង្ឃដែលមានវត្តនៅក្បែរវិហារនោះតាមឧឃោសនាស័ព្ទ។ តាមពិតមានពុទ្ធបរិស័ទជាច្រើនចង់ស្គាល់គ្រីស្ទសាសនាដែរ ដោយគេយល់ថាពុទ្ធសាសនាលែងមានប្រសិទ្ធិភាពហើយ ព្រោះទ្រឹស្ដីព្រះពុទ្ធបានចែងថា "*ធ្វើបុណ្យបានបុណ្យធ្វើបាបបានបាប* " នោះមិនសូវត្រឹមត្រូវទេ។ គេនិយាយថា "*យើងបានធ្វើបុណ្យទៅជាបានទទួលបាបដោយរងគ្រោះបែបនេះ ចំណែកខ្មែរក្រហមដែលបានធ្វើបាបវិញនៅតែកាន់អំណាចដដែល* "។ អ្នកខ្លះទៀតមានការភ្ញាក់ផ្អើលដោយឃើញអង្គការមនុស្សធម៌ស្ទើរតែទាំងអស់ចេញមកពីគ្រីស្ទបរិស័ទ។ សូម្បីតែអង្គការកាកបាទក្រហមអន្តរជាតិក៏ពាក់សញ្ញាឈើឆ្កាងដែរ! ហើយមានតែអង្គការមួយគត់ដែលចេញមកពីបងប្អូនខាងពុទ្ធបរិស័ទគឺ អង្គការ JSRC សហគមន៍ពុទ្ធបរិស័ទជប៉ុនសូកហ្កាកៃ (Sokkogakai)។ អង្គការនេះមកជួយជនភៀសខ្លួន ទោះបីគេមានលក្ខណៈខុសឆ្ងាយពីពុទ្ធសាសនាខ្មែរក៏ដោយ(ព្រះសង្ឃខាងសហគមន៍នេះមានគ្រួសារ!)។ ចំណែកបងប្អូនពុទ្ធបរិស័ទថៃវិញ ហាក់ដូចជារវល់តែធ្វើបុណ្យនៅក្នុងវត្ត ជាជាងជួយជនភៀសខ្លួន ដែលកំពុងតែជួបនូវការខ្វះខាតដ៏ធ្ងន់ធ្ងរនេះ រីឯ ទាហានថៃគេមានចិត្តកាចសាហាវ គ្មានការអាណិតអាសូរឬឈឺឆ្អាលបន្តិចសោះ។ ជនភៀសខ្លួនខ្មែរខ្លះធូរចិត្តដោយដាក់បាទព្រះសង្ឃ ដែលមានចំនួនកាន់តែច្រើនឡើងៗ និងកសាងវត្តអារាមនេះ។ គេយល់ថា ធ្វើដូច្នេះប្រពៃណីខ្មែររស់ឡើងវិញ។ ប៉ុន្តែ មានជនភៀសខ្លួនជាច្រើនយល់ថា នៅក្នុងគ្រាដ៏សែនវេទនានេះ ធ្វើដូច្នេះមិនសមទាល់តែសោះ។ ផ្ទុយទៅវិញ ព្រះសហគមន៍គ្រីស្ទបរស័ទនានាត្រឡប់ជាកន្លែងមួយដ៏កក់ក្ដៅជាកន្លែង ដែលគេយល់នូវទុក្ខវេទនារបស់ជនភៀសខ្លួន។

អ្នកខ្លះដូចជាពុំដឹងថាហេតុអ្វីបានជាគេនៅមានជីវិតនៅឡើយ ក្រោយពីបានឆ្លងកាត់ស្ថាននរកនៃរបប ប៉ុល ពត។ អ្នកខ្លះទៀតយល់ថា ប្រហែលជាមានព្រះមួយបានសង្គ្រោះគេហើយ។ នៅពេលចូលមកដល់ក្នុងជំរំ ពួកអ្នកឃោសនាខាងអាមេរិកពន្យល់ថាគឺព្រះយេស៊ូហើយដែលបានសង្គ្រោះពួកគេ។ សេចក្ដីពន្យល់នេះហាក់ដូចជាស្របនឹងទ្រឹស្ដីខាងពុទ្ធសាសនាដែរ ព្រោះគេថាអ្នកដែលស្លាប់ក្រោមរបប ប៉ុល ពត សុទ្ធតែអ្នកមានបាប ចំណែកអ្នកដែលនៅរស់គឺជាអ្នកដែលមានបុណ្យទៅវិញ។

អ្នកទទួលខុសត្រូវខាងព្រះសហគមន៍កាតូលិកមួយចំនួន ទាស់ចិត្តជាខ្លាំងនឹងរបៀបទាក់ទាញចិត្តជនភៀសខ្លួនតាមរបៀបអមេរិកនេះ ហើយយល់ថា ធ្វើដូច្នេះផ្ទុយស្រឡះនឹងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលពួកគេមានភារកិច្ចនាំឲ្យដល់បងប្អូនខ្មែរស្គាល់នោះ។

ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនៅឆ្នាំ ១៩៩០ មានបូជាចារ្យម្នាក់សុំអភ័យទោសពីសំណាក់ព្រះសង្ឃ ក្នុងនាមគ្រីស្តបរិស័ទទាំងអស់អំពីពាក្យប្រមាថមើលងាយរបស់គ្រីស្តបរិស័ទខ្លះៗទៅលើព្រះពុទ្ធសាសនានោះ។ ប៉ុន្មានថ្ងៃមុន លោកគ្រូសង្ឃរាជវត្តខៅអ៊ីដាង ក្នុងពេលធ្វើសម្ភាសជាមួយអ្នកសារពត៌មាន អន្តរជាតិបានប្រកាសថា៖ "*យើងជាពុទ្ធបរិស័ទ មានសត្រូវពីរក្រុមគឺ ប៉ុល ពត និងគ្រីស្តបរិស័ទ*"។ លោក រ៉ីណេ និង លោកបូជាចារ្យ ដែលធ្វើការជាមួយគាត់បានញែកយ៉ាងច្បាស់ពីបញ្ហាជំនួយខាងសម្ភារៈឲ្យដាច់ពីការណែនាំខាងជំនឿ។ អស់លោកធ្វើដូច្នេះ ដើម្បីចៀសវាងកុំឲ្យអ្នកដែលចង់ដឹងនិងចង់ស្គាល់ព្រះយេស៊ូមកយកលេស ដោយសង្ឃឹមថានឹងបានទទួលផលប្រយោជន៍ខាងសម្ភារៈអ្វីឡើយ។

បន្តិចម្តងៗជនភៀសខ្លួនខ្លះយល់ថា គេអាចទទួលជំនួយខ្លះ ដោយគ្មានបង្ខិតបង្ខំឲ្យចូលជាគ្រីស្តបរិស័ទឡើយ។ ក្នុងកាលៈទេសៈដ៏សែនវេទនា អស់លោកបូជាចារ្យយកចិត្តទុកដាក់ណែនាំជនភៀសខ្លួន ឲ្យបញ្ចេញសេចក្តីស្រឡាញ់ ដែលមនុស្សម្នាក់មាននៅក្នុងចិត្ត។ ដូចជា នៅថ្ងៃមួយ បូជាចារ្យម្នាក់ធ្វើអត្ថាធិប្បាយអំពីព្រះបន្ទូលរបស់ព្រះយេស៊ូថា៖ "*ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក ចូរអង្វរព្រះជាម្ចាស់លើកលែងទោសដល់អ្នកដែលបានធ្វើទុក្ខបុកម្នេញដល់អ្នក*" ។ លោកបូជាចារ្យមានប្រសាសន៍ថា៖ "*ព្រះយេស៊ូសូមឲ្យយើងអត់ឱនទោសឲ្យ ប៉ុល ពត ដែលបានសម្លាប់ឪពុកម្តាយ បង ប្អូន មិត្តភក្តិរបស់យើង។ តែអ្នកណាអត់ទោសបាន? ចូរសុំអង្វរព្រះវិញ្ញាណយាងមកជួយយើង ឲ្យចេះអត់ឱនដូចព្រះយេស៊ូដែរ*" ។ ពេលនោះ មានមនុស្សជាង ៥០០ នាក់ អង្គុយស្តាប់លោកបូជាចារ្យទាំងស្ងៀមស្ងាត់សោះអង្គើយ ស្ទើរតែប្រឆាំងនឹងសេចក្តីនេះ។ លោកបូជាចារ្យដឹងខ្លួនថា សេចក្តីដែលលោកនិយាយនោះធ្ងន់ពេក គង់តែមានគេខឹងខ្លាំង នឹកចង់សម្លាប់លោកហើយមើលទៅ!។ ស្អែកឡើង ពេលត្រឡប់មកជំរំវិញ លោកជួបពុទ្ធបរិស័ទក្មេងម្នាក់ជម្រាបលោកថា "*ម្សិលមិញខ្ញុំបានស្តាប់ធម៌ទេសនារបស់លោក ហើយខ្ញុំបានទៅជួបមិត្តរង់ដែលជាអតីត កម្មាភិបាលខ្មែរក្រហមម្នាក់ គាត់ជាជនភៀសខ្លួនដែរ ហើយខ្ញុំបាននិយាយជាមួយគាត់* " ម្នាក់ទៀតបានបន្ថែមថា "*ប្រសិនបើយើងនៅតែចងគំនុំនឹង*

*ខ្មែរក្រហម យើងពុំប្រសើរលើសខ្មែរក្រហមទាំងនោះទេ យើងចង់កែនិងឈ្នះវា ដោយចិត្តស្រឡាញ់របស់យើងវិញ* "។

ស្ត្រីគ្រីស្តបរិស័ទម្នាក់មានកូន ១២ នាក់។ កូនគាត់ ១០ នាក់ស្លាប់ក្នុងរបបប៉ុលពត។ ប្តីគាត់ក៏ត្រូវគេសម្លាប់ដែរ ព្រោះគាត់ធ្វើគយពីរបបមុន។ ស្ត្រីនោះនិយាយទាំងទឹកភ្នែករហាមថា៖ "*ខ្ញុំបាត់បង់កូន ១០ នាក់ ហើយប្តីខ្ញុំត្រូវគេសម្លាប់ទៀត តែខ្ញុំមិនស្អប់អ្នកដែលសម្លាប់ប្តីខ្ញុំទេ ខ្ញុំសុខចិត្តលះបង់ចោលកំហឹង និងគំនុំទាំងអស់* " ។

ព្រះសហគមន៍មានកង្វល់មួយទៀត គឺធ្វើឲ្យជនទាំងនោះទទួលស្គាល់កិត្តិយសដ៏ថ្លៃថ្នូររបស់ខ្លួនឡើងវិញ។ ថ្ងៃមួយបុរសម្នាក់មកសុំប្រាក់មួយចំនួន សម្រាប់សូកប្រធានសង្កាត់ ដើម្បីឲ្យបានសំបុត្រស្នាមជូនស្ត្រីមេម៉ាយម្នាក់ដែលទើបមកដល់។ ប្រសិនបើគ្មានសំបុត្រស្នាមនោះទេ អ្នកនោះពុំអាចទទួលរបបអាហារ ពីអង្គការជួយរ៉ាប់រងជនភៀសខ្លួនឡើយ។ បូជាចារ្យម្នាក់ឆ្លើយតបទៅបុរសនោះថា៖ "*មិនត្រូវសូកប៉ាន់ទេ ប្រសិនបើប្រធានក្រុមមិនព្រមសូមអញ្ជើញទៅជួបប្រធានកង បើប្រធានកងមិនព្រមទៀត សូមទៅជួបប្រធានជំរំ ហើយបើនៅតែពុំបានទៀត សូមអញ្ជើញទៅជួបអ្នកទទួលខុសត្រូវជនភៀសខ្លួន* "។ បុរសនោះមានកម្លាំងក្លាហាន ថ្មីបើកន្លងមកនៅក្នុងការសុំសំបុត្រនេះ គេបានទទួលបរាជ័យជាបន្តបន្ទាប់ក៏ដោយ ទីបញ្ចប់គេក៏បានទទួលសំបុត្រនោះពីអ្នកទទួលខុសត្រូវខាង"*ស្នងការជាន់ខ្ពស់នៃ អ ស ប សម្រាប់ជនភៀសខ្លួន*" (UNGCR)។ ពេលក្រោយគាត់ជម្រាបលោកបូជាចារ្យថា "សូមអរគុណលោក! លោកមិនឲ្យអស់លុយទេ ផ្ទុយទៅវិញ លោកធ្វើឲ្យខ្ញុំយល់ថា ជីវិតខ្ញុំមានតម្លៃថ្លៃថ្នូរវិញ" ។

សេចក្តីក្លាហានរបស់បុរសយើងនេះ បានធ្វើឲ្យពួកជនខិលខូចមួយចំនួនក្តៅក្រហាយជាខ្លាំង ពួកគេចងគំនុំ និងគំរាមកំហែងបុរសយើងគ្រប់បែបយ៉ាង។ ប៉ុន្តែ បុរសយើងមិនតក់ស្លុតឡើយ គាត់យល់ថា ជំនឿចំពោះគ្រីស្តសាសនាបានជំរុញឲ្យគាត់បម្រើបងប្អូនរួមជាតិដោយឥតរួញរាឡើយ។ គាត់សម្រេចចិត្ត ថាចង់ស្គាល់ជំនឿនេះ ហើយពីរឆ្នាំក្រោយមកគាត់បានទទួលបុណ្យជ្រមុជទឹក ។

**សិទ្ធិទីមួយរបស់ជនភៀសខ្លួន**

តើព្រះសហគមន៍មានភារកិច្ចសម្រួលជនភៀសខ្លួនចេញទៅរស់នៅបរទេស ឬយ៉ាង

ណា? ដោយយក គំរូតាម "*ស្នងការជាន់ខ្ពស់នៃ អ ស ប សម្រាប់ជនភៀសខ្លួន*" ព្រះសហគមន៍បានរំឭកជាច្រើនដងថា បស្ចឹមប្រទេសមិនអាចដោះស្រាយបញ្ហាជនភៀសខ្លួនបាន ដោយគ្រាន់តែទទួលជនភៀសខ្លួនទាំងនោះទៅរស់នៅឯបស្ចឹមប្រទេសប៉ុណ្ណោះទេ គឺត្រូវដោះស្រាយបញ្ហានយោបាយដែរ។ ម្យ៉ាងទៀត ទទួលជនភៀសខ្លួនទៅរស់នៅឯបរទេសគឺដកហូតកម្លាំងមួយធំពីប្រទេសកម្ពុជា។ មនុស្សគ្រប់រូបមានសិទ្ធិទីមួយគឺរស់នៅក្នុងមាតុភូមិរបស់ខ្លួនដោយសេរី ។

នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៨៤ សម្តេចប៉ាប យ៉ូហាន ប៉ូលទី ២ ធ្វើទស្សនកិច្ចនៅប្រទេសថៃ លោកចូលជំរំផាណានិគម ដើម្បីមើលនូវទិដ្ឋភាពរបស់ជនភៀសខ្លួនទាំងនោះដោយខ្លួនលោក។ លោកថ្លែងសុន្ទរកថាមួយនៅចំពោះសមាជិករដ្ឋាបាលថៃនិងអង្គទូតនានាមានសេចក្តីជាអាទិ៍ដូចតទៅ៖

> *«ការនិរទេសជាជនភៀសខ្លួនខុសស្រឡះនឹងសម្បជញ្ញៈមនុស្សលោក និងផ្ទុយនឹងច្បាប់ក្នុងសង្គមមនុស្ស ការនិរទេសនេះគឺផ្ទុយទៅនឹងសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិផង។ ដូច្នេះរដ្ឋាភិបាលទាំងអស់និងសហគមន៍អន្តរជាតិទាំងមូលត្រូវខិតខំដោះស្រាយបញ្ហានយោបាយដែលបង្ករបង្កើតឲ្យ គេភៀសខ្លួននោះ ជាស្ថានពរ។ ប្រសិនបើជនភៀសខ្លួនទាំងអស់ចេញទៅប្រទេសទីបី ក៏នៅតែមានបញ្ហាដែរ។ ជនភៀសខ្លួនទាំងនេះមានសិទ្ធិនឹងត្រឡប់ទៅរស់នៅក្នុងមាតុភូមិរបស់ខ្លួនវិញ ទៅកាន់ភូមិកំណើតរបស់ខ្លួន ជាប្រជាជននៃប្រទេសឯករាជ្យបូរណភាពទឹកដី និងអាចសម្រេចអ្វីៗ ដោយខ្លួនឯងបាន មានសិទ្ធិរក្សាទំនៀមទម្លាប់ និងជំនឿ ដូចប្រជាជនទាំងអស់នៅលើផែនដីយើងនេះ ។*
>
> *បើរិះរកញែកឲ្យច្បាស់ទៅ បញ្ហាស្មុគស្មាញទាំងនេះ អាចនឹងដោះស្រាយទៅបានលុះត្រាតែប្រជាជាតិនីមួយៗ សហគមន៍ និងជនជាតិផ្សេងៗពីគ្នាចេះសម្រុះសម្រួលនិងចេះអត់ឱនគ្នាទៅវិញទៅមក។ មានមធ្យោបាយតែមួយគត់ពោលឲ្យខ្លី គឺត្រូវឲ្យប្រជាជនខ្មែរចេះស្រឡាញ់គ្នា អត់ឱនគ្នា បំភ្លេចរឿងដែលកន្លងផុតមក និងរួបរួមគ្នាកសាងអនាគតដ៏ប្រសើរមួយ»។*

ទោះបី ក្រុមរក្សាសន្តិសុខពុំអនុញ្ញាតឲ្យសម្តេចប៉ាបចូលជិតជនភៀសខ្លួនក៏ដោយ ក៏លោកពុំព្រងើយកន្តើយចំពោះទុក្ខវេទនារបស់អ្នកទាំងនោះដែរ លោកមានប្រសាសន៍ផ្តែផ្តាំលោក រ៉ីណោ ថា៖

*«ខ្ញុំក្រៀមក្រំចិត្តជាខ្លាំង ដោយឃើញជនកំសត់ទាំងនេះអង្គុយក្រោមកំដៅថ្ងៃ រង់ចាំខ្ញុំរាប់ម៉ោង ដោយមានទាហានយាមពួកគេបីដូចសត្វ។ សូមលោកស្រឡាញ់អ្នកទាំងនោះតទៅទៀត ពេលលោកឃើញជនភៀសខ្លួន លោកឃើញព្រះគ្រីស្ត លោកប្រាស្រ័យទាក់ទងជាមួយជនភៀសខ្លួន គឺដូចលោកប្រាស្រ័យជាមួយព្រះគ្រីស្ត លោកស្រឡាញ់ជនភៀសខ្លួនដូចលោកស្រឡាញ់ព្រះគ្រីស្តដែរ។»*

«**ជនផ្លាស់ប្តូរទីកន្លែង**»

ពីថ្ងៃទី ១៥ វិច្ឆិកា ១៩៨៤ ដល់ខែមេសា ១៩៨៥ ពួកកងទ័ពវៀតណាមបានធ្វើការ "*បោសសំអាត*" តំបន់តាមព្រំដែនកម្ពុជា ថៃ ដើម្បីរារាំងប្រជាជនលែងឲ្យរត់ចេញទៅក្រៅតទៅទៀត ហើយនិងបិទព្រំដែន មិនឲ្យកងទ័ពអ្នកតស៊ូជ្រៀតចូលមកក្នុងប្រទេសកម្ពុជាបាន។ សាធារណរដ្ឋប្រជាមានិតកម្ពុជាចាប់ផ្តើមកេណ្ឌប្រជាជនដើម្បីទៅ "*ក ៥*" សង់ "*ជញ្ជាំងឫស្សី*" នៅតាមបណ្តោយព្រំដែន មានប្រវែងប្រហែល ៨០០ គ.ម. ព្រមទាំងបង្កប់មីននៅតាមជញ្ជាំងនេះផង។ ការ "*បោសសំអាត*" នេះ បណ្តាលឲ្យជនភៀសខ្លួនប្រមាណ ៣០០.០០០ នាក់ ភៀសខ្លួនចូលទៅក្នុងដីថៃ។ អង្គការអន្តរជាតិក៏បានបង្កើតជំរំមួយចំនួនសម្រាប់ "*ជនផ្លាស់ប្តូរទីកន្លែង*" ទាំងនោះ គឺមានជំរំសាយធូ (site 2) ដែលមានប្រជាជនប្រមាណ ១៦០.០០០នាក់ ស្ថិតនៅក្រោមការត្រួតត្រារបស់ "*រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ*" ជំរំសាយប៊ី (site B) មានប្រជាជនប្រហែល ៦២.០០០ នាក់ ស្ថិតនៅក្រោមការត្រួតត្រារបស់ "*រណសិរ្សរួបរួមជាតិ ដើម្បីកម្ពុជាឯករាជ្យអព្យាក្រឹត្យ និងសហប្រតិបត្តិ*" និងជំរំសាយអេក (site 8) ព្រមទាំងជំរំតូចៗមួយចំនួនទៀត ដែលមានប្រជាជនសរុបប្រហែល ១០០.០០០នាក់ស្ថិតនៅក្រោមការកាន់កាប់របស់ពួកខ្មែរក្រហម។

ប្រជាជន "*ប្តូរទីកន្លែង*" ទាំងនេះ ពុំមានលក្ខន្តិកៈជាជនភៀសខ្លួនទេ ហើយពុំមានសិទ្ធិចេញទៅរស់នៅឯបរទេសឡើយ។ ប្រជាជនទាំងនេះ ត្រូវតែវិលត្រឡប់ទៅមាតុភូមិវិញ ពេលសភាពការអនុគ្រោះឲ្យ។ នៅតាមជំរំទាំងនេះ ប្រជាជនអាយុតិចជាង ១៥ ឆ្នាំ មានរហូតដល់ ១៥០.០០០នាក់ កុមារកុមារីអាយុតិចជាង ៥ ឆ្នាំ មានចំនួនប្រមាណ ៧០.០០០នាក់។ កុមារកុមារីទាំងនោះ ពុំស្គាល់អ្វីក្រៅពីរបងលួសបន្លាឡើយ។

តាំងពីឆ្នាំ ១៩៨០ មក អង្គការព្រះសហគមន៍កាតូលិកថៃឈ្មោះកូអ៊ែរ (COERR) បានផ្តល់ជំនួយខ្លះ ៗដល់ជនភៀសខ្លួន។ ព្រះសហគមន៍ថៃមានចំនួនស្តួចស្តើង ពុំអាចធ្វើអ្វីធំដុំ

បានទេ។ ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ព្រះសហគមន៍នេះពុំអាចជួយជនភៀសខ្លួនខ្មែរដោយចេញមុខបានទេ ព្រោះរដ្ឋាភិបាលថៃ ខ្វល់ខ្វាយនឹងជនភៀសខ្លួន បានន័យថាគេប្រឆាំងនឹងរដ្ឋាភិបាលរបស់ប្រទេសគេ។ តែទោះបីជាជួបការលំបាកយ៉ាងនេះក៏ដោយ អ្នកដឹកនាំព្រះសហគមន៍នេះបានបង្ហាញនូវសេចក្ដីយកចិត្តទុកដាក់ ចំពោះវត្តមានរបស់អស់លោកបូជាចារ្យជាជនជាតិបរទេសដែលជួយជនភៀសខ្លួននៅតាមជំរំនានា ហើយបានលើកទឹកចិត្តបូជាចារ្យទាំងនោះផង។ ក្នុងខែកញ្ញា ១៩៧៩ ព្រះសហគមន៍ថៃមកធ្វើការនៅតាមជំរំនានា ដើម្បីជួយជនភៀសខ្លួន ហើយក្រោយមក ព្រះសហគមន៍នេះទទួលបន្ទុកស្ទើរតែទាំងស្រុងក្នុងជំរំជនភៀសខ្លួន នៅផាណានិគម (Phanatnikom).

ចាប់ពីឆ្នាំ ១៩៨៥ ព្រះសហគមន៍ថៃបានចូលជួយ "*ជនផ្លាស់ប្ដូរទីកន្លែង*" នៅជំរំសាយធូ ជំរំសាយអេក និងក្នុងជំរំខ្មែរក្រហមដ៏ទៃទៀត (*អូរត្រាវ តាលួន*) ហើយបានក្លាយទៅជាអង្គការមនុស្សធម៌មួយយ៉ាងសំខាន់បំផុត។ សមាជិកនៃអង្គការនេះ ភាគច្រើនជាគ្រីស្ដបរិស័ទថៃ។ ពួកគេបានបង្ហាញឲ្យឃើញថា ព្រះសហគមន៍ថៃមានការខ្វល់ខ្វាយខ្លាំង ចំពោះជនភៀសខ្លួនខ្មែរដែរ។

នៅឆ្នាំ ១៩៨០ លោកបូជាចារ្យ សីលាសីរ៉ាក (Pierre Ceyrac) និងលោក យូហាន ប៊ីងហ្គាម (John Bingham) នៃសហគមសហជីវិនព្រះយេស៊ូ មកពីប្រទេសឥណ្ឌា មកស្នាក់នៅក្នុងជំរំផាណានិគម។ លោកទាំងពីរប្រព្រឹត្តតាមបញ្ជារបស់លោកអ័រុប៉េ (Aruppe) ជានាយកសមាគមជីវិនព្រះយេស៊ូ។ លោកអ័រុប៉េមកពិនិត្យមើលសភាពជនភៀសខ្លួននៅប្រទេសថៃដោយផ្ទាល់ខ្លួនលោក។ លោកនាយកក៏មានការខ្វាយខ្វល់ជាខ្លាំងចំពោះជនភៀសខ្លួនទាំងអស់ នៅក្នុងពិភពលោកយើងដែរ។ លោកបូជាចារ្យទាំងពីរនាក់បានចាប់អារម្មណ៍នឹងសេចក្ដីខ្វះខាត និងទុក្ខលំបាកវេទនារបស់ជនភៀសខ្លួន ហើយបានខិតខំណែនាំឲ្យអង្គការរបស់សមាគមសហជីវិនព្រះយេស៊ូ ដែលមានភារកិច្ចជួយជនភៀសខ្លួនទូទៅ ក្នុងលោក (JRS: Jesuite Refugee sevice) ឲ្យមកនៅប្រទេសថៃ។ នៅប្រទេសថៃអង្គការ JRS នេះបានធ្វើការក្នុងក្របខ័ណ្ឌរបស់ កូអ៊ែរ COERR ហើយទទួលបន្ទុកជួយជាច្រើន មានវិស័យវឌ្ឍនភាពសមាគមជាអាទិ៍។ ព្រះសហគមដទៃទៀតក៏បានយកកម្លាំងខ្លួនមកជួយដែរ ក្នុងចំណោមនេះ មានក្រុមគ្រួសារសាលេស៊ីយ៉ាំង (Salésiens) ដែលទទួលបន្ទុកខាងអប់រំបច្ចេកទេស។ ក្រុមគ្រួសារ

ម៉ារីណុល (Maryknoll) ពីស.រ.អ.បានទទួលឧបត្ថម្ភមនុស្សជរា និងជនឯកោគ្មានទីពឹង។

អស់លោកដែលទទួលខុសត្រូវលើព្រះសហគមន៍ខ្មែរ បណ្តាលឲ្យអង្គការកាតូលិកទាំងនេះបំពេញភារកិច្ចទំនុកបម្រុង និងផ្តល់ជំនួយមនុស្សធម៌តាមឧត្តមគតិរៀងៗខ្លួន តែអស់លោកដែលចូលរួមនៅក្នុងក្របខ័ណ្ឌរបស់កូអ៊ែរដែរនោះ បានបន្តសកម្មភាពរបស់ខ្លួន គឺខិតខំជួយគ្រីស្តបរិស័ទ បង្កើតព្រះសហគមន៍ឲ្យមានលក្ខណៈជាខ្មែរ។ កង្វល់ទីមួយរបស់លោកបូជាចារ្យទាំងនោះ គឺប្រមែប្រមូលគ្រីស្តបរិស័ទដែលបែកខ្ញែកគ្នា និងកសាងព្រះសហគមន៍ឡើងវិញ ដើម្បីឲ្យពួកគេអាចជួបជុំគ្នាបាន។ លោករ៉ីណោ បានចាប់ផ្តើមអប់រំអ្នកដែលចង់ស្គាល់ព្រះយេស៊ូ ដូចនៅជំរំខៅអ៊ីដាងពីមុនដែរ។ សកម្មភាពទាំងនេះ បណ្តាលឲ្យកើតទំនាស់ខ្លះៗជាមួយអ្នកដឹកនាំជនភៀសខ្លួន។ អ្នកដឹកនាំទាំងនោះអះអាងថាមានតែខ្លួនគេទេ ជាអ្នកអាចថែរក្សាវប្បធម៌ និងអារ្យធម៌ខ្មែរ។ អ្នកដឹកនាំខ្លះមិនព្រមឲ្យគ្រីស្តបរិស័ទបង្ហាញជំនឿរបស់ខ្លួនតាមអារ្យធម៌របស់ខ្មែរទេ។ ទំនាស់ធំមួយទៀត គឺទំនាស់ជាមួយអ្នកនយោបាយឬយោធាខ្មែរ ដែលគ្រប់គ្រង និងកាន់កាប់ជនភៀសខ្លួនទាំងនោះ។

ទាំងពីឆ្នាំ ១៩៨៩ មក ជនភៀសខ្លួនខ្មែរមានសង្ឃឹមថា នឹងវិលត្រឡប់ទៅកាន់មាតុប្រទេសវិញ។ អស់លោកដែលទទួលបន្ទុកណែនាំព្រះសហគមន៍ខ្មែរនាំគ្នាគិតថា ត្រូវតែយកចិត្តទុកដាក់អប់រំគ្រីស្តបរិស័ទឲ្យទទួលខុសត្រូវក្នុងព្រះសហគមន៍ ព្រោះថា ក្នុងពេលអនាគតសហគមន៍ខ្មែរនេះ ត្រូវតែទទួលបន្ទុកក្នុងគ្រប់កិច្ចការទាំងអស់ ដោយគ្មានសាសនទូតបរទេសជួយអប់រំទៀតទេ។ ដូច្នេះ គ្រីស្តបរិស័ទបានតែងតាំងគណៈកម្មការបី មានគណៈកម្មការអ្នកណែនាំដែលទទួលបន្ទុកខាងអប់រំជំនឿទូទៅ ក្រុមនេះតែងជួបប្រជុំគ្នារិះគិតជាមួយគ្នា និងទទួលការអប់រំយ៉ាងមាំទាំ។ គណៈកម្មការមួយទៀតទទួលបន្ទុករៀបចំធ្វើពិធីបុណ្យផ្សេងៗ គឺពេលប្រជុំនៅថ្ងៃអាទិត្យ ពេលធ្វើបុណ្យជ្រមុជទឹក អាពាហ៍ពិពាហ៍។ល។ គណៈកម្មការមួយទៀត ជាគណៈកម្មការសង្គហៈ ទទួលខាងឧបត្ថម្ភជនក្រីក្រ និងដាស់តឿនគ្រីស្តបរិស័ទឲ្យជួយអ្នកក្រីក្រជាងខ្លួនទៅទៀត។ សមាជិកគណៈកម្មការនេះ តែងទៅសាកសួរទុក្ខអ្នកក្រីក្រដោយមិនប្រកាន់សាសនា និងមិនរវល់ឃោសនាពីសាសនាឡើយ។ ពួកគេរិះគិតរួមគ្នា និងសម្រេចចែកចាយជំនួយដ៏ស្តួចស្តើងឲ្យអ្នកដែលក្រីក្រជាងគេ។

ជនជាតិបរទេសតែងចែកចាយជំនួយផ្សេងៗដ៏បរិបូរណ៍ ឲ្យជនភៀសខ្លួនដែលពូកែសុំ រីឯគណៈកម្មការយើងនេះ ខិតខំពង្រឹងចិត្តគំនិតជនទាំងនោះឲ្យទៅជាមនុស្សដែលមានគុណសម្បត្តិខ្ពស់ លែងទៅជាអ្នកសុំទានទៀត។ នេះជាជំហានដំបូងនៃ "*បដិវត្តន៍ខាងផ្លូវចិត្ត* "។ វត្តមានរបស់អង្គការអន្តរជាតិនានានៅក្នុងជំរំបានបង្កើតនូវវិបត្តិជាច្រើន។ ការចែកជំនួយឲ្យប្រជាជននៅតាមជំរំនានា ដែលស្ថិតនៅក្រោមការកាន់កាប់របស់ចលនាតស៊ូឬក៏ចែកជំនួយឲ្យប្រជាជននៅក្នុងប្រទេសកម្ពុជា មិនអាចជៀសផុតពីរឿងនយោបាយបានឡើយ។ ដូច្នេះអង្គការទាំងនេះពុំមែនជាអង្គការអព្យាក្រឹត្យទេ។ ដោយចេតនា ឬដោយអចេតនា អង្គការទាំងនោះបន្តសង្គ្រាមយូរអង្វែងតទៅទៀត។ ជំនួយទាំងនេះពិតជាត្រឹមត្រូវ និងខានពុំបានមែន តែទន្ទឹមនេះ ជំនួយទាំងនោះមានលក្ខណៈនយោបាយគឺគាំទ្របក្សនីមួយៗ និងបណ្តាលឲ្យសង្គ្រាមបន្តទៅទៀតគ្មានថ្ងៃឈប់។

អ្នកទទួលខុសត្រូវអង្គការមនុស្សធម៌ទាំងនេះ ភាគច្រើនមិនចាប់អារម្មណ៍នឹងបញ្ហានយោបាយនេះទេ ហើយស្ម័គ្រចិត្តបម្រើជនភៀសខ្លួនទាំងប៉ុន្មានដោយស្មោះ។ ភាគច្រើនមិនបានរិះគិតឲ្យបានជ្រៅជ្រះ អ្នកខ្លះអំពាវនាវរកជំនួយផ្សេងៗ ទាំងដាស់តឿនមហាជនឲ្យមានសទ្ធាជ្រះថ្លា ក៏ប៉ុន្តែ គេភ្លេចគិតដល់បុព្វហេតុដែលបណ្តាលឲ្យមានជនភៀសខ្លួនជាច្រើននឹងវិលត្រឡប់ទៅមាតុប្រទេសរបស់ខ្លួនវិញពុំខាន។ ប្រសិនបើអស់ជំនួយបរទេស ពួកនាយទាហាន និងអ្នកនយោបាយប្រាកដជាខំយកចិត្តទុកដាក់រកមធ្យោបាយ ដោះស្រាយសោកនាកម្មរបស់ជាតិខ្លួនជាពុំខាន។ ម្យ៉ាងទៀត ជំនួយមនុស្សធម៌ទាំងនេះធ្វើឲ្យប្រជា ពលរដ្ឋខ្មែរក្លាយទៅជាអ្នកសុំទានគេ ហើយបាត់បង់អស់មោទនភាពរបស់ខ្លួន។

ជនបរទេសដែលពុំចេះនិយាយភាសាខ្មែរ តែងតែទាក់ទងជាមួយជនភៀសខ្លួនដែលចេះភាសាបារាំង ឬអង់គ្លេស។ ដូច្នេះ ជនបរទេសទាំងនេះច្រើនពុំស្គាល់ និងពុំដឹងពីការរស់នៅដ៏សែនលំបាកវេទនារបស់ជនក្រីក្រនៅក្នុងជំរំទេ។ ពួកជនបរទេសទាំងនេះ ច្រើនចែកចាយប្រាក់កាសឬរបស់របរអ្វីៗដល់ជនភៀសខ្លួន ដែល"*ប៉ិនសុំ* "។ ជំនួយបែបនេះក្លាយទៅជាការប្រមាថមើលងាយដល់អ្នកក្រ។ ជំនួយទាំងនេះ ក៏ធ្វើឲ្យវណ្ណៈអ្នកមាននិងអ្នកក្រកាន់តែឃ្លាតឆ្ងាយពីគ្នាទៅទៀត។ មិនតែប៉ុណ្ណោះ របៀបចែកជំនួយដូច្នេះបណ្តាល ឲ្យអំពើពុករលួយកាន់តែរីកសាយខ្លាំងឡើងថែមទៀត។ ជនភៀសខ្លួន

ខ្មែរម្នាក់ដែលទទួលខុសត្រូវខាងព្រះសហគមន៍បានស្តីបន្ទោសជនបរទេសម្នាក់ដែលមានសទ្ធាជ្រះថ្លា "*ហួសពេក*" ថា៖ "*ដោយលោកផ្តល់អ្វីៗដល់អ្នកសុំ លោកធ្វើឲ្យជនទាំងនោះក្លាយជាជនពុករលួយ*"។ ម្យ៉ាងទៀត *លោកធ្វើឲ្យអ្នកផង ទាំងពួងយល់ថា "ពួកយើងទៅជាគ្រីស្តបរិស័ទ ដើម្បីបានទទួលប្រាក់ពីលោក លោកធ្វើដូច្នេះនាំឲ្យខូចកេរ្តិ៍ឈ្មោះ ខូចកិត្តិយសយើងជាគ្រីស្តបរិស័ទតែម្តង*" ។

# ជំពូកទី ១៩

# ព្រះសហគមន៍រស់ឡើងវិញ

## ការនិរតុគន៍ទៅភូមិកំណើត

នៅឆ្នាំ ១៩៧៩ បន្ទាប់ពីកងទ័ពវៀតណាម *"រំដោះ"* ប្រទេសកម្ពុជាបានទាំងស្រុងហើយ ប្រជាជនដែលប៉ុល ពត បានកៀរឲ្យទៅនៅជនបទនោះ វិលត្រឡប់ទៅកាន់ភូមិឋានរបស់ខ្លួនវិញ។ គ្រីស្ដបរិស័ទនៅភូមិចំណោមដែលភាគច្រើនជាកសិករ ក៏ចាប់ផ្ដើមកសាងព្រះសហគមន៍របស់ខ្លួនឡើងវិញដែរ។ នៅភូមិនេះមានតែគ្រួសារមួយគ្រួសារប៉ុណ្ណោះ ដែលស្លាប់បាត់បង់ជីវិតនៅក្នុងសម័យ ប៉ុល ពត នោះ។ នៅឆ្នាំ ១៩៧៩ ព្រះសហគមន៍នៅភូមិចំណោមមានចំនួន ៥៥ គ្រួសារ ហើយមានសមាជិកទាំងអស់ប្រហែល ២០០ នាក់។ ពួកគេបានជុសជួលព្រះវិហារ និងចាប់ផ្ដើមជួបជុំគ្នារាល់ថ្ងៃអាទិត្យ។ ជួនកាលមានទាហានវៀតណាមចូលរួមផងដែរ។ នៅខែកញ្ញា ១៩៧៩ ទុរ្ភិក្សនៅតំបន់នេះបានជម្រុញឲ្យគ្រីស្ដបរិស័ទចំនួន ៨ គ្រួសារភៀសខ្លួនចូលទៅជំរំខៅអ៊ីដាង រួចអ្នកនោះចេញទៅប្រទេសផ្សេងៗទៀត។

ប៉ុន្មានខែដំបូង ក្រោយពេល *"រំដោះ"* អ្នកទទួលបន្ទុកអប់រំខាងគ្រីស្ដសាសនា ត្រូវគេចាត់តាំងឲ្យបង្រៀនអក្សរកុមារក្នុងភូមិ។ គាត់ក៏បានទទួលសេចក្ដីអនុញ្ញាតឲ្យអប់រំខាងគ្រីស្ដសាសនាដែរ។ ប៉ុន្តែ ចាប់ពីឆ្នាំ ១៩៨២ មក សភាពការនយោបាយកាន់តែតឹងឡើងៗជាលំដាប់។ អ្នកកាន់រដ្ឋអំណាចបានរឹបយកព្រះវិហារ ទៅធ្វើជាសាលាសាធារណៈ។ គេហាមឃាត់មិនឲ្យអប់រំជំនឿគ្រីស្ដសាសនា ហើយអ្នកអប់រំសាសនានេះក៏ប៉ិះត្រូវគេចាប់ឃុំឃាំង។ ស្ថានការណ៍តឹងតែងនេះប្រហែលបណ្ដាលមកពីការទាមទារសេរីភាពរបស់ក្រុមគ្រីស្ដបរិស័ទ និងក្រុមសហជីព"សាមគ្គី" (Solidarnost) នៅប្រទេសប៉ូឡូញនោះ។ តាំងពីពេលនោះមក គ្រីស្ដបរិស័ទនៅភូមិចំណោមតែងជួបជុំគ្នានៅតាមគេហដ្ឋានរៀងៗខ្លួន ក្នុងឱកាសបុណ្យណូអែល ឬបុណ្យភ្ជុំបិណ្ឌជាដើម។

នៅថ្ងៃបុណ្យចម្លងឆ្នាំ ១៩៨៨ គេបានធ្វើបុណ្យជ្រមុជទឹកឲ្យកុមារចំនួនប្រហែល ៤០ នាក់ និងរៀបអាពាហ៍ពិពាហ៍គូស្រករថ្មីចំនួនពីរគូដែរ។

ចំណែកគ្រីស្តបរិស័ទនៅបាត់ដំបង ក៏ដូចប្រជាជនទូទាំងប្រទេសដែរ គឺពួកគេបានវិលត្រឡប់មកកាន់ភូមិឋានរបស់គេវិញ ហើយរស់នៅតាមដងស្ទឹងសង្កែតាំងពីដើមឆ្នាំ ១៩៧៩ មក។ ព្រះសហគមន៍គ្រីស្តបរិស័ទបាត់ដំបងនៅសល់សមាជិកតែ ២១៤ នាក់ប៉ុណ្ណោះ គឺមិនបានពាក់កណ្តាលផង ហើយតាមស្មានមើលទៅ ប្រហែលជាមានបងប្អូនខ្លះនៅរស់នៅតាមភូមិដែលគេជម្លៀសទៅនោះ ហើយមានគ្រីស្តបរិស័ទខ្លះទៀតប្រហែលមិនទាន់ហ៊ានបង្ហាញខ្លួនដែរ។ មិនតែប៉ុណ្ណោះ ប្រជាជនចំនួន ៧៩ គ្រួសារបានសម្រេចចិត្តភៀសខ្លួនចូលទៅប្រទេសថៃដោយមិនទាំងបានវិលត្រឡប់ចូលភូមិកំណើតរបស់ខ្លួនវិញផង។

ក្រោយពីបានវិលត្រឡប់ចូលភូមិវិញ គ្រីស្តបរិស័ទបាត់ដំបងបានឃើញព្រះវិហារ និងកន្លែងបញ្ចុះសពត្រូវពួកប៉ុល ពត ឈូសចោលក្លាយជាកន្លែងដាក់រថយន្តទៅវិញ។ ទោះបីយ៉ាងនេះក៏ដោយ ក៏រាល់ថ្ងៃអាទិត្យគេបានជួបជុំគ្នានៅអតីតផ្ទះរបស់លោកបូជាចារ្យក្រោមការណែនាំរបស់លោក នូ ផល ដែលជាអតីតលេខាធិការរបស់លោកអភិបាលទេពអ៊ីម។

នៅឆ្នាំ ១៩៧៩ លោក នូ ផល ខិតខំប្រមែប្រមូលគ្រីស្តបរិស័ទដែលនៅខ្ចាត់ខ្ចាយតាមតំបន់ផ្សេងៗនិងធ្វើជំរឿនចំនួនពួកគេ។ កាលពីមុនគាត់ប្រកបអាជីវកម្មជាអ្នកជួសជុលអង្គុលីលេខ ហើយរដ្ឋអំណាចថ្មី បានចាត់តាំងគាត់ឲ្យទទួលខុសត្រូវខាងពត៌មាន ប្រចាំខេត្តបាត់ដំបងទៀតផង។ ដូច្នេះ គាត់បានច្បាប់អនុញ្ញាតពីរដ្ឋអំណាចយ៉ាងស្រួល មានលទ្ធភាពអាចជួបជុំគ្រីស្តបរិស័ទទាំងអស់ជារៀងរាល់ថ្ងៃអាទិត្យនៅគេហដ្ឋានកុមារសង្គ្រោះរបស់ក្រុមដូនជីឧបការគុណ។ តែនៅឆ្នាំ ១៩៨២ ថ្វីបើមានអន្តរាគមន៍ពីលោកនូ ផល និងពីគ្រីស្តបរិស័ទទាំងអស់ក៏ដោយ ក៏រដ្ឋបាលក្រុងបានយកគេហដ្ឋាននេះទៅធ្វើជាមន្ទីរពេទ្យយោធាវិញ។ លោកនូ ផល ក៏ត្រូវរដ្ឋអំណាចបង្ខំឲ្យឈប់ណែនាំព្រះសហគមន៍គ្រីស្តបរិស័ទដែរ។

ចំណែកគ្រីស្តបរិស័ទនៅកំពង់គវិញមាននៅសល់គ្នាតែពាក់កណ្តាលប៉ុណ្ណោះ គឺប្រហែល ៤០០ នាក់ នៅក្នុងចំណោមស្ត្រីមេម៉ាយប្រហែល ៤០ នាក់។ គ្រីស្តបរិស័ទ

កំពង់គចំនួន ១២ គ្រួសារ បានភៀសខ្លួនទៅប្រទេសថៃ ហើយអ្នកដែលនៅសេសសល់បានតាំងទីលំនៅតាមដងស្ទឹងសែន ក្បែរកំពង់ធំ និងនៅព្រៃស្បូវ។ មានគ្រួសារមួយទៀតទៅនៅតាំងគោក។ គ្រីស្តបរិស័ទទាំងនោះប្រកបរបរធ្វើស្រែចម្ការដូចពីដើម។

តាំងពីឆ្នាំ ១៩៧៩ មក រដ្ឋអំណាចបានធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទទាំងអស់នោះគ្មានឈប់ឈរទេ។ នៅឆ្នាំ ១៩៨០ រដ្ឋបាលបានចាប់ឃុំឃាំងគ្រីស្តបរិស័ទប្រហែល ៦០ នាក់ ដោយចោទថា អ្នកទាំងនោះមានការទាក់ទងនឹងពួកតស៊ូ។ រដ្ឋបាលស្រុកក៏បានហាមឃាត់គ្រីស្តបរិស័ទទាំងនោះ មិនឲ្យពាក់សញ្ញាផ្សេងៗ បង្ហាញថាខ្លួនជាគ្រីស្តបរិស័ទឡើយ។ ពេលជួបជុំគ្នាម្តងៗ គ្រីស្តបរិស័ទត្រូវប្រគល់បញ្ជីឈ្មោះសមាជិកទាំងអស់ឲ្យរដ្ឋបាលប្រចាំភូមិ។ ទោះបីយ៉ាងនេះក៏ដោយ ក៏មានស្ត្រីមេម៉ាយម្នាក់បានយកចិត្តទុកដាក់រក្សាជំនឿពួកគេ ទាំងធ្វើបុណ្យជ្រមុជទឹកឲ្យកុមារទាំងអស់។

ប្រជាជននៅក្រុងភ្នំពេញ បានទទួលការអនុញ្ញាតឲ្យវិលត្រឡប់ទៅតាំងទីលំនៅក្នុងក្រុងវិញ ក្រោយគេបង្អស់។ រដ្ឋបាលថ្មីអំពាវនាវរកអ្នករដ្ឋការ និងអ្នកឯកទេសជំនាញឲ្យមកកាន់កាប់កិច្ចការនៅតាមក្រសួងនានា និងនៅតាមរោងចក្រ។

រដ្ឋការថ្មីបានចែកចាយគេហដ្ឋានដល់អ្នកធ្វើការទាំងអស់ ឲ្យរស់នៅជិតរោងចក្រ ឬជិតក្រសួងដែលគេធ្វើការ ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យសកម្មភាពរបស់អ្នកទាំងនោះនិងក្នុងការចែកចាយរបបផង។

រដ្ឋអំណាចថ្មីបានត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ចំពោះប្រជាជនដែលចូលមករស់នៅក្រុងភ្នំពេញនោះ ព្រោះគេខ្លាចមានក្រុម "*ម៉ូលីណាកា* " [១] ដែលជាចលនាតស៊ូមួយក្រោមការដឹកនាំរបស់បក្សសម្តេចសីហនុ បន្លំ ចូលមកជាមួយដែរ។ នៅឆ្នាំ ១៩៨០ មានការបន្ធូរបន្ថយច្រើន ប្រជាជនស្ទើរតែទាំងអស់មានសិទ្ធិអាចវិលត្រឡប់មករស់នៅក្រុងភ្នំពេញវិញបាន។ គ្រីស្តបរិស័ទក៏បានវិលមកក្រុងភ្នំពេញវិញ ដូចប្រជាជនដ៏ទៃទៀតដែរ តែគ្មានអ្នកណាមានសិទ្ធិចូលទៅនៅផ្ទះរបស់ខ្លួនពីសម័យមុននោះទេ។ គេហដ្ឋាននីមួយៗត្រូវរដ្ឋចែកចាយឲ្យប្រជាជន និងអ្នករដ្ឋការ ជិតកន្លែងធ្វើការរៀងៗខ្លួនដូចប្អូនស្រីលោកសាឡាស់ ឈ្មោះសុភាពរៀបរាប់បន្ទាប់ពីបានត្រឡប់ចូលមកភូមិព្រះមាតា នាដើមឆ្នាំ ១៩៨០ ថា៖

*«ខ្ញុំមិនឃើញព្រះវិហារទៀតទេ ហើយគ្រីស្តបរិស័ទក៏បាត់ខ្លួនអស់ ពុំដឹងជានៅឯណា។ ខ្ញុំចូលផ្ទះកំណើតរបស់ខ្ញុំ ឃើញនៅតែរូបថតចាស់ពីរសន្លឹករបស់លោកសាឡាស់លេងស្គីនៅស្រុកបារាំង។ ផ្ទះសម្បែងដីធ្លីទាំងអស់ក្លាយទៅជាសម្បត្តិរដ្ឋ ហើយផ្ទះរបស់គ្រីស្តបរិស័ទត្រូវរដ្ឋចាត់ចែងឲ្យបុគ្គលិករោងចក្រអគ្គិសនី និងបុគ្គលរោងចក្រកៅស៊ូនៅ។ ភូមិគ្រឹះល្អៗក្លាយជាលំនៅឋានរបស់កងទ័ពវៀតណាម ចំណែកផ្ទះមួយចំនួនទៀតរបស់គ្រីស្តបរិស័ទ ត្រូវប្រជាជនរុះរើយកទៅសង់នៅតាមជាយក្រុង និងយកទៅធ្វើជាអុសដុត។ គ្រានោះអាជ្ញាធរក្រុងភ្នំពេញតឹងរ៉ឹងណាស់ នរណាចង់ធ្វើការនៅក្នុងរោងចក្រ ទាល់តែមានឪពុកម្តាយធានាទទួលខុសត្រូវ។ ហើយដោយយើងពុំមានចំណេះបច្ចេកទេសខាងអគ្គិសនី ឬខាងរោងចក្រកៅស៊ូកង់ឡាន យើងពុំអាចចូលធ្វើការ និងរស់នៅទីនោះបានឡើយ ម្ល៉ោះហើយគ្រីស្តបរិស័ទត្រូវខ្ចាត់ខ្ចាយបែកគ្នាអស់»។*

ម្យ៉ាងទៀត នាងសុភាពមិនទាន់ដាច់ចិត្តចាកចោលខ្ទមកំសត់របស់នាងនៅឯតាំងគោកនៅឡើយទេ គឺខ្ទមកំសត់ពោរពេញទៅដោយអនុស្សាវរីយ៍ដ៏សែនជូរចត់ជាច្រើន ហើយដែលមានតម្លៃលើសអ្វីៗទាំងអស់ ចំពោះរូបនាង។ ម្ល៉ោះហើយ ទោះបីជាក្រុមគ្រួសាររបស់នាងទាំងអស់បានវិលត្រឡប់មកនៅភ្នំពេញវិញ ហើយក៏ដោយក៏នាងរស់នៅក្នុងខ្ទមនោះតែម្នាក់ឯងក្នុងរយៈជិតមួយឆ្នាំ។

គ្រីស្តបរិស័ទនៅភ្នំពេញក៏ដូចគ្រីស្តបរិស័ទនៅបាត់ដំបងដែរ បានសង្កេតឃើញថាព្រះសហគមន៍នៅភ្នំពេញបាត់បង់សមាជិកអស់ជាច្រើន ព្រោះគ្រីស្តបរិស័ទមួយចំនួនធំជាអ្នករដ្ឋការឬក៏ជានាយទាហានក្នុងសម័យសីហនុនិងសម័យលន់ ណុល។ គ្រីស្តបរិស័ទម្នាក់ធ្វើជំរឿនគ្រីស្តបរិស័ទទាំងអស់នៅភ្នំពេញ ហើយបានឲ្យដឹងថា ពួកគេមានគ្នានៅសល់តែ ៥៦១ នាក់ប៉ុណ្ណោះ មានគ្រីស្តបរិស័ទ ៦៧ នាក់ទៀតភៀសខ្លួនចូលទៅនៅក្នុងប្រទេសថៃ។ សរុបទៅ គ្រីស្តបរិស័ទពីរភាគបី បានបាត់ខ្លួនទៅហើយ។

នាងសុភាពបានបន្ថែមថា ៖

*«ខ្ញុំបានវិលចូលភ្នំពេញវិញហើយ ប៉ុន្តែ ខ្ញុំមិនអាចធ្វើអ្វីជាមួយបងប្អូនគ្រីស្តបរិស័ទបានទេ ម្យ៉ាងដោយសារយើងរស់នៅដាច់ឆ្ងាយពីគ្នា ហើយខ្វះមធ្យោបាយធ្វើដំណើរផង យើងធ្វើដំណើរដោយជើងជានិច្ច ម្យ៉ាងទៀតបញ្ហា*

*ជីវភាពបានចោទឡើងយ៉ាងធ្ងន់ ព្រោះយើងវិលចូលភ្នំពេញវិញ មានតែបាតដៃទទេ រដ្ឋការផ្គត់ផ្គង់អង្ករ ប្រេង សាប៊ូ ស្ករឲ្យយើងបានសមរម្យដែរ។ ចំណុចសំខាន់បំផុតចំពោះយើងដែលជាគ្រីស្តបរិស័ទ គឺការដែលរដ្ឋមិនអនុញ្ញាតឲ្យជឿព្រះជាម្ចាស់ទេ ដោយរដ្ឋបានកំណត់ថា ជាសាសនាប្រតិកិរិយា។ ដូច្នេះក្នុងការរស់នៅ យើងត្រូវលាក់ខ្លួនជានិច្ច ហើយរាល់ពេលរៀនសូត្រនយោបាយយើងត្រូវស្ដាប់ពេញៗត្រចៀក នូវពាក្យសម្ដីត្មះតិះដៀលចំពោះសាសនាយើង និងចំពោះព្រះជាម្ចាស់។ យើងជាអ្នកធ្វើការយើងមិនក្បត់ព្រះអង្គទេ តែយើងត្រូវប្រកែកថាយើងមិនស្គាល់ព្រះអង្គទេ គឺដូចជាសាវ័កសិលាដែរ។*

*នៅចុងឆ្នាំ ១៩៨០ មានបូជាចារ្យម្នាក់មកពីប្រទេសវៀតណាម។ យើងបានលួចអញ្ជើញលោកមកអភិបូជានៅផ្ទះបងម្នាក់។ លោកបានណែនាំ និងផ្ដែផ្ដាំឲ្យយើងខំលាក់ខ្លួន ព្រោះលោកដឹងថា យើងគ្មានសេរីភាពទេ ហើយយើងមានគ្នាតិចណាស់ទៅទៀត ត្រូវធ្វើឲ្យចំនួននេះកើនឡើងវិញ មិនត្រូវឲ្យបាត់បង់ទៅដោយឥតប្រយោជន៍នោះទេ។ គឺនៅក្នុងបុណ្យអភិបូជានេះហើយ ដែលខ្ញុំបានសុំព្រះកាយពីលោក ហើយរៀបចំអាសនៈតម្កល់ព្រះកាយក្នុងផ្ទះគោរពថ្វាយបង្គំជារៀងរាល់រហូតមក។ ក្រោយមកយើងដឹងថា លោកត្រូវរដ្ឋអំណាចចាប់ខ្លួននៅច្បារអំពៅ ហើយយកលោកទៅដាក់គុក ដោយសារតែគ្រីស្តបរិស័ទវៀតណាមម្នាក់បានរាយការណ៍ប្រាប់ដល់រដ្ឋអំណាចថាលោកជាបូជាចារ្យ។ ការនេះបានធ្វើឲ្យយើងមានសេចក្ដីបារម្ភ និងមិនសូវទុកចិត្តគ្នាទៅវិញទៅមក ព្រោះយើងមិនអាចដឹងថា អ្នកណាមួយជាអ្នកក្បត់ដូចជាយូដាសនោះទេ»។*

**ធម៌មេត្តាករុណារបស់ព្រះសហគមន៍ឯទៀតៗ**

តាំងពីខែកញ្ញា ១៩៧៩ មក ព្រះសហគមន៍ជាច្រើននៅក្នុងលោកទាំងមូលជួយប្រជាពលរដ្ឋខ្មែរ។ គេបានបញ្ជូនតំណាងអង្គការមនុស្សធម៌ជាច្រើនមកភ្នំពេញ មានជាអាទិ៍: "*គណៈកម្មការកាតូលិក ប្រឆាំងទុរ្ភិក្ស និងដើម្បីវឌ្ឍនភាព* " (C.C.F.D.) មកពីប្រទេសបារាំងមាន "*គណៈកម្មការអន្តរជាតិ ដើម្បីវឌ្ឍនៈភាពសង្គម និងសេដ្ឋកិច្ច* " (A.R.C.)។ អង្គការទាំងប៉ុន្មាននេះ បានជួយឧបត្ថម្ភតាមគម្រោងការណ៍ជាច្រើន ហើយបានចូលរួមយ៉ាងសកម្មក្នុងការកសាងប្រទេសកម្ពុជាឡើងវិញ រហូតមកទល់សព្វថ្ងៃនេះ។

នៅថ្ងៃ ៦ មករា ឆ្នាំ ១៩៨៣ សម្ដេចប៉ាបបានបង្កើត "*អង្គការទទួលបន្ទុកពង្រឹង និងពង្រីកការប្រកាសដំណឹងល្អក្នុងចំណោមប្រជាជនខ្មែរ* " (B.P.A.C.) ដែលមានភារកិច្ច "*ចាត់ចែង និងពង្រីកការប្រកាសដំណឹងល្អ នៅគ្រប់កន្លែងដែលមានជនជាតិខ្មែររស់នៅ* "។ សម្ដេចប៉ាបបានតែងតាំងលោក អ៊ីវ វ៉ាមូស ដែលជាអតីតអភិបាលព្រះសហគមន៍ប្រចាំប្រទេសកម្ពុជា ឲ្យទទួលខុសត្រូវលើអង្គការនេះ។ នៅឆ្នាំ ១៩៨៤ លោកអភិបាល វ៉ាមូស និងលោក ឡឺស៊ូអែហ្វ ទទួលបន្ទុកទាំងស្រុងនៅក្នុងការណែនាំគ្រីស្ដបរិស័ទនៅប្រទេសកម្ពុជា។ ទោះបីលោកមិនអាចបំពេញភារកិច្ចនេះ នៅក្នុងប្រទេសខ្មែរក៏ដោយ ក៏លោកនៅតែទទួលការខុសត្រូវនៅក្នុងភារកិច្ចនេះដែរ។

ក្នុងរយៈកាលដ៏ពិបាកប៉ុន្មានឆ្នាំនេះ គ្រីស្ដបរិស័ទទាំងកាតូលិក ទាំងក្រុមប្រកាសដំណឹងល្អ បានដើរផ្លូវរួមជាមួយគ្នា។ កាលពីឆ្នាំ ១៩៧៩ ក្នុងចំណោមគ្រូគង្វាលទាំង ១២ នាក់នៃក្រុមប្រកាសដំណឹងល្អខ្មែរ មានតែលោក សៀងអាង ម្នាក់ប៉ុណ្ណោះដែលបានរួចផុតពីការកាប់សម្លាប់ ហើយលោកក៏បានប្រមូលផ្ដុំអ្នក ដែលនៅសល់ទាំងអស់ បង្កើតជាក្រុមជំនុំតូចមួយ។ នៅឆ្នាំ ១៩៨០ លោកគ្រូគង្វាលក្រុមកាល់វ៉ាំង ជាតិបារាំងម្នាក់ឈ្មោះយ៉ូហានក្លាវ៉ូ (Jean Clavaud) ដែលធ្លាប់នៅប្រទេសខ្មែរពីឆ្នាំ ១៩៦៥ ដល់ឆ្នាំ ១៩៧៥ ត្រូវបានអង្គការមនុស្សធម៌ប្រូតេស្ដង់អន្តរជាតិ បញ្ជូនឲ្យមកប្រចាំការនៅប្រទេសកម្ពុជា។ គ្រីស្ដបរិស័ទប្រហែលហាសិបនាក់ទាំងកាតូលិក និងក្រុមប្រកាសដំណឹងល្អតែងជួបប្រជុំគ្នាជាញឹកញាប់។ លោកក្លាវ៉ូ យកចិត្តទុកដាក់គាំទ្រជំនឿរបស់គ្រីស្ដបរិស័ទ ហើយតែងចូលរួមប្រជុំជាមួយពួកគេម្ដងៗដែរ។ តែក្រុមតម្រួតធ្វើអន្តរាគមន៍នៅរាល់ពេលប្រជុំ ហើយសូមកត់ឈ្មោះសមាជិកអង្គប្រជុំទាំងអស់ រួចហាមឃាត់មិនឲ្យប្រជុំទៅទៀតទេ។ លោកគ្រូគង្វាល សៀងអាង ត្រូវគេចាប់ដាក់គុក ហើយលោកក្លាវ៉ូ ត្រូវគេបណ្ដេញ ចេញពីប្រទេស។ បន្ទាប់រួចពីគុកមក លោកសៀងអាង រត់ភៀសខ្លួនទៅប្រទេសថៃ រួចលោកវិលត្រឡប់ មកបំពេញភារកិច្ចរបស់លោកនៅក្រុងភ្នំពេញវិញ។

**«គ្រីស្ដបរិស័ទម្នាក់ៗបានយកផ្ទះរបស់ខ្លួនធ្វើជាវិហារមួយ»**

រដ្ឋបាលបានត្រួតពិនិត្យ និងគៀបសង្កត់ប្រជាជនខ្មែរកាន់តែខ្លាំងឡើងៗ ជាហេតុបណ្ដាលឲ្យកើតការ មន្ទិលសង្ស័យរវាងគ្នាឯងនិងមានការប្ដឹងប្ដល់គ្នាទៅវិញទៅមក។ គ្រីស្ដបរិស័ទខ្លះទៀតឆ្លៀតឱកាសនេះ ដើម្បីទាញយកកម្រៃផ្ទាល់ខ្លួន ដូចនាងសុភាពបានរៀបរាប់ថា៖

*«ចាប់ពីឆ្នាំ ១៩៨២ មក មានគ្រីស្តបរិស័ទខ្លះបានប្រកាសថា៖ "លោកអភិបាលព្រះសហគមន៍បានតែងតាំងខ្លួនគេ ឲ្យធ្វើជាអ្នកទទួលការខុសត្រូវនៅក្នុងព្រះសហគមន៍។ យើងទាំងអស់គ្នាបានអបអរដោយលួចលាក់ និងស្ងាត់ៗ។ តែមិនយូរប៉ុន្មានកិច្ចការដែលគេថា "ធ្វើការងារថ្វាយព្រះសហគមន៍នេះ" បានលេចចេញទៅជាការគួបផ្សំ ដោយលុយកាក់ ហើយបណ្តាលឲ្យមានការមិនទុកចិត្តគ្នា លើបញ្ហាលុយកាក់នោះ។ ដោយសារបញ្ហានេះ ទោះបីជាមានការខ្វះខាតខ្លាំងយ៉ាងណាក៏ដោយ អ្នកដែលមិនរវល់នឹងបញ្ហាលុយកាក់ ក៏បានដកខ្លួនថយចេញឆ្ងាយ ព្រោះគេមិនពេញចិត្តចំពោះអ្នកដែលយកការងារព្រះអង្គធ្វើជាអាជីវកម្មដូច្នេះ។ មួយចំនួនគិតថា ចាំពេលណាមានច្បាប់ទម្លាប់ត្រឹមត្រូវឲ្យគោរពថ្វាយបង្គំព្រះជាម្ចាស់ និងមានលោកបូជាចារ្យឬក៏ដូនជីទើបគេរួបរួមជាមួយគ្នា។ នេះជាចរិតពិតរបស់គ្រីស្តបរិស័ទដែលមានទម្លាប់ជឿទុកចិត្តលើអ្នកបួសជាងឧបាសកគ្នាឯង តែគេមិនភ្លេចព្រះអង្គទេ ផ្ទុយទៅវិញជំនឿគេកាន់តែរឹងមាំខ្លាំងឡើងថែមទៀត ដ្បិតក្នុងរបប ប៉ុលពត ពេលណាក៏គេថ្វាយជីវិតទៅលើព្រះអង្គដែរ ពេលនេះគេបានរួចរស់ជីវិតគេកាន់តែមានជំនឿលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គថែមទៀត តែគេគ្រាន់តែកំណត់ថាធ្វើបុណ្យជាមួយអាចារ្យបាំងឈើ គឺកាន់តែធ្វើឲ្យគេមានបាបជាមួយព្រះអង្គមិនមែនបានទៅជាទីគាប់ព្រះហឫទ័យរបស់ព្រះអង្គទេ ហើយម្យ៉ាងទៀតគេក៏ពុំព្រមឲ្យខ្លួនគេ ក្លាយទៅជាគ្រាប់អង្ករសម្រាប់អាចារ្យយកទៅដាំបាយហូបឆ្ងាញ់ឆ្អែតស្រួលក្នុងគ្រួសារនោះដែរ»។*

ទោះបីជាគ្រីស្តបរិស័ទមិនបានទទួលការអនុញ្ញាត ដើម្បីជួបជុំគ្នាក៏ដោយ ក៏គេនៅតែអធិដ្ឋានដោយ ស្ងាត់តាមក្រុមតូចៗ។ គេអាចទទួលការអនុញ្ញាតពីក្រុមតម្រួតបានលុះត្រាតែគេសុខចិត្តទទួលការត្រួតពិនិត្យពីរដ្ឋអំណាចរាល់ពេលវេលា និងព្រមឲ្យគេកត់ឈ្មោះសមាជិកដែលមកជួបជុំគ្នាផងដែរ។ ពួកគេជួបជុំគ្នាតាមគ្រួសារ នៅជុំវិញរូបឈើឆ្កាងរបស់លោកអភិបាល យូសែប ឆ្មារ សាឡាស់។ បន្ទាប់ពីស្តាប់គម្ពីរ និងអធិដ្ឋានមក ម្នាក់ៗចូលមកគោរពរូបឈើឆ្កាងនេះទុកជាសញ្ញាសម្គាល់ បញ្ជាក់ថាពួកគេនៅរួមផ្លូងជាមួយព្រះសហគមន៍សកលជានិច្ច។ មានយាយម្នាក់ទទួលភារកិច្ចទាក់ទងជាមួយនឹងគ្រួសារគ្រីស្តបរិស័ទទាំងអស់។ ជួនកាលមានគ្រីស្តបរិស័ទ

ដែលធ្វើការនៅក្នុងក្រសួងស៊ីវិល ត្រូវរដ្ឋអំណាចបញ្ជូនឲ្យទៅបំពេញបេសកកម្ម នៅវៀតណាម គាត់ឆ្លៀតយកព្រះកាយមកវិញ ហើយចែកទៅគ្រីស្តបរិស័ទ នៅបាត់ដំបងនិងទៅគ្រីស្តបរិស័ទនៅចំណោមទៀតផង។

នាងសុភាពបានរៀបរាប់បន្ថែមទៀតថា ៖

*«ក្រៅពីអធិដ្ឋានតាមគ្រួសារនាថ្ងៃអាទិត្យ យើងរស់នៅយ៉ាងសាមញ្ញសមរម្យ និងឆ្លៀតយកពេលទំនេរពីការងាររដ្ឋ ទៅសួរសុខទុក្ខបងប្អូនដែលមានជំងឺ។ ជួនកាលបងម្នាក់បានទទួលសៀវភៅ "ជីវិតថ្មី" ដូច្នេះ ក្រៅពីការជួបជុំគោរពព្រះជាម្ចាស់គាត់បាននិយាយរៀបរាប់ពីខ្លឹមសារក្នុង "ជីវិតថ្មី" ។ ជួនកាល គាត់អាននូវចំណុចសំខាន់ៗ ឲ្យយើងទាំងអស់គ្នាស្តាប់។ ដោយបំពេញកិច្ចការទាំងនេះ យើងដោះស្រាយបានមួយចំនួននូវទំនាស់ក្នុងគំនិតបងប្អូនដែលចោទថា អ្នកធ្វើការបម្រើព្រះអង្គសុទ្ធតែធ្វើឡើងនិងខិតខំធ្វើ ដោយសារតែបានទទួលលុយកាក់ពីព្រះសហគមន៍។ល។ យើងបានធ្វើឲ្យគេមានការទុកចិត្តមកលើយើង ព្រោះយើងសុទ្ធតែជាអ្នកធ្វើការមិនមែនជាអ្នកដើរលេងទេ។ ដោយគ្រីស្តបរិស័ទភាគច្រើនជាបុគ្គលិករដ្ឋ ដូច្នេះ យើងអាចយល់ចិត្តគ្នាបានល្អ យល់ពីស្ថានភាពនយោបាយ ស្ថានភាពសេដ្ឋកិច្ចជីវភាពរស់នៅ យល់ពីស្ថានភាពប្រទេសជាតិ ហើយយើងអាចស្រុះស្រួលគ្នាបានច្រើន។ យើងដឹងច្បាស់ណាស់ថា យើងមិនមែនខ្វះជាតិអំបិលទេយើងមិនមែនត្រជាក់នោះទេ ផ្ទុយទៅវិញ ជំនឿយើងនៅតែរឹងមាំជានិច្ចតែដោយយើងនៅសល់គ្នាតិចពេក ដូច្នេះ យើងត្រូវរស់យ៉ាងណាឲ្យបានគាប់ព្រះហឫទ័យព្រះអង្គ និងខិតខំធ្វើយ៉ាងណាឲ្យព្រះសហគមន៍ខ្មែរបានគង់វង្សល្អ។ យើងមិនខ្លាចស្លាប់ទេ តែយើងក៏មិនត្រូវឲ្យសមាជិករបស់ព្រះសហគមន៍បាត់ខ្លួនទៅដោយឥតប្រយោជន៍នោះដែរ»។*

នៅខែមករា ឆ្នាំ ១៩៨៦ គ្រីស្តបរិស័ទម្នាក់បានរៀបរាប់ពីជីវិតរបស់ព្រះសហគមន៍ដូចតទៅ៖

*«យើងនាំយកព្រះកាយទៅជូនអ្នកឈឺជិតស្លាប់ យើងជួបជុំគ្នាថ្ងៃបុណ្យចម្លង ថ្ងៃភ្ជុំបិណ្ឌ ថ្ងៃចូលឆ្នាំខ្មែរ ដើម្បីស្តាប់គម្ពីរ និងអធិដ្ឋាន។ យើងរៃប្រាក់ពីគ្នីគ្នាយើងដើម្បីជួយគ្រួសារខ្លះ ដែលពុំមានអ្វីសម្រាប់ព្យាបាលជំងឺរបស់ខ្លួន។ យើងបានជួយឧបត្ថម្ភដល់គ្រួសារ ដែលគ្មានថវិកាសម្រាប់ធ្វើបុណ្យសព។ យើងបាន*

*ស្រង់ថ្ងៃបុណ្យទាំងឡាយពីប្រតិទិនវៀតណាម កត់ចុះទៅលើប្រក្រតីទិនរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា គឺក្នុងឆ្នាំនេះ យើងចែកប្រក្រតីទិនបែបនោះបានមួយរយច្បាប់។ យើងបានចម្លងធម៌ដូចជា ធម៌ "ឱព្រះបិតា" ធម៌"ប្រកាសជំនឿ" ធម៌"សូមលើកតម្កើង" ធម៌"សូមក្រាបសំពះ" ធម៌"សូមតម្កើងសិរីរុងរឿង" ព្រមទាំងចម្រៀងខ្មែរខ្លះចែកដល់គ្រួសារកាតូលិក។ យើងក៏បានបង្ហាត់បង្រៀនសាសនាដល់អ្នកជឿថ្មីៗ ដែលតាំងពីឆ្នាំ ១៩៨០ មក មានក្មេងចំនួន ២៣ នាក់ និងមនុស្សពេញវ័យ ២ នាក់បានទទួលបុណ្យជ្រមុជទឹក ហើយនៅមានកុមារជាច្រើនដែលពុំទាន់បាន ទទួលបុណ្យជ្រមុជទឹកនៅឡើយ ព្រោះឪពុកម្ដាយមានធុរៈនិងកង្វល់ក្នុងការចិញ្ចឹមជីវិត។ យើងក៏បានធ្វើជាសក្សីនៅក្នុងពិធីមង្គលការជាច្រើនដែរ។ តាំងពីពីរឆ្នាំមក គ្រីស្តបរិស័ទបានយកផ្ទះរបស់ខ្លួនធ្វើជាវិហារមួយ ក្រុមគ្រួសារនីមួយៗបានត្រឡប់ទៅជាអាសនៈសម្ងាត់របស់ព្រះអម្ចាស់។ ក្នុងឱកាសបុណ្យណូអែល ផ្ទះនីមួយៗត្រឡប់ទៅជាកន្លែងដែលព្រះកុមារយេស៊ូមានកំណើតមក»។*

នៅដំណាច់ឆ្នាំ ១៩៨៦ ក្រុមកាតូលិកបានរើសគណៈកម្មាធិការរួម ដែលមានសមាជិក ៤នាក់ទទួលខុសត្រូវក្នុងដំណើររបស់ព្រះសហគមន៍ ដូចសេចក្តីដែលនាងសុភាពបានថ្លែង៖

*«ដើម្បីឲ្យការអធិដ្ឋានរបស់យើង មានលក្ខណៈជាខ្មែរសុទ្ធសាធ និងឲ្យការកោតសរសើរព្រះជាម្ចាស់មានសំឡេងតែមួយ ជាភាសាខ្មែរ»។*

តាមពិតព្រះសហគមន៍នៅប្រទេសកម្ពុជា បានជួបប្រទះនូវឧបសគ្គជាច្រើនទៀតដូចពីជំនាន់មុនៗដែរ គឺតាំងពីឆ្នាំ ១៩៧៩ មក ក្នុងចំណោមអាណិកជនវៀតណាមដែលមករស់នៅក្នុងប្រទេសខ្មែររាប់សែននាក់នោះ មានគ្រីស្តបរិស័ទកាតូលិកប្រហែល ២.០០០ នាក់ដែរ។ អ្នកទាំងនោះបានតាំងទីលំនៅនៅវត្តចំប៉ា ដែលស្ថិតនៅចម្ងាយប្រហែល ១២ គ.ម. ខាងត្បូងក្រុងភ្នំពេញ។ មានគ្រីស្តបរិស័ទវៀតណាមមួយចំនួនទៀតបានមកតាំងទីលំនៅនៅជាយក្រុងភ្នំពេញ និងនៅបាត់ដំបង។ ក្នុងចំណោមគ្រីស្តបរិស័ទវៀតណាមទាំងនេះ មានអ្នកខ្លះធ្លាប់រស់នៅប្រទេសខ្មែរកាលពីមុន ហើយត្រូវគេដេញនៅឆ្នាំ ១៩៧០ ប៉ុន្តែភាគច្រើនជាអាណិកជនថ្មី។

ថ្វីបើអាជ្ញាធរខ្មែរនៅភ្នំពេញហាមឃាត់យ៉ាងណាក៏ដោយ ក៏គ្រីស្តបរិស័ទវៀតណាមនៅវត្តចំប៉ាបានសង់ព្រះវិហារមួយ ហើយមានដូនជីវៀតណាមម្នាក់ជាអ្នកបង្ហាត់បង្រៀន

កុមារាកុមារីប្រហែល ១០០ នាក់ អំពីគ្រីស្តសាសនាផង។ ក្នុងឆ្នាំ ១៩៨៦ គ្រីស្តបរិស័ទវៀតណាមទាំងនេះបានទទួលការអនុញ្ញាតឲ្យជួបជុំគ្នា ដើម្បីធ្វើបុណ្យចូលឆ្នាំវៀតណាម។ បន្ទាប់មកក្នុងឱកាសបុណ្យណូអែល អ្នកធ្វើដំណើរបានឃើញមានផ្ទាំងសំពត់ធំៗ សរសេរជាភាសវៀតណាម និងភាសាខ្មែរខ្លះ។

ព្រឹត្តិការណ៍ទាំងនេះ បានធ្វើឲ្យគ្រីស្តបរិស័ទខ្មែរបារម្ភ អំពីចំនួនគ្រីស្តបរិស័ទវៀតណាមនៅក្នុងប្រទេសខ្មែរ។ ម្យ៉ាងទៀត អាជ្ញាធរភ្នំពេញនៅតែបដិសេធមិនព្រមទទួលស្គាល់វត្តមានរបស់គ្រីស្តបរិស័ទខ្មែរទាល់តែសោះ។ គ្រីស្តបរិស័ទខ្មែរទាំងនោះបានធ្វើសំណូមពរដល់រដ្ឋាភិបាលជាច្រើនលើក សុំច្បាប់អនុញ្ញាតជួបជុំគ្នា ក៏ប៉ុន្តែសំណូមពរទាំងនេះពុំដែលទទួលចម្លើយណាមួយទាល់តែសោះ ថ្វីបើមានអន្តរាគមន៍ពីសំណាក់លោកអភិបាលព្រះសហគមន៍បរទេសខ្លះៗ ដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក៏ដោយ។

គ្រីស្តបរិស័ទខ្មែរខ្លះ ជាពិសេសអ្នករដ្ឋការមិនហ៊ានចូលរួមជាមួយគ្រីស្តបរិស័ទវៀតណាមនៅក្នុងពិធីបុណ្យផ្សេងៗ ដែលគ្រីស្តបរិស័ទវៀតណាមជាអ្នករៀបចំធ្វើនោះទេ។ មានគ្រីស្តបរិស័ទខ្មែរខ្លះនិយាយថា «*មានអ្នកខ្លះចង់បង្ខំយើងឲ្យចូលរួមជាមួយពួកវៀតណាម!*»។

**ការបន្តនៃសង្គ្រាមស៊ីវិល**

នៅថ្ងៃ ២៨ កក្កដា ១៩៨៦ នៅវ្លាឌីវ៉ូស្តុក (Vladivostock) លោកមីកាអែលហ្គ័របាឆេវ (Mikhaïl Gorbatchev) បានថ្លែងសុន្ទរកថាដ៏សំខាន់មួយ បញ្ជាក់ពីគោលនយោបាយថ្មីៗរបស់សហភាពសូវៀតចំពោះភូមិភាគអាស៊ី។ តាំងពីពេលនោះមកសភាពការណ៍នយោបាយនៅប្រទេសកម្ពុជាបានប្រែបន្តិចម្តងៗ។ នៅខែធ្នូ ឆ្នាំ ១៩៨៧ សម្តេចសីហនុដែលជាប្រធាន "*រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ*" និង លោក ហ៊ុន សែន ដែលជារដ្ឋមន្ត្រីទីមួយនៃ "*សាធារណរដ្ឋប្រជាមានិតកម្ពុជា*" បានជួបគ្នាជាលើកដំបូងនៅប្រទេសបារាំង។ ក្រោយមកមានការជួបគ្នាជាច្រើនលើកទៀតដើម្បីរកមធ្យោបាយដោះស្រាយបញ្ហាខ្មែរ។ ថ្ងៃទី ១ ឧសភា ឆ្នាំ ១៩៨៩ លោកហ៊ុនសែនបានប្រកាសនូវរដ្ឋធម្មនុញ្ញថ្មីមួយ គឺសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រឡប់ទៅជា "*រដ្ឋកម្ពុជា*" ទទួលស្គាល់ព្រះពុទ្ធសាសនាទុកជាសាសនាជាតិ។ ក្នុងខែសីហា ១៩៨៩ មានចែងសន្និសិទ្ធនៅក្រុងប៉ារីសមួយ ដើម្បីដោះស្រាយបញ្ហាខ្មែរតែសន្និសីទនេះត្រូវបរាជ័យទាំងស្រុង។ ភាគីខ្មែរទាំងបួននៅតែបន្តការចរចារទៅមុខទៀតទោះបីជាពុំឃើញមានលទ្ធផល

អ្វីក៏ដោយ។

បន្ទាប់ពីវៀតណាមបានប្រកាសជាផ្លូវការថា ដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជានៅថ្ងៃទី ២៦ កញ្ញា ១៩៨៩ មក កងទ័ពខ្មែរក្រហមព្រមទាំងកងទ័ពតស៊ូទាំងពីរក្រុមទៀតចេះតែវាយកកងទ័ពរបបភ្នំពេញ។ ចំណែករដ្ឋាភិបាលរបស់លោក ហ៊ុន សែន នៅភ្នំពេញវិញ បានខិតខំទាក់ទាញសេចក្តីអនុគ្រោះ និងរកការគាំទ្រពីមតិជាតិនិងអន្តរជាតិ ដើម្បីទប់ទល់នឹងខ្មែរក្រហមព្រមទាំងចលនាតស៊ូទាំងពីរក្រុមទៀត។

ថ្វីបើបញ្ហាសាសនាមិនមែនជាបញ្ហាសំខាន់របស់គូចរចាក៏ដោយ ក៏របបក្រុងភ្នំពេញបន្ធូរបន្ថយក្នុងការ ត្រួតត្រាខាងផ្នែកសាសនានានាដែរ ជាពិសេសចាប់ពីឆ្នាំ ១៩៨៦ មក។

## ព្រះពុទ្ធសាសនាជាសាសនាជាតិ

ក្នុងសម័យខ្មែរក្រហម (១៩៧៥-១៩៧៩) ពួកគេបានបំបាត់ព្រះពុទ្ធសាសនាចោល គឺពួកគេបានបង្ខំ លោកសង្ឃទាំងអស់ឲ្យសឹកនិងហាមផ្តាច់មិនឲ្យធ្វើបុណ្យអ្វីទាំងអស់។ បន្ទាប់ពីកងទ័ពវៀតណាមបានចូល "*រំដោះ*" ប្រទេសកម្ពុជានាឆ្នាំ ១៩៧៩ មក របបក្រុងភ្នំពេញបានអនុគ្រោះឲ្យមានព្រះពុទ្ធសាសនាឡើងវិញ ប៉ុន្តែព្រះពុទ្ធសាសនាស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹងជាទីបំផុត ពីសំណាក់អាជ្ញាធរក្រុងភ្នំពេញ។ ប្រជាជនដែលចង់បួសជាព្រះសង្ឃត្រូវមានអាយុចាប់ពី ៥៥ ឆ្នាំឡើងទៅ ហើយត្រូវមានប្រវត្តិរូបស្អាតល្អទៀតផង។ បេក្ខជនដែលចង់បួស ត្រូវធ្លាប់បម្រើបដិវត្តន៍តាំងពីដើមមក ហើយត្រូវធ្វើប្រវត្តិរូប និងជូនពាក្យសុំរបស់ខ្លួនទៅឲ្យរណសិរ្សស្នេហាជាតិពិនិត្យមើលយ៉ាងហ្មត់ចត់។ ព្រះសង្ឃទាំងនោះ ត្រូវចិញ្ចឹមជីវិតដោយខ្លួនលោក និងគ្មានសិទ្ធិបិណ្ឌបាតប្រជាជដូចកាលពីដើមឡើយ។ មិនតែប៉ុណ្ណោះសោត ព្រះសង្ឃត្រូវបង់ពន្ធអាករឲ្យរដ្ឋ ហើយត្រូវទទួលការអប់រំខាងមនោគមវិជ្ជា ម៉ាក្ស លេនីន ជារៀងរាល់សប្តាហ៍ ដូចជាអ្នករដ្ឋការឯទៀតៗដែរ។ តាមយោបល់ពុទ្ធបរិស័ទដែលរត់ភៀសខ្លួនមកក្រៅ៖ «*ព្រះសង្ឃត្រូវទេសនា ដោយបញ្ចូលលិទ្ធិម៉ាក្សលេនីន ឲ្យបានស្មើនឹងទ្រឹស្តីរបស់ព្រះពុទ្ធ*»។

សម្តេចសង្ឃ ទេព វង្ស ដែលជាសមាជិកនៃរណសិរ្សស្នេហាជិត តែងទទួលប្រតិភូអន្តរជាតិទាំងឡាយ ដែលធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ដើម្បីបង្ហាញឲ្យ

ជនជាតិបរទេសទាំងនោះដឹងថា ប្រទេសកម្ពុជាមានសេរីភាពខាងជំនឿ ពេញលេញឡើងវិញហើយ។

ចាប់ពីឆ្នាំ ១៩៨៦ មករដ្ឋអំណាចនៅប្រទេសកម្ពុជា បានប្រែនយោបាយផ្នែកខាងសាសនា។ អ្នកដែលចង់បួសធ្វើជាព្រះសង្ឃ អាចបួសបានតាមបំណងរបស់ខ្លួន។ អាជ្ញាធរភ្នំពេញបានអនុញ្ញាតឲ្យធ្វើពិធីបុណ្យព្រះពុទ្ធសាសនាផ្សេងៗឡើងវិញ ហើយអនុញ្ញាតឲ្យពុទ្ធបរិស័ទជួសជុលវត្តអារាមឡើងវិញផង។ ជាពិសេសទៅទៀត នៅខែកក្កដា ឆ្នាំ ១៩៨៨ វិទ្យុជាតិបានផ្សាយធម៌ទេសនាជាលើកទីមួយ។ ខែកុម្ភៈ ឆ្នាំ ១៩៨៩ ពេលលោករដ្ឋមន្ត្រីទី១ ហ៊ុន សែន ទៅធ្វើទស្សនកិច្ចនៅតំបន់កំពត លោកសុំអភ័យទោសពីសំណាក់ពុទ្ធបរិស័ទ អំពីអ្នកកាន់អំណាចបានធ្វើទុក្ខបុកម្នេញដល់ពុទ្ធសាសនានេះ។ នៅខែមេសា ឆ្នាំ ១៩៨៩ មានទាំងរដ្ឋមន្ត្រីជាច្រើនរូប ទាំងប្រមុខរដ្ឋផង បានចូលរួមនៅក្នុងពិធីដង្ហែរព្រះពុទ្ធរូបនៅក្រុងភ្នំពេញ។ តាមប្រភពច្បាស់ការបានឲ្យដឹងថា ប្រទេសខ្មែរមានព្រះពុទ្ធសង្ឃចំនួន ៨.០០០ អង្គ ហើយវត្តអារាមចំនួន ៣.០០០ បានជួយជួសជុលឡើងវិញរួចហើយ។

**សាសនាអ៊ីស្លាម**

ទោះបី មានអ្នកកាន់សាសនាអ៊ីស្លាមនៅប្រទេសកម្ពុជាច្រើនបានចូលរួមធ្វើបដិវត្តន៍តាំងពីឆ្នាំ ១៩៧០ មកក៏ដោយ ក៏ខ្មែរក្រហមបានចាប់ពួកអ្នកកាន់សាសនាអ៊ីស្លាមយកទៅសម្លាប់ ឬធ្វើទារុណកម្មយ៉ាងឃោរឃៅដែរ។ ព្រះវិហាររបស់ពួកគេត្រូវខ្មែរក្រហមរុករានដុតបំផ្លាញគម្ពីរចោលផង។ ខ្មែរក្រហមបានបង្ខំអ្នកកាន់សាសនាអ៊ីស្លាម ជាពិសេសស្ត្រីអ៊ីស្លាមឲ្យលះបង់ទំនៀមទម្លាប់របស់ខ្លួនចោល ដោយបង្ខំពួកគេឲ្យ ស្លៀកពាក់ខោអាវខ្មៅដូចជនជាតិខ្មែរ ឲ្យចិញ្ចឹមជ្រូកនៅក្នុងព្រះវិហារ ព្រមទាំងឲ្យបរិសភោគសាច់ជ្រូកថែមទៀតផត។ ប្រជាជនក្នុងភូមិចាមជាច្រើនបានបះបោរប្រឆាំងនឹងខ្មែរក្រហម តែខ្មែរក្រហមបានសម្លាប់រង្គាលទាំងភូមិៗយ៉ាងសែនឃោរឃៅ។

ចាប់ពីឆ្នាំ ១៩៧៩ មក ពួកអ្នកកាន់សាសនអ៊ីស្លាមមានសេរីភាពច្រើនជាងអ្នកកាន់សាសនាដទៃទៀត ហើយមានពួកគេខ្លះបានកាន់កាប់ក្រសួងធំៗផង។ វិហារអ៊ីស្លាមចាស់ៗនៅជុំវិញក្រុងភ្នំពេញបានបើកទ្វារឡើងវិញ។ មិនតែប៉ុណ្ណោះ ពួកអ្នកកាន់សាសនាអ៊ីស្លាមបានកសាងវិហារថ្មីៗថែមទៀតផង។ ព្រឹត្តិការណ៍នេះ ជាប់ទាក់ទង

នឹងបញ្ហានយោបាយ។ រដ្ឋអំណាចក្រុងភ្នំពេញបានទទួលស្គាល់សាសនាអ៊ីស្លាម ជាផ្លូវការ ព្រោះគេចង់ឲ្យអ្នកកាន់សាសនានេះគាំទ្រគេជាពិសេសទៅទៀត គឺចង់ឲ្យប្រទេសធំៗខ្លះដែល មានសាសនាអ៊ីស្លាមជាសាសនាជាតិ ដូចជាប្រទេសឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី និងប្រទេសអារ៉ាប់ជាច្រើនទៀតនៅមជ្ឈិមបូព៌ាគាំទ្រ។

**រដ្ឋអំណាចទទួលស្គាល់គ្រីស្តបរិស័ទ**

ខ្មែរក្រហមបានកម្ទេចចោលនូវអ្វីៗជាសញ្ញាសម្គាល់នៃគ្រីស្តសាសនា។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានសាងអាគារសាធារណៈនៅកន្លែងវិហារខ្លះដែលខ្មែរក្រហមបានកម្ទេចចោលនោះ ដូចនៅកន្លែងព្រះវិសាលវិហារក្រុងភ្នំពេញ រដ្ឋអំណាចបានសង់ស្ថានីយ៍ទូរគមនាគមន៍តាមផ្កាយរណប។ នៅកន្លែងព្រះវិហារព្រះមាតា រដ្ឋអំណាចសង់អាគារពេទ្យវិញ។ រដ្ឋាភិបាលថ្មីបានកសាងអាគារដូច្នេះ ដូចជាចង់បំផ្លាញគ្រីស្តសាសនាដែរ។

ថ្វីត្បិតតែរដ្ឋធម្មនុញ្ញចុះថ្ងៃទី ១ ឧសភា ឆ្នាំ ១៩៨៩ ទទួលស្គាល់សេរីភាពខាងជំនឿ និងខាងសាសនាក៏ដោយ ក៏មួយខែក្រោយមក គឺនៅខែមិថុនាក្រុមប្រឹក្សារដ្ឋមន្ត្រីនៅតែហាមឃាត់ "*ការផ្សព្វផ្សាយគ្រីស្តសាសនានៅប្រទេសកម្ពុជា* " ។ អស់លោកអនុគ្រោះតែ "*ការទទួលព្រះគម្ពីរ*" និងសៀវភៅខ្លះៗ ព្រមទាំងអំណោយជាសម្ភារៈផ្សេងៗពីអង្គការមនុស្សធម៌ប៉ុណ្ណោះ។

នៅខែសីហា ឆ្នាំ ១៩៨៩ រដ្ឋមន្ត្រីទីមួយឆ្លើយតបនឹងសំណួរមួយរបស់មេធាវីអាមេរិកាំងម្នាក់ថា៖ *«រដ្ឋកម្ពុជាគ្មានបំណងឲ្យជនបរទេសនាំសាសនាផ្សេងៗ ចូលមកក្នុងប្រទេសកម្ពុជាទេ ក៏ប៉ុន្តែ រដ្ឋនឹងរិះគិតអំពីសំណូមពរទាំងឡាយរបស់ជនជាតិខ្មែរ ដែលរស់នៅក្នុងប្រទេស»*។ ប៉ុន្តែ បើតាមលោករដ្ឋមន្ត្រីដឹងវិញ គ្មានគ្រីស្តបរិស័ទ ណាបានធ្វើពាក្យសុំទេ ម្យ៉ាងទៀតលោកយល់ថា តាំងពីឆ្នាំ ១៩៨០ មកម្ល៉េះ គ្រីស្តបរិស័ទមានសេរីភាពគោរពសាសនារបស់ខ្លួន ទោះបីពួកគេគ្មានព្រះវិហារក៏ដោយ ក៏គ្រីស្តបរិស័ទតែងជួបជុំគ្នាធ្វើពិធីផ្សេងៗ នៅតាមផ្ទះដែរ។

ថ្ងៃទី ១៨ មករា ឆ្នាំ ១៩៩០ តាមសំណូមពររបស់លោករដ្ឋទូតប្រទេសហុងគ្រី រដ្ឋាភិបាលក្រុងភ្នំពេញ យល់ព្រមអនុញ្ញាតឲ្យគ្រីស្តបរិស័ទកសាងវិហារមួយ សម្រាប់គ្រីស្តបរិស័ទទាំងអស់។ ព្រះវិហារនេះត្រូវសង់ឡើងនៅលើកន្លែងមួយ ស្ថិតនៅចម្ងាយប្រហែល ៦ គ.ម. ពីក្រុងភ្នំពេញ។ គេបានបង្កើតគណៈកម្មាធិការចម្រុះមួយ ដែលមានក្រុមកាតូលិក ក្រុមប្រូតេស្តង់ផ្សេងៗរួមគ្នា ហើយនិងរណសិរ្សស្នេហាជាតិចូលរួមផង ដើម្បីដឹកនាំនិងគ្រប់គ្រងវិហារនេះ។

ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩០ គណៈកម្មាធិការព្រះសហគមន៍កាតូលិកសរសេរលិខិតមួយច្បាប់ផ្ញើជូនប្រធានាធិបតីរដ្ឋកម្ពុជា សុំអនុញ្ញាតធ្វើពិធីបុណ្យចូលឆ្នាំខ្មែរ (១៣-១៥ មេសា) "*ទៅតាមប្រពៃណីគ្រីស្តសាសនា*"។ នៅថ្ងៃ ៣ មេសា ការិយាល័យនយោបាយមជ្ឈិមបក្សអនុម័តយល់ព្រម ហើយថ្ងៃទី ៩ មេសា លោកជា ស៊ីម ជាប្រធានរណសិរ្សជាតិបានចុះហត្ថលេខាលើលិខិតអនុញ្ញាតមួយច្បាប់ ដែលមានចុះផ្សាយនៅតាមវិទ្យុជាតិ និងទូរទស្សន៍ខ្មែរ។ ក្នុងលិខិតនោះ រដ្ឋអំណាចទទួលស្គាល់ជាផ្លូវការណ៍នូវវត្តមានរបស់គ្រីស្តបរិស័ទខ្មែរ និងបានបរិយាយពីគ្រោះមហន្តរាយ ដែលគ្រីស្តបរិស័ទ និងគ្រីស្តសាសនាបានទទួលក្នុងរបបខ្មែរក្រហម។

> *«ពួកខ្មែរក្រហមបានបំផ្លាញចោលគ្រីស្តសាសនា ដូចសាសនាដទៃទៀតដែរ។ ដោយសាសនានេះ មានដើមកំណើតមកពីបស្ចឹមប្រទេស បន ប៉ុល ពត អៀង សារី បានកម្ទេចសាសនានេះ យ៉ាងសាហាវនិងឃោរឃៅខ្លាំងជាងសាសនាដទៃទៀត។ ព្រះវិហារត្រូវឈូសចោលទាំងអស់ ព្រះគម្ពីរដែលជាគោលនិងជាច្បាប់នៃគ្រីស្តសាសនាត្រូវពួកវាដុតបំផ្លាញចោល អ្នកអប់រំសាសនា និងគ្រប់គ្រីស្តបរិស័ទដែលមានចំនួនតិចផងត្រូវគេសម្លាប់យ៉ាងឃោរឃៅស្ទើរតែគ្មានសល់។ រណសិរ្សយល់ថាពេលនេះគួរតែអនុញ្ញាតឲ្យកសាងព្រះវិហារមួយ សម្រាប់គ្រីស្តសាសនា។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរណសិរ្សសង្ឃឹមថា សេចក្តីប្រកាសនេះនឹងបានទទួលការអបអរស្វាគមន៍យ៉ាងទូលំទូលាយពីសំណាក់មជ្ឈដ្ឋានជាតិនិងអន្តរជាតិជាមិនខាន ហើយនឹងបានទទួលជំនួយខាងផ្លូវចិត្ត និងខាងផ្លូវសម្ភារៈ ពីអង្គការអន្តរជាតិនានា ពីគ្រីស្តបរិស័ទនៃប្រទេសផ្សេងៗនៅក្នុងលោក ដើម្បីរួមចំណែកជាមួយគ្រីស្តបរិស័ទខ្មែរ ក្នុងការកសាងសន្តិភាពនិងវឌ្ឍនភាពនៃសង្គមជាតិកម្ពុជា»។*

សេចក្តីប្រកាសនេះ នាំឲ្យគ្រីស្តបរិស័ទទាំងអស់ត្រេកអរនិងរីករាយយ៉ាងខ្លាំងឥតឧបមា ព្រោះជាលើកទីមួយហើយ តាំងពី ១៥ ឆ្នាំមក ដែលគ្រីស្តបរិស័ទមានសិទ្ធិជួបជុំគ្នាធ្វើបុណ្យចម្លង។ ថ្ងៃទី ១៤ មេសា គ្រីស្តបរិស័ទខ្មែរវៀតណាមនិងជនជាតិបរទេសទៀតៗជាង ១៥០០ នាក់ទាំងកាតូលិក ទាំងក្រុមប្រកាសដំណឹងល្អបានជួបជុំគ្នាថ្វាយអភិបូជានៅក្នុងសាលមហោស្រពក្រុងភ្នំពេញ "ចេនឡា" ដោយមានទាំងតំណាងរបស់រណសិរ្សចូលរួមជាមួយដែរ។

ពេលបើកពិធីបុណ្យ តំណាងគ្រីស្តបរិស័ទបានប្រកាសថា៖ «*ជាសំណាងល្អណាស់ក្នុងឱកាសនេះ ដោយមានបូជាចារ្យបរទេសម្នាក់នៅក្នុងអង្គការអន្តរជាតិបានមកបំពេញភារកិច្ចជួយប្រទេសយើង យើងក៏បានអញ្ជើញលោកឲ្យមកចូលរួមអធិដ្ឋានជាមួយយើង*»។

ប៉ុន្មានខែក្រោយមក គ្រីស្តបរិស័ទជិតមួយពាន់នាក់នៅបាត់ដំបង និងនៅចំណោមបានជួបជុំគ្នាថ្វាយអភិបូជានៅក្នុងមន្ទីររបស់រណសិរ្សដែរ។ ទោះបីសេរីភាពថ្មីនេះមិនទាន់រឹងប៉ឹង និងនឹងនរក៏ដោយ ក៏សេរីភាពថ្មីនេះបានបើកផ្លូវនិងផ្តល់សេចក្តីសង្ឃឹមឲ្យគ្រីស្តបរិស័ទដែរ។ បន្ទាប់ពីបានរងទុក្ខគ្រប់បែបយ៉ាងក្នុងរបបខ្មែរក្រហម និងបន្ទាប់ពីបានលាក់ខ្លួនបំពេញអាត្មាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ព្រះសហគមន៍នៅប្រទេសកម្ពុជាមានជីវិតថ្មីឡើងវិញហើយ។

---

(១) លោក គង់ ស៊ីលាស់ និងលោក ញៀម សុផុន បានបង្កើតចលនា "*មូលីណាកា*" ថ្ងៃ ៣១ សីហា ឆ្នាំ ១៩៧៩ ដោយមានក្រុមប្រដាប់អាវុធប្រហែល ៣០ ក្រុម គាំទ្រសម្តេច នរោត្តម សីហនុ។ លោកគង់ ស៊ីលាស់ ទទួលមរណភាពក្នុងខែ សីហា ឆ្នាំ ១៩៨០ នៅជំរំណងចាន់ដោយត្រូវគេបំពុល។ នៅឆ្នាំ ១៩៨១ កងទ័ពរបស់ មូលីណាកា បានចូលធ្វើជាកងទ័ពរបស់សម្តេចសីហនុ។ មានក្រុមជាច្រើន បានប្រឆាំងនឹងរបប ហេង សំរិន គឺមាន «កុកស» «ព្រលឹងខ្មែរ» «ពស់វែក» «ដំរីសត្តុកខៀវ» ជាដើម។

កងទ័ពវៀតណាមបានហាមផ្តាច់ មិនឲ្យប្រជាជនខ្មែរចូលទីក្រុងភ្នំពេញ មកពីកងទ័ពនេះរឹបយករបស់របរទាំងអស់ដែលមាននៅសល់ក្នុងក្រុង។ មុនដំបូងកងទ័ពវៀតណាមយកគ្រឿងចក្រទាំងអស់ទៅស្រុកគេទាំងឡានៗ។ ក្រោយមក ប្រជាជនវៀតណាមបាន "*ជិះ* " ផ្ទះដោយយករបស់របរប្រើប្រាស់ក្នុងផ្ទះឲ្យអស់។ ក្រោយបង្អស់ កងទ័ពនេះអនុញ្ញាតឲ្យរដ្ឋការខ្មែរចូលទៅនៅ។

# ជីវិតទៅអនាគត!

តាំងពីឆ្នាំ ១៩៩០ ប្រវត្តិប្រទេសកម្ពុជាឈានទៅមុខជាលំដាប់។

-ថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩១ នៅទីក្រុងប៉ារីសតំណាង ១៨ ប្រទេស និង លេខាធិការអង្គការសហប្រជាតិបានចុះហត្ថលេខាលើការព្រមព្រៀងរវាងភាគីខ្មែរទាំងបួន ទុកជាកិច្ចបញ្ចប់នៃការចរចា ដែលចាប់ផ្ដើមឡើងនាឆ្នាំ ១៩៨៧។ អង្គការសហប្រជាជាតិសន្យាថានឹងបញ្ជូនកងទ័ព ១៥.០០០ នាក់ និងភ្នាក់ងារស៊ីវិល ៧.០០០ នាក់ពី ៤០ ប្រទេស មកកម្ពុជា ដើម្បីដកអាវុធពីកងទ័ពគ្រប់ភាគីខ្មែរ ត្រួតត្រាលើកិច្ចការរដ្ឋបាលនៃទាំងពីរដែលជាគូប្រឆាំងគ្នា រៀបចំការបោះឆ្នោតដោយសេរីព្រមទាំងដឹកនាំជនភៀសខ្លួនដែលស្នាក់ប្រទេសថៃ ឲ្យធ្វើមាតុភូមិនិវត្តន៍មកកាន់មាតុភូមិខ្លួនវិញ។ គេហៅកងទ័ពនិងជនស៊ីវិលទាំងនោះជាភាសាអង់គ្លេសថា "UNTAC" មានន័យថា "អំណាចបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិនៅលើប្រទេសកម្ពុជា" ។

-ថ្ងៃប្រជាជនកម្ពុជាបោះឆ្នោតនៅថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ ១៩៩៣។ គណបក្សរាជានិយម FUNCINPEC បានសំឡេងច្រើនជាងគេ គឺ៤៥,៤៧% គណបក្សប្រជាជនបាន ៣៨,២២% គណបក្សប្រជាធិបតេយ្យសិរីនិយមព្រះពុទ្ធសាសនា ៣,៨១% គណបក្សម៉ូលីណាកា ១,៣៧%។ តែគណបក្សប្រជាជនដែលកាន់កាប់រដ្ឋអំណាចកងទ័ពនិងប៉ូលិសក្នុងប្រទេសទាំងមូល មិនសុខចិត្តប្រគល់អំណាចឲ្យគណបក្សដែលឈ្នះក្នុងការបោះឆ្នោតទេ។ នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៣ ព្រះអង្គម្ចាស់ចក្រពង្សប្រកាសថាខេត្តទាំងប្រាំពីរប៉ែកខាងកើតនៃប្រទេសកម្ពុជាបែកចេញពីរដ្ឋអំណាចភ្នំពេញ។ តែនៅថ្ងៃទី១៦ ខែដដែល ក្រុមអ្នកបំបែកខ្លួនក៏សុំចុះចូលវិញ ។

-ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៣ តំណាងរាស្ត្រ ១២០ នាក់ទទួលស្គាល់រដ្ឋាភិបាលបណ្តោះអាសន្ន ដែលមានព្រះអង្គម្ចាស់ រណរិទ្ធ ជានាយករដ្ឋមន្ត្រី ទី ១ លោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ ។

-ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ សម្តេចនរោត្តមសីហនុប្រកាសរដ្ឋធម្មនុញ្ញថ្មី ហើយឡើងសោយរាជ្យក្នុងឋានៈជាព្រះមហាក្សត្រ សាជាថ្មី ។

-ថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៩៦ អៀងសារីបែកចេញពីប៉ុលពត ហើយចូលមកធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាលភ្នំពេញ។

-ថ្ងៃទី ៥-៦ ខែកក្កដា ឆ្នាំ ១៩៩៧ កងទ័ពនៃគណបក្សប្រជាជន ដេញកងទ័ពនិយមជ្រុល FUNCINPEC និងទាហានអាណាធិបតេយ្យ។

-ថ្ងៃទី ៦ ខែសីហា ឆ្នាំ ១៩៩៧ រដ្ឋសភាបោះឆ្នោតឲ្យលោកអ៊ឹងហួត ធ្វើជានាយករដ្ឋមន្ត្រីទី១ ។

***

តាំងពីឆ្នាំ ១៩៩០ ព្រះសហគមន៍ក៏បានរីកចម្រើនលូតលាស់ជាលំដាប់ដែរ។ យូរៗទៅគ្រីស្តបរិស័ទដែលខ្ចាត់ខ្ចាយ នាំគ្នាមកជួយជុំគ្នាតាមភូមិតាមស្រុកដែលខ្លួនរស់នៅ ហើយបង្កើតជាសហគមន៍។

មុនដំបូង លោកអេមីលដេតម្ប មករស់នៅភ្នំពេញ ក្នុងនាមអង្គការការីតាសអន្តរជាតិ។ លោកទាក់ទងជាមួយគ្រីស្តបរិស័ទជិតឆ្ងាយ នាំគេឲ្យរួបរួមគ្នា។ លោកធ្វើគម្រោងការអភិវឌ្ឍន៍សហគមន៍នៅភូមិល្វា ក្នុងខេត្តបន្ទាយមានជ័យ ដើម្បីឲ្យមានលទ្ធភាពទៅសួរសុខទុក្ខបងប្អូនគ្រីស្តបរិស័ទនៅភូមិចំណោមដែលនៅជិតនោះដែរ។ លោកក៏ជួយផ្គត់ផ្គង់ដល់មណ្ឌលកុមារកំព្រាមួយនៅបាត់ដំបង ដើម្បីឲ្យមានលទ្ធភាពទៅសួរសុខទុក្ខបងប្អូនកាតូលិនៅបាត់ដំបងដែរ។ លោកទៅបាត់ដំបងជាលើកទីមួយនៅថ្ងៃទី ១៤ មិថុនា ឆ្នាំ ១៩៩០ ហើយថ្វាយអភិបូជាដោយមានគ្រីស្តបរិស័ទជាងមួយពាន់នាក់ ព្រមទាំងមានតំណាងគណបក្ស

ប្រជាជនធ្វើជាអធិបតីផង! ។ នៅភ្នំពេញលោកក៏ខិតខំចងក្រុង ដើម្បីឲ្យអង្គការមនុស្សធម៌កាតូលិកនានារួបរួមគ្នាដែរ។

នៅឱកាសបុណ្យណូអែលឆ្នាំ ១៩៩០ រដ្ឋអំណាចបានប្រគល់អតីតទេវវិទ្យាល័យនៅផ្សារតូចមួយចំណែក ឲ្យព្រះសហគមន៍វិញ។ នៅឆ្នាំ ១៩៩២ រដ្ឋអំណាចក៏ប្រគល់អាគារទាំងមូលមកព្រះសហគមន៍វិញ។ ដូច្នេះ អតីតទេវវិទ្យាល័យនៅផ្សារតូចនោះត្រឡប់មកជាមណ្ឌលនៃព្រះសហគមន៍កាតូលិកនៃភូមិភាគភ្នំពេញ និងប្រទេសកម្ពុជាទាំងមូល។ កាលពីថ្ងៃ ២៥ ខែ មីនា ឆ្នាំ ១៩៩៤ រាជរដ្ឋាភិបាលចងចំណងទូតជាមួយរដ្ឋវ៉ាទីកង់ លោកលុយប្រែសង់ជាអគ្គរាជទូត។

តាំងពីឆ្នាំ ១៩៩២ គ្រីស្តបរិស័ទជាតិកម្ពុជាយល់ឃើញថា គេជាព្រះសហគមន៍នៅប្រទេសរបស់ខ្លួន! មិនមែនព្រះសហគមន៍គ្រាន់តែជាលោកអភិបាល ឬបូជាចារ្យជនជាតិបរទេសនោះទេ!។ គេរួបរួមគ្នាទទួលខុសត្រូវលើព្រះសហគមន៍របស់ខ្លួនថែមទៀត។ ដូច្នេះគេចាត់ចែង "មហាសន្និបាត" មួយឆ្នាំពីរដង ដើម្បីឲ្យតំណាងព្រះសហគមន៍នីមួយៗស្គាល់គ្នាចែកការពិសោធន៍លើការលំបាកនិងសេចក្ដីសង្ឃឹមដល់គ្នាទៅវិញទៅមក ខិតខំដោះស្រាយបញ្ហាជាមួយគ្នា។ គេរិះគិតជាមួយគ្នាអំពីព្រះសហគមន៍ អំពីមុខងាររបស់ខ្លួនធ្វើជាសាក្សីរបស់ព្រះគ្រីស្តក្នុងប្រទេសកម្ពុជា។

ដូច្នេះព្រះសហគមន៍នីមួយៗចាត់ចែងការងារខ្លួនឯងដោយមានអនុគណៈកម្មការបី គឺអនុគណៈកម្មការពិធិបុណ្យ ដែលមានភារកិច្ចទទួលខុសត្រូវចាត់ចែងពិធីផ្សេងៗ អនុគណៈកម្មការបន្តជំនឿសម្រាប់អប់រំក្មេងៗនិងមនុស្សពេញវ័យ ដែលចង់ក្លាយខ្លួនទៅជាគ្រីស្តបរិស័ទ និងអនុគណៈកម្មការសង្គហៈសម្រាប់ដាស់តឿនគ្រីស្តបរិស័ទឲ្យសម្តែងធម៌មេត្តាករុណារបសព្រះជាម្ចាស់ចំពោះអ្នកខ្វះខាត។ អនុគណៈកម្មការទាំងបីនោះមានភារកិច្ចដាស់តឿនគ្រីស្តបរិស័ទទាំងអស់ឲ្យយកចិត្តទុកដាក់បំពេញមុខងារទាំងបីនៃព្រះសហគមន៍ គឺលើកតម្កើង បន្តជំនឿ និងបង្ហាញសេចក្តីស្រឡាញ់អ្នកដទៃ។

ក្រោយពីជនភៀសខ្លួនវិលត្រឡប់មកមាតុភូមិវិញ មានក្រុមគ្រីស្តបរិស័ទជាច្រើនកើតឡើងក្នុងភូមិភាគភ្នំពេញ គឺនៅបឹងទំពុន តាកែវ ក្រុងងុយ។ល។

ថ្ងៃទី ៥ ខែតុលា ឆ្នាំ ១៩៩៧ លោកអេមីលដេតម្បទទួលអគ្គសញ្ញា ជាអភិបាលឧបត្ថម្ភកៈរបស់លោកអ៊ីវ-រ៉ាមូស។ លោកវិរជ័យ កាន់មុខងារជាអ្នកណែនាំគ្រីស្តបរិស័ទភ្នំពេញជំនួសលោក។

ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ រដ្ឋាភិបាលទទួលស្គាល់លក្ខន្តិកៈនៃព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា។

**ភូមិភាគបាត់ដំបង**

នៅឆ្នាំ ១៩៩២ លោកប៉ែរណារ ឌីប្រាស ជាបូជាចារ្យនៃភូមិភាគសងបេរី ហើយដែលធ្លាប់បម្រើជនភៀសខ្លួនខ្មែរ ក្នុងជំរំប្រទេសថៃជាយូរឆ្នាំមកហើយនោះ ក៏បានទៅរស់នៅទីក្រុងបាត់ដំបង។ លោកមកជាមួយយុវជន ៤ នាក់ដែលមានបំណងចង់ក្លាយខ្លួនទៅជាបូជាចារ្យ។ ប៉ុន្តែនៅសម័យនោះមិនទាន់មានសេរីភាពធ្វើដំណើរទៅណាមកណាបានស្រួល លោកក៏ចាប់ផ្តើមទាក់ទងគ្រីស្តបរិស័ទនៅចំណោម នៅតាហែន។ នៅឆ្នាំ ១៩៩៣ រដ្ឋអំណាចសុខចិត្តប្រគល់ដីព្រះសហគមន៍ នៅភូមិរំចេកឲ្យព្រះសហគមន៍វិញ។ លោកប៉ែរណារជួសជុលផ្ទះដូនជីក្រុមគ្រួសារឧបការគុណធ្វើជាទេវវិទ្យាល័យ និងយកបន្ទប់ដេករបស់កុមារកំព្រាធ្វើជាព្រះវិហារសម្រាប់គ្រីស្តបរិស័ទជួបជុំគ្នាជារៀងរាល់ថ្ងៃអាទិត្យ។

យូរៗទៅ ដោយមានគ្រីស្តបរិស័ទដែលជាជនភៀសខ្លួន បានវិលត្រឡប់មកវិញជាច្រើននោះ ព្រះសហគមន៍តូចៗ ដូចជានៅតាពូង នៅស្វាយស៊ីសូផុន សៀមរាប ពោធិសាត់ ប៉ោយប៉ែត។ល។ ក៏កើតមានឡើង។ មានដូនជីក្រុមឧបការគុណពីរនាក់មកនៅក្នុងភូមិចម្ការដូង ( បាត់ដំបង ) ជួយណែនាំគ្រីស្តបរិស័ទនិងទៅសួរសុខទុក្ខនាក់ជំងឺក្នុងពេទ្យ។

ប៉ុន្តែ ភារកិច្ចសំខាន់របស់ព្រះសហគមន៍ គឺអប់រំយុវជនដែលមានបំណងចង់ទៅជាបូជាចារ្យ។ នៅឆ្នាំ ១៩៩២ មានបួននាក់ នៅឆ្នាំ ១៩៩៤ មាននិស្សិតពីរនាក់ទៀត នៅឆ្នាំ ១៩៩៦ មានពីរនាក់ទៀត។ តាំងពី ឆ្នាំ ១៩៩២ លោកសូមឲ្យលោកប៉ុងសូដ៏ទៅជួយបង្រៀនគម្ពីរដល់យុវជនទាំងនោះ។ នៅឆ្នាំ ១៩៩៤ លោកយ៉ូហាន-ម៉ារី បៀរសង្ស ក៏ជួយបង្រៀនអំពីទស្សនវិជ្ជាដែរ។ ការអប់រំ

របស់និស្សិតទាំងនោះមិនគ្រាន់តែជាការរៀនវិជ្ជាប៉ុណ្ណោះទេ គឺរាល់ថ្ងៃសៅរ៍ និងអាទិត្យនិស្សិតទាំងនោះទៅណែនាំព្រះបរិស័ទតាមភូមិនានារួចធ្វើសេចក្ដីរាយការណ៍មករិះគិតជាមួយគ្នា។

នៅថ្ងៃទី ២ កក្កដា ឆ្នាំ ១៩៩៥ លោកទម្លាប់ សុផល ទទួលអគ្គសញ្ញាជាមួយបូជាចារ្យសម្រាប់បម្រើព្រះសហគមន៍នៃភូមិភាគបាត់ដំបង។ លោកសុផលកើតនៅភ្នំពេញ។ ដល់ឆ្នាំ ១៩៨០ លោកភៀសខ្លួនទៅប្រទេសថៃ។ លោករ៉ូប៊ែររីណេ សូមឲ្យលោកសុផលអប់រំអ្នកដែលចង់ទៅជាគ្រីស្តបរិស័ទ។ ក្រោយមកលោកទៅរស់នៅប្រទេសកាណាដា។ នៅទីនោះលោកសម្រេចចិត្តចូលទៅទេវវិទ្យាក្រុងលីយ៉ុង(បារាំង)។ លោកត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ ១៩៩៤ ហើយទៅរស់នៅកំពង់ធំរយៈពេលមួយឆ្នាំ។ ក្រោយពីបានទទួលអគ្គសញ្ញាជាបូជាចារ្យ លោកទទួលមុខងារជាអ្នកណែនាំគ្រីស្តបរិស័ទនៅតំបន់កំពង់ធំ។ លោកយកចិត្តទុកដាក់អប់រំយុវជនយុវនារី បង្កើតក្រុមកុមារកុមារីហៅថា "**ពន្លកថ្មី**"!

**ភូមិភាគកំពង់ចាម**

នៅឆ្នាំ ១៩៩២ លោកអន់ដ្រេឡឺស្វែហ្សជាអភិបាលកំពង់ចាម ក៏អញ្ជើញទៅសួរសុខទុក្ខបងប្អូនគ្រីស្តបរិស័ទនៅកំពង់ចាមនោះ ទោះបីមានចំនួនតិចតួចក៏ដោយ។ នៅឆ្នាំ ១៩៩៣ លោកទៅរស់នៅទីនោះទិញផ្ទះមួយធ្វើជាមណ្ឌលសម្រាប់ជួបជុំគ្នា។ យូរៗទៅលោកទៅទាក់ទងជាមួយគ្រីស្តបរិស័ទនៅក្ដុលលើ នៅរតនគីរី ស្ទឹងត្រែង ស្វាយរៀង ព្រៃវែង។ល។ មានគ្រីស្តបរិស័ទម្នាក់មកពីជំរំនៅមកពីជំរំប្រទេសថៃវិលត្រឡប់ទៅនៅត្រពាំងកណ្ដោល ជាភូមិកំណើតរបស់ខ្លួន។ នៅទីនោះមានប្រជាជនជាច្រើន សូមខ្លួនទៅជាគ្រីស្តបរិស័ទ។

នៅឆ្នាំ ១៩៩៤ មានដូនជីជនជាតិថៃពីរនាក់ទៅនៅកំពង់ចាមហើយបង្កើតសាលារៀន ដើម្បីអប់រំយុវនារីអំពីវិជ្ជាមេផ្ទះនិងអំពីគ្រីស្តសាសនា។ ដូនជីធ្លាប់ទទួលកូនសិស្ស ១២ នាក់ អស់ប្រាំមួយខែ។ នៅឆ្នាំ ១៩៩៥ លោកសេរាលដ៍ រ៉ូសាំងក៏ទៅនៅបម្រើគ្រីស្តបរិស័ទភូមិភាគកំពង់ចាម។ យូរៗទៅមានក្រុមតូចៗ

របស់ប្រជាជនដែលចង់ស្គាល់ ព្រះយេស៊ូកើតមានឡើងដូចជានៅក្ដីបឹង ភូមិថ្មី។ល។

នៅថ្ងៃ ១៦ ខែកក្កដា ១៩៩៧ លោកអន់តូនីសាមីស៊ូសៃរាជ ទទួលភារកិច្ចណែនាំភូមិភាគកំពង់ចាម ជំនួសលោកអន់ជ្រេឡឺស្វែហ្វ ដែលសូមលាលែងមុខតំណែងពីរដង ព្រោះលោកអាយុដល់ប៉ែតសិបឆ្នាំទៅហើយ!។

លោកអន់តូនីសាមី ជាជនជាតិឥណ្ឌា មកពីភូមិភាគសាឡឹមនៅខាងត្បូងប្រទេសឥណ្ឌា។ លោករៀនសូត្រនៅទេវវិទ្យាល័យបឹងកាឡូរ រួចទទួលអគ្គសញ្ញាជាបូជាចារ្យនៅឆ្នាំ១៩៧៨។ បន្ទាប់ពីបានបម្រើព្រះសហគមន៍អស់រយៈពេលពីរឆ្នាំ អភិបាលព្រះសហគមន៍នៅក្រុងសាឡឹម ឲ្យលោកទៅរៀននៅមហាវិទ្យាល័យទេវវិជ្ជាឡាត្រង់នាក្រុងរ៉ូម។ ពេលលោកត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ លោកក៏ទទួលភារកិច្ចណែនាំក្រុមគ្រីស្តបរិស័ទនៅសាឡឹម រួចលោកសូមទៅបម្រើព្រះសហគមន៍នៅក្រៅប្រទេស គឺលោកសូមចូលក្នុងក្រុមសាសនទូតក្រៅប្រទេសនៅប៉ារីស នៅឆ្នាំ ១៩៩៤។ សមាគមសាសនទូតនោះចាត់លោកឲ្យទៅប្រទេសកម្ពុជានៅខែឧសភា ឆ្នាំ ១៩៩៥។ លោករៀនភាសាខ្មែរនៅភ្នំពេញ និងនៅកំពង់ធំ។

***

តាំងពីឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាចាប់ផ្ដើមដំណាក់កាលថ្មីនៃប្រវត្តិរបស់ខ្លួន។ ព្រះសហគមន៍ក៏ចាប់ផ្ដើមដំណាក់កាលមួយថ្មីដែរ។ សព្វថ្ងៃ ព្រះសហគមន៍មានលក្ខណៈខ្មែរ គឺក្នុងគ្រប់ពិធីជាផ្លូវការ មានប្រើភាសាខ្មែរ និងរបៀបខ្មែរ ជាពិសេសក្នុងអភិបូជានិងអាពាហ៍ពិពាហ៍។ ទោះបីគ្រីស្តបរិស័ទវៀតណាមមានចំនួនច្រើនយ៉ាងណាក៏ដោយ(ប្រហែល ១០.០០០ នាក់) ក៏គ្រីស្តបរិស័ទទាំងនោះយល់ឃើញថាគេរស់នៅប្រទេសកម្ពុជាហើយត្រូវតែប្រើភាសាខ្មែរដែរ។ គេមិននៅក្នុងស្រុករបស់ខ្លួនទៀតទេ ហើយគេមានមុខងារបង្ហាញជំនឿរបស់ខ្លួនដល់ជនជាតិខ្មែរដែរ។

គ្រីស្តបរិស័ទគ្រប់និកាយចាប់ផ្ដើមធ្វើការជាមួយគ្នា មានការបកប្រែគម្ពីរជាដើម។ គម្ពីរសម្ពន្ធមេត្រីថ្មីបកប្រែចប់ នៅឆ្នាំ ១៩៩៣ បញ្ចប់គម្ពីរទាំងមូលនៅឆ្នាំ ១៩៩៧។ លេខាធិការនៃសមាគមគម្ពីរជាគ្រីស្តបរិស័ទកាតូលិក។

មានក្រុមគ្រួសារបព្វជិត និងសមាគមសាសនទូតផ្សេងៗ មកធ្វើការក្នុងប្រទេសកម្ពុជា។ កាលពីមុនមានតែបូជាចារ្យ នៃសមាគមសាសនទូតក្រុងប៉ារីសប៉ុណ្ណោះ។ តាំងពីឆ្នាំ ១៩៩០ មានសមាជិកសមាគម សាសនទូតម៉ារីណុលពីរនាក់ មកបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា។ លោកទាំងពីរទទួលមុខងារបម្រើគ្រីស្តបរិស័ទវៀតណាម រហូតដល់ឆ្នាំ ១៩៩៧។ នៅឆ្នាំ ១៩៩១ មានសមាជិកនៃគ្រឹះស្ថានសាសនទូតក្រៅប្រទេសនៃស្រុកអ៊ីតាលី មកតាំងទីលំនៅប្រទេសកម្ពុជា តែអស់លោកកាន់កាប់តែអង្គការមនុស្សធម៌របស់ខ្លួនប៉ុណ្ណោះ។ នៅឆ្នាំ ១៩៩៣ លោកវិរជ័យជាបូជាចារ្យថៃ ដូនជីថៃពីរនាក់និងគ្រីស្តបរិស័ទថៃម្នាក់ជាសមាជិកសមាគមសាសនទូតក្រៅប្រទេសនៃប្រទេសថៃ មកបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា។ នៅឆ្នាំ ១៩៩៦ មានសមាជិកនៃសមាគមសាសនាទូតក្រៅប្រទេសនៃប្រទេសកាណាដានិងយេរូម៉ាល (ពីប្រទេសកូឡុំប៊ី) មកបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជាដែរ។ នៅឆ្នាំ ១៩៩២ សមាជិកនៃសមាគមសហជីវិនព្រះយេស៊ូ មកប្រទេសកម្ពុជាដែរ។ មុនដំបូងគេនៅកាន់កាប់តែក្នុងអង្គការមនុស្សធម៌របស់គេប៉ុណ្ណោះ តែតាំងពីឆ្នាំ ១៩៩៥ មកគេសុខចិត្តជួយណែនាំគ្រីស្តបរិស័ទ ហើយបង្រៀននៅទេវវិទ្យាល័យទៀតផង។

មានក្រុមគ្រួសារបព្វជិតដូនបូស្កូទាំងបុរសទាំងស្ត្រីមកនៅប្រទេសកម្ពុជា ហើយចាប់ផ្តើមអប់រំយុវជនយុវនាគី នូវវិជ្ជាជីវៈតាមផ្នែក។ គេជួយកសាងអនាគតប្រទេសកម្ពុជាយ៉ាងសកម្ម។ មានដូនជីមេត្តាករុណាជាច្រើននាក់មកជួយជនក្រីក្រដែរ។ មុនដំបូងក្រុមទាំងនោះ មិនសូវមានទំនាក់ទំនងជាមួយព្រះសហគមន៍នៅប្រទេសកម្ពុជាទេ! ប៉ុន្តែ យូរៗទៅគេរួមសហប្រតិបត្តិការជាមួយគ្នាបម្រើប្រជាជន ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់!។